អក្សរសិល្ប៍ និងភាសាខ្មែរកណ្ដាល តាមរយៈសិលាចារឹកនគរវត្ត

ដោយ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

សហការជាមួយគ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា
Sipar
២០២១

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
អក្សរសិល្ប៍ និងភាសាខ្មែរកណ្ដាល
តាមរយៈសិលាចារឹកនគរវត្ត

ភាសា«ខ្មែរកណ្ដាល» គឺជាភាសាដែលមានលក្ខណៈអន្តរកាលពីភាសា «ខ្មែរ-បុរាណ» ទៅភាសា «ខ្មែរទំនើប» ដោយអ្នកនិពន្ធប្រើប្រាស់ពាក្យពេចន៍នៃ «ខ្មែរ-បុរាណ» លាយឡំជាមួយនឹងភាសាសំស្ក្រឹត ភាសាបាលី និងភាសា «ខ្មែរកណ្ដាល»។ នៅសម័យអង្គរខ្មែរបានខ្ចីពាក្យសំស្ក្រឹត ដើម្បីប្រើប្រាស់នៅក្នុងភាសាប្រចាំថ្ងៃ ដែលធ្វើឱ្យវប្បធម៌សំស្ក្រឹតចាក់ឫសចូលយ៉ាងជ្រៅនៅក្នុងវប្បធម៌និងភាសាខ្មែរបុរាណ។ នៅសម័យក្រោយអង្គរភាសាបាលីត្រូវបានគេយកមកប្រើទន្ទឹមគ្នានឹងភាសាសំស្ក្រឹត។

ភាសាខ្មែរកណ្ដាល គឺជាដំណាក់កាលមានការផ្លាស់ប្ដូរទាំងការប្រើពាក្យ វេយ្យាករណ៍ និងសូរសព្ទ និងការចាប់ផ្ដើមនៃដំណាក់កាលនៃភាសាខ្មែរទំនើបនៅពាក់កណ្ដាលទី២នៃសតវត្សទី១៨។

ISBN: 978-9924-34-107-9
9 789924 341079

អក្សរសិល្ប៍
និងភាសាខ្មែរកណ្ដាល
តាមរយៈសិលាចារឹកនគរវត្ត

រចនាទំព័រ និងសម្រួលអត្ថបទដោយអង្គការ Sipar

© ហង់ជួន ណារ៉ុន

រក្សាសិទ្ធិគ្រប់យ៉ាង

មាតិកា

អារម្ភកថា vii

ជំពូកទី១ ៖ ការវិវត្តភាសាខ្មែរក្នុងរយៈពេលបីសតវត្ស ពីភាសាខ្មែរចាស់សម័យអង្គរ មកខ្មែរកណ្ដាល

១.១.ការបញ្ច្រាបពាក្យសព្ទបាលីចូលក្នុងភាសាខ្មែរចាស់ ៩
១.២.អន្តរកាលពីភាសាខ្មែរចាស់ ទៅភាសាខ្មែរកណ្ដាល ១៧

ជំពូកទី២ ៖ មូលដ្ឋានគ្រឹះនៃភាសាខ្មែរកណ្ដាល

២.១.ដំណើរការវិវត្តពីភាសាខ្មែរចាស់ទៅខ្មែរកណ្ដាល ២៣
២.២.ឥទ្ធិពលពុទ្ធសាសនាថេរវាទទៅលើភាសាខ្មែរកណ្ដាល ... ២៨
២.៣.មូលហេតុនៃការធ្លាក់ចុះនៃអារ្យធម៌អង្គរ ៣១
២.៤.ប្រភពនៃការសិក្សាភាសាខ្មែរកណ្ដាល ៣៣

ជំពូកទី៣ ៖ សម័យលង្វែកនៅសតវត្សទី១៦ យុគពណ្ណរាយនៃភាសាខ្មែរកណ្ដាល

៣.១.ទិដ្ឋភាពប្រវត្តិសាស្ត្រនៅសតវត្សទី១៦ .... ៤៩
៣.២.លក្ខណៈទូទៅនៃភាសាខ្មែរកណ្ដាល ៦៧
៣.៣.អត្ថរូបនៃសិលាចារឹកនគរវត្ត ១០៤

ជំពូកទី៤ ៖ កំណែទម្រង់រដ្ឋក្នុងសម័យឧដុង្គ និងការវិវត្តភាសាខ្មែរកណ្ដាល នៅសតវត្សទី១៧ និងដើមសតវត្សទី១៨

៤.១.ទិដ្ឋភាពប្រវត្តិសាស្ត្រខ្មែរនៅសតវត្សទី១៧ .... ១២៤
៤.២.ភាសាខ្មែរកណ្ដាលនៅសតវត្សទី១៧ ក្នុងសម័យឧដុង្គ .. ១៤២
៤.៣.សិលាចារឹកជ័យនន្ទ៖ ការវិវត្តពីភាសាខ្មែរកណ្ដាល ទៅភាសាខ្មែរទំនើប ១៥០

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជំពូកទី៥ ៖ វេយ្យាករណ៍នៃភាសាខ្មែរកណ្ដាល

៥.១.ការវិវត្តអក្ខក្រម..១៥៩
៥.២.គោលការណ៍នៃការបង្កើតពាក្យដោយកម្ចាយ............១៧២
៥.៣.ការសរសេរបរិច្ឆេទ..១៧៥
៥.៤.សម្ព័ន្ធឃ្លា..១៧៧
៥.៥.នាម..១៧៧
៥.៦.គុណនាម..១៨៨
៥.៧.កិរិយាសព្ទ..១៩៣
៥.៨.សព្វនាម...១៩៣
៥.៩.ពាក្យសម្រាប់ជាស្នៀត...២០១
៥.១០.និបាតសព្ទ...២០២
៥.១១.ការប្រើប្រាស់សញ្ញា...២០២
៥.១២.ការវិវត្តសួរសព្ទ..២០៣
៥.១៣.ការវិវត្តនៃភាសាខ្មែរកណ្ដាលនៅសតវត្សទី១៦.........២១៥
៥.១៤.ព្យាង្គតម្រួត..២១៧

ជំពូកទី៦ ៖ ការវិវត្តិភាសាខ្មែរក្នុងរយៈពេលបីសតវត្សភាសាខ្មែរកណ្ដាលមកភាសាខ្មែរទំនើប

៦.១.អាណាចក្រខ្មែរក្នុងជង្ហៀបរវាងសៀម និងវៀតណាម....២១៩
៦.២.អក្សរសិល្ប៍ពុទ្ធនិយមនៅសតវត្សទី១៨ និងទី១៩........២៤៧
៦.៣.ការបណ្ដុះបណ្ដាលធនធានមនុស្ស
និងទំនើបកាវូបនីយកម្មភាសាខ្មែរ..............................២៦៤
៦.៤.គណកម្មការវប្បធម៌ និងកម្មវិវាក្យសព្ទបាលីក្នុង
ភាសាខ្មែរទំនើប...២៨១
៦.៥.ចលនាខេមរយានកម្ម និងទំនើបកាវូបនីយកម្មភាសាខ្មែរ...២៨៥
ឧបសម្ព័ន្ធ..២៩២
គន្ថនិទ្ទេស...៤២១

អារម្ភកថា

នៅសម័យក្រោយអង្គរ ក្រោមឥទ្ធិពលនៃព្រះពុទ្ធសាសនាថេរវាទ ចាប់ពីសតវត្សទី១៥ មកទល់សតវត្សទី១៨ ភាសាខ្មែរបានវិវត្តចូលក្នុងដំណាក់ថ្មីមួយ គឺភាសា «ខ្មែរកណ្ដាល»។ តឹកតាងនៃភាសាខ្មែរកណ្ដាល គឺ «សិលាចារឹកនគរវត្ត» ដែលជាអត្ថបទចារលើផ្ទាំងថ្មនៃប្រាសាទអង្គរវត្ត ដែលត្រូវបានរៀបចំតាមលំដាប់ឆ្នាំ ពីលេខ១ ដល់លេខ៣៩។

ភាសា «ខ្មែរកណ្ដាល» គឺជាភាសាដែលមានលក្ខណៈអន្តរកាល ពីភាសា «ខ្មែរបុរាណ» ទៅភាសា «ខ្មែរទំនើប» ដោយអ្នកនិពន្ធប្រើប្រាស់ពាក្យពេចន៍នៃ «ខ្មែរបុរាណ» លាយឡំជាមួយនឹងភាសាសំស្ក្រឹត ភាសាបាលី និងភាសា «ខ្មែរកណ្ដាល»។ នៅសម័យអង្គរខ្មែរបានខ្ចីពាក្យសំស្ក្រឹតដើម្បីប្រើប្រាស់នៅក្នុងភាសាប្រចាំថ្ងៃ ដែលធ្វើឱ្យវប្បធម៌សំស្ក្រឹតចាក់ឫសចូលយ៉ាងជ្រៅនៅក្នុងវប្បធម៌និងភាសាខ្មែរបុរាណ។ នៅសម័យក្រោយអង្គរ ភាសាបាលីត្រូវបានគេយកមកប្រើទន្ទឹមគ្នា នឹងភាសាសំស្ក្រឹត។ ការវិវត្តពីភាសាខ្មែរចាស់ ទៅភាសាខ្មែរកណ្ដាល គឺការឈប់បញ្ចេញសំឡេងព្យញ្ជនៈខាងចុងពាក្យ ហើយការបង្កើតស្រៈថ្មីមួយចំនួន។

នៅចុងសតវត្សទី១៧ និងដើមសតវត្សទី១៨ មានការផ្លាស់ប្ដូរខាងផ្នែកសូរសព្ទ ដែលឈានទៅដល់ការលេចឡើងនូវភាសាខ្មែរទំនើប។ ហើយការផ្លាស់ប្ដូរសំឡេងនេះកើតកាន់តែខ្លាំងឡើងនៅក្នុងភាសាខ្មែរកណ្ដាលនៃដំណាក់កាលទី២ ជាពិសេស គឺការបង្កើតស្រៈថ្មី ដូចជាស្រៈ «អួ» ជាដើម។ ភាសាខ្មែរកណ្ដាល គឺជាដំណាក់កាលអន្តរកាលមួយ នៅចន្លោះភាសាខ្មែរចាស់ និងខ្មែរទំនើប ដែលមានការផ្លាស់ប្ដូរទាំងការប្រើពាក្យ វេយ្យាករណ៍ និងសូរសព្ទ និងការចាប់ផ្ដើមនៃដំណាក់កាលនៃភាសាខ្មែរទំនើបនៅពាក់កណ្ដាលទី២នៃសតវត្សទី១៨។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជំពូកទី១

ការវិវត្តភាសាខ្មែរ ក្នុងរយៈពេលបីសតវត្ស ពីភាសាខ្មែរចាស់សម័យអង្គរ មកខ្មែរកណ្តាល

សម័យកណ្តាល គឺជាសម័យកាលនៃការផ្លាស់ប្តូរភូមិសាស្ត្រនយោបាយ និងសាសនា ដែលធ្វើឱ្យមានផលវិបាកយ៉ាងខ្លាំងមកលើអាណាចក្រខ្មែរ។ ភូមិសាស្ត្រនយោបាយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍បានប្រែប្រួល ដោយសារតួនាទីកម្ពុជានៅក្នុងតំបន់បានធ្លាក់ចុះបន្តិចម្តងៗ ហើយតួនាទីនៃអយុធ្យា និងក្រុងហ្វេបានកើនឡើងជាប្រចាំ រហូតដល់អាណាចក្រខ្មែរបានក្លាយទៅជាសាមន្តរដ្ឋនៃប្រទេសជិតខាងៗ ខាងផ្នែកសាសនាសម័យកណ្តាល គឺជាសម័យរុងរឿងនៃព្រះពុទ្ធសាសនាថេរវាទ និងការចាប់ផ្តើមប្រើប្រាស់កម្ចីពាក្យសព្ទបាលីនៅក្នុងភាសាខ្មែរ ទន្ទឹមនឹងការបន្តទទួលយកកម្ចីពាក្យសព្ទសំស្ក្រឹត ដែលជាដំណាក់កាលថ្មីមួយទៀតនៃភាសាខ្មែរ។ ដូចនេះហើយទើបភាសាវិទូបានបែងចែកការវិវត្តនៃភាសាខ្មែរជាបីដំណាក់កាល៖

(១) *ភាសាខ្មែរបុរាណចាប់ពីសតវត្សទី៦ ដល់សតវត្សទី១៤៖ តាមរយៈការសិក្សានៃការវិវត្តអក្ខរក្រម គេអាចបែងចែកភាសា «ខ្មែរចាស់» ជាពីរដំណាក់កាល គឺដំណាក់កាលទី១ សម័យមុនអង្គរ (សតវត្សទី៦-ទី៨) និងដំណាក់កាលទី២ សម័យអង្គរ (សតវត្សទី៩-ទី១៤) ដូចមានសិលាចារឹកជាច្រើនដែលជាបេតិកភណ្ឌជាតិខ្មែរ។*

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(២) ភាសាខ្មែរកណ្ដាលចាប់ពីសតវត្សទី១៥ មកទល់សតវត្សទី១៨ ដូចមានចារនៅក្នុង «សិលាចារឹកនគរវត្ត (Inscriptions modernes d'Angkor Vat)» និងអត្ថបទច្បាប់ផ្សេងៗ។

(៣) ភាសាខ្មែរទំនើបចាប់ពីពាក់កណ្ដាលសតវត្សទី១៨ មកទល់បច្ចុប្បន្ន។

១.១. ការបញ្ជ្រាបពាក្យសព្ទសំស្ក្រឹតចូលក្នុងភាសាខ្មែរចាស់

មុននឹងយើងសិក្សាភាសាខ្មែរកណ្ដាល យើងពិនិត្យមើលមូលដ្ឋានគ្រឹះនៃភាសាខ្មែរចាស់បន្តិចសិន។ ភាសា «ខ្មែរចាស់» វិវត្តយ៉ាងជិតស្និទ្ធក្រោមឥទ្ធិពលនៃភាសាសំស្ក្រឹត។ បុព្វបុរសខ្មែរបានទទួលយកភាសាសំស្ក្រឹតជាភាសាសរសេរមុនការបង្កើតភាសា«ខ្មែរចាស់»សម្រាប់សរសេរនៅសតវត្សទី៦ទៅទៀត។

ភាសាខ្មែរចាស់សម័យមុនអង្គរ ដែលបង្កើតឡើងចាប់ពីសតវត្សទី៦ មក មានពាក្យកម្ចីពីវាក្យសព្ទនៃភាសាសំស្ក្រឹតចំនួនប្រមាណជា ៣០%-៤០%។ កម្ចីពាក្យពីភាសាសំស្ក្រឹត គឺជាការចាំបាច់ដោយសារតែឥទ្ធិពលនៃសាសនា គំនិតនយោបាយ នីតិសាស្ត្រ និងប្រាសាទបុរាណ មកលើគ្រប់ទិដ្ឋភាពទាំងអស់នៃសង្គមខ្មែរ។ ភាសាសំស្ក្រឹតបានក្លាយជា«ភាសាពិសិដ្ឋ» និងជា «ភាសាអាទិទេព-ទេវសព្ទ» ដែលពួកព្រាហ្មណ៍ប្រើប្រាស់ក្នុងពិធីបួងសួងខាងផ្នែកព្រហ្មញ្ញសាសនា និងជាភាសាសម្រាប់គម្ពីរស័ក្តិសិទ្ធិខាងផ្នែកសាសនា។ ដូច្នេះហើយ ទើបពាក្យសំស្ក្រឹតត្រូវបានប្រើប្រាស់ក្នុងភាសាខ្មែរចាប់តាំងពីមានសិលាចារឹកទីមួយមកម៉្លេះ។ ភាសាសំស្ក្រឹតជា «ភាសាកម្រិតខ្ពស់» របស់ព្រះរាជា និងជា«ភាសាផ្លូវការ»ផងដែរ សម្រាប់ចារលើសិលាចារឹកក្នុងគោលដៅសរសើរដល់ព្រះរាជា ឬមន្ត្រីជាន់ខ្ពស់។ សិលាចារឹកភាសាសំស្ក្រឹតភាគច្រើនត្រូវបានតែងនិពន្ធជាកំណាព្យប្រភេទកាវ្យ (kāvya) របស់ឥណ្ឌាដែលជាភាសាអក្សរសាស្ត្រ និងអក្សរសិល្ប៍ ដើម្បីសរសើរវត្ថុស័ក្តិសិទ្ធិ និងក្រុមព្រះ (vraḥ) ដែលជា «អាទិទេពនៃលោក»ឬកម្រតេងជគត (kamrateṅ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

jagat) និងទេវតារក្សាទឹកដី ឬកម្រតេងផ្ទៃករោម (kamrateṅ phdai karom) ដូចកំណាព្យប្រសស្តិ (praśasti) របស់ឥណ្ឌាដែលសរសេរ ដើម្បីសរសើរដល់ព្រះរាជា ឬមន្ត្រីជាន់ខ្ពស់ (BHATTACHARYA, 1991, វង់ សុជាក៉, 2003, ពៅ សាវរស, 2013)។

តាមសទ្ទានុក្រមសំស្ក្រឹត-ខ្មែរ-បារាំង រៀបចំដោយលោកស្រីបណ្ឌិត ពៅ សាវរស (2013) ហើយដោយបំពេញបន្ថែមតាមប្រភេទនៃពាក្យ (JACOB, 1977) យើងអាចចែកកម្ចីពាក្យសព្ទសំស្ក្រឹត ជាប្រភេទពាក្យដូចតទៅ៖

(១) ពាក្យពាក់ព័ន្ធនឹងកាលបរិច្ឆេទ និងការដាក់បណ្តាសាដល់អ្នកដែលបំផ្លាញប្រាសាទ៖

សិលាចារឹក K. 600

ត្រៃត្រី(ម)សោត្តរបញ្ចសត សគ បរិគ្រ(ហ) ត្រយោទសី កេត មាឃ បុស្យ នក្សត្រ តុលលគ្ន០

«៣-៣០-(ឧត្តរ) បូក-៥០០ (៥៣៣ សគ ត្រូវជា៦១១នៃគ.ស) (បរិគ្រហ) ដែលកន្លងទៅទី១៣កើត ខែមាឃ ជាថ្ងៃនក្ខឫក្ស«បុស្យ» ចំពេលព្រះចន្ទ និងព្រះអាទិត្យមកជួបគ្នា (តុលលគ្ន)»។

សិលាចារឹកភ្នំបយ៉ំខ្លោ K. 852

១០២៩ គក ទគមី ពោច វៃគាខ អាទិត្យវារ រេវតិ នក្សត្រ

១០២៩ សក ពោច ខែពិសាខ ថ្ងៃអាទិត្យ ជាថ្ងៃនក្ខឫក្ស «រេវតិ»

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



នៅគេត សក្ក កល្បានានេះ គេស្វេយត្រៃត្រឹគ នរក យាវតចន្ទ្រាទិត្យ មានលេយះ នរណាគេ យកតង្វាយនេះ គេសោយនៅនរកទាំង៣៣ ដរាបណាព្រះចន្ទនិងព្រះអាទិត្យមាននៅឡើយ។

(២) នរនាម (ទេវនាម និងនាមមនុស្ស) ស្ថាននាម និងគោរមងារ

ទេវនាមត្រូវបានបង្កើតឡើង ដោយប្រើប្រាស់ភាសាសំស្ក្រឹត ដែលជាភាសាពិសិដ្ឋខាងផ្នែកព្រហ្មញ្ញសាសនា៖ (១) គីរ៖ ទង្វើល្អ ឬ បរមសុខ, (២)ភវ៖ វឌ្ឍនភាព ឬ សម្បូររុងរឿង, (៣) អមោឃ៖ ដុះដាល, (៤) ភទ្រ៖ សោភ័ណ, (៥) ហរ៖ បំផ្លាញ (អ្វីដែលអាក្រក់), (៦) រុទ្រ, (៧) ឦសាន, (៨) វិរេន្ទ្រ, (៩) គ្វីស្រម, (១០) ភទ្រេស្វរ,(១១) ស្វយម្ភុ (ឡុង សៀម, 1996)។

នាមព្រះមហាក្សត្រ	អត្ថន័យ	ប្រភព
ភវវម៌្ម	ជនដែលព្រះឥស្វរការពារ	K.149
ឦសានវម៌្ម	ជនដែលព្រះឥសានការពារ	K.22
ជ័យវម៌្ម	ប្រកបដោយជោគជ័យ	K.453
ឥន្ទ្រវម៌្ម	ជនដែលព្រះឥន្ទ្រការពារ	K.14
សូរ្យវម៌្ម	ជនដែលព្រះអាទិត្យការពារ	K.31

នៅក្នុងសិលាចារឹក គេឃើញមានឈ្មោះជាភាសាខ្មែរ តែខ្មែរបានខ្ចីពាក្យសំស្ក្រឹតសម្រាប់ដាក់ឈ្មោះអ្នកចម្រៀង និងអ្នករបាំ (ឡុង សៀម. 1996)។ ឈ្មោះជាភាសាសំស្ក្រឹតជាឈ្មោះដែលមានច្រើនព្យាង្គ ដូចជា៖ (១) វសន្តមាលិកា «ផ្កាម្លិះនាវសន្តរដូវ» (២) គន្ធារី «មានគុណសម្បត្តិល្អ» (៣)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចារុមតី «ម្ហូបចំណីសម្រាប់ពិចារណា» (៤) អរុណមតិ «ធម៌ពេលព្រឹក» (៥) គន្ធីទី «មានក្លិនឈ្ងុយឈ្ងប់»។ ប្រពៃណីយកពាក្យសំស្ក្រឹតមកប្រើជាឈ្មោះនៅបន្តរហូតមកដល់សព្វថ្ងៃ។

ឋាននាម ជាភាសាសំស្ក្រឹតមានជាអាទិ៍ ឈ្មោះរាជធានីនៃកម្ពុជាជាច្រើនជំនាន់៖ (១) វ្យាធបុរៈ (ទីក្រុងរាជាដែលជាព្រានប្រមាញ់ដំរី ឬបាភ្នំ) (២) ឦសានបុរៈ (ទីក្រុងព្រះឦសាន ឬសំបូរព្រៃគុក, K.314) (៣) ហរិហរាលយ័បុរៈ (ទីក្រុងព្រះវិស្ណុ និងព្រះឥសូរ ឬលលៃ, K.235) (៣) យសោធរបុរៈ (ទីក្រុងដ៏ស្រស់ប្រិមប្រិយ៍ ឬអង្គរធំ, K.70) វិសយៈ (ផ្នែក)។

ការផ្សំទីងនាមរបស់ព្រះសិវៈ៖ ស្រុករុទ្រ, ឦសានបុរ, ហរាគ្រាម, វិរេន្ទ្របុរ, គង្គស្រម, ភវបុរ,គ្រិកទ្រេគ្ធា គ្រម, អមោឃបុរ, ស្វយម្ភុបុរ (Bhattacharya, 1961)។

(៣)នាមរូបី សម្រាប់សម្គាល់មនុស្ស តួនាទី វត្ថុ និងខ្លឹមសារដូចជាពាក្យ៖ ទេវៈ(អាទិទេព) ទេវាលយ(ស្ថានអាទិទេព) ទេវី(ស្តេចស្រី) អាចារ្យៈ (អ្នកបង្រៀន) អាចារ្យប្រធាន (មេក្រុមអាចារ្យ) យជមានៈ (អ្នករៀបចំពិធី) កវិ(កវី) ការិ(អ្នករាំ) ស្ត្រី(ស្រី) នារី(ស្រី) បិតា (ឪពុក) ស្វាមិ(ប្តី) បុត្រ (កូនប្រុស) បុរស (ប្រុស) បុរោហិត (ព្រាហ្មណ៍ដឹកនាំ សាសនា) សេនាបតិ (មេបញ្ជាការកងទ័ព) សេនា (យោធា) ហោរៈ (ពេល/ហោរ) សង្ឃរាជ (ស្តេចសង្ឃ) សាមនេរ (អ្នកបួសដំបូង) ភិក្សុ (ភិក្ខុ) នាយៈ (មេ) សន្តាន (ដំណរ គ្រួសារ) សាក្សី (សាក្សី) មកុដ (មកុដ) គ្វាល (ទ្រមាក់ដំរី) ចារេ (អ្នកស៊ើបការណ៍) តុល (រង្វាស់ ទម្ងន់) ទាសៈ ទាសី (អ្នកបម្រើ) ទិនៈ (ថ្ងៃ) នក្សត្រៈ (សម្គាល់ឆ្នាំ ដែល បាលីថា នក្ខតឫក្ស) និករៈ (ក្រុម)ជាដើម។

(៤) នាមអរូបី ដូចជាពាក្យ៖ អាជ្ញា (ការបង្គាប់បញ្ជា) អាគមៈ (ទំនៀម) អាករ (ចំណូល) អស្ដមិ (ទី៨) អស្វរ្យៈ (ក្រៃលែង) បុណ្យ (អំពើល្អ) បូជា (បូជាដល់ទេវរូប) បូណ៌មី (ថ្ងៃ១៥កើត) បុស្ស (ខែទី២) សប្ត (៧) សិទ្ធិ (ជ័យជម្នះ) សិទ្ធិសក្តិ (អំណាចអច្ឆរិយ) ស្វស្តិ (ជុំជ្រើង/សួស្តី) មង្គល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(ពរប្រសើរ) សីមា (ព្រំដែន) សុខៈ (រីករាយ) សុធិ (ប្រាជ្ញា) សុកៈ (ល្អ) ស្ងត់ (ស្ងាត់ស្ងៀម) និព្វាណៈ (និព្វាន) សាន្តិ (សុខសាន្ត) សីលៈ (គុណធម៌នៃសីល) សុចិ (បរិសុទ្ធ) ហឫទ័យ (បេះដូង) វិបត្តិ (ខូចខាត) សមៈ (ស្មើ) សំញាន (សញ្ញា) សរវជ្ញៈ (ព្រះសរពេជ្ញសព្វញ្ញាណ) សំបូណ៌ (ស្កប់ស្កល់) សរ៉ៈ (សព្វ) សាធុ (ប្រពៃណាស់) សារៈ (សារៈសំខាន់) សិក្សា (រៀន) ភទ្រ (ប្រសើរ) ភិត (ភ័យ) ភ័យ (ខ្លាច) ភាគ (ចំណែក) ភោគ (ប្រយោជន៍) មហា (ធំ) កុលសន្តានៈ (ក្រុមគ្រួសារ) កិសរ (លំអងផ្កា) ក្រម (ច្បាប់) ក្រោធ (ខឹង) ក្រយា (តង្វាយអាហារ) ក្សយ (រលាយខ្លួន) ក្សេម (សុខសាន្ត) ក្សេត្រ (ចម្ការ) នគរៈ (រាជធានី) នរៈ (មនុស្ស) នរកៈ (នរក) នាមៈ (ឈ្មោះ) និត្យៈ (ខ្ជាប់ខ្ជួន) និទ្រា (ដំណេក) និមិត្តៈ (សញ្ញា) និយមៈ (បង្ខំ) បវិត្រៈ (បរិសុទ្ធ) បាបៈ (ទង្វើអាក្រក់) បារមី (គុណធម៌ឧត្តម) បាល (អ្នកការពារ) បិណ្ឌ (ពំនូត) បុណ្យានិសង្ស (បរិបូរដោយអំពើល្អ) ប្រចណ្ឌ (កាច) ប្រជា (មនុស្ស) ប្រជ្ញា (ចំណេះ) ប្រជ្ញាបារមិតា (ការសញ្ជឹងគិតនៃគតិបណ្ឌិត) ប្រណំ (ថ្វាយបង្គំ) ប្រណិធាន (សម្បថ) ប្រតិជ្ញា (សច្ចា) ប្រតិទិន (រាល់ថ្ងៃ) ប្រតិមា (រូប) ប្រសស្តិ (ការ សរសើរ) ជាដើម។

ពាក្យសំស្ក្រឹតបានក្លាយជាពាក្យវប្បធម៌របស់ខ្មែរសម័យបច្ចុប្បន្ន ដូចជាពាក្យ៖ ឧត្តម (ខ្ពង់ខ្ពស់) ឧត្តរ (ទិសជើង) ឧទយៈ (ថ្ងៃរះ) ឧទ្យាន (សួនច្បារ) ឧបភោគៈ (មធ្យោបាយរស់នៅ) ឧបាធ្យាយៈ (សាស្ត្រាចារ្យ) ឧបាយៈ (មធ្យោបាយ) វិមាន (វាំង) សរវាង្គ (ថ្វាយខ្លួន) សុគន្ធ (ក្លិនក្រអូប) សុចរិតៈ (សន្តានចិត្តល្អ) ករុណា (អាណិតអាសូរ) កល្យាណ (ល្អប្រសើរ) ភោជនៈ (ចំណី) មធ្យម (មធ្យម) មនុស្ស (មនុស្ស) មនោ (គំនិត) មន្ទីរ (សាលធំ) មាគ៌ (ផ្លូវ) មារ្យាទ (ចរិតល្អ) មិត្រ (សំឡាញ់) យាត្រា (ក្បួនហែ) យាន (ទាញ) យុទ្ធ (សង្គ្រាម) យោធា (ពល) កម៌ៈ (អំពើ) កាល (ពេល) កេរ្តិ៍ (ល្បីឈ្មោះ) កុដិ (កុដិ) កុមារ (កុមារ) គណៈ (ក្រុម) គតិ (ដំណើរ) គណនា (រាប់) គន្ធា (ក្លិនក្រអូប) គិរិ (ភ្នំ) គុណ (អំពើល្អ) គុរុ (គួរគោរព)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឃោសនា (ប្រកាស)ចរិត (ឥរិយាបថល្អ) ចលាចល (គ្មានលំនឹង) ចិត្ត (គិត) ចិន្តា (គំនិត) ទេសៈ (ប្រទេស) នវៈ (ថ្មី) បក្សៈ (ក្រុម) បុរៈ (ក្រុង)។ល។

ជនជាតិខ្មែរបានខ្ចីពាក្យសំស្ក្រឹតដើម្បីប្រើប្រាស់នៅក្នុងភាសាប្រចាំថ្ងៃ ដែលធ្វើឱ្យវប្បធម៌សំស្ក្រឹតចាក់ឫសចូលយ៉ាងជ្រៅនៅក្នុងវប្បធម៌ និងភាសាខ្មែរបុរាណ។ ពាក្យសំស្ក្រឹតត្រូវបានខ្មែរយកមកប្រើក្នុងភាសានិយាយនិងភាសាសាមញ្ញផងដែរដូចជា៖ អក្សរៈ (ស្ថិតស្ថេរជានិច្ច) អគារ (សំណង់) អាគ្នេយ (ទិសអាគ្នេយ៍) អង្គៈ (ខ្លួនមនុស្ស) អង្គរក្ស (អ្នកការពារអង្គ) អង្គារ (ថ្ងៃអង្គារ) អតិថិ (ដំណើរទៅបូជាព្រះ) អតីតៈ (ពេលកន្លងទៅ) អធិការ (បុព្វសិទ្ធិ) អធិបតិ (ចៅហ្វាយ) ឧបករណ (ប្រដាប់ប្រដារ) កបាល (ក្បាល) កថោរ (កន្តោរ) កថា (និយាយ) ទិសៈ (ទិស) ទុគ្គៈ (ឈើចាប់) ទុរ្ភិក្សៈ (អត់ឃ្លាន) ទេសនា (ទូន្មាន) ទោសៈ (កំហុស) ទ្វារៈ (ទ្វារ) ទ្វារបាល (ឆ្មាំទ្វារ) ធនៈ (ទ្រព្យ) ធរណី (ដី) ធម៌ (របៀបរបបនៃពិភពលោក) ធម៌កថា (សេចក្តីប្រកាសត្រឹមត្រូវ) ធូលិ (កំទេច)។

(៥) កិរិយាសព្ទ គុណនាម ដូចជា៖ សាមន្តៈ (នៅជិតខាង) សុប្រតិស្ឋ (ទេវស្ថានប្រណីត) កត្តិ (ស្មោះត្រង់) កល្បនា (រៀបចំពិធី) កបតៈ (ក្បត់) ទិវង្គត (ទៅកាន់ស្ថានសួគ៌) និរ្វាសៈ (បណ្តេញ និរទេស) ប្រតិសេធ (មិនព្រម) ប្រតិស្ឋា (សង់) ប្រទាន (ថ្វាយ)

(៦) ពាក្យផ្សេងៗទៀត ដូចជា ជាតិ (កំណើត) ជីវៈ (រស់នៅ) ដិកា (បរិយាយ) តដាក (បឹង) តន្ត្រី (ភ្លេង) តូរ្យៈ (វង់ភ្លេង) តេជះ (បារមី) ទ្វិ (ពីរ) ត្រៃ (បី) ត្រយោទសី (១៣) ត្រិណិ (ទី៣) ត្រិកុវនៈ (ពិភព៣) ត្រៃត្រិង្សៈ (ស្ថានសួគ៌មានទេវតា ៣៣ ជាបរិវារនៃព្រះឥន្ទ្រ) ត្រៃ លោក្យៈ (ពិភព៣) បញ្ចៈ (៥) នវមី (ទី៩) ទសមី (ទី១០) ទ្វាទសី (១២) ទានៈ (អំណោយ) ទក្សិណា (អំណោយ) នានាប្រការៈ (ច្រើនប្រភេទ) បញ្ជី បណ្ឌិតៈ (អ្នកប្រាជ្ញ) បតិ (គ្រូ ប្តី) បទ (ជំហាន) បរៈ (ផ្សេងទៀត) បរទេសៈ (បរទេស)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បរមៈ (ឧត្តមបំផុត) បរិច្ឆេទ (ទី បញ្ចប់) បរិបាល (ថែរក្សា) បរិបូណ៌ (គ្រប់ចំនួន) បរិភោគ (មធ្យោបាយរស់នៅ) បរិមណ្ឌល (បរិវេណ) បរិមាណ (វង្វាស់) បរិវារ (អ្នក ការពារ) បល្ល័ង្កៈ (អាសនៈ)។

គេយកពាក្យសំស្ក្រឹតជាគោល សម្រាប់បង្កើតពាក្យថ្មី ដូចជាការច្របាច់បញ្ចូលពាក្យបាលី និងសំស្ក្រឹតចូលគ្នា ដើម្បីបង្កើតពាក្យថ្មី ដូចជាពាក្យ៖ (១) អធិ+បតី= អធិបតី (២) ធម្ម+ក= ធម្មិក (៣) វីរ+បុរស=វីរបុរស ជាដើម។ អ្នកប្រាជ្ញខ្មែរបានធ្វើខ្មែរនីយកម្មនៃពាក្យសំស្ក្រឹត ដោយ៖ (១) កែប្រែសូររបស់ពាក្យសំស្ក្រឹត ដូចជាពាក្យ វណសិរ្ស និងមាតា (២) បង្រួញព្យាង្គដូចជាពាក្យ ពោធិ៍ ពាទី និងព្រហស្បតិ៍ ជាដើម។

ភាសាខ្មែរចាស់បានខ្ចីពាក្យជាច្រើនពីភាសាសំស្ក្រឹត។ ពាក្យសំស្ក្រឹតដែលមានពីរ ឬបីព្យាង្គ ត្រូវបានបំលែងឱ្យទៅជាពាក្យខ្មែរ ដែលមានមួយព្យាង្គ ដែលគេស្គាល់ថា និន្នាការឯកព្យាង្គក្នុងការវិវឌ្ឍសូរសព្ទភាសាខ្មែរ។ ជាទូទៅពាក្យខ្មែរសុទ្ធ ឬពាក្យកម្ចីដែលបំលែងមកជាពាក្យខ្មែរ មិនអាចលើសពីពីរព្យាង្គឡើយ។ នៅចុងពាក្យមិនអាចមានព្យញ្ជនៈលើសពីមួយទេ។ ព្យញ្ជនៈចុងពាក្យនេះអាចជាព្យញ្ជនៈច្រមុះ ប៉ុន្តែមិនអាចជាព្យញ្ជនៈបិទអាស្ពីរេ ឬបិទសូន័រឡើយ។ ដំណើរការបំលែងពាក្យពីសំស្ក្រឹតទៅជាពាក្យខ្មែរបុរាណប្រព្រឹត្តទៅអស់រយៈពេលជាច្រើនសតវត្ស (ឡុង សៀម.1996)។

ដោយសារកម្ចីនេះហើយ យើងឃើញថាទម្រង់សំណេរនៃភាសាខ្មែរចាស់មានលក្ខណៈស្មុគ្រស្មាញដូចភាសាសំស្ក្រឹតដែរ។ ទន្ទឹមនឹងការប្រើប្រាស់ពាក្យជាព្យាង្គរាយ នៅក្នុងអត្ថបទភាសាខ្មែរចាស់ គេឃើញមានពាក្យផ្ញើ-ជើង និងព្យាង្គតម្រួតដូចមាននៅក្នុងភាសាសំស្ក្រឹតដែរ។

ភាសាខ្មែរចាស់ក៏មានខ្ចីពាក្យពីភាសាបាលីផងដែរ។ សិលាចារឹកពីសតវត្សទី៣ ដល់សតវត្សទី៥ នៃគ.ស. ត្រូវបានសរសេរជាភាសាសំស្ក្រឹតសុទ្ធ សំស្ក្រឹតលាយខ្មែរ និងភាសាខ្មែរសុទ្ធ ហើយមានតិចតួចណាស់ដែលសរសេរជាភាសាបាលីសុទ្ធ និងជាភាសាបាលីលាយខ្មែរ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សរុបមក ភាសាសំស្ក្រឹតសម័យមុនអង្គរ និងសម័យអង្គរ គឺជាភាសាពិសិដ្ឋ ប្រកបដោយកិត្យានុភាព ភាសាប្រើប្រាស់ក្នុងរាជការ ភាសាយានប្រើប្រាស់សម្រាប់ការសិក្សា និងជាភាសាសាសនា។ តាមរយៈភាសាសំស្ក្រឹត អ្នកប្រាជ្ញបញ្ញវន្តខ្មែរសិក្សាអំពីច្បាប់ នយោបាយ ការដឹកនាំរដ្ឋ និងប្រវត្តិសាស្ត្រជាដើម។ ដូច្នេះហើយ ភាសាសំស្ក្រឹតមានឥទ្ធិពលដ៏លើសលប់ទៅលើវចនាសម្ព័ន្ធវចនសព្ទខ្មែរ ហើយឈានដល់កម្រិតកំពូលនៅសតវត្សទី១២ ហើយរហូតដល់សតវត្សទី១៣ និងទី១៤ ដូចជាសិលាចារឹកប្រាសាទបាយ័ន K.470 ឆ្នាំ១៣២៧ ដែលមានពាក្យចំនួន២៤០ ក្នុងនោះកម្ចីពាក្យសំស្ក្រឹតមានចំនួនរហូតដល់១១០ពាក្យ។

១.២.អន្តរកាលពីភាសាខ្មែរចាស់ ទៅភាសាខ្មែរកណ្ដាល

មកទល់សតវត្សទី១៣ ភាសាខ្មែរចាស់ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ នៅក្នុងសិលាចារឹកសម័យអង្គរ។ សិលាចារឹកបន្ទាយឆ្មារ K.227 ចារនៅគោបុរៈទី២ លើទ្វារចូលខាងកើតនៃប៉មកណ្ដាលនៃក្រុមប្រាសាទខាងកើត មេទ្វារត្បូង ជាភាសាខ្មែរ មាន២៣+៦បន្ទាត់ ចារនៅចុងសតវត្សទី១២-ដើមសតវត្សទី១៣ រៀបរាប់ពីព្រឹត្តិការណ៍ចម្បាំងនឹង ករត ករហូ ត្រូវបានធ្លាក់លើចម្វាក់លើជញ្ជាំងនៅរបងខ្សែក្រវ៉ាត់ទី៣។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការប្រៀបធៀបអក្សរខ្មែរចាស់ និងខ្មែរកណ្ដាល

សិលាចារឹកបន្ទាយឆ្មារ K.227 សតវត្សទី១៣

សិលាចារឹកនគរវត្តលេខ៣



នៅសតវត្សទី១៣ ខាងផ្នែកវាក្យសព្ទ ភាសាខ្មែរចាស់នៅមានប្រើ វាក្យសព្ទសំស្ក្រឹតលាយឡំនឹងពាក្យខ្មែរចាស់ នៅក្នុងសិលាចារឹកៗ ខាងផ្នែក

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វេយ្យាករណ៍វិញ ភាសាខ្មែរចាស់នៅមិនទាន់មានប្រើសមាសធាតុទាំងអស់នៃភាសានៅឡើយ។

ចារឹកបន្ទាយឆ្មារ K. 227	ជាភាសាខ្មែរទំនើប
(១)ㆍ នាករតេវាហុសំរ្ទិទ្រោហតវ្រះ បាទត្រីយគោវម៌្មទេ	(១) នាពេលដែលករតេវាហុផ្សំគំនិតក្បត់នឹងព្រះបាទស្រីយសោវម៌្មទេ-
(២)វបិថ្ងៃចបវ្រះមន្ទិរតែសវលេនគរផោងបង្សិតយក	(២) ហើយបានទៅដល់ព្រះមន្ទីរអស់ពលនគរផងបោះបង់ហើយថយ
(៣) ន្តាលមត្តវាររតតស្សស្តចថ្ងៃឡងអញនក្សញ្ចកអជុំនអ្ន	(៣) (ដល់) កណ្តាលមត្តវាររត់អស់ស្តេចឡើងច្បាំងមេទ័ពអជុំន
(៤)ក្សញ្ចកគ្រីធរទេវបុរឡងករសំតចស្បង្គត្វលតោយវ្ន	(៤) អ្នកសញ្ចកគ្រីធរទេវបុរច្បាំងការ(ពារ)សម្តេចសឹងដួលដោយក្អែក
(៥)កស្តចផ្តលមុះផ្ទលករតេវាហុចំន្យររផ្សង្ហិប្រែឱយនាមវ្រះកំ	(៥) ស្តេចដល់ប្រមុះផ្ទួល(ផ្ទួល)ករតេវាហុចំណោរមកឱយនាមថា«វ្រះកំ
(៦)ម្រតេងអញគ្រីទ្ធបសិង្ហវម៌្មអញនក្សញ្ចកទេវបុរតជាបុ	(៦) ម្រតេងអញ គ្រីទ្ធបសិង្ហវម៌្ម»ដល់មេទ័ពទេវបុរតជាបុត្រ
(៧) ត្រអ្នក្សញ្ចកគ្រីធរទេវបុរឱយនាមអំតេងតអ្នក្សញ្ចក្តប្បរ	(៧) អ្នក្សញ្ចកគ្រីធរទេវបុរឱយនាម«អំតេង»ដល់អ្នក្សញ្ចកទាំងពីរ
(៨) ស្ថាបនារូបតសកុសលបក្សផោងស្តចប្រកោប្យំបតនុក្រមㆍ	(៨) ស្ថាបនារូបចំពោះក្រុមញាតិផងស្តេចប្រទានទ្រព្យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមរយៈការសិក្សាប្រើធៀបអត្ថបទខាងលើ យើងអាចបង្ហាញពីការវិវត្តនៃភាសាខ្មែរ ពីខ្មែរចាស់ទៅខ្មែរទំនើបដូចខាងក្រោម៖

ខ្មែរចាស់	ខ្មែរទំនើប	ខ្មែរចាស់	ខ្មែរទំនើប
សំ	ផ្សំ	ប្រះបាទ	ព្រះបាទ
ថ្វេង	ឡើង	ប្រះមន្ទិរ	ព្រះមន្ទីរ
វល	ពល	នគរ	នគរ
ផោង	ផង	តយ	ថយ
កន្ទាល	កណ្ដាល	សញ្ចក	មេទ័ព
ឥស្ស	អស់	វត	វត់
ឡ្បង	ប្លាំង	ស្បន្ត	សឹង
អ្នក	អ្នក	ករ	ការ (មាន់ការកូន)
ត្វល	ដួល	តោយ	ដោយ
វ្នក	ភ្នែក	ស្តច	ស្តេច
ផ្ទល់	ជល់	មុះ	ច្រមុះ
ផ្ទួល	ផ្តួល	ចំន្យរ	ចំណោរ
ប្រេ	ប្រើ	ឱយ	ឱយ
នាម	នាម	ទេវបុរត	ទេវបុត្រ
បុត្រ	បុត្រ	វ្យរ	ពីរ
ស្ថាបនា	ស្ថាបនា	រូប	រូប
កុសល	កុសល	បក្ស	បក្ស ក្រុមញាតិ
ប្រកោប	ប្រកប	នុក្រម	ទ្រព្យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូចនេះ ភាសាខ្មែរចាស់សម័យអង្គរ គឺជាមូលដ្ឋានគ្រឹះនៃភាសាខ្មែរទំនើប ហើយភាសាខ្មែរសម័យកណ្ដាល គឺជាដំណាក់កាលអន្តរកាលមួយដែលភាសាខ្មែរវិវត្តក្នុងរយៈពេលជិត៤០០ឆ្នាំ។

ក្នុងរយៈពេលប្រមាណជា៤០០ឆ្នាំនៃភាសាខ្មែរយើងឃើញសិលាចារឹកភាសាបាលីមានតិចតួចប៉ុណ្ណោះ បើយើងប្រៀបធៀបជាមួយនឹងសិលាចារឹកភាសាសំស្ក្រឹតសម័យមុនអង្គរ និងសម័យអង្គរ ដែលសម្បូណ៌យ៉ាងខ្លាំង។ រឿងនេះអាចមានបញ្ហាពីរគឺ៖ (១) ភាសាបាលីពិបាកនឹងជ្រាបចូលក្នុងសង្គមខ្មែរសម័យអង្គរ និង (២) កលិយុគក្នុងសម័យក្រោយអង្គរធ្វើឱ្យការសិក្សានៅក្នុងអាណាចក្រខ្មែរធ្លាក់ចុះ ហើយវប្បធម៌ចារសិលាចារឹកកាន់តែតិចទៅៗ។

បណ្ឌិត ពៅ សារស បានបោះពុម្ពផ្សាយសិលាចារឹកភាសាបាលីនៅក្នុងវណ្ណកម្មរបស់លោកស្រី ក្នុងសៀវភៅនៃវិទ្យាស្ថានបូព៌ាបារាំង «Nouvelles inscriptions du Cambodge» (សិលាចារឹកថ្មីនៃកម្ពុជា) ភាគទី១ ដែលមានចំនួនតែ២៩ប៉ុណ្ណោះ។ សិលាចារឹកភាសាបាលីចំនួនពីរចារនៅចុងសតវត្សទី១៤ គឺ K.888 និង K.768។

សិលាចារឹកព្រះខ័ន K.888 មានតែ៤បន្ទាត់ប៉ុណ្ណោះ ដែលខ្លឹមសារគឺការវន្ទនាដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ៖

(១) នមោ វុទ្ធាយ គុរវេ

(២) នមោ ធម្មាយ តាយនេ

(៣) នមោ សង្ឃាយ បមាតេ

(៤) ត្រៃ...នម...នមស្ស...មាន្តប្រះកម្រតេងអញ

ចំណែកឯសិលាចារឹក K.768 ក៏មានតែបួនបន្ទាត់យ៉ាងខ្លីស្ដីពីការសាងព្រះពុទ្ធរូបដោយពុទ្ធសាសនិក ដែលចង់ទៅកាន់និព្វាន។

ការចារសិលាចារឹកចាប់ផ្ដើមឡើងវិញនៅក្នុងសម័យលង្វែក ចាប់ពីពាក់កណ្ដាលសតវត្សទី១៦ ដូចជាសិលាចារឹកនគរវត្តលេខ៤ (គ.ស.១៥៦៦)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងសិលាចារឹកទួលចារឹក K.106។ នៅចុងសតវត្សទី១៦ មានសិលាចារឹកសំខាន់ពីរគឺសិលាចារឹកនគរវត្តលេខ៣(គ.ស.១៥៧៩) ស្ដីពីសច្ចាប្រណិធាននៃសម្ដេចព្រះជ័យជេដ្ឋាធិរាជ (សត្ថាទី១) និងសិលាចារឹកភ្នំបាខែង K.465 (គ.ស.១៥៨៣) ស្ដីពីសម្ដេចព្រះរាជមុនិបពិត្រ ដែលបានទៅភ្នំបាខែង ដើម្បីជួសជុលព្រះពុទ្ធរូបនៅលើកំពូលភ្នំបាខែង និងបានសាងព្រះពុទ្ធរូបចំនួន ២៦បន្ថែមទៀត ដើម្បីឱ្យអានិសង្សនេះសម្រេចជាមហានិព្វាន និងបានបួងសួងថ្វាយសម្ដេចមហាឧបាសក មហារាជបពិត្រ ព្រះនាមព្រះបាទជ័យជេដ្ឋាធិរាជ ឱង្ការបពិត្រ សូមបានសោយរាជ្យត្រង់ផ្ទៃក្រោមកម្ពុជទេសឱ្យស្ថិតស្ថិរ ស្ថាពរ និងសូមឱ្យព្រះរាជបុត្រព្រះអង្គទ្រង់បានស្នងរាជ្យផ្ទៃក្រោមផង។

នៅសម័យលង្វែក ព្រះពុទ្ធសាសនាថេរវាទបានចាក់ចូលជ្រៅចូលទៅក្នុងសង្គមខ្មែរ។ នៅសតវត្សទី១៦ ភាសាខ្មែរបានវិវត្តចូលក្នុងដំណាក់ថ្មីមួយដែលគេប្រសិទ្ធនាមថាភាសា «ខ្មែរកណ្ដាល»។ តឹកតាងនៃភាសាខ្មែរកណ្ដាលគឺ «សិលាចារឹកនគរវត្ត» ដែលជាអត្ថបទចារលើផ្ទាំងថ្មនៃប្រាសាទអង្គរវត្តដែលត្រូវបានរៀបចំតាមលំដាប់ឆ្នាំ ពីលេខ១ ដល់លេខ៣៩។ នៅក្នុងរាជ្យព្រះបាទអង្គច័ន្ទ ដែលជាព្រះមហាក្សត្រដ៏មានមហិទ្ធិឫទ្ធិខ្លាំងពូកែ និងប្រកបដោយទសពិធរាជធម៌ ព្រះអង្គទ្រង់បានប្រមូលអ្នកប្រាជ្ញរាជបណ្ឌិត ព្រះសង្ឃព្រមទាំងគម្ពីរដីកា ក្រាំង សាស្ត្រា ឯកសារទាំងអស់ទុកជាគ្រឹះរបស់ព្រះនគរ។ ទ្រង់បានទំនុកបម្រុងអ្នកមានចំណេះវិជ្ជា មេទ័ពមានថ្វីអាវុធយុទ្ធសាស្ត្រ រក្សាទុកជាកម្លាំងការពារជាតិមាតុភូមិ ទំនុកបម្រុងព្រះពុទ្ធសាសនា សាងសង់វត្តអារាម លើកតម្កើងវប្បធម៌ជាតិ មានល្ខោន និងតន្ត្រីសព្វបែបយ៉ាង។ ព្រះអង្គចាត់ចែងកសាងវត្តអារាម និងបានឱ្យមន្ត្រីធ្វើការជួសជុលអង្គរ និងបានចារសិលាចារឹកមួយចំនួននៅកន្លែងព្រះពាន់។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជំពូកទី២

មូលដ្ឋានគ្រឹះ
នៃភាសាខ្មែរកណ្ដាល

២.១.ដំណើរការវិវត្តពីភាសាខ្មែរចាស់ទៅខ្មែរកណ្ដាល

ព្រះពុទ្ធរូបកាច់ចង្កេះសតវត្សទី៧ដែលរកឃើញនៅអង្គរបុរីបញ្ជាក់ជាប្រជាជនខ្មែរជឿលើសាសនាព្រះពុទ្ធតាំងតែពីជំនាន់សម័យនគរភ្នំមកម្ល៉េះ។ ប្រាសាទភីម៉ៃ និងព្រះពិធូរ គឺជាតឹកតាងយ៉ាងសំខាន់នៃជំនឿព្រះពុទ្ធសាសនានៅក្នុងសតវត្សទី១២។ ម្យ៉ាងវិញទៀត ប្រាសាទព្រះបាលិលៃសង់ដោយព្រះបាទធរណីន្ទ្រវម៌្មទី២ ដែលជាព្រះបិតានៃព្រះបាទជ័យវម៌្មទី៧ គឺជាសំណាង់ព្រះពុទ្ធសាសនាដ៏ស្រស់ស្អាត។ នៅក្នុងរាជ្យព្រះបាទជ័យវរម្ម័ទី៧ ព្រះពុទ្ធសាសនាបានក្លាយទៅជាសាសនារដ្ឋ។ នៅដើមសតវត្សទី១៤ នៅពេលដែលអាណាចក្រខ្មែរងាកមកប្រកាន់យកព្រហ្មញ្ញសាសនាវិញ សង្គ្រាមរវាងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាបានកើតឡើង ហើយគេបានធ្លាក់ឡើងវិញរូបបដិមាព្រះពុទ្ធនៅតាមប្រាសាទដែលព្រះអង្គបានសាងសង់ និងបានរកឃើញព្រះកេសព្រះពុទ្ធកប់ក្នុងដីចំនួន២៧២ នៅប្រាសាទបន្ទាយក្ដី។

សតវត្សទី១៤ គឺជាសតវត្សនៃព្រះពុទ្ធសាសនានៅក្នុងអាណាចក្រខ្មែរ។ បន្ទាប់ពីព្រះបាទឥន្ទ្រវម៌្មទី៣ បានដាក់រាជ្យនៅឆ្នាំ ១៣០៨ ព្រះបាទស្រិន្ទ្រជ័យវម៌្ម(១៣០៨-២៧) បានឡើងសោយរាជ្យ គេចាប់ឃើញមានការសរសេរ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិលាចារឹកជាភាសាបាលី ដែលបញ្ជាក់យ៉ាងច្បាស់ថាព្រះពុទ្ធសាសនាថេរវាទ គឺជាសាសនារដ្ឋ (K.754 វត្តគោកផុស សៀមរាប)។ ក្នុងរយៈពេលជាង១៥០ ឆ្នាំ ពីចុងរជ្ជកាលព្រះបាទជ័យវម៌្មទី៧ មកដល់ចុងសតវត្សទី១៤ គេឃើញមានសិលាចារឹកចំនួនតែ២៣ប៉ុណ្ណោះ៖ ៦ ជាភាសាសំស្ក្រឹត, ១៣ជាភាសាខ្មែរ, ២ ជាភាសាបាលី និង២ ជាភាសាសំស្ក្រឹត និងខ្មែរ។ ដូចនេះ ការផ្លាស់ប្តូរសាសនានៅក្នុងអាណាចក្រខ្មែរបានធ្វើឱ្យមានសង្គ្រាមសាសនា និងការបាត់បង់បញ្ញវន្ត និងធនធានមនុស្ស ជាពិសេសពួកព្រាហ្មណ៍ដែលត្រូវបានបណ្តេញចេញទៅរស់នៅអយុធ្យាវិញ។ ប្រការនេះបានធ្វើឱ្យអារ្យធម៌ខ្មែរចាប់ផ្តើមធ្លាក់ចុះ។ ចាប់ពីពេលដែលព្រះពុទ្ធសាសនាថេរវាទ ត្រូវបានលើកតម្កើងជាសាសនារដ្ឋនៃអាណាចក្រខ្មែរនៅឆ្នាំ១៣៣៦ រហូតដល់ពេលចាកចោលអង្គរនៅឆ្នាំ១៤៣២ មានរយៈពេលជិត១០០ឆ្នាំ។

នៅអាស៊ីអាគ្នេយ៍គូប្រណាំងប្រជែងដ៏មានឥទ្ធិពលបានលេចឡើង ដូចជាក្រុងអយុធ្យា និងវៀតណាម។ ដូចនេះ ការចុះខ្សោយនៃអាណាចក្រខ្មែរបាននាំមកនូវការប្រែប្រួលខាងផ្នែកភូមិសាស្ត្រនយោបាយក្នុងតំបន់។ ការផ្លាស់ប្តូរសាសនាក៏មានឥទ្ធិពលយ៉ាងខ្លាំងក្លាមកលើការវិវត្តនៃភាសាខ្មែរផងដែរ។ បន្ទាប់ពីការបែកបាក់នៃអាណាចក្រខ្មែរ ភាសាខ្មែរចាស់បានវិវត្តយ៉ាងលឿន ទៅជាភាសាខ្មែរកណ្តាល ហើយជនជាតិខ្មែរដែលរស់នៅតាមតំបន់ផ្សេងៗនៃអតីតអាណាចក្រខ្មែរ ដូចជានៅប្រទេសថៃ ឡាវ និងវៀតណាមខាងត្បូង វិវត្តភាសាខ្មែររបស់ខ្លួនពីភាសាខ្មែរចាស់។

ពីពេលដំបូង មានការប្រឆាំងនឹងការប្រើប្រាស់ភាសាបាលី ដោយសារតែភាសាសំស្ក្រឹតបានចាក់ឫសចូលជ្រៅនៅក្នុងភាសា និងសង្គមខ្មែរ។ ក៏ប៉ុន្តែនៅសតវត្សទី១៤ អ្នកនិពន្ធខ្មែរចាប់ផ្តើមទទួលយកជាបណ្តើរៗនូវភាសាបាលី ហើយគេលែងឃើញមានបាតុភូតប្រឆាំងការប្រើប្រាស់ភាសាបាលីនេះទៀត ហើយដែលជាដំណាក់កាលថ្មីមួយទៀតសម្រាប់ភាសាខ្មែរ ដូចមានសិលាចារឹក K-177, និង K-549 ជាសក្ខីភាពស្រាប់ ដោយសារសិលាចារឹក

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទាំងនេះ គឺជាសិលាចារឹកនៅសេសសល់ពីសតវត្សទី១៥ (Pou, 1992)។

នៅដើមសតវត្សទី១៤ គេចាប់ផ្ដើមឃើញមានសរសេរក្នុងសិលាចារឹកនូវលទ្ធិនៃព្រះពុទ្ធសាសនាថេរវាទ ទាំងខាងផ្នែកខ្លឹមសារ ទាំងខាងផ្នែកទម្រង់ (Pou, 1992)។ ម្យ៉ាងវិញទៀត គេសង្កេតឃើញមានការប្រើពាក្យបាលីលាយឡំ ជាមួយពាក្យភាសានិយាយខ្មែរ ដែលចេញមកពីភាសា «ខ្មែរបុរាណ» និងភាសាសំស្ក្រឹត។ ចាប់ពីពេលនោះមក ភាសាបាលីត្រូវបានគេយកមកប្រើទន្ទឹមគ្នា នឹងភាសាសំស្ក្រឹត ដែលចាក់ឫសចូលជ្រៅក្នុងសង្គមបញ្ញវន្តខ្មែរទៅហើយ។ ការប្រើប្រាស់ភាសាបាលី ដើម្បីជំនួសភាសាសំស្ក្រឹតដំណើរការទៅជាច្រើនសតវត្ស។ យើងសង្កេតឃើញថា ភាសាបាលីពិបាកនឹងជ្រៀបចូលចាក់ឫសចូលក្នុងសង្គមកម្ពុជា ទាំងនៅក្នុងទិដ្ឋភាពទូទៅទាំងនៅក្នុងអត្ថបទពុទ្ធសាសនាថេរវាទ។ លោកស្រីបណ្ឌិត ពៅ សាវរស បានសិក្សាស្រាវជ្រាវនិងសរសេរអត្ថបទជាច្រើន ដែលបង្ហាញពីការលំបាក ក្នុងការបញ្ជ្រាបភាសាបាលីចូលភាសាខ្មែរ ហើយគេអាចត្រឹមតែយកភាសាបាលី មកជំនួសភាសាសំស្ក្រឹតដែលមានស្រាប់ប៉ុណ្ណោះ រហូតមកទល់បច្ចុប្បន្ននេះ នៅក្នុងភាសាទូទៅ និងនៅក្នុងអត្ថបទព្រះពុទ្ធសាសនា ដោយសារតែភាសាសំស្ក្រឹតបានចាក់ឫសចូលទៅក្នុងភាសាខ្មែររាប់សតវត្សមកហើយ។ ដូច្នេះហើយទើបក្នុងដំណាក់កាលដំបូងនៃការបញ្ជ្រាបចូលនៃភាសាបាលី ក្នុងភាសាខ្មែរ គេសង្កេតឃើញថាអ្នកប្រើប្រាស់ភាសាសំស្ក្រឹតនៅបន្តប្រឆាំងនឹងភាសាថ្មីនេះ។ ផ្ទុយពីសិលាចារឹកភាសាសំស្ក្រឹតដែលឈានដល់ដំណាក់កាលកំពូលនៃការអភិវឌ្ឍអារ្យធម៌អង្គរ សិលាចារឹកភាសាបាលីសរសេរមានកំហុសវេយ្យាករណ៍ច្រើន។ នេះបង្ហាញឱ្យឃើញថា នៅក្នុងសម័យអង្គរ អ្នកប្រាជ្ញខ្មែរមិនសូវចេះភាសាបាលីស្ទាត់ជំនាញ ដូចភាសាសំស្ក្រឹតឡើយ។

នៅសម័យក្រោយកណ្ដាលប្រាសាទអង្គរវត្តបានក្លាយទៅជាទីសក្ការៈបូជាដ៏សំខាន់បំផុតនៃព្រះពុទ្ធសាសនា នៅកម្ពុជា។ មន្ត្រីជាន់ខ្ពស់ និងព្រះសង្ឃរាជខ្មែរបានមកស្ទានទេពនេះ ដើម្បីធ្វើបុណ្យជូនកុសលដល់អ្នកមាន

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គុណ និងឧទ្ទិសគេជះផលានិសង្សនេះ ដើម្បីបានទៅដល់និព្វានៗ ដើម្បីជាសាក្សីពេជញាណនៃសទ្ធានេះ គេបានចារនូវសិលាចារឹកដែលជាតឹកតាងនៃភាសា «ខ្មែរកណ្ដាល»ៗ

ភាសា «ខ្មែរកណ្ដាល» គឺជាភាសាដែលមានលក្ខណៈអន្តរកាលពីភាសា«ខ្មែរបុរាណ»ទៅភាសា«ខ្មែរទំនើប»ដោយអ្នកនិពន្ធប្រើប្រាស់ពាក្យពេចន៍នៃ «ខ្មែរបុរាណ» លាយឡំជាមួយនឹងភាសាសំស្ក្រឹតភាសាបាលី និងភាសា«ខ្មែរកណ្ដាល»ៗ ប្រការនេះ ជាលក្ខណៈសំខាន់នៃការខុសគ្នារវាងភាសា«ខ្មែរកណ្ដាល» ពីភាសា «ខ្មែរបុរាណ» ដែលខុសពីភាសា «ខ្មែរទំនើប» ខ្លាំងៗ

បណ្ឌិត ពៅ សាវរស បានអះអាងថា ភាសា «ខ្មែរកណ្ដាល» មានលក្ខណៈដូចតទៅ៖ (១) ជាប្រភពមិនចេះរីងស្ងួតដែលមានសមាសធាតុនៃភាសា «ខ្មែរទំនើប» ពោលគឺជាប្រភពនៃ «ពាក្យគោល» ដែលគេអាចទាញយកនូវ«ពាក្យក្លាយ» (dérivation) ជាច្រើនទៀត និង (២) ភ្ជាប់ដំណាក់កាលទាំងពីរនៃការវិវត្តភាសាខ្មែរ ដោយមានបង្កើតនូវវេយ្យាករណ៍សម្រាប់ភាសាខ្មែរផងដែរៗ យើងនឹងសិក្សាវេយ្យាករណ៍នៃភាសាខ្មែរកណ្ដាលនៅក្នុងជំពូកទី៥ៗ

បន្ទាប់ពីបានសិក្សាឯកសារនៃគន្ថនិទ្ទេសមូលនិធិខ្មែរ ដែលតម្កល់ទុកនៅបណ្ណាល័យជាតិនៃទីក្រុងប៉ារីស និងដែលរៀបចំដោយលោក ឱ ឈាង (AU Chhieng, Catalogue du fonds khmer, 1953) លោកស្រីបណ្ឌិត ពៅ សាវរស បានអះអាងថា ចំណាត់ថ្នាក់ភាសា «ខ្មែរទំនើប» ដែលគ្របដណ្ដប់រយៈពេលដ៏វែងពីសតវត្សទី១៤ ដល់សតវត្សទី១៩ មិនមានលក្ខណៈប្រាកដនិយមឡើយៗ ជាការពិតភាសាខ្មែរមានការវិវត្តជាប្រចាំ តែយឺតៗ ដោយចាប់ផ្ដើមពីភាសា «ខ្មែរបុរាណ» ក្រោមឥទ្ធិភាពនៃការផ្លាស់ប្ដូរពហុវិស័យ ដូចជាផ្នែកសាសនា សង្គម និងភាសា (POU, 2017)ៗ លោកស្រីបានចាត់ទុកថា ភាសា«ខ្មែរកណ្ដាល» វិវត្តជាដំណាក់កាលចាប់ពីសតវត្សទី១៥ មកទល់សតវត្សទី១៨ៗ ភាសាវិទូដែលសិក្សាភាសាខ្មែរលើកឡើងពីភាសាខ្មែរកណ្ដាល អាច

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចែកចេញជំណាក់កាលចំនួនពីរ។ ភាសា «ខ្មែរកណ្ដាល» មានប្រភពយ៉ាងសម្បូណ៌បែប ដូចរៀបរាប់ខាងក្រោម៖

ទី១-«សិលាចារឹកនគរវត្ត»៖ គឺជាអត្ថបទចារលើផ្ទាំងថ្មនៃប្រាសាទអង្គរវត្ត ដែលត្រូវបានរៀបចំតាមលំដាប់ឆ្នាំពីលេខ១ ដល់លេខ៤១។ យើងអាចសិក្សាការវិវត្តភាសាខ្មែរកណ្ដាលបានតាមរយៈការសិក្សា «សិលាចារឹកនគរវត្ត» ដែលមានចារកាលបរិច្ឆេទត្រឹមត្រូវ។ តាមរយៈសិលាចារឹកទាំងនេះ គេឃើញមានការចាប់ផ្ដើមជំណាក់កាលថ្មីមួយទៀតនៃការវិវត្តនៃភាសាខ្មែរ ដោយសារការទទួលយកនូវភាសាបាលីនៅក្នុងសំណេរ ហើយសតវត្សទី១៥ និងទី១៦ គឺជាការចាប់ផ្ដើមនូវជំណាក់កាលថ្មីមួយ មុននឹងការលេចឡើងនូវវណ្ណកម្មនិពន្ធដ៏ល្អផូរផង់នៅក្នុង «សិលាចារឹកនគរវត្ត» (Saveros Lewitz 1972, Edwards, P. 2007) ដែលបញ្ជាក់ ពីការជ្រាបចូលនៃភាសាបាលី និងលទ្ធិនៃព្រះពុទ្ធសាសនាថេរវាទ នៅក្នុងវណ្ណកម្មតែងនិពន្ធខ្មែរ។ ប្រការនេះ គឺជាមូលហេតុសំខាន់ ដែលធ្វើឱ្យអ្នកឯកទេសខាងផ្នែកភាសាខ្មែរធ្វើសេចក្ដីសន្និដ្ឋានថា នៅសតវត្សទី១៥ មានការកាត់ផ្ដាច់ការវិវត្តនៃភាសាខ្មែរ និងការចាប់ផ្ដើមនៃជំណាក់កាលនៃភាសា «ខ្មែរកណ្ដាល»។

ទី២-«វណ្ណកម្មអក្សរសិល្ប៍ខ្មែរ»៖ គឺជាស្នាដៃអក្សរសិល្ប៍រឿង «រាមកេរ្តិ៍» និងវណ្ណកម្មកំណាព្យ ដូចជា «ល្បើកអង្គរវត្ត» ជាដើម។

ទី៣-«កម្រងច្បាប់ទូន្មាន»៖ តាមការវិភាគការចាប់ចុងចួននៅក្នុងការតែងកំណាព្យខ្មែរ គេបានចាត់ទុកថា «ច្បាប់កេរកាល» និង «ច្បាប់ក្ងួនចៅ» គឺជាច្បាប់ដែលតែងឡើងនៅក្នុងជំណាក់កាលទី១នៃភាសាខ្មែរកណ្ដាល។

គេឃើញមានអត្ថបទជាច្រើនសរសេរជាភាសាខ្មែរកណ្ដាលជំណាក់កាលទី២ រួមមានអត្ថបទច្បាប់ និងច្បាប់ទូន្មានជាច្រើន។ ក៏ប៉ុន្តែ ឯកសារពាក់ព័ន្ធនឹងភាសាខ្មែរកណ្ដាលជាច្រើនទៀតមិនមានចារកាលបរិច្ឆេទឡើយ ជាពិសេសឯកសារពីសតវត្សទី១៤ដល់សតវត្សទី១៧។ គេបានចាត់ទុកថា «ច្បាប់» ជាច្រើនដែលត្រូវបានតាក់តែងឡើងមុន «ច្បាប់ស្រី» របស់ព្រះបាទ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អង្គឌួង(១៧៨៩-១៨៥៩) គឺជាអត្ថបទសរសេរជាភាសាខ្មែរកណ្ដាល។

ការវិវត្តពីភាសាខ្មែរចាស់ ទៅភាសាខ្មែរកណ្ដាល គឺការឈប់បញ្ចេញសំឡេងព្យញ្ជនៈខាងចុងពាក្យ និងការបង្កើតស្រៈថ្មីមួយចំនួន។ គេបានឃើញការផ្លាស់ប្ដូរសំឡេងពីភាសាខ្មែរចាស់ ទៅភាសាខ្មែរកណ្ដាល នៅក្នុងសិលាចារឹកនៃភាសាខ្មែរចាស់ នៅពេលដែលគេប្រៀបធៀបជាមួយអត្ថបទនៃភាសាខ្មែរកណ្ដាល ហើយការផ្លាស់ប្ដូរសំឡេងនេះកើតកាន់តែខ្លាំងឡើងនៅក្នុងភាសាខ្មែរកណ្ដាលនៃដំណាក់កាលទី២ ជាពិសេស គឺការបង្កើតស្រៈថ្មី ដូចជាស្រៈ «អួ» ជាដើម។

អត្ថបទអក្សរសិល្ប៍សម័យកណ្ដាលមានលក្ខណៈសម្បូណ៌បែប។ ក្នុងចំណោមអត្ថបទចំនួន១២៦ ដែលគេបានរកឃើញមានអត្ថបទចំនួន៣% សរសេរនៅសតវត្សទី១៥, អត្ថបទចំនួន១៥% នៅសតវត្សទី១៦, អត្ថបទចំនួន៦៥% នៅសតវត្សទី១៧, និងអត្ថបទចំនួន១៧% នៅសតវត្សទី១៨ (MIKAELIAN, 2009)។ អត្ថបទដែលសម្បូណ៌ជាងគេនៅសតវត្សទី១៧ គឺជាអត្ថបទច្បាប់។

២.២.ឥទ្ធិពលពុទ្ធសាសនាថេរវាទទៅលើភាសាខ្មែរកណ្ដាល

វប្បធម៌សម័យកណ្ដាលខុសពីសម័យបុរាណនៅត្រង់ការផ្លាស់ប្ដូរសាសនាពីព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយានមកព្រះពុទ្ធសាសនាថេរវាទ។ នៅក្នុងសម័យបុរាណ ប្រជាជនកម្ពុជាប្រតិបត្តិសាសនាច្រើនបែបដែលហូរចូលមកពីប្រទេសឥណ្ឌា ដូចជានិកាយផ្សេងៗនៃព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា (មហាយាន និងថេរវាទ)។ នៅក្នុងអាណាចក្រខ្មែរសម័យអង្គរ ឥទ្ធិពលនៃសាសនាធំៗទាំងពីរ គឺព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយាន និងភាសាសំស្ក្រឹតបានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមខ្មែរដូច្នេះហើយ ទើបនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (១១៨១-

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១២២០) នៅចុងស.វ.ទី១២ និងដើមស.វ.ទី១៣ យើងឃើញថា ប្រាង្គប្រាសាទ ដែលសាងសង់នៅក្នុងរជ្ជកាលរបស់ព្រះអង្គ គឺជាប្រាសាទដែលឧទ្ទិសដល់ ព្រហ្មញ្ញសាសនាផង និងព្រះពុទ្ធសាសនាមហាយានផង ហើយសិលាចារឹក សុទ្ធសឹងតែចារឹកជាភាសាសំស្ក្រឹត។ នៅចុងសម័យអង្គរ ក្នុងឆ្នាំ១៣៣៦ មានការរីកលូតលាស់ព្រះពុទ្ធសាសនាថេរវាទ ជំនួសឱ្យព្រះពុទ្ធសាសនា មហាយាន និងព្រហ្មញ្ញសាសនា។

ថ្វីត្បិតតែព្រះពុទ្ធសាសនាថេរវាទត្រូវលើកតម្កើងជាសាសនារដ្ឋនៃ អាណាចក្រខ្មែរ នៅក្នុងឆ្នាំ១៣៣៦ ក៏ប៉ុន្តែការទទួលយកព្រះពុទ្ធសាសនា ថេរវាទនេះ អាចជាដំណើរការសន្សឹមៗ ដោយត្រូវឆ្លងកាត់ដំណាក់កាល អន្តរកាល ដែលមានដំណាក់កាលមួយនោះ ប្រជាជនកម្ពុជាគោរពបូជាក្នុង ពេលតែមួយនូវព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនាមហាយាន និងព្រះពុទ្ធ សាសនាថេរវាទ។ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ នៅចុងសតវត្សទី១២ និងដើមសតវត្សទី១៣ សាសនាទាំងនោះរួមរស់ជាមួយគ្នា ក្នុងសន្តិសហ-វិជ្ជមាន។ ក៏ប៉ុន្តែចាប់ពីសតវត្សទី១៣ មកព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា មហាយានចាប់ផ្តើមថមថយឥទ្ធិពលបន្តិចម្តងៗ ដោយសារប្រជាជនកម្ពុជា កាន់តែច្រើនឡើងប្រតិបត្តិព្រះពុទ្ធសាសនាថេរវាទ ដែលចូលមកអាណាចក្រ ខ្មែរពីប្រទេសមន តាមរយៈប្រទេសសៀម។ លោកបណ្ឌិតសភាចារ្យ ឃីង ហុកឌី បានលើកឡើងថា៖ «ចាប់ពីស.វ.ទី១៣មក យុវជនបានទទួលការ អប់រំពីវត្តអារាម ដែលមានព្រះសង្ឃជាគ្រូអាចារ្យឬឧបជ្ឈាយ៍» (ឃីង ហុកឌី ២០០៧, Pelliot, P 1902)។ សម្មតិកម្ម នេះ ធ្វើឡើងដោយឈរលើមូលដ្ឋាន កំណត់ត្រារបស់បេសកជនចិន ជីវ តាក្វាន់ នៅពេលមកទស្សនាអង្គរនៅ ឆ្នាំ១២៩៥-១២៩៦ ដោយបញ្ជាក់ថា«បុត្រគ្រហស្ថនានាទៅសាលាដោយ មានព្រះសង្ឃជាអ្នកបង្រៀនអប់រំ ដល់ធំចាកសិក្ខាបទមកកាន់ជីវិតគ្រហស្ថ វិញ» (ឃីង ហុកឌី ២០០៧)។

ក៏ប៉ុន្តែ ទន្ទឹមនឹងនេះ ព្រះពុទ្ធសាសនាថេរវាទក៏ចាប់ផ្តើមមានឥទ្ធិពល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅកម្ពុជរដ្ឋហើយ ដោយសារបុត្រមួយអង្គរបស់ព្រះបាទជ័យវរ្ម័នទី៧ បាន បួសជាព្រះសង្ឃ និងបានទៅរៀនទ្រឹស្តីព្រះពុទ្ធសាសនាថេរវាទនៅប្រទេស ស្រីលង្កា (KEYES, 1977)។

ពាក្យ «ថេរវាទ» មានន័យថា «មាគ៌ា (វាទ) នៃបុព្វបុរស (ថេរ)»។ ពាក្យ ដែលពុទ្ធបរិស័ទនិយមប្រើ គឺ «ព្រះថេរានុថេរៈគ្រប់ព្រះអង្គ» គឺជាវិញ្ញូជន នៃព្រះសង្ឃដែលគោរពបូជាសាសនាព្រះពុទ្ធ។ ១០០ឆ្នាំក្រោយពេលដែល ព្រះសម្មាសម្ពុទ្ធបានចូលនិព្វាន ព្រះសង្ឃដែលជាក្រុមភាគច្រើនបានផ្តាច់ ខ្លួនចេញពីសហគមន៍សង្ឃដើម ដែលជា «ព្រះថេរ» ឬដែលជានិកាយ «ថេរវាទ» ហើយដែលរក្សានូវប្រពៃណីទាំងស្រុង និងយ៉ាងតឹងរឹងនៃគម្ពីរ ព្រះពុទ្ធសាសនាមកដល់សព្វថ្ងៃ។ និកាយថេរវាទ គឺជាព្រះពុទ្ធសាសនាភាគ ខាងត្បូងនៃប្រទេសឥណ្ឌា។

ព្រះពុទ្ធសាសនាថេរវាទប្រើភាសាបាលីជាភាសាសម្រាប់ផ្សព្វផ្សាយ សាសនាព្រះពុទ្ធ។ បាលីមានន័យថា «មាគ៌ា» ឬ «និយាម»។ លទ្ធិនៃព្រះពុទ្ធ សាសនាថេរវាទមានចែងនៅក្នុងគម្ពីរ «ព្រះត្រៃបិដក» ដែលចែកជា៖ (១) វិនយបិដក ឬព្រះវិន័យសម្រាប់ព្រះសង្ឃ ពោលគឺជាគម្ពីរខាងព្រះពុទ្ធ សាសនាដែលបានចារឹកទុកនូវពុទ្ធប្បញ្ញត្តិនិងពុទ្ធានុញ្ញាត (ចាប់ពីសៀវភៅ លេខ១ ដល់១៣) (២) សុត្តន្តបិដក ឬព្រះសូត្រជាគម្ពីរដែលបានរួបរួម នូវព្រះធម៌ មានលក្ខណៈជាការសម្តែង ចាត់ជាក្រុម ជាពួក តាមហេតុការណ៍ និងចរិត អធ្យាស្រ័យរបស់សត្វ ឬគូសន្ទនា (ចាប់ពីសៀវភៅលេខ១៤ ដល់ ៧៧) និងព្រះអភិធម្ម ឬហៅថា អភិធម្មបិដក (ចាប់ពីសៀវភៅលេខ៧៨ ដល់១១០)។

ព្រះពុទ្ធសាសនាថេរវាទមានទ្រឹស្តីសំខាន់ៗដូចតទៅ (ល្វី - ហ៊្វីណូត៍, ១៩២៦) ៖ (១)-សេចក្តីប្រាថ្នារបស់មនុស្ស គឺអរហត្តផលរួចបានព្រះនិព្វាន (២)- និព្វានសម្រេចបាន ដោយបុញ្ញកិរិយាវត្ថុ (៣)- ព្រះអរហត្តនោះ បានដល់តែភិក្ខុទេ (៤)- ការធ្វើកុសល ដោយយកប្រយោជន៍របស់ខ្លួន ដើម្បី

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យបានឧត្តមសុខដល់ខ្លួន (ល្វី-ហ្វីណូត៍, ១៩២៦)។

ព្រះសិអារមេត្រី គឺជាព្រះពុទ្ធតទៅមុខ។ ព្រះសមណគោតម ឬព្រះសាក្យមុនី មានព្រះពុទ្ធដែលបានត្រាស់ដឹងពីមុនៗ។ នៅក្នុងព្រះត្រៃបិដកមាន២៧ ព្រះអង្គមុន ឯព្រះពុទ្ធដែលនឹងបានត្រាស់តទៅអនាគតមានចំនួន១០ព្រះអង្គ។ ព្រះពុទ្ធដែលនឹងបានត្រាស់ដឹងតពីព្រះសមណគោតម ទៅមុខនោះគឺព្រះសិអារមេត្រី ឬអរិយមេត្តយោ ប៉ុន្តែយើងខ្មែរដឹងជាក់នឹងថ្វាយបង្គំជាជម្មតាតែ៥ព្រះអង្គៈ(១)ព្រះកក្កុសន្ធោ(ទី២៥)(២)ព្រះកោនាគមនោ(ទី២៦) (៣) ព្រះកស្សបោ (ទី២៧) (៤) ព្រះសមណគោតម (ទី២៨) គឺព្រះពុទ្ធអង្គសព្វថ្ងៃនេះ និង (៥) ព្រះសិអារមេត្រី ជាព្រះពុទ្ធតទៅមុខ។ ព្រះពុទ្ធទាំង៥ ព្រះអង្គនេះ ដើមឡើយជាបងប្អូន ក្នុងជាតិមុនៗ ព្រះពុទ្ធទាំង៥ ត្រូវបានត្រាស់តៗគ្នារៀងទៅ ក្នុងកំណត់កប្ប ឬកល្ប ហៅ ភទ្ទកប្ប ឬភទ្រកល្ប រួចពីនោះកើតឆេះកល្បរំលាយលោកិយឱ្យសោះសូន្យ (ល្វី-ហ្វីណូត៍, ១៩២៦)។ នៅសតវត្សទី១៦ ព្រះពុទ្ធសាសនានិកាយ ព្រះសិអារ្យមេត្រីត្រូវបានគោរពយ៉ាងខ្លាំងនៅកម្ពុជា។

២.៣. មូលហេតុនៃការធ្លាក់ចុះនៃអារ្យធម៌អង្គរ

ខុសពីព្រហ្មញ្ញសាសនាដែលជាសាសនារបស់នាហ្មឺនមន្ត្រី ព្រះពុទ្ធសាសនាថេរវាទគឺជាសាសនា ដែលប្រជាជនសាមញ្ញគោរពបូជានៅតាមតំបន់ជនបទ (Harris, 2005)។ ចាប់ពីពេលដែលព្រះពុទ្ធសាសនាថេរវាទត្រូវបានប្រកាសជាសាសនារបស់រដ្ឋ ក្រុមបូជាចារ្យព្រាហ្មណ៍ជាច្រើន ដែលមានការអប់រំខ្ពង់ខ្ពស់បានភៀសខ្លួនចេញពីអាណាចក្រខ្មែរ ហើយមួយចំនួនបានរត់ភៀសខ្លួនទៅកាន់ប្រទេសសៀម និងត្រូវបានទទួលការយកចិត្តទុកដាក់ជាខ្លាំងដោយស្តេចសៀម។ ចាប់ពីពេលនោះមក អាស្រមនានា (មជ្ឈមណ្ឌលសាសនា) ត្រូវបានកាន់កាប់ដោយព្រះសង្ឃពុទ្ធសាសនា។ ប្រាសាទអង្គរត្រូវបានប្រែក្លាយទៅជាទីសក្ការៈសម្រាប់ព្រះពុទ្ធសាសនា។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«គម្ពីរព្រហ្មញ្ញសាសនា ព្រមទាំងសាលារៀនត្រូវបានបំផ្លាញ ក៏ព្រោះតែគ្រូទាំងនោះ គឺជាអ្នកគោរពបូជាព្រហ្មញ្ញសាសនាទាំងអស់» (Thach Toan, 2012)។ ការទទួលយក នូវពុទ្ធសាសនាថេរវាទ ធ្វើឱ្យជនជាតិខ្មែរឈប់សាងសង់ប្រាង្គប្រាសាទជាថ្ម ដែលបន្សល់ទុកនូវកេរ្តិ៍តំណាងជាច្រើន ហើយចាប់ផ្ដើមសាងសង់វត្តអារាម និងសំណង់ជាឈើវិញ។

ការចាកចេញនៃអ្នកប្រាជ្ញខាងសាសនាព្រាហ្មណ៍ និងខាងផ្នែកភាសាសំស្ក្រឹតពីអាណាចក្រខ្មែរ អាចឱ្យយើងធ្វើសេចក្ដីសន្និដ្ឋានបានថា ការទទួលយកព្រះពុទ្ធសាសនាថេរវាទ បានធ្វើឱ្យភាសាសំស្ក្រឹតត្រូវបានជំនួសដោយភាសាបាលី ដែលជាភាសានៃពុទ្ធសាសនាថេរវាទ។ បើតាមលោក Coedès ដែលបានស្រាវជ្រាវអត្ថបទសិលាចារឹក ភាសាបាលីដែលជាភាសាសក្ការៈនៃព្រះពុទ្ធសាសនាថេរវាទ ត្រូវបានចាប់ប្រើប្រាស់នៅកម្ពុជានៅដើមស.វ.ទី១៤ (G. Coedès, 1936)។ ក៏ប៉ុន្តែភាសាសំស្ក្រឹតបានជ្រាបចូលលាយឡំជាមួយនឹងភាសាខ្មែរ ហើយពាក្យសំស្ក្រឹតខ្លះបានក្លាយជាពាក្យខ្មែរផងដែរ។ ចាប់ពីពេលនោះមក ភាសាសំស្ក្រឹតមិនត្រូវបានប្រើប្រាស់ក្នុងការតែងនិពន្ធទៀតឡើយ។ ក៏ប៉ុន្តែខ្មែរនៅបន្តខ្ចីពាក្យពីភាសាសំស្ក្រឹតមកប្រើប្រាស់យ៉ាងទូលំទូលាយ នៅក្នុងអត្ថបទខ្មែរកណ្ដាល។ ភាសាបាលីត្រូវបានប្រើប្រាស់សម្រាប់ការតែងនិពន្ធ ដើម្បីសម្ដែងការគោរពដល់ព្រះពុទ្ធសាសនាថេរវាទ (ព្រះមហាពិទូរ ក្រសេម, 1984)។

យើងឃើញថា ចាប់ពីពេលដែលព្រះពុទ្ធសាសនាថេរវាទត្រូវបានលើកតម្កើង ជាសាសនារដ្ឋនៃអាណាចក្រខ្មែរនៅក្នុងឆ្នាំ១៣៣៦ រហូតដល់ពេលចាកចោលអង្គរនៅឆ្នាំ១៤៣២ គឺមានរយៈពេលជិត១០០ឆ្នាំ។ ដូច្នេះការធ្លាក់ចុះជាបណ្ដើរៗនៅក្នុងស.វ.ទី១៤នេះ គឺបណ្ដាលមកពីការបាត់បង់បញ្ញវន្ត និងធនធានមនុស្សខ្មែរ ដែលធ្លាប់រៀនសូត្រជាភាសាសំស្ក្រឹត។ ទន្ទឹមនឹងនេះប្រវត្តិវិទូក៏បានលើកពីសម្មតិកម្មដទៃទៀត ដូចជាផលវិបាកនៃការចាញ់សង្គ្រាមជាមួយសៀម និងបញ្ហាផ្លាស់ប្ដូរបរិស្ថានជាដើម។ ជាពិសេស

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របកគំហើញរបស់ក្រុមស្រាវជ្រាវនៃសាលាបារាំងចុងបូព៌ា តាមរយៈការគូរដោយបច្ចេកវិទ្យាស្កេនឡាស៊ែរពីលើអាកាស (LIDAR) នៅឆ្នាំ២០១៥ បានរកឃើញនូវទីក្រុងបុរាណខ្មែរ មហេន្ទ្របវ៌ត[1] ទាំងមូលដែលមានទំហំ៥០គីឡូម៉ែត្របួនជ្រុងជុំវិញភ្នំគូលែន ដែលលាតសន្ធឹងដល់ប្រាសាទព្រះខ័នកំពង់ស្វាយ។ ក្នុងបរិវេណទីក្រុងដ៏ធំនេះ មានប្រាសាទថ្ម ការដ្ឋានស្មដែក ព្រមទាំងប្រព័ន្ធផ្លូវទឹកសម្រាប់ស្រោចស្រព និងចរាចរណ៍។ របកគំហើញនេះបញ្ជាក់ពីមូលហេតុនៃការធ្លាក់ចុះសម័យអង្គរ ដែលបណ្តាលមកពីការបាត់បង់ប្រជាជន (The Cambodia Daily, ភ្នំពេញប៉ុស្តិ៍ ២០១៦)។ ប្រវត្តិវិទូក៏បានលើកឡើងពីការកើនឡើងនៃពាណិជ្ជកម្មនៅតំបន់ទន្លេចតុមុខនៃរាជធានីភ្នំពេញ ដែលអាចជាមូលហេតុនៃការផ្លាស់ប្តូររាជធានីផងដែរ។ របកគំហើញមួយទៀតរបស់បុរាណវិទូអំពីមូលហេតុនៃការធ្លាក់ចុះនៃអារ្យធម៌អង្គរ គឺការរីងស្ងួតហួតហែងនៃបារាយណ៍ និងប្រព័ន្ធធារាសាស្ត្រនៃតំបន់អង្គរ។

ក្រោយសម័យអង្គរ ខ្មែរលែងសាងសង់ប្រាសាទធំៗជាថ្មភក់ទៀតហើយ។ ភាសាខ្មែរបានវិវត្តយ៉ាងលឿន ដោយសារនៅសម័យលង្វែកខ្មែរនៅបន្តដើរតួនាទីយ៉ាងសំខាន់នៅអាស៊ីអាគ្នេយ៍នៅសតវត្សទី១៥ និង១៦។ ភាសាបាលីបានជំនួសភាសាសំស្ក្រឹតនៅក្នុងមជ្ឈដ្ឋានបញ្ញវន្ត។ ចំណែកឯកភាសាភាសា «ខ្មែរបុរាណ» ក៏លែងវិវត្តទៅមុខដែរ បន្ទាប់ពីការធ្លាក់ចុះនៃអង្គរ។

២.៤. ប្រភពនៃការសិក្សាភាសាខ្មែរកណ្តាល

២.៤.១. សិលាចារឹក

បន្ទាប់ពីការបែកបាក់នៃអាណាចក្រខ្មែរ ភាសាខ្មែរចាស់លែងជាភាសានៃរដ្ឋដ៏មានឥទ្ធិពលខ្លាំងក្លាដូចមុន ហើយភាសាខ្មែរចាប់ផ្តើមទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា។ រជ្ជទាយាទនៃព្រះរាជវង្សានុវង្សខ្មែរត្រូវបានប្រទេស

[1] ដែលជាពាក្យបាលី ដែលមានន័យថា ៖ ភ្នំនៃព្រះឥន្ទដ៏មហិមា ដែលជាទីតាំងនៃភ្នំគូលែនបច្ចុប្បន្ន។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សៀមចាប់ខ្លួនជាឈ្លើយសឹក ហើយទទួលការអប់រំ និងចិញ្ចឹមបីបាច់ថែរក្សានៅទីក្រុកបាងកក។ អ្នកប្រាជ្ញ ករីនិពន្ធត្រូវបាត់បង់ជីវិតក្នុងសង្គ្រាម និងត្រូវចាប់ខ្លួនជាឈ្លើយ ជាហេតុធ្វើឱ្យប៉ះពាល់ដល់ការវិវត្តនៃភាសាខ្មែរ។

នៅសតវត្សទី១៦ និង១៨ គេឃើញមានសិលាចារឹកចំនួន៤២ផ្ទាំងចារចាប់ពីគ.ស. ១៥៦៦ ដល់ គ.ស.១៧៤៧ ដែលគេប្រសិទ្ធនាមថា «សិលាចារឹកនគរវត្តទំនើប»(Inscriptionsmodernesd'AngkorVat) ដែលស្ថិតនៅក្នុងប្រាសាទអង្គរវត្ត តាមកន្លែងផ្សេងៗគ្នា៖ (១) សិលាចារឹក ចំនួន២៨ផ្ទាំងស្ថិតនៅក្នុង «ព្រះពាន់» ដែលជាថែវកាត់គ្នានៅជាន់ទីមួយនៃប្រាសាទអង្គរវត្ត (២) សិលាចារឹកចំនួន១៣ផ្ទាំង ស្ថិតនៅជាន់ទី៣ លើសសរនៃ «បាកាន» និង (៣) សិលាចារឹកមួយផ្ទាំងដ៏ធំជាងគេ ហើយនៅដាច់ពីគេ ដែលស្ថិតនៅក្នុងថែវ ផ្នែកខាងកើតដែលជាសិលាចារឹក «ជ័យនន្ទ»។ លោក AYMONIER (1883) បានសិក្សា និងបោះផ្សាយ «សិលាចារឹកនគរវត្ត» នេះមុនគេ បន្ទាប់មក ព្រះមហាពិទូរ ក្រសេម និងបណ្ឌិត ពៅ សាវរស បានសិក្សា និងបោះពុម្ពផ្សាយជាបន្តបន្ទាប់។

ការវិវត្តសំខាន់ៗនៃភាសា «ខ្មែរកណ្ដាល» ពីសតវត្សទី១៤ មកទល់ពាក់កណ្ដាលសតវត្សទី១៨ មានដូចតទៅ៖ (១) អក្សរសរសេរមានការប្រែប្រួលយ៉ាងខ្លាំង ខុសពីអក្សរនៃភាសា «ខ្មែរបុរាណ» ជំនាន់អង្គរដោយប្រើអក្សរ «មូល» ចាប់ពីសតវត្សទី១៦, (២) ការចាប់ផ្ដើមប្រើពាក្យ «បាលី» នៅលាយឡំជាមួយពាក្យ «សំស្រ្កឹត» ដែលចាក់ឫសចូលជានិច្ចនិរន្តរ នៅក្នុងភាសាខ្មែររួចទៅហើយ (៣) ឥទ្ធិពលនៃលទ្ធិព្រះពុទ្ធសាសនាថេរវាទមកលើភាសាខ្មែរ (៤) ការពង្រីកមូលដ្ឋានពាក្យដែលប្រើប្រាស់ថ្មីៗនៅក្នុងភាសាខ្មែរ (៥) ការបង្កើតក្បួនវេយ្យាករណ៍ជាច្រើន ដែលរៀបចំភាសាខ្មែរឱ្យមានលក្ខណៈជាប្រព័ន្ធទៅតាមមុខងារ និងវិធីជាច្រើន (POU, 2017)។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

២.៤.២. សាស្ត្រាស្លឹករឹត

ស្នាដៃអក្សរសិល្ប៍ត្រូវបានកត់ត្រាទុកលើ «ក្រាំង» ដែលជាសន្លឹកក្រដាសស្នាច់បត់ជាផ្នត់ និងលើស្លឹករឹតដែលហៅថា «សាស្ត្រា» ដែលសរសេរជាពាក្យកាព្យ។ វណ្ណកម្មអក្សរសិល្ប៍ឆ្នើម ដែលលេចធ្លោនៅសម័យកណ្ដាលមាន៖

(១) រឿង«រាមកេរ្តិ៍» ដែលជាអត្ថបទ សរសេរជាពាក្យកាព្យដ៏អស្ចារ្យ តែគ្មានការបញ្ជាក់ពីពេលវេលានៃការតែងនិពន្ធ និងឈ្មោះរបស់កវីនិពន្ធឡើយ។ តាមការសិក្សារបស់លោកស្រីសាស្ត្រាចារ្យ ពៅ សាវរស់ រឿងរាមកេរ្តិ៍ត្រូវបានតែងនិពន្ធ ដោយប្រើប្រាស់ពាក្យពេចន៍នៃភាសាខ្មែរសម័យកណ្ដាលនៅសតវត្សទី១៥ និងទី១៦ ពោលគឺនៅសម័យមុនលង្វែក និងនៅសម័យលង្វែក។

រឿងរាមកេរ្តិ៍ ដែលតែងជាពាក្យកាព្យ គឺជាជម្រកពាក្យពេចន៍នៃភាសា និងវោហារសាស្ត្រខ្មែរ និងជាប្រភពនៃការច្នៃប្រឌិតខាងតែងនិពន្ធ។ គេបានប្រើប្រាស់ពាក្យកាព្យក្នុងរឿងរាមកេរ្តិ៍ ដើម្បីបង្កើតវណ្ណកម្មថ្មីៗទៀត ដូចជាវិចិត្រកម្ម សិល្បនាដសាស្ត្រ និងល្ខោន។ សិល្បករ នាដករ និងអ្នកនិពន្ធខ្មែរបានយករឿងរាមកេរ្តិ៍ទៅសម្ដែងក្នុងល្ខោនព្រះរាជទ្រព្យ ល្ខោនខោល ល្ខោន-ស្បែកតូច និងស្បែកធំ។ ដូច្នេះហើយទើបរឿងរាមកេរ្តិ៍ជ្រាបចូលជ្រៅទៅក្នុងសង្គមខ្មែរ។ ចលនាអក្សរសិល្ប៍បែបព្រាហ្មណ៍និយមដែលតំណាងដោយរឿងរាមកេរ្តិ៍ មានរូបសេចក្ដី និងសណ្ឋានដែលដកស្រង់ចេញពីប្រភពនៃរាមាយណៈរបស់ឥណ្ឌា។

រឿងរាមកេរ្តិ៍ជាស្នាដៃអក្សរសិល្ប៍សម័យក្រោយអង្គរដ៏អស្ចារ្យ ដែលជាបេតិកភណ្ឌជាតិខាងផ្នែកអក្សរសាស្ត្រ។ រឿងរាមកេរ្តិ៍មានលំនាំប្រហាក់ប្រហែលនឹងរឿងរាមាយណៈ ដែលជាវីរកថា (épopée) របស់ឥណ្ឌាក៏ពិតមែន តែកវីនិពន្ធខ្មែរបានយករឿងនោះមកស្វកែច្នៃសាច់រឿង និងថែមគ្រឿងដោយប្រើប្រាស់វិធីសាស្ត្រ និងសិល្បវិធីតែងនិពន្ធ ថែមថយពាក្យពេចន៍

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បញ្ចូលទស្សនៈ និងខ្លឹមសារ ឱ្យផ្ទុះបញ្ចាំងពីតថភាពក្នុងសង្គមខ្មែរ ប្រើប្រាស់វោហារសាស្ត្រខ្មែរ ដើម្បីឱ្យសាច់រឿងនេះ ក្លាយជារបស់ខ្មែរសុទ្ធសាធ។

យើងក៏ឃើញដូចគ្នាដែរ ថាប្រាង្គប្រាសាទ និងរូបចម្លាក់ ដែលនៅរចនាបថសម្បូណ៌ព្រៃគុកមានលក្ខណៈស្រដៀងឥណ្ឌា។ ក៏ប៉ុន្តែ បន្ទាប់ពីអ្នកប្រាជ្ញ និងសិល្បករខ្មែរបានដុសខាត់ កែលម្អ និងវិវត្តអស់រយៈពេលជិត៥០០ឆ្នាំមក ស្នាដៃសិល្បៈទាំងនេះបានក្លាយទៅជារបស់ខ្មែរពិតៗ។ ឧទាហរណ៍ រូបបដិមាព្រះនាងទុគ៌ា ដែលរកឃើញនៅក្នុងប្រាសាទសម្បូណ៌ព្រៃគុកបង្ហាញឱ្យឃើញពីសម្រស់និងរូបរាងស្ត្រីឥណ្ឌាតែម្តង។ ផ្ទុយទៅវិញ រូបបដិមាដែលរកឃើញនៅក្នុងប្រាសាទអង្គរវត្តមានរាងរាវ និងបង្ហាញឱ្យឃើញពីសម្រស់ និងរូបរាងស្ត្រីខ្មែរពិតៗ។

រឿងរាមកេរ្តិ៍ គឺជាវណ្ណកម្មឯក ដែលផ្ទុះបញ្ចាំងនូវទេពកោសល្យនៃកវីនិពន្ធខ្មែរ ហើយដែលត្រូវបានចាត់ទុកជាវណ្ណកម្មអក្សរសិល្ប៍ព្រាហ្មណ៍និយម។ មានអ្នកសិក្សាស្រាវជ្រាវជាច្រើនបានសរសេរវិភាគរួចមកហើយនូវរឿងរឿមកេរ្តិ៍នេះ ដូចជាៈ(១) លោកសាស្ត្រាចារ្យសរ សារុន សាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវឯកសារគរុកោសល្យ (២) លោកសាស្ត្រាចារ្យលាង ហាប់អាន (៣) លោកសាស្ត្រាចារ្យឃួន សុខម្ភូ (៤) លោកស្រីសាស្ត្រាចារ្យពៅ សាវរស់ និងមានសៀវភៅសិក្សាអក្សរសិល្ប៍ខ្មែរ ចលនាព្រាហ្មណ៍និយមជាច្រើនទៀត។

អ្នកនិពន្ធមុនៗបានបង្ហាញពីភាពខុសគ្នារវាងរឿងរាមកេរ្តិ៍ និងរឿងរាមាយណៈ របស់វាល្មីកិ ដែលតែងនិពន្ធ ចាប់ពីការផ្តើមរឿងខុសគ្នា ដល់ដំណើររឿងតែម្តង។ រាមច្បងរបស់យើងបានសិក្សាពីទីកន្លែងរឿង តួអង្គរឿង បញ្ហាទំនាស់ក្នុងរឿង ការដោះស្រាយបញ្ហារឿង និងបញ្ហាផ្សេងៗទៀត ដែលអ្នកនិពន្ធបានលើកមកចោទ និងដោះស្រាយនៅក្នុងរឿងរាមកេរ្តិ៍។ អ្នកនិពន្ធបានលើកយកបញ្ហាមនុស្សមកចោទសួរ មកបង្ហាញ មករិះគន់ និងមកដោះស្រាយ តាមរយៈកម្រងកំណាព្យដែលតែងនិពន្ធ នៅក្នុងសតវត្សទី១៥

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងទី១៦ នៅពេលដែលខ្មែរយើងខិតខំប្រឹងប្រែងកសាងជាតិឡើងវិញ នៅក្នុងគ្រប់វិស័យ ជាពិសេសក្នុងការលើកកម្ពស់អក្សរសិល្ប៍ខ្មែរសម័យកណ្ដាល។

សាស្ត្រារឿងរាមកេរ្តិ៍ ត្រូវបានបំផ្លាញចោល នៅពេលដែលព្រះពុទ្ធសាសនាមានឥទ្ធិពលខ្លាំងនៅកម្ពុជា។ ដូច្នេះហើយ ទើបរឿងរាមកេរ្តិ៍ត្រូវបានហាមឃាត់មិនឱ្យផ្សព្វផ្សាយជាសាធារណៈមុនអំឡុងទសវត្សឆ្នាំ១៩៥០។ សាស្ត្រាដែលនៅសេសសល់ពីខ្សែទី១ ដល់ទី១០ និងពីខ្សែទី៧៥ ដល់៨០ ដោយសារតែលោកស្រី ស៊ូហ្សាន កាប៉ឺឡេស រក្សាទុកយ៉ាងស្ងាត់កំបាំង បន្ទាប់មកយកទៅរៀបរៀងបោះពុម្ពផ្សព្វផ្សាយឡើងវិញនៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យក្នុងទសវត្សឆ្នាំ១៩៥០។ ការបោះពុម្ពឡើងវិញលើកទី៣ បានធ្វើឡើងនៅឆ្នាំ១៩៥៩។

រឿងរាមកេរ្តិ៍ពីទី១ ដល់ទី១០ តែងឡើងជាពាក្យកាព្យ តាមបទពំនោល ដោយមានចាប់ចុងជួន ណែងណងគួរឱ្យពីរោះជាប់ចិត្ត។ ការប្រើពាក្យពេចន៍នៅក្នុងកំណាព្យនេះសម្បូណ៌ដោយពាក្យជាភាសាសំស្ក្រឹត និងភាសាបាលីយ៉ាងច្រើនលើសលុប ហើយប្រហាក់ប្រហែលទៅនឹង «សិលាចារឹកនគរវត្ត» ដែលមានចារកាលបរិច្ឆេទផងដែរ។

សម្រស់នាងសីតា (នៅក្នុងខ្សែទី១)

ជងនោះឥស្សរមិថិលា	រៀបរាជយោធា	នូវថ្វាត់រីងថ្កានព្រះនគរ។
នាំរាជកញ្ញាសុបវរ	ស្មើបុត្រដ៏ឧទរ	កំលុះលើករាជពិភព។
ស្ដេចរក្សារាស្ត្រផងស្កល់ស្កប់	ស្ដេចទើបឱ្យអ-	ភិសេកប្រកបនាមា។
ដោយហេតុហៅរាជសីតា	បរិសុទ្ធិសោភា	ដូចបូណ៌ព្រះចន្ទ្រប្រាលប្រាស។
វរកត្រូវរលក្សណ៍យល់ច្បាស់	អស់ទេពទសសហ័ស្ស	ពុំស្មើនូវរាជបុត្រី។
ជងនោះព្រះបាទនរបតី	យល់រាជបុត្រី	ពិសេសពិសុទ្ធសុន្ទរ។
នោះព្រះមុនីរាជដ៏បវរ	ជបធនូសិល្បសរ	នូវសព្ទសច្ចាអធិស្ឋាន។
ជាទោះទេពតាឫទ្ធិមាន	ដ៏យអាចលើកបាន	ធនូសិល្បនូវតេជោជ័យ។
យើងនូវយករ័តន៍សីតាថ្លៃ	អភិសេកឱ្យឲ្យ	នាទេពដ៏មានចេស្ដា។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អស្ចារ្យទូទសទិសា កក្រើកត្រៃត្រឹង្សា ឧណ្ហាអស់ទេពដ៏និករ។
អស់ទេពតាផងសឹងដ៏អរ បរន្ទាវិវរ រត់ចុះពីត្រៃត្រឹង្សា។

ឫទ្ធានុភាពរបស់ព្រះរាម

ព្រះរាមស្តេចមើលអស់គូ- ធរលើកឫទ្ធីធនូ កំព្រើសព្រះកត្រូប្រិមប្រិយ៍។
ស្តេចចូលលងឫទ្ធិដ៏ពិធី អស់ទេពដ៏ឥសី ក្សត្រទតអានុភាពចេស្តា។
ព្រះរាមរឹងឫទ្ធិមោះហិមា ស្តែងស្តេចចេស្តា ធិការនុភាពលើសក្រៃ។
ស្តេចលើកកៅទ័ណ្ឌសរជ័យ អស់ទេពមនុស្សឮ ដ៏មានកំឡុងលោកជាតុ។
សឹងថ្វាយសព្ទសាធុការសោទរ ព្រះបរមនាថ ឫទ្ធីអំណាចយល់ផ្តើង។
ស្តេចវាត់កៅទ័ណ្ឌបីជុំឡើង កោះសរសក្តិថ្លើង សម្តែងនូវតេជប្រត្យក្ស។
ស្តេចក្រាយកៅទ័ណ្ឌសរសក្តិ រូមណ្ឌលចក្រ រំកាយព្រះករសោភា។

ពាក្យកម្ពីបាលី និងសំស្ក្រឹតនៅក្នុងរឿង «រាមកេរ្តិ៍» មានដូចតទៅះ ក្សិណ (ខណនោះ) ស័ក្តិ (អំណាច) សុកតិត្តី (ថ្លៃល្អ) សីហនាទ (បន្ទឺសូរសៀង ដូចសីហ) សុន្ទរ (ល្អ ពីរោះ) សួស្តី (សេចក្តីចម្រើន) ស្មៀន (លេខា) អាចិណ្ណ (ជានិច្ច) អម្ពរ (អាកាស) អសុរា (សេះ) តេជោពល (កម្លាំងនៃតេជះ) សច្ចាអធិស្ឋាន (សច្ចាប្រណិធាន) អមរនាគេន្ទ្រ (ដំរីរបស់ព្រះឥន្ទ្រ) ករី (ដំរី) ត្រៃពេទជោតិសារ (គម្ពីរត្រៃវេទ) ឧណ្ហា (ក្តៅ) ករ (ដៃ) កលហ (ឈ្លោះគ្នា) កទលិ (ចេក) ក្របី (ស្វា) ក្របិន្ទ្រ (ស្តេចស្វា) ក្រលាតបៈ (ផ្ទៃទីសម្រាប់ធ្វើតបៈ) នរបតី (ព្រះរាជា) នរពន្ធុ (អំបូរមនុស្ស) នរពិន (កំពូលមនុស្ស) ពលខ័ន្ធ (កងពល) ទូងរាជគិរី (ទូងស្គរ) គជសារ អស្សពាហ៍ (សេះ) ឥស្សរ មិថិលា (ព្រះចៅក្រុងមិថិលា) ឥស្សរសក្តា (អំណាចដ៏ធំ) ឧទារ (សម្បើម) ពាជី (សេះ) សិង (ស្ថិតនៅ) អាធ្វា (ផ្លូវឆ្ងាយ) ទូរគម (ផ្លូវឆ្ងាយ) ទីឃាយុ (អាយុយឺនយូរ) គិម្ហន្តមាសា (រដូវក្តៅ)

(២) កំណាព្យ«ល្បើកអង្គរ» និពន្ធដោយកវីអ្នក ប៉ាង តាត (ម៉ុញ សារី, ២០១១) ដែលសរសេរជាបទព្រហ្មគីត បទកាកគតិ និងបទពំនោលដែល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លោកស្រីបណ្ឌិត ពៅ សាវរស បានបកស្រាយតាមវិទ្យាសាស្ត្រនៃភាសាវិទ្យាថា សរសេរនៅឆ្នាំ១៦២០ (ឃីង ហុកឌី, ២០០៦) ហើយដែលសរសេរឡើងនៅពេលដែលប្រជាជនកម្ពុជាមានជំនឿលើព្រះពុទ្ធសាសនាថេរវាទ និងបានផ្ទុះបញ្ចាំងពីលទ្ធិសុខដុមនីយកម្មរវាងសាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធ (Edwards, P. 2007)។ ខ្ញុំសូមដកស្រង់នូវអត្ថបទខ្លះដូចខាងក្រោម៖

បទព្រហ្មគីតិ

ប្រាសាទនេះឯងណា ព្រះឥន្ទ្រាទិព្វទេពថ្លៃ
ប្រើព្រះពិស្ណុការនៃ ចុះមកសាងថ្វាយក្សត្រា។
កាល្មោះអស្ចារ្យក្រៃ មានក្សត្រិយ៍ថ្លៃសោយរាជា
ស្ដេចទ្រង់ព្រះនាមា ហៅព្រះបាទវង្សអស្ចារ្យ។
ស្ដេចមានព្រះអំណាច សេពសោយរាជ្យនូវធម្មា
គ្រប់គ្រងអស់រាស្ត្រណា សឹងក្សេមដោយព្រះបារមី។
ស្ដេចមានវរជាយា ទ្រង់នាមាទេវតី
ឆោមឆាយស្រស់សោភី ជាច្បងច្បាស់អស់ស្នំផង។
អនេកនូវបរិពារ ស្រីស្រីឆ្ពាឥតឯធ្លង
ស្រីស្រស់ទន់ទងវង រៀបរាយរៀងបំរើនិត្យ។
ព្រះមហាក្សត្រិយ៍ត្រកូល ជាឥសូរអង្គឯកក្សត្រិយ៍
សឹងមកប្រណិប័តន៍ ថ្វាយបង្គំឥតឯធ្លង។

បទពំនោល

ប្រាសាទទាំងបួនមានទ្វារ គ្រប់សព្វនូវប្រការ បន្ទាប់ទ្រាប់ត្រួតលើគ្នា។
ផ្ទះផ្ទាំងជញ្ជាំងប្រាង្គប្រា- សាទសួគ៌សោភា ចម្លាក់ចំឡៅអស់ក្ដី។
ឆ្លាក់ជារូបរតន៍នារី ហៅកោត្តវតី គឺស្រីប្រសើរសួគ៌ា។
រូបទ្រង់បញ្ចង់សោភា ឈរឈមរៀងគ្នា លេងលើប្រាសាទសោតហោង។
ខ្លួនមូលសសួលឥតហ្មង ទន់ភ្លន់មុខឈ្នង ប្រកបនូវលក្ខណ៍បានខ្នាត។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជូតចារក្រីញារស្អាងស្អាត ខ្លះបួងខ្លះកាត់ កែមកាលកេសាសោតសម។
ចង្កេះរៀវឆ្មៀវម្លូលក្លំ ដោះសោតសឹងក្បំ ក៏ដូចក្រពុំបទុមា។
ស្រឡះសជ្រះអង្គា សឹងពាក់មាលា គន្ធារកែមពកាឡើ។
ចងទូវចំណងកេសី ពេទព័ន្ធទងភ្លី ស័ក្តិសមបន្ទាយល្អក្រៃ។
ខ្លះដោតខ្លះក្រងដ៏ប្រពៃ ខ្លះទើបយកដ សឹកសៀតកាន់ក្រងផ្កាត់ផ្កាយ។
ខ្លះសោតសិតសក់បន្ទាយ ខ្លះសោតកាន់ជាយ សំពត់ក៏ទាក់ឡើងផង។
ខ្លះកាន់ភ្លីសួគ៌ទាំងទង ខ្លះកាន់នៅកម្រង ភ្ញីទេសទាំងទងលតា។
ខ្លះផ្ទៀងឈ្មងឈ្មៀងមើលគ្នា ខ្លះចូលប្រការ កាន់ស្មាដណ្តើមទងភ្ញី។
ខ្លះសេចញញឹមប្រិមប្រិយ ហាក់នឹងស្រដី សំណេះសំណាលរួមរក្សា។

(៣) «សាស្ត្រាល្បែង» ដែលជាអត្ថបទអក្សរសិល្ប៍ពេញនិយមនៅសម័យឧដុង្គ ជារឿងច្នៃប្រឌិតសម្រាប់ប្រលោមលួងលោមអារម្មណ៍អ្នកអានក្នុងកម្រងភាសាកំណាព្យដ៏ប្រណីត ពោលគឺជាកម្រងអត្ថបទរឿងរ៉ាវបែបប្រពៃណីដែលតាក់តែងជាកាព្យឃ្លោងឡើង នៅរវាងស.វ.ទី១៨-១៩ (ឃីង ហុកឌី, ២០០៣) ដូចជារឿងគ្រុងសុភមិត្រ (១៧៩៨) ភោគកុលកុមារ (១៨០៤) កាកី (១៨១៥) ដាវ រឿង (១៨៣៧) រឿងព្រះជិនវង្ស វរវង្ស សូរវង្ស ស័ង្ខសិល្បជ័យ ជ័យទត្ត ជាដើម ក្នុងគោលដៅអប់រំ និងសម្រាប់បន្ធូរចិត្តទុក្ខព្រួយចិត្តលំបាកតឹងតែង ឱ្យធូរស្រាល (លាង ហាប់អាន, ១៩៦៧)។

រឿងសាស្ត្រាល្បែង ជារឿងពីរោះពិសា មានសារប្រយោជន៍ខាងផ្លូវអក្សរសាស្ត្រ ហើយជារឿងសម្រាប់ដឹកនាំអ្នកស្តាប់ ឱ្យកើតសតិបញ្ញា យល់ការខុសត្រូវ រាក់ជ្រៅច្រើន ឱ្យមានគំនិតខ្ពស់ស្គាល់គុណទោស រួមយ៉ាងខ្លី គឺឱ្យស្គាល់គតិលោក គតិធម៌។ ក្នុងរឿងសាស្ត្រាល្បែង យើងបានសង្កេតដំណើររឿងនិមួយៗ ឃើញបានគតិពីរយ៉ាងគឺ ខាងដើមរឿងច្រើននិយាយពីការព្រាត់ប្រាស កណ្តាលរឿងច្រើននិយាយពីការច្បាំងគ្នា ការប្រណាំងប្រជែងគ្នាជាគតិលោក។ ខាងចុងបំផុតរឿង ច្រើននិយាយពីតួឯកក្នុងរឿងចេញបួសជាតាបសឬសី ដែលជាគតិធម៌ ដើម្បីទាញអារម្មណ៍អ្នកអានអ្នកស្តាប់ឱ្យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រេកត្រអាលក្នុងកាមតាមផ្លូវលោកជាខាងដើម ឱ្យទៀយណាយ ចាកកាម តាមផ្លូវធម៌ជាខាងចុង ហើយជាពិសេសបំផុតគឺ ច្រើនតែរឿងឃោសនា ដើម្បីទាញទ្រឹស្តីអ្នកអានអ្នកស្តាប់ឱ្យជឿកម្មផល តាមគតិពុទ្ធសាសនា។

២.៤.៣. សាស្ត្រាស្លឹករឹត ជាបេតិកភណ្ឌជាតិខ្មែរ

រឿងព្រេង និងរឿងសាស្ត្រាល្បែងទាំងប៉ុន្មាន ដែលកើតមាននៅប្រទេសកម្ពុជាយើងនេះចែកជា២ផ្នែក៖ (១) អ្នកប្រាជ្ញបុរាណបាននិពន្ធទុក ហើយបច្ឆាជនបានចារដាក់ស្លឹករឹតខ្លះ សរសេរដាក់ក្រាំងខ្លះ ដាក់សៀវភៅខ្លះតៗគ្នា ទុកនៅតាមវត្តអារាម ភូមិស្រុកនានាពេញប្រទេសកម្ពុជាទាំងមូល និង(២) ចាស់បុរាណបាននិទានទុកហើយ បច្ឆាជនបានដំណាលប្រាប់គ្នាតមកដោយមាត់ទទេ ឥតបានសរសេរឡើយ។

សាស្ត្រាចារលើស្លឹកទ្រាំង មានលក្ខណៈចំណាស់ស្មើនឹងសម័យមានឥទ្ធិពលនៃអារ្យធម៌ឥណ្ឌា និងមានវត្តមានដំណាលគ្នានឹងការចូលមកនៃព្រះពុទ្ធសាសនា និងសាសនាផ្សេងទៀតពីប្រទេសឥណ្ឌា (De BERNON, 2018)។ លោក ជីវ តាក្វាន់ ដែលបានមកទស្សនាអង្គរនៅឆ្នាំ១២៩៥-៩៦ បានសរសេរថា៖ លោកសង្ឃសូត្រធម៌ជារៀងរាល់ថ្ងៃ ដោយអានសាស្ត្រាស្លឹករឹតដែលធ្វើឡើងពី «ស្លឹករឹតចងផ្តោបគ្នា។ នៅលើស្លឹករឹតនេះ ព្រះសង្ឃសរសេរអក្សរពណ៌ខ្មៅ ប៉ុន្តែមិនប្រើជក់ ឬទឹកខ្មៅទេ» (PELLIOT, 1915:15)។ លើសាស្ត្រាស្លឹករឹត ដែលចងដាក់ទៅក្នុងឃ្នាប គេប្រើ «ហិង្គុល» លាបលើសន្លឹកនីមួយៗ និងជួនកាលលាបពណ៌មាស។

ចំណាត់ថ្នាក់សាស្ត្រាស្លឹករឹត៖ ក្រុមការងារ EFEO-FEMC បានធ្វើចំណាត់ថ្នាក់សាស្ត្រាស្លឹករឹតតាមប្រភេទដូចតទៅ (De BERNON, 2018)៖

១. សាស្ត្រាឧបទេស៖ (១) ច្បាប់ទូន្មាន (២) ច្បាប់សុភាសិត (៣) ល្បើកព្រះធម៌

២. សាស្ត្រាល្បែង៖ (១) ប្រលោមលោកបុរាណ (២) ល្បើកអប់រំ

៣. សាស្ត្រាទេសន៍៖ (១) ព្រះសទ្ធម្ម (២) ព្រះសូត្រ (៣) ព្រះវិន័យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(៤) ព្រះអភិធម្ម (៥) ជាតក (៦) អានិសង្ស

៤. ប្រវត្តិ៖ (១) ជីវប្រវត្តិ (២) ប្រវត្តិសាស្ត្រ

៥. គម្ពីរបុរាណ៖ (១) រឿងលក្ខណៈបុរាណ (២) ច្បាប់បុរាណ (៣) កម្មដ្ឋាន

៦. ក្បួនបុរាណ៖ (១) ហោរា (២) ថ្នាំ (៣) យ័ន្ត (៤) មន្តវិជ្ជា (៥) សង់ផ្ទះ (៦) ក្បួនធ្វើបុណ្យ

៧. អត្ថបទជាភាសាបាលី

៨. ផ្សេងៗ។

អ្នកនិពន្ធ ឬអ្នកចារ ប្រើចំណងជើងប្លែកៗនិងខុសៗគ្នា ទៅតាមប្រភេទនៃឯកសារដូចជា ព្រះកម្មដ្ឋាន វិន័យអភិធម្ម។ល។ ហើយសាស្ត្រាដែលមានចំណងជើងវិន័យ ឬព្រះវិន័យ មានចែកជាវិន័យសិក្ខាបទ ឬវិន័យសាមណេរ ឬជាគម្ពីរផ្សេងមួយទៀត។ សាស្ត្រាខ្លះមានចំនួនខ្សែច្រើន ហើយត្រូវបានចងក្រងសង្ខេបមក មួយខ្សែវិញ ឬគេចារជាពាក្យកាព្យមួយខ្សែ ដូចជា៖ (១) សាស្ត្រាទសជាតក (ខ្សែវែង ជាង៦០ខ្សែ) (២) មហាវេស្សន្តរជាតក (ខ្សែវែង ១៧ខ្សែ) និង (៣) បឋមសម្ពោធិ (តែងជាពាក្យកាព្យមួយខ្សែចប់ ដែលមានចំណងជើង «ល្បើកបឋមសម្ពោធិពាក្យឃ្លោង» សម្រាប់ស្មូត មុនគេបង្ហស់ក្នុងពិធីមាឃបូជា និងវិសាខបូជា) (ឡេង កុកអាន លក្ខណៈប្លែកៗនៃចំណងជើងសាស្ត្រាស្លឹករឹតខ្មែរ កម្ពុជសុរិយា)។

សាស្ត្រាស្លឹករឹតដែលចាស់ជាងគេ ដែលគេបានរកឃើញ គឺធ្វើនៅចុងសតវត្សទី១៨ ដោយសារម្យ៉ាងគេមិនបានចុះកាលបរិច្ឆេទត្រឹមត្រូវ ហើយម្យ៉ាងទៀតកម្ពុជាជួបប្រទះនឹងចម្បាំងរាំងជល់ ជាច្រើនលើកច្រើនសារ។ នៅពាក់កណ្តាលសតវត្សទី១៩ សង្គ្រាមរវាងសៀម និងវៀតណាមលើទឹកដីកម្ពុជាបានបំផ្លិចបំផ្លាញវត្តអារាមស្ទើរទាំងស្រុង។ នៅតាមវត្ត និងនៅតាមបណ្ណាល័យសឹងតែគ្មានសាស្ត្រាសម្រាប់រៀនសូត្រ។ ព្រះបាទអង្គឌួង បានចាប់ផ្តើមកសាងវត្តអារាមឡើងវិញ និងរៀបចំឱ្យបង្រៀនព្រះត្រៃបិដកឡើង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិញ។ បន្ទាប់ពីកម្ពុជាទទួលយកការការពារពីបារាំង អ្នកប្រាជ្ញបារាំងចាប់ផ្ដើមកសាងរាជបណ្ណាល័យឡើងវិញ។ ចាប់ពីសម័យព្រះបាទអង្គឌួងមក ខ្មែរចាប់ផ្ដើមចារសាស្ត្រាស្លឹករឹតឡើងវិញ ដើម្បីទុកសម្រាប់ការសិក្សាតាមវត្ត និងសម្រាប់ព្រះសង្ឃសូត្រធម៌។ នៅសម័យអាណាព្យាបាលបារាំង ដោយមានព្រះរាជអនុញ្ញាតពីព្រះបាទរាមាទី៤ (មង្កុត) និងសម្ដេចសង្ឃរាជថៃ Vajirañāṇavarorasa លោក George COEDÈS បានថតចម្លងនៅឆ្នាំ ១៩១៦-១៩១៨ សាស្ត្រាស្លឹករឹតបាលីយ៉ាងច្រើនសម្រាប់ព្រះសង្ឃខ្មែរ ក្នុងគោលដៅកាត់បន្ថយឥទ្ធិពលរបស់សៀមមកលើខ្មែរ។

នៅពេលដែលរោងពុម្ពត្រូវបានបង្កើតឡើងនៅកម្ពុជា នៅទសវត្សឆ្នាំ១៩២០ ព្រះសង្ឃបានប្រឆាំងនឹងការបោះពុម្ពសៀវភៅជាភាសាខ្មែរ និងអត្ថបទព្រះពុទ្ធសាសនា ដោយសារលោកយល់ថាការបោះពុម្ពលែងធ្វើឱ្យអត្ថបទនោះស័ក្ដិសិទ្ធិហើយ។ ព្រះសង្ឃនៃគណៈធម្មយុត្តិកនិកាយយល់ថា មានតែអក្សរបុរាណសរសេរដោយដៃ និងចារលើសាស្ត្រាស្លឹករឹតទេដែលមានភាពស័ក្ដិសិទ្ធិ។ ផ្ទុយទៅវិញ ព្រះសង្ឃនៃព្រះធម៌ថ្មីកំណែទម្រង់ ដែលដឹកនាំដោយសម្ដេចសង្ឃ ជួន ណាត និង សម្ដេច ហួត តាត យល់ពីសារៈសំខាន់នៃការបោះពុម្ព (De BERNON, 2018)។

សាលាបារាំងចុងបូព៌ាដែលបង្កើតឡើងនៅដើមសតវត្សទី២០ បានយកចិត្តទុកដាក់លើការអភិរក្សសិលាចារឹក។ ចាប់តាំងពីដើមសតវត្សទី២០ អ្នកប្រាជ្ញបារាំងបានយកចិត្តទុកដាក់ចំពោះសិលាចារឹកដ៏ពិសិដ្ឋទាំងនេះដែលគេរកឃើញនៅភ្នំពេញ។ លោកស្រី Suzane Karpelès នាយិកាព្រះរាជបណ្ណាល័យជាតិ ដែលបង្កើតឡើងនៅឆ្នាំ១៩២៥ ជាអ្នកអភិរក្សដំបូងគេបំផុត។ បន្ទាប់មក បណ្ណាល័យនេះត្រូវបានប្ដូរទៅក្នុងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលបង្កើតឡើងនៅឆ្នាំ១៩៣០។ ក្រោយថ្ងៃរំដោះសម្ដេចព្រះវនរ័ត កែន វង្ស ព្រះចៅអធិការវត្តសារាវ័នបានប្រមូលសាស្ត្រាស្លឹករឹតពីពុទ្ធសាសនបណ្ឌិត្យ ដើម្បីយកមកអភិរក្សនៅវត្តសារាវ័ន។ នៅឆ្នាំ១៩៩២ ពីរឆ្នាំមុនលោកសុគត

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លោកបានសុំឱ្យក្រុមការងារសាលាបារាំងចុងបូព៌ា-មូលនិធិសិលា ស្លឹករឹតកម្ពុជា (EFEO-FEMC) ជួសជុល និងធ្វើចំណាត់ថ្នាក់សមុច្ច័យនេះឡើងវិញ (De BERNON, 2018)។ ចាប់តាំងពីឆ្នាំ១៩៩០ មក ក្រុមការងារបារាំងចំណាយពេលជាង២០ឆ្នាំ ដើម្បីជួសជុល និងរៀបចំបញ្ជីសារពើភ័ណ្ឌសាស្ត្រាស្លឹករឹតនៅទូទាំងប្រទេសកម្ពុជា និងបានបោះពុម្ពសៀវភៅចំនួនពីរក្បាល។ ក្បាលទី២ បោះពុម្ពនៅឆ្នាំ២០១៨។ ខ្ញុំស្នើសុំគ្រឿងឥស្សរិយយសជូនដល់ក្រុមការងារមានលោក Olivier de BERNON លោកគុន សុភាព និងលោក ឡេង កុកអាន។ សាស្ត្រាស្លឹករឹតជាច្រើនមានទុកនៅបណ្ណាល័យ សម្តេចព្រះវនរ័ត កែន វង្ស (៣២០០បាច់) បណ្ណាល័យជាតិ (៨០០បាច់) និងនៅបណ្ណាល័យសម្តេចតេជោ ហ៊ុន សែន ជាដើម។

២.៤.៤. កម្រងច្បាប់ទូន្មាន និងភាសាខ្មែរកណ្តាល

«ច្បាប់» (ច្បាប់ផ្សេងៗ, ១៩៩៥) គឺជាអត្ថបទអក្សរសិល្ប៍ទូន្មានដែលសរសេរជាកំណាព្យ ដែលអ្នកប្រាជ្ញ និងកវីនិពន្ធបុរាណចងក្រងទុកជាក្បួនច្បាប់សម្រាប់ពលរដ្ឋដែលត្រូវដឹងពីគោលការណ៍ចរិយាធម៌ និងសុជីវធម៌រស់នៅក្នុងសង្គម (POU, 1981) និងសម្រាប់ប្រៀនប្រដៅ ពត់ហាត់កាយ វាចា ចិត្ត របស់កុលបុត្ត កុលធីតា អ្នកច្បាប់ មន្ត្រី បុរស ស្ត្រី ព្រមទាំងសម្រាប់កុមារ និងមាតាបិតា ដោយខ្លឹមសារផ្តោតលើពលរដ្ឋវិជ្ជា របៀបរបបរស់នៅ (Hansen 2004, 43) និងត្រូវបានរៀនសូត្រដោយចាំមាត់ (Moura, 1988។

ច្បាប់ទាំងនេះសរសេរលើសាស្ត្រាស្លឹករឹត ហើយត្រូវបានចម្លងតៗគ្នាសម្រាប់គ្រូនៅតាមវត្តយកទៅបង្រៀនសិស្សគណតាមសាលាវត្ត ដែលជាកន្លែងសម្រាប់រៀនសូត្រចាប់ពីសតវត្សទី១៦ មកទល់ដើមសតវត្សទី២០។ បន្ទាប់ពីកំណែទម្រង់វិស័យអប់រំនៅដើមសតវត្សទី២០ដោយប្រែក្លាយសាលាវត្ត ឱ្យទៅជាសាលាបារាំង-ខ្មែរ ច្បាប់ទាំងនេះត្រូវបានចម្លងចេញពីសាស្ត្រាស្លឹករឹត ដើម្បីទុកឱ្យកុលបុត្ត និងកុលធីតាខ្មែររៀនសូត្រចងចាំពីវប្បធម៌ និងអារ្យធម៌ខ្មែរ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លោកស្រីបណ្ឌិត ពៅ សាវរស បានធ្វើចំណាត់ថ្នាក់ «ច្បាប់» ទាំងនេះ តាមកាលបរិច្ឆេទ ជាពីរក្រុម គឺច្បាប់ចាស់ និងច្បាប់ថ្មី ដោយឈរលើមូលដ្ឋាននៃភាសាក្នុងអត្ថបទៗ ចំណែកឯលោក JENNER បានធ្វើចំណាត់ថ្នាក់ ដោយឈរលើមូលដ្ឋាននៃបទកំណាព្យ ហើយទទួលបាននូវលទ្ធផលប្រហាក់ប្រហែលគ្នា។

តារាងចំណាត់ថ្នាក់ច្បាប់តាមកាលបរិច្ឆេទ

<table>
<tr><th>ដំណាក់កាល</th><th>អត្ថបទច្បាប់</th><th>ច្បាប់ចាស់-ច្បាប់ថ្មី</th></tr>
<tr><td>ខ្មែរកណ្ដាលមុន
(Haut Khmer Moyen)
សតវត្ស១៥-១៧</td><td>- ច្បាប់កេរ្តិ៍កាល
- ច្បាប់កូនចៅ
- ច្បាប់រាជនេតិ
(ព្រះរាជសម្ភារ)
- ច្បាប់ក្រមៗលៗ</td><td rowspan="2">ច្បាប់ចាស់</td></tr>
<tr><td rowspan="2">ខ្មែរកណ្ដាលក្រោយ
(Bas Khmer Moyen)
សតវត្ស១៨-ពាក់កណ្ដាលសតវត្សទី១៩</td><td>- ច្បាប់ត្រីនេតិៗលៗ</td></tr>
<tr><td>- លោកនយបករណ៍
(នង, 1794)
- ច្បាប់ប្រុស
(បណ្ឌិត ម៉ឺន មៃ)
- ច្បាប់ស្រី
(បណ្ឌិត ម៉ឺន មៃ)</td><td rowspan="2">ច្បាប់ថ្មី</td></tr>
<tr><td>ខ្មែរសម័យទំនើប
(Khmer Moderne)
ពាក់កណ្ដាលសតវត្សទី១៩-ពាក់កណ្ដាលសតវត្សទី ២០</td><td>- ច្បាប់សូស្តី
- ច្បាប់ក្រម ង៉ុយ
- ច្បាប់រាជនីតិសាស្ត្រ
(១៩៣០-១៩៥០)</td></tr>
</table>

ប្រភព៖ (POU, 1981)

ច្បាប់ទូន្មាននេះត្រូវបានតែងនិពន្ធដោយកវីនិពន្ធខ្មែរចាប់តាំងពីស.វ. ទី១៥ មកម្ល៉េះសម្រាប់អប់រំប្រៀបប្រដៅមនុស្សនៅក្នុងសង្គមជាតិ និងនៅក្នុងគ្រួសារ។ ឧទាហរណ៍«ច្បាប់រាជសម្ភារ» ច្បាប់ក្រម ច្បាប់ហៃសាធុជន ឬច្បាប់ត្រីនេត្រ។ល។ អត្ថបទច្បាប់នេះគ្មានចុះកាលបរិច្ឆេទឡើយ។ ក៏ប៉ុន្តែតាមគោលគំនិត ពាក្យសម្ដី និងទំនៀមទម្លាប់ដែលមានចែងក្នុងអត្ថបទ គេអាចកំណត់ថា អត្ថបទភាគច្រើនកើតនៅក្នុងសម័យឧដុង្គវាំងស.វ.ទី១៧-១៨ និង១៩ប៉ុណ្ណោះ (ច្បាប់ផ្សេងៗ, ១៩៩៥)។ ចំពោះច្បាប់ចាស់ ដូចជាច្បាប់កេរ្តិ៍កាល អត្ថបទច្បាប់នេះ ប្រហែលជាតែងនៅក្នុងសតវត្សទី១៦ (POU, 1981)។

អត្ថរូបៈ ច្បាប់ទូន្មាននេះត្រូវបានតែងនិពន្ធជាកំណាព្យ តាមបទផ្សេងៗដូចជាបទព្រហ្មគីតិ (ច្បាប់ទូន្មានខ្លួន, ច្បាប់ពាក្យចាស់, ច្បាប់វិធុរបណ្ឌិត, ច្បាប់ប្រុស, ច្បាប់ហៃមហាជន) បទកាកគតិ (ច្បាប់រាជនេតិ ឬច្បាប់ព្រះរាជសម្ភារ, ច្បាប់ក្រម, ច្បាប់កូនចៅ, ច្បាប់ត្រីនេតិ, ច្បាប់អរិយសត្ថា, ច្បាប់បណ្ដាំបិតា, ច្បាប់កូនចៅល្បើក, ច្បាប់ស្រីជាព្រះរាជនិពន្ធនៃព្រះអង្គឌួង) និងបទភុជង្គលីលា (ច្បាប់ស្រីរបស់បណ្ឌិតម៉ឹន មៃ)។

អត្ថន័យ៖ ច្បាប់ទូន្មាននេះ កវីនិពន្ធបុរាណខ្មែរបានដកស្រង់គំនិតពី (POU, 1981)៖

- ទ្រឹស្ដីព្រហ្មញ្ញសាសនា ត្រិវគ៌ (Trivarga) ពោលគឺ (១) ព្រះធម៌ (dharma) (ដែលជាសណ្ដាប់ (saṇtāp) ដែលគ្រប់គ្រងលោក និងសង្គម, យុត្តិធម៌និងភារកិច្ច (dharmaśāstra) ច្បាប់ខាងផ្នែកសីលធម៌) (២) អត៌ (artha) (អត្ថប្រយោជន៍ និងភាពជោគជ័យ) (៣) កាម (kāma) (ចំណង់) (POU, 1983)។
- ទ្រឹស្ដីព្រះពុទ្ធសាសនាថេរវាទ (១) កម្មផល (karma) (២) ព្រះធម៌ (dharma) របស់ព្រះសម្មាសម្ពុទ្ធដែលទូន្មានកូនចៅ ឱ្យប្រព្រឹត្តតែបុណ្យកុសល សុំសីល និងដាក់ទាន។

១. ច្បាប់ទូន្មានខ្លួន៖ កវីនិពន្ធបុរាណខ្មែរដាស់តឿនក្រើនរំឭកយុវកុល-

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បុត្តកុលធីតា ឱ្យកាន់កិរិយាមារយាទល្អ កុំសេពគប់នឹងមនុស្សអាក្រក់ខូច គាប់ត្រូវមានការពិចារណាជាមុនឱ្យដិតដល់សិន សឹមធ្វើ និងប្រព្រឹត្ត។ អ្នកនិពន្ធទូន្មានឱ្យកូនចៅប្រព្រឹត្តល្អតាមផ្លូវធម៌ យកធម៌ព្រះពុទ្ធធ្វើជាគោល សម្រាប់ប្រកបការងារចិញ្ចឹមជីវិតផង សម្រាប់សាងសេចក្ដីល្អក្នុងជីវភាពក្នុងសង្គមនិងសម្រាប់ធ្វើដំណើរទៅកាន់បរលោកដោយសុខសាន្ត ដោយបន្សល់នូវកេរ្តិ៍ឈ្មោះពីរោះល្អក្នុងចិត្តគំនិតមនុស្ស ក្នុងសង្គមមនុស្សតាមទ្រឹស្ដីព្រះសម្មាសម្ពុទ្ធជាម្ចាស់។ អ្នកដែលធ្វើល្អនឹងបានល្អ ចំណែកអ្នកដែលធ្វើអាក្រក់នឹងបានផលអាក្រក់តាមទ្រឹស្ដីកម្មផល។

២.ច្បាប់ពាក្យចាស់៖ កវីនិពន្ធបុរាណខ្មែររំឭកដាស់តឿនកូនចៅថា បើធ្វើអ្វីត្រូវគិតដល់អ្នកដទៃ ត្រូវយកអ្នកដទៃមកថ្លឹងប្រមាណនឹងខ្លួន ត្រូវស្គាល់កំហុសខ្លួនឯង ត្រូវថ្លឹងគិតនូវហេតុការណ៍គ្រប់យ៉ាងជានិច្ច និងត្រូវមានការប្រុងប្រយ័ត្នចំពោះកិច្ចការគ្រប់យ៉ាងទាំងអស់ដែលខ្លួនត្រូវធ្វើ ត្រូវនិយាយ ឬត្រូវប្រព្រឹត្ត។

៣.ច្បាប់វិធុរបណ្ឌិត៖ កវីនិពន្ធបុរាណខ្មែររំឭកដាស់តឿនតួអង្គព្រះរាជាឱ្យប្រឹងសិក្សារៀនសូត្រ យកវិជ្ជាសិល្បសាស្ត្រ ត្រូវដឹងសុខទុក្ខប្រជារាស្ត្រដែលនៅក្រោមព្រះរាជឱវាទ និងអាណាចក្ររបស់ព្រះអង្គ។ កវីនិពន្ធក៏បានដាស់តឿនមនុស្សទូទៅ ឱ្យមានគំនិតមារយាទ ប្រព្រឹត្ត ធ្វើខ្លួន ធ្វើការងារឱ្យល្អ ដោយមានការប្រុងប្រយ័ត្នជានិច្ច។

៤.ច្បាប់ប្រុស៖ កវីនិពន្ធបុរាណខ្មែរឱ្យដំបូន្មានសម្រាប់ប្រុសៗគ្រប់វ័យ ឱ្យចេះគួរសម និយាយដោយសម្ដីសមរម្យ មានសុជីវធម៌ក្នុងការពិសាម្ហូប និងចំណីអាហារ មានការប្រុងប្រយ័ត្នពេលយប់អធ្រាត្រ និងចេះថ្វាយព្រះរតនត្រ័យ និងទេវតារក្សាខ្លួន។ ពេលធ្វើដំណើរ មនុស្សប្រុសត្រូវមានមារយាទជានិច្ច។ ក្នុងការបំពេញការងារ មនុស្សប្រុសត្រូវឧស្សាហ៍ខ្មីឃ្មាតជានិច្ច ត្រូវប្រឹងធ្វើស្រែចម្ការ ដាំដំណាំផ្សេងៗសម្រាប់បរិភោគផង និងសម្រាប់លក់ដូរផង។ ក្នុងការចាយវាយ មនុស្សប្រុសត្រូវចាយដោយប្រុងប្រយ័ត្ន

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កុំធ្វូរពេកតែកុំតឹងពេក ត្រូវមើលធនធានខ្លួនផង ត្រូវធ្វើគ្រឿងប្រើប្រាស់ឱ្យមានគ្រប់មុខ។ មនុស្សប្រុសមិនត្រូវលេងល្បែង ស្រី ស្រា និងល្បែងភ្នាល់ព្រោះជាហេតុនាំឱ្យវិនាសទ្រព្យ។

ជារួមនៅក្នុង «ច្បាប់» ផ្សេងៗ អ្នកនិពន្ធដកស្រង់គំនិតពីពុទ្ធឱវាទ (ដំបូន្មានរបស់ព្រះពុទ្ធ) គំនិតនិងពាក្យសម្តីពីបុរាណ ព្រមទាំងការពិសោធផ្ទាល់យកមកប្រៀនប្រដៅ។ អត្ថបទច្បាប់ពត់ហាត់មនុស្សឱ្យមានចរិយាល្អដើម្បីរស់នៅសុខសាន្តក្នុងសង្គម អប់រំឱ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវ តាមគន្លងប្រពៃណីជាតិ ដែលជាកេរអរិយធម៌យូរអង្វែងហើយ អប់រំឱ្យមានប្រាជ្ញាវាងវៃ បង្កើនសណ្តាប់ធ្នាប់ល្អ រស់នៅតាមគន្លងច្បាប់គ្រប់គ្រងប្រទេស ពោលគឺជាមធ្យោបាយជួយ ដោះស្រាយបញ្ហាក្នុងសង្គម និងរៀបចំគ្រួសារ ឬសង្គមជាតិឱ្យសុខក្សេមក្សាន្ត។

ទី៥-«កម្រងច្បាប់ខ្មែរពីបូរាណ» (Les codes cambodgiens) គឺជាព្រះរាជកេរមរតកវប្បធម៌ នីតិសាស្ត្រ ធម្មសាស្ត្រ និងយុត្តិធម៌របស់អតីតព្រះមហាក្សត្រខ្មែរ ដែលផ្តួចផ្តើមដោយព្រះបាទជ័យជេដ្ឋាទី១ ពិនិត្យឡើងវិញដោយព្រះបាទជ័យជេដ្ឋាទី២ (១៦១៨-១៦២៥) និងដោយព្រះបាទអង្គសួរជ័យជេស្តា (១៦៧៥-១៧០៦) នៅស.វ.ទី១៧ និងបន្ទាប់មកត្រូវបានកែលម្អឡើងវិញដោយព្រះបាទអង្គឌួង (១៨៤៧-១៨៦០) ចាប់ពីឆ្នាំ១៨៥៣ តាមគំរូឯកសារដើម និងត្រូវបានព្រះបាទនរោត្តមត្រាស់បង្គាប់ឱ្យបង្កើយការងារត្រួតពិនិត្យដើម្បីបោះពុម្ពផ្សាយ មុនពេលដែលប្រព័ន្ធច្បាប់និងយុត្តិធម៌ខ្មែរបានទទួលរងឥទ្ធិពលពីប្រព័ន្ធច្បាប់និងយុត្តិធម៌បារាំង។ ថ្មីៗនេះក្រុមការងារស្រាវជ្រាវ និងចងក្រងបោះពុម្ពច្បាប់ខ្មែរពីបុរាណនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដឹកនាំដោយលោកសាស្ត្រាចារ្យ Olivier de BERNON និងបណ្ឌិតហ៊ែល ចំរើន បានបោះពុម្ពជាពីរភាគ ដែលមានច្បាប់ និងក្រមទាំងអស់ចំនួន៣០[2]។

[2] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៦) «កម្រងច្បាប់ខ្មែរពីបុរាណ» (Codes anciens du Cambodge. Corpus de 1891) ក្រុមប្រឹក្សានីតិកម្ម។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជំពូកទី៣

សម័យលង្វែកនៅសតវត្សទី១៦ យុគពណ្ណរាយ នៃភាសាខ្មែរកណ្តាល

៣.១. ទិដ្ឋភាពប្រវត្តិសាស្ត្រនៅសតវត្សទី១៦

៣.១.១.ប្រភពនៃការសិក្សាប្រវត្តិសាស្ត្រខ្មែរសម័យកណ្តាល

ប្រភពនៃប្រវត្តិសាស្ត្រកម្ពុជាសម័យក្រោយអង្គរ គឺព្រះរាជពង្សាវតារនៃកម្ពុជាដែលមានចំនួនសរុបជាង៤០ (KHIN SOK, 1988, 1991; MAK PHOEUN, 1995)។ *ព្រះរាជពង្សាវតារដែលចាស់ជាងគេ គឺព្រះរាជពង្សាវតារព្រះអង្គអេង ដែលព្រះអង្គថ្វាយស្តេចសៀមក្នុងឆ្នាំ១៧៩៦ និងពង្សាវតារលង្វែកដែលសម្តេចព្រះអង្គកែវ ថ្វាយព្រះចៅសៀមនៅក្នុងឆ្នាំ១៨០៨ (បោះពុម្ពក្នុងឆ្នាំ១៩៦៩ជាភាសាថៃ ក្នុងប្រជុំពង្សាវតារ)។ ព្រះរាជពង្សាវតារនៃកម្ពុជាចាស់ជាងគេមួយទៀត គឺព្រះរាជពង្សាវតារនង ដែលសរសេរនៅក្នុងឆ្នាំ១៨១៨ ដោយព្រះឃ្លាំងនង កវីរាជបណ្ឌិតក្នុងរជ្ជកាលព្រះអង្គច័ន្ទ ដែលនិពន្ធរឿង «ភោគកុលកុមារ» នៅឆ្នាំ១៨០៤។*

ក្នុងរជ្ជកាលព្រះបាទនរោត្តម នៅពេលដែលព្រះអង្គចាកចេញពីរាជធានីឧដុង្គឆ្នាំ១៨៦៥ ដើម្បីមកគង់ប្រថាប់នៅព្រះបរមរាជវាំងនៅភ្នំពេញ ទ្រង់បានព្រះរាជបញ្ជាឱ្យតែងនិពន្ធ ព្រះរាជពង្សាវតារដែលនិពន្ធចប់នៅឆ្នាំ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៦៦៩។ ព្រះរាជពង្សាវតារនេះចាប់ផ្ដើមពីរជ្ជកាលព្រះនិព្វានបទដល់ចុង សតវត្សទី១៨។ នៅឆ្នាំ១៨៧៨ ព្រះអម្ចាស់«នុប្បារ័ត្ន» បុត្រព្រះបាទអង្គឌួង បាននិពន្ធព្រះរាជពង្សាវតារ ដោយចម្លងចេញពីពង្សាវតារ «នង» ហើយ បន្ថែមព្រឹត្តិការណ៍មួយចំនួនទៀត។ ព្រះរាជពង្សាវតារនេះចែកចេញជាពីរ ផ្នែក៖ ផ្នែករឿងនិទាន និងផ្នែកប្រវត្តិសាស្ត្រ។

ព្រះរាជពង្សាវតារដែលពេញលេញជាងគេគឺ ព្រះរាជពង្សាវតារដែល ជានិពន្ធដោយក្រុមជំនុំបង្កើតដោយព្រះបាទនរោត្តម ក្រោមព្រះរាជនិពន្ធ របស់សម្ដេចមហាសង្ឃរាជ និល ទៀង គណៈមហានិកាយ ព្រះសុគន្ធ បាន និងឧកញ៉ា សន្ធរវោហារ ម៉ុក។ អត្ថបទនៃព្រះរាជពង្សាវតារនេះត្រូវបានលោក ADHÉMAR LECLÈRE យកមកធ្វើជាមូលដ្ឋានសម្រាប់សរសេរសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជា» នៅឆ្នាំ១៩១២។

នៅឆ្នាំ១៩០៣ ព្រះបាទនរោត្តម ទ្រង់ព្រះរាជបញ្ជាឱ្យឧកញ៉ាវាំង ជួន បង្កើតក្រុមជំនុំដើម្បីនិពន្ធព្រះរាជពង្សាវតារថ្មី។ អត្ថបទពេញលេញនៃ «ព្រះ រាជពង្សាវតារក្រុងកម្ពុជាធិបតី» ត្រូវបានរៀបចំឡើងវិញនៅឆ្នាំ១៩២៩ និង បោះពុម្ពនៅឆ្នាំ១៩៣២។ ក្រៅពីនោះ នៅមានព្រះរាជពង្សាវតារផ្សេងទៀត ដូចជាពង្សាវតារ«វត្តកោកកាក» សរសេរនៅឆ្នាំ១៨៦៩ ពង្សាវតារ«វត្តសិត្បូ» សរសេរនៅឆ្នាំ១៨៧៨ និងពង្សាវតារ«វត្តទឹកវិល» សរសេរនៅឆ្នាំ១៩២១។ នៅដើមទសវត្សឆ្នាំ១៩៧០ លោក អេង សុត សមាជិកនៃគណៈកម្មការ ប្រវត្តិសាស្ត្រ និងវប្បធម៌បានបោះពុម្ពផ្សាយ «ឯកសារមហាបុរសខ្មែរ» ដោយ យកចេញពីសាស្ត្រានៃពង្សាវតារ «វត្តទឹកវិល»។

ពង្សាវតារភាគច្រើនចាប់ផ្ដើមពីរាជ្យព្រះបាទនិព្វានបទ ហើយដែល មានកាលបរិច្ឆេទមិនច្បាស់លាស់ដែលចាប់ផ្ដើមពីឆ្នាំ១៣៤០ ឬខ្លះពីឆ្នាំ ១៣២៦។ លោក VICKERY បានសិក្សាយ៉ាងលម្អិតពីកាលបរិច្ឆេទ និង ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃពង្សាវតារពីប្រភពផ្សេងៗ (VICKERY, 2002) ពោលគឺព្រឹត្តិការណ៍ប្រវត្តិសាស្ត្រកម្ពុជាមានភាពមិនច្បាស់លាស់ ដោយសារ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តែខ្មែរមិនបានចារសិលាចារឹក ឬសរសេរស្នាដៃប្រវត្តិសាស្ត្រទៀតឡើយ។ អ្នកប្រវត្តិសាស្ត្រនៅសតវត្សទី១៩ ត្រូវប្រឌិតរឿងមួយចំនួន ដើម្បីតែងនិពន្ធព្រះរាជពង្សាវតារកម្ពុជាដែលមានរឿងរ៉ាវ និងកាលបរិច្ឆេទខុសៗគ្នា។

សម័យក្រោយអង្គរគឺជាសម័យកាល ដែលខ្មែរចុះដុនដាបខាងផ្នែកសេដ្ឋកិច្ច ដោយសារអស្ថិរភាពនយោបាយ ដែលបង្កើតឡើងដោយសារទំនាស់ផ្ទៃក្នុងរាជវង្សខ្មែរ ជាពិសេសបញ្ហាស្នងរាជ្យសម្បត្តិ ការឃុបឃិតនិងទំនាស់រវាងមន្ត្រីជាន់ខ្ពស់ និងសង្គ្រាមជាមួយប្រទេសជិតខាង។ នៅសម័យក្រោយអង្គរ គេលែងប្រើពាក្យ វ្រ៉ះ ឬវ្រ៉ះ ដើម្បីសម្គាល់ព្រះនាមស្តេចហើយ។ ដើម្បីសម្គាល់ស្តេច គេប្រើពាក្យពញា ជំនួសវិញ។ លុះក្រោយមកទៀត គេឈប់ប្រើពាក្យពញា ហើយប្រើពាក្យ ស្រី និងអង្គ ដូចជា ស្រីរាជា និងអង្គឌួង ជំនួសវិញ ដើម្បីភ្ជាប់ទៅនឹងព្រះនាមស្តេច។ សម័យកាលក្រោយអង្គរ ចាប់ពីសតវត្សទី១៥ គឺជា «សម័យកាលកណ្តាល» នៃប្រវត្តិសាស្ត្រកម្ពុជា។ ថ្វីត្បិតតែសម័យក្រោយអង្គរកម្ពុជាជួបនឹងកលិយុគយ៉ាងខ្លាំងក្តាក៏ដោយអក្សរសាស្ត្រខ្មែរមានការរីកចម្រើនយ៉ាងខ្លាំង អត្ថបទអក្សរសិល្ប៍ជាច្រើនរឿង ដូចជារឿងរាមកេរ្តិ៍ ច្បាប់សុភាសិត គម្ពីរធម៌ និងរឿងល្បែងផ្សេងៗត្រូវបានសរសេរនៅក្នុងសម័យកណ្តាលនេះ។

៣.១.២. ការប្រកួតប្រជែងរវាងអាណាចក្រកម្ពុជា និងអយុធ្យា

ការធ្លាក់ចុះនៃកម្ពុជានៅសតវត្សទី១៣ និងទី១៤ ឆ្លុះបញ្ចាំងពីវដ្តទាំងបីនៃអារ្យធម៌៖ (១) ការអភិវឌ្ឍ (២) ភាពចាស់ទុំ និង (៣) ការធ្លាក់ចុះ (CHAPMAN, 2018)។ ការធ្លាក់ចុះនៃអារ្យធម៌នៅអាស៊ីអាគ្នេយ៍មានមូលហេតុផ្សេងៗ ដូចជាទំនាក់ទំនងពាណិជ្ជកម្មជាមួយចិន និងទ្វីបអឺរ៉ុប ដែលនាំឱ្យមានការផ្លាស់ប្តូររាជធានី ទៅកាន់កំពង់ផែទឹកជ្រៅមាត់សមុទ្រ ហើយដែលបង្កើតនូវមជ្ឈមណ្ឌលសេដ្ឋកិច្ច និងនយោបាយថ្មី និងអាចមកពីការប្រែប្រួលអាកាសធាតុផងដែរ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅសតវត្សទី១៤ និងទី១៥ យើងឃើញមានការប្រែប្រួលខាងផ្នែកភូមិសាស្ត្រនយោបាយក្នុងតំបន់ ជាពិសេសការផ្លាស់ប្តូរសាសនានៅក្នុងអាណាចក្រខ្មែរ ពីព្រហ្មញ្ញសាសនា ទៅព្រះពុទ្ធសាសនាបានធ្វើឱ្យមានអស្ថិរភាពនយោបាយ និងមានការហូរចេញនៃបញ្ញវន្តព្រាហ្មណ៍និយមពីកម្ពុជា។ ចំណុចស្នូលនៃស្ថានភាពនយោបាយក្នុងតំបន់ គឺការប្រកួតប្រជែងរវាងក្រុងកម្ពុជា និងអយុធ្យា ក្នុងការត្រួតត្រាច្រកទៅកាន់ពាណិជ្ជកម្មអន្តរជាតិ (VICKERY, 1977)។

សតវត្សទី១៥ គឺជាសតវត្សនៃការងើបឡើងនៃអយុធ្យា តែអាណាចក្រខ្មែរនៅមានតួនាទីគ្របដណ្តប់ខាងផ្នែកនយោបាយ និងពាណិជ្ជកម្មនៅអាស៊ីអាគ្នេយ៍។ អយុធ្យាបានខិតខំពង្រីកឥទ្ធិពលរបស់ខ្លួន ដោយពង្រឹងអំណាចនយោបាយ តាមដងទន្លេចៅប្រាយ៉ា ដោយវាយយកសុខោទ័យ និងប្រមូលផ្តុំរដ្ឋតូចៗផ្សេងទៀត ក្នុងគោលដៅប្រែក្លាយខ្លួនទៅជាមហាអំណាចក្នុងតំបន់ (RUNGSWASDISAB, 1995) តាមរយៈការអនុវត្តនយោបាយវាតទីនិយម និងការបន្តធ្វើសង្គ្រាមជាមួយអាណាចក្រខ្មែរ ដើម្បីពង្រីកដែនដី។ នៅពេលនោះ អយុធ្យាមានទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសចិន ជប៉ុន និងអឺរ៉ុបរួចទៅហើយ ។

សតវត្សទី១៦ គឺជាសតវត្សនៃសង្គ្រាមរវាងក្រុងកម្ពុជា និងអយុធ្យា ក្នុងគោលដៅពង្រឹងអំណាចនយោបាយ និងតួនាទីតំបន់ ក្នុងពាណិជ្ជកម្មអន្តរជាតិ។ ទន្ទឹមនឹងសង្គ្រាមបង្ហូរឈាមរវាងភូមា និងអយុធ្យា ប្រទេសសៀមបានវាយចូលក្រុងកម្ពុជាជាច្រើនលើកច្រើនសារ ហើយក្រុងកម្ពុជាបានវាយចូលអយុធ្យាចំនួន៦ដង ចន្លោះពីឆ្នាំ១៥៧០ និងឆ្នាំ១៥៨៧ (RUNGSWASDISAB, 1995)។ ក៏ប៉ុន្តែអន្តរាគមន៍យោធាពីរលើក ដែលដឹកនាំដោយព្រះចៅនរេន្ទសួរ នៅចុងសតវត្សទី១៦ បានកម្ទេចរាជធានីលង្វែក និងបញ្ចប់នូវតួនាទីរបស់ក្រុងកម្ពុជាក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយចាប់ពីពេលនោះមក ក្រុងកម្ពុជាជួបប្រទះតែនឹងវិបត្តិរីករគ្មានពេលស្បើយ ដែលបន្ត

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឡើង ដោយសារតែការប្រទាញប្រទង់រវាងក្រុងអយុធ្យា និងក្រុងហ្វេ ដើម្បីគាបសង្កត់ និងពង្រឹងឥទ្ធិពលលើក្រុងកម្ពុជា។

៣.១.៣. អាណាចក្រខ្មែរក្រោយការចាកចោលអង្គរ

ប្រវត្តិសាស្ត្រខ្មែរសម័យក្រោយអង្គរ អាចចែកចេញជាពីរដំណាក់កាលធំៗ(Khin Sok 1991)៖

(១) ដំណាក់កាលទី១៖ ដំណាក់កាល ចតុមុខ-លង្វែក ពីឆ្នាំ១៤៣១ ដល់ ១៥៩៥ និង

(២) ដំណាក់កាលទី២៖ ដំណាក់កាលឧដុង្គ ពីឆ្នាំ១៥៩៦ ដល់១៨៦៣។

ចាប់ពីឆ្នាំ១៤៣១ ដល់១៥៩៥ គឺជាដំណាក់កាលចតុមុខ-លង្វែក។ ក្នុងរយៈពេលជាង១៥០ឆ្នាំក្រោយការចាកចោលអង្គរ ខ្មែរនៅរក្សាបានទួរតួនាទីសំខាន់នៅជ្រោយឥណ្ឌូចិន និងនៅអាស៊ីអាគ្នេយ៍នៅឡើយ។ នៅសម័យចតុមុខ កម្ពុជាត្រូវបានបែងចែកជាបីម្ដង និងជាពីរម្ដង។ បន្ទាប់មករាជធានីត្រូវបានលើកទៅលង្វែក។ នៅក្នុងសម័យលង្វែក ខ្មែរបានខិតខំប្រឹងប្រែងពង្រឹងខ្លួនឡើងវិញ តាមរយៈការកសាងរដ្ឋ និងការជួសជុលប្រាសាទអង្គរ។ នៅក្នុងដំណាក់កាលនេះ ស្ដេចបីអង្គគឺ ស្រីរាជា, បរមរាជា, និងអង្គច័ន្ទ បានខិតខំពង្រឹងសន្តិភាព និងស្ថិរភាព ដោយធ្វើការទប់ទល់ជាមួយប្រទេសសៀម។ តែការបែកបាក់ក្នុងរាជវង្សបានធ្វើឱ្យខ្មែរបាត់បង់នូវភាពធន់ចំពោះការគំរាមកំហែងពីខាងក្រៅ។ បន្ទាប់ពីចាញ់សង្គ្រាមជាមួយសៀមហើយកម្ពុជាងើបលែងរួចតែម្ដង។

រជ្ជកាលព្រះបាទពញាយ៉ាត (គ.ស.១៤៣១-១៤៦៣) ត្រូវទឹងការសោយរាជ្យនៃស្ដេចសៀម ព្រះបាទបរម្មារាជាទី២ (១៤២៤-១៤៤៨)។ បន្ទាប់ពីសៀមវាយយកបាន និងកាន់កាប់អង្គរ នៅចន្លោះឆ្នាំ១៤៣១-១៤៤៥ (តាមប្រកពពង្សាវតារអយុធ្យា តែឯកសារខ្លះថាឆ្នាំ១៤៣៣) មួយឆ្នាំបន្ទាប់មកព្រះបាទពញាយ៉ាត ផ្លាស់ប្ដូររាជធានីពីអង្គរមកទួលបាសាន សៀមបានកាន់កាប់អង្គរអស់រយៈពេល១៥ឆ្នាំ ហូតដល់ព្រះបាទពញាយ៉ាត ច្បាំងរំដោះ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អង្គរពីអយុធ្យាបានវិញ។ លោក VICKERY បានលើកឡើងនូវសម្មតិកម្មថា មូលហេតុនៃសង្គ្រាមនេះ គឺការដណ្តើមត្រួតត្រារាជធានីអង្គរដ៏អស្ចារ្យ និង ការដណ្តើមត្រួតត្រាកំពង់ផែតាមឈូងសមុទ្រថៃ ព្រោះទាំងអយុធ្យា និងកម្ពុជា កំពុងធ្វើការអភិវឌ្ឍពាណិជ្ជកម្មជាមួយចិន (VICKERY, 2002)។ កំណត់ហេតុ ចិនបង្ហាញថា នៅដើមសតវត្សទី១៥ កម្ពុជាចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើ ទំនាក់ទំនងជាមួយចិន ហើយបានបញ្ជូនបេសកកម្មការទូតទៅកាន់ប្រទេស ចិននៅឆ្នាំ១៤២៦-៣៥។ មានការសន្និដ្ឋានមួយទៀត គឺការជ្រើសរើសភ្នំពេញ ជារាជធានីថ្មី គឺដោយសារតែតួនាទីនៃទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ តាមផ្លូវសមុទ្របានកើនឡើង។

នៅសតវត្សទី១៦ អយុធ្យា គឺជារដ្ឋនៅមិនទាន់រឹងមាំនៅឡើយ។ ដោយសារកង្វះខាតឯកសារជាលាយល័ក្ខអក្សរ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅ សម័យមុនរជ្ជកាលព្រះបាទអង្គច័ន្ទ (១៥២៦-១៥៦៦) នៅក្នុងពង្សាវតារ មានភាពមិនច្បាស់លាស់។ លោក VICKERY ថែមទាំងលើកសម្មតិកម្មថា សង្គ្រាមនៅក្នុងកំណត់ហេតុពង្សាវតារអយុធ្យានៅសតវត្សទី១៤-១៥ មិន មែនជាសង្គ្រាមរវាងសៀមជាមួយខ្មែរទេ ក៏ប៉ុន្តែ គឺជាសង្គ្រាមរវាងខ្មែរពីរក្រុម ដែលមួយស្ថិតនៅអយុធ្យា និងមួយនៅអង្គរ។

បន្ទាប់ពីចាកចេញពីអង្គរ ព្រះបាទពញាយ៉ាត ផ្លាស់ប្តូររាជធានីពីអង្គរ មកទួលបាសាន។ ប៉ុន្តែដោយមានទឹកជំនន់ធំ ព្រះអង្គក៏រើរាជធានីពីទីនោះមក នៅចតុមុខវិញនៅឆ្នាំ១៤៣៤។ លុះសម្រេចការកសាងហើយ ព្រះរាជាទ្រង់ តាំងប្រទាននាមព្រះរាជធានីថ្មីនេះថា ជាក្រុងចតុមុខមង្គលសកលកម្ពុជា-ធិបតីខត្តិយាមហានគរ។ ឯទីប្រជុំទន្លេទាំង៤ ដែលស្ថិតនៅមុខរាជធានីនេះ ក៏ ទ្រង់បានប្រសិទ្ធិនាមថ្មីថា ទន្លេចតុមុខ។ ចតុមុខស្ថិតនៅជារាជធានីនៃព្រះ រាជាណាចក្រកម្ពុជាធិបតីអស់រយៈពេល៣០ឆ្នាំ រហូតដល់ចុងស.វ.ទី១៥។ ព្រះបាទពញាយ៉ាត មានបុត្របីព្រះអង្គ៖ (១) ព្រះបាទនរាយរាជា (២) ស្រីរាជា និង (៣) ធម្មរាជា (ជាមួយព្រះស្នំឯកសៀមអ្នកម្នាងស៊ីសាដាម)។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣.១.៤.សង្គ្រាមដណ្តើមរាជ្យលើកដំបូងនិងការបែកបាក់កម្ពុជាជាអាណាចក្រពីរ

នៅឆ្នាំ១៦៦៣ ព្រះបាទពញាយ៉ាត បានបង្វែររាជ្យសម្បត្តិទៅព្រះរាជបុត្រច្បងរបស់ព្រះអង្គ ព្រះនាមនរាយរាជា (១៦៦៣-១៦៦៧)។ ក្នុងឆ្នាំ១៦៦៦ព្រះបាទពញាយ៉ាតសោយទិវង្គតទៅក្នុងជន្មាយុជាង៧០ព្រះវស្សា ដោយព្រះបរមអដ្ឋិធាតុរបស់ព្រះអង្គត្រូវបានបញ្ចុះនៅក្នុងចេតិយនៅចង្កេះវត្តភ្នំ។ បន្ទាប់ពីរជ្ជកាលព្រះបាទនរាយរាជា ព្រះអនុជព្រះបាទស្រីរាជាឡើងសោយរាជ្យ (១៦៦៨ដល់១៦៨៥)។ នៅឆ្នាំ១៦៧៥ ព្រះអង្គបានប្រកាសធ្វើចម្បាំងរំដោះយកទឹកដីខ្មែរ ដែលសៀមយកក្នុងរជ្ជកាលព្រះរាជាមុនៗមកវិញ។ ទ្រង់បានដឹកនាំទ័ពដោយព្រះអង្គឯង ហើយចាត់តាំងព្រះស្រីសុរិយោទ័យជាក្មួយឱ្យប្រមូលកម្លាំងទ័ព និងស្បៀងសម្រាប់ឧបត្ថម្ភសមរភូមិមុខ រីឯព្រះធម្មរាជា ជាឧបរាជនៅគ្រប់គ្រងរាជធានីចតុមុខ។

នៅពេលនោះសង្គ្រាមដណ្តើមរាជ្យបានចាប់ផ្តើមឡើង ដែលបង្ហាញពីការចាប់ផ្តើមបែកបាក់ក្នុងរាជវង្សខ្មែរលើកដំបូង ហើយដែលបង្កើតឱ្យមានគំរូឡើងសោយរាជ្យដោយប្រើប្រាស់កម្លាំង។ នៅពេលដែលព្រះបាទស្រីរាជាជាប់ដៃប្រយុទ្ធនៅសមរភូមិ ព្រះអង្គម្ចាស់ ស្រីសុរិយោទ័យទី២ ដែលជាក្មួយ (បុត្រព្រះនរាយរាជា) មានគំនិតក្បត់ និងបានបង្កើតជាតំបន់អបគមន៍មួយដែលមានរាជធានីនៅស្រីសន្ធរ។ ព្រះបាទស្រីរាជាក៏លើកទ័ពមកវាយបណ្តេញទ័ពបះបោររំដោះអាណាខេត្តខាងជើង។ ដោយមានបំណងចង់សោយរាជ្យតែម្នាក់ឯង នៅឆ្នាំ១៦៨៥ព្រះធម្មរាជា បានលបលួចទាក់ទងជាសម្ងាត់ជាមួយស្តេចសៀម ដើម្បីស្នើសុំជំនួយកម្លាំងយោធា។ ស្តេចសៀមបានបញ្ជូនកម្លាំងទ័ពសៀមមកក្នុងកម្ពុជា ក្នុងន័យចូលមកសម្រុះសម្រួលព្រះរាជាខ្មែរទាំងបីអង្គដែលកំពុងទាស់គ្នា។

ចុងសតវត្សទី១៥ និងដើមសតវត្សទី១៦ គឺជាដំណាក់កាលអស្ថិរភាពនយោបាយ។ នៅក្នុងពាក់កណ្តាលទី២ នៃសតវត្សទី១៥ ដោយសារជម្លោះ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្ទៃក្នុងរាជវង្ស ទឹកដីកម្ពុជាត្រូវបានចែកជាបីផ្នែក៖ (១) អាណាចក្រខាងជើង មានរាជធានីនៅកំពង់សៀម គ្រប់គ្រងដោយព្រះបាទស្រីរាជា (ពីកំពង់សៀម ជើងព្រៃ និងស្ទឹងត្រង់នៅផ្នែកខាងកើតដល់រលាផ្អៀ ខេត្តពោធិ៍សាត់នៅផ្នែកខាងលិច និងដល់កំពង់ស្វាយ និងសុរិន្ទ និងព្រំដែនលាវនៅផ្នែកខាងជើង) (២) អាណាចក្រខាងកើត មានរាជធានីនៅស្រីសន្ធរ គ្រប់គ្រងដោយព្រះបាទស្រីសុរិយោទ័យទី២ ពីឆ្នាំ១៤៧៧ (ពីស្រីសន្ធរ ដល់សំបូណ៌ ត្បូងឃ្មុំ បាភ្នំ ដល់ខេត្តដូងណាយ) និង (៣) អាណាចក្រខាងត្បូង មានរាជធានីនៅចតុមុខ គ្រប់គ្រងដោយព្រះបាទធម្មរាជាពីឆ្នាំ១៤៧៨ (ពីចតុមុខ ដល់កំពង់សោម កំពត បាសាក់ ព្រះត្រពាំង និងក្រមួនសរហូតដល់មាត់សមុទ្រ។

បន្ទាប់ពីបែងចែកកម្ពុជាជាបីផ្នែក ក្នុងរយៈពេលជាង១០ឆ្នាំរួចមក ស្តេចទាំងបីអង្គចាប់ផ្តើមចរចា ដើម្បីបង្រួបបង្រួមប្រទេសឡើងវិញ។ ស្តេចទាំងបីអង្គបានលើកពហ៍ពល មកតាំងនៅឧដុង្គ ដើម្បីរួមពិភាក្សាបញ្ចប់សង្គ្រាមផ្ទៃក្នុងនេះ។ ក្នុងឱកាសបើកកិច្ចចរចាជាដំបូង ព្រះធម្មរាជាបានស្នើសុំឱ្យព្រះចៅសៀមធ្វើជាចៅក្រមផ្សះផ្សារទំនាស់ក្នុងព្រះរាជវង្សខ្មែរ។ ស្តេចសៀមក៏បានយល់ព្រមហើយសម្រេចយកព្រះបាទស្រីរាជា និងស្រីសុរិយោទ័យទៅគង់នៅឯក្រុងអយុធ្យា។ ព្រះបាទធម្មរាជា (បុត្រជាមួយស្នំឯកសៀម) ត្រូវបានស្តេចសៀមរៀបចំអភិសេកជាព្រះមហាក្សត្រក្រុងកម្ពុជា ក្នុងឆ្នាំ១៤៨៦ នៅរាជធានីចតុមុខ។ ក្រោយពីបានជួយធ្វើអន្តរាគមន៍ផ្សះផ្សារទំនាស់ក្នុងរាជវង្សខ្មែរមក ស្តេចសៀមបានទាមទារយកខេត្ត ដែលព្រះបាទស្រីរាជាទើបរំដោះបាននោះទៅវិញទាំងអស់។

៣.១.៥. ការបែកបាក់កម្ពុជាជាអាណាចក្រពីរម្តងទៀត

ព្រះបាទធម្មរាជា មានបុត្រពីរព្រះអង្គ គឺព្រះបាទស្រីសុគន្ធបទ និងចៅពញាចន្ទរាជា។ នៅពេលព្រះរាជបុត្រច្បងព្រះបាទស្រីសុគន្ធបទឡើងគ្រងរាជ្យ (គ.ស.១៥០៤-១៥១២) ព្រះអង្គទ្រង់តាំងកូនស្រីចៅហ្វាយស្រុក

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បាសានឈ្មោះពិជ័យនាគ ជាព្រះស្នំឯកឈ្មោះអ្នកព្រះម្នាងកេសរបុប្ផា។ ព្រះអង្គតែងតាំងប្អូនប្រុសព្រះស្នំឯកនាយកន ដែលមានចំណេះវិជ្ជា ប្រាជ្ញា ខ្លាំងពូកែ ជាមហាតលិក ហើយក្រោយមក ជាយុទលួងព្រះស្តេចត្រួតលើពលព្រះរតនត្រៃទាំងអស់។ នៅគ.ស.១៥០៧ ព្រះបាទស្រីសុគន្ធបទ ទ្រង់តាំងព្រះអនុជចៅពញាចន្ទរាជា ជាមហាឧបរាជ ទៅគង់នៅក្នុងក្រុងចតុមុខ ដើម្បីគ្រប់គ្រងខេត្តនៅត្រើយខាងលិចឱ្យបានក្សេមក្សាន្ត។

នៅគ.ស.១៥០៩ព្រះបាទស្រីសុគន្ធបទទ្រង់ព្រះសុបិននិមិត្តឃើញនាគមួយធំមានឫទ្ធិមហិមា មកដេញព្រះអង្គចេញពីព្រះរាជវាំង ហើយព្រួសភ្លើងឆេះអស់ព្រះនគរ។ ហោរាទាយទៅចំលើនាយកន ដែលកើតឆ្នាំរោង។ ស្តេចភ័យក៏រៀបចំឧបាយកលក្លែងទៅបង់សំណាញ់ ហើយក្លែងធ្វើជាសំណាញ់ជាប់គល់ រួចហើយបង្គាប់ឱ្យកនមុជចុះទៅដោះ រួចសម្លាប់ចោល។ ព្រះស្នំឯកលបស្តាប់ឮ ក៏លួចប្រាប់ប្អូន។ ដោយដឹងឧបាយកលមុន កនបានគេចរួចផុតពីសេចក្តីស្លាប់ ហើយរត់ទៅប្រមូលទ័ពក្នុងខេត្តនៅត្រើយខាងកើត ក្នុងគោលដៅសងសឹកវិញ។

នាយកន ប្រើល្បិចបញ្ឆោតចៅហ្វាយខេត្តនានាថា ព្រះបាទស្រីសុគន្ធបទបញ្ជាឱ្យកេណ្ឌទ័ពទៅកម្ចាត់មហាឧបរាជ ច័ន្ទរាជា ដែលក្បត់ហើយមានបំណងឡើងសោយរាជ្យនៅក្រុងចតុមុខ។ ព្រះច័ន្ទរាជា ភ័យខ្លួនក៏រត់ទៅគង់ប្រថាប់នៅប្រទេសសៀម។ នាយកន ប្រមូលបានកងទ័ពវាយលុកយកខេត្តជុំវិញរាជធានីទួលបាសាន។ ព្រះបាទស្រីសុគន្ធបទ ក៏ដកថយទៅតាំងទីនៅស្ទឹងសែន ហើយនាយកនដេញតាមដល់ក្អំសន្ទុក។ ព្រះបាទស្រីសុគន្ធបទ ត្រូវពួកបះបោរធ្វើគុតនៅបន្ទាយស្ទឹងសែន ក្នុងឆ្នាំ១៥១២។ បន្ទាប់មកនាយកនបានប្រកាសខ្លួនជាស្តេចកន ដោយមានរាជនាមថា ស្រីជេដ្ឋាធិរាជរាមាធិបតី លើករាជធានីទៅតាំងទីនៅភូមស្រឡប់ ខេត្តត្បូងឃ្មុំ ហើយបានបោះប្រាក់ស្លឹងប្រើប្រាស់ដោយមានរូបនាគជាសញ្ញា។

ក្នុងឆ្នាំ១៥១៦ ព្រះច័ន្ទរាជា ត្រឡប់ពីសៀមចូលមកកម្ពុជាវិញ ហើយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កេណ្ឌទ័ពវាយដណ្ដើមបានខេត្តបាត់ដំបង ពោធិ៍សាត់កំពង់ស្វាយ និងខេត្តទាំងអស់ដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ។ ព្រះអង្គច័ន្ទ មានការគាំទ្រយ៉ាងប្លូរផ្ដាច់ពីគ្រួសារតាពេជ្រ (ឃ្លាំងមឿង) ដែលបានធ្វើពលិកម្មបូជាជីវិតដើម្បីរំដោះទឹកដី។ នៅឆ្នាំ១៥១៩ ស្ដេចកន បានលើកទ័ពមកវាយខេត្តកំពង់សៀម តែមិនបានសម្រេច។ ស្ដេចទាំងពីរក៏សម្រេចចិត្តបែកកម្ពុជាជាពីរ ដើម្បីគ្រប់គ្រង ក្នុងរយៈពេល៦ឆ្នាំ ពីឆ្នាំ១៥១៩ ដល់១៥២៥។ ទឹកដីកម្ពុជាត្រូវបានបែកជាពីផ្នែក៖ មួយផ្នែកគ្រប់គ្រងដោយស្ដេចកន និងមួយផ្នែកទៀតគ្រប់គ្រងដោយព្រះបាទច័ន្ទរាជា (១៥១៦-១៥២៥)។ នៅក្នុងឆ្នាំ១៥២៥ ព្រះច័ន្ទរាជាលើកទ័ពទៅវាយលុកក្រុងស្រឡប់ទទួលបានជោគជ័យ ហើយចាប់ និងសម្លាប់ស្ដេចកនតែម្ដង។

៣.១.៦. ការពង្រឹងឥទ្ធិពលកម្ពុជានៅក្នុងសម័យលង្វែក

នៅឆ្នាំ១៥២៩ ព្រះបាទអង្គច័ន្ទរាជា បានលើករាជធានីទៅលង្វែក។ សម័យលង្វែកមានព្រះមហាក្សត្រសំខាន់ៗបីអង្គគ្រងរាជ្យ គឺ៖ (១) ព្រះបាទអង្គច័ន្ទរាជា (១៥២៩-១៥៦៦) និង (២) ព្រះបាទបរមរាជា (១៥៦៦-១៥៧៦) ជាបុត្ររបស់ព្រះអង្គ ដែលធ្វើឱ្យកម្ពុជារឹងមាំឡើងវិញ និង (៣) ព្រះបាទជ័យជេដ្ឋាទី១ ឬសត្ថាទី១ (១៥៧៦-១៥៨៦) ដែលជាបុត្រាទី២របស់ព្រះបរមរាជា និងជាចៅរបស់ព្រះបាទអង្គច័ន្ទរាជា ដែលធ្វើឱ្យលង្វែកបែកបាក់។

សម័យលង្វែក ក្នុងសតវត្សទី១៦ គឺជាសម័យកាលមួយ ដែលខ្មែរនៅមានឥទ្ធិពលនៅឡើយនៅលើជ្រោយឥណ្ឌូចិន ហើយដែលខ្មែរបានខិតខំប្រឹងប្រែងងើបឡើងវិញបន្ទាប់ពីចាកចោលអង្គរ។ លង្វែកស្ថិតនៅក្នុងស្រុកកំពង់ត្រឡាច ខេត្រកំពង់ឆ្នាំង និងជាកន្លែងយុទ្ធសាស្ត្រមួយមានទន្លេ បឹង ជាពិសេសព្រៃក។ ព្រះច័ន្ទរាជាបញ្ជាឱ្យមន្ត្រីឧកញ៉ាសេនាបតីឱ្យកេណ្ឌរាស្ត្រកាប់ឈើ ជញ្ជូនថ្ម រែកដី ដើម្បីសង់បន្ទាយ និងរាជវាំង ដែលមានកំពែងការពារ៥ជាន់ព្រមទាំងដាំរបងឫស្សីយ៉ាងក្រាស់មានគូទឹក មានទ្វារ៨ខាងក្នុងបន្ទាយទាំង៥ជាន់ ដាក់សុទ្ធតែទាហានកាំភ្លើងវែង។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងរាជ្យព្រះបាទអង្គច័ន្ទរាជា ឬបរមរាជាទី២ ស្ថានភាពភូមិសាស្ត្រនយោបាយតំបន់មានភាពអំណោយផលដល់កម្ពុជា ដោយសារនៅដើមសតវត្សទី១៦សន្តតិវង្សតោងហ៊ូ(១៥១០-១៧៥២) នៅភូមាបានបង្រួបបង្រួមប្រទេស ហើយបង្កើតនូវអាណាចក្រដ៏ធំមួយនៅអាស៊ីអាគ្នេយ៍។ ស្តេចតបិនស្វេហតិ បានពង្រីកឥទ្ធិពលខ្លួនដល់បាហ្កាន់នៅឆ្នាំ១៥៤៤។ ការងើបឡើង នៃភូមាបានដាក់សម្ពាធយ៉ាងខ្លាំងក្លាលើអយុធ្យា ដែលជារដ្ឋមួយនៅមិនទាន់រឹងមាំនៅឡើយនៅពេលនោះ ទាំងខាងផ្នែកយោធា សេដ្ឋកិច្ចនិងវប្បធម៌។ ដូចនេះ ភូមិសាស្ត្រនយោបាយនៅក្នុងពេលនោះ គឺការប្រកួតប្រជែងរវាងរដ្ឋចំនួនបីគឺៈ កម្ពុជា ភូមា និងសៀម ដើម្បីក្លាយជារដ្ឋឈានមុខក្នុងអនុតំបន់។ សៀមនៅមិនទាន់មានអំណាចកណ្តាលមាំ ដោយសារមានស្តេចត្រាញ់ចំណុះច្រើន។

ព្រះបាទអង្គច័ន្ទ បានថែរក្សាទឹកដីកម្ពុជានៅគង់វង្ស។ ដោយសារព្រះអង្គមិនព្រមបញ្ជូនសួយទៅថ្វាយស្តេចសៀម ដែលបានចាត់ទុកនគរខ្មែរជានគរចំណុះតាំងពីរាជ្យព្រះធម្មរាជាមក នៅឆ្នាំ១៥៣០ និងនៅឆ្នាំ១៥៤០ ព្រះចៅស្តេចសៀមបានលើកទ័ពមកលុកលុយខេត្តអង្គរ តែត្រូវទ័ពព្រះច័ន្ទរាជា វាយឱ្យបែកខ្ចាត់ខ្ចាយបរាជ័យនៅត្រង់ស្ទឹងអង្គរ ត្រង់ភូមិមួយដែលជាប់ឈ្មោះថា«សៀមរាប» ខេត្តសៀមរាបរហូតមកដល់សព្វថ្ងៃនេះ។

តាមប្រកពព្រះរាជពង្សាវតារអយុធ្យាបានឱ្យដឹងថា នៅឆ្នាំ១៥៤៧ ព្រះចៅសៀម ព្រះបាទជ័យរាជា បានចូលទិវង្គត ហើយព្រះរាជបុត្រព្រះអង្គព្រះនាមយ៉តហ្វា ដែលមានព្រះជន្ម១១ឆ្នាំឡើងស្នងរាជ្យ។ នៅឆ្នាំ១៥៤៨ នៅក្នុងវាំងស្តេចសៀមមានកើតការបះបោរជ្រែករាជ្យដោយ ឃុន វរវង្សា តែត្រូវពួកមន្ត្រីបង្ក្រាបបាន។ ពួកមន្ត្រីបានអញ្ជើញព្រះអង្គម្ចាស់ធានរាជា ដែលជារាជវង្សនៃព្រះបាទជ័យរាជា ដែរនោះឡើងសោយរាជ្យ ជាព្រះបាទចក្រក័ត (១៥៤៨-១៥៦៩) (Wyatt, 2006)។ ឆ្លៀតពេលនោះ ហង្សាវតី (ភូមា) បានលើកទ័ពមកវាយអយុធ្យានៅឆ្នាំ១៥៤៩ តែមិនបានសម្រេច ក៏ដកទ័ព

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចេញវិញទៅ។ ឱកាសដែលសៀមជាប់ដៃច្បាំងនឹងភូមានៅឆ្នាំ១៥៤៩ ព្រះបាទច័ន្ទរាជាទ្រង់បានដឹកនាំលើកទ័ពទៅវាយសៀមហើយរំដោះយកខេត្តច័ន្ទបុរី និងខេត្តផ្សេងទៀតនៅជិតនោះបានមកវិញ។ នៅឆ្នាំ១៥៥១ និងនៅឆ្នាំ១៥៥៦ សៀមបានលើកទ័ពមកវាយលង្វែកដើម្បីសងសឹកវិញ តែមិនបានសម្រេចឡើយ។

ព្រះចៅ បាយិនទូង ដែលឡើងសោយរាជ្យបន្ទាប់បានបន្តនយោបាយវាតទីនិយម ហើយវាយយករដ្ឋជាច្រើននៅភូមា រួមទាំងប្រទេសសៀមនៅឆ្នាំ ១៥៦៤ និងឆ្នាំ១៥៦៩ ផងដែរ។ កងទ័ពព្រះចៅបាយិនទូង របស់ហង្សាវតី (ភូមា) បានដឹកនាំកងទ័ពវាយលុកពិស្ណុលោក ក្នុងឆ្នាំ១៥៦៣-១៤៦៤។ ព្រះចៅពិស្ណុលោក ព្រះចៅធម្មារាជាធិរាជ្យបានចុះចាញ់ ដោយសារខ្វះស្បៀងនិងដោយសារការរាតត្បាតនៃជំងឺអុត។ ស្តេចបាយិនទូង បានដាក់ពិស្ណុលោក និងអយុធ្យាជារដ្ឋចំណុះ ហើយចាប់ព្រះរាជបុត្រ អង្គនរេទ្ធសូរជាឈ្លើយដើម្បីធានានូវការស្មោះត្រង់។ ក្រោយពីព្រះចៅបាយិនទូងចូលទិវង្គត នៅឆ្នាំ១៥៦១ ចក្រភពភូមាចាប់ផ្តើមបែកបាក់ ដោយសាររដ្ឋចំណុះទាមទារឯករាជ្យ។

នៅក្នុងសតវត្សទី១៥ និងទី១៦ ខ្មែរបានខិតខំប្រឹងប្រែងកសាងជាតិឡើងវិញ ក្នុងគ្រប់វិស័យ ជាពិសេសក្នុងការលើកកម្ពស់អក្សរសិល្ប៍ខ្មែរសម័យកណ្តាល។ អ្នកនិពន្ធខ្មែរបានតែងនិពន្ធរឿងរាមកេរ្តិ៍ ដោយប្រើប្រាស់ពាក្យពេចន៍នៃភាសាខ្មែរកណ្តាលនៅសម័យលង្វែក។ អត្ថបទសរសេរជាពាក្យកាព្យដ៏អស្ចារ្យនេះ មិនបានបញ្ជាក់ពីពេលវេលានៃការតែងនិពន្ធ និងឈ្មោះរបស់កវីនិពន្ធឡើយ។ រឿងរាមកេរ្តិ៍ គឺជាវណ្ណកម្មឯក ដែលឆ្លុះបញ្ចាំងនូវទេពកោសល្យនៃកវីនិពន្ធខ្មែរ ហើយដែលត្រូវបានចាត់ទុកជាវណ្ណកម្មអក្សរសិល្ប៍ព្រាហ្មណ៍និយម។

ការវិវត្តនៃអក្សរសិល្ប៍កំណាព្យខ្មែរឆ្លុះបញ្ចាំងពីការវិវត្តនៃអក្សរសាស្ត្រខ្មែរជារួម ពីការសរសេរជាភាសាបាលីសំស្ក្រឹត និងខ្មែរបុរាណ និងខ្មែរកណ្តាល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មកសរសេរជាភាសាខ្មែរក្នុងចុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០ ទាំងការវិវត្តខាងផ្នែកក្បួនវេយ្យាករណ៍ ការសរសេរពាក្យដ៏សម្បូណ៌បែបដែលអាចចាត់ទុកជាបេតិកភណ្ឌអរូបីនៃជាតិខ្មែរយើង ការតែងកំណាព្យជាបទដ៏ច្រើនសន្ធឹកសន្ធាប់ ដែលឆ្លុះបញ្ចាំងពីភាពរស់រវើក និងការចេះច្នៃប្រឌិតរបស់កវីនិពន្ធខ្មែរ។

ព្រះចន្ទរាជា មានបុត្រពីរអង្គគឺព្រះបុត្រា ព្រះបាទបរមរាជា ប្រសូតនៅឆ្នាំ១៥២០/១ និងព្រះអម្ចាស់ក្សត្រី ទេវីក្សត្រី ដែលដើរតួនាទីសំខាន់នៅចុងសតវត្សទី១៦ និងដើមសតវត្សទី១៧។ ព្រះបាទច័ន្ទរាជា គឺជាព្រះមហាក្សត្រដែលបានសោយរាជ្យយូរជាងគេ ក្នុងរយៈពេលកន្លះសតវត្ស។

ព្រះបាទបរមរាជាទី៣ (១៥៦៦-១៥៧៦) ដែលជាបុត្រច្បងរបស់ព្រះចន្ទរាជា ឡើងស្នងរាជ្យក្នុងព្រះជន្មាយុ៤៧វស្សា។ ព្រះអង្គបន្តធ្វើចម្បាំងជាមួយសៀម ដើម្បីដណ្ដើមយកអាណាខេត្ត ដែលសៀមធ្លាប់ដណ្ដើមយកទៅ។ ព្រះរាជពង្សាវតារអយុធ្យាបានកត់ត្រាពីសង្គ្រាមរវាងអយុធ្យា និងលង្វែកនៅក្នុងឆ្នាំ១៥៧០ និង១៥៧៥។ ក្រោយមកអយុធ្យា និងក្រុងកម្ពុជាបានចុះព្រះរាជសញ្ញាចងសម្ព័ន្ធមេត្រីភាពជាមួយគ្នា។

នៅឆ្នាំ១៥៧០ ព្រះបាទបរមរាជា បានយាងទៅគង់នៅរាជធានីអង្គរ ដើម្បីប្រមូលទ័ពទៅរំដោះយកខេត្រនគររាជសីមា ហើយដាក់មន្ត្រីខ្មែរឱ្យនៅត្រួតត្រាទីនោះ។ ដើម្បីទប់ទល់នឹងស្ដេចខ្មែរ ស្ដេចថៃ មហាចក្រក័ត សុំស្ដេចភូមា បាយិនទូង យាង នរេន្ទ្រសួរ ជាបុត្រត្រឡប់មកសៀមវិញនៅឆ្នាំ១៥៧១។ នៅឆ្នាំ១៥៧៤ ដោយទ័ពភូមា និងទ័ពខ្មែរវាយតាបសៀមខ្លាំងពេក ស្ដេចសៀមបង្ខំចិត្តចុះសន្ធិសញ្ញាចងស្ពានមេត្រីជាមួយខ្មែរ ហើយព្រមប្រគល់ខេត្រនគររាជសីមា ខេត្តចន្ទបុរី និងខេត្តបស្ចិមបុរីឱ្យមហាក្សត្រខ្មែរវិញ។ នៅឆ្នាំ១៥៧៥ព្រះបាទបរមរាជា បានលើកទ័ពជើងទឹកមកវាយអយុធ្យាម្ដងទៀត (Wyatt, 2006)។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣.១.៧. ជម្លោះផ្ទៃក្នុង និងការបែកបាក់លង្វែក

ព្រះបាទបរមរាជាទី៣ ទ្រង់សោយរាជ្យបាន១១ឆ្នាំ និងមានបុត្រយ៉ាងហោចណាស់ ៣ព្រះអង្គ គឺ៖ ព្រះបាទសត្ថា ប្រសូតនៅឆ្នាំ១៥៥៣/៤, ព្រះបាទស្រីសុរិយោពណ៌ ប្រសូតនៅឆ្នាំ១៥៥៦/៧, និងចៅពញាអន ប្រសូតនៅឆ្នាំ១៥៦៥/៦។ ព្រះបាទបរមរាជា ទ្រង់ចូលទិវង្គតនៅគ.ស.១៥៧៦។ ព្រះបាទសត្ថាទី១ (១៥៧៦-១៥៨៦) ជាព្រះរាជបុត្រច្បងបានឡើងរាជភិសេកសោយរាជសម្បត្តិបន្ត ដោយមានព្រះបរមនាមព្រះបាទជ័យជេដ្ឋាធិរាជ ឯព្រះអនុជព្រះអង្គ ព្រះបាទស្រីសុរិយោពណ៌ ត្រូវបានអភិសេកជាមហាឧបរាជ។ សង្គ្រាមជាមួយសៀមបានកើតឡើងនៅឆ្នាំ១៥៧៨ និង១៥៨១។ នៅឆ្នាំ១៥៨១ ព្រះបាទសត្ថាបាននាំទ័ពទៅវាយយកខេត្តពេជ្របុរីពីអយុធ្យាបានវិញ។ នៅឆ្នាំនោះបុត្រព្រះចៅសៀមមហាធម្មរាជានរេន្ទ្រសូរ បានត្រឡប់ពីភូមាមកអយុធ្យាវិញ។ អយុធ្យាចាប់ផ្ដើមពង្រឹងបន្ទាយការពារ និងកសាងកងទ័ពឡើងវិញ។

ពង្សាវតារទាំងអស់ ទោះបីជាផ្ដល់នូវកាលបរិច្ឆេទខុសៗគ្នា តែសុទ្ធតែចែងថា ព្រះបាទសត្ថា មានយ៉ាងហោចណាស់បុត្រពីរអង្គ ជាមួយព្រះអគ្គមហេសី ព្រះភគវតី ត្រីចក្រពត្តិរាជ ហៅ ពៅ គឺព្រះបាទជ័យជេដ្ឋា ប្រសូតនៅឆ្នាំ១៥៧៤/៥, និងចៅពញាតន់ ប្រសូតនៅឆ្នាំ១៥៧៩/៨០។

នៅឆ្នាំ១៥៨៥ ភូមាបានវាយលុកចូលប្រទេសសៀមយ៉ាងខ្លាំង ពេលនោះស្ដេចសៀម មហាធម្មរាជា បានបញ្ជូនរាជទូតមកក្រុងកម្ពុជាដើម្បីសុំកងទ័ពជំនួយ តាមព្រះរាជសញ្ញាចងព្រះរាជមេត្រីភាព។ ព្រះបាទសត្ថាទី១ ក៏បញ្ជាឱ្យសម្ដេចព្រះស្រីសុរិយោពណ៌ កេណ្ឌទ័ពទៅជួយច្បាំងសៀមហូតទទួលបានជ័យជម្នះលើទ័ពភូមា ហើយបានបណ្ដេញទ័ពភូមាចេញពីទឹកដីសៀមទៀត។ នៅឆ្នាំ១៥៨៦ ព្រះអង្គនរេន្ទ្រសូរ វាយយកបានឈាងម៉ៃ ហើយប្រមូលបានទ័ព និងអាវុធយុទ្ធភណ្ឌជាច្រើន។ នៅពេលនោះ ព្រះអង្គធ្លាប់មានវិវាទជាមួយព្រះអង្គម្ចាស់នរេន្ទ្រសូរ ដែលជាមេបញ្ជាការទ័ពសៀម

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហើយបានត្រឡប់មកកម្ពុជាវិញ។ នៅឆ្នាំ១៥៨៦ ព្រះបាទនន្ទបាយិន បានលើកទ័ពមកវាយនិងហ៊ុមព័ទ្ធអយុធ្យាដោយផ្ទាល់ តែមិនបានជោគជ័យ។

ដោយសារតែព្រះបាទសត្ថាទី១ ភ័យនឹងព្រះអនុជខ្លួន គឺព្រះបាទស្រីសុរិយោពណ៌ ដែលជាស្តេចមានប្រាជ្ញាឈ្លាសវៃ និងមានប្រជាប្រិយភាព ហើយខ្លាចថាថ្ងៃក្រោយបុត្ររបស់ព្រះអង្គមិនអាចស្នងរាជបល្ល័ង្កបាន នៅឆ្នាំ១៥៨៦ ព្រះអង្គបានដាក់រាជសម្បត្តិថ្វាយទៅព្រះរាជបុត្រទាំងពីររបស់ព្រះអង្គ៖ ព្រះរាជបុត្រច្បងព្រះនាមជ័យជេដ្ឋាទី១ (១៥៨៦-១៥៩៣) ឡើងគ្រងរាជ្យសម្បត្តិ ក្នុងព្រះជន្មទើបតែ១១ព្រះវស្សា និងព្រះរាជបុត្រទី២ ព្រះនាមពញាតន់ មានព្រះជន្ម៦ព្រះវស្សា ជាមហាឧបរាជ ហើយសម្តេចព្រះស្រីសុរិយោពណ៌ ជាមហាឧកយោរាជ។

ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី១ប្រទេសជាតិចុះទន់ខ្សោយយ៉ាងខ្លាំង ដែលបណ្តាលមកពីវិបត្តិរាជវង្សានុវង្ស មន្ត្រីសេនាបតី និងប្រជារាស្ត្រគ្មានជំនឿនឹងគោរពព្រះរាជាវ័យក្មេង គ្មានព្រះរាជតម្រិះបន្តិចសោះ ធ្វើឱ្យប្រទេសជិតខាង ជាពិសេសប្រទេសសៀមលើកទ័ពមកវាយលុកចូលប្រទេសខ្មែរជាច្រើនលើកច្រើនសារ។

នៅចុងសតវត្សទី១៦ ពួកអឺរ៉ុបចាប់ផ្តើមយកចិត្តទុកដាក់លើការបង្កើតទំនាក់ទំនងជាមួយអាស៊ី ជាពិសេស ដោយផ្តោតលើការផ្សព្វផ្សាយសាសនាគ្រិស្ត។ ព្រះចៅស្រីអយុធ្យា នរេសួរ បានទិញកាំភ្លើងពីពួកព័រទុយហ្គាល់ដើម្បីពង្រឹងកងទ័ពសៀម។ ដើម្បីពង្រឹងអំណាចរបស់ព្រះអង្គ ព្រះបាទសត្ថាបានអនុញ្ញាតឱ្យបព្វជិតព័រទុយហ្គាល់សាងសង់ព្រះវិហារគ្រប់ទីកន្លែង។ នៅឆ្នាំ១៥៨៩ ជនជាតិព័រទុយហ្គាល់មួយក្រុម ដឹកនាំដោយ Diogo Veloso បានមកដល់កម្ពុជា។ ព្រះបាទសត្ថាបានសព្វព្រះទ័យរៀបអភិសេកលោក ជាមួយប្អូនស្រីជីដូនមួយរបស់ព្រះអង្គ។ ជនជាតិអេស្ប៉ាញក៏បានមកដល់កម្ពុជាដែរ គឺ Ruiz de Hernan Gonzales ដែលព្រះមហាក្សត្រខ្មែរបានតែងតាំងជាអង្គរក្ស។ ជនជាតិបរទេសទាំងនេះបានជួយព្រះបាទសត្ថា ក្នុងការធ្វើសង្គ្រាមជាមួយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សៀម។

ក្រោយពីកម្ទេចកូមាហើយ សៀមបានរំលោភលើព្រះរាជសញ្ញាមេត្រីភាព ហើយលើកទ័ពមកវាយកម្ពុជាម្តង។ នៅឆ្នាំ១៥៨៨ សៀមវាយយកបានបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ រហូតដល់ស្រុកបរិបូរណ៍ ព្រមទាំងហ៊ុមព័ទ្ធបន្ទាយលង្វែកទៀតផង។ ទ័ពសៀមព័ទ្ធបន្ទាយលង្វែកអស់រយៈពេល៣ខែតែត្រូវបាក់ទ័ពរត់ខ្ចាត់ខ្ចាយទៅវិញ ដោយសារខ្វះស្បៀង និងកើតជំងឺផង។ ដើម្បីទប់ទល់ជាមួយសៀមព្រះបាទសត្ថា បានបញ្ជូនជនជាតិព័រទុយហ្គាល់ពីរនាក់ ឈ្មោះ វេឡូសូ (Diego Belloso) និង រុយប្លាស (Ruiz Blas) ទៅសុំជំនួយយោធាពីក្រៅប្រទេស ដោយសន្យាថានឹងទទួលយកគ្រិស្តសាសនា។

នៅឆ្នាំ១៥៩០ ព្រះបាទមហាធម្មរាជាធិរាជ ចូលទិវង្គត ហើយព្រះអង្គនរេន្ទ្រសូរ បានអភិសេកជាព្រះចៅក្រុងអយុធ្យាសាន់ភិតទី២។ ព្រះអង្គបានសហការជាមួយជនជាតិព័រទុយហ្គាល់ ដោយទិញកាំភ្លើងធំ កាំភ្លើងតូច និងគ្រាប់រំសេវ ដើម្បីពង្រឹងកងទ័ពសៀម ក្នុងការធ្វើសង្គ្រាមសឹកជាមួយប្រទេសជិតខាង។ នៅឆ្នាំ១៥៩២ កូមាបានលើកទ័ពមកវាយសៀមម្តងទៀត។ ព្រះចៅនរេន្ទ្រសូរ ប្រុងនឹងលើកទ័ពមកវាយលុកកម្ពុជា តែក៏បង្វែរទិសទៅទប់ទល់នឹងកូមាវិញ។ ព្រះចៅនរេន្ទ្រសូរ បានរំដោះអយុធ្យាពីការគ្រប់គ្រងរបស់កូមា និងបានរៀបចំប្រព័ន្ធនយោបាយ យុត្តិធម៌ និងយោធានៅអយុធ្យាឡើងវិញ។ ផ្ទុយទៅវិញ ក្រុងកម្ពុជាក្នុងរាជ្យព្រះបាទជ័យជេដ្ឋាទី១ បណ្តារាស្ត្រ រេហ៍ពល មានចិត្តប្រមាថថា សៀមរាងចាលលែងលើកទ័ពមកវាយកម្ពុជាទៀតហើយ។ ចំណែកឯព្រះរាជវង្សានុវង្សសេនាបតីក៏អន់ចិត្ត មិនយកចិត្តទុកដាក់នឹងកិច្ចការ ព្រះនគរ។

នៅឆ្នាំ១៥៩២ ស្តេចសៀម នរេន្ទ្រសូរ បានលើកទ័ពមកវាយខ្មែរជាលើកទីពីរ ដោយមានកងទ័ពច្រើនជាងមុន និងមានអាវុធទំនើបជាងមុនតាមជើងគោកផង និងតាមជើងទឹកផង។ ព្រះបាទសត្ថាទី១ និងព្រះបាទ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជ័យជេដ្ឋាទី១ ភៀសព្រះកាយពីលង្វែកទៅនៅដែនដីលាវ ហើយក៏សោយទិវង្គតនៅទីនោះទៅ។ សម្ដេចព្រះស្រីសុរិយោពណ៌ បាននាំទ័ពច្បាំងទប់ទល់និងទ័ពសៀម ដើម្បីការពារបន្ទាយលង្វែក។ បន្ទាប់ពីហ៊ុមព័ទ្ធបន្ទាយលង្វែកអស់ជាច្រើនខែមក សៀមចាប់បានសម្ដេចព្រះស្រីសុរិយោពណ៌ ព្រមទាំងព្រះរាជវង្សានុវង្ស។ ស្ដេចសៀមចាត់មន្ត្រីសៀម ជាមហាមន្ត្រីឱ្យគ្រប់គ្រងនៅឧដុង្គ ហើយនាំសម្ដេចព្រះស្រីសុរិយោពណ៌ ព្រះរាជបុត្ររបស់ព្រះអង្គទាំងពីរអង្គ និងព្រះរាជវង្សានុវង្ស មន្ត្រីអ្នកមុខអ្នកការ អ្នកប្រាជ្ញ ព្រមទាំងគម្ពីរក្បួនខ្នាត និងកៀរប្រជារាស្ត្រខ្មែរជាច្រើនយកទៅរស់នៅក្រុងអយុធ្យា។ នៅពេលនោះព្រះ ស្រីសុរិយោពណ៌ មានព្រះជន្មាយុ៤៩ព្រះវស្សា។

មូលហេតុនៃការបែកបន្ទាយលង្វែក៖ ការបែកបាក់លង្វែកកើតឡើងដោយសារមូលហេតុពីរយ៉ាង៖(១) ការមិនទុកចិត្តគ្នា និងការបែកបាក់ក្នុងជួរព្រះរាជវង្សានុវង្សនិង(២) ការគ្រប់គ្រងខ្សោយនិងសង្គ្រាមជាមួយសៀម។ ក្រោយពីបែកបន្ទាយលង្វែកមក ប្រទេសកម្ពុជាអស់ឫទ្ធានុភាព ហើយធ្លាក់ទៅជារដ្ឋទន់ខ្សោយមួយនៅតំបន់អាស៊ីអាគ្នេយ៍។ ពួកសៀមបានប្រមូលយកកេតនភណ្ឌជាតិ ទ្រព្យសម្បត្តិ គម្ពីរ ក្បួនខ្នាត និងឯកសារផ្សេងៗជាច្រើនយកទៅស្រុកសៀម។ អ្នកប្រាជ្ញ និងបណ្ឌិតជាច្រើនត្រូវភៀសខ្លួន និងត្រូវបានចាប់ជាឈ្លើយសឹកទៅនៅស្រុកសៀម។ ស្នាដៃអក្សរសិល្ប៍ក៏ធ្លាក់ចុះដែរ ដោយមិនមានអ្វីបន្សល់ទុកជាដុំកំភួន។ ម្យ៉ាងវិញទៀត ក្រាំង និងសាស្ត្រាស្លឹករឹតក៏វិនាសខ្ទេចខ្ទីដោយសារសង្គ្រាមផងដែរ មិនបានបន្សល់ទុកដល់ជនជំនាន់ក្រោយ។ សាស្ត្រាជំនាន់អង្គរជាច្រើនត្រូវបានបាត់បង់ផងដែរនៅក្នុងសង្គ្រាម ខ្លះទៀតត្រូវគេប្រមូលយកទៅទីក្រុងអយុធ្យា ហើយត្រូវភ្លើងឆេះអស់នៅពេលដែលភូមាដុតក្រុងអយុធ្យាក្នុងឆ្នាំ១៧៦៧។ នៅស.វ.ទី១៦ ខ្មែរបានខិតខំប្រឹងប្រែងកសាងប្រទេស ហើយស្នាដៃអក្សរសិល្ប៍ក៏ចាប់ផ្ដើមងើបឡើងវិញដែរ។ ដូច្នេះហើយទើបយើងមិនមានអក្សរសិល្ប៍អ្វីដែលនៅសេសសល់ពីដំណាក់កាលលង្វែកឡើយ។ ប្រទេសកម្ពុជាបានបាត់បង់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាណាខេត្រខាងលិច និងពាយព្យ ដូចជាខេត្រចន្ទបុរី បស្ចិមបុរី នគររាជសីមា។ល។ ប្រទេសជាតិធ្លាក់ទៅក្នុងភាពអនាធិបតេយ្យ ហើយគ្រោះទុរភិក្សបានចូលមកយាយីប្រជារាស្ត្រខ្មែរពេញផ្ទៃប្រទេស។

នៅឆ្នាំ១៥៩៥ ព្រះរាមាជើងព្រៃ បានកេណ្ឌទ័ពទៅវាយយកក្រុងលង្វែកពីទ័ពសៀម ដែលតាំងទីនៅលង្វែក ហើយដេញទ័ពសៀមទាល់តែផុតពីកម្ពុជា។ បន្ទាប់មក ព្រះរាមាជើងព្រៃ បានឡើងគ្រងរាជ្យសម្បត្តិនៅស្រីសន្ធរ។ បីឆ្នាំក្រោយមក ជនជាតិព័រទុយហ្គាល់ពីរនាក់ ឈ្មោះ ឌៀឡូសូ (Diego Belloso) និងរុយប្លាស (Ruiz Blas) ដែលធ្លាប់ជាមិត្តរបស់ព្រះសត្ថាត្រឡប់មកពីប្រទេសហ្វីលីពីន។ លុះដឹងថាក្រុងកម្ពុជាត្រូវសៀមវាយបែក ហើយព្រះរាមជើងព្រៃ បានជ្រែករាជ្យសម្បត្តិ ក៏បានចូលគាល់ព្រះអង្គដោយយកកាំភ្លើងទៅផង ហើយបាញ់សម្លាប់ព្រះបាទរាមាជើងព្រៃស្លាប់ភ្លាម។ ព្រះរាមាជើងព្រៃ មានបុត្រពីរអង្គ។ បន្ទាប់ពីព្រះរាមាជើងព្រៃ ចូលទិវង្គត បុត្រព្រះអង្គ ចៅពញានូរ ឡើងសោយរាជ្យនៅស្រីសន្ធរ។

នៅឆ្នាំ១៥៩៧ ជនជាតិព័រទុយហ្គាល់ទាំងពីរបានយាង ចៅពញាតន់ពីប្រទេសឡាវ មកសោយរាជ្យសម្បត្តិនៅស្រីសន្ធរ។ ក៏ប៉ុន្តែស្ថានភាពនយោបាយនៅកម្ពុជានៅមានភាពវឹកវរ ដោយសារសម្ដេចព្រះបរមរាជាទី៥ ចៅពញាតន់ មិនសូវយកព្រះទ័យទុកដាក់ក្នុងកិច្ចការផែនដី។ នៅពេលនោះមានការបះបោរចៅហ្វាយខេត្តជាញឹកញាប់។ នៅឆ្នាំ១៥៩៩ ចាមបានបះបោរ ហើយការប្រយុទ្ធគ្នាបានផ្ទុះឡើងរវាងពួកព័រទុយហ្គាល់ទាំងពីរនាក់ និងចាមនៅភ្នំពេញ។ ពួកចាមបានសម្លាប់មន្ត្រីជាន់ខ្ពស់ខ្មែរ ព្រមទាំង ឌៀឡូសូ (Diego Belloso) និងរុយប្លាស (Ruiz Blas) ផងដែរ។ ប្រការនេះបានធ្វើឱ្យកម្ពុជាជួបវិបត្តិយ៉ាងធ្ងន់ធ្ងរ ហើយស្ថានភាពនយោបាយនៃក្រុងកម្ពុជាមានអស្ថិរភាព និងមានការផ្លាស់ប្ដូររាជ្យយ៉ាងញឹកញាប់ ដូចជាការឡើងគ្រងរាជ្យនៃពញាអននៅឆ្នាំ១៥៩៩ និងពញាញោម នៅឆ្នាំ១៦០០។ នៅក្នុងសិលាចារឹកនគរវត្តលេខ៦ នៅឆ្នាំ១៥៩៩ ឱកល្ហួង អគ្គេរាជ បានមកអង្គរវត្ត ដើម្បីធ្វើបុណ្យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងឧទ្ទិសកុសលសូមឈ្នះអស់សត្រូវ សូមកុំបីមានសត្រូវមកបៀតបៀនកម្ពុជទេស និងបានបួងសួងសុំឱ្យកម្ពុជទេសមានសុខក្សេមក្សាន្តកុំបីមានចលាចលឡើយ។

៣.២. លក្ខណៈទូទៅនៃភាសាខ្មែរកណ្ដាល

បន្ទាប់ពីចាកចោលអង្គរមក នៅសម័យលង្វែកក្នុងរជ្ជកាលព្រះបាទអង្គច័ន្ទរាជា និងព្រះបាទបរមរាជា (ស.វ.ទី១៦) អ្នកប្រាជ្ញខ្មែរបានចាប់រៀបចំភាសាខ្មែរឡើងវិញ ដោយយកតម្រាប់តម្រាខ្លះដែលសល់ពីសម័យអង្គរ។

តួអក្សរនៃភាសាខ្មែរកណ្ដាលមានការវិវត្ត ពីអក្សរជ្រេងនៅក្នុងសម័យអង្គរនៅក្នុងសតវត្សទី១៣ ដែលពេញនិយម ក្នុងការសរសេរក្នុងរាជ្យព្រះបាទជ័យវម៌្មទី៧ មកជាអក្សរមូល។ នៅក្នុងសតវត្សទី១៣ មានសរសេរអក្សរមូលដែរ តែមិនពេញនិយមទេ។ សិលាចារឹកនគរវត្តចាប់ពីសតវត្សទី១៦ រៀងមក គេឃើញប្រើប្រាស់អក្សរមូលទាំងស្រុង។ អក្សរមូល គឺជាប្រភេទអក្សរដែលមានទម្រង់មូល។ គេច្រើនសរសេរអក្សរមូល នៅក្នុងសៀវភៅធម៌ជាភាសាបាលីឬសំស្ក្រឹត។ ម្យ៉ាងទៀតការសរសេរមន្តអាគមគាថា លើកន្សែងយ័ន្តលើអាវគេជះសាក់លើខ្លួនប្រាណ ក៏គេនិយមប្រើអក្សរមូលដែរ។

៣.២.១. វាក្យសព្ទខ្មែរចាស់

តាមរយៈការសិក្សាសិលាចារឹកនគរវត្តយើងឃើញនៅមានប្រើវាក្យសព្ទខ្មែរចាស់ដូចតទៅ៖

ខ្មែរចាស់	ខ្មែរកណ្ដាល	ខ្មែរទំនើប
 (K.600)	(IMA-3)	ឮតិ=ឮដ៏
(K. 484)	(IMA-3)	តិ=ចំពោះ
(K. 484)	(IMA-3)	កុំម្បី

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(K.227)	(IMA-3)	ទា
(331Sa)	(IMA-3)	ទូរ
(K.600)	 (IMA-3)	ឱយ
(K.331A)	 (IMA-2)	កើត
	(IMA-10)	ពោច
(K.214)	(IMA-4)	ជូន=ជូន
	 (IMA-8)	ខ្ញុំបម្រើ
(K.484)	(IMA-2)	តុត=ជុត
 (K.38)	(IMA-2)	បុញ=បុណ្យ
(K. 38)	(IMA-2)	គិ=គឺ
(K. 38)	(IMA-3)	ផោង=ផង
(K. 38)	 (IMA-10)	ត្ងៃ=ថ្ងេយ=ថ្ងៃ
(K. 38)	 (IMA-2)	រាជ
	(IMA-2)	មាស
(K. 600)	(IMA-2)	ព្រះ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

	(IMA-3)	សោយរាជ្យសម្បត្តិ
(K. 484)	(IMA-3)	ចិន្តា
(K.569)	 (IMA-3)	ព្រាហ្មណាចារ្យ
(K.331A)	(IMA-3)	ស្រេច (តិ)
(K.331A)	(IMA-37)	ដោយ
(K. 266)	(IMA-3)	កម្រតេងយេង
(បន្ទាយឆ្មារ)	(IMA-3)	ស្តេច
(K.484)	(IMA-9)	វន្ទះ
(K.484)	(IMA-9)	ភ្នែក
	(IMA-9)	អ្នក
(K. 154) កោន	(IMA-8)	កូណា=កូន

៣.២.២. កម្ចីពាក្យសព្ទបាលី-សំស្ក្រឹត

សិលាចារឹកនគរវត្តបង្ហាញពីការប្រើប្រាស់កម្ចីភាសាសំស្ក្រឹត និងភាសាបាលី នៅក្នុងភាសាខ្មែរកណ្ដាល និងឆ្លុះបញ្ចាំងពីការទទួលយកនូវទ្រឹស្ដីព្រះពុទ្ធសាសនា នៅក្នុងសង្គមខ្មែរ ការប្រើប្រាស់រាជសព្ទ និងការសរសេរពាក្យបាលីលាយឡំជាមួយនឹងពាក្យខ្មែរ និងវាក្យសព្ទសំស្ក្រឹត ដែល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្មែរបន្តប្រើជារៀងរហូតមក។

សិលាចារឹកនគរវត្តលេខ១ ជាសិលាចារឹកគ្មានកាលបរិច្ឆេទ ដែលបានពណ៌នាពីក្ដីប្រាថ្នា និងការបូជាប្រគេនថ្វាយព្រះសង្ឃ និងសាមណេរ។

IMA	សរសេរជាខ្មែរទំនើប	សេចក្ដីជាខ្មែរទំនើប
	ត្រិពិទ្ធ ត្រៃយសរវន្ទនា ពាហុល ឧតុ(ល) អត្តិរេកឯកចិតាតិទ្ធ សុចរិតសាទរ	សូមថ្វាយបង្គំដល់ប្រជុំ៣ នៃសរណវត្ថុបីប្រការ ដ៏មាំមួន រកអ្វីស្មើពុំបាន អតិរេក បិតនៅ (តិដ្ឋតិ) ឯកចិត្ត សុចរិត សាទរ

សិលាចារឹកលេខ១ បង្ហាញពីកម្ចីពាក្យពីភាសាបាលី ដោយប្រើពាក្យបាលី និងសំស្រ្កឹតចូលគ្នាតែម្ដង ដែលជាលក្ខណៈពិសេសនៃភាសាខ្មែរកណ្ដាល។ ប្រការនេះមានន័យថា ខ្មែរនៅនិយមពាក្យសព្ទសំស្រ្កឹត ហើយបន្ថែមពាក្យសព្ទបាលី ដែលហូរចូលក្នុងភាសាខ្មែរ តាមរយៈការគោរពប្រតិបត្តិព្រះពុទ្ធសាសនា។

IMA	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ត្រិពិទ្ធ (សំ)	មាន ៣ ប្រការ
	ត្រៃយសរវន្ទនា (សំ)	ថ្វាយបង្គំដល់សរណវត្ថុទាំងបី (ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ)
	ពាហុល (បា)	ពាឡ្ហំ = មាំមួន
	ឧតុល (សំ)	គ្មានអ្វីស្មើ
	អត្តិរេក (បា)	អតិរេក = លើសលុប
	ឯកចិតា (បា)	ចិត្តតែមួយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

	តិទ្ធ (បា)	តិដ្ឋតិ= ឋិតនៅ
	សុចរិត	ស្អាត ទៀងត្រង់
	សាទរ (បា)	ប្រកបដោយសេចក្ដីប្រកាន់អបអរ

ជាភាសាខ្មែរ

ត្រិពិធ ត្រយសរណវន្ទនា ពហុល អតុល អតិរេក ឯកចិត្តឋិធ សុចរិត សាទរ ករ ទស នក្ខកពង្គលិ ត្រិបាទារវិន្ទ អចិន្តី អតិរេក អនេក វៃបុល អតុល បេស្នាទិពល អតិកល្វហទយ។ ដោយបុព្វំពោធិសត្វផង ស្បង្គរំពឹង ដោយប្រាជ្ញាសុំទៅជាព្រះពុទ្ធ សំតេចព្រះមហាថេរ ត្រៃវត្នមហាពោធិ ប្រតិស្ឋាព្រះមហាពោធិព្រឹក្សចំនួនប្រាំមួយដើម ថៅនិស្រេយមុនិ មួយអង្គ ថៅសាមនេរ វត្នលង្ការ មួយអង្គ ថៅសាមនេរ ឥន្ទមោលិ មួយអង្គ ថៅសាមនេរ ចន្ទចូលា មួយអង្គ ថៅសាមនេរ ធម៌មង្គល និងថៅសាមនេរ ខ្មៅ មួយអង្គ ថៅសាមនេរ ទេពចូលា មួយអង្គ និងបណ្ឌិត ព្រហ្ម, ក្រ្យ, ថា, ឱវ, សាគរ។ មហាថេរប្រតិស្ឋាព្រះនិវ៌ាណ។

លក្ខណៈសំខាន់នៃសិលាចារឹកនគរវត្ត គឺការសរសេរលាយគ្នា នៅក្នុងអត្ថបទពាក្យជាភាសាបាលីសំស្ក្រឹត ពាក្យខ្មែរចាស់ និងពាក្យខ្មែរ (LEWITZ, Savaros, 1972)។ បើប្រៀបធៀបជាមួយសិលាចារឹកសម័យអង្គរ សិលាចារឹកនគរវត្តមិនបានសរសេរតាមក្បួនខ្នាតវេយ្យាករណ៍ត្រឹមត្រូវ ដូចនៅសម័យអង្គរឡើយ ហើយការសរសេរទៀតសោត ក៏មានកំហុសអក្ខរាវិរុទ្ធផងដែរ ដែលបង្ហាញថា នៅជំនាន់នោះ គ្មានសាលារៀនបណ្ដុះបណ្ដាលត្រឹមត្រូវ ដូចនៅជំនាន់អង្គរ ហើយការរៀនសូត្រ គឺធ្វើឡើងតាមប្រពៃណីសូត្រតៗគ្នាដោយផ្ទាល់មាត់ ជាជាងការផ្ដោតលើការសរសេរអត្ថបទ។ អត្ថបទខាងក្រោម គឺជាការបកប្រែពីភាសាបារាំង ដែលស្រាវជ្រាវដោយបណ្ឌិត ពៅ សាវរស ផង និងពិនិត្យតាមសទ្ទានុក្រមបាលីខ្មែរនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតផង។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

IMA-1

K 303 IMA 1 Imprint sheet no./លេខផ្ទាំង: 95

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាភាសាខ្មែរទំនើប

(១) វត្តមហាពោធិនាមេន (២) មយាសម្តោជិមិច្ចតា
(៣) ពោធិវុក្ខាតិពេបេត្វា (៤) សជិនប្បដិមំតមំ (ឥមំ)
(៥) សមត្តញ្ញាយោមយ្ហំ (៦) បាបេតុំសព្វសម្បទំ
(៧) បសន្នបនសាសាធូ (៨) សាធុពោអនុមោទថ
(៩) ត្រិពិទ្ធ ត្រៃយសវន្ទនា ៣ (១០) ហុល ឧតុ (ល) អត្ថិវេកឯកចិតាតិ
(១១) ទ្វសុចរិតសាទរករទេសន (១២) ក្ខអកពន្លលិ គ្រិបាទារពិទ្ធអ
(១៣) ចិន អត្ថិវេកអនេកពៃបុលឧ (១៤) តុលចេស្តាទិពលតិ កលហុ
(១៥) ទៃតោយបុព្វំពោធិសត្វជោ (១៦) ង ស្បន្តរំពិងនានុប្រាថ៌នាសូម
(១៧) ជាព្រះពុទ្ធគិបិសំតេចព្រះម (១៨) ហាថេរ គ្រិវត្តមហាពោធិ ប្រ
(១៩) តិស្ឋាព្រះមហាពោធិព្វក្សអង្គប្រ (២០) មួយចៅនិស្រេយមុនិ អង្គមួ
(២១) យ ចៅស្រាមនេវត្ថលង្ការអង្គ (២២) មួយ ចៅស្រាមនេវឥន្ទមោ
(២៣) លិអង្គមួយ ចៅស្រាមនេវច (២៤) ន្ទចូលាអង្គមួយ ចៅស្រាម
(២៥) នេវធម្មមង្គល នុចៅស្រាមនេ (២៦) វខ្មោអង្គមួយ ចៅស្រាមនេវទេ
(២៧) ពចូលាអង្គមូល នុមណ្ឌិ(ត) ព្រហ្ម (២៨) ក្សេថា ឱ វ សាគរប្រស្វាព្រះ
(២៩) អង្គមួយ...និព្វាន...(៣០)...

លក្ខណៈពិសេសនៃភាសាខ្មែរកណ្តាល គឺពាក្យសំស្ក្រឹតនៅបន្តចាក់ឫស និងបញ្ជ្រាបចូលក្នុងភាសាខ្មែរ ហើយជាពិសេស គឺការប្រើពាក្យសំស្ក្រឹត និងបាលីលាយឡំជាមួយនឹងពាក្យខ្មែរបុរាណ។ នៅពេលខ្លះ នៅក្នុងឃ្លាមួយមានប្រើពាក្យសំស្ក្រឹតផង និងពាក្យបាលីផង ដែលមានន័យដូចគ្នា លាយឡំជាមួយនឹងពាក្យខ្មែរ។

អត្ថិវេក (បា.) អនេកពៃបុល (សំ.) ឧតុល (សំ.) ចេស្តាទិពល = កម្លាំងមានចេស្តាច្រើនលើសលុប និងបរិបូណ៌ជាអនេក (IMA-1)

កោប្រុន (ខ.) ធញបុញ (បា.) លក្សណ (សំ.) = ប្រកបទ្វលក្ខណៈជាអ្នកមានសម្បត្តិបុណ្យ (IMA-1)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សទ្ទាមហាវិបុលអតុល្យអតិរេក (IMA-3)

៣.២.២.១. ខាក្យសព្ទបាលីក្នុងភាសាខ្មែរកណ្ដាល

ភាសាបាលី ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅកម្ពុជា ជាភាសានៃព្រះពុទ្ធសាសនាថេរវាទ ហើយភាសានេះត្រូវបានប្រើប្រាស់ផងដែរ នៅក្នុងមជ្ឈដ្ឋាននៃបញ្ញវន្តកម្ពុជា និងបានជ្រាបចូលក្នុងគ្រប់សរសៃសង្វៃនៃសង្គមជាតិកម្ពុជា។ ដើម្បីក្លាយជាអ្នកចេះដឹង បញ្ញវន្តខ្មែរជាច្រើនជំនាន់បានសិក្សាភាសាបាលី ក្នុងវត្តអារាម និងនៅក្នុងសាលាបាលី។

អស់ជាច្រើនសតវត្ស បន្ទាប់ពីការដួលរលំនៃសម័យអង្គរ ទីអារាមព្រះពុទ្ធសាសនាបានក្លាយជាមជ្ឈមណ្ឌលសិក្សារៀនសូត្រ និងក្លាយទៅជាទីកន្លែងសម្រាប់ថែរក្សា និងអភិរក្សវប្បធម៌ ហើយបព្វជិតព្រះពុទ្ធសាសនាគឺតំណាងឱ្យបញ្ញាជនកម្ពុជា។ ប្រព័ន្ធអប់រំខ្មែរសម័យក្រោយអង្គរ គឺជាប្រព័ន្ធអប់រំបែបព្រះពុទ្ធសាសនា។ វត្តអារាមមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្ស ឱ្យមកបម្រើនៅក្នុងរាជការ។ ភាសាយានគឺភាសាបាលី ដែលជាភាសាកម្រិតខ្ពស់ និងភាសាខ្មែរ ដែលជាភាសាសម្រាប់ប្រជាជនសាមញ្ញ។ ប្រព័ន្ធអប់រំនេះមានចំណុចខ្លាំង និងចំណុចខ្សោយរបស់វា។ ចំណុចខ្លាំងស្ថិតត្រង់ថា ការអប់រំបែបព្រះពុទ្ធសាសនាត្រូវផ្ដោតលើការរៀនសូត្រព្រះត្រៃបិដក ច្បាប់ស្នាដៃអក្សរសិល្ប៍ និងគម្ពីរសាស្ត្រានានា ដែលជាមូលដ្ឋាននៃសាសនាព្រះពុទ្ធ។ ក៏ប៉ុន្តែ ដោយសារសំណង់វត្តអារាមគឺជាសំណង់ឈើ គេគ្មានតម្រូវការក្នុងការបណ្ដុះបណ្ដាលស្ថាបត្យករ ឬវិស្វករឡើយ។ ដូច្នេះហើយ កម្មវិធីសិក្សាគ្មានមុខវិជ្ជាដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រដូចនៅអាស៊ីប្រទេសឡើយ។ ជាក់ស្ដែង យើងគ្មានភស្តុតាងពីវត្តមានអ្នកប្រាជ្ញខាងផ្នែកគណិតវិទ្យា ឬវិទ្យាសាស្ត្រនៅប្រទេសកម្ពុជាឡើយ។ ក៏ប៉ុន្តែប្រព័ន្ធអប់រំពុទ្ធសាសនានេះក៏បានផលិតនូវអ្នកប្រាជ្ញ កវីនិពន្ធល្បីៗដែលបង្កើតនូវចលនាអក្សរសិល្ប៍ពុទ្ធនិយម ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយ ឱ្យអរិយធម៌ខ្មែរមានភាពសម្បូណ៌បែប។

តាមរយៈការសិក្សាសិលាចារឹកនគរវត្ត យើងអាចចែកកម្ចីវាក្យសព្ទ សំស្ក្រឹត ជាប្រភេទពាក្យដូចតទៅ៖

ពាក្យពាក់ព័ន្ធនឹងរាជសព្ទ

IMA	អក្សរបច្ចុប្បន្ន	អត្ថន័យបច្ចុប្បន្ន
	ស្មោយរាជសម្បត្តិ	ឡើងគ្រងរាជ្យ
	មហារាជបពិត្រ	ព្រះមហាក្សត្រ
	ថ្វាយបង្គំ	សំពះ
	ប្រទំម្យ	ក្រាប
	ទូល	ជម្រាប
	ព្រះវរបាទាពិន្ទុ	ព្រះបាទផ្កា ឈូកដ៏ប្រសើរ
	ព្រះរាជចំពោះប្រាជ្ញា	ព្រះរាជប្រាជ្ញា
	ព្រះរាជកុសល	ព្រះរាជកុសល
	ថ្វាយ	ជូន
	ព្រះអង្គ	ព្រះអង្គ
	ព្រះវរបិតា	ព្រះវរបិតា
	ព្រះញាតិ	ព្រះញាតិ
	មហារាជបពិត្រ	ព្រះមហាក្សត្រ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

	រាជកុសល	អំពើល្អ
	ព្រះរាជអធិដ្ឋាន	សច្ចាដោយស្មោះត្រង់
	ព្រះរាជបុត្រ	ព្រះរាជបុត្រ
	ទ្រង់	ទ្រង់
	ព្រះរាជឱរស	កូន
	ព្រះនោម	ព្រះនោម
	ទាសាទាសី	ទាសាទាសី
	ថ្វាបន្តិ	ថ្វាយបន្តិ

ពាក្យពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា

IMA	អក្សរបច្ចុប្បន្ន	អត្ថន័យបច្ចុប្បន្ន
	ព្រះមហា ត្រីរត្នត្រៃយ	ព្រះត្រៃបិតក (ព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្ម)
	មហាសង៏រាជ	មហាសង្ឃរាជ
	សាមនេរ	សាមណេរ
	ថេរានុថេរ	ថេរ អនុថេរ =ព្រះថេរានុថេរ
	ឪបាសក	ឧបាសក

	បូសសំនក្ក័	បូសសំណាក់
	លាផ្នួសបព្វជ្ជាកម្ម	លាផ្នួសជាបព្វជិត
	សាស្នា ព្រះតថាគត	សាសនាព្រះតថាគត
	ចត្តាឡីសក	៤០
	សទ្ធាំ	សទ្ធា
	អដ្ឋារស្ស (បាលី)	១៨
	ព្រះចៃយតិយ	ព្រះចេតិយ
	ពោធិ	ពោធិ
	ទាសាទាសី	ទាសាទាសី
	បញ្ចចុះ	បញ្ចុះ
	អាត្មា	អាត្មា
	សេមា	សេមា
	ញោម	ញោម
	ផលានិសង្ស	ផលបុណ្យ
	ត្រាស់	ត្រាស់ដឹង
	អនុមោទនា	សេចក្តីត្រេកអរតាម

	តុស៊ិទ្ធ	តុសិត =ស្ថានសួគ៌ជាន់ទី៤

នាមអរូបី ដូចជាពាក្យ៖ អាជ្ញា (ការបង្គាប់ បញ្ជា)

IMA	អក្សរបច្ចុប្បន្ន	អត្ថន័យបច្ចុប្បន្ន
	មហា	ធំធេង
	វិបុល	ធំដោយវិសេស
	ឯកត្តតា	ទិសដៅតែមួយ(ទៅនិព្វាន)
	ប្រាមោទ្យ	បាមោជ្ជ =សេចក្តីពេញចិត្តខ្លាំង
	ជោតិ	សេចក្តីរុងរឿង
	វេណុពិន្ទ	វេណុពិន្ទុ=តូចដូចល្អងធុលី
	អច្ចិ	រស្មីពន្លឺ
	សុគន្ធ	ក្លិនក្រអូប
	បវរសរ	សំឡេងពីរោះ
	មនស្សាកិលង្កិត	កំណត់ដោយមនោ
	វិកសិតសោត្តរ	រីកស្រស់ត្រកាល
	បរមបទុម្មាភា	ស្រស់ស្អាតបីដូចជាផ្កាឈូក
	ប្រកាសយ្យ	Meilleurs des remparts
	សមុត្តិ	វិមុត្តិ= ព្រះនិព្វាន

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

	មហោត្តំ	មហាឧត្តម
	សមទ្ធ	ទាំងមូល
	សច្ចាទិដ្ឋាន	សច្ចាទិដ្ឋាន= ទីដែលឃើញការពិត
	ពន្ទរាយ	ពណ្ណ+រាយ(ខ)= ការរីកសាយពន្លឺ
	សំម្បត្ត	សម្បត្តិ= គុណដ៏ខ្ពង់ខ្ពស់
	អធិដ្ឋាន	សច្ចាដោយស្មោះត្រង់
	ឪប្បជាក	ទំនុកបំរុង
	អនុកូល	អនុគ្រោះ
	ទុក្ខវេទនា	ទុក្ខវេទនា
	សុពណ្ណ៌	សុវណ្ណ

ពាក្យសព្ទសំស្ក្រឹតក្នុងភាសាខ្មែរកណ្តាល

ភាសាខ្មែរកណ្តាលបន្តប្រើប្រាស់វាក្យសព្ទកម្ចីពីភាសាសំស្ក្រឹត ដែលមានទាំងពាក្យសំស្ក្រឹត និងពាក្យកម្ចីដែលបំលែងមកជាពាក្យខ្មែរចាស់។ ជាទូទៅ ពាក្យសំស្ក្រឹតដែលមានពីរព្យាង្គ ឬបីព្យាង្គ ត្រូវបានបំលែងឱ្យទៅជាពាក្យខ្មែរចាស់ ដែលមានមួយព្យាង្គ ដែលជានិន្នាការឯកព្យាង្គ ក្នុងការវិវត្តសូរសព្ទភាសាខ្មែរ។ ពាក្យខ្មែរចាស់ទាំងនេះនៅបន្តប្រើប្រាស់នៅក្នុងភាសាខ្មែរកណ្តាល។ នៅក្នុងភាសាខ្មែរកណ្តាលវាក្យសព្ទសំស្ក្រឹតត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ លាយឡំជាមួយវាក្យសព្ទបាលី និងវាក្យសព្ទខ្មែរ នៅក្នុងអត្ថបទសិលាចារឹកនគរវត្ត ដែលនិពន្ធដោយបព្វជិត និងមន្ត្រីដែលមានឋានន្តរសក្តិខ្ពង់ខ្ពស់ ដែលជាភាសាវប្បធម៌នៅសម័យនោះ។ ដូចនេះ ទោះបី

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាមានការហូរចូលនៃភាសាបាលី តាមរយៈព្រះពុទ្ធសាសនាក្ដី ក៏ភាសាសំស្ក្រឹតនៅបន្តដើរតួនាទី ជាភាសាដែលមានកិត្យានុភាព សម្រាប់តាំងបញ្ញត្តិ និងទ្រឹស្ដីធំៗ ក្នុងវិស័យសាសនា នយោបាយ រដ្ឋបាល ច្បាប់ និងក្នុងការរស់នៅប្រចាំថ្ងៃផងដែរ។

IMA	អក្សរបច្ចុប្បន្ន	អត្ថន័យបច្ចុប្បន្ន
	ត្រិពិធ	បីប្រការ
	សុចរិត	ស្មោះត្រង់
	អតុល្យ	ឧតុល=គ្មានអ្វីស្មើ
	បង្គជវត្ត	គ្រាប់ឈូក
	អចិន្ត្យ	អចិន្ត្យ=ជានិច្ចអចិន្ត្រៃយ៍
	ប្រិតិ	អំណរវិសេស
	មានោជ្ញ	ស្អាត
	ពៃរោជ្យ	វៃរោជន=ធ្លាតវៃ
	វាច្ចៈ	សំដី វាចា
	ប្រណិធាន	សម្បថ
	ត្រីត្រិករនាទិត្យពង្ស	អ្នកមានព្រះអាទិត្យការពារផ្សាយអំណាចក្នុងភពទាំងបី
	វត្ត	ត្បូង រតនៈវត្ថុ (ព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្ម)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

	ពិន្ទ	ពិន= កំពូល
	កាលជាប្រថំម	កាលពីដំបូង
	ប្រវេណី	ប្រពៃណីក្សត្រិយ៍
	នព្វសូល	កំពូល ៩
	ពិចិត្រ	វិចិត្រ=ល្អប្រណីត
	ស្ថាបណា	សាងសង់
	កល្ប័នា	ការសម្រេច
	បរិសុទ្ធ	បរិសុទ្ធ
	គុណ	អំពើល្អ អំណាច ប្រយោជន៍
	កុសល	អំពើល្អ
	ជាអាទិ	ដូចជា
	បរម	ឧត្តមបំផុត
	បពិត្រ	បវិត្រៈ=បរិសុទ្ធ
	ប្រនិធាន	ប្រណិធាន=សម្បថ
	បុញ្ញប្រាជ្ញា	បុព្វប្រាជ្ញា= បំណងពីមុន
	យស	កិត្តិយស កិត្តិនាម ជ័យជម្នះ
	ប្រាកដ	ប្រាកដ

	សំបូណ៌	ស្កប់ស្កល់ ចម្រើន
	ធម្មន្តរាយ	អន្តរាយធម៌
	ខ្សេម	ក្សេមក្សាន្ត
	សម្ឫទ្ធិ	សំឫទ្ធិ= ចម្រើនល្អឥតខ្ចោះ
	ស្ពាពរ	ស្ពាពរ
	គព៌្ភណិ	គភ៌ ផ្ទៃពោះ
	ប្រាជ្ញា	ប្រាជ្ញា=សំណូម
	ចរិត	ឥរិយាបថល្អ
	ចិន្តា	គំនិត ការសម្ដែងឆន្ទៈ
	ហេតុ	ដោយសារ
	សំយក្ស៌	ស្មោះស្ម័គ្រ
	ភក្តី	ភក្តី
	បុរស	ប្រុស
	ស្រី	ស្រី
	បរិសុទ្ធ	ស្អាត ឥតសៅហ្មង
	សាក្សីពេជញាណ	វេជ្ជានិក=សាក្សី
	ប្រជាណ	ប្រធាន
	ឱត្បត្ត	ឧត្បត្តិ=កើត
	លក្ស៌	លក្ខណៈ
	មាត្រោទរ	ផ្ទៃមាតា

	ទេព្វបុត	ទេពចុះមក
	ឧត្តុំ	ឧត្តម = ខ្ពង់ខ្ពស់ ធំលើសគេ
	ប្រចំមអធ្វាត	នៅពេលអធ្រាត្រ
	ប្រាកដ	លេចច្បាស់លាស់
	ស្ថិត	ស្ថិតៈ=តាំងនៅ ស្ថិត
	ខ្វួណ	ខ្លួន
	ជា	ជាវ
	បីត	បិទ
	សុពណ្ណ៍	សុវណ្ណ
	អដ្ឋារស្ស (បាលី)	១៨
	ព្រះចៃយតិយ	ព្រះចេតិយ
	ពោធិ	ពោធិ
	ចបសុពេច	ចប់ស្រេច
	ប្រូស	ប្រុស
	ត្រីយ	ស្រី
	ទាសាទាសី	ទាសាទាសី
	ទេព្វ	ទើប
	បញ្ចចុះ	បញ្ចុះ

	ចុះ	ចុះ
	យោក	យក
	អាត្មា	អាត្មា
	សទ្ធាំ	សទ្ធា
	សេមា	សេមា
	ញោម	ញោម

ភាសាខ្មែរកណ្ដាលបានទទួលឥទ្ធិពលយ៉ាងខ្លាំងក្លាពីទស្សនៈ និងវាក្យសព្ទនៃព្រះពុទ្ធសាសនាថេរវាទ និងភាសាបាលី ថ្វីត្បិតតែភាសាសំស្ក្រឹត និងភាសាខ្មែរចាស់នៅបន្តចាក់ឫស ក្នុងវាក្យសព្ទនៃភាសាខ្មែរកណ្ដាល។ ក៏ប៉ុន្តែការសរសេរភាសាបាលីនៅក្នុងសិលាចារឹកនគរវត្តមិនបានត្រឹមត្រូវទៅតាមក្បួនច្បាប់ទេ ដែលបង្ហាញថាថ្វីត្បិតតែព្រះពុទ្ធសាសនាបានចាក់ឫសចូលជ្រៅ ក្នុងសង្គមកម្ពុជានៅសម័យលង្វែក តែវត្តអារាមនៅមិនទាន់ក្លាយជាកន្លែងសម្រាប់ការសិក្សាភាសាបាលីឡើយ។

៣.២.៣. លក្ខណៈរួម និងខុសគ្នារវាងភាសាបាលីនិងភាសាសំស្ក្រឹត

ភាសាបាលី និងភាសាសំស្ក្រឹត គឺជាភាសាដែលស្ថិតនៅក្នុងគ្រួសារតែមួយ និងជាភាសាដែលប្រើប្រាស់ក្នុងទីកន្លែងជាមួយគ្នា និងក្នុងរយៈពេលមិនឆ្ងាយពីគ្នាប៉ុន្មានឡើយ។ ភាសាសំស្ក្រឹត ជាភាសាដែលមានបែបផែនជាក់ច្បាស់ និងមានការប្រើប្រាស់ក្នុងកម្រិតតែនៅក្នុងក្រុមមនុស្សដែលមានការសិក្សា ដូចជាពួកព្រាហ្មណ៍ ឬបព្វជិតពុទ្ធសាសនានិកាយមហាយាន។ ដោយឡែក ភាសាបាលី គឺជាភាសាដែលគេជឿថាជាភាសាប្រាក្រឹតប្រភេទទី១ ក្នុងការប្រាស្រ័យទាក់ទងជាទូទៅ។ ភាសាទាំងពីរមានភាពខុស គ្នាមួយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំនួនតែក៏មានពាក្យសព្ទជាច្រើនខ្លាំងណាស់ដែលប្រើប្រាស់រួមគ្នា។ ដោយភាសាសំស្ក្រឹតមានចំនួនសំឡេងស្រៈ និងសំឡេងព្យញ្ជនៈច្រើនជាងភាសាបាលី គេអាចញែកភាសាសំស្ក្រឹតពីភាសាបាលី តាមលក្ខណៈផ្សេងៗជាច្រើន។

អ្នកស្រាវជ្រាវប្រើប្រាស់ភាសាសំស្ក្រឹត ជាភាសាគោលក្នុងការអធិប្បាយ ដើម្បីប្រៀបធៀបភាសាទាំងពីរ។ ដោយសារភាសាសំស្ក្រឹត គឺជាភាសាកម្រិតខ្ពស់ សម្រាប់ការសិក្សា និងសាសនា ភាសាសំស្ក្រឹតអាចអភិរក្សរបៀបបែបផែននៃភាសាដើមបានយ៉ាងល្អ បើប្រៀបធៀបនឹងភាសាបាលីជាភាសាដែលប្រើប្រាស់ទូទៅ និងមានការប្រែប្រួលផ្លាស់ប្ដូរយ៉ាងលឿន និងយ៉ាងខ្លាំងក្លា។ ទោះបីជាភាសាទាំងពីរមានភាពដូចគ្នាខ្លាំង និងមានភាពខុសគ្នា ក៏ដោយ ក៏អ្នកស្រាវជ្រាវមិនបានសន្និដ្ឋានថា ភាសាបាលី ជាភាសាដែលវិវត្តចេញពីភាសាសំស្ក្រឹតឡើយ។ លោក Kangvol Khatshima បានសិក្សាយ៉ាងលម្អិតពីភាពដូចគ្នា និងភាពខុសគ្នារវាងភាសាបាលី និងភាសាសំស្ក្រឹតនៅក្នុងនិក្ខេបបទបណ្ឌិតរបស់លោកដែលមានចំណងជើងថា៖ «កម្ចីពាក្យសព្ទបាលីសំស្ក្រឹតនៅក្នុងភាសាខ្មែរ» (KHATSHIMA, 2005)។

៣.២.៣.១. ភាពដូចគ្នារវាងភាសាបាលីនិងភាសាសំស្ក្រឹត

លក្ខណៈដូចគ្នាទី១ រវាងភាសាបាលី និងសំស្ក្រឹត គឺសូរសព្ទនៃព្យញ្ជនៈដើម និងស្រៈនៃភាសាទាំងពីរដូចគ្នាគឺ៖

ក	ខ	គ	ឃ	ង	ច	ឆ	ជ	ឈ	ញ
k	kh	g	gh	ṅ	c	ch	j	jh	ñ
ដ	ឋ	ឌ	ឍ	ណ	ត	ថ	ទ	ធ	ន
ṭ	ṭh	ḍ	ḍh	ṇ	t	th	d	dh	n
ប	ផ	ព	ភ	ម	យ	រ	ល	វ	ស
p	ph	b	bh	m	y	r	l	v	s
ហ	ឡ								
h	ḷ								

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណែកឯសូរសៀងស្រៈនៃភាសាទាំងពីរដូចគ្នា គឺ៖

អ	អា	ឥ	ឦ	ឧ	ឩ	ឯ	ឱ
a	ā	i	ī	u	ū	e	o

៣.៣.២.៣. ភាពខុសគ្នាខាងពាក្យសព្ទបាលី និងសំស្ក្រឹត

ខាងផ្នែកព្យញ្ជនៈ៖ ភាសាសំស្ក្រឹតមានព្យញ្ជនៈលើសភាសាបាលីចំនួនពីរគឺ៖ (១) ឝ (ś) និង (២) ឞ (ṣ) ៖

ឝ	ឞ	ស
ś	ṣ	s

ខាងផ្នែកស្រៈ៖ ភាសាសំស្ក្រឹតមានស្រៈលើសភាសាបាលីចំនួន៥គឺ៖ (១) ឰ (ai) (២) ឳ (au) (៣) ឫ (ṛ) (៤) ឬ (ṝ) និង (៥) ឭ (ḷ)៖

ឰ	ឳ	ឫ	ឬ	ឭ
ai	au	ṛ	ṝ	ḷ

ភាពខុសគ្នាខាងផ្នែកសូរសព្ទ

I. ដោយសារភាសាសំស្ក្រឹតមានស្រៈលើសភាសាបាលីចំនួន៥ ទើបធ្វើឱ្យភាសាទាំងពីរខុសគ្នាខាងផ្នែកសូរសព្ទដូចខាងក្រោម៖

(១) ពាក្យសព្ទសំស្ក្រឹតប្រើស្រៈមានសូរសៀង (អៃ) ចំណែកឯពាក្យសព្ទបាលីមានសូរសៀង (អេ) ឬ (អូ) ៖

ពាក្យសំស្ក្រឹត (ai)	ពាក្យបាលី (e)	អត្ថន័យ
កៃលាស	កេលាស	ភ្នំកៃលាស
វៃទ្យ	វេជ្ជ	ពេទ្យ វេជ្ជ
មៃត្រិ	មេត្តិ	មេត្រី

ពាក្យសំស្ក្រឹត (ai)	ពាក្យបាលី (i)	អត្ថន័យ
សៃន្ធវ	សិន្ធវ	សេះសិន្ធវ

(២) ពាក្យសព្ទសំស្ក្រឹតប្រើស្រៈមានសូរសៀង «ឱ (au)» ចំណែកឯពាក្យសព្ទបាលីមានសូរសៀង «ឱ (o)» ឬ «ឧ (u)» ៖

ពាក្យសំស្ក្រឹត (au)	ពាក្យបាលី (o)	អត្ថន័យ
បូរាណ	បុរាណ	បុរាណ
លៅក្យ	លោកិយ	លោកិយ
ពាក្យសំស្ក្រឹត (au)	ពាក្យបាលី (u)	អត្ថន័យ
ឱទ្ធត្យ	ឧទ្ធច្ច	សេចក្តីរាយមាយ

(៣) ពាក្យសព្ទសំស្ក្រឹតប្រើស្រៈមានសូរសៀង «ឫ (ṛ)» ចំណែកឯពាក្យសព្ទបាលីមានសូរសៀង «អ (a)» «ឥ (i)» ឬ «ឧ (u)» ៖

ពាក្យសំស្ក្រឹត (ṛ)	ពាក្យបាលី (a)	អត្ថន័យ
មឫត	មត	ស្លាប់
គឫហ	គហ	គេហដ្ឋាន
ពាក្យសំស្ក្រឹត (ṛ)	ពាក្យបាលី (i)	អត្ថន័យ
ឫសិ	ឥសិ	ឥសី
ឫទ្ធិ	ឥទ្ធិ	ឫទ្ធិ (ឥទ្ធិពល)
ពាក្យសំស្ក្រឹត (ṛ)	ពាក្យបាលី (u)	អត្ថន័យ
ឫតុ	ឧតុ	រដូវ (ឧតុនិយម)
ឫជុ	ឧជុ	ត្រង់

II. ដោយសារភាសាសំស្ក្រឹតមានព្យញ្ជនៈលើសភាសាបាលីចំនួន២ នៅពេលដែលពាក្យសព្ទសំស្ក្រឹតប្រើ «ឝ (ś)» និង «ឞ (ṣ)» ពាក្យសព្ទបាលីប្រើ «ស (s)» និង «ឆ (ch)» ដូចជា៖

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាក្យសំស្ក្រឹត (ś)	ពាក្យបាលី (s)	អត្ថន័យ
ឝាខ	សាខា	សាខា មែកឈើ
ឝីល	សីល	សីល
ពាក្យសំស្ក្រឹត (ś)	ពាក្យបាលី (ch)	អត្ថន័យ
ឝវ	ឆវ	សាកសព
ឝាវ	ឆាវ	កូនសត្វ
ពាក្យសំស្ក្រឹត (ṣ)	ពាក្យបាលី (s)	អត្ថន័យ
បរិឞទ	បរិសា	ក្រុមហ៊ុន
កាឞាយ	កាសាវ	ក្រណាត់ម៉្យាង
ពាក្យសំស្ក្រឹត (ṣ)	ពាក្យបាលី (ch)	អត្ថន័យ
ឞឞ្ឋ	ឆដ្ឋ	ទី៦

ភាពខុសគ្នាខាងផ្នែកសូរសព្ទព្យញ្ជនៈ

វាក្យសព្ទសំស្ក្រឹតមានសូរសព្ទព្យញ្ជនៈដើមគួប ២ និង ៣ មានចំនួនច្រើនណាស់ ចំណែកឯភាសាបាលីមានចំនួនតិចជាង។

I. *វាក្យសព្ទសំស្ក្រឹតមានសូរសព្ទព្យញ្ជនៈដើមគួប (ផ្ញើជើង) ចំណែកឯនៅក្នុងវាក្យសព្ទបាលី គេបានបន្ថែមស្រៈខ្លី «អ (a)» «ឥ (i)» និង «ឧ (u)» ដូចជា៖*

ពាក្យសំស្ក្រឹត	ពាក្យបាលី (a)	អត្ថន័យ
គ្រហណ	គរហា	និន្ទា
ពាក្យសំស្ក្រឹត	ពាក្យបាលី (i)	អត្ថន័យ
ក្រិយា	កិរិយា	ទង្វើ
ឝ្រី	សិរិ	សិរី
ស្នេហ	សិនេហ	ស្នេហា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាក្យសំស្ក្រឹត	ពាក្យបាលី (u)	អត្ថន័យ
ឝ្វាន	សុវាណ	ឆ្កែ

II. វាក្យសព្ទសំស្ក្រឹតមានសូរសព្ទព្យញ្ជនៈ «ឞ (ṣ) » និង «ស (s) » ដែលបង្កើតជាព្យញ្ជនៈគួប ជាមួយព្យញ្ជនៈដើមផ្សេងៗ ចំណែកឯវាក្យសព្ទបាលីមាន សូរសព្ទ «ហ (h)» ដូចជា៖

ពាក្យសំស្ក្រឹត (kṣ)	ពាក្យបាលី (kh)	អត្ថន័យ
ក្ឞីរ	ខីរ	ទឹកដោះ
ក្ឞយ	ខយ	ក្ស័យ
ក្ឞេត្រ	ខេត្ត	ខេត្ត ស្រែ
ក្ឞណ	ខណ	ខណៈ ក្សិណ សិន
ក្ឞត្រិយ	ខត្តិយ	ក្សត្រិយ៍
ពាក្យសំស្ក្រឹត (sk)	ពាក្យបាលី (kh)	អត្ថន័យ
ស្កន្ធ	ខន្ធ	រាងកាយ
ពាក្យសំស្ក្រឹត (st)	ពាក្យបាលី (th)	អត្ថន័យ
ស្តម្ភ	ថម្ភ	ស្តម្ភ សសរ
ពាក្យសំស្ក្រឹត (str)	ពាក្យបាលី (th)	អត្ថន័យ
ស្ត្រី	ថី	ស្ត្រី
ពាក្យសំស្ក្រឹត (sp)	ពាក្យបាលី (ph)	អត្ថន័យ
ស្បឞ	ផស្ស	ត្រូវ
ពាក្យសំស្ក្រឹត (kṣ)	ពាក្យបាលី (kh)	អត្ថន័យ
ក្ឞណ	ខណ	បុណ្យធ្វង
ក្ឞម	ខម	អត់ធន់
ក្ឞារិកា	ខារិកា	មានរសខារ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាក្យសំស្ក្រឹត (sth)	ពាក្យបាលី (th)	អត្ថន័យ
ស្ថិរ	ថិរ	ស្ថិតស្ថិរ
ស្ថល	ថល	លើ
ពាក្យសំស្ក្រឹត (ps)	ពាក្យបាលី (ch)	អត្ថន័យ
ប្សាត	ឆាត	ហេវ

III.ពាក្យសព្ទព្យញ្ជនៈដើមត្តួបក្នុងភាសាសំស្ក្រឹត ដែលមានព្យញ្ជនៈទី២ យរលវត្រូវនឹងពាក្យសព្ទបាលីដែលមានព្យញ្ជនៈមួយដោយកាត់សូរសព្ទព្យញ្ជនៈទី២ ដោយទុកតែសូរសព្ទនៃព្យញ្ជនៈដើមដែលដូចគ្នា ដូចជា៖

ពាក្យសំស្ក្រឹត (cy)	ពាក្យបាលី (c)	អត្ថន័យ
ច្យុតិ	ចុតិ	ធ្លាក់ ស្លាប់
ច្យវន	ចវន	ធ្លាក់ ស្លាប់
ពាក្យសំស្ក្រឹត (jy)	ពាក្យបាលី (j)	អត្ថន័យ
ជ្យោតិ	ជោតិ	ពន្លឺ រុងរឿង
ជ្យេឞ្ឋ	ជេដ្ឋ	ល្អប្រសើរ បង
ជ្យាលា	ជាលា	ពន្លឺចែងចាំង
ពាក្យសំស្ក្រឹត (śy)	ពាក្យបាលី (s)	អត្ថន័យ
ឝ្យាម	សាម	ខ្មៅ
ពាក្យសំស្ក្រឹត (dr)	ពាក្យបាលី (d)	អត្ថន័យ
ទ្រវ្យ	ទព្វ	ទ្រព្យ
ទ្រុម	ទុម	ដើមឈើ
ពាក្យសំស្ក្រឹត (pr)	ពាក្យបាលី (p)	អត្ថន័យ
ប្រភា	បភា	ពន្លឺចែងចាំង
ពាក្យសំស្ក្រឹត (kr)	ពាក្យបាលី (k)	អត្ថន័យ
ក្រោធ	កោធ	ខឹង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាក្យសំស្ក្រឹត (śr)	ពាក្យបាលី (s)	អត្ថន័យ
ស្រទ្ធា	សទ្ធា	សទ្ធា
ស្រេស្ឋិន	សេដ្ឋិ	សេដ្ឋី
ពាក្យសំស្ក្រឹត (śl)	ពាក្យបាលី (s)	អត្ថន័យ
ស្លេស្មណ	សេម្ហ	ស្លេស្ម៍
ពាក្យសំស្ក្រឹត (dv)	ពាក្យបាលី (d)	អត្ថន័យ
ទ្វីប	ទីប	ទ្វីប កោះ
ពាក្យសំស្ក្រឹត (dhv)	ពាក្យបាលី (dh)	អត្ថន័យ
ធ្វជ	ធជ	ទង់
ធ្វនិត	ធនិត	សំឡេង
ពាក្យសំស្ក្រឹត (jv)	ពាក្យបាលី (j)	អត្ថន័យ
ជ្វរ	ជរ	ឈឺ ជក
ពាក្យសំស្ក្រឹត (śv)	ពាក្យបាលី (s)	អត្ថន័យ
ស្វេត	សេត	ស
ពាក្យសំស្ក្រឹត (sv)	ពាក្យបាលី (s)	អត្ថន័យ
ស្វាមិន	សាមី	ម្ចាស់ ស្វាមី

ភាពខុសគ្នាដោយការនិយមប្រើស្វរសព្ទផ្សេងគ្នា

I. *ភាពខុសគ្នាដោយសារភាសាសំស្ក្រឹតប្រើស្រៈស្វរវែង តែភាសាបាលីប្រើស្រៈស្វរខ្លី ដូចខាងក្រោម៖*

ពាក្យសំស្ក្រឹត (ā)	ពាក្យបាលី (a)	អត្ថន័យ
មាគ៌	មគ្គ	ផ្លូវ
ធាន្យ	ធញ្ញ	ធញ្ញជាតិ
ឝាន្តិ	សន្តិ	សន្តិ ស្ងប់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាត្មន	អត្ត	ខ្លួន
ពាក្យសំស្ក្រឹត (ī)	ពាក្យបាលី (i)	អត្ថន័យ
កីត៌ិ	កិត្តិ	កិត្តិយស
វីរ្យ	វិរិយ	វិរិយ
គ្រីឞ្ម	គិម្ហ	ក្តៅ
ឦរ្យ	ឥរិយា	ឥរិយាបថ
ពាក្យសំស្ក្រឹត (ū)	ពាក្យបាលី (u)	អត្ថន័យ
ឝូន្យ	សុញ្ញ	សូន្យ
បូណ៌	បុណ្ណ	ពេញ
សូត្រ	សុត្ត	ព្រះសុត្ត
សូរ្យ	សុរិយ	ព្រះអាទិត្យ

II. ការប្រើស្រៈផ្សេងគ្នា ទោះបីជាភាសាបាលី និងសំស្ក្រឹតមានស្រៈដូចគ្នា គឺ៖ «អ (a)», «អ (a)», «អា (ā)», «ឥ (i)», «ឦ (ī)», «ឧ (u)», «ឩ (ū)», «ឯ (e)», «ឱ (o)», មានពាក្យសព្ទមួយចំនួន ដែលភាសាសំស្ក្រឹតប្រើស្រៈមួយ តែភាសាបាលីប្រើស្រៈផ្សេងវិញ ដូចជា៖

ពាក្យសំស្ក្រឹត (a)	ពាក្យបាលី (u)	អត្ថន័យ
បជ៌ន្យ	បជ្ជុន្ន	ពពក
ពាក្យសំស្ក្រឹត (a)	ពាក្យបាលី (e)	អត្ថន័យ
ឝយ្យា	សេយ្យា	កន្លែងគេង
ពាក្យសំស្ក្រឹត (i)	ពាក្យបាលី (u)	អត្ថន័យ
ឥឞុ	ឧសុ	ព្រួញ
ពាក្យសំស្ក្រឹត (i)	ពាក្យបាលី (e)	អត្ថន័យ
មហិឞី	មហេសី	មហេសី

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាក្យសំស្ក្រឹត (i)	ពាក្យបាលី (o)	អត្ថន័យ
ឥក្សវាកុ	ឱកកាក	ត្រកូលអោកកាក
ពាក្យសំស្ក្រឹត (u)	ពាក្យបាលី (a)	អត្ថន័យ
គុរុ	គរុ	គ្រូ
ពាក្យសំស្ក្រឹត (u)	ពាក្យបាលី (i)	អត្ថន័យ
បុរុឞ	បុរិស	បុរស ប្រុស
ពាក្យសំស្ក្រឹត (u)	ពាក្យបាលី (o)	អត្ថន័យ
បុឞ្ករិណី	បោក្ខរណី	ស្រះ, ត្រពាំង
ពាក្យសំស្ក្រឹត (e)	ពាក្យបាលី (i)	អត្ថន័យ
មហេន្ទ្រ	មហិន្ទ	ព្រះឥន្ទ
ពាក្យសំស្ក្រឹត (e)	ពាក្យបាលី (o)	អត្ថន័យ
ទ្វេឞ	ទោស	ទោស ខឹង
ពាក្យសំស្ក្រឹត (o)	ពាក្យបាលី (u)	អត្ថន័យ
ហោត្រ	ហុត	ការបូជាភ្លើង

III.ការប្រើព្យញ្ជនៈផ្សេងគ្នា គឺទោះបីជាពាក្យសព្ទមួយចំនួនធំក្នុងភាសាបាលី និងសំស្ក្រឹត មានព្យញ្ជនៈដែលមានសូរសព្ទដូចគ្នាក្តី តែមានពាក្យសព្ទមួយក្រុមនៃភាសាទាំងពីរប្រើព្យញ្ជនៈផ្សេងគ្នា ដូចជា៖

ពាក្យសំស្ក្រឹត (ឌ)	ពាក្យបាលី (ឡ)	អត្ថន័យ
ក្រីឌា	កីឡា	កីឡា
ពាក្យសំស្ក្រឹត (ឍ)	ពាក្យបាលី (ឡ)	អត្ថន័យ
វិរូឍ	វិរូឡ្ហ	ស្អាត
ពាក្យសំស្ក្រឹត (ដ)	ពាក្យបាលី (ឡ)	អត្ថន័យ
កក្ខដ	កក្ខឡ	កក

ខេដ	ខេឡ	ទឹករមាត់
ពាក្យសំស្ក្រឹត (យ)	ពាក្យបាលី (វ)	អត្ថន័យ
អាយុធ	អាវុធ	អាវុធ
ពាក្យសំស្ក្រឹត (យ)	ពាក្យបាលី (ល)	អត្ថន័យ
យស្តិ	លដ្ឋិ	ឈើ
ពាក្យសំស្ក្រឹត (យ)	ពាក្យបាលី (ព)	អត្ថន័យ
បូយ	បុព្វ	ខ្ទុះ
ពាក្យសំស្ក្រឹត (ល)	ពាក្យបាលី (ឡ)	អត្ថន័យ
នលិន	នឡិន	ឈូក
តាល	តាឡ	កូនសោរ
ពាក្យសំស្ក្រឹត (ល)	ពាក្យបាលី (ន)	អត្ថន័យ
លាង្គល	នង្គល	នង្គ័ល

IV.ភាពខុសគ្នានៅពេលមានព្យាង្គផ្ញើជើង ឬព្យាង្គតម្រួត ដោយសារតែនៅពេលដែលវាក្យសព្ទភាសាសំស្ក្រឹតមានព្យាង្គផ្ញើជើង ឬព្យាង្គតម្រួត វាក្យសព្ទភាសាបាលីមានការប្រើស្នៀតបន្ថែមជាស្រៈ ឬប្រើព្យញ្ជនៈទី២ផ្សេងពីភាសាសំស្ក្រឹត ។

ករណីទី១៖ ការប្រើស្រៈ (i) និង (u) ជាស្នៀតសិកចន្លោះព្យញ្ជនៈ ក្នុងវាក្យសព្ទបាលី ដូចជា៖

ពាក្យសំស្ក្រឹត	ពាក្យបាលី (i)	អត្ថន័យ
វជ្រ	វជិរ	ពេជ្រ
ចរ្យ	ចរិយ	ចរិយា
សូរ្យ	សុរិយ	សុរិយា
អាចារ្យ	អាចរិយ	អាចារ្យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាក្យសំស្ក្រឹត	ពាក្យបាលី (u)	អត្ថន័យ
សទ្មន	សទុម	អគារ
កល្ស	កលុស	បាប/កខ្វក់
បទ្ម	បទុម	ផ្កាឈូក

ករណីទី២៖ ការផ្លាស់ប្តូរព្យញ្ជនៈទី២ក្នុងភាសាបាលីដោយប្រើព្យញ្ជនៈខ្លួនឯង នៅពេលដែលក្នុងភាសាសំស្ក្រឹតមានប្រើព្យញ្ជនៈ «ក រ ល វ» និងព្យញ្ជនៈមួយចំនួន ដូចជា៖

ពាក្យសំស្ក្រឹត (ក្រ)	ពាក្យបាលី (ក្ក)	អត្ថន័យ
ចក្រ	ចក្ក	ចក្រ
ពាក្យសំស្ក្រឹត (ក្ល)	ពាក្យបាលី (ក្ក)	អត្ថន័យ
សុក្ល	សុក្ក	កុសល
ពាក្យសំស្ក្រឹត (គ្ន)	ពាក្យបាលី (គ្គ)	អត្ថន័យ
អគ្និ	អគ្គិ	ភ្លើង
ពាក្យសំស្ក្រឹត (គ្រ)	ពាក្យបាលី (គ្គ)	អត្ថន័យ
អគ្រ	អគ្គ	អគ្គ ខ្ពង់ខ្ពស់
ពាក្យសំស្ក្រឹត (គ្យ)	ពាក្យបាលី (គ្គ)	អត្ថន័យ
យោគ្យ	យោគ្គ	ការប្រកប/ចំណង
ពាក្យសំស្ក្រឹត (ត្រ)	ពាក្យបាលី (ត្ត)	អត្ថន័យ
បុត្រ	បុត្ត	បុត្រ
មិត្រ	មិត្ត	មិត្រ
ពាក្យសំស្ក្រឹត (ទ្រ)	ពាក្យបាលី (ទ្ទ)	អត្ថន័យ
និទ្រា	និទ្ទា	និទ្រា/ដេក
ពាក្យសំស្ក្រឹត (ត៌)	ពាក្យបាលី (ត្ត)	អត្ថន័យ
កិតិ៌	កិត្តិ	កិត្តិ កេរ្តិ៍

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាក្យសំស្ក្រឹត (ឞ៌)	ពាក្យបាលី (ស្ស)	អត្ថន័យ
វស៌ា	វស្សា	វស្សា/ឆ្នាំ/ភ្លៀង
ពាក្យសំស្ក្រឹត (ឝ៌)	ពាក្យបាលី (ស្ស)	អត្ថន័យ
ទឝ៌ន	ទស្សន	ទស្សន
ពាក្យសំស្ក្រឹត (ឝ្វ)	ពាក្យបាលី (ស្ស)	អត្ថន័យ
អឝ្វ	អស្ស	សេះ
ពាក្យសំស្ក្រឹត (ល្ប)	ពាក្យបាលី (ប្ប)	អត្ថន័យ
កល្ប	កប្ប	យុគ
សិល្ប	សិប្ប	សិល្បៈ
ពាក្យសំស្ក្រឹត (ណ៌)	ពាក្យបាលី (ណ្ណ)	អត្ថន័យ
បូណ៌	បុណ្ណ	បូណ៌
ពាក្យសំស្ក្រឹត (ម៌)	ពាក្យបាលី (ម្ម)	អត្ថន័យ
កម៌	កម្ម	កម្ម
ធម៌	ធម្ម	ធម៌

ករណីទី៣៖ ភាពខុសគ្នានៅពេលមានព្យាង្គតម្រួតក្នុងភាសាសំស្ក្រឹត ដែលមានព្យញ្ជនៈ «រ» ភាសាបាលីប្រើព្យញ្ជនៈ ដូចជា៖

ពាក្យសំស្ក្រឹត (ឃ៌)	ពាក្យបាលី (គ្ឃ)	អត្ថន័យ
អឃ៌	អគ្ឃ	មានតម្លៃ
ពាក្យសំស្ក្រឹត (ថ៌)	ពាក្យបាលី (ត្ថ)	អត្ថន័យ
អថ៌	អត្ថ	ខ្លឹមសារ
សមថ៌	សមត្ថ	សមត្ថភាព
ពាក្យសំស្ក្រឹត (ធ៌)	ពាក្យបាលី (ទ្ធ)	អត្ថន័យ
អធ៌	អទ្ធ	កន្លះ/ពាក់កណ្ដាល
មូធ៌ន	មុទ្ធា	កំពូល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាក្យសំស្រ្កឹត (ភ៌)	ពាក្យបាលី (ព្ភ)	អត្ថន័យ
គភ៌	គព្ភ	គភ៌ ផ្ទៃពោះ

ករណីទី៤៖ ភាពខុសគ្នានៅពេលមានព្យាង្គតម្រួតក្នុងភាសាសំស្រ្កឹត ដែលមានព្យញ្ជនៈ «រ» ភាសាបាលីប្រើព្យញ្ជនៈ ដូចជា៖

ពាក្យសំស្រ្កឹត (ក្ត)	ពាក្យបាលី (ត្ត)	អត្ថន័យ
រក្ត	រត្ត	ក្រហម
ភក្ត	ភត្ត	អាហារ
ពាក្យសំស្រ្កឹត (ឌ្គ)	ពាក្យបាលី (គ្គ)	អត្ថន័យ
ខឌ្គ	ខគ្គ	ព្រះខន្ធ
ពាក្យសំស្រ្កឹត (ត្ក)	ពាក្យបាលី (ក្ក)	អត្ថន័យ
សត្ការ	សក្ការ	សក្ការៈ
ពាក្យសំស្រ្កឹត (ត្ប)	ពាក្យបាលី (ប្ប)	អត្ថន័យ
ឧត្បាត	ឧប្បាត	ឧប្បាត/ចង្រៃ
ឧត្បល	ឧប្បល	ឈូក
ពាក្យសំស្រ្កឹត (ប្ត)	ពាក្យបាលី (ត្ត)	អត្ថន័យ
គុប្ត	គុត្ត	រក្សា
សប្ត	សត្ត	៧

ករណីទី៥៖ វាក្យសព្ទសំស្រ្កឹតដែលមាន ព្យញ្ជនៈកណ្តាល «វ៌» ឬ «វ្យ» ត្រូវនឹងវាក្យសព្ទបាលីដែលប្រើព្យញ្ជនៈ «ប្ប» ដូចជា៖

ពាក្យសំស្រ្កឹត («វ៌» ឬ «វ្យ»)	ពាក្យបាលី (ព្វ)	អត្ថន័យ
សវ៌	សព្វ	ទាំងពួង
បុវ៌	បុព្វ	មុន
បវ៌ត	បព្វត	បវ៌ត

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និវាណ	និព្ពាន	និព្វាន
ទិវ្យ	ទិព្ព	ទិព្វ

ករណីទី៦៖ ពាក្យសព្ទសំស្ក្រឹតដែលមាន ព្យញ្ជនៈស្មៀត «ដ» ឬ «ត» ជាមួយ «យ» ត្រូវនឹងពាក្យសព្ទបាលីដែលប្រើព្យញ្ជនៈ «ច» ដូចជា៖

ពាក្យសំស្ក្រឹត (ដ្យ)	ពាក្យបាលី (ច្ច)	អត្ថន័យ
នាដ្យ	នច្ច	នាដ្យ រាំ
ពាក្យសំស្ក្រឹត (ត្យ)	ពាក្យបាលី (ច្ច)	អត្ថន័យ
និត្យ	និច្ច	ជានិច្ច
សត្យ	សច្ច	សច្ច
អាទិត្យ	អាទិច្ច	អាទិត្យ
ពាក្យសំស្ក្រឹត (ណ្យ)	ពាក្យបាលី (ញ្ញ)	អត្ថន័យ
បុណ្យ	បុញ្ញ	បុណ្យ
អរណ្យ	អរញ្ញ	ព្រៃ
ពាក្យសំស្ក្រឹត (ន្យ)	ពាក្យបាលី (ញ្ញ)	អត្ថន័យ
គូន្យ	សុញ្ញ	សូន្យ ទីសុញ្ញអាកាស
សាមាន្យ	សាមញ្ញ	សាមញ្ញ
ពាក្យសំស្ក្រឹត (ទ្យ)	ពាក្យបាលី (ជ្ជ)	អត្ថន័យ
វិទ្យា	វិជ្ជា	វិទ្យា វិជ្ជា
វិទ្យុត	វិជ្ជុ	ខ្សែមេឃ
ពាក្យសំស្ក្រឹត (ធ្យ)	ពាក្យបាលី (ជ្ឈ)	អត្ថន័យ
មធ្យម	មជ្ឈិម	មធ្យម មជ្ឈិម
ពាក្យសំស្ក្រឹត (ថ្យ)	ពាក្យបាលី (ច្ឆ)	អត្ថន័យ
មិថ្យា	មិច្ឆ	ខុស
រថ្យា	រច្ឆា	ផ្លូវ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ករណីទី៧៖ ភាពខុសគ្នានៅពេលមានព្យាង្គតម្រួតក្នុងភាសាសំស្ក្រឹត ដែលមានព្យញ្ជនៈ «រ» ភាសាបាលីប្រើព្យញ្ជនៈ ដូចជា៖

ពាក្យសំស្ក្រឹត (ឞ្ណ)	ពាក្យបាលី (ណ្ហ)	អត្ថន័យ
ឧឞ្ណ	ឧណ្ហ	ក្ដៅឧណ្ហៗ
តឫឞ្ណា	តណ្ហា	តណ្ហា
ពាក្យសំស្ក្រឹត (ស្ម)	ពាក្យបាលី (ម្ហ)	អត្ថន័យ
វិស្មយ	វិម្ហយ	ពិសម័យ/ភ្ញាក់ផ្អើល
ពាក្យសំស្ក្រឹត (ឝ្ន)	ពាក្យបាលី (ញ្ហ)	អត្ថន័យ
ប្រឝ្ន	បញ្ហ	ប្រស្នា បញ្ហា

ករណីទី៨៖ ភាពខុសគ្នានៅពេលភាសាសំស្ក្រឹតមាន ព្យញ្ជនៈ «ហ» នៅក្នុងព្យញ្ជនៈប្រកបកណ្ដាលពាក្យ វាក្យសព្ទបាលីលប់ចោលប្រើព្យញ្ជនៈ «ហ» ដូចជា៖

ពាក្យសំស្ក្រឹត	ពាក្យបាលី	អត្ថន័យ
ជិហ្វា	ជិវ្ហា	ជីវ្ហា/អណ្ដាត
សាយាហ្ន	សាយណ្ហ	សាយណ្ហ/ពេលល្ងាច
ហ្រទ	រហទ	រហាល់/អណ្ដូងទឹក

ករណីទី៩៖ ភាពខុសគ្នានៅពេលភាសាសំស្ក្រឹតមានដូចជា៖

ពាក្យសំស្ក្រឹត	ពាក្យបាលី	អត្ថន័យ
តបស	តប	ការប្រព្រឹត្តធម៌
មនស្	មន	ចិត្ត
វយស	វយ	វ័យ
វបុស	វបុ	កាយ

ភគវត	ភគវន្តុ	អ្នកមានជោគ
អាស្រម	អស្សម	អាស្រម
រាស្ត្រ	រដ្ឋ	រាស្ត្រ រដ្ឋ
ក្ឫតា	កតា	ក្រឹត
អម្ឫត	អមត	អមត អម្រឹត
ឫទ្ធិ	ឥទ្ធិ	ឥទ្ធិ ឫទ្ធិ
សិក្សា	សិក្ខា	សិក្សា សិក្ខា
វិគ្រហ	វិគ្គហ	ពិគ្រោះ
បស្ចឹម	បច្ឆិម	បស្ចិម
ប្រមោទ្យ	បាមោជ្ជ	ប្រាមោទ្យ
ឧបាធ្យាយ	ឧបជ្ឈាយ	ឧបជ្ឈាយ៍
ជ្ញាតិ	ញាតិ	ញាតិ
ប្រជ្ញប្តិ	បញ្ញត្តិ	បញ្ញតិ
ការុណ្យ	ការុញ្ញ	ករុណា
ស្ថាន	ឋាន	ស្ថាន ឋាន
ស្ថិត	ឋិត	ស្ថិត
ស្ថាបនា	ឋាបនា	ស្ថាបនា ឋាបនា
គ្រហស្ថ	គហដ្ឋ	គ្រហស្ថ
ឱស្ឋ	ឱដ្ឋ	មាត់
បរិបូណ៌	បរិបុណ្ណ	បរិបូណ៌
នេត្រ	នេត្ត	នេត្រ
សត្វ	សត្ត	សត្វ
ស្ថាវរ	ថាវរ	ស្ថាពរ
ស្តូប	ថូប	ស្តូប

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិស្តារ	វិត្ថារ	ពិស្តារ វិត្ថារ
សស្ត្រ	សត្ថ	សស្ត្រា
ប្រមាទ	បមាទ	ប្រមាទ
ប្រមាណ	បមាណ	ប្រមាណ
ប្រតិបត្តិ	បដិបត្តិ	ប្រតិបត្តិ បដិបត្តិ
និម៌ល	និម្មល	និមល
អាស្រយ	អាសយ	អាស្រ័យ
ស្វត៌	សគ្គ	សួគ៌
ឥស្វរ	ឥស្សរ	ឥស្សរ
បុស្យ	បុស្ស	បុស្ស
មនុស្យ	មនុស្ស	មនុស្ស

និន្នាការក្នុងការប្រើភាសាបាលី ឬសំស្ក្រឹតដែលងាយអាន និងនិយាយជាភាសាខ្មែរ និងមានមួយ ឬពីរព្យាង្គ។

ឧទាហរណ៍៖

ពាក្យសំស្ក្រឹត (៣ព្យាង្គ)	ពាក្យបាលី (២ព្យាង្គ)	ខ្មែរ (១ព្យាង្គ)
ទិវ្យ	ទិព្វ	ទិព្វ
សប្ត	សត្ត	សប្ត

ភាសាខ្មែរកណ្តាលបានប្រើព្រះរាជសព្ទ និងពាក្យប្រើសម្រាប់ព្រះសង្ឃបានយ៉ាងបរិបូណ៌ពេញលេញ ជាភាសា។

ភាសាខ្មែរកណ្តាលបានវិវត្តយ៉ាងលឿន ដោយបង្កើតជាក្បួនច្បាប់វេយ្យាករណ៍សម្បូណ៌បែបសម្រាប់ទាំងភាសានិយាយនិងភាសាសរសេរ។ ក៏ប៉ុន្តែ គេសង្កេតឃើញថានៅមិនទាន់មានសង្គត្តភាពក្នុងការសរសេរពាក្យ។

គេមិនឃើញមានស្នាកស្នាមនៃឥទ្ធិពលសៀម និងកម្ចីពាក្យសៀម

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងភាសាខ្មែរកណ្ដាល សម័យលង្វែកឡើយ។ នេះគឺជាតឹកតាងបញ្ជាក់ថា កម្ពុជាសម័យលង្វែកនៅជារដ្ឋមួយដ៏សំខាន់ និងរឹងមាំនៅអាស៊ីអាគ្នេយ៍ ហើយក៏ជាគូប្រកួតប្រជែងដ៏សំខាន់នៃក្រុងអយុធ្យាដែរ។

៣.២.៤. ពាក្យសព្ទខ្មែរកណ្ដាល

នៅសម័យកណ្ដាលមានលេចឡើងនូវពាក្យសព្ទជាច្រើន ដែលមិនមែនជាភាសាខ្មែរចាស់ ហើយដែលជាពាក្យបង្កើតថ្មី ដែលនៅបន្តប្រើនៅក្នុងភាសាខ្មែរទំនើប។

IMA	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	គ្នា	គ្នា
	ឥលូ	ឥលូវ
	ឥនាម្ប្យ	នរណាម្នាក់
	ឥត	ឥត
	ត្លៀនា	ឯណា
	ជ្រោម	ជ្រោមជ្រែង
	ជុំម	ជុំ
	ជួយ	ជួយ
	ជុប	ជុប
	ក	កសាង
	កស	គាត់
	ជុំមឃ្វី	ជំងឺ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

	ក្រេង	ក្រែង
	ក្រោ្យ	ក្រោយ
	កុំលុង	កំឡុង
	លែង	លែង / ឈប់ / ចាកចោល
	លែងបាន	សូមឱ្យបាន
	ក្រៃលែង	ណាស់
	ល្អហ	ល្អ
	លា	លា
	លាញ	រងគ្រោះ ផុះឆ្ងាយ
	ណាយ	ណាយ
	ណ្ដោះលែង	ដោះលែង
	មិញ	តាមហ្នឹង (យ៉ាងណាមុិញ)
	ម្ដាយ	ម្ដាយ
	ម្ដោង	ម្ដង
	មុហ្និ	នេះ
	មុន	មុន
	ម្ដ៉ង	ម្ដង
	ននាមួយ	នរណាមួយ

៣.៣. អត្ថរូបនៃសិលាចារឹកនគរវត្ត

«សិលាចារឹកនគរវត្ត» ត្រូវបានចារពីអំឡុង គ.ស.ឆ្នាំ១៥៦៦ ឬមហាសករាជឆ្នាំ១៤៨៨ (IMA-4) ដល់ គ.ស.ឆ្នាំ១៧៤៧ ឬមហាសករាជឆ្នាំ ១៦៦៩ (IMA-39) ពោលគឺ ក្នុងរយៈពេលជិត២០០ឆ្នាំ ហើយត្រូវបានរៀបចំតាមលំដាប់ឆ្នាំពីលេខ១ ដល់លេខ៣៩។ សិលាចារឹកពីលេខ១ ដល់លេខ៦ ចារនៅសម័យលង្វែក ចំណែកសិលាចារឹកពីលេខ៧ ដល់លេខ៤០ ចារនៅសម័យឧដុង្គ។ សិលាចារឹកលេខ៤ មានកាលបរិច្ឆេទ ស.ក.១៤៨៨ ដែលត្រូវនឹងគ.ស.១៥៦៦ គឺចារនៅក្នុងរជ្ជកាលព្រះបាទច័ន្ទរាជា (១៥២៩-១៥៦៦)។ សិលាចារឹកលេខ៤ គឺជាសិលាចារឹកដែលចារមុនគេបង្អស់នៅក្នុងសម័យលង្វែក។

លោក AYMONIER បានសិក្សាមុនគេ និងបកប្រែជាភាសាបារាំងនៅក្នុងទស្សនាវដ្ដី Journal Asiatique ទីក្រុងប៉ារីស នៅក្នុងឆ្នាំ១៨៩៩-១៩០០។ ព្រះមហាពិទូរ ក្រសេម ដែលជា គន្ថរចនបណ្ឌិត នៃព្រះរាជបណ្ណាល័យកម្ពុជាបានរៀបចំធ្វើវចនាធិប្បាយលើពាក្យដែលគេកម្រជួបប្រទះ ហើយ «សិលាចារឹកនគរវត្ត» ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៣៨ ហើយបទានុក្រមត្រូវបានបោះពុម្ពនៅឆ្នាំ១៩៥៨។ ដូចនេះ ព្រះមហាពិទូរ ក្រសេម គឺជាអ្នកប្រាជ្ញខ្មែរទីមួយ ដែលរៀបចំមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាខ្មែរ នៅក្នុងប្រទេសកម្ពុជា។

ប្រាសាទអង្គរវត្តបានក្លាយជាបូជនីយដ្ឋានដ៏សំខាន់សម្រាប់ពុទ្ធសាសនិកជន ជាពិសេសសម្រាប់រាជវង្សានុវង្ស និងមន្ត្រីសេនាបតី។ ក្នុងដំណាក់កាលប្រវត្តិសាស្ត្រដ៏សំខាន់ទាំងនៅក្នុងសម័យលង្វែក សម័យអន្តរកាលពីលង្វែកមកឧដុង្គ និងនៅក្នុងសម័យឧដុង្គ ក៏សិលាចារឹកនគរវត្តមិនបានលើកឡើងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមកនិយាយដែរ។

អត្ថន័យនៃ «សិលាចារឹកនគរវត្ត» គឺការធ្វើបុណ្យផ្សេងៗ ការប្រោសខ្ញុំឱ្យរួចជាអ្នកជាការបំបួសមនុស្ស លាបំណន់ សាងរូបបដិមា សាងពិតាន និង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថ្វាយរបស់ជាពុទ្ធបូជា ដោយព្រះរាជា មន្ត្រី និងប្រជារាស្ត្រធម្មតា។ សិលាចារឹកភាគច្រើនកត់ត្រាពីអំណោយព្រះពុទ្ធរូបដល់វត្តអារាម និងការធ្វើបុណ្យសន្សំកុសល តាមរយៈការដោះលែងខ្ញុំទាសករឱ្យមានសេរីភាពរស់នៅជាអ្នកជា។ ទន្ទឹមនឹងនេះ ក៏មានសិលាចារឹកមួយចំនួនតូច ដែលផ្តល់ទិន្នន័យប្រវត្តិសាស្ត្រ ចាប់ពីពាក់កណ្តាលសតវត្សទី១៦ ដល់ដើមសតវត្សទី១៨។ សិលាចារឹក «បាកាន» ចារអំពីការធ្វើបុណ្យសន្សំកុសលនៅតាមទីវត្តអារាម។ សិលាចារឹកនេះក៏បាននិយាយអំពីការជួលជុលប្រាសាទអង្គរនៅឆ្នាំ១៥៧៧, ១៥៨៧, និង១៦៩៣។ សិលាចារឹកទាំងនេះប្រហែលជាចារនៅក្នុងសតវត្សទី១៥។

លោកស្រីបណ្ឌិត ពៅ សាវរស ចាត់ទុកអត្ថបទក្នុងសិលាចារឹកនគរវត្តថាជាអត្ថបទ ដែលមានលក្ខណៈជា «សច្ចាប្រណិធាន» (satyapraṇidhān) (សច្ច+បណិធានឬសត្យ+ប្រណិធាន) ពោលគឺការតាំងប្រកាសពាក្យពិតឬការសំបូងសង្រួង ដែលពុទ្ធសាសនិកបួងសួងសុំសម្រាប់ខ្លួនឯង ឬអ្នកដទៃ (LEWITZ, 1970)។ លោកស្រីបណ្ឌិតបានសិក្សា «សិលាចារឹកនគរវត្ត» ហើយបែងចែកតាមប្រធានបទចំនួន៦ធំ។ (Saveros LEWITZ, 1970; 1971; 1972a; 1972b; 1973a; 1973b)។

សិលាចារឹកនគរវត្ត មានគោលដៅសម្តែង «សច្ចាប្រណិធាន» ចំពោះព្រះពុទ្ធជាអម្ចាស់ ទៅតាមប្រពៃណីនៃព្រះពុទ្ធសាសនា។ សាសនិកជនមានសទ្ធាជ្រះថ្លា ធ្វើបុណ្យ សាងកុសល ដូចជាកសាងប្រាសាទ ព្រះពុទ្ធរូប ហើយឧទ្ទិសកុសលផលបុណ្យនេះ ចំពោះបុព្វការីជន និងបួងសួងសុំឱ្យជាតិក្រោយសម្រេចបានដូចបំណងប្រាថ្នា។

៣.៣.១. សច្ចាប្រណិធាននៃឱកញ្ញាអគ្គយរាជ

នៅឆ្នាំ១៥២១ សុក្ក ដែលត្រូវជា គ.ស.ឆ្នាំ១៥៩៩ (IMA.6) ឱកញ្ញាអគ្គរាជបានទៅកាន់ស្ថានព្រះពិស្នុលោក (ប្រាសាទអង្គរវត្ត) និងមានចិត្តសទ្ធាសាងប្រាសាទបួនមុខ ដោយថ្វាយព្រះថ្ម ព្រះសំណា និងរៀបចំក្រយា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បូជា និងនិមន្តព្រះសង្ឃមកធ្វើការប្រោះព្រំមង្គល ដើម្បីជាផលានិសង្ស ដើម្បីបង្ហាញពីកតញ្ញូ និងកតវេទីរបស់ឱកហ្ញុងអគ្គរាជ ដើម្បីជូនជាកុសលផលបុណ្យដល់មាតាបិតា។ ឱកហ្ញុងអគ្គរាជបានឧទ្ទិសតេជះផលានិសង្សនេះឱ្យរួចផុតពីទុក្ខភ័យ កុសលផលបុណ្យដល់ព្រះសិអារ្យមេត្រីយ។

ភាសាខ្មែរកណ្តាលមានការវិវត្តរីកចម្រើនផងដែរ។ សិលាចារឹកនគរវត្តលេខ ២,៥ និង៦ សរសេរពីសច្ចាប្រណិធាននៃឧត្តមមន្ត្រីខ្មែរ នៅក្នុងសតវត្សទី១៦ ដែលមានគោរមងារជា អកហ្ញុង និងមាននាមផ្លូវការ អកយរាជ និងភរិយាអ្នកអកធម្ម៌។ សិលាចារឹកទាំងនេះត្រូវបានលោក AYMONIER និងលោកស្រីបណ្ឌិតពៅ សាវរស យកមកសិក្សាម្តងរួមមកហើយ។ យើងនឹងពិភាក្សាជាថ្មីពីទស្សនវិស័យនៃការវិវត្តភាសាខ្មែរសម័យកណ្តាល ដោយប្រៀបធៀបនឹងភាសាខ្មែរទំនើប។ គោរមងារ អកហ្ញុង ត្រូវបានផ្តល់ជូនឧត្តមមន្ត្រីដែលមានឋានៈបន្ទាប់ ឧកញ៉ា និងព្រះ (Savaros LEWITZ, 1971)។ សិលាចារឹកលេខ២, ៥, ៦ និង៧ ត្រូវបានចារដោយកិក្ខុ ឥន (ក្នុង IMA-4B បន្ទាត់ទី១២)។ សិលាចារឹកលេខ២ ចារនៅចុងរជ្ជកាលព្រះបាទច័ន្ទរាជា នៅគ.ស.១៥៦៦ (ស.ក.១៤៨៨) ចំណែកឯសិលាចារឹកលេខ៦ ចារនៅក្នុងគ.ស.១៥៩៩ ក្រោយបែកលង្វែកទៅហើយ។

សិលាចារឹកលេខ២ (ស.ក.១៤៨៨-គ.ស.១៥៦៦) គឺជាសិលាចារឹកដែលចាស់ជាងគេ ចារនៅចុងរជ្ជកាលព្រះបាទច័ន្ទរាជា។ ព្រះអង្គ គឺជាព្រះមហាក្សត្រ ដែលបានបង្កើតរាជធានីនៅលង្វែកចាប់ពីគ.ស.១៥២៩ បន្ទាប់ពីព្រះអង្គឈ្នះសង្គ្រាមក្នុងស្រុកជាមួយស្តេចកន ដែលបន្ទាយពេលអស់ពេល ៩ឆ្នាំ (គ.ស. ១៥១៦-១៥២៥)។

សុតមស្ត

មហាសករាជឆ្នាំ ១៤៨៨ (គ.ស.១៥៦៦) ឆ្នាំខាល ជាថ្ងៃនក្ខត្តឫក្សពេញបូរមី កើតខែមិខសិរ ថ្ងៃព្រហស្បតិ៍។ មានអកហ្ញុងអកៃរាជ និងអ្នកអកធម្ម៌ មានចិត្រសទ្ធាចាប់ផ្តើមសាងព្រះវិហារនោះ នៅឆ្នាំឋោះ នៅពេល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់ឧកញ៉ាឱង។ លុះដល់ឆ្នាំខាល នៅពេលអ្នកព្រះឱង្ការព្រើត្រនីព្វាន ទើបចប់ស្រេច។ គាត់ទាំងប្តីប្រពន្ធបានជាវមាសមកបិតព្រះពុទ្ធរូបកម្ពស់១៨ហត្ថ និងព្រះពុទ្ធរូបថ្ម៥ ព្រះអង្គ ព្រះមាស១ ព្រះប្រាក់១ និងសាងព្រះចេតិយដាំព្រះស្រីមហាពោធិ៍ សាងរូបព្រះអភិធម្ម មហាជាតក។

លុះចប់ស្រេច ទើបបញ្ចុះសីមាបំបួសអាត្មាសច្ចាំយកទាសាទាសីខ្ញុំស្រីខ្ញុំប្រុស ឈ្មោះអាចាន១ អាកែវ១ មេសុត១ មេអន១ មេនៃយ១ មេសរ ១ មេរស១ មេសម១ មេហង១ មេគាម១ អានោក១ អាកន១ អាសែន អាស្រីយ១ អាជោត១។ រីឯញោមទាំងអំបាលនេះសឹងថ្វាយជាញោមព្រះពុទ្ធរូបនៅសម្រាប់ព្រះវិហារជាទីនៅនេះ។ រីឯក្មេងប្រុសទាំង៣នេះ គាត់យកជាចៅតាំងពីនៅគ្រហស្ថមកបំបួស ជាពណ្ណស្រម ឱយនៅសម្រាប់ថែរក្សាព្រះវិហារនេះ ឱយអ្នកមហាថេរ ឪទៃ យកជាគ្រងរក្សាញោមទាំងនេះ ទោះព្រះមហាថេរឪទៃយក្តថា បំបួសសោតសាមណេរទាំង៣នេះ ទោះបីសាមណេរមួយនៃអ្នកបួសបរិបូណ៌បានឧបសម្បត្តិ (ក្លាយជាភិក្ខុ) ឱយគ្រងអស់ញាតិគាត់ទាំងអំបាលនេះវិញ តាង (ជំនួស) ព្រះមហាថេរឪទៃយកថាវិញ។

រីឯចៅហ្វូងវង្សាភិនេតនូចោព្រំម្ម ឱយជួយរក្សាកុំឱ្យមានអ្នកនិន្ទាបៀតបៀនវាឱយអន្តរាយព្រះពុទ្ធរូបនោះឡើយ។ ទោះបីមានបងប្អូនកូនក្មួយប្រាំពីរសន្តាន កល្យានមិត្តសម្លាញ់ជាពិសេសព្រះមហាក្សត្រ រាជកូលមន្ត្រីយចតុរង្គសេនាបតិយសុភា សុថានក្តី ទោះបីគេមកអង្វរក្តី ធ្វើឱយអន្តរាយទានព្រះពុទ្ធរូបនេះក្តី សូមឱ្យអ្នកទាំងនោះទៅនៅចតុរាបាយភូមិនិងមហាអវិចិយនរក កុំឱ្យឱយព្រះពុទ្ធអំបាលខ្សាច់កុំឱ្យប្រោសអ្នកនោះបានឡើយ។ «ឥទំ មេ ទានំ សព្វញ្ញុតញ្ញាណំ បច្ច័យំ សបច្ចយោ ហោតុ» (សូមឱយទានជាបច្ច័យនាំខ្ញុំទៅកាន់សព្វញ្ញុតាញ្ញាណំ ឬនិព្វានហោង)។

អ្នកចោពិស ឥនជួយសាងស្នាដៃនៅ សុកមស្ត មហាសករាជឆ្នាំ១៥០២ (គ.ស.១៥៨០) ឆ្នាំចរ ថ្ងៃនក្ខត្តឫក្ស ខែបុស្ស ថ្ងៃអាទិត្យពេញបូណ៌មី។ ឱកហ្លួងអកែរាជមានចិត្តសទ្ធា សាងប្រាសាទថ្មត្រលែងកែង (មុខ៤) មួយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងព្រះពុទ្ធរូបថ្ម៤ ទុកនៅបញ្ចប្រាសាទ (ប្រាំជាន់) ព្រះពុទ្ធរូបសំណ១ ព្រះសិរីទ្ធ១ ព្រះទង់ដែង១ ភិមព្រះពុទ្ធ រូបតិ (ដី) ១ ព្រះក្អុក១ ព្រះខ្ទឹមច័ន្ទ ១ ព្រះមោគលាន ព្រះសារិបុត្រ ព្រះបទ្ម១ បញ្ចុះព្រះធាតុ កាត់ទង់ ធ្វើឆ័ត្រ ឱយទានបាយទឹក សំពត់មាសប្រាក់ និងស្វាម្ពុ ក្រយា បំពេញចិញ្ចឹមៗ សូម ផលានិសង្សនេះចម្រើនដល់អស់ពួកទេពតាផងទាំងឡាយខាងលើ និងដល់ អកនិស្ឋព្រហ្ម (នៅខ្ពស់បំផុត) ចម្រើនទៅក្សត្រាធិរាជ រាជវង្ស មន្ត្រី ចតុរង សេនាបតី និងម្តាយឪពុក បងប្អូនកូនៗ

អ្នកចៅកិក្ខុអំម អ្នកសិត ជាសាក្សីពេជញាណឧត្តមជួយអនុមោទនា ញាតិប្រាំពីរសន្តាន និងមិត្តសំលាញ់ អ្នកដែលមានគុណសប្បុរសដែល ចិញ្ចឹម ទោះអ្នកទាំងនេះវង្វេងទៅឯនរកចតុរាបាយភូមិ សូមឱ្យអ្នកទាំងនេះ រួចលែងភ័យចតុរាបាយ ពណ្ណរាយ និងសម្រេចបានសម្បត្តិទាំងបីវិញហោង។ សូមតេជះផលានិសង្សនេះជូនទៅសត្វនរកផងទាំងឡាយដល់អវិចិនរកភូមិ។ សូមតេជះផលានិសង្សនេះជូនទៅសត្វនរកផងទាំងឡាយដល់នៅទសសហ (១០ពាន់) ចក្រវាឡៗ គាត់ (អកហ្វងអកៃរាជ) សុំជាឧបាសករត្ននៃព្រះ សិអារ្យមេត្រីពោធិសត្វ លើកសាសនា មានចិត្រសទ្ធាបានបួសដោយព្រះវិន័យ កើតទៅជាទេវត្រិង្សមហាបុរស (មហាបុរសដែលមានគ្រប់លក្ខណសម្បត្តិ ៣២) កុំប្បីឱ្យថយសម្បត្តិឡើយ។ សូមទៅកើតអ្នកដែលមានត្រកូលសន្តាន យសតស្សរ (ខ្ពង់ខ្ពស់) សូមមានហត្ថិរតអាជានេយ្យរត សូមមានអាហារទិព្វ សម្លៀកបំពាក់ទិព្វ ប្រិមប្រិយ បចេយោ ហោតុ។

សិលាចារឹកលេខ៥ (គ្មានកាលបរិច្ឆេទ) ចារក្នុងរជ្ជកាលព្រះបាទ ជ័យជេដ្ឋាទី១ (នៅក្នុងសម័យលង្វែក) ពិពណ៌នាពីអ្នកអកហ្វង អកយរាជ បានស្បថថា៖«ទោះកូនអញឯងក្តី ក្មួយអញក្តី ទោះចៅអញក្តី ជាព្រះសង្ឃក្តី អស់ក្មួយ កូនចៅទាំងនេះអញពុំឱយដឹងឡើយ ឱយបំពេញដូចក្រិស្នា ជាលិយ ដល់ចូលនិព្វានហោង»។

សិលាចារឹកលេខ៦ ចារដោយអ្នកចៅកិក្ខុ ឥន ដោយពិពណ៌នាថា នៅ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មហាសករាជឆ្នាំ១៥២១ ត្រូវជាគ.ស.ឆ្នាំ១៥៩៩ ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី១ (ក្រោយបែកលង្វែក) អកហ្លួង អភ័យរាជ និងអ្នកចៅកិត្តុសរ ឱកបាកខាវ មកស្ថានព្រះពិស្ណុលោក (អង្គរវត្ត) ដែលជាស្ថានជុំនុំនៃទេវតា និងទេវតារក្សាព្រះរាជាណាចក្រកម្ពុជា និងមានចិត្តសទ្ធាសាងប្រាសាទបួនមុខ និងថ្វាយព្រះ និងថ្វាយតង្វាយបូជាព្រះ ហើយបួងសួងសូមឱ្យកុសលផលបុណ្យ និងតេជះនៃផលានិសង្សនេះសូមរំដោះឱ្យរួចលែងភ័យចតុរាបាយទៅពណ្ណរាយដោយសម្បត្តិសម្បូណ៌បីប្រការវិញ ដើម្បីចូលនគរនិព្វាន សូមឱ្យតេជះនៃសម្ដេចព្រះមហាស្រីរតនត្រៃ និងតេជះសក្តិសិទ្ធិនៃទេវតារក្សាព្រះរាជាណាចក្រជួយជ្រោម រក្សាឱកហ្លួងអភ័យរាជសូមចម្រើនពរមង្គលទាំងអស់ ថែមទាំងមានសមុឬទ្ធិ ស្ថិរ ទិឃាយុ សុខ សួស្តាធិការ (សួស្តីត្រៃលែង) ឈ្នះអស់សត្រូវដែលមានចិត្តមកបៀតបៀនកម្ពុជទេស និងសូមឱ្យកម្ពុជទេសនេះមានសុខក្សេមក្សាន្ត កុំឱ្យមានចលាចលឡើយ។

៣.៣.២. សច្ចាប្រណិធាននៃសម្ដេចព្រះជ័យជេដ្ឋាធិរាជ

សិលាចារឹកនគរវត្តចំនួនពីរ ដែលត្រូវបានចារនៅក្នុងរាជ្យព្រះបាទសត្ថាទី១ គឺសិលាចារឹកលេខ២ ដែលមានកាលបរិច្ឆេទឆ្នាំ១៥៧៧ (មហាសករាជឆ្នាំ១៤៩៩) និងសិលាចារឹកលេខ៣ ចារនៅឆ្នាំ១៥៧៩ (មហាសករាជឆ្នាំ១៥០១)។

សិលាចារឹកលេខ២ គឺជាការសម្ដែង នូវសទ្ធារបស់សម្ដេចព្រះរាជមាតាមហាកល្យាណវត្តី ស្រីសុជាតា ដែលយល់ដល់ស្ដេច ព្រះរាជបុត្រ (ព្រះបាទជ័យជេដ្ឋាធិរាជ នៅក្នុងសិលាចារឹកលេខ៣) ដែលទ្រង់មានសទ្ធាជួសជុលប្រាសាទអង្គរវត្ត ឱ្យបរិបូណ៌ដូចបុរាណវិញ។ ព្រះអង្គបានកោរព្រះកេស និងសាងព្រះពុទ្ធរូបនៅបាកាណ ហើយមានសច្ចាទិដ្ឋាន សូមឱ្យក្លាយទៅជាឧបាសករតនសុំសីលប្រាំ។ លុះអស់អាយុទៅសម្ដេចព្រះរាជមាតាសុំឱ្យតេជៈនៃផល្លានិសង្សនោះជួយទ្រង់មានកំណើតជាមហាបុរស ប្រកបដោយធញ្ញបុញ្ញ (សម្បត្តិមានបុណ្យ) ស្មោះស្ម័គ្រនឹងព្រះពុទ្ធសាសនា សុំបម្រើដល់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្តេចព្រះសិរិអាមេត្រីជាឧបាសក និងសុំបានស្តាប់ធម៌ត្រាស់ដឹង៣៧ប្រការ។

ចំណែកឯសិលាចារឹកលេខ៣ គឺជាសុចរិតវាចា សច្ចាប្រណិធាននៃសម្តេចព្រះជ័យជេដ្ឋាធិរាជ (ព្រះបាទសត្ថា) កាលដែលព្រះអង្គបានឡើងសោយរាជ្យសម្បត្តិគ្រងរាជ្យ ស្តេចមានព្រះរាជប្រាថ្នាសាង (ជួសជុល) មហាប្រាសាទព្រះពិស្ណុលោក (អង្គរវត្ត) លើកថ្មដាក់កំពូលទាំង៩ នៃប្រាសាទ សំអាតពិចិត្របិតមាសផងដែរ។ ព្រះរាជកុសលនេះព្រះអង្គសូមថ្វាយទៅអតីតព្រះមហាក្សត្របួនអង្គ ជាពិសេសសម្តេចព្រះវររាជបិតា និងព្រះញាតិប្រាំពីរសន្តានទាំងឡាយ ឱ្យពណ្ណរាយឮដំត្រិពិធសម្បត្តិ ហើយសម្តេចព្រះមហាឧបាសករំពឹងប្រាថ្នា ដើម្បីសាងសាសនាព្រះតថាគត ឱ្យប្រាកដឮដំកម្ពុជទេស លើកយសព្រះរាជសន្តានឱ្យបរិបូណ៌ដូចមុនវិញ កុំបីមានធម្មន្តរាយឡើយ។ នៅពេលដែល សម្តេចព្រះភគវតិ ត្រៃចក្រពត្តិ អគ្គរាជមហេសី ព្រះពិធរណិន្ទ្រជេយ្យរាជទេពិត្រធម្មធិតាបពិត្រ ទ្រង់មានគភ៌នោះ សម្តេចមានចិន្តាប្រាថ្នានាំព្រះរាជបុត្រនេះព្រះរាជអធិស្ឋាន ថ្វាយជាឧបាសកឧបាសិកា ដើម្បីទំនុកបម្រុងដល់ព្រះមហាត្រៃរតនត្រៃ ស្មោះស្ម័គ្រនឹងសាសនាព្រះតថាគត។ ដោយតេជៈនៃផលានិសង្ស ដែលសម្តេចព្រះមហាឧបាសកស្មោះពំនាក់ឮដំព្រះមហាត្រៃរតនត្រៃឥតបីល្អៀងឡើយ ទើបទេពបុត្តមកកើតក្នុងផ្ទៃនៃសម្តេចព្រះរាជទេពី មានកំណើតព្រះរាជបុត្រប្រកបនូវលក្ខណៈឧត្តមសមនូវព្រះលក្ខណាភាសី សឹងបរិបូណ៌ នៅថ្ងៃពុធ ១៤រោចខែអាសាធ ឆ្នាំថោះ មហាសករាជ១៥០១ (គ.ស.១៥៧៩)។ លុះដល់ថ្ងៃអាទិត្យគំរប់១២ថ្ងៃ មានជំនុំសម្តេចព្រះរាជមាតាបពិត្រ និងរាជគ្រូហោរាព្រាហ្មណាចារ្យផង ដើម្បីធ្វើពិធីដែលសម្តេចព្រះរាជបិតាបពិត្រមានព្រះទ័យប្រសិទ្ធិព្រះនាមដល់សម្តេចព្រះរាជឱរសជាសម្តេចព្រះបរមរាជាធិរាជ។ ស្តេចនាំសម្តេចព្រះបរមរាជាធិរាជ ព្រះរាជឱរសមកព្រះពិស្ណុលោក ជាស្ថានជំនុំនៃទេព។

សិលាចារឹកទាំងពីរនេះបង្ហាញពីភាពខុសគ្នារវាងព្រះនាមព្រះមហា-

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្សត្រសម័យលង្វែក នៅក្នុងព្រះរាជពង្សាវតារ ដែលសរសេរនៅសតវត្ស ទី១៩ និងសិលាចារឹកដែលចារនៅសម័យនោះ។ ពោលគឺព្រះនាមសោយរាជ្យ នៃព្រះមហាក្សត្រនៅពេលនោះ គឺ ព្រះជ័យជេដ្ឋាធិរាជ ដែលពេលប្រសូត ព្រះអង្គមានព្រះនាមថា សម្តេចព្រះបរមរាជាធិរាជ។ ដូចនេះ លោក VICKERY បានលើកឡើងថាព្រះមហាក្សត្រដែលសោយរាជ្យនៅសម័យនោះ មិនមែន ព្រះនាមព្រះបាទបរមរាជា (១៥៦៦-១៥៧៦) ទេ តែគឺជាព្រះបាទជ័យ ជេដ្ឋាធិរាជ។ លោកបានលើកឡើងថា សិលាចារឹកភ្នំបាខែង K-285 (ឆ្នាំ១៥៨៣) ក៏បញ្ជាក់ថាព្រះរាជាសម័យនោះមានព្រះនាមជ័យជេដ្ឋាធិរាជដែរ។ ចំណែក ឯលោក Bernard Philippe GROSLIER វិញ ដោយលើកពីប្រកពបព្វជិត Manoel CARVALHO ប៉ាន់ស្មានថាព្រះរាជានៅឆ្នាំ១៥៩៩ មានព្រះជន្ម ប្រមាណ៦០ព្រះវស្សា ហើយបើតាមពង្សាវតារនេង ញៅញាតន់ ប្រសូតនៅ ឆ្នាំ១៥៧៩ នោះអ្នកចារចារឹកលេខ៣ គឺជាព្រះបាទបរមរាជាទី៤ (ព្រះសត្ថា) (១៥៧៦-១៥៨៦) នោះឯង។

សិលាចារឹកលេខ២

នេះគឺត្រីពិធ (បីប្រការ) សុចរិតសទ្ធានៃខ្ញុំព្រះអម្ចាស់សម្តេចព្រះរាជ មាតាមហាកល្យាណវត្តី ត្រីសុជាតា ឧត្តមជាតិក្សត្រី ព្រះមហាឧបាសិការតន បពិត្រ ថ្វាយបង្គំប្រណម្យទូលចំពោះព្រះវរបាទរពិន្ទ (ព្រះបាទផ្កាឈូកដ៏ មានសិរី) នៃសម្តេចព្រះមហាគ្រីវត្នត្រៃកម្រតែងយើង ដែលជាពុំនាក់ត្រើយ ត្រាណ បីដូចជាសំពៅធំដ៏ឧឡុង្គ នាំឆ្លងសមុទ្រ ពោល គឺជាកពជាតិវេទនា មិនចេះចប់។ ខ្ញុំអម្ចាស់មានសទ្ធាតម្កាចិត្តប្រព្រឹត្តិសាងសព្វកុសលរៀងមក លុះជាតិឥឡូវនេះ។ នេះគឺលុះដល់មហាសករាជ១៤៩៩ (គ.ស.១៥៧៧) ឆ្នាំឆ្លូវនក្ខត្តឫក្ស ទី១៤កើត ខែអាសាឍ ថ្ងៃសៅរ៍ខ្ញុំអម្ចាស់យល់ស្តេចព្រះរាជបុត្រ មានសទ្ធា សាង(ជួសជុល) ព្រះពិស្នុលោក កុម្មុជបុរាណនេះឱយបរិបូរ ដូចបុរាណវិញ។ ខ្ញុំអម្ចាស់ត្រេកអរអនុមោទនានូវស្តេចព្រះរាជបុត្រពេក ហោង។ ខ្ញុំអម្ចាស់មានសទ្ធាជ្រះថ្លាចំពោះព្រះសាសនាព្រះតថាគតស្រេគត់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បែរគិតដល់ អនិច្ចា រំពឹងយល់នាម រូបធម្មនេះពុំទៀង ពុំមែនជារបស់អាត្មា។ ខ្ញុំអម្ចាស់កោរ ក្នុងព្រះកេសដ៏មានចេស្ដាក្រៃលែង សម្រាប់នូវមុទ្ធាភិសេក (ពិធីស្រោចទឹកមន្ត) នេះ នៅស្ថានព្រះពិស្ណុលោកនេះ រួចដុតជាក្អុកសាង ព្រះពុទ្ធរូបនៅស្ថានបាកាណ (ជាន់លើបំផុតនៃអង្គរវត្ត) នេះ។ ខ្ញុំអម្ចាស់មាន សច្ចាធិដ្ឋាន (តាំងចិត្តដោយសច្ចៈ) ជាឧបាសករតន សុំសីល៥ (បញ្ចសីល) ដោយវីរ្យ ព្យាយាម និងសុំសីល ៨ (អស្ដាង្គិកសីល) នៅថ្ងៃទី៨ពេញបូរមី ថ្ងៃខែដាច់ជាប្រក្រតី លុះអាយុក្ស័យជាបង្អស់ហោង។

បពិត្រដោយតេជះផលានិសង្សនោះ ដោយកាលណាអស់ជីវិត ទៅកើតក្នុងជាតិអន្ទោលទៅមកនៅក្នុងសំសារភព ក្នុងជាតិអនាគតកាលជាច្រើន សូមកើតគ្រប់ជាតិជាមហាបុរស សូមប្រកបដោយធញ្ញបុញ្ញលក្ខណ (មានទ្រព្យអនាគត) ស្មោះស្ម័គ្រចំពោះព្រះសាសនាព្រះតឋាគតប្រាកដដូចសំណូមតាមបំណងប្រាថ្នាមុននេះវិញហោង។

ដោយកាលណាបើ សម្ដេចព្រះគ្រីអាយ្យមៃត្រិស្ដេចចុះមកត្រាស់ដឹងសព្វញាណ នៅក្នុងលោកនេះ សូមឱ្យខ្ញុំអម្ចាស់បានបំរើជាឧបាសករត្នៃនៃ សម្ដេចព្រះគ្រីះអាយ្យមៃត្រី សូមខ្ញុំបានស្ដាប់ សូត្រធម៌អមតៈ គឺធម៌ត្រាស់ដឹងចំនួន៣៧ប្រការ ចេញបួស បានឧបសម្បត្តិ (ពិធីបួសពីសាមណេរជាភិក្ខុ) មានព្រះកេសកោរ ជាអ្នកចេះដឹងនៅកណ្ដាលជំនុំនៃចតុពិធបរិសត្វ (ស្ដេច ព្រាហ្មណ៍ គ្រូ និងសង្ឃ) រួចហើយជាធុតង្គ១៣ (តេរស) ផ្លូវការនៅ តាមចត្ដាឡិសកម្មឋាន (កម្មដ្ឋានទាំង៤០) ដែលនាំទៅឋានអរហត្ត និងនាំទៅចតុប៉ិតិសម្ភិទាញាណ (អត្ថ ធម្ម និរុត្តិ បដិភាណ) សូមចូលនិព្វាន ជាមួយនឹងព្រះគ្រីអាយ្យមៃត្រីបពិត្រហោង។

នៅក្នុងសិលាចារឹកនេះមាន៖ (១) ការប្រើ«គ» នៅសល់ពីខ្មែរចាស់៖ ព្រះគ្រីអាយ្យមៃត្រិ និង (២) ការប្រើព្យញ្ជនៈ «ឡ»៖ ចត្ដាឡិសកំ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពន្យល់ពាក្យ

ព្រះវរបាទារវិន្ទ = ជើងផ្កាឈូក;

រ= ដូច;

ធ្នោង= ធ្នង;

ស្រមុទ្រ= សមុទ្រ;

ពោលមនតិ= ពោលតី;

កព្ភជាត= កពជាតិ;

កន្តារ = ផ្លូវពិបាក;

សារនា= ហូរ ដំណើរទៅមិនចេះចប់;

ធ្នូនក្សត្រ= ធ្នូវនក្ខត្តក;

ចតុទ្ទិតិកេត= ១៤កើត;

អាសាឍ្យសោរពារ= ខែអាសាឍ ថ្ងៃសៅរ៍;

តាល=បែរគិតដល់;

នាមរុប= នាម រូប;

ពុំជូអាត្មាគុះ= ពុំមែនអាត្មាសោះ;

តាកព្រះកេសមោលី = កោរក្បួងសក់;

ចេស្តាធិការ= សំ. មានចេស្តាខ្ពស់ បំពេញនូវអំពើខ្ពង់ខ្ពស់;

មុទ្ធាភិសេក= ពិធីកោរសក់;

សុវេចតុតជាក្នុក= សម្រេចជុតជាខ្នុក

ក្នុក= ផេះខ្នុក;

សច្ចាទិប្ឋាន= បំណងប្រាថ្នា;

បញ្ចសិល= សីលប្រាំ;

អស្តាង្គសិល= សីលប្រាំបី;

ថ្ងៃអដ្ឋមី= ថ្ងៃទី៨;

បុន៌មី=ពេញបូរមី;

អំមាពិស្យា=អមាវាសី ថ្ងៃខែដាច់;

ជាប្រក្រុតិ= ជាប្រក្រតី;

លុះអាយុក្ខយ្សត= លុះអាយុអស់;

បញ្ចខន្ធ= ខន្ធទាំងប្រាំ (រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ)

នោតេជះ= ដោយតេជះ;

អន្ទោលទោមោក=

អន្ទោលទៅមក;

ពួតស័សារាកព្ភ=

នៅក្នុងភពសំសារ;

សប្បៗជាតកំនេត= គ្រប់ជាតិកំនើត;

កោប្រ = ខ. ប្រកប;

ធញ្ញបុញ្ញ= បា. ទ្រព្យអនាគត;

លក្សណា= លក្ខណៈ;

សំយក្ស= សំ. ស្មោះត្រង់;

តួចសំនួមសាត= ដូចសំណូមពរ;

សាតប្រណីធានមុហ្និ= សំ. សច្ចាប្រណិធានមុននេះ;

នោកាល្នាបិ= នៅកាលណា;

ត្រស្សរសព្វំផ្តុតាញាន= ត្រាស់ដឹងសព្វញាណ; ខ្នំង= ខំទង ខំសូត្រ;

ធម្មាម្រុត= សំ. ធម៌មិនចេះស្លាប់;

គិ= គឺ;

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សត្តតិស័វរពោធិបក្ខិឌ្ឌិ= ខ. ធម៌ត្រាស់ដឹង ៣៧ ប្រការ;
ឧបូសំម្បុទ នុងឯ ហិភិក្ខុ= បា. បួសដោយការៈជា ឯហិ ភិក្ខុ;
ចតុពិធបរសត្វ= សំ. បរិស័ទ្យ៤ ប្រភេទៈ ក្សត្រិយ៍ ព្រាហ្មណ៍ ម្ចាស់ផ្ទះ និងព្រះសង្ឃ;
តេរសធុតង្គ= ម.ធុតង្គ ១៣;
ចត្តាឡិសកំមឋាន = ម.កម្មដ្ឋាន៤០;
ចតុបិតិសម្ពិទាញាណ= ម.ញាណបែក៤ប្រការ

សិលាចារឹកលេខ៣

នេះគឺត្រីពិធ (បីប្រការ) សុចរិតសទ្ធា មហាវិបុល អតុល្យ អតិរេក ឯកត្តតា ប្រាមោទ្យ ជោតិ បង្កជវត្ត វេណ្វាពិន្ទ អចិ អចិន្ត្យនិយប្រីតិមានោជ្យ ពៃពោជ្យ សុគន្ធបវរសរមនស្សកិលង្គិត វិកសិតសោត្តរ មរមទុម្មាកាប្រកាសយ្យ សមយ្យសមុត្តិមហុតិមហោត្តំ សមន្ធអសខ័រិកចិត សុចរិតវាច្ចា សច្ចាធិដ្ឋាន (ការតាំងចិត្តទៀងទាត់) ប្រណិធាន (ការបួងសួងស្បថ) នៃសំតេចព្រះជៃយ្យជេដ្ឋាធិរាជឱង្ការបរមរាជាធិរាជរាមាធិបតិត្រីត្រិករនោទិត្យពម្ម៌ ធម្មិករាជមនុវង្សោត្តរ មហាបរមចក្រពត្តិរាជកម្ពុជេស្វរ សុរិន្ទតេជោជេយ្យ ត្រៃវត្ថមកុដវិសុទ ជិនសាស្នធរបរមត្តុបថម្ភករាជសំតេចព្រះមហាឱបាសកមហារាជពិត្រ ថ្វាយបង្គំប្រណម្យទូលដល់ព្រះវរបាទារពិន្ទនៃសម្តេចព្រះមហាត្រីវត្តត្រៃយ បរមបពិត្រ នៅពេលតំបូង សំតេចព្រះមហាឧបាសកបានឡើងសោយរាជសម្បត្តិគ្រងរាជ្យ តាមខ្សែស្តេចនោះ ស្តេចមានព្រះរាជប្រាថ្នា ដើម្បីលើកសាសនាព្រះតថាគត ដោយជួសជុលជញ្ជាំងថៃវព្រះពិស្ណុលោកលើកថ្មជួសជុលជំបូលប្រាសាទកំពូល៩ សំអាតពិចិត្របិតមាសរួចហើយ ស្ថាបនាព្រះមហាសារិកធាតុ ឆ្លងចំរើនព្រះរាជកុសលនេះ សម្រេចថ្វាយទៅសំតេចព្រះជីទាំងបួនព្រះអង្គ ជាពិសេសដល់វិញ្ញាណក្ខន្ធសំតេចព្រះវរបិតាធិរាជបពិត្រ និងព្រះញាតិទាំងប្រាំពីរសន្តានផង សូមឱយពណ្ណរាយក្នុងសម្បត្តិទាំងបីប្រការហោង។ បន្ទាប់មក សំតេចព្រះមហាឧបាសកមហារាជបពិត្រ រំពឹងដល់ប្រាថ្នាពីមុនដើម្បីសាងសាសនា ព្រះតថាគតឱយរុងរឿងនៅកម្ពុជ-

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទេសនេះ លើកយសព្រះរាជសន្តានឱយសំបូណ៌ ដូចបុព្វកាលវិញ កុំម្បីមានធម្មន្តរាយឡើយ សូមមានភាពក្សេមក្សាន្ត សមិទ្ធិ ស្ថិតស្ថិរ ជាស្ថាពរហោង។

មួយនេះនាប្រថមកាល សំតេចព្រះភគវត្រ៊ៃគីចក្រពត្តិអគ្គរាជមហេសី ព្រះពិធរណិន្ទ្រជេយ្យរាជទេពិគ្រងធម្មំធិតាបពិត្រទ្រង់មានគភ៌ នោះសំតេចព្រះមហាឱបាសកមហារាជបពិត្រមានព្រះចរិតចិន្តាប្រាថ្នាចាំនាំព្រះរាជបុត្រនេះ ទោះប្រុសក្តី ឬស្រីក្តី ថ្វាយព្រះរាជអទិស្ឋាន ថ្វាយជាឧបាសក ឧបាសិកា បម្រើសំតេចព្រះមហាគ្រីរត្នត្រៃបរមបពិត្រ មានភក្តីភាពចំពោះព្រះសាសនាព្រះតថាគតហោង កុំម្បីចាកលែងព្រះសាស្នាឡើយ។ បើជាព្រះរាជបុត្រាព្រះរាជអទិស្ឋានថ្វាយជាពុទ្ធបុត្រពំនាក់ព្រះមហាគ្រីរត្នត្រៃបរមបពិត្រ ជាប្រធាននៃព្រះអង្គ លុះនាបានបួសសំណាក់ព្រះសាសនាហោង។ លុះកាលណា បើលាផ្នួសបព្វជ្ជាកម្មវិញមក សូមបានគ្រងព្រះរាជជាមហាក្សត្រវិញតាមវង្សស្តេច សូមមានស្វាមីភក្តិចំពោះព្រះមហាគ្រីរត្នត្រៃបរមបពិត្រ ជាប្រធានពំនាក់របស់ព្រះរាជបុត្រនេះហោង។

ហេតុតេជះផលានិសង្សសំតេចព្រះមហាឧបាសកមហារាជបពិត្រស្មោះពំនាក់ចំពោះព្រះមហាគ្រិរត្នត្រៃបរមបពិត្រ ពិតឥតបីល្អៀងឡើយ ទើបទេពច្យុតមកឧបត្តិនៅផ្ទៃមាតានៃសំតេចព្រះរាជទេពិទិព្យ ដែលមានបុណ្យកើត ព្រះរាជបុត្រប្រកបដោយលក្ខណៈ ឱត្តំសំនុព្រះលគ្នារាសីតិថី ស្សិវ្រ្គិ អនុកូលបរិបូណ៌្ន។ ឧបត្តិនាមហាសករាជ ១៥០១ (គ.ស. ឆ្នាំ១៦៧៩) ឆ្នាំជោះ ថ្ងៃពុធនក្ខត្តឫក្ស ១៤រោជ ខែអាសាធ មុនអជ្រាត នៅពេលប្រថមរាសី ប្រសូតព្រះអង្គដ៏បរិសុទ្ធ។ លុះដល់ថ្ងៃអាទិត្យ គម្រប់១២ថ្ងៃ មានជំនុំសំតេច ព្រះរាជមាតាបពិត្រ និងរាជគ្រូហោរ ព្រាហ្មណាចារ្យផង ដើម្បីកំណាត់កំណើតព្រះបាទសំតេចព្រះរាជបិតាបពិត្រមានព្រះរាជហឫទ័យប្រទានព្រះនាមពរប្រសិទ្ធិដល់សំតេចព្រះរាជឱរស ជាសំតេចព្រះបរមរាជាធិរាជបពិត្រ។

រួចមក ស្តេចនាំសំតេច ព្រះបរមរាជាធិរាជព្រះរាជឱរសមកកាន់ព្រះពិស្ណុលោក ដែលជាស្ថានជំនុំនៃទេព មហាខេត្រ មហាឥសីព្រហ្ម សិទ្ធិស័ក្តិ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងទេព្វរក្សបិត្តរគណាផោង នៅពេលជំនុំសមុគ្គតានោះ ស្តេចមានព្រះរាជសទ្ធានាំសំតេចព្រះបរមរាជាធិរាជថ្វាយជាឱបាសករត្នបត្តិបត្តិសំតេចព្រះមហាត្រីរត្នត្រៃបរមបពិត្រ។ រួចស្តេចឱយរន្តាប់ក្រយាបូជាសម្រាប់សរាទកាល (ចុងរដូចភ្លៀង)។ គេនិមន្តព្រះសង្ឃអស្ថារ្យ៨អង្គ ដែលទ្រង់ចតុបារិសុទ្ធសីល (កាន់សីល៨) និងរាជគ្រូអាចាយ៌្យផងមក ធ្វើពិធី តប៉្បណា ទ្វាទស (១២) បិណ្ឌ និងអស្សោត្តរសត (១០៨) មង្គល ដោយមានសព្វផ្លែឈើ ភ្ញី គន្ធ ក្រយាបញ្ចយជ្ញ (បូជាយជ្ញ៥) ផង តាមយថាសាស្ត្រ ដើម្បីថ្វាយកុសលបុណ្យទៅថ្វាយព្រះញាតិទាំង៧សន្តាន និងសព្វសត្វ ដែលធ្លាក់ទៅនៅចតុរាបាយភូមិ (ស្ថានទុក្ខទាំងបួន) ខាងលើរួចដល់អគ្គនិដ្ឋព្រហ្ម ខាងក្រោមរួចដល់ស្ថានអវចិ ខាងខាងរួចដល់ទសសហស្សចក្រវាឡនេះ។

សូមផលានិសង្សនៃសំតេចព្រះមហាឱបាសកមហារាជបពិត្រមានកត្តញុកត្តវេទិ ខ្ញុំជូនកុសលផលបុន្យនេះចំរើនអ្នកផងអំបាលនេះ ទោះបីអ្នកផងអំបាលនេះវង្វេងទៅដល់ចតុរាបាយភូម នោះតេជះផលានិសង្សនេះសូមរំដោះឱ្យរួចផុតចតុរាបាយ ទៅពណ្ណរាយនៅសម្បត្តិទាំងបីប្រការសំបូណ៌វិញ។ ទោះបីអ្នកផងអំបាលនេះបានស្មោះស្ពោះទៅសោយទិព្វសម្បត្តិសំបូណ៌ហើយក្តី នោះតេជះផលានិសង្សនេះសូមទៅចំរើនទិព្វសម្បត្តិវិញសំបូណ៌ ពិពទ្ធ៌ មួយសារ លុះបានចូលទៅបទមោក្ស មហានគរនិព៌្វាន ជាបង្អស់ហោង។

បពិត្រ តេជះនៃសំតេចព្រះមហាត្រីរត្នត្រៃបរមពិត្រនុតេជះសិទ្ធិសក្តិនៃទេព្វតាមហាខ្សេត្រផងនាគ្រោងប្រទិបត្តិព្រះសាសនានេះ សូមជ្រោមរក្សាព្រះអង្គសំតេចព្រះបរមរាជាធិរាជព្រះរាជឱរសនេះ សូមចំរើនព្រះពរមង្គលស្គាល់ តេម សម្ទ្ធិ ស្ថិរ ទិឃាយុ លុះដល់សុខសួស្ឋាធិការ ពិពទ្ធ៌ មួយសារលែងបានបួសសំណាក់ចំពោះព្រះសាសនា ឧបត្តិ ប្រណិបត្តិ ដោយព្រះបន្ទូលហោងនៅកាលណាបើលាបព្វជិតកម្មវិញមកសូមទេវតាជ្រោមរក្សាព្រះអង្គសំតេចព្រះបរមរាជាធិរាជឱយរំដោះលែងសព្វទុក្ខសព្វសោក សព្វ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពោគ សព្វភ័យ សព្វ...។

ពន្យល់ពាក្យ

ឯកត្តតា=បា. តម្រង់ឆ្ពោះទៅគោល-ដៅមួយ; ត្រៃត្រិភវនាទិត្យពម្ន៌ = សំ. អ្នកមានព្រះអាទិត្យការពារផ្សាយអំណាចក្នុងភពទាំងបី;

មន្ទិកាលជា ប្រថំម= ខ. សំ. មទ គឺ កាលជាបឋម;

ប្រវាណី=សំ. រាជវង្ស ឬប្រពៃណី;

ព្រះពិស្ពុលោកប្រាការ = សំ. កំពែងប្រាសាទនគរវត្ត;

នព្វសូល = សំ. កំពូល ៩;

ស្ថាបណា=ឧទ្ទិស;

កល្បនា = សំ. ការសម្រេច;

សប្តសន្តាន = សំ. ៧ សន្តាន;

អន្តាប្ប័នោះ=បន្ទាប់ពីនោះ

តេម្បិ=ដើម្បី;

បូព៌ប្រាថ្នា=ដូចប្រាថ្នា;

ពោះ បូព៌កាលវិង = ខ. សំ. ដូចកាលដើមវិញ; លេយ=ឡើយ

ខ្សេម សម្ឫទ្ធិ = សំ. ក្សេមក្សាន្តសន្តិភាព;

សម្ឫទ្ធិ = សំ. ជោគជ័យ;

ស្ថិរស្ថាពរ= សំ. ស្ថេរភាពស្ថាពរ;

មួយ្ឆិ នាប្រថំមកាល = ខ. សំ. មួយនី នាប្រថមកាល;

ទ្រង័គព៌្ណណិ = សំ. ទ្រង់មានគភ៌;

គីណាព្រះរាជអទិស្ឋាន;

ឪប្បជាក= ម. បំរើ;

ស៊ុំសំយ័ក្ស កត្តី = សំ. សូមសំណាក់កត្តី;

មោក ឪត្បត្ត = សំ. មកឧត្ប័ត្តិ មកកើត;

មាត្រោទរ = សំ. មាតុឧទរ ផ្ទៃមាតា;

កុលព្រះរាជបុត្រ = សំ. ប្រសូតព្រះរាជបុត្រ; កោប្រទុល័ក្ស = សំ. ប្រកបនូវលក្ខណៈ;

ឪត្តំ សំ នុព្រះលគ្នារាសី តីថី= ម.ខ. ឧត្តម សម នូវព្រះលក្ខណារាសីតិត្ថី (ថ្ងៃ);

ស៊ិន្ត អនុកូល បរិបូណ្ណ៌ = សំ. ស្បន្ត អនុកូល បរិបូណ៌;

ចតុទ្ទំគី ពោច = សំ. ចតុទំគី (១៤)ពោច

នា ប្រថ្រំអថ្ងំាត = សំ. នៅពេលអាជ្រាត;

លគ្នា ស្ថិត = សំ. លក្ខណា ស្ថិត;

គំរប្ប ទ្វាទសទិន = សំ. គំរប់ ទ្វាទសទិន (១២ថ្ងៃ);

មហាខ្សត្រ = សំ. ទេវតាធំៗ គឺព្រះ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍;
មហាព្រហ្មរសីហ = សំ. ឫសីដ៏ប្រសើរ៖ ១) ព្រហ្មឫសី ២) ទេពឫសី ៣) រាជឫសី ៤) មុនី;
នុ ទេពរក្ស បិត្តរគណា ផោង = ខ.សំ. ទេពរក្សបិតរគណៈ គឺពួកព្រះបិតរ (វិញ្ញាណព្រះអយ្យកោ អយ្យកា ព្រះជនក ព្រះជននី) ដែលកើតជាទេពរក្ស;
សមុគតា = សំ. ជួបជុំព្រម;
សរប្ប សរាទ កាល = សំ. សរទៈរដូវ (ស្លឹកឈើជ្រុះ);
ត អស្ធារ = សំ. ដ៏អស្ចារ្យ;
ពិធិ តប៉្បណា ទ្វាទសបិណ្ឌា = សំ. ពិធីច្រួចទឹកដាក់បិណ្ឌ១២;
នុ អស្នោត្តរសតមង្គល = សំ. មង្គល ១០៨ (អដ្ឋ=៨; សត=១០០;);
យថាសាស្រ្ត = សំ. តាមតម្រាសាស្ត្រ;
លន្ឡឹង = សំ. លន្ទីង កើត ស្ថិត;
រ្វំចដល់ អគ្គនិដ្ឋពំហ្ម = សំ. រួចដល់ អកនិដ្ឋព្រហ្ម;
បទមោក្ស = សំ. ព្រះនិព៌ាន (រួចចាក ទុក្ខ);
ជាបទឥស = ខ. ជាបន្តស់;
ស្កល = ខ. សកល គ្រប់មុខ;
តេម សម្ឫទ្ធិ ស្ថិរ ទិឃាយុ = សំ. ថែម ឱ្យមានអាយុវែងស្ថិតស្ថេរ;
សុខ ស្វស្ធាធិការ = សំ. សុខសួស្តីក្រៃលែង;
ឱត្សាប្រទិបាត្តកតិ = សំ. ឧស្សាហប្រណិប័តន៍ ប្រកតិ (ក្រឹត្យ);
ត នានាប្រាកាយ៉្ស = សំ. ដ៏នានាប្រការ;
សព៌្វប្រាការផោង សប្បអន្វេហ = សំ. សព្វប្រការ សព្វអន្វើ;
ឥសកាលតលង្ស = សំ. អស់កាលដ៏លង់
ពេះព្រះរាជចំនង = សំ. ដូចព្រះរាជ ចំណង់;
ព្យីរព្រះអង្គ = សំ. ពីរព្រះអង្គ;
សប្តប្រក្ធតិ = សំ. ប្រក្ធតិ៧យ៉ាង (ព្រះរាជា អាមាត្យ នគរ ប្រទេស ទ្រព្យ ពល មិត្រ);
ចលាចល្និលេយ = សំ. ចលាចលនី លើយ (នីមួយៗឡើយ);
ព្រះមហាសព៌្វជ្ញពុទ្ធ = សំ. (ម. មហាសព្វញ្ញូពុទ្ធ) មហាសារពេជ្ញ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣.៣.៣. ពិធីដោះលែង (បម្រាស) ខ្ញុំបម្រើឱ្យក្លាយជាអ្នកជា

សិលាចារឹកលេខ៨

សុកមស្ត ជៃយា តិរេក

នៅមហាសករាជឆ្នាំ១៥៤៧ ត្រូវជាគ.ស.ឆ្នាំ១៦២៥ ឱកហ្លួងចក្រីកន្សែង និមន្តព្រះអរិយសង្ឃ ដើម្បីជំនុំពិភាក្សាលើរឿង ដែលឱកហ្លួងរាជាតេជះ ដែលត្រូវជាបងរបស់ឱកហ្លួងចក្រីកន្សែងបានប្រោស (ដោះលែង) ខ្ញុំបម្រើតាំងតែ២៤ឆ្នាំមុន (នៅឆ្នាំ១៦០១) ដែលគ្រួសារនេះមានកូនបីនាក់ឪពុកឈ្មោះខុណបញ្ចងទេ ប្រពន្ធឈ្មោះមេអេព្ង ដោយមានមន្ត្រីជាសាក្សី ហើយបានសុំឱ្យឱកហ្លួងចក្រីកន្សែងជាប្អូនជាអ្នកកាន់បណ្តាំបម្រាសនេះឱ្យបានខ្ជាប់ៗ ក៏ប៉ុន្តែ នៅឆ្នាំ១៦២៥ ព្រះអ្នកស្តេចយស បានបំពានលើបម្រាសនេះៗ គេបាននាំក្តីវិវាទស្តីពីសម្រោសនេះមកដល់ចៅក្រមសូភា ដែលបានពិភាក្សាក្តីនេះ ហើយនាំក្តីនេះមកដល់ចៅពញា សួរេន ឥន្ទ្រារាធិប្បត្តិ ស្រីអង្គឯកអគ្គសេនាយោធាភិមុក្ខអង្គរឥន្ទប្រាស្ស ហើយកាត់ក្តីនេះឱ្យឱកហ្លួងចក្រីកន្សែងឈ្នះៗ ចៅពញាបានឱ្យឱកហ្លួងចក្រីកន្សែងនិមន្តព្រះអរិយសង្ឃ ដែលមានអ្នកព្រះធម្មកិត្តិ មហាសង្ឃរាជបពិត្រ ជាព្រះប្រធាន និងបានសរសេរចារឹកនេះបញ្ចុះនៅព្រះពិស្ណុលោក ដោយមានសាក្សីពេជញាណៗ បើមាននរណាមួយមកស្រតីរើសយកអ្នកទាំងនោះជាខ្ញុំវិញ ទោះព្រះពុទ្ធត្រាស់ទៅហើយក្តី និងព្រះពុទ្ធដែលនឹងមកត្រាស់ក្រោយក្តី កុំប្បីប្រោសអ្នកនោះឡើយ ហើយសូមឱ្យអ្នកនោះទៅកើតនៅបញ្ចនរក៥០០ពាន់ជាតិ កុំប្បីរំដោះចេញពីរនកនោះឡើយៗ អ្នកឱកហ្លួងចក្រីឥន្សែង ព្រហ្មវង្សា និងអ្នកស្តេចព្រះឥនកិលាស ធ្វើកុសលនេះជូនទៅអ្នកឱកហ្លួងរាជាតេជះ សូមបានទៅកើតនាស្ថានតុសិតហោងៗ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣.៣.៤.ពិធីកសាងកុសលផលបុណ្យរបស់អ្នកឪទេយបុញ្ញា

សិលាចារឹកលេខ១០

សុភមស្តុ មង្គលា តិរេក

នៅមហាសករាជឆ្នាំ១៩៤៩ ត្រូវជាគ.ស.ឆ្នាំ១៩៩៩ អ្នកឧទយបញ្ញា (មានប្រាជ្ញាកើនឡើង) មានចិត្តសទ្ធានាំមេបា បងប្អូន កូនចៅមកពីស្រុកជ្រលង មកកាត់ទងសត្បុករទាំង៧ ហើយធ្វងផ្ទសៗ អ្នកទាំងនោះបានជួយអនុមោទនាជារណ្ដាប់ជាប្រាក់ៗ សូមកុសលផលបុណ្យជួយអ្នកទាំងអស់នេះបានលុះត្រៃពិទ្ធសម្បត្តិ កុំឡើវង្វេងទៅកើតនាចតុរាបាយនរក សូមរំដោះពីអកយចតុរាបាពយភូមិនរកនោះ សូមទៅកើតនា សោឡស កវត្តព្រហ្ម (ស្ថានសួគ៌ជាន់ទី១៦ ខាងលើនៃព្រហ្ម)ៗសូមខ្ញុំបានសោយផលអានិសង្ស (ផលបុណ្យ) នេះច្រើនហោង សូមចំរើនញាតិកាទាំង៧សន្តាន មានទ្រព្យក្តីអត់ទ្រព្យក្តី ឱ្យបានសម្បត្តិវិមានត្រៃយត្រិង្ស (ស្ថានសួគ៌៣៣ជាន់)ៗ ចារឹកនេះសរសេរដោយ ជី នៃយ ទុកជាកីលៗ អ្នកឪទយបញ្ញាសុំទៅកើតនាស្ថានសួគ៌ ឱយបានសម្បត្តិនិព្វាន ជាស្ថានក្សេមក្សាន្ត ឱយផុតពីចតុរាបាយភូមិនរក សូមមានភោជនីយហារបរិភោគកុំឡើដាច់ឡើយ សូមមានសំពត់ស្លៀកឡើដាច់ឡើយ បើជាគ្រហស្ថ សូមមានស្ត្រីរតនល្អដូចចិត្តប្រាថ្នានោះហោងៗ

៣.៣.៥. ឧស្សនវិជ្ជាព្រះពុទ្ធសាសនា

សិលាចារឹកលេខ១៧

សិរី ឫទ្ធិ (សិទ្ធិ) សុវណ្ណី សុចរិត ទសពិត្រ បុណ្យក្រយា មហាកុសលផលការិត ហតសុខ មហោឡារាសី ពិសាល សម្ដោធ ដោត នាកា ទិសានុទិស្សដោង ឧកាស កន្ត្ដេ

បពិត្រព្រះមហាត្រៃរត្នត្រៃបរមបពិត្រ កម្រតែងយើង នេះគឺសត្តិយាអធិស្ឋានប្រណិធាននៃចៅជេត និងនាងសួស ចំពោះបងប្អូនកូនចៅផៅ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សន្តាន មានជាអាទិញាតិមិត្រជិតឆ្ងាយផង។ បំណងបណ្តាលចិត្តសទ្ធាសាទរ បវរអនុកូលមូលជាកុសលផលាទិធម្មវេទិនិយា ប្រាថ្នាសម្បត្តិទាំងបីប្រការ។ សឹងប្រព្រឹត្តដោយក្តីសោមនស្សនមស្សការថ្វាយបង្គំ ប្រណម្យវរបាទារវិន្ទ (ផ្កាឈូកក្រោមព្រះបាទ) ព្រះសាស្តាចារ្យទារ្យពិននៃព្រះបាទកម្រតែងយើង ស្រីរត្នត្រៃបពិត្រ ជាត្រើយត្រាណ បីដូចសំពៅរត្នដំរុងរឿង ឧដុង្គ ពិសាល ពិសេសអាចចម្លងពពួកទេវតា មនុស្ស សត្វ នាគ គរុឌា កុម្ភន្ទ គន្ធព្វ យក្ខ គ្រុឌ នាគ វិជ្ជាធរ កិន្នរី កិន្នរ សត្វនិករ គណៈជន។

ជាអាទិ៍ គឺយើងខ្ញុំផងធ្វងវាលវដ្តសង្សារមហាសាគរ ដែលលុះដល់មហានគរនិព្វានក្សេម ប្រាសចាកអស់ពីជាតិកំណើត ជរាព្យាធិ មរណទុក្ខជានិច្ច។ បពិត្រយើងខ្ញុំគិតដល់អតីត អនាគត និងបច្ចុប្បន្ន ដែលមិនទៀង និងដោយឃើញពិតថាសរីរជាប់ជំពាក់នឹងសមានទុក្ខមហិមាឥតល្ហែល្ហើយ ទើបយើងខ្ញុំរព្ញកស្មារតីបណ្តាលសទ្ធាថ្វាយរន្ទាប់សព្វសារពើដំប្រពៃ មានទង់អភិធម្មដ៏បវរតូចធំ ព្រះពុទ្ធរូបបិតសុពណ៌ (មាស) ពិចិត្ររចនាប្រពៃ ពណ្ណរាយ។ យើងខ្ញុំមានសទ្ធានាំញាតិកាមកព្រះនគរវត្តរាសី នៅមហាសករាជ ឆ្នាំ១៥៥៤ ត្រូវជាគ.ស.ឆ្នាំ១៦៣៧ នៅថ្ងៃទក្ខត្តឫក្ស ខែអាសាឍ ពេញបូរមី ថ្ងៃព្រហស្បតិ៍ ហើយមានជំនុំសង្ឃ និងគ្រហស្ថ។ អ្នកទាំងនោះជួយអនុមោទនា នឹងចៅជេត និងនាងសួសមានចិត្តសទ្ធាឱ្យអាសួស្សរូចជាព្រៃ (អ្នកជា) ស្រឡះ ជ្រះឥតមានបំណុលឡើយ។ ចៅជេត នាងសួសមានចិត្តសទ្ធានាំអាសួសនេះ មកព្រះពិស្ណុលោក ដែលជាស្ថានជំនុំនៃទេវតា មហាក្សេត្រ (ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍) មហាព្រហ្មឫសី ស័ក្តិ និងទេពរ័ក្ស បិតរគណៈ (វិញ្ញាណព្រះមហាក្សត្រ)ផង។ នៅពេលមកជំនុំសមុគតា (ជួបជុំគ្នា) គប្បី យើងខ្ញុំបំបួសអ្នកសួសនេះរួចជាពាណាំស្រម រួចថ្វាយជាកុលបុត្រនៃព្រះ ស្រីសក្យមុនី ព្រះស្រីរត្នត្រៃបរម្មបូពិត្រ ទើបយើងខ្ញុំឱ្យរន្ទាប់ផ្លែឈើ គន្ធ គោជ្ជនៈគ្រប់សព្វ និងអាហារផង។ គប្បីយើងខ្ញុំអាភទនា (ពេញចិត្ត)និមន្ត ព្រះសង្ឃទ្រង់ចតុបរសុទ្ធសិល មកគង់លើអាសនដ៏ប្រសើរ។ គប្បីយើងខ្ញុំ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថ្វាយបូជាព្រះសាស្តាចារ្យកម្រតែងយើង ព្រះស្រីរត្នត្រៃ បពិត្រគិតជាបុញ្ញាភិសង្ខារ ឪឡារជយនៃយើង។

បពិត្រ អំពើកុសលផលបុណ្យនៃយើងខ្ញុំ រន្ធាប់នេះសូមឱ្យចម្រើនយសស្វស្តាធិការ (សួស្តីក្រៃលែង) ដល់កម្រតែងផ្ទៃក្រោម (ព្រះមហាក្សត្រ) ហើយមួយភាគយើងខ្ញុំជូនទៅទេពតាផងឯលើទៅដល់ព្រហ្មលោក ឯក្រោមទៅដល់ឧទុក្ខបរិយន្ត (ស្ថាននរក) ឯខាងទៅដល់ទសសហ (១០ពាន់) ចក្រវាឡ ត្រអាលឱ្យសត្វទាំងឡាយសោយ លែងទុក្ខពិបាកនោះ ឱ្យដោះលែងកន្លល់ដល់វិមានស្ថានភិរម្យសម្បត្តិពីភពមនុស្សហោង។ មួយភាគយើងជូនទៅដល់ព្រះញាតិ បើវង្វេងក្រែងទៅចតុរាបាយ ចូរសោយលែងទុក្ខនោះឱ្យស្មោះ ទៅសោយសុខគ្រប់ៗគ្នា។ បពិត្រមួយវិញទៀត យើងខ្ញុំអន្ទោល ទៅមកឰតកពជំតូចពុំស្គាល់អំពីបរមជាតិ (ជាតិមុន) ក្រែងយើងខ្ញុំធ្វើក្តីប្រមាថ មិនគោរពដល់បរមបពិត្រព្រះសាស្តាចារ្យកម្រតែងយើង ព្រះស្រីរត្នត្រៃ ដោយកាយកម្ម វាចាកម្ម មនោកម្ម ដោយតែសារទ្វាទស (១២) អកុសលចិត្តប្រព្រឹត្តិទ្វាសដ្ឋីទ្វស្ឋិមិច្ឆ (សេចក្តីឃើញខុស៦២) ចតុទស (១៤) ចេសិកា ជាកុសលមូល និងជាអកុសលមូល។

បពិត្រយើងខ្ញុំសូមលាវេរានុវេរ (ពៀរជំតូច) ការគិតប្រមាថមិនគោរពដល់ញាតិ ជាអាទិ គឺព្រះមាតាបិតា សត្រូវជំតូចៗ កំទារ (កំហុស)នៃខ្ញុំ សូមលាកុំម្បីមានឡើយ។ បពិត្រ យើងខ្ញុំគោរពស្មាលាទោសនោះផង សូមយើងខ្ញុំពណ្ណរាយលែងចតុរាបាយ សូមយើងពណ្ណរាយឰតសួគ៌ភិរម្យសមយល់ដ៏ប្រសើរ។ សូមយើងបានទាន់ព្រះស្រីអារ្យមេត្រី កាលស្តេចកើតត្រាស់ជាព្រះពុទ្ធ។ សូមយើងបានលុះអរហត្តផល ប្រកបដោយបដិសម្ភិទា ព្រះកម្រតែងយើង ព្រះសិអារ្យមេត្រីពោធិសត្វហោង។ ប្រសិនបើ ញាតិណាមួយនឹងពិពាតយកអ្នកសួសនេះជាខ្ញុំ ឬកម្រតែងណាបង្គាប់ឱ្យរើសយកសោត ទោះកើតមកដល់មួយសែនកោដិជាតិក្តី កុំឱ្យទាន់ព្រះពុទ្ធឡើយ។ បពិត្រសូមធុតៗ សាធុប្រណិធាននេះ តាមបន្ទូលព្រះសព្វជ្ញពុទ្ធកម្រតែងស្តេច។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣.៣.៦. ពិធីកសាងកុសលផលបុណ្យ

សិលាចារឹកលេខ២៦

សុភមស្តុ សួស្តី សិរី មង្គល ពហុលចេស្តា ជយាតិរេក

នៅមហាសករាជឆ្នាំ១៥៨៥ ត្រូវជាគ.ស.ឆ្នាំ១៦៦៣ នៅថ្ងៃនក្ខត្តឫក្ស ឆ្នាំថោះ ខែកត្តិក ពេញបូរមី ថ្ងៃពុធ មានការជំនុំព្រះសង្ឃផង ត្បិតកាលនាងហៀមមកគិតនឹងសាងកុសលផលបុណ្យ បានឱ្យលោកសាងព្រះពុទ្ធរូប ទងអភិធម្ម ជាដង្វាយដល់ព្រះពុទ្ធតម្កើងយើង។ លុះសាងរួចស្រេចហើយ បានអរាធនានិមន្តព្រះសង្ឃ៣០អង្គមកសូត្រមន្តនៅព្រះពាន់។ បន្ទាប់មក ពេលព្រឹករាប់បាតថ្វាយសម្តេចអារិយសង្ឃផងទាំងឡាយ និងព្រះថេរានុថេរផង ដែលដឹងឮនាងហៀមមករណ្តាប់ធ្វងព្រះពុទ្ធរូបលើព្រះពាន់។ នាងហៀមស្រដីថា ព្រះសានាយុក គឺជាប្តីមានជំងឺទារុណនោះមក បានផ្តាំនាងហៀមជាប្រពន្ធថា «ជីន្សៃនេះមានគុណសប្បុរសច្រើន ឱ្យបួសរួចជាព្រៃយរំដោះពីបំណុល និងឱ្យប្រាក់១០លឹងនេះទៅជីន្សៃហោង»។ ឯប្អូនវិញ គឺជីលើកជីផ្ទូណ និងកូនគឺជីព្រហ្មា នាងសិតក៏ព្រមដែរ ដែលមានព្រះសង្ឃ និងគ្រហស្ថជាសាក្សី។ អស់អ្នកទាំងអម្បាលនេះសុទ្ធសឹងតែជាសាក្សីវិញ្ញាណមានបីតិសោមនស្ស ស្មោះស្ម័គ្រសាទរ ព្រមជាមួយនឹងព្រះសានាយុកនិងនាងហៀម។ បើមានបងប្អូនកូនចៅឯណាក្តីមកជំទាស់មាត្រានេះ ហើយថាជីន្សៃនេះជាខ្ញុំបម្រើ សូមឱ្យព្រះពុទ្ធត្រាស់ឮតកន្ទងទៅហើយក្តី ព្រះពុទ្ធដែលនឹងត្រាស់ក្តី កុំឱ្យប្រោសអ្នកនោះបានឡើយ ហើយសូមឱ្យរន្ទះអនន្តចក្រវាឡបាញ់មហាប្រថពីក្តី បាញ់ឈើព្រឹក្សាក្តី កុំឱ្យបាញ់ឡើយឡើយ។ សូមបាញ់តែអ្នកដែលរើបម្រាស់នោះហោង។ ចារឹកនេះសាងដោយសម្តេចព្រះរាជ្យករី នៅថ្ងៃពុទ្ធនេះហោង។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជំពូកទី៤

កំណែទម្រង់រដ្ឋក្នុងសម័យឧដុង្គ និងការវិវត្តភាសាខ្មែរកណ្តាល នៅសតវត្សទី១៧ និងដើមសតវត្សទី១៨

៤.១. ទិដ្ឋភាពប្រវត្តិសាស្ត្រខ្មែរនៅសតវត្សទី១៧

សម័យឧដុង្គ (១៦២០-១៨៦៦) នៅសតវត្សទី១៧ និង១៨ គឺជាដំណាក់កាលទី២នៃប្រវត្តិសាស្ត្រខ្មែរក្រោយអង្គរ។ សម័យឧដុង្គ គឺជាសម័យកាលដែលខ្មែរចុះដុនដាបខាងផ្នែកសេដ្ឋកិច្ច ដោយសារតែអស្ថិរភាពនយោបាយដែលបង្កើតឡើងដោយសារទំនាស់ផ្ទៃក្នុងរាជវង្សខ្មែរ ជាពិសេសបញ្ហាស្នងរាជ្យសម្បត្តិ ការឃុបឃិតនិងទំនាស់រវាងមន្ត្រីជាន់ខ្ពស់ និងសង្គ្រាមជាមួយប្រទេសជិតខាង។ ក្នុងរយៈពេល២៤៣ឆ្នាំ នៃសម័យឧដុង្គ គឺពីឆ្នាំ១៦២០ដល់ឆ្នាំ១៨៦៦ កម្ពុជាធ្លាក់ចុះបន្តិចម្តងៗទៅក្នុងកលិយុគ រហូតដល់បាត់តួនាទីទាំងស្រុង នៅក្រោយកូសាំងស៊ីន។

សម័យឧដុង្គចែកចេញជាពីរដំណាក់កាល៖ ដំណាក់កាលទី១ ពីឆ្នាំ១៦២០ ដល់ឆ្នាំ១៧៥៥ និងដំណាក់កាលទី២ ពីឆ្នាំ១៧៥៦ ដល់ឆ្នាំ១៨៦៦។

នៅដំណាក់កាលទី១នៃសម័យឧដុង្គ វិបត្តិដណ្តើមរាជ្យក្នុងរាជវង្សានុវង្សបានជំរុញឱ្យប្រទេសជិតខាងលេបត្របាក់ទឹកដីខ្មែរ បន្តិចម្តងៗ ទាំងពីខាងលិចទាំងពីខាងកើត។ នៅដើមសម័យឧដុង្គ កម្ពុជាបានខិតខំដកខ្លួនពីឥទ្ធិពល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់សៀម ដោយយកវៀតណាមជាជញ្ជីងតុល្យភាព។ យុទ្ធសាស្ត្រនេះផ្តល់ឱកាសឱ្យវៀតណាមពង្រីកទឹកដី និងឥទ្ធិពលរបស់ខ្លួនមកលើកម្ពុជាទៅវិញ។ សតវត្សទី១៧ គឺជាសតវត្សនៃការចាប់ផ្តើមបាត់បង់ទឹកដីកម្ពុជាក្រោម។ វិបត្តិនៅឧដុង្គបណ្តាលពីកត្តាដូចតទៅ៖ (១) ការគ្រប់គ្រងរដ្ឋតាមបែបបុរាណ (២) សេដ្ឋកិច្ចកម្ពុជាមិនពឹងផ្អែកលើពាណិជ្ជកម្មជាមួយបរទេស (៣) កម្ពុជាគ្មានទំនាក់ទំនងសំខាន់ជាមួយប្រទេសខាងក្រៅ ជាហេតុធ្វើឱ្យការអភិវឌ្ឍធនធានមនុស្សនៅអន់ថយ និង (៤) មន្ត្រីធំៗមិនសូវគិតដល់ប្រយោជន៍ជាតិ។

សម័យឧដុង្គ នៅស.វ.ទី១៧ និង១៨ គឺជាដំណាក់កាលដែលស្ថានភាពនយោបាយនៅកម្ពុជាកាន់តែមានសភាពយ៉ាប់យ៉ឺនទៅៗ ហើយគឺជាសតវត្សនៃការប្រឈមមុខរវាងអាណាចក្រកម្ពុជា និងវៀតណាម។ ប្រទេសសៀមបានក្លាយជាកន្លែង ដែលស្តេចខ្មែររត់ទៅជ្រកកោន ដើម្បីគេចផុតពីវៀតណាម។ ព្រះមហាក្សត្រខ្មែរជាច្រើនអង្គបានភៀសខ្លួនទៅនៅ និងទៅសិក្សានៅប្រទេសថៃ ហើយថែមទាំងបានរៀនពីប្រវត្តិសាស្ត្រ និងរឿងព្រេងថៃថែមទៀត (VICKERY, 2002)។

៤.១.១.ការកសាងជាតិឡើងវិញក្រោយបែកបាក់ខ្មែរ

បន្ទាប់ពីរាជធានីលង្វែកត្រូវដួលរលំ ដើម្បីបញ្ចប់ចលាចល និងអស្ថិរភាពនយោបាយ នៅឆ្នាំ១៦០១ នាហ្មឺនអស់មុខមន្ត្រីបានសុំព្រះចៅនរេន្ទ្រសួរយាងព្រះបាទស្រីសុរិយោពណ៌ (១៦០១-១៩) ពីទីក្រុងអយុធ្យា ឱ្យត្រឡប់មកសោយរាជ្យវិញនៅក្រុងកម្ពុជាវិញ។ ព្រះអង្គយាងចូលមកតាមច្រកកំពតមកគង់នៅកោះស្លាកែត (ស្រុកលើកដែក) ហើយបានកេណ្ឌទ័ព និងតែងតាំងមន្ត្រីគ្រប់គ្រងតាមបណ្តាខេត្ត។ ព្រះអង្គបានបង្ក្រាបចលនាបះបោរនៅក្នុងប្រទេស ហើយទ្រង់បានសាងសង់ព្រះរាជវាំងនៅល្វាឯម ត្រង់ទីតាំងវត្តអរិយក្សត្រ ហើយក៏គ្រងរាជ្យនៅទីនោះពីឆ្នាំ១៦០៣ ដល់១៦១៣ ក្នុងព្រះជន្មាយុ៦០វស្សា។ ទ្រង់ទទួលរាជាភិសេកជាស្តេចផែនដីនៅឆ្នាំ១៦១៣។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តែស្តេចសៀមទុកព្រះរាជបុត្រពីរអង្គនៃព្រះបាទស្រីសុរិយោពណ៌ គឺជ័យជេដ្ឋា និងឧទ័យ ឱ្យគង់នៅរៀនសូត្រនៅអយុធ្យា។ ដូចនេះ ព្រះបាទស្រីសុរិយោពណ៌ ត្រូវស្ថិតនៅក្នុងស្ថានភាពរណបក្រុងអយុធ្យា។

អាទិភាពនៃការគ្រងរាជ្យនៃព្រះបាទ បរមរាជាទី៧ (ស្រីសុរិយោពណ៌) គឺការពង្រឹងសន្តិភាពផ្ទៃក្នុងប្រទេស ដោយបង្រួបបង្រួមខេត្តឱ្យស្ថិតនៅក្រោមការគ្រប់គ្រងនៃចៅហ្វាយខេត្ត ទៅតាមរចនាសម្ព័ន្ធគ្រប់គ្រងប្រពៃណី។ ព្រះចៅនរេន្ទ្រសូរ បានបញ្ជូនទ័ពឱ្យចូលមកវាយកម្ពុជា នៅឆ្នាំ ១៦០៣/០៤ ក្នុងគោលដៅដាក់សម្ពាធលើព្រះបាទស្រីសុរិយោពណ៌។ នៅពេលដែលបុត្ររបស់ព្រះអង្គត្រូវបានឃាត់ខ្លួនជាឈ្លើយនៅក្រុងអាយុធ្យា និងក្រោយពេលអន្តរាគមន៍យោធាសៀមនៅកម្ពុជា ព្រះបាទស្រីសុរិយោពណ៌ ត្រូវបង្ខំចិត្តថ្វាយសួយសារអាករជាប្រចាំដល់ព្រះចៅក្រុងអយុធ្យា។

ព្រះអង្គបានតែងតាំងព្រះសង្ឃរាជ៧អង្គ មានតំណែងទ្រទ្រង់ ឬរាជាគណៈ គឺ៖ (១) ព្រះសុគន្ធាធិបតី (២) ព្រះមង្គលទេព្វាចារ្យ (៣) ព្រះមហាលិខិត (៤) ព្រះពោធិវង្ស (៥) ព្រះវនរ័ត (៦) ព្រះមហាព្រហ្មមុនី និង (៧) ព្រះមហាវិមលធម្ម។

ព្រះអង្គបានតែងតាំងមន្ត្រីជាន់ខ្ពស់ទាំង៧ គឺ៖ ចៅហ្វាទឡ្ហៈ ឬ «ខ្នងពស់» ដែលជានាយករដ្ឋមន្ត្រី និងចតុស្តម្ភ ឬ «ជើងគ្រុស» គឺ៖ (១) ឧកញ៉ាយមរាជ (រដ្ឋមន្ត្រីយុត្តិធម៌) (២) ឧកញ៉ាវាំង (រដ្ឋមន្ត្រីព្រះបរមរាជវាំង និងហិរញ្ញវត្ថុ) (៣) ឧកញ៉ាក្រឡាហោម (រដ្ឋមន្ត្រីកងទ័ពជើងទឹក គយ និងដឹកជញ្ជូនផ្លូវទឹក) និង (៤) ឧកញ៉ាចក្រី (រដ្ឋមន្ត្រីសង្គ្រាម ទ័ពដីរ និងដឹកជញ្ជូនផ្លូវគោក) និងរដ្ឋមន្ត្រីពីរទៀត គឺឧកញ៉ាមហាមន្ត្រី និងឧកញ៉ាមហាទេព ដែលទទួលបន្ទុកផ្នែកពិធីការ និងសាលរាជបល្ល័ង្ក ដោយបង្កើតឱ្យមានគោរមងារ «ឧកញ៉ា» ដូចនៅអយុធ្យាដែរ (MAK Phoeun, 2009)។ ព្រះបាទស្រីសុរិយោពណ៌ បានធ្វើកំណែទម្រង់រដ្ឋបាលខេត្ត ហើយដើម្បីពង្រឹងស្ថាប័នរដ្ឋ ព្រះអង្គបានរៀបចំបង្កើតឱ្យមានក្រមច្បាប់មួយចំនួន ក្នុងគោលដៅពង្រឹងវិស័យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យុត្តិធម៌។

កម្ពុជាចុះខ្សោយដោយបាត់បង់បញ្ញវន្ត និងចាប់ផ្តើមទទួលឥទ្ធិពលពីអយុធ្យា តាមរយៈព្រះពុទ្ធសាសនាថេរវាទ ដោយកម្ពុជាមិនមានកន្លែងសម្រាប់បណ្តុះបណ្តាលបញ្ញវន្តនៅតាមវត្តអារាម។ តាម «ប្រវត្តិនៃវត្តសំបុក» (១៦០២) បន្ទាប់ពីបានទទួលជ័យជម្នះលើបាលីកងចក្រ និងគ្រប់គ្រងបានខេត្តសំបុក សំបូរ ធ្នូង និងក្រចេះ ព្រះអង្គបានតែងតាំងមន្ត្រីពីរនាក់ ដើម្បីសាងសង់វត្តសំបុក។ បន្ទាប់ពីសាងសង់ហើយ ព្រះអង្គបានចាត់ឱ្យខ្ញុំ២០គ្រួសារនៅថែរក្សាវត្ត ព្រះពុទ្ធបដិមា និងចេតិយ។ ព្រះអង្គបានតែងតាំងសម្តេចព្រះអរិយគាថា ជាសម្តេចព្រះនគរវ័ន និងជាសង្ឃរាជនៃវត្តសំបុក។ សម្តេចសង្ឃរាជបានតែងតាំងឧកញ៉ាវង្សាអញ្ចិត ជាអ្នកត្រួតពិនិត្យយកពន្ធលើអ្នកជំនួញ ដើម្បីចិញ្ចឹមគ្រួសារខ្ញុំទាំង២០នោះ។

ការពង្រឹងអធិបតេយ្យភាព៖ អាណាចក្រខ្មែរក៏ចាប់ផ្តើមពង្រីកទំនាក់ទំនងជាមួយប្រទេសខាងក្រៅ ដើម្បីកាត់បន្ថយឥទ្ធិពលអយុធ្យាមកលើក្រុងកម្ពុជា និងចាប់ផ្តើមពង្រឹងរដ្ឋកម្ពុជាឡើងវិញ។ ជប៉ុនមានទំនាក់ទំនងពាណិជ្ជកម្មជាប្រវត្តិសាស្ត្រជាមួយកម្ពុជា ដោយនាំចូលកម្ពុជានូវសព្វាវុធកាំភ្លើង និងរបស់របរប្រើប្រាស់ផ្សេងៗ ដោយផ្លាស់ប្តូរជាមួយស្បែក ស្នែងក្ញុកដំរី ទឹកឃ្មុំ ។ល។ ជនជាតិជប៉ុនត្រូវបានតែងតាំងជាមេដឹកនាំសំពៅជំនួញខ្មែរ និងជាមេការផលិតគ្រឿងសព្វាវុធផងដែរ (MAK Phoeun, 2009)។ នៅឆ្នាំ១៦០៥ ព្រះបាទ ស្រីសុរិយោពណ៌ បានផ្ញើចុតហ្មាយទៅមេទ័ព យេយ៉ាស៊ូ ស្ថាបនិកនៃតូគូហ្គាវ៉ា ដែលរស់នៅក្រុងអេដូ (តូក្យូ) ដើម្បីកាត់បន្ថយចំនួនសំពៅពាណិជ្ជកម្មជប៉ុនមកកម្ពុជា ដោយសារតែអ្នកដើរសំពៅទាំងនេះមានអាកប្បកិរិយាមិនសូវល្អ។

ដើម្បីពង្រឹងកិត្យានុភាពរបស់ប្រទេស ឧកញ៉ាស្រីអគ្គរាជ និងឧកញ៉ាធម្មតេជោ ថ្វាយចុតហ្មាយទៅព្រះអធិរាជជប៉ុន នៅខែមេសា ឆ្នាំ១៦០៦ ក្នុងគោលដៅបង្កើតទំនាក់ទំនងពាណិជ្ជកម្មផ្ទាល់ជាមួយជប៉ុន។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ប្រភព៖ ទំព័រហ្វេសប៊ុករបស់ Dūc Ṃ Pūrā

[1] សារ នោ ឧកញា ត្រីអគ្គរាជ នុឧកញា ធម្មតេជោយេងខ្ញុមទាង២ ថ្វាយ
បំគម្ម មោកស្តេចញីប៉ុន កុ

[2] កជូឫ យេងនោស្រុកកម្ពុជ្ជាធិបតីបានយលស្តេចញីប៉ុនសាបុរ្សប្រសេថ្ន
ពៀកទេព

[3] ឲយតេងសំពៅរខ្មេរ១ឲយទោ សពៅរឈ្មោះស្សុយីមុនកានោក

[4] ទោះស្តេចយីប៉ុនកុកចូ ស្រលេងយេងខ្ញុំទាង២ពិតឲយស្តេចកុកចូរ

[5] ឲយទំនេរចោសំពៅរចេញទោវនាបកុំប្បីឲយនៅរអាយលេយ ឥតអិយៗ
នុថ្វាយ

[6] មោកស្តេចលេយ សោមមោកថ្វាយចៀម៥ ក្រមួនហាប១ ខាន់សាកករ ហា

[7] ប១ សាកកសរ ហាប១ កន្ទុយកង៉ោក១០ ស្បែកខលាតម្បោង

[8] ៥ថ្វាយមោកស្តេចចង់ទេងព្រហ្បនគំមោកឯក្រោយម្តង់ទៀតទេពតេំងត្រា

[9] ផ្កាមកថ្វាយ..

សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
សារ	សារ
នុ	និង
យេងខ្ញុមទាង២	យើងខ្ញុំទាំង២

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្លាយបំគម្ម	ប្លាយបង្គំ
នោស្រុកកុម្ម៉ជ្ឈាធិបតី	នៅស្រុកកម្ពុជាធិបតី
សំពោវ	សំពៅ
ហោ សពោវ	ហោរសំពៅ
ឥតអិយៗនុថ្វាយ	ឥតអ៊ីៗនឹងថ្វាយ
សោមមោកថ្វាយ	សូមមកថ្វាយ
សាកករ	ស្ករ
កន្ទុយកដោក	កន្ទុយក្ងោក

៤.១.២. នយោបាយតុល្យភាពជាមួយសម្ព័ន្ធខាងកើត

នៅឆ្នាំ១៦០៤ ព្រះចៅនរេន្ទ្រសួរ បានចូលទិវង្គតលើសមរភូមិ ក្នុងសង្គ្រាមជាមួយភូមា។ បុត្រព្រះអង្គ ជ័យជេដ្ឋា ឆ្លៀតពេលដែលសៀមកំពុងរវល់ធ្វើបុណ្យសព ក៏បានរត់គេចព្រះអង្គត្រឡប់មកកម្ពុជាវិញ។ ដើម្បីទប់ទល់នឹងឥទ្ធិពលរបស់សៀម ព្រះបាទស្រីសុរិយោពណ៌ បានរៀបចំផែនការបង្កើតតុល្យភាពកម្លាំង ដោយសាកល្បងចងសម្ព័ន្ធភាពជាមួយវៀតណាម។

នៅសតវត្សទី១៦ ប្រទេសវៀតណាម ដឹកនាំដោយត្រកូលពីរ ក្នុងនាមព្រះចៅអធិរាជឡេ គឺត្រកូល ទ្រិញ នៅភាគខាងជើង (តុងកឹង) និងត្រកូលង្វៀង (ប្អូនថ្លៃរបស់ ទ្រិញគាម) នៅភាគខាងត្បូង (នៅអាណាម) ដែលវាយយកបានទឹកដីខ្លះពីចម្ប៉ានៅសតវត្សទី១៥។ នៅឆ្នាំ១៦០៣ ង្វៀង ហ្វូង បានបញ្ជូនទូតលើកទី១ មកកាន់កម្ពុជា។

នៅឆ្នាំ១៦១៦ ព្រះអង្គបានចងសម្ព័ន្ធមិត្រនឹងព្រះចៅក្រុងហ្វេ ដោយចងស្ពានព្រះរាជមេត្រីផ្សំផ្គុំព្រះជ័យជេដ្ឋា ជាព្រះរាជបុត្រច្បង ជាមួយនឹងព្រះអង្គម្ចាស់ក្សត្រីនៃរាជវង្ស ង្វៀង ព្រះនាម អង្គចូវ ជាព្រះរាជទេពី។ ក៏ប៉ុន្តែសម្ព័ន្ធភាពថ្មីនេះ មិនបានបង្កើតឱ្យមានសុខសន្តិភាពសម្រាប់ប្រជាជនខ្មែរឡើយ ដោយសារវាក្លាយជាទម្ងន់ថ្មីថែមទៀតមកលើកម្ពុជា។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រះបាទជ័យជេដ្ឋាទី២(១៦១៩-១៦២៧)បានឡើងស្នងរាជ្យពីព្រះបិតានៅរាជវាំងល្វាឯម ក្នុងព្រះជន្ម៣៤វស្សា។ បុត្រព្រះបាទ ស្រីសុរិយោពណ៌ គឺព្រះឧទ័យ ត្រូវបានតែងតាំងជាមហាឧបរាជ ជាពូជព្រះមហាក្សត្រខ្មែរ ដែលបន្តរហូតនៅក្នុងសម័យឧដុង្គ និងតមកដល់សម័យបច្ចុប្បន្ននេះ។ ព្រះបាទស្រីសុរិយោពណ៌ គង់នៅជាឧភយោរាជ តែសោយទិវង្គតមួយឆ្នាំក្រោយការឡើងគ្រងរាជ្យរបស់ព្រះបាទជ័យជេដ្ឋាទី២។

នៅឆ្នាំ១៦២០ ព្រះបាទជ័យជេដ្ឋាទី២ បានលើករាជធានីពីល្វាឯម មកឧដុង្គ។ សៀមបានលើកទ័ពមកវាយយកកម្ពុជាពីរលើក នៅឆ្នាំ១៦២២ និង ១៦២៣ តាមផ្លូវគោកតាមច្រកខេត្តបាត់ដំបង និងពោធិ៍សាត់ និងតាមផ្លូវទឹកតាមខេត្តកំពត និងបន្ទាយមាស តែត្រូវទ័ពខ្មែរវាយបក ហើយត្រឡប់ទៅស្រុកវិញ។ ព្រះចៅក្រុងអយុធ្យា ប្រាសាត ថង(១៦២៩-១៦៥៦) បានបញ្ជាឱ្យសាងសង់វត្ត ជ័យវឌ្ឍនារាម នៅអយុធ្យាតាមដងទន្លេចៅប្រាយ៉ា ដើម្បីអបអរសាទរជោគជ័យនៃសង្គ្រាមនេះ (FOUSER, 1996; HARRIS, 2005)។ ទំនាក់ទំនងជាមួយសៀមមានភាពស្ងប់ស្ងាត់រហូតដល់ដំណាច់សតវត្សទី១៧។

បន្ទាប់ពីប្រាសាត ថង សុគតនៅឆ្នាំ ១៦៥៦ វិបត្តិស្នងរាជ្យបានកើតឡើង។ ដោយមានការគាំទ្រពីពួកហូឡង់ ជប៉ុននៅថៃ និងពួកម៉ាឡេ ព្រះបាទណារ៉ៃ បានឡើងសោយរាជ្យនៅអយុធ្យា។ អាយុធ្យាបានពង្រីកទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសអឺរ៉ុប ដូចជាហូឡង់ អង់គ្លេស ដាណឺម៉ាក និងបារាំង ហើយសេដ្ឋកិច្ចនៅក្នុងរាជាណាចក្រអយុធ្យាបានរីកចម្រើនឡើង។ នៅឆ្នាំ១៦៥៦-១៦៨៨ អយុធ្យាបង្កើតទំនាក់ទំនងការទូតជាមួយស្តេចល្វីទី១៤ របស់បារាំង តាមរយៈអ្នកផ្សងព្រេង និងទីប្រឹក្សាជាតិក្រិចឈ្មោះ ប៉ូល កុន (១៦៤៧-១៦៨៨)។

ប៉ុន្តែ បន្ទាប់ពីបានកាន់កាប់ទឹកដីចម្ប៉ាទាំងស្រុងនៅដើមសតវត្សទី១៧ វៀតណាមបានចាប់ផ្តើមវាតទីយកទឹកដី ដោយធ្វើដំណើរទៅទិសខាងត្បូង (នយោបាយណាំទៀន)។ នៅឆ្នាំ១៦២៦ សន្តតិវង្សង្វៀងនៅភាគខាងត្បូង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បានផ្តាច់ទំនាក់ទំនងជាមួយសន្តតិវង្សឡេនៅហាណូយ ចាប់ផ្តើមពង្រីងអំណាចរបស់ខ្លួនលើខេត្តនៃភាគខាងត្បូង ហើយដីសណ្តទន្លេមេគង្គ គឺជាដីដ៏មានជីជាតិសម្រាប់ដំណាំស្រូវ។

ការពង្រឹងស្ថាប័នរដ្ឋ និងតុលាការ៖ ព្រះបាទជ័យជេដ្ឋាទី២ បានបន្តព្រះរាជកិច្ច ក្នុងការធ្វើកំណែទម្រង់ច្បាប់នៅក្នុងប្រព័ន្ធតុលាការខ្មែរ ដោយយល់ឃើញថាមានក្រមមួយចំនួនមិនទាន់មានភាពយុត្តិធម៌នៅឡើយ។ ព្រះបាទជ័យជេដ្ឋាទី២ បានពិនិត្យកែប្រែ និងអនុម័តក្រមបានចំនួន២២៖ ច្បាប់ព្រះក្រឹត (១៦១០?), ព្រះរាជក្រឹត្យប្រាជ្ញាភិសេក (១៦១៣, ១៦១៩, ១៦២៩), ច្បាប់ក្រមុំ ស្រុក៨ប្រការ (១៦២២) (MIKAELIAN, 2009) ព្រមទាំងក្រមសុភាធិបតី ក្រមទសករិយា ក្រមចែកពល ក្រមឧទេន ក្រមសុរង់សង្ឃ ក្រមពលទេព ក្រមសួស្តី ព្រះអយ្យការ ដើម្បីកាត់ក្តីពាក់ព័ន្ធនឹងកិច្ចការប្រទេសជាតិ ជាពិសេសសមាជិករាជវង្សានុវង្ស ក្រមព្រះនគរបាល ច្បាប់ពីព្រេងនាយ ច្បាប់ «ជ័យជេដ្ឋាទី២» ដែលចែកជា៖ ក្រមចោរ និងក្រមសុភាធិបត្តិ សម្រាប់ដោះស្រាយជម្លោះរវាងប្រជាជន ក្រមដំរី សម្រាប់គ្រប់គ្រងលើដំរីនៅក្នុងព្រះរាជាណាចក្រ (MAK PHOEUN, 1995) ជាដើម (ត្រឹង ង៉ា, 1973)។ ច្បាប់ដែលពិនិត្យរួចត្រូវដាក់ឱ្យអនុវត្តនៅឆ្នាំ១៦២២ នៅក្នុងតុលាការ។

ស្ថានភាពភូមិសាស្ត្រនយោបាយការបរទេស៖ ព្រះបាទជ័យជេដ្ឋាទី២ ចាប់ផ្តើមមានទំនាក់ទំនងពាណិជ្ជកម្មជាមួយក្រុមហ៊ុនហូឡង់ East Indies (VOC) ដោយអនុញ្ញាតឱ្យក្រុមហ៊ុនបង្កើតត្រីស្ថានដំបូងនៅកម្ពុជា។ ចំណែកជនជាតិព័រទុយហ្គាល់ និងអេស្ប៉ាញផ្តោតសកម្មភាពលើការផ្សព្វផ្សាយសាសនាគ្រិស្ត ដោយព្យាយាមទាក់ទាញព្រះរាជា និងប្រជាពលរដ្ឋខ្មែរឱ្យងាកចេញពីការជឿសាសនាព្រះពុទ្ធ មកជឿសាសនាគ្រិស្តវិញ។

ខាងផ្នែកនយោបាយក្រៅប្រទេស ព្រះបាទជ័យជេដ្ឋាទី២ ងាកមកចងសម្ព័ន្ធភាពជាមួយវៀតណាម ដើម្បីទប់ទល់ជាមួយប្រទេសសៀម។ នៅឆ្នាំ១៦២៣ ព្រះអង្គទ្រង់បានអនុញ្ញាតឱ្យគណៈបេសកកម្មទូតវៀតណាមបង្កើត

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រើះស្ពានជំនួញនៅប៉ែកខាងត្បូងប្រទេសខ្មែរពីរ មានខេត្តព្រៃនគរ និងកំពង់ក្របី ព្រមទាំងសុំអនុញ្ញាតឱ្យមានសិទ្ធិកាន់កាប់ក្រសួងគយនៅទីនោះផង។ ចំណុចនេះ អ្នកប្រវត្តិសាស្ត្របានចាត់ទុកថា ជាយុទ្ធសាស្ត្រវាតទីរបស់វៀតណាម ដើម្បីដណ្តើមយកទឹកដីកម្ពុជា និងការចាប់ផ្តើមនយោបាយ «ដំណើរឆ្ពោះទៅទិសខាងត្បូង»។

ព្រះបាទជ័យជេដ្ឋាទី២ មានព្រះរាជបុត្រ៥អង្គ៖ (១) អ្នកអង្គទេពបញ្ញាក្សត្រី (២) ចៅពញាតូ (៣) ចៅពញានូ (៤) ចៅពញាចន្ទ និង (៥) ចន្ទវតីក្សត្រី (ឬបុប្ផាវតី)។

ព្រះបាទជ័យជេដ្ឋាទី២ បាននាំចៅពញាតូ ជាព្រះរាជបុត្រច្បងទៅបួសជាភិក្ខុនៅនគរវត្ត នៅពេលព្រះអង្គមានព្រះជន្ម២១ព្រះវស្សា។ ព្រះអង្គបានទំនុកបម្រុងព្រះអង្គច័ន្ទវតី ព្រះរាជបុត្រី ឱ្យជាព្រះជាយាកំណាន់នៃចៅពញាតូ ក្រោយពេលចាកសិក្ខាបទ។

៤.១.៣. ព្រះឧទ័យរាជា និងនយោបាយតុល្យភាពជាមួយអយុធ្យា

នៅឆ្នាំ១៦២៧ បន្ទាប់ពីព្រះបាទជ័យជេដ្ឋាទី២ចូលទិវង្គត ព្រះរាជបុត្រច្បង ព្រះរាជសំភារ ចៅពញាតូ ទ្រង់គង់នៅក្នុងព្រះផ្នួសជាភិក្ខុនៅនគរវត្ត។ ព្រះបរមរាជវង្សានុវង្ស និងនាហ្មឺនសព្វមុខមន្ត្រីក៏រៀបចំព្រះរាជពិធីព្រះរាជាភិសេក ថ្វាយព្រះឧទ័យ ដែលជាព្រះអនុជរបស់ព្រះបាទជ័យជេដ្ឋាទី២ ជាព្រះឧភយោរាជ ដើម្បីរក្សារាជសម្បត្តិទុកសិន ទម្រាំសម្ដេចព្រះអង្គតូចាកសិក្ខាបទ។ ប៉ុន្តែតែព្រះឧទ័យ (១៦២៧-១៦៤២) មានឋានៈជាព្រះឧភយោរាជ តែកិច្ចការទាំងអស់ស្ថិតនៅក្នុងការគ្រប់គ្រងរបស់ព្រះអង្គ ហើយព្រះអង្គងាកមកគាំទ្រនយោបាយណោបអយុធ្យា និងប្រឆាំងនឹងការធ្វើកំណែទម្រង់របស់ព្រះបាទជ័យជេដ្ឋាទី២។ ព្រះឧទ័យ បានរៀបអភិសេកជាមួយក្មួយស្រីព្រះអង្គ ដែលជាបុត្រីព្រះបាទជ័យជេដ្ឋាទី២ ព្រះនាមចន្ទវតី និង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទ្រង់តែងតាំងជាសម្តេចព្រះម៉ែ យូវតីត្រួតត្រាលើព្រះស្នំក្រមការទាំងពួង។ ព្រះអង្គបានបន្តពង្រឹងអំណាច ពង្រីកទំនាក់ទំនងរវាងកម្ពុជា ជាមួយអយុធ្យា និងចិត្តទុកដាក់ដល់ទំនាក់ទំនងពាណិជ្ជកម្មជាមួយក្រុមហ៊ុនឥណ្ឌាខាងកើតរបស់ហូឡង់ផងដែរ។ ព្រះឧទ័យ មានបុត្រ៤អង្គ គឺៈ (១) អ្នកអង្គនន់ទី១, (២) អ្នកអង្គសួរ, (៣) អ្នកអង្គតន់ និង (៤) អ្នកអង្គអិម (ឥន្ទ)។

ទំនាស់ផ្ទៃក្នុងរាជវង្សានុវង្សបានចាប់ផ្តើមឡើងរវាងព្រះឧទ័យរាជា ដែលចង់មានទំនាក់ទំនងជិតស្និទ្ធជាមួយអយុធ្យា និងសម្តេចព្រះមាតាអង្គចូវ ព្រះមហេសីនាមនៃព្រះបាទជ័យជេដ្ឋាទី២ ដែលចង់មានទំនាក់ទំនងជិតស្និទ្ធជាមួយក្រុងហ្វេ។ ដូចនេះហើយ មន្ត្រីដែលជិតស្និទ្ធនឹងសម្តេចព្រះមាតាអង្គចូវ បានទៅសុំឱ្យ ចៅពញាតូ សឹកចាកសិក្ខាបទ ដើម្បីថ្វាយតួនាទីជាសម្តេចព្រះវររាជមាតា ព្រះទាវព្រះកន្ទោង ដល់សម្តេចព្រះមាតាអង្គចូវ។ ព្រះអង្គជាព្រះរាជបុត្របង្កើតរបស់ព្រះបាទជ័យជេដ្ឋា និងអ្នកម្នាងសុទ។

នៅឆ្នាំ១៦២៧ ព្រះរាជសម្ភារ ចៅពញាតូ បានឡើងសោយរាជ្យជាព្រះបាទ ស្រីធម្មរាជា ទី១(១៦២៧-១៦៣២)។ ដោយសារទំនាស់ផ្ទៃក្នុង និងដើម្បីមានពេលតែនិពន្ធ ព្រះអង្គបានចាកចេញពីឧដុង្គ ដើម្បីមកគង់ប្រថាប់នៅគោកធ្លក ទន្លេធំ ជិតជ្រោយចង្វារ។ ថ្វីត្បិតតែព្រះបាទស្រីធម្មរាជាទី១ ជាព្រះមហាក្សត្រក៏ដោយ តែព្រះអង្គមានចំណង់ចំណូលចិត្តខាងផ្នែកសាសនា និងខាងផ្នែកតែងនិពន្ធ។ នៅឆ្នាំ ១៦៣៨-១៦៣៩ ព្រះអង្គបានធ្វើកំណែទម្រង់វេទនាសម្ព័ន្ធគ្រប់គ្រងវត្ត (MIKAELIAN, 2009)។ ព្រះរាជសម្ភារគឺជាកវីរាជក្នុងស.វ.ទី១៧។ ស្នាព្រះហស្តរបស់ព្រះអង្គមានច្បាប់រាជនីតិកំណាព្យ«ច្បាប់រាជសម្ភារ» (ឆ្នាំ១៦២២) លិខិតផ្ញើទៅថ្វាយព្រះម៉ែយូវត្តីពាក្យកាព្យសរសេរលើចុងត្នោត មុនពេលសុគតដោយទាហានព័រទុយហ្គាល់បាញ់កំណាព្យសរសើរហោមន្តមាស កំណាព្យ «កន្ទង់មាសមង្គលថ្ងៃ» កំណាព្យ «ព្រលឹងមាសអើយ» ច្បាប់ក្រម និងច្បាប់ហៃសាធុជន ឬច្បាប់ត្រីនេត្រ (លាង ហាប់អាន, ១៩៦៧)។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បន្ទាប់ពីមានវិបត្តិផ្ទៃក្នុងព្រះរាជវាំងជាមួយព្រះបិតុលា ព្រះឧទ័យ និងមានទំនាក់ទំនងស្នេហាជាមួយព្រះអម្ចាស់ចន្ទវតី ព្រះរាជសម្ភារ ចៅពញាតូ ត្រូវបានពួកអឺរ៉ុបសម្លាប់នៅឆ្នាំ១៦៣៣ តាមបញ្ជារបស់ព្រះឧទ័យ។ បន្ទាប់ពី ព្រះរាជសម្ភារ ចៅពញាតូ ចូលទិវង្គត ចៅពញានូ ដែលជាព្រះរាជបុត្រ ព្រះបាទជ័យជេដ្ឋាទី២ បានឡើងសោយរាជ្យសម្បត្តិដោយមានព្រះនាមជា ព្រះបាទអង្គទងរាជា ចៅពញានូ(១៦៣២-១៦៤០)។ព្រះអង្គបានទាមទារសុំ ព្រៃនគរ និងកំពង់ក្របីមកវិញ តែអង្គចូវសុំពន្យាពេល។ នៅក្នុងរាជ្យរបស់ ព្រះអង្គ ទំនាក់ទំនងពាណិជ្ជកម្មជាមួយក្រុមហ៊ុនហូឡង់នៅបន្តទៀត ដោយ ផ្ដោតលើការលក់កាំភ្លើងធំ និងកាំភ្លើងតូចពីអឺរ៉ុបមកកម្ពុជា។

បន្ទាប់ពីព្រះបាទអង្គទងរាជា ចូលទិវង្គត បុត្ររបស់ព្រះឧទ័យ ព្រះបាទ បទុមរាជាទី១ (អង្គនន់) (១៦៤០-១៦៤២) បានឡើងសោយរាជ្យសម្បត្តិបន្ត ហើយព្រះឧទ័យ នៅតែជាព្រះឧភយោរាជដដែល។ វិបត្តិក្នុងរាជវង្សបាន កើតមានឡើង ដោយសារតែបុត្ររបស់ព្រះបាទជ័យជេដ្ឋាទី២ ចៅពញាចន្ទ មិនបានឡើងសោយរាជ្យ។ ព្រះអង្គបានទាក់ទងជាមួយស្ដេចចម្ប៉ា ដើម្បីសុំ ការគាំទ្រពីកងទ័ពចាម ដើម្បីរៀបចំធ្វើគុតព្រះបាទបទុមរាជទី១ និងព្រះឧទ័យ នៅឆ្នាំ១៦៤២។

ក្រោយពីការផ្ដួលរំលំព្រះរាជាបានសម្រេច ចៅពញាចន្ទ ដែលជាបុត្រ ពៅរបស់ព្រះបាទជ័យជេដ្ឋាទី២ ជាមួយអ្នកម្នាងបុស្ស មានដើមកំណើតឡាវ បានឡើងគ្រងរាជ្យសម្បត្តិដោយមានព្រះនាមជាព្រះបាទរាមាធិបតីទី១ (១៦៤២-១៦៥៨)។ ព្រះអង្គបានរៀបអភិសេកជាមួយអ្នកម្នាងអ៊ិស្លាម និង បានចូលសាសនាអ៊ិស្លាម។ ព្រះអង្គបានយកជនជាតិចាមជាច្រើនចូលបម្រើ ក្នុងព្រះបរមរាជវាំង។ នៅឆ្នាំ១៦៥៨ មានសង្គ្រាមជាមួយក្រុងអយុធ្យា។

នៅក្នុងរាជព្រះអង្គ ទំនាក់ទំនងជាមួយក្រុមហ៊ុនដែលមានទំនាក់ទំនង ល្អជាមួយព្រះឧទ័យបានជួបនឹងវិបត្តិ។ គ្រឹះស្ថានជំនួញហូឡង់ត្រូវបានពួក ចាមប្លន់ មេគ្រឹះស្ថានជំនួញនិងបុគ្គលិកត្រូវបានគេសម្លាប់ ហើយទ្រព្យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្បត្តិត្រូវបានរឹបអូសអស់។ ក្រុមប្រឹក្សាក្រុមហ៊ុនបានបញ្ជូនកងនាវា និងទាហានមកធ្វើសង្គ្រាមជាមួយស្តេចខ្មែរនៅឆ្នាំ១៦៤៤ ដើម្បីទាមទារសំណង។ ដើម្បីបញ្ចប់សង្គ្រាម កិច្ចព្រមព្រៀងមួយត្រូវបានរៀបចំឡើងនៅឆ្នាំ១៦៥៥ ដោយជួសជុលសោហ៊ុយដល់គ្រឹះស្ថានជំនួញនេះ។

៤.១.៤. អន្តរាគមន៍យោធាលើកទី១របស់វៀតណាម

វិបត្តិនិងការសងសឹកក្នុងរាជវង្សបានបន្តទៀត ដោយបុត្ររបស់ព្រះឧទ័យ គឺព្រះអង្គសូរ និងព្រះអង្គតន់ បានសុំអន្តរាគមន៍ពីវៀតណាម ដើម្បីមកផ្តួលរំលំព្រះបាទរាមាធិបតីទី១។ នៅឆ្នាំ១៦៥៨-៥៩ វៀតណាមបានធ្វើអន្តរាគមន៍យោធាលើកទី១ ដើម្បីជួយស្តេចខ្មែរឱ្យឡើងសោយរាជ្យ។

បន្ទាប់ពីព្រះបាទរាមាធិបតីទី១ ត្រូវបានធ្វើគុតរួចមក ព្រះអង្គសូរបានឡើងសោយរាជ្យសម្បត្តិ ដោយមានព្រះនាមថាព្រះបាទបរមរាជាទី៨ (អង្គសូរ) (១៦៥៩-១៦៧២) ចំណែកព្រះអង្គតន់ត្រូវបានតែងតាំងជាឧភយោរាជ។ ក៏ប៉ុន្តែនៅក្នុងរាជ្យព្រះអង្គ មានការប្រកួតប្រជែងរវាងព្រះរាជា ដែលជាអ្នកការពារនិគមចិនដែលចូលមករស់នៅកម្ពុជា និងព្រះអនុជអង្គតន់ ដែលការពារជនជាតិវៀតណាម ហើយដែលប្រវត្តិវិទូសន្និដ្ឋានថា អាណាចក្រខ្មែរត្រូវបានចែកជាពីរ មួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជា និងមួយផ្នែកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឧបយោរាជ ហើយប្រជាជនខ្មែរទទួលរងគ្រោះយ៉ាងខ្លាំងដោយសារការបែកបាក់នេះ។ នៅឆ្នាំ១៦៦៥ បេសកជនបព្វជិតបារាំងទី១ ឈ្មោះ LOUIS CHEVREUL បានមកដល់កម្ពុជាជាលើកដំបូង (MAK PHOEUN, 1995)។ នៅក្នុងរាជ្យព្រះអង្គ ព្រះបាទបរមរាជាទី៨ បានឈប់លើកសួយសារអាករទៅឱ្យវៀតណាម។

ជម្លោះផ្ទៃក្នុងនេះបានបង្កើតនូវអស្ថិរភាពនយោបាយ។ ស្ថានភាពផ្ទៃក្នុងប្រទេស និងទំនាក់ទំនងជាមួយបរទេសក៏កាន់តែយ៉ាប់យ៉ឺនទៅ។ នៅឆ្នាំ១៦៧២ ព្រះអង្គសូរ ត្រូវក្មួយ និងជាបុត្រសុណិសា ស្រីជ័យជេដ្ឋ ដែលជាបុត្ររបស់ព្រះបាទបទុមរាជា អង្គនន់ លួចធ្វើគុត ដើម្បីឡើងសោយរាជ្យ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រះអង្គតន់ ជាឧកយោរាជច្បាំងចាញ់ ក៏រត់ទៅវៀតណាម។ ការធ្វើគុតនេះ បានធ្វើឱ្យស្ថានភាពផ្ទៃក្នុងអាណាចក្រខ្មែរកាន់តែធុនដាបទៅ។ ព្រះបាទស្រីជ័យជេដ្ឋ ឡើងសោយរាជ្យសម្បត្តិ ដោយមានព្រះនាមថា ព្រះបទុមរាជាទី២ (១៦៧១-១៦៧២) ហើយយកអគ្គមហេសីព្រះអង្គសូរ ព្រះទាវក្សត្រីជាអគ្គមហេសី។

៤.១.៥. អន្តរាគមន៍យោធាលើកទី២របស់វៀតណាម

ព្រះបាទបទុមរាជាទី២ សោយរាជ្យមិនបានមួយឆ្នាំផង ហើយ៥ខែក្រោយមក សម្តេចព្រះរាជអគ្គមហេសីបានឃុបឃិតឱ្យគេធ្វើគុតព្រះបទុមរាជាទី២ ហើយលើកបុត្រព្រះអង្គសូរ (ចៅព្រះឧទ័យ) ព្រះនាមអង្គជីឱ្យឡើងសោយរាជ្យ ដោយមានព្រះនាមថា កែវហ្វ៊ាទី២ (១៦៧៣-១៦៧៥)។ ស្តេចអង្គនេះបានចាប់មន្ត្រីជាន់ខ្ពស់ ដែលបានក្បត់នឹងព្រះបិតាព្រះអង្គ ហើយអ្នកខ្លះបានរត់ទៅនៅឯបរទេស។ ព្រះអង្គថែមទាំងធ្វើគុតព្រះទាវក្សត្រី ថែមទៀតផង។ ក៏ប៉ុន្តែ នៅក្នុងរាជ្យរបស់ព្រះអង្គ ព្រះបិតុលា ព្រះអង្គតន់ ដែលរត់ទៅវៀតណាម និងព្រះរាជវង្សម្នាក់ទៀតព្រះនាមអង្គនន់ (បុត្ររបស់អង្គអិម កើតនៅឆ្នាំ១៦៥៥-៥៦ បានពឹងទ័ពយួនមកច្បាំងដណ្តើមរាជ្យ។

វៀតណាមបានលើកទ័ពមកធ្វើអន្តរាគមន៍យោធាលើកទី២ នៅកម្ពុជានៅឆ្នាំ១៦៧៣-៧៩។ គោលដៅនៃអន្តរាគមន៍នេះ គឺដើម្បីធានាឱ្យដំណើរការនៃការវិវត្តនយោបាយនៅកម្ពុជាបន្តបម្រើផលប្រយោជន៍របស់វៀតណាម។ អន្តរាគមន៍នេះមានគោលដៅបីគឺ៖ (១) គាំទ្រដល់អង្គនន់ ដែលរត់មករកកន្លែងជ្រកកោននៅវៀតណាម (២) ការពារដល់ជនជាតិវៀតណាមដែលរស់នៅតាមតំបន់ព្រំដែន និង (៣) ទប់ទល់នឹងឥទ្ធិពលសៀមមកលើកម្ពុជា។ ដោយសង្គ្រាមគ្មានឈ្នះចាញ់ ប្រទេសត្រូវបានបែងចែកជាពីរខាងលិចគ្រប់គ្រងដោយព្រះកែវហ្វ៊ាអង្គជី និងខាងកើតដោយព្រះអង្គតន់។

ដើម្បីទប់ទល់នឹងវៀតណាម ព្រះកែវហ្វ៊ា អង្គជី បានទៅសុំជំនួយពីក្រុងអយុធ្យា។ ដើម្បីចៀសវាងចម្បាំងជាមួយសៀម វៀតណាមក៏សម្រេច

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចិត្តដកទ័ពចេញពីកម្ពុជា។ ថ្វីត្បិតតែកងទ័ពវៀតណាមបានដកទៅអស់មែន តែស្ថានភាពនយោបាយផ្ទៃក្នុង នៅតែតានតឹង ដោយសារសង្គ្រាមផ្ទៃក្នុង នៅតែបន្តរវាងបក្សពួករបស់ព្រះមហាក្សត្រ កែវហ្វ៊ាទី២ អង្គជី និងបក្សពួករបស់ឧកយោរាជបទុមរាជា(អង្គនន់) ដែលមកតាំងទីលំនៅនៅកោះស្លាកែត ហើយបញ្ជូនទ័ពមកវាយទីតាំងស្រីសន្ធរ។

ដោយយល់ឃើញថាឧកយោរាជក្បត់នឹងពាក្យសន្យាឈប់ច្បាំង ព្រះបាទកែវហ្វ៊ាទី២ បានទុកឱ្យព្រះអនុជព្រះអង្គជ័យជេដ្ឋា(អង្គសូរ) នៅគ្រប់គ្រងឧដុង្គ ហើយបានមកកេណ្ឌទ័ពនៅខេត្តសំពៅទង។ សង្គ្រាមរវាងព្រះរាជានិងឧបកយោរាជនៅបន្តក្នុងរយៈពេលបីឆ្នាំ(១៦៧៤-៧៧) ដោយសារតែកម្លាំងរបស់ឧកយោរាជអង្គនន់ មានប្រៀបជាង។ ព្រះកែវហ្វ៊ាអង្គជីបានចូលទិវង្គតដោយព្រះអាពាធ។

បន្ទាប់ពីព្រះកែវហ្វ៊ាអង្គជី បានចូលទិវង្គត ព្រះអនុជជ័យជេដ្ឋា (អង្គស៊ូ) បានឡើងគ្រងរាជ្យសម្បត្តិ ដោយមានព្រះនាមថា ជ័យជេដ្ឋាទី៣ (រជ្ជកាលទី១) (១៦៧៧-១៦៩៥) នៅពេលព្រះអង្គមានព្រះជន្មាយុ១៦វស្សានៅឡើយ។ ស្ថានភាពនយោបាយផ្ទៃក្នុងកម្ពុជានៅតែមានភាពតានតឹងដដែល ដោយសារសង្គ្រាមក្នុងស្រុកនៅតែបន្ត។ ឯកសារខ្លះបានបញ្ជាក់ថា ព្រះរាជាថ្មីទទួលបានការគាំទ្រខាងផ្នែកយោធាពីព្រះចៅក្រុងអយុធ្យា ណារ៉ៃ។ បន្ទាប់ពីចាញ់សឹកសង្គ្រាមអង្គនន់ បានភៀសព្រះកាយទៅវៀតណាម ហើយស្ថានភាពនៅកម្ពុជាក៏ស្ងប់មួយរយៈ។

នៅចុងសតវត្សទី១៧ ការផ្លាស់ប្តូររាជវង្សប្រទេសចិន ពីរាជវង្សមីងទៅរាជវង្សឈីង ហើយបានជំរុញឱ្យអតីតទាហាននៃរាជវង្សមីងបានចាកចេញពីប្រទេសចិន ដើម្បីរស់នៅលើដែនដីសណ្តទន្លេមេគង្គ។ ចិនមួយក្រុមក្រោមការដឹកនាំរបស់ឈ្មួញចិនម៉ាកគីវ (Mac Cuu) មកពីខេត្តក្វាងទុងបានមកដល់ក្រុងកម្ពុជានៅឆ្នាំ១៦៧១ ហើយត្រូវបានព្រះបាទជ័យជេដ្ឋាទី៣ ផ្តល់គោរមងារជាឧកញ៉ា ហើយរស់នៅក្នុងតំបន់ពាម (ហាទៀង)។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៤.១.៦. អន្តរាគមន៍យោធាលើកទី៣របស់វៀតណាម

នៅប្រទេសវៀតណាម អង្គនន់ និងអ្នកម្នាងដើមកំណើតចិនប្រសូតបានបុត្រមួយអង្គ ព្រះនាមអង្គអិម។ ព្រះអង្គនៅតែរកឱកាសដើម្បីស្វែងរកជំនួយយោធា មកធ្វើសង្គ្រាមជាមួយព្រះបាទជ័យជេដ្ឋាទី៣។ នៅព្រៃនគរ អង្គនន់ ប្រមូលបានអតីតទ័ពចិនរជ្ជកាលមីង ដែលបានរត់ចេញពីប្រទេសចិន ដោយសន្យាថានឹងផ្តល់ដីឱ្យពួកគេនៅពេលច្បាំងឈ្នះ។ ក្នុងឆ្នាំ១៦៧៩ កងទ័ពចិនរជ្ជកាលម៉េងចំនួន៣០០០នាក់ បានជិះសំពៅភៀសខ្លួនសុំជ្រក-កោនជាមួយវៀតណាម។ ស្តេចវៀតណាម ហៀនវួង បានបញ្ជូនពួកគេឱ្យមករស់នៅជិតព្រៃនគរ និងនៅតំបន់មីថូដែលនៅពេលនោះនៅជាដីខ្មែរនៅឡើយ។ នៅឆ្នាំ១៦៨២ វៀតណាម ដោយមានជំនួយពីវៀតណាមផង អង្គនន់បានដឹកនាំទ័ពវៀតណាម និងចិនមកធ្វើអន្តរាគមន៍យោធានៅតំបន់បារៀ និងដូនណាយ ហើយកាន់កាប់ព្រៃនគរ។ នៅខែធ្នូឆ្នាំ១៦៧៩ ទ័ពអង្គនន់បានវាយយកបានរាជធានីឧដុង្គ។

ព្រះបាទជ័យជេដ្ឋាទី៣ បានសុំជំនួយពីសៀម តែក្រុងអយុធ្យាបញ្ជូនទាហានមកតិចតួច។ ព្រះរាជាបានកេណ្ឌទ័ពជាថ្មី ហើយចាប់វាយបកទៅទ័ពអង្គនន់វិញ។ បន្ទាប់ពីបំផ្លិចបំផ្លាញឧដុង្គហើយ ទ័ពចិនទាំងនោះក៏ដកចេញវិញអស់។ នៅអំឡុងឆ្នាំ១៦៨២ ព្រះបាទជ័យជេដ្ឋាទី៣ បានយាងចូលមកប្រថាប់នៅឧដុង្គវិញ ចំណែកឯទ័ពអង្គនន់ វិញបានបោះទីតាំងនៅស្រីសន្ធរ។ កម្ពុជាត្រូវបានបែងចែកជាពីរម្តងទៀត។ នៅពេលនោះ ព្រះបាទជ័យជេដ្ឋាទី៣ បានបញ្ជូនបេសកជនទៅសុំជំនួយពីស្តេចសៀមម្តងទៀត។ ព្រះចៅក្រុងអយុធ្យាបានបញ្ជូនទ័ពជាច្រើនម៉ឺននាក់តាមផ្លូវគោកមកកម្ពុជា។

ចំណែកឯនៅអយុធ្យាវិញ នៅឆ្នាំ១៦៨៨ ស្តេចណារ៉ៃ ទ្រង់ប្រឈួនខ្លាំង។ នៅអយុធ្យាមានចលាចលមួយយ៉ាងធំប្រឆាំងនឹងវត្តមានបរទេស។ មេកងដំរីរបស់រាជវាំង ឈ្មោះ កេត្រាចា បានរៀបចំផែនការដកតំណែងរបស់ប៉ូលកុន និងក្តោបយកអំណាច។ នៅឆ្នាំ១៦៨៨ កេត្រាចា បានជ្រែករាជ្យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាព្រះរាជានៅអយុធ្យា។

៤.១.៧. អន្តរាគមន៍យោធាលើកទី៤របស់វៀតណាម

នៅឆ្នាំ១៦៨៧-៨៨ ព្រះបាទជ័យជេដ្ឋាទី៣ ទ្រង់ប្រឈួនដោយជំងឺអុតគ្រុន និងហឺត។ ព្រះអង្គក៏ដាក់រាជ្យថ្វាយព្រះរាជមាតាព្រះទាវ។ បន្ទាប់ពីជាពីជំងឺព្រះអង្គបានបួសជាបព្វជិតនៅវត្តព្រះសុគន្ធមានបុណ្យ។ នៅឆ្នាំ១៦៨៨-៨៩ មន្ត្រីជាន់ខ្ពស់នៃព្រះរាជវាំងពីរនាក់បានក្បត់ ហើយទៅចុះចូលជាមួយឧកយោរាជអង្គនន់។ ភាគីទាំងសងខាងចាប់ផ្ដើមប្រយុទ្ធគ្នាឡើងវិញ។ នៅឆ្នាំ១៩៨៩ វៀតណាមបានបញ្ជូនកងទ័ពមកធ្វើអន្តរាគមន៍យោធាលើកទី៤ ដើម្បីជួយអង្គនន់។ បន្ទាប់ពីវាយយកបានភ្នំពេញ និងឧដុង្គរួចមកស្ដេចខ្មែរបានសន្យាថានឹងលើកសួយសារអាករទៅឱ្យវៀតណាម ទើបកងទ័ពនេះដកចេញពីកម្ពុជាវិញ។ នៅឆ្នាំ១៦៩០ កងទ័ពវៀតណាមបានវាយចូលកម្ពុជាម្ដងទៀតតែត្រូវទទួលបរាជ័យនៅជិតឧដុង្គ។ បន្ទាប់ពីវាយឈ្នះទ័ពវៀតណាម រួចមកនៅឆ្នាំ១៦៩០ ព្រះបាទជ័យជេដ្ឋាទី៣ បានរៀបអភិសេកឡើងសោយរាជ្យក្នុងជន្មាយុ៣០ព្រះវស្សាជាមួយនឹងព្រះអង្គម្ចាស់ក្សត្រីអង្គអីក្សត្រី។ ឧកយោរាជអង្គនន់ ប្រឈួន ហើយចូលទិវង្គតនៅស្រីសន្ធរនៅឆ្នាំ១៦៩១-៩២ ហើយសង្គ្រាមក្នុងស្រុកក៏ត្រូវបានបញ្ចប់។

ជម្លោះក្នុងរាជវង្សខ្មែរមិនត្រឹមតែនាំឱ្យកម្ពុជាបាត់បង់ឯករាជ្យប៉ុណ្ណោះទេ តែថែមទាំងបាត់បង់ទឹកដីទៀតផង។ បន្ទាប់ពីអង្គនន់ចូលទិវង្គតមកមេទ័ពចិនបាននាំទាហានមកតាំងទីលំនៅក្នុងតំបន់កូសាំងស៊ីន ដូចជាព្រៃនគរដូនណាយ និងបារៀ ដែលគេចាត់ទុកថាជាដីរបស់ពួកគេ។ ជាលទ្ធផលនៃអន្តរាគមន៍យោធារបស់វៀតណាមនៅកម្ពុជានៅឆ្នាំ១៦៩០ គឺជាការទទួលបានដីខ្មែរនៅកម្ពុជាក្រោម ហើយកងទ័ពវៀតណាមបានចូលកាន់កាប់ជាផ្លូវការទឹកដីទាំងនោះ នៅឆ្នាំ១៦៩៨ បន្ទាប់ពីមេបញ្ជាការយោធាវៀតណាមត្រូវបានតែងតាំងជាអគ្គទេសាភិបាលនៃដែនដីកម្ពុជាក្រោម។ ក្រុងអយុធ្យាក៏ទទួលបានផលប្រយោជន៍ពីជម្លោះនេះដែរ បន្ទាប់ពីបានជួយដល់ព្រះបាទ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជ័យជេដ្ឋាទី៣ ក្នុងការទប់ទល់ជាមួយអង្គទន់ ក្នុងឆ្នាំ១៦៨០។ ព្រឹត្តិការណ៍នេះជួយសៀមឱ្យគ្រប់គ្រងទាំងស្រុងលើខេត្តស៊ីសាកេត ចុងកាល់ សុរិន និងគោកខាំ ហើយព្រំដែនខាងលិចនៃប្រទេសសៀមក្នុងរជ្ជកាលព្រះចៅណារ៉ៃបានយកខេត្តខ្មែរនៅនគរាជសីមា និងចន្ទបុរីចូលទៀតផង។ កម្ពុជាបានក្លាយទៅជាសាមន្តរដ្ឋនៃក្រុងអយុធ្យា (KHIN SOK, 1995)។

៤.១.៨. កំណែទម្រង់ជ័យរដ្ឋនៃរជ្ជកាលជេដ្ឋាទី៣

បន្ទាប់ពីទទួលបានសន្តិភាពវិញមក ព្រះបាទជ័យជេដ្ឋាទី៣ បានចាប់ផ្ដើមពង្រឹងការគ្រប់ប្រទេសឡើងវិញ ដោយផ្លាស់ប្ដូររាជធានីជាញឹកញាប់ ដូចជានៅស្រះកែវ (ឧដុង្គ) នៅកណ្ដាលច្រាំតម្លង និងនៅបន្ទាយពេជ្រជាដើម។ ទន្ទឹមនឹងនេះ ព្រះអង្គបានបញ្ជាឱ្យនាហ្មឺន និងសម្ដេចព្រះសង្ឃរាជ ព្រះសុគន្ធាធិបតី ពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មលើច្បាប់មួយចំនួន ដើម្បីបន្ធូរបន្ថយទោសទណ្ឌ ដែលមានលក្ខណៈតឹងតែងពេកសម្រាប់ប្រជារាស្ត្រ និងដើម្បីសមស្របទៅតាមកាលៈទេសៈផងដែរ។ ព្រះអង្គបានតែងតាំងមន្ត្រីជាន់ខ្ពស់ ដែលមានថ្វីដៃក្នុងការបំពេញការងារ មានស្វាមីភក្តិនឹងព្រះអង្គ និងដែលបានដឹកនាំការប្រយុទ្ធប្រកបដោយជោគជ័យ ឱ្យកាន់តំណែងសំខាន់ៗ ជាពិសេសជា ឧកញ៉ាវាំង និងឧកញ៉ាយមរាជ និងជាអភិបាលខេត្តផងដែរ។

ការតែងតាំងមន្ត្រីជាន់ខ្ពស់៖ ឧកញ៉ា យមរាជ ជ័យ នន្ទ សិលាចារឹកទី៣៦ ឆ្នាំ១៦៩៧ និងលេខ៣៨។

នៅឆ្នាំ១៦៩១-៩២ សង្គ្រាមបានផ្ទុះឡើងរវាងអាណាចក្រហ្លួងព្រះបាង និងវៀងចន្ទ។ អ្នកអម្ចាស់នៃអាណាចក្រវៀងចន្ទ បានរួមគំនិតក្បត់ជាមួយព្រះចៅហ្លួងព្រះបាង ដើម្បីដណ្ដើមរាជ្យពីព្រះមហាក្សត្រ។ តែព្រះមហាក្សត្រវៀងចន្ទបានលើកម្ចាស់ក្សត្រីឱ្យទៅព្រះចៅក្រុងអយុធ្យា ដើម្បីចងសម្ព័ន្ធភាព ហើយទទួលបានជំនួយយោធាពីសៀម។ ដោយភ័យខ្លួន អ្នកអម្ចាស់រូបនោះបានរត់គេចខ្លួនមករស់នៅកម្ពុជា។ ម្យ៉ាងវិញទៀត នៅឆ្នាំ១៦៩២ បន្ទាប់ពី

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រាំងចាញ់វៀតណាម ស្តេចចាមបានសុំជ្រកកោនជាមួយខ្មែរផងដែរ។

នៅឆ្នាំ១៦៩៥ ព្រះបាទជ័យជេដ្ឋាទី៣ សម្រេចចិត្តដាក់រាជ្យម្តងទៀតដើម្បីបួសបម្រើសាសនាព្រះតថាគត ដែលជាទម្លាប់ធម្មតាសម្រាប់មន្ត្រីជាន់ខ្ពស់សម័យនោះដើម្បីធ្វើបុណ្យសាងកុសលសម្រាប់ជាតិខាងមុខ។ ព្រះបាទរាមាធិបតីទី២ (អង្គយ៉ង) (១៦៩៥-១៦៩៦) ដែលជាបុត្រអង្គជី (៨) និងជាចៅទួត ព្រះឧទ័យ និងជាបុត្រសុណិសារបស់ព្រះអង្គឡើងស្នងរាជ្យបន្ត។ នៅក្នុងរាជ្យព្រះអង្គគ្មានព្រឹត្តិការណ៍អ្វីធំដុំឡើយ។ ឡើងសោយរាជ្យមិនបានមួយឆ្នាំផង ព្រះរាជាក៏អាពាធ ហើយចូលទិវង្គត។

ព្រះបាទជ័យជេដ្ឋាទី៣ បានឡើងសោយរាជ្យឡើងវិញ (១៦៩៦-១៧០០) ដែលជាការឡើងសោយរាជ្យទី២ របស់ព្រះអង្គ។ ដើម្បីបញ្ចប់ជម្លោះក្នុងរាជវង្សានុវង្ស ព្រះបាទជ័យជេដ្ឋាទី៣ បានអនុវត្តនូវនយោបាយបង្រួបបង្រួមរាជវង្ស ដោយបញ្ជូនទូតទៅចរចាសុំវៀតណាម ឱ្យបញ្ជូនព្រះរាជបុត្ររបស់អង្គនន់ និងអ្នកម្នាងចិន ព្រះនាម អង្គអិម មករស់នៅឧដុង្គវិញ។ បន្ទាប់មកព្រះអង្គក៏បានរៀបអភិសេក ព្រះអង្គអិម ជាបុត្រសុណិសារបស់ព្រះអង្គទោះបីមានការជំទាស់ពីមន្ត្រីជាន់ខ្ពស់ ដែលយល់ឃើញថា ក្សត្រអង្គនេះធ្លាប់មានទំនាក់ទំនងជិតស្និទ្ធជាមួយវៀតណាម។ នយោបាយបង្រួបបង្រួមរាជវង្សនេះមិនបានបញ្ចប់ជម្លោះឡើយ។ ផ្ទុយទៅវិញ អង្គអិម បានក្លាយជាគូបដិបក្សនៃព្រះរាជបុត្រព្រះបាទជ័យជេដ្ឋាទី៣ ដែលនាំមកនូវសង្គ្រាមក្នុងស្រុកសារជាថ្មី និងជាដើមចមនាំឱ្យមានអន្តរាគមន៍យោធាពីបរទេស។

៤.១.៦. អន្តរាគមន៍យោធាលើកទី៥របស់វៀតណាម

នៅឆ្នាំ១៦៩៩-១៧០០ វៀតណាមបានលើកទ័ពវាយចូលកម្ពុជាជាលើកទី៥ តាមការស្នើសុំរបស់ឧកញ្ញាវេទ្ទ ឥម មន្ត្រីជាន់ខ្ពស់នៅឧដុង្គដែលមិនពេញចិត្តនឹងព្រះរាជា ហើយរត់ទៅពឹងវៀតណាមមកធ្វើអន្តរាគមន៍យោធា។ ក៏ប៉ុន្តែ មូលហេតុពិតនៃការវាយលុកនេះប្រហែលជាមានគោលដៅរាតទីយកទឹកដី។ កងទ័ពវៀតណាមត្រូវបានកងទ័ពខ្មែរវាយរត់ខ្ចាត់ខ្ចាយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បន្ទាប់ពីបានប្រយុទ្ធគ្នានៅតំបន់លង្វែក ភ្នំពេញ និងគៀនស្វាយ។ ជារួមនៅចុងសតវត្សទី១៧ វៀតណាមបានចូលមកវាយលុកធ្វើសង្គ្រាមចំនួន៥ លើកនៅកម្ពុជា ដើម្បីបន្តពង្រីកដែនដីរបស់ខ្លួននៅកូសាំងស៊ីន។ ព្រះបាទជ័យជេដ្ឋាទី៣ បានរុញកងទ័ពវៀតណាមចេញទៅវិញពីភាគកណ្តាលនៃប្រទេស តែពួកគេបានបោះទីតាំង និងរៀបចំបង្កើតខេត្តថ្មីនៅកម្ពុជាក្រោម ដើម្បីជំរុញឱ្យប្រជាជនគេមកតាំងទីលំនៅនៅទីនោះ និងដើម្បីទទួលយកនិគមចិនដែលរត់ចេញពីប្រទេសចិនផងដែរ។

ដូច្នេះ វិបត្តិក្នុងសម័យឧដុង្គកើតឡើងដោយសារកត្តាមួយចំនួន ដូចជាកត្តាភូមិសាស្ត្រនយោបាយ ដំណើរទៅទិសខាងត្បូងនៃជនជាតិវៀតណាម ទំនាស់ក្នុងរាជវង្សខ្មែរដើម្បីដណ្តើមរាជ្យ និងការបែកបាក់ផ្ទៃក្នុងមន្ត្រីជាន់ខ្ពស់ខ្មែរ។

៤.២. ភាសាខ្មែរកណ្តាលនៅសតវត្សទី១៧ ក្នុងសម័យឧដុង្គ

៤.២.១.កំណែទម្រង់ច្បាប់ និងវាក្យសព្ទតិយុត្តិនៃភាសាខ្មែរកណ្តាល

នៅក្រោមសម័យលង្វែក កវីនិពន្ធខ្មែរបានតែងនិពន្ធរឿងរាមកេរ្តិ៍ ដែលជាវណ្ណកម្មអក្សរសិល្ប៍ដ៏ពិសិដ្ឋនៃសតវត្សទី១៦។ នៅដើមសតវត្សទី១៧ គេមិនសូវឃើញមានសិលាចារឹក។

សិលាចារឹកលេខ ៧ (ស.ក.១៥៤៤-គ.ស.១៦២២ ពីរឆ្នាំក្រោយការចាប់ផ្តើមសម័យឧដុង្គ ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ (១៦១៩-១៦២៧)។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



IMA-7

សព្វមសតុជៃយាសទិតិរេក ១៥៤២ ចហ នក្សត្រ
ខែកទ្របុត្រ ១៥ រោចថ្ងៃយ

ដើម្បីពង្រឹងស្ថាប័នរដ្ឋ ព្រះបាទស្រីសុរិយោពណ៌បានរៀបចំបង្កើតឱ្យមានក្រមច្បាប់មួយចំនួន ក្នុងគោលដៅពង្រឹងវិស័យយុត្តិធម៌។ ព្រះបាទជ័យជេដ្ឋាទី២ បានបន្តព្រះរាជកិច្ច ក្នុងការធ្វើកំណែទម្រង់ច្បាប់នៅក្នុងប្រព័ន្ធតុលាការខ្មែរ ដោយយល់ឃើញថាមានក្រមមួយចំនួនមិនទាន់មានភាពយុត្តិធម៌នៅឡើយ។ កំណែទម្រង់ច្បាប់នេះមានបច្ច័យសំខាន់ពីរយ៉ាងគឺ៖ (១) វាក្យសព្ទនៃភាសាខ្មែរកណ្ដាលកាន់តែសំបូណ៌បែប និង (២) កម្ចីវាក្យសព្ទពីភាសាសៀម។

ការរៀបចំ និងអនុម័តច្បាប់នៅដើមសម័យឧដុង្គបានចូលរួមចំណែកក្នុងការវិវត្តភាសាខ្មែរ កណ្ដាលឱ្យកាន់តែសម្បូណ៌បែបខ្លាំងឡើងថែមទៀតជាពិសេស គឺការប្រើប្រាស់ពាក្យក្នុងវិស័យគតិយុត្ត និងតុលាការក្នុងគោលដៅពង្រឹងអភិបាលកិច្ច និងកសាងស្ថាប័ន ដើម្បីឱ្យសង្គមខ្មែរកាន់តែមានស្ថិរភាពតាមរយៈការលើកកម្ពស់ការគោរពច្បាប់។

នៅដើមសតវត្សទី១៧ នៅសម័យឧដុង្គ បន្ទាប់ពីកំណែទម្រង់វិស័យច្បាប់ និងតុលាការ ភាសាខ្មែរកណ្ដាលបានវិវត្តខិតជិតភាសាខ្មែរទំនើប និងមានវាកសព្ទសម្បូណ៌បែបខាងផ្នែកច្បាប់ និងតុលាការផងដែរ។ យើងសង្កេតឃើញការវិវត្តសូរសព្ទផងដែរ។ ឧទាហរណ៍ ការវិវត្តនៃពាក្យ «កោន» នៅសម័យអង្គរមក «កូណ» នៅដើមសម័យឧដុង្គ ហើយក្លាយជា «កូន» នាពេលបច្ចុប្បន្ន។ វាក្យសព្ទពាក់ព័ន្ធនឹងព្រះពុទ្ធសាសនាត្រូវបានប្រើប្រាស់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យ៉ាងទូលំទូលាយ ហើយមិនមានការប្រែប្រួលមកដល់សព្វថ្ងៃនេះ ដូចជាពាក្យ «និមន្ត»។ ម្យ៉ាងវិញទៀត យើងឃើញលេចឡើងនូវពាក្យកម្ចីពីភាសាសៀមផងដែរ នៅក្នុងវាក្យសព្ទរដ្ឋបាល ដូចជាពាក្យ «ចៅមឿង» និង «ពាន់» ជាដើម។

ក្រោយពេលដែលសៀមបានមកវាយកម្ទេចក្រុងលង្វែកនៅចុងសតវត្សទី១៦ សៀមបានប្រមូលយកគម្ពីរក្បួនខ្នាតអ្នកចេះដឹងទាំងឡាយយកទៅអស់។ តាំងពីនោះមក ខ្មែរយើងសរសេរពាក្យដែលកម្ចីពីបាលីសំស្ក្រឹតលែងត្រូវទៀតហើយ។ ក្រោយបែកលង្វែកមានសិលាចារឹកពេញលេញតែមួយគត់ គឺ IMA-6 ដែលចារដោយឧត្តមមន្ត្រី ឱកហ្លួងអព្ភរាជ នៅឆ្នាំ១៥៩៩ ដែលលោកនៅបន្តគ្រប់គ្រងប្រទេសពីសម័យលង្វែកតមក។ ក៏ប៉ុន្តែនៅដើមសតវត្សទី១៧ គេលែងឃើញមានសិលាចារឹក រហូតដល់ឆ្នាំ១៦២២ មានសិលាចារឹកខ្លីមួយ ហើយនៅឆ្នាំ១៦២៥ និងនៅឆ្នាំ១៩២៧ ទើបមានសិលាចារឹកពីរដ៏វែង។

សិលាចារឹកលេខ៨

(ស.ក.១៥៤៧-គ.ស.១៦២៥ សម័យឧដុង្គ ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ (១៦១៩-១៦២៧)។

សព្វមស្តុ (សំ. សុភមស្តុ= សេចក្តីល្អចូរមានដល់ខ្ញុំ) ជយ្យាតិរេក (សូមឱ្យបានជោគជ័យធំធេង) ១៥៤៧ ស.ក. ឆ្នាំវអ្នក្សត្រ ខែមាឃបួនរោច ថ្ងៃអាទិត្យ ឱកហ្លួងចក្រីឥន្ទ្រេងនិមន្តព្រះអរិយសង្ឃដោងជំនុំដើម្បីមូលហេតុដូចតទៅ។ ឱក្កហ្លួង រាជាតេជះហ ជាបង ឱកហ្លួង ចក្រី ឥន្ទ្រេង ប្រោសខ្ញុំទាំងគ្រួសារ មានកូនបីនាក់ មួយកើតក្នុងបំរេម្រាស ឪពុកឈ្មោះ យុន បញ្ចង់ រទយ ប្រពន្ធ ឈ្មោះ មេអេព្វ កូនប្រុសឈ្មោះ កីរ១ ឈ្មោះ...១ ស្រី១ ឈ្មោះ មេ...ក្នុងបំរេម្រាសឱយឱកហ្លួងចក្រីឥន្ទ្រេ...កាន់បណ្តាំបំរេម្រាសដោងឱ្យខ្ជាប់។ កាលនោះ តមានចៅ កុសល ១ ចៅ អន កូនគាត់ឯង ១

ពង្សាបរទេស ១ ឱកហ្លួង រាជាអប្បករ ១ អ្នក សង្ឃវរសត្ថា ១ ឱកហ្លួង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពង្សានកុល ១ ប្ញា...រ ១ ប្ញាច័ន្ទ្រ ១ អ្នកស្តេចព្រះ យស្សជរ ១ អ្នក ម្ចាថេរសរ ១ ប្ញា ន្អក ១ ចៅរ ជ្ញែយ ១ ប្ញា អន ១ ប្ញា នោក ១ ឥស្សអ្នកទាំងអម្បាលនោះជាសាក្សីៗ ឱកហ្ញូង រាជាតេជ្ជះប្រោសខ្ញុំ សាងសង់ព្រះៗ

អ្នកស្តេំច យស ឯង បន្ទាប់ពីឆ្នាំខាល ចៅមឿង (មេភូមិ) ប្រាំពីរនោះហើយ លុះដល់២៤ ឆ្នាំក្រោយមក ជាឆ្នាំឆ្លូវនៃទេមេសរ ស្តីពី(ស្រិតី) រិវាទ (ព្យីពាធិ) បំប្រមាស នាំក្តីមកដល់អស់ចៅក្រម ([ប្ញា]វក្រំមសូភា) ពេកក្តិពិ ពាក្យានាមក្តិតលប្ញារ[ព]ញា សូរេន ឥន្ទ្រារាជិប្បត្តិ ស្រីយអង្គឯកអត្តសេ[ន] យោទ្ធាភិមុក្ខអង្គរ ឥន្ទ្រិប្រាស្ស កាត់ក្តីនេះជា ទៃហមំប្រមាសហោងៗ ទើបឱយឱកហ្ញូង ចក្រ្កី ឥន្ទ្សេង និមន្តអស់ព្រះអរិយសង្ឃផងជុំ[នុំ] បោះចារិកឱ្យឱកហ្ញូង ចក្រ្កី ឥន្ទ្សេង មានអ្ន[ក] ព្រះធម្មំក្ខិតិ ម្ចាសង្ករាជបពិត្រជាព្រះធានៗ អ្នកព្រះសូគុណ្ឋាមហាសង្ឃរាជសសេរចារិកនេះ បញ្ចុះនៅព្រះពិស្សនូលោក្ក (អង្គរវត្ត)ៗ ក៏អ្នកស្តេំចព្រះមហាមង្គលបពិត្រ អ្នកស្តេំចព្រះរាជពោធិសមុះ អ្នកស្តេំចម្ចាឱត្តល អ្នកស្តេំចព្រះធម្មបារមី អ្នកស្តេំចព្រះឥន្ទ្រទិព្វចក្រ អ្នកស្តេចមោក អ្នកម្ចាថេរព្រះធម្មអរិយ អ្នកបញ្ញាសុត្ត អ្នកស្តេំចប្រញ្ញានន អ្នកស្តេំចព្រះបញ្ញាជេដ្ឋ អ្នកបវរបញ្ញាទាំងពីរ អ្នកស្តេចសមេត្តបញ្ញា អ្នកកស្តេចព្រះឥនកីលាស អ្នកស្តេចព្រះរាជកិរិញ អ្នកមហាថេរអរិយកីញាណ អ្នកមថេរវិរយ្យាមរម្មិ អ្នកព្រះ[មុ]និសធម្ម អ្នកមហាថេរបវរគាថា មហាបាលិ អ្នកមហាថេរបវរទក្ខិណា អស់ស្តេំចព្រះគ្រូថេរានុថេរ ភិក្ខុសង្ឃ សាមណេរផង ជាសាក្សីពេជញាណចៅន្អក ចៅនុក ចៅមោកផងៗ

ទោះបើនៅពេលណាមួយ កូនចៅអ្នកឱកហ្ញូង[ចក្រ្កី] ឥស្សេង...នេះផង ក្រោយបើមកស្រតីរើសយកជាខ្ញុំវិញ ទោះព្រះពុទ្ធត្រាស់អម្បាលខ្សាច់កន្ទង់ទៅហើយក្តី មកត្រាស់ឯក្រោយអម្បាលខ្សាច់ក្តី កុំម្បីប្រោសអ្នកនោះឡើយ ឱ្យអ្នកនោះទៅកើតនៅ អានទនតរិក (នរក) ទាំងប្រាំ៥០០ ពាន់ជាតិក្តី កុំម្បីដោះចេញពីនរកនោះឡើយហោងៗ

អ្នកឱកហ្ញូងចក្រ្កីឥន្ទ្សេព្រំហ្មវង្សា អ្នកស្តេំចព្រះឥនកិលាស ធ្វើកុសល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះជូនទៅអ្នកឪក[ហ្វង] សូមបានទៅកើតនាស្ថានតុស្សិទ្ធហោង។

កំណែទម្រង់ច្បាប់ និងវាក្យសព្ទគតិយុត្តិនៃភាសាខ្មែរកណ្តាល

IMA-8	អក្សរបច្ចុប្បន្ន	អត្ថន័យបច្ចុប្បន្ន
	បទ	សំ៖ រឿង កម្មវត្ថុ មូលហេតុ
	បម្រោស	ដោះលែងឱ្យខ្ញុំ បម្រើមានសេរីភាព
	បំន្ទ័ម	បណ្តាំ
	ខ្នាប្ប	ខ្នាប់
	ចៅមឿង	អភិបាលក្រុង
	សាក្សី	សាក្សី
	ចៅក្រមសូភា	ចៅក្រមកាត់ក្តី
	ស្រិតី	ជំទាស់
	ព្សីពាធិ	សំ គី វិវាទ
	ពាកក្តិពិភាក្សា	រកក្តីពិភាក្សា ស្រាវជ្រាវរឿងក្តី
	នាំមក្តិដល	នាំក្តីដល់
	កាត្តក្តី	កាត់ក្តី

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

	ព្រះជាន	សំ ប្រជាន ប្រមុខ
	បញ្ចនទតរិក	ស្ថាននរក «អានន្តរិក» ទាំង៥

សិលាចារឹកលេខ៥

(ស.ក.១៥៣៩-គ.ស.១៦២៦ សម័យឧដុង្គ ក្នុងរជ្ជកាលព្រះបាទ-ជ័យជេដ្ឋាទី២ (១៦១៨-១៦២៨)។

នេះឧកញ៉ា ស្មណសង្គ្រាម្ម និងនាងឯប្ប និងឧកញ៉ា ពេជ្ជសង្គ្រមនិង ចៅពញា ជ្យេធិប្បត្យ នាង ព្រះ និងចៅពញាតេជោជៃ នាងរស និងចៅពញា ស្មាសង្គ្រាម្ម នាងអំ និងចៅជស និងអ្នកសម្តេចមោក និងនាងសរ និងនាងនុង និងនាងមាហ និងកី ចៅកេវ និងចៅសោម្ម និងចៅរាជ។ អស់អ្នកទាំងនេះ មានសាទ្ធាសោមនស្ស ព្រមទាំងឧកញ៉ាស្មណសង្គ្រាម្ម មកសាងកុសលផល បុណ្យប្រោសខ្ញុំ។

សុភមស្តុ១៥៣៩ ឆ្នាំម្សាញ់ នក្សត្រ ទុត្តិយាសាឍ ថ្ងៃ២ កើត អង្គារ មានជំនុំអ្នកព្រះ ធម្មវិត្ត មហាសង្ឃរាជបពិត្រ និងអ្នកព្រះសោគុណ មហាបពិត្រ និងអ្នកព្រះមហាមង្គល និងអ្នកព្រះរាជពោធិសមុហ និងអ្នកព្រះ ឱត្តលជេត្ត និងអ្នកព្រះព្រំមវត្ត និងអ្នកព្រះធម៌កាយ និងអ្នកពុទ្ធរាម្ម និង អ្នកសម្តេចមោក និងអ្នកព្រះធម្មអរិយ្យ ថេរានុថេរ ភិក្ខុសង្ឃផង ជាសាក្សី វិញាណ។ ឧកញ៉ា ស្មណសង្គ្រាម្ម មានចិត្តសទ្ធាសាងអំពើកុសលផលបុណ្យ ប្រោសកូន មេតោយ អាសុក្ខ ឈ្មោះ មេអប្ប ១ មេតិយ១ ឱ្យរួចជា ព្រេយ (ខ្ញុំ មានសេរីភាព) ឱ្យរក្សាចង្ហាន់អ្នកសម្តេចមោកហោង។

បើនរណាពិពាត្តមាត្រានេះ ឱ្យព្រះពុទ្ធអម្បាលខ្សាច់មកត្រាស់ក្តីកុំបី ប្រោសអ្នកនោះឡើយ ឱ្យអ្នកនោះទៅកើតនៅបញ្ចនរក នរកទាំង៥០០ ជាតិកំណើត កុំបីយល់តមកឡើយហោង។ ឯញាតឧកញ៉ាសោតមានពញាជ្យេ ១ ព្រះមនិស្សត្ត ១ អាផុល ១ មេសរ ១ មេនង ១ អស់ញាតអម្បាលនេះជួយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដីងផងសោតហោង។
មសុកមស្តុ១៥៤៩ ស.ក. ឆ្នាំឋោះ នក្សត្រ ឯម្មិកើត ទុត្តិយ្យសាធ នៅជា
ប្រថមសាធ្យលេយ ថ្ងៃអង្គារ៍ មានតីឧកញា ស្នួណសង្គ្រាម្ម និងនាងឯប្ប
រៀបចំរន្ទាប់ជាកុសលអរតនា និមន្តអស់សង្ឃផងមកឆ្លងព្រះពុទ្ធបដិមា។
នោះទើប ឧកញា ស្នួណសង្គ្រាម្ម និងនាងឯប្ប មានចិត្តត្រេកអរសទ្ធារំពឹង
អនិចំធម៌ នេះពុំទៀងលេយ យល់ជាបច្ឆិមវ័យហោង ទើបបណ្ដាលចិត្តគិត
កតញ្ញូកតវេទី បំបួសអ្នកស្នួណអារិយ្យ ឱ្យបានឧបសម្ប័ទជាភិក្ខុបរិបូណ៌
ស្រឡះឥតកំតិងលេយ។ មួយវិញទៀត គេបានប្រោសមេកេន កូនអ្នកស្នួណ
អារិយ កូនប្រុសមេកេន១ ឈ្មោះអាធុន ឱ្យស្រឡះជាព្រេយ្យឥតកំតិងឡើយ។
រីអ្នកជាសាក្សីវិញាណ មានសម្ដេចព្រះត្រីយសព្វេជ ព្រះពុទ្ធនៃយើងជា
ប្រធានឧត្តម។ ឯសង្ឃសោត មានអ្នកសម្ដេចព្រះមហាមង្គលបពិត្រ អ្នកសម្ដេច
មោកបពិត្រ អ្នកសម្ដេចព្រះធម្មអរិយបពិត្រ អ្នកសម្ដេចព្រះបូម្មិបពិត្រ អ្នក
សម្ដេចឪទ្យេបញ្ញាបពិត្រ អ្នកព្រះអរិបពិត្រ អ្នកព្រះមហាថេរព្រហ្មបពិត្រ
អ្នកព្រះស្នួណធាម្មបពិត្រ និងអស់ថេរានុថេរ ភិក្ខុសង្ឃផងច្រើន។ រីឯគ្រហស្ថ
សោតមាន ចៅល្ហួងមន្ត្រិយពិរភា ចៅរាជ ព្រះវិជាស្នួត និងអស់ក្មួយកូណ
ចៅផៅសន្តាន (វណ៌) មហាសប្បុរសផងច្រើនជាសាក្សីវិញាណកុំបីមាន
មេនានារើសយកជាខ្ញុំប្រយោជន៍អាត្មាឡើយ។ មួយវិញទៀត កុំបីមានបង
ប្អូន កូនចៅផៅសន្តានផងនានាមករើសឡើយ។ ទោះអ្នកនោះរើសសោត
ឱយអ្នកនោះទៅធ្និននៅនាបញ្ចនន្តរិកជារៀងតរាប។ ព្រះពុទ្ធត្រាស់អម្បាល
ខ្សាច់កន្ទងទៅហើយក្តី ព្រះពុទ្ធអម្បាលខ្សាច់នីងមកនៅថ្ងៃមុខក្តី កុំបីឱយ
ប្រោសអ្នកនោះបានឡើយ។ មួយវិញទៀត ឱយរន្ទះទាំងអានទ្ធចក្រវាឡ
នេះកុំបីឱយបាញ់ឈើព្រៃទៀតឡើយ ឱយបាញ់តែអ្នកដែលរើបម្រោសនេះ
សព្វៗជាតិកំណើតកុំបីដាច់ឡើយ។ មួយវិញទៀត ទោះមេក្រុមការបង្គាប់
ឱយយកជាខ្ញុំ ឱយមេក្រុមក្រុមការនោះទៅសោយទុក្ខវេទនាឰតបញ្ចនន្តរិក
នាអស់កាលនោះតលង់ហោង។ ទោះនាយក្រុមការនោះសោតជ្រោមជ្រែង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អនុមោទនាពុំឱ្យអើសសោតឱ្យមេក្រមការនោះបានទៅសោយត្រៃពិធ សម្បត្តិដ៏រាបដល់និព្វានហោង។ នេះឧកញ៉ាស្មួណសង្គ្រាម្ម គាត់ឯងមកឱ្យ បោះចារឹកនេះអស់ជំនុំដែលជាសម្រេចហោង។

៤.២.២.ការបាត់បង់ធនធានមនុស្សក្រោយសម័យលង្វែក សិលាចារឹកលេខ១០

(ស.ក. ១៥៤៩-គ.ស. ១៦២៧ សម័យឧដុង្គ ក្នុងរជ្ជកាលព្រះបាទជ័យ- ជេដ្ឋាទី២ (១៦១៨-១៦២៨)។

សុភមស្តុមង្គលាតិរេក ១៥៤៩ គក ថោះ នក្សត្រ ខែមាឃ ១ កើត ថ្ងៃ អាទិត្យ អ្នកឧកញ៉ាបញ្ញា មានចិត្តសាទ្ធានាំបងប្អូនពីស្រុកជ្រលងមកទាំង សប្តពករណ៍ មកធ្វើផ្នួស។ ចៅសោមជួយអនុមោទនាជាវន្តាប់។ ឯកុសល ផលបុណ្យសូមលុះត្រៃវិធសម្បត្តិកុំបីវង្វេងទៅកើតនាចតុរាបាយនរក។ សូម ផុតអស់ពីភ័យចតុរាបាយភូមនរកនោះ សូមទៅកើតនាសោឡសកវត្តព្រហ្ម។ សូមខ្ញុំបានសោយផលអានិសង្សនេះច្រើនហោង ចំរើនញាតិកាទាំង៧សន្តាន មានទ្រព្យៈ ឥតទ្រព្យៈ ឱ្យបានសម្បត្តិនៅស្ថានត្រៃយត្រិង្សហោង។ ចារឹកនេះ សាងដោយជីនៃយ ទុកជាកីលមួយ។ អ្នកឧកញ៉ាបញ្ញា បួងសួង៖ «ខ្ញុំសូម កើតនៅសួគ៌ាជាស្ថានក្សេម ឱ្យផុតពីចតុបាកយភូមនរក។ ខ្ញុំសូមមានភោជន អាហារបរិភោគកុំបីដាច់ឡើយ។ ខ្ញុំសូមសំពត់ស្បៀកកុំបីដាច់ឡើយ។ បើជា គ្រហស្ថ ខ្ញុំសូមមានគ្រឿវត្ថុល្អដូចចិត្តប្រាថ្នានេះហោង។

៤.២.៣. កំណែទម្រង់កំណែទម្រង់ភាសាខ្មែរនៅចុង សតវត្សទី១៧

ព្រះបាទជ័យជេដ្ឋាទី៣ អង្គស៊ូ ជាបុត្ររបស់អង្គសួរ និងជាចៅព្រះ ឧទ័យរាជា។ រហូតមកដល់ចុងសតវត្សទី១៧ នៅរជ្ជកាលព្រះបាទជ័យ ជេដ្ឋាទី៣ ឬអង្គស៊ូ (១៦៧៥-១៦៩៥) ភាសាខ្មែរបានលូតលាស់ឡើងវិញ ដោយព្រះអង្គបានប្រមូលធនធានមនុស្ស ដើម្បីយកទៅបណ្តុះបណ្តាល និង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជ្រើសរើសអ្នកប្រាជ្ញ ឱ្យជួយធ្វើកំណែទម្រង់រដ្ឋ។ ព្រះអង្គបានធ្វើកំណែទម្រង់យុត្តិធម៌ ដោយរៀបចំបង្កើតឱ្យមានក្រមច្បាប់មួយចំនួនថែមទៀត ក្នុងគោលដៅពង្រឹងវិស័យយុត្តិធម៌ ដែលបន្តពីរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ ដូចជា (MIKAELIAN, 2009)៖

(១) ច្បាប់ទុំទីមពីរប្ញហ៊ាន (១៦៩១)

(២) ក្រមបលជិប្ប (ក្រមកសិកម្ម) (១៦៩៣?)

(៣) ច្បាប់គិតតម្លៃ (១៦៩៣?)

(៤) សស្រ្តាប្រាម្មណ្ឌាន សាកែវ (១៦៩៣?)

(៥) ច្បាប់ក្រមស្រុកព្រះជ័យជេស្តា (១៦៩៣)

(៦) មាត្រាច្បាប់សាព្គិគុន្ទី (១៦៩៣)

(៧) ច្បាប់សំពៅ (១៦៩៣) (១៦៩៧?)

(៨) ច្បាប់សាព្គីល្បែងភ្នាលគ្នា (១៦៩៣?)

(៩) ក្រមសែះ (១៦៩៣)

(១០) នេះច្បាប់ កុលបន្ទប ១០ សន្និកកន្ទះ (១៦៩៣)

៤.៣. សិលាចារឹកជ័យនន្ទៈ ការវិវត្តពីភាសាខ្មែរកណ្តាលទៅភាសាខ្មែរទំនើប

សិលាចារឹកជ័យនន្ទ ស្ថិតនៅក្នុងថែវនៃប្រាសាទអង្គរវត្ត នៅជាន់ទី១ ផ្នែកខាងកើត។ ផ្ទាំងសិលាចារឹកនេះមានទំហំៈ កម្ពស់១,៣២ ម៉ែត្រ និងទទឹង១,៨២ម៉ែត្រ។ សិលាចារឹកចារជាអក្សរមូលនៃភាសាខ្មែរកណ្តាល ហើយមាន៥៣បន្ទាត់។ កាលបរិច្ឆេទដាក់នៅលើសិលាចារឹកនេះ គឺថ្ងៃ១២ កើត ខែមាឃ ឆ្នាំម្សាញ់ ឆ្នាំ១៦២៣ ស.ក. ដែលត្រូវនឹងខែមករា-កុម្ភៈ ឆ្នាំ១៧០២។ លោក ឱ. គាម បានចម្លង «សិលាចារឹកជ័យនន្ទ» ចេញពីប្រាសាទអង្គរវត្ត នៅឆ្នាំ១៩៦៣ និងបានសិក្សាវិភាគសិលាចារឹកនេះ ហើយបានបោះពុម្ពផ្សាយអត្ថបទវិភាគអក្សរសាស្រ្តខ្មែរ នៅក្នុងទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំទី៣៥ លេខ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៥, លេខ៦, លេខ៧ និងលេខ៨ ឆ្នាំ១៩៦៣។

៤.៣.១. អត្ថរូប

សិលាចារឹក ជ័យទន្ទ គឺជាអត្ថបទជាពាក្យកាព្យ ជាភាសា«ខ្មែរកណ្ដាល» ដែលតែងនៅឆ្នាំ១៦២៣ ស.ក. ដែលត្រូវជា គ.ស.១៧០១ ដោយបណ្ឌិត ជ័យទន្ទ ដែលជាកវី និងមន្ត្រីជាន់ខ្ពស់មួយរូប ។ លោកត្រូវបានតែងតាំង ជាចៅហ្វាយខេត្ត ព្រៃក្ដី (នៅខាងជើងខេត្តកំពង់ធំ) និងជាចៅហ្វាយខេត្ត ត្បូងឃ្មុំ។ បន្ទាប់មកលោកត្រូវបានតែងតាំងជាឧកញ៉ាយោមរាជ ជ័យទន្ទ។



ប្រភព៖ «សិលាចារឹកជ័យទន្ទ» ថតនៅអង្គរវត្ត ថ្ងៃទី២៧ មេសា ឆ្នាំ២០១៩

«សិលាចារឹកជ័យទន្ទ» រៀបរៀបរាប់ពីខ្លួនលោក និងភរិយាដែលមាន រូបឆោមប្រិមប្រិយ៍ ឈ្មោះដើមនាង ប៉ែន សន ហើយបន្ទាប់មកបានឡើង យសជាជំទាវសុពណ៌ នៅពេលដែលលោកត្រូវបានតែងតាំងជាឧកញ៉ា យមរាជ។ បណ្ឌិតជ័យទន្ទ បានរៀបរាប់ពីការរៀបចំធ្វើពិធីបុណ្យនៅអង្គរ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វត្ត ដើម្បីឧទ្ទិសទៅដល់កូនរបស់លោកទាំងពីរ និងភរិយា។ លោកបានបួសជាសង្ឃ ដើម្បីឆ្លងចេតិយហើយបានរៀបរាប់ពីការកសាងព្រះមាស សាងត្រីសូរ ការធ្វើបុណ្យសាងសង់សាលា ព្រះវិហារ និងពិធីបញ្ចុះសីមាផងដែរ។

«សិលាចារឹកជ័យនន្ទ» គឺជាស្នាដៃអក្សរសិល្ប៍ដែលមានទម្រង់ជា «ធម៌ល្បា»ឬ«របា» ដែលនេះនៅសម័យកណ្ដាលគឺជាធម៌កាព្យរៀបរាប់អំពីព្រះត្រ័យលក្ខណ៍ ដែលគេសូត្រនៅពេលមានមនុស្សឈឺធ្ងន់ ឱ្យមានធម្មសំវេគ។ អ្នកនិពន្ធខ្មែរតែង «ធម៌ល្បា» នេះទុកសម្រាប់សូត្ររំដោះគ្រោះ និងបាបពៀរវេរាកុំឱ្យជួបនឹងក្តីអន្តរាយ និងអំពើអាក្រក់នៅជាតិខាងមុខ។

គឺជាការបួងសួងរបស់លោកថា ប្រសិនបើមានជាតិក្រោយមែន សូមឱ្យជួបគ្នាម្តងទៀតជាមួយភរិយាលោក។ អ្នកនិពន្ធបានកត់ត្រាទុកពីគ្រឿងបូជាតង្វាយព្រះ ឬការកសាងព្រះពុទ្ធរូប ដើម្បីសន្សំកុសលផលបុណ្យ ការត្រាប្រណីដោះលែងទាសាទាសីឱ្យជាអ្នកជាមានសេរីភាព និងរៀបរាប់ពីសមណស័ក្តិ និងគោរមងាររបស់ព្រះសង្ឃ ដូចជាតំណែងមហាសង្ឃរាជ ៩ អង្គ និងតំណែងរាជាគណៈជាដើម។

លោកបានតែងសិលាចារឹកមួយ ដែលប្រកបដោយសម្ផស្សដើងកាព្យដែលអាចយកជាគំរូមេកាព្យបាន។

៤.៣.២. អត្ថន័យ

ការសិក្សាស្តីពីអត្ថន័យនៃ «សិលាចារឹកជ័យនន្ទ» សំដៅលើការលើកឡើងក្នុងអត្ថបទកំណាព្យនូវមតិ ទស្សនៈ និងបញ្ហាសំខាន់ៗក្នុងអក្សរសិល្ប៍ដើមសតវត្សរ៍ទី១៨នេះ។

ទ្រឹស្តីពុទ្ធនិយមៈ «សិលាចារឹកជ័យនន្ទ» ចាប់ផ្តើមពីសទ្ធាចិត្តរបស់ពុទ្ធសាសនិកជន និងការក្រាបបង្គំព្រះរតនត្រៃ (ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ) ព្រះពោធិសត្វដែលតែងតែឈ្នះអស់មារសត្រូវ ព្រះសក្យមុនី និងព្រះសិអារ្យ-មេត្រី និងការត្រាស់ធម៌ និងនាំសត្វលោកក្នុងគន្លងនៃកាលៈ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១- «សព្ទមសសួស្តី ត្រីសព្វត្រឹមង្គលា
ពហុលព្រះដៃយ្យា គ្បោសាផ្ទាំអតិរេក»
២- «ខ្ញុំមក្រាប្បំក្រោមព្រះបាទ អញ្ជីវាទវរវន្ទី
គិតថ្វាយទៅព្រះត្រី រត្នត្រៃត្រីក្កាលា»។
៣- «រុងរឿងបាល្ងំពេជ្ញ ពីរចិត្តស្រេចវិច្ឆនា
ទ្វាកទ្វៅជាក្ងីផ្កា បរបួបួនទន្តប្បហាត់។
តាមប្ដូងស្បិងគ្រប់ពាណ្ឌ ល្អឥស្វាប្រឆ្នុះប្រវាត្ត
កេតផ្សពោធិសត្វ ព្រះគុងស្ថិតឈ្នះមារផោង។
ថ្វាយព្រះសាខ្យម្នីនោ ព្រះត្រីអារសោតហោង
ត្រ័ស្បូជម្ម៍ន្នាំសត្វផោង ក្នុងគន្ទងកាល្បនៃះនោះ។

តាមរយៈកំណាព្យនេះ យើងបានដឹងថា នៅសតវត្សទី១៧ និងនៅដើមសតវត្សទី១៨ ព្រះពុទ្ធសាសនារុងរឿងណាស់។

៤-«ខ្ញុំក្រាបក្រោមព្រះបាទ អញ្ជីវាទវរវន្ទា
ព្រណាំព្រះសស្តា បញ្ចពុទ្ធារត្ន តត្រៃ»។

អ្នកនិពន្ធបានរៀបរាប់ថា លោកមាននាមហៅថា ជ័យនន្ទ។ ចំណែកភរិយារបស់លោក ឈ្មោះនាង បែន សន ដែលមានរូបឆោមស្រស់ស្អាត។

«ខ្ញុំសូមនោះរិកមោក ជាពន្ធកសព៌ផ្ទៃ
អង្គខ្ញុំនៃះឯងនៃ គ្បោនាម្មៃ ហោរជៃយនន្ទ។
រីនាងជាកន្សៃ ឈ្មោះពិរនៃមឹងបែនស្អួន
រូបឆោម្មទនអេនអន យលស្មា កសម្មចរិត្តត្រី»។

លោកត្រូវបានព្រះរាជាតែងតាំងជាអធិបតីនៃខេត្តព្រៃក្តី។ បន្ទាប់មកក៏ត្រូវបានតែងតាំងជាអធិបតីនៃខេត្តត្បូងឃ្មុំ មុននឹងត្រូវបានតម្លើងឋានៈជានាហ្មឺនធំ ជាឧកញ៉ាយមរាជ ហើយភរិយាក៏ក្លាយទៅជាជំទាវទេពសុពណ៌។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«លះព្រះបាទ្ធរាជ្ជា ឱ្យសក្តាទិខ្សែខ្ញុំ
ដែន្ទួនស្វាធិពូត្យ ហើយឱ្យធ្យូរៀព្រេត្តហោង។
តលទៅធិ្យប្យូងឃ្មុំម ហ្វាហ្មុនធំឯកឯងហោង
លុះជាយម្នរាជផោង នោះឯងហោងសាងត្រីសួរ។
ឯមិងបែននោះនា យសសក្វតាតៅគុំទ្ធរ
ឈ្មោះនោះយលបរបូរជា ជុំទាវទេពូសុពណ្ណ៌»។

«សិលាចារឹកជ័យនន្ទ» បង្ហាញនូវទស្សនៈសំខាន់ៗ ដែលមានជាលក្ខណៈសង្គម លក្ខណៈអច្ឆរិយៈ លក្ខណៈមនុស្ស និងចរិយាធម៌ ដូចតទៅ៖

៤.៣.៣. អត្ថរស

«អត្ថរស»សំដៅលើរសជាតិខ្លឹមសារ ដែលធ្វើឱ្យអត្ថបទមានលម្អ មានលក្ខណៈពីរោះជាទីចាប់ចិត្ត ចាប់អារម្មណ៍។ តម្លៃនៃ«សិលាចារឹកជ័យនន្ទ» ស្តែងចេញនូវការស្របញ្ចូលគ្នា នូវទស្សនៈព្រះពុទ្ធសាសនា ជាមួយនឹងទស្សនៈខ្មែរ ក្នុងការអប់រំមនុស្ស ដើម្បីសម្រេចបានសេចក្តីសុខពិតប្រាកដតាមរយៈការបំបាត់កម្ម ការធ្វើសមាធិ ការបង្កើតវិជ្ជា ការបំបាត់តណ្ហា និងការគិតគូរពីប្រយោជន៍រួម។ អត្ថរសនៃអត្ថបទអក្សរសិល្ប៍ពុទ្ធនិយមអាចចែកចេញជា៖

តម្លៃនៃស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមស្តែងចេញនូវទស្សនៈរបស់ព្រះពុទ្ធ គឺធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ និងការអប់រំសីលធម៌ព្រះពុទ្ធសាសនា។ អត្ថរសនៃអត្ថបទអក្សរសិល្ប៍ពុទ្ធនិយមអាចចែកចេញជា៖

ទីមួយបច្ចេករស ដោយប្រើប្រាស់ពាក្យកាព្យ និងរៀបចំជាដំណើររឿងឱ្យមានភាពអណ្តែតអណ្តូង ឱ្យអ្នកអានរំភើបតាមដំណើររឿង។

ទីពីរវិសេសរស ដោយបង្ហាញពីតម្លៃល្អ តម្លៃអាក្រក់ សកម្មភាពអស្ចារ្យវីរភាពរបស់តួអង្គ សកម្មភាពតស៊ូរបស់តួអង្គ សោកនាដកម្ម និងសកម្មភាពរស់រវើក និងកំប្លែង ដើម្បីឱ្យអ្នកអានរីករាយ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទីបីសព្វរស ដោយធ្ងុះបញ្ជាំងពីតថភាពក្នុងសង្គម ជីវភាពប្រចាំថ្ងៃ លក្ខណៈអច្ឆរិយៈ និងកុសលរសដែលជាតម្លៃនៃការទូន្មានប្រៀនប្រដៅ។

ដើម្បីឱ្យមានភាពទាក់ទាញអ្នកនិពន្ធបានរៀបចំអក្សរសិល្ប៍ពុទ្ធនិយម នេះជាកំណាព្យ ដែលជាកម្រងពាក្យសម្ដី មានន័យចាប់ចុងចួន ណែងណង មានចង្វាក់ សូរសៀង សំនៀងពីរោះរណ្ដំ។ កំណាព្យនៃ«សិលាចារឹកជ័យនន្ទ» មានសោភ័ណផ្សេងៗដូចតទៅ៖

ទីមួយសោភ័ណខាងសូរសព្ទ៖ កវីនិពន្ធ ជ័យនន្ទបានតែងកំណាព្យ ជាបទច្រើនដូចខាងក្រោម៖

១.បទព្រហ្មគីតិ៖ ចម្រៀងព្រះព្រហ្ម ដែលលន្លង់លន្លោច ដើម្បីសម្ដែង ទុក្ខសោក ការនិរាសព្រាត់ប្រាស។

១០- «រ៉ឺអ្នកនេះទំព្យីរ	តៀរមិលយលឥសចយ៉ំ
ជាតនេះព្ទុទ្វទារ កេត	ទុក្ខព្រាតជាទាឃាត។
ជាតនេះព្ទុំបរប្ទូរ	ប្រាសព្ទុំមូលច្រើនឃ្វាឃ្វាត
ទោះកើតសព្វៗជាត	កុំត្រា ឃ្វាតតលតេចល្បិ

២.បទកុជង្គលីលា៖ ដំណើរនាគ ដែលមានលក្ខណៈទន់ភ្លន់ អែនអន ផ្អែមល្ហែម ប្រើប្រាស់ក្នុងការរៀបរាប់ពិពណ៌នា និងការស្ញើចសរសើរ។

៣.បទកាកគតិ៖ ដំណើរក្អែក ប្រើក្នុងការសន្ទនា និងក្នុងសេចក្ដីផ្ដើម រឿង។

ទីពីរសោភ័ណខាងវោហារសាស្ត្រ៖ ក្នុងអក្សរសិល្ប៍កំណាព្យ កវីនិពន្ធ ខ្មែរអាចរៀបរាប់ដោយលេងពាក្យ ឱ្យណែងណង ឱ្យមានសំឡេងរណ្ដំដូច ភ្លេងរនាត។

ទីបីសោភ័ណខាងទស្សនវិជ្ជាខ្មែរ៖ អត្ថបទអក្សរសិល្ប៍គឺជានិក្ខេបបទ ខាងផ្នែកទស្សនវិជ្ជាពុទ្ធនិយម ដែលអ្នកនិពន្ធត្រូវលើកយកប្រធានបទនៃ ពុទ្ធសាសនាមកបកស្រាយ ក្នុងគោលដៅទូន្មាន បង្ហាញពីការប្រយុទ្ធគ្នា រវាងអំពើល្អ និងអំពើអាក្រក់ យុត្តិធម៌និងអយុត្តិធម៌ និងជួយដោះស្រាយបញ្ហា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលបង្ហាញលក្ខណៈសង្គមនៃអក្សរសិល្ប៍ពុទ្ធនិយម ហើយមិនមែនតែផ្ដោតលើសាសនាប៉ុណ្ណោះទេ។

ប្រការដូចបានរៀបរាប់ខាងលើ បានធ្វើឱ្យអក្សរសិល្ប៍ពុទ្ធនិយមសម័យក្រោយអង្គរបានក្លាយជាវណ្ណកម្មឯកត្តានពីរបស់ខ្មែរ។

៤.៣.៤. ការវិវត្តនៃភាសាខ្មែរនៅដើមសតវត្សទី១៨

ភាសា«ខ្មែរកណ្ដាល» នៅក្នុង«សិលាចារឹកជ័យនន្ទ»បង្ហាញឱ្យឃើញថា ពាក្យសំស្ក្រឹត និងពាក្យបាលីបានចូលជ្រួតជ្រាបក្នុងសរសៃសង្វាក់នៃភាសានិយាយខ្មែរទៅហើយ។ ក៏ប៉ុន្តែ ក្នុងភាសាសរសេរផ្លូវការវិញ គេមិនទាន់ឃើញនូវការបង្កើតវិធានរួមនៃវេយ្យាករណ៍សម្រាប់សរសេរ ឱ្យមានលក្ខណៈស្តង់ដារួមនៅឡើយទេ។ ពាក្យដែលមានដើមកំណើតពីសំស្ក្រឹត និងបាលីត្រូវបានអ្នកនិពន្ធយកមកសរសេរជាភាសា«ខ្មែរកណ្ដាល» ដោយមិនបានគោរពទៅតាមអក្ខរាវិរុទ្ធភាសាដើម។

លក្ខណៈពិសេសនៃភាសា«ខ្មែរកណ្ដាល»៖ គឺអ្នកប្រាជ្ញ និងកវីនិពន្ធខ្មែរបានប្រើប្រាស់ភាសាបាលី ដើម្បីជំនួសភាសាសំស្ក្រឹត ដោយសារនៅសម័យកណ្ដាលប្រជាជនកម្ពុជាប្រតិបត្តិព្រះពុទ្ធសាសនាថេរវាទ។

នៅក្នុងរឿងរាមកេរ្តិ៍ អ្នកនិពន្ធបានជ្រើសរើសយកពាក្យប្លែកៗ ដ៏មានអត្ថរសជ្រាលជ្រៅពីសាស្ត្រាបុរាណមកប្រើ ដោយប្រើចម្រុះរវាងភាសាខាងក្រោម ដែលធ្វើឱ្យយើងពិបាកយល់ន័យ និងទំពារមិនបែក៖

(១) ពាក្យខ្លះជាភាសា«ខ្មែរបុរាណ»ដែលពេលខ្លះយើងអាចស្គាល់ន័យ តែពាក្យខ្លះយើងមិនដឹងន័យរបស់ពាក្យនេះទេ (ដូចជាពាក្យថា រូ, រូបហាន, ផ្គ័រ, និង ម្ដោយ ជាដើម)។

(២) ពាក្យខ្លះជាភាសា«សំស្ក្រឹត» និងភាសា«បាលី»សរសេរចម្រុះគ្នា។

(៣) ពាក្យខ្លះជាភាសា «ខ្មែរទំនើប» ដែលសរសេរលាយឡំគ្នា។

ភាសា «ខ្មែរកណ្ដាល» គឺជាភាសារស់រវើក ដែលអ្នកនិពន្ធថ្លៃប្រឌិតជាប្រចាំ និងបញ្ចេញបញ្ចូលតាមតម្រូវការនៃអត្ថបទ និងបរិបទនៃសាច់រឿង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(សង្គម, សាសនា, និងអក្សរសិល្ប៍) ដើម្បីបង្កើតបាននូវវណ្ណកម្មជាច្រើន ដូចជា «សិលាចារឹកនគរវត្ត», «រឿងរាមកេរ្តិ៍», និង «ល្បើកអង្គរវត្ត» ដែលមានតម្លៃជាអក្សរសិល្ប៍សម័យកណ្តាល។

កម្ចីពាក្យសព្ទពីភាសាសៀម

សៀមបានខ្ចីពាក្យខ្មែរបុរាណនៅសម័យអង្គរ ដើម្បីប្រើក្នុងភាសាសៀម ហើយអក្សរសៀមទៀតសោត ក៏ជាកម្ចីពីភាសាខ្មែរបុរាណផងដែរ។ ក៏ប៉ុន្តែក្រោយសម័យលង្វែក ខ្មែរបានខ្ចីពាក្យទាំងនោះពីសៀមមកវិញ (អៀវ កើស, 1947)។ នៅក្នុងសិលាចារឹកលេខ៨ គេឃើញមានប្រើពាក្យសព្ទសៀមមួយចំនួនៈ

ទីមួយ-ពាក្យ «ចៅមឿង» គឺជាកម្ចីសមាសនាមរវាងពាក្យសៀម «ចៅ» ដែលមានន័យថាម្ចាស់ និងពាក្យ «មឿង» ដែលមានន័យថាក្រុង ដែលពាក្យខ្មែរបច្ចុប្បន្នហៅថា «អភិបាលក្រុង»។

ទីពីរ-ពាក្យ «ចៅក្រម» គឺជាកម្ចីសមាសនាមរវាងពាក្យសៀម «ចៅ» ដែលមានន័យថាម្ចាស់ និងពាក្យសំស្រ្កឹត «ក្រម» ដែលមានន័យថា «វិធានប្រពៃណី ឬច្បាប់» (LEWITZ, 1972)។

ទីបី-ពាក្យ «ព័ន» គឺជាកម្ចីពីសៀម «ពាន់» (៥០០ ពាន់ជាតិ)។

IMA	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	៥០០ព័នជាតិ (IMA-8) ១៦២៥	៥០០ពាន់ជាតិ
	ពាន្ទហារយកព្វជាតិ (IMA-32)	ពាន់ហារយ ភពជាតិ
	ត្រូ (IMA-39)	ត្រូសារ
	ហា (IMA-16) ១៦៣១	៥
	ហារយ (IMA-26) ១៦៣៩	៥០០

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមរយៈការសិក្សាសិលាចារឹកនគរវត្តយើងឃើញថា នៅសម័យកណ្តាលនៅពេលដែលកម្ពុជាបាត់បង់ធនធានមនុស្សដោយសារសង្គ្រាមខ្មែរចាប់ផ្តើមខ្ចីពាក្យមួយចំនួនពីភាសាថៃ ដើម្បីមកបំពេញបន្ថែមតម្រូវការ ដូចបានបញ្ជាក់ខាងលើ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជំពូកទី៥

វេយ្យាករណ៍ នៃភាសាខ្មែរកណ្តាល

៥.១. ការវិវត្តអក្ខរក្រម

៥.១.១. ព្យញ្ជនៈ

៥.១.១.១. ការវិវត្តនៃព្យញ្ជនៈ

សម័យមុនអង្គរ (សតវត្សទី៦-ទី៨)	*សម័យកណ្តាល (សតវត្សទី១៦-ទី១៨)*	*សម័យទំនើប*
		ក
		ខ
		គ
		ឃ
		ង
		ច

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

		ឆ
		ជ
		ឈ
		ញ
		ដ
		ឋ
		ណ
		ត
		ថ
		ទ
		ធ
		ន
		ប
		ផ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

		ព
		ភ
		ម
		យ
		រ
		ល
		វ
		ស
		ឝ
		ហ
		ឡ
		អ

ka
kha
ga
gha
ṅa
ca
cha
ja
jha
ña
ṭa
ṭha
–
ḍa
–
ḍha
ṇa
ta
tha
da
dha
na
pa
pha
ba
bha
ma
ya
ra
la
va
śa
ṣa
sa
ha
ḷa
a

៥.១.១.២. ការវិវត្តនៃជើងព្យញ្ជនៈ

ព្យញ្ជនៈសម័យកណ្ដាល (សតវត្សទី១៦-ទី១៨)	ជើងព្យញ្ជនៈសម័យកណ្ដាល (សតវត្សទី១៦-ទី១៨)	សម័យទំនើប
		ក
		ខ
		គ
		ឃ
		ង
		ច
	ch	ឆ
		ជ
	jh	ឈ
		ញ

		ដ
		ឋ
		ណ
		ត
		ថ
		ទ
		ធ
		ន
		ប
	ph	ផ
		ព

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

		ក
		ម
		យ
		វ
		ល
		រ
		ស
		គ
		ហ
		ឡ
		អ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្យញ្ជនៈដែលគេប្រើពីសម័យដើមជាព្យញ្ជនៈសំស្ក្រឹតមានចំនួនលើស ពីចំនួនព្យញ្ជនៈបច្ចុប្បន្នពីរតួគឺ ឞ និង ឝ ។ លក្ខណៈពិសេសនៃព្យញ្ជនៈ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្មែរកណ្ដាលមានដូចតទៅៈ

១) ឞ និង ឝ គេប្រើនៅសតវត្សទី ១៧ ហើយមកដល់ពាក់កណ្ដាលសតវត្សទី១៨ (គ.ស ១៧៤៧) ឃើញថាគេប្រើតួអក្សរ ស ជំនួសវិញ។

២) ក្នុងសម័យបុរាណ ព្យញ្ជនៈ ដ ឋ ឌ ឍ ណ ឡ និង ឞ ឝ ទុកសម្រាប់ប្រើតែពាក្យមកពីបាលី សំស្ក្រឹត ក្នុងពាក្យខ្មែរសុទ្ធមិនមានប្រើទេ។

៣) ត ប្រើជំនួស ដ ឧទាហរណ៍ តល (ដល់)

ភាសាខ្មែរកណ្ដាល	ភាសាខ្មែរទំនើប
តល	ដល់
តោយ (ន) យថាសាស្ត្រ (IMA-6)	ដោយយថាសាស្ត្រ

៤) ន ប្រើជំនួស ណ ឧទាហរណ៍ ឯនាម្ប (ឯណាមួយ)

ភាសាខ្មែរកណ្ដាល	ភាសាខ្មែរទំនើប
 សំនូម	សំណូម
 បុរាន (IMA-2)	បុរាណ

៥) ល ប្រើជំនួស ឡ ឧទាហរណ៍ លេយ (ឡើយ)។

ភាសាខ្មែរកណ្ដាល	ភាសាខ្មែរទំនើប
 កំលុង	កំឡុង
លេយ (IMA-3)	ឡើយ

៦) ការដូរពីព្យញ្ជនៈ «វ» ទៅជា «ព»។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភាសាខ្មែរកណ្ដាល	ភាសាខ្មែរទំនើប
កុម្ទុជ (IMA-2)	កម្ពុជ

៧) ការប្រើប្រាស់ «ថ្ង» ជំនួស «ឡ» ដែលទើងបង្កើតឡើងនៅពេលក្រោយ។


(១៦) បរមបពិត្រ មន្ទិអំពិកាលជាគបើមសំដត្តគពឹះមហា (១៧) ឪបាសកបានថ្ងៃស្នោយរាជ្យសម្បត្តិគ្រោងរាជ (IMA-3)

៨) ការនៅប្រើប្រាស់ព្យញ្ជនៈ «គ»។

(IMA-2)

៩) ការប្រើប្រាស់ព្យញ្ជនៈ «ន» ជំនួស «ណ»។

ភាសាខ្មែរកណ្ដាល	ភាសាខ្មែរទំនើប
ញាន (IMA-3)	ញាណ

នៅចុងសតវត្សទី១៧ មានការចាប់ផ្ដើមសរសេរព្យញ្ជនៈ «ណ» នៅក្នុង IMA-30 ក្នុងឆ្នាំ១៦៨៤។

ភាសាខ្មែរកណ្ដាល	ភាសាខ្មែរទំនើប
វិញាណ (IMA-30)	ញាណ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១០) ការប្រើប្រាស់«្ប» ជំនួស « ់ »។

ភាសាខ្មែរកណ្ដាល	ភាសាខ្មែរទំនើប
 ស្ដាប្ប (IMA-2)	ស្ដាប់

ខ្មែរកណ្ដាល	ខ្មែរទំនើប
ពម្ណ៌ = ពណ៌	ការដូរព្យញ្ជនៈពី វម្ណ៌ ទៅ ពម្ណ៌
ថ្វេង = ឡើង	ព្យញ្ជនៈ «ថ្វ» ប្រើជំនួស «ឡ»
សំនូម = សំណូម	ព្យញ្ជនៈ «ន» ប្រើជំនួស «ណ»
បំរេហ= បំរើ	«រេហ» ប្រើជំនួសស្រៈ «អើ»
ចំរេន= ចំរើន	ចម្រើន
ត្រី	ស្ត្រី
លគ្នា	លក្ខណា= ព្យញ្ជនៈ«ន» ប្រើជំនួស«ណ»
គំរប្ប	គំរប់ ជើង «្ប» ប្រើជំនួស « ់ »

៥.១.២. ស្រៈ

នៅក្នុងសតវត្សទី១៤ ដែលយើងមានចម្លាក់សិលាចារឹកក៏ឃើញថា ចំនួនស្រៈនៅដដែល។ តែក្រោយមកដោយសារភាសាយើងជាភាសាមានពាក្យឯកព្យាង្គ និងទ្វិព្យាង្គច្រើន ដែលត្រូវការប្រើតួស្រៈច្រើនដើម្បីកុំឱ្យច្រឡំពាក្យគ្នាខ្មែរយើងនៅសម័យបុរាណនៅតែទ្រាំប្រើចំនួនស្រៈតិចអស់រយៈរាប់រយឆ្នាំ ដោយការប្រកាន់យកទំនៀមដើមតាមលំអានឥណ្ឌា។ ដូច្នេះហើយទើបយើងឃើញថា ចាស់បុរាណសរសេរពាក្យ ម្វាយ (មួយ) តាមលំនាំដើមរហូតមកដល់សតវត្សទី១០។ តែនៅដើមសតវត្សទី១១ មកទើបលោកកែប្រែមកសរសេរជា មួយ វិញ។ រហូតមកដល់សតវត្សទី១៨ ទើបមានស្រៈ អួ ហើយក៏នៅសរសេរ ម្ប ទៀត។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៥.១.២.១. ការវិវត្តនៃស្រៈ

ស្រៈនិស្ស័យ

ការវិវត្តស្រៈនៃភាសាខ្មែរមុនអង្គរ និងសម័យទំនើប

សម័យមុនអង្គរ (សតវត្សទី៦-ទី៨)	(សតវត្សទី៩ទី១៤)	សម័យទំនើប
		អា
		អិ
		អី
		អុ
		អូ
		អួ
		អើ
		អឿ
		អៀ
		អេ

		អែ
		អៃ
		អោ
		អៅ
		អុំ
		អំ
		អាំ
		អះ
		អុះ
		អេះ
		អោះ


aḥ
ā
i
ī
ị
ị̄
u
ū
uo
oe
ioe
ie
e
ae
ai
o
au
uṃ
aṃ
āṃ
uḥ
iḥ
eḥ
oḥ

៥.១.២.២. ស្រៈពេញតួ

ដើមឡើយខ្មែរយើងប្រើស្រៈដែលមានក្នុងតួអក្សរគឺស្រៈសំស្ក្រឹត ១៤ តួមាន៖ អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ។

ស្រៈពេញតួ

សម័យមុនអង្គរ (សតវត្សទី៦-ទី៨)	(សតវត្សទី៩-ទី១២)	សម័យទំនើប
		ឥ
		ឦ
		ឧ
		ឩ
		ឯ
		ឰ
		ឱ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



៥.២.គោលការណ៍នៃការបង្កើតពាក្យដោយកម្លាយ

ផ្នត់ដើម

ប្រែ បំរែ

ផ្នត់ដេក

ប្រោស + [*បម*] -> *បំម្រោស* (IMA-8)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៥.៣. ការសរសេរបរិច្ឆេទ

ការសរសេរកាលបរិច្ឆេទនៅក្នុងភាសា «ខ្មែរកណ្ដាល» មានលក្ខណៈស្រដៀងគ្នាទៅនឹងភាសា «ខ្មែរបុរាណ»៖

សិលាចារឹកអង្គរ និងមុនអង្គរ

ឆ្នាំ	ថ្ងៃ រោច ឬ ខ្នើត	ខែ	ថ្ងៃ
សិលាចារឹកប្រាសាទបាតជុំ K.226			
៨៨២ ឞក	ឯកាទឞី រោច	អាឞាឍ	គុគ្រវារ
មហាសករាជ ៨៨២	ទី១១ រោច	ខែអាសាឍ	ថ្ងៃសុក្រ
សិលាចារឹកភ្នំបយ៉ង្កោ K.852			
១០២៩ ឝក	ទឝមី រោច	វៃឝាខ	អាទិត្យវារ រេវតិ នក្សត្រ
១០២៩ សក	១១ រោច	ខែពិសាខ	ថ្ងៃអាទិត្យ «រេវតិ»

សិលាចារឹកនគរវត្ត

ការសរសេរកាលបរិច្ឆេទនៃសិលាចារឹកនគរវត្តចាប់ផ្ដើមពីការប្រសិទ្ធិពរ៖

 «សព្តមស្តុ» (IMA.4) ឬ «ស់ព្វមស្តុ» (IMA.6)៖ សុភមស្តុ (Subham astu) = សព្តមស្តុ=សុភម(បាលី) អស្តុ(សំ) = សូមជោគជ័យមានដល់ខ្ញុំ។

«សព្វមសតុជៃយាសទិតិរេក»(IMA.7) សុភមស្តុជៃយា (ជោគជ័យ) សិទ្ធិ (ជ័យជម្នះ) អតិរេក (គ្មានអ្វីស្មើ)

«សព្វមស្សស្តុជយ្យាតីរេក្ក» (IMA.8), ឬ «សព្វមសស្តុជយាតិរេក» (IMA.11)។

«សព្តម្មស្តុ សំម្មត្តីតិរេក្ក» (IMA.12)= សុភមស្តុ សម្ឫទ្ធិ (ចម្រើន) អតិរេក

«ស្តមស្សស្ត សូស្សតិស្រិសទ្ធាតីរេក» (IMA.23)= សុភមស្តុ ស្វស្តី

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(ថ្កុំថ្កើង) ត្រីសង្វាំតិរេក

«សព្វម្មសតុមង្គលពហុលចេស្តាជេយ្យាតិរេក» (IMA.25)= សុភម្មសតុ មង្គល (សុខចម្រើន) ពហុលចេស្តា (តេជះ អំណាច) ជេយ្យាតិរេក (ជ័យជម្នះជំពេង)


(IMA.6)

(IMA.25) (1662)

យើងសង្កេតឃើញថាការសរសេរនេះមិនមានសង្គតភាពទេ។

	គ.ស. ឆ្នាំ	សក		ខែ	ថ្ងៃ
IMA.4	១៥៦៦	១៤៨៨ សក ខាលអដ្ឋក្សត្រ	បុរមី កេត	ខែហមាគ្គសិរ	ព្រហស្បតី
IMA.6	១៥៩៩	១៥២១ សុក្កកុរអដ្ឋក្សត្រ	បុរមិ កេត	ខែហមាគ្សសិរ	ព្រហស្បតី

(IMA-3)



នា ១៥០១ ស.ក ហោះនក្ស័ត្រចតុទ្ធ័គី រោជអាសាទ្ធ ពុទ្ធពារ

(IMA-25)	គ.ស. ឆ្នាំ១៦៦២



១៥៨៤ ស័កន័កខ្សត្រឆ្នាំមខាលអដ្ឋមិរោជបុសថ្ងៃ ព្រហសសម្តិយពារសោរណា ឥសជុំទុំម្ហាយំរាជ្ជពា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៥.៤.សម្ព័ន្ធឃ្លា

គម្ពីសម្ព័ន្ធឃ្លាពីសំស្ក្រឹត

ឃ្លាប្រយោគ ឬល្បះត្រូវមានប្រធានកិរិយាសព្ទ និងកម្មបទ៖

IMA-2
ខ្ញុំអំចស្យមានសុចរិតសទ្ធាព្វត ព្រះសាស្នាព្រះតថាគត

ប្រធាន	កិរិយាសព្ទ	កម្មវត្ថុ
ខ្ញុំអំចស្យម	មាន	សុចរិតសទ្ធាព្វតព្រះសាសនាព្រះតថាគត
ខ្ញុំអម្ចាស់	មាន	សទ្ធាជ្រះថ្លាចំពោះព្រះសាសនាព្រះតថាគត

៥.៥.នាម

នាម គឺជាពាក្យសម្រាប់សម្គាល់មនុស្ស សត្វ វត្ថុ ភាវៈរូបិយ និងអរូបិយ ដែលប្រើជាប្រធាន ឬជាកម្មបទ នៅក្នុងល្បះ។ នាមចែកជា៖ (១) សាធារណៈនាម ដែលប្រើសម្រាប់មនុស្ស សត្វ វត្ថុ និង (២) អសាធារណនាម ដែលជាឈ្មោះមនុស្ស និងទិសស្ថាននាម ដែលបញ្ជាក់ពីទីកន្លែង។ «សិលាចារឹកអង្គរ» បានកត់ត្រានូវឈ្មោះព្រះពុទ្ធ ព្រះមហាក្សត្រ ព្រះសង្ឃរាជ មន្ត្រីជាន់ខ្ពស់ បព្វជិត និងរាស្ត្រសាមញ្ញ ។

៥.៥.១. គោរមងារព្រះពុទ្ធ

ទេវនាមដែលគេជួបប្រទះក្នុងសិលាចារឹកនគរវត្ត គឺជានាមព្រះពុទ្ធ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្សេងៗដូចជា៖ បុព៌្វពោធិសត្វ, ត្រីអាយ៌្យមៃត្រិ, ព្រះតថាគត,

កម្រតែង៖ ជាឋានន្តរនាមខ្ពស់ជាងគេ ដែលបន្តពីសម័យអង្គរត្រូវបានប្រើ សំដៅព្រះពុទ្ធ នៅចុងសតវត្សទី១៦។

សំតេចព្រះមហាត្រីរត្នត្រៃកម្រតែងយេង (IMA-2)

«សំតេច» សម្រាប់ព្រះពុទ្ធជាអម្ចាស់៖



សំតេចព្រះត្រីអាយ៌្យមៃត្រិ (IMA-2)



សំតេចព្រះមហាត្រីរត្នត្រៃយ (IMA-3)

៥.៥.២. នាមនិងគោរមងារព្រះមហាក្សត្រ

«សំតេច» គឺជាគោរមងារម្រាប់ព្រះមហាក្សត្រ និងក្រុមរាជវង្សានុវង្សផងដែរ៖

សំតេចព្រះរាជមាតាមហាកល្យាណវត្តីត្រីសុជាតា (IMA-2)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



សំតេចព្រះកតវត្តីគ្រីចក្រពត្តិអគ្គ័រាជមហេសីព្រះពិធរណិន្ទ្រជេយ្យរាជ
ទេព្រីគជម្ម៌ធិតា (IMA-3)

គោរមង៉ារព្រះមហាក្សត្រ



សំតេចព្រះជៃយ្យជេដ្ឋាធិរាជឱង្ការបរមេរាជាធិរាជរាមាធិបតិ
គ្រីត្រិភវនាទិត្យពម្ម៌ ធម្មិករាជ មនុវង្សោត្តរ
មហាបរមចក្រពត្តិរាជកម្ពុជ្ជេស្វរ សុរិន្ទតេជោជេយ្យ
ត្រៃរត្នមកុដវិសុទ្ធ ជិនសាស្នធរបរមត្ថុបថម្ភករាជ

(IMA-3)

សម្តេចព្រះជៃជេដ្ឋាធិរាជ ឱង្ការបរមរាជាធិរាជ រាមាធិបតិ (រាម ដែលជាអធិបតី) គ្រីត្រិភវនាទិត្យពម្ម៌ (ព្រះអង្គដែលការពារដោយព្រះអាទិត្យនៃភពទាំងបីដ៏មានសិរី) ធម្មិករាជ (ស្តេចប្រកបដោយធម៌) មនុវង្សោត្តរ (ត្រកូលក្សត្របង្កើតលោក) មហាបរមចក្រពត្តិរាជកម្ពុជ្ជេស្វរ សុរិន្ទតេជោជេយ្យ (ទេវតាដែលឈ្នះដោយអំណាច) ត្រៃរត្នមកុដ (មកុដរតនទាំងបី)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិសុទ្ធ ជិនសាស្នធរ (ចេះអស់ធម្មព្រះពុទ្ធ) បរមត្ថ បឋម្ភករាជ (រាជឧបត្ថម្ភ នៃបរមវត្ថុ)


IMA.2

សំតេចព្រះរាជមាតាមហាកល្យាណវត្តី ត្រីសុជាតា

៥.៥.៣. គោរមងារព្រះសង្ឃ

នៅក្នុងសម័យកណ្តាល ព្រះសង្ឃរាជ បព្វជិតជាន់ខ្ពស់ និងព្រះសង្ឃជាន់ខ្ពស់មាននាមជាភាសាបាលី និងសំស្ក្រឹត ដូចជា៖ សំតេចព្រះមហាថេរត្រីរត្នមហាពោធិ, ចៅនិស្រយមុនិ, ចៅស្រាមនេររត្នលង្ការ, ចៅស្រាមនេរឥន្ទមោ, ចៅ

IMA-8	សរសេរជាខ្មែរ	អត្ថន័យជាភាសាខ្មែរទំនើប
	អ្នកស្តេចព្រះយស្សធរ	អ្នកមានយស
	អ្នកព្រះធម្មកិត្តិ	ខេត្តនៃព្រះធម៌
	អ្នកស្តេចព្រះមហាមង្គល	សេចក្តីចម្រើនដ៏ខ្ពង់ខ្ពស់
	អ្នកស្តេចព្រះរាជពោធិសមុះ	ប្រជុំរាជពេញចិត្ត
	អ្នកស្តេចមហាឱត្តល	មិនអាចប្រៀបស្មើបាន
	អ្នកស្តេចព្រះធម្មបារម្មី	ព្រះធម្មដ៏ឧត្តម

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

	អ្នកស្ដេច ព្រះឥន្ទ្រទិព្វចក្រ	ចក្ខុទិព្វដូច ព្រះឥន្ទ្រ
	អ្នកស្ដេចមោក	មោក្ខ = ធម្មឱ្យរួចចាកទុក្ខ
	អ្នកមហាថេរ ព្រះធម្មអរិយ	ធម្មដ៏ចម្រើន
	អ្នកបញ្ញាសុត្ត	មានប្រាជ្ញាបរិសុទ្ធ
	អ្នកស្ដេចប្រញ្ញានន	បញ្ញានន្ទតិ =រីករាយនឹងប្រាជ្ញា
	អ្នកស្ដេច ព្រះបញ្ញាជេដ្ឋ	ខ្ពង់ខ្ពស់ដោយ ប្រាជ្ញា
	អ្នកបវរបញ្ញា	ប្រាជ្ញាប្រសើរបំផុត
	អ្នកស្ដេចសមេត្តបញ្ញា	ប្រាជ្ញាអ្នកប្រាជ្ញ
	អ្នកស្ដេច ព្រះឥនកិលាស	ព្រះឥន្ទនៃ ស្ថានកៃលាស
	អ្នកស្ដេចព្រះរាជកិរិយ	ព្រះរាជការី
	អ្នកមហា ថេរអរិយកិញ្ញាណ	វិញ្ញាណដ៏ចម្រើន
	អ្នកមហាថេរវីរ យ្យាមរម្មិ	សេចក្តី អង់អាចដ៏ឧត្តម
	អ្នកព្រះមុនិសធម្ម	អ្នកប្រាជ្ញចេះធម្ម
	អ្នកមហាថេរបវរ គាថាម្ហាបាលី	អ្នកប្រាជ្ញបាលី ដ៏ប្រសើរ

	អ្នកមហាថេរបវរទក្ខិណ	បវរទក្ខោ =ឈ្លាសវៃដ៏ប្រសើរ

ពាក់កណ្ដាលសតវត្សទី១៦ សម័យលង្វែក (ឆ្នាំ១៥៦៦)

នៅពាក់កណ្ដាលសតវត្សទី១៦ គោរមងារព្រះសង្ឃជាន់ខ្ពស់មាន ៖

(១) «អ្នកម្ដា»៖ អ្នកមហាសង្ឃរាជ

	អ្នកម្ដាសឃ័រាជព្រះធម៌ខេត (IMA-4)
	អ្នកម្ដាសឃ័រាជព្រះស្មេត្ត (IMA-4)

(២) «ថៅ»៖

	ថៅនិស្រេយមុនិ (IMA-4)
	ថៅស្រាមនេរវត្តលង្ការ (IMA-4)

ចុងសតវត្សទី១៧ សម័យឧដុង្គ (ឆ្នាំ១៦៨២)

សំតែចព្រះសូរបញ្ញាបុពិត្រ សំតែចព្រះមរវិនៃបុពិត្រ សំតែចព្រះជេដ្ឋសិទ្ធាន្ទ សំតែចព្រះជេដ្ឋស័ត្ថា សំតែចព្រះបរវិទូ សំតែចព្រះបញ្ញាវិនៃ ព្រះបញ្ញាពិទូរ ព្រះមហាថេរស្មេណគីរ អ្នកបវរពោធិ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅចុងសតវត្សទី១៧ គោរមងារព្រះមហាសង្ឃរាជមានបីថ្នាក់គឺ៖

(១) សំតេច៖ សំតែចព្រះសួរបញ្ញាបុពិត្រ, សំតែចព្រះមរវិនៃបុពិត្រ, សំតែចព្រះជេដ្ឋសិទ្ធាន្ទ, សំតែចព្រះជេដ្ឋស័ត្ថា, សំតែចព្រះបរវិទូ, សំតែចព្រះបញ្ញាវិនៃ

(២) ព្រះ៖ ព្រះបញ្ញាពិទូរ, ព្រះមហាថេរស្មណកីរ និង

(៣) អ្នក៖ អ្នកបវរពោធិ។

ជារួម ព្រះសង្ឃជាន់ខ្ពស់នៅសម័យលង្វែក គឺជា «ព្រះអរិយសង្ឃ» ដែលមានគោរមងារផ្សេងៗ។

៥.៥.៤. គោរមនាមរបស់មន្ត្រី

គោរមនាមមន្ត្រីជាន់ខ្ពស់ដែលគេជួបប្រទះក្នុង «សិលាចារឹកអង្គរ» គឺជាពាក្យទោលផង ពាក្យសមាសផង និងកន្សោមពាក្យផង។ មន្ត្រីជាន់ខ្ពស់មាន «គោរមនាមបំពេញមុខងារ» ជាភាសាបាលី និងសំស្ក្រឹត ដូចជា៖ អកហ្លួង អកៃរាជ, អកញ្ញា ឱង, ឱកហ្លួង ចក្រីឥស្សែង, ពញា សួរេនឥន្ទ្រាធិប្បត្តិ (អធិបតីនៃព្រះឥន្ទ្រ)។ គោរមងារមន្ត្រីជាន់ខ្ពស់មាន៖ (១) អកហ្លួង (២) ឱកហ្លួង (៣) អ្នកអកជម្ទ័

អ្នកឧទេបុញ្ញា= បា. អ្នក-ឧទ័យបញ្ញា (គោរមងារ)

IMA	សរសេរជាខ្មែរ	អត្ថន័យជាភាសាខ្មែរទំនើប
	អកហ្លួងអកៃយរាជ (IMA-4)	ការអត់អោនទោស
	ឱកហ្លួងពង្សាទកុល (IMA-8)	ករុណា សង្រ្គោះ
	ពង្សាបរទេស (IMA-8)	វង្សាប្រទេស

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាក់កណ្ដាលសតវត្សទី១៦ សម័យលង្វែក (ឆ្នាំ១៥៦៦)

នៅពាក់កណ្ដាលសតវត្សទី១៦ គោរមងារមន្ត្រីជាន់ខ្ពស់មាន ៖

(១) «អកហ្លួង» ឬ «ឱកហ្លួង» ៖ គឺជាគោរមងារនៃអ្នកដែលគ្រប់គ្រងវណ្ណៈសូទ្រ។

	អកហ្លួងអកៃយរាជ (IMA-4)
	អកហ្លួងអកៃយរាជ (IMA-6)

(២) «អ្នក» ៖ ព្រះបញ្ញាពិទូរ, ព្រះមហាថេរស្មេណាគីរ និង

	អ្នកចៅរភិក្ខុសរ (IMA-6)
	អ្នកអកជម៌ (IMA-4)

អ្នកឱទេបុញា= បា. អ្នក-ឱទ័យបញ្ញា (IMA-10)

អ្នក ប្បញាទស្សី = បា., អ្នក បញ្ញាទស្សី (IMA-11)

(៣) «អកញា» ៖ អ្នកបវរពោធិ។

	អកញាឱង (IMA-4)

ចុងសតវត្សទី១៦ ក្រោយបែកលង្វែក (ឆ្នាំ១៥៩៩)

	ឱកហ្លួងអក្តៃរាជ (IMA-6)
	អ្នកចោរភិក្ខុឥន (IMA-6)

«អ្នកចោរ» ៖

«ថ្ងៅរ» ៖ (IMA-12) ថ្ងៅរពោរនាំមាន ថ្ងៅរព្រំហ្មនាំបុស ថ្ងៅរសុក្ខនាំទេ

«អ្នក» ៖

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«ជំទាវ»៖

IMA-8	សរសេរជាខ្មែរ	អត្ថន័យជាភាសាខ្មែរទំនើប
	អ្នកស្តេចព្រះយស្សធរ	អ្នកមានយស
	អ្នកព្រះធម្មក្ខិត	ខេត្តនៃព្រះធម៌
	អ្នកស្តេចព្រះមហាមង្គល	សេចក្តីចម្រើនដ៏ខ្លាំងក្លា

នៅចុងសតវត្សទី១៧ សម័យឧដុង្គ (ឆ្នាំ១៦៨៤)

នៅចុងសតវត្សទី១៧ គោរមងារមន្ត្រីជាន់ខ្ពស់មាន (IMA-30)៖

ចៅពញាកម្មជោ ព្រះមន្ត្រីធូបេស ព្រះជិតខ្សត្រិ ព្រះមនោអនិជិត្រ

(១)«ចៅពញា»៖សម្រាប់មន្ត្រីជាន់ខ្ពស់ជាងគេ៖ចៅពញាកមតេជោ ដែលទំនងមានឋានៈជា «នាយករដ្ឋមន្ត្រី»

(IMA-8) ឲ្យាវពញា សួរេនឥន្ទ្រាភធិប្បត្តិ ដែលមានមុខងារជា ឯកអគ្គសេនយោទ្ធាមុក្ខ (ឯកអគ្គបញ្ជាការយោធា)

(២) ព្រះ៖ព្រះ គឺជាគោរមងារបន្ទាប់ពីចៅពញា៖ព្រះមន្ត្រីបិបេសរ៍ ព្រះជិតខ្សត្រិ ព្រះមនោឥន្ទជិត ដែលទំនងជាគោរមងារដែលមានឋានៈកម្រិត «រដ្ឋមន្ត្រី» ។

៥.៥.៥. នាមរបស់រាស្ត្រសាមញ្ញ

ជារួម មនុស្សស្រទាប់ក្រោមនៅសម័យកណ្តាលមានឈ្មោះជាពាក្យខ្មែរផង និងសំស្ក្រឹតផង។ នរនាមត្រូវបានបង្កើត ដោយប្រើប្រាស់នូវវិធាន ដូចខាងក្រោម៖

- កេទ+នាម ៖ អាចាន, អាកែវ, មេសុត មេអន មេសរ
- នាម+នាម៖ ខុណា (ឃុន) បញ្ចងរទេយ (ហ្ឫទ័យ)

នៅក្នុងសិលាចារឹក គេប្រើឋានន្តរនាមដើម្បី៖ (១) សម្គាល់ភេទប្រុស ដូចជា ចៅ និងអ្នកសម្រាប់ហៅមនុស្សប្រុសដែលមានឋានៈខ្ពង់ខ្ពស់ និងអា សម្រាប់ហៅខ្ញុំបម្រើប្រុស (២) សម្គាល់ភេទស្រី ដូចជា នាង សម្រាប់ហៅ មនុស្សស្រីដែលមានឋានៈខ្ពង់ខ្ពស់ និង មេ សម្រាប់ហៅខ្ញុំបម្រើស្រី។ ឋានន្តរនាមនេះមានការផ្លាស់ប្តូរ បើប្រៀបធៀបទៅនឹងសម័យអង្គរ ដូចមាននៅក្នុងតារាងខាងក្រោម។

ភេទ	សម័យអង្គរ	សម័យកណ្ដាល
មនុស្សប្រុស	សិ សី	(IMA-16) ចៅវ៍
		(IMA-11) អ្នក
		 អា (IMA-10 ខ្ញុំប្រុស)
មនុស្សស្រី		(IMA-11) នាង
	តៃ (មកពីកន្ថែ) តៃយ អ្មេ	 មេ (IMA-10 ខ្ញុំស្រី)

នៅពាក់កណ្ដាលសតវត្សទី១៦ (ឆ្នាំ១៥៦៦) ងារខ្ញុំមាន ៖

(១) «អា» ៖ សម្រាប់សម្គាល់ខ្ញុំប្រុស៖



ខ្ញុំប្រុសឈ្មោះអាចាន ១ អាកែវ ១

(២) «មេ» ៖ សម្រាប់សម្គាល់ខ្ញុំស្រី៖



មេសុត ១ មេអន ១ មេនៃយ ១ មេសរ
១ មេរស ១ មេសម ១ មេហង ១ មេគា

នៅក្នុងសម័យឧដុង្គនៅដើមសតវត្សទី១៧   យើងចាប់ឃើញមានឥទ្ធិពលថៃ នៅក្នុងការដាក់ឈ្មោះ និងហៅរាស្ត្រសាមញ្ញ។ នៅក្នុង IMA-8 *ចារក្នុងឆ្នាំ១៦២៥ គេឃើញមានឈ្មោះ ខុណ (ឃុន) បញ្ញវទយ និងមានប្រើពាក្យកម្ចីសៀម ដូចជា ចៅម្អើង (ចៅមឿង) ដែលជាចៅហ្វាយក្រុង។*

ពាក់កណ្ដាលសតវត្សទី១៧ សម័យឧដុង្គ (ឆ្នាំ១៦៨២)

នៅចុងសតវត្សទី១៧ ងារខ្ញុំមាន ៖

(១) «អ្នក» ៖ សម្រាប់សម្គាល់ខ្ញុំប្រុស៖

អ្នកវ្ទិប អ្នកសី ១ អ្នកមោក

(២) «មេ» ៖ សម្រាប់សម្គាល់ខ្ញុំស្រី៖



មេរត្ន មេកែវ មេបុក

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៥.៥.៦. ឋាននាម

ឋាននាម គឺជាពាក្យដែលគេយកមកហៅឈ្មោះទីតាំងផ្សេងៗនៅក្នុងប្រទេស។ នៅក្នុងសិលាចារឹកនគរវត្ត គេបានរកឃើញមានឋាននាម៖

IMA-8	សរសេរជាខ្មែរ	អត្ថន័យជាភាសាខ្មែរទំនើប
	កំម្ពុជទេស (IMA-3)	ប្រទេសកម្ពុជា
	ព្រះពិស្នុលោក (IMA-3)	ប្រាសាទអង្គរវត្ត
	មហានគរ (IMA-12)	អង្គរធំ
	លង្វែក (IMA-39)	
	ស្រុកកុំពង់ស្វាប្យ (IMA-39)	ស្រុកកំពង់ស្វាយ
	ស្រុករលាប្បអៀរ (IMA-39)	ស្រុករលាប្អៀរ

ស្ថាននាមជាពាក្យខ្មែរបានត្រូវគេប្រើប្រាស់ជាផ្លូវការសម្រាប់ដាក់ឈ្មោះភូមិភាគ ដែនដីនិងចំណុចភូមិសាស្ត្រដទៃទៀតនៃកម្ពុជទេស៖ ដូចជាបន្ទាយព្រិច ស្រុកក្អែកទុំ លង្វែក។

៥.៦.គុណនាម

គុណនាម គឺជាពាក្យដែលគេបន្ថែមដើម្បីបញ្ជាក់ពីលក្ខណៈរបស់នាម និងសម្គាល់នាមនោះ។ នៅក្នុងល្បះនៃភាសាខ្មែរកណ្ដាល ការប្រើគុណនាម ដើម្បីពិពណ៌នានាម អាចដាក់ខាងមុខនាមក៏បាន និងអាចដាក់ពីក្រោយនាមក៏បាន ដូចក្នុងភាសាសំស្ក្រឹត និងបាលីដែរ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

IMA-3

(១) នែះគិពោះត្រិពិធសុចរិតសទ្ធាមហា (២) វិបុលអតុល្យអតិរេកឯកត្ថតាប្រា

នេះ គឺពោះសទ្ធាជ្រះថ្លាបីប្រកាមហា វិបុលគ្មានអ្វីប្រដូចបានធំធេងផ្តោះទៅគោលដៅមួយ

៥.៦.១. គុណនាមប្រក្រតី

គុណនាម គឺជាពាក្យដែលគេបន្ថែមទៅលើនាមដើម្បីបញ្ជាក់លក្ខណៈរបស់នាម និងសម្រាប់សម្គាល់នាមៗ គេចែកគុណនាមជាគុណនាមប្រក្រតី និងគុណនាមមិនប្រក្រតីៗ

នៅក្នុងភាសាខ្មែរកណ្តាលគុណនាមប្រក្រតីភាគច្រើនដែលប្រើ គឺជាកម្ចីពីភាសាសំស្ក្រឹត និងបាលីៗ ឧទាហរណ៍ «ត្រិពិទ្ធ ត្រៃយសវន្ទនា» ៖ សូមថ្វាយបង្គំបីដងដល់សរណៈវត្ថុទាំង៣ ព្រះពុទ ព្រះធម៌ និងព្រះសង្ឃៗ

៥.៦.២. គុណនាមមិនប្រក្រតី

គុណនាមមិនប្រក្រតីចែកចេញជា៖ (១) គុណនាមចំនួន (២) គុណនាមលំដាប់ (៣) គុណនាមកម្មសិទ្ធិ និង (៤) គុណនាមចង្អុលៗ

៥.៦.២.១ គុណនាមចំនួន

គុណនាមចំនួន គឺជាគុណនាមសម្រាប់ប្រាប់ចំនួន ដូចជាមួយ ពីរ បី ៗលៗ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

IMA	សរសេរជាខ្មែរ	ជាភាសាខ្មែរទំនើប
IMA-2	មួយ	១
IMA-11	ពិរ	២
IMA-8	បិ	៣
IMA-37	បួន	៤
	បញ្ច	៥
	ឆ	៦
IMA-8	ប្រាំពិល	៧
IMA-36	ប្រាំប្យិ	៨
	នព្វ	៩
	ទស	១០
	ទ្វាទស	១២
	ចតុទស	១៤
	អដ្ឋារស	១៨

ប្រព័ន្ធលេខ

ពាក្យសព្ទសំស្ក្រឹត	អធិប្បាយសព្ទជាភាសាខ្មែរ
មូយ	មួយ
ពីឬ	ពីរ
បិ = ត្រី	បី
ចតុ	បួន
បញ្ច	ប្រាំ
ប្រមូយ	ប្រាំមួយ
សប្ត	ប្រាំពីរ
អដ្ឋ	ប្រាំបី
នព្វ	ប្រាំបួន
ទស	ដប់
តេរស	ដប់បី
ចតុទ្ទំគិ	ដប់បួន
ទ្វាទស	ដប់ពីរ
អដ្ឋារស្យ	ដប់ប្រាំបី
សត្តតិស័វរ	សាមសិបប្រាំពីរ
ចត្តាឡិស	សែសិប
អស្ដោត្តរសត	មួយរយប្រាំបី

៥.៦.២.២. គុណនាមលំដាប់

គុណនាមលំដាប់ គឺជាគុណនាមចំនួនសម្រាប់បង្ហាញលំដាប់ និងជាន់ថ្នាក់របស់នាម។ ភាសាខ្មែរកណ្ដាលប្រើកម្ទីបាលី សម្រាប់ប្រើក្នុងគុណនាមលំដាប់។

សរសេរជាខ្មែរ	ភាសាខ្មែរទំនើប
ឯក	១
ទោ	២
ត្រី	៣
ចតុ	៤
បញ្ច	៥
ឆ	៦
សប្ត	៧
អដ្ឋ	៨
នព្វ	៩
សំរឹទ្ធ	១០
ទ្វាទស	១២
ចតុទស	១៤
អដ្ឋារស	១៨

៥.៦.២.៣. គុណនាមចង្អុល

សព្វនាមចង្អុល «នេះ នោះ»



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៥.៧. កិរិយាសព្ទ

កិរិយាសព្ទ គឺជាពាក្យសម្រាប់ប្រាប់អំពើ ដែលប្រធានធ្វើ។

៥.៧.១. ការប្រើប្រាស់នាមជំនួសកិរិយាសព្ទ

នៅក្នុងល្បះខ្លះនៃភាសាខ្មែរចាស់ នាមត្រូវបានប្រើប្រាស់ជំនួសឱ្យកិរិយាសព្ទ៖

ក្ញុំអំនោយជំអញព្វតវ្រះកម្រតាងអញមហាគណបតិ

ប្រធាន	កិរិយាសព្ទ	កម្មវត្ថុ
ក្ញុំអំនោយជំអញ		ព្វតក្បោញកម្រតាងអញ

ជំអញផ្តល់អំណោយជាក្ញុំដល់ព្រះគនេស (វ្រះកម្រតាងអញមហាគណបតិ)

៥.៨. សព្វនាម

សព្វនាមសម្រាប់ប្រើជំនួសកន្សោមនាម ដែលគេនិយាយរួចហើយ ដែលគេពុំទាន់និយាយ និងបង្ហាញបុគ្គលរួមក្នុងការប្រាស្រ័យទាក់ទងគ្នា។ សព្វនាមអាចចែកចេញជាថ្នាក់ផ្សេង៖ (១) សព្វនាមបុរិស ដូចជា «ខ្ញុំ», «គាត» (២) សព្វនាមចង្អុល (៣) សព្វនាមឈ្នាប់ (៤) សព្វនាមសំណួរ។

៥.៨.១. សព្វនាមបុរិស

«ខ្ញុំ»

សព្វនាម «ខ្ញុំ» នៅ (IMA.3)

	«ខ្ញុំ»	ខ្ញុំ

«ខ្ញុំ» វិវត្តមកពីពាក្យខ្មែរចាស់ «ខ្ញុំ» បម្រើ

«គាត»

សព្វនាម «គាត» នៅ (IMA. 4)

	«គាត»	គាត់

«គាត» វិវត្តមកពីពាក្យខ្មែរចាស់ «ជគត» ដែលខ្មែរទំនើប គឺ «គាត់»

«គេ»

សព្វនាម «គេ» នៅ (IMA. 16)

	«គេ»	គេ

«គេ» គឺពាក្យខ្មែរចាស់ នៅ (K.214) សិលាចារឹកបន្ទាយនាង

«អញ»

សព្វនាម «អញ» នៅ (IMA. 11)

	«អញ»	អញ

«អញ» វិវត្តមកពីពាក្យខ្មែរចាស់«អញ» ជាពាក្យមិនគួរសមសម្រាប់ អ្នកធំជាង

«ឯង»

សព្វនាម «ឯង» នៅ (IMA. 11)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

	«ឯង»	ឯង

«ឯង» មានន័យថា «អ្នក»

៥.៨.២. សព្វនាមចង្អុល

សព្វនាមចង្អុល «នេះគិ»

នេះតតិ (IMA-2) = *នេះគឺជា*

នេះតតិត្រិពិតសុចិរិតសទ្ធាំនៃខ្ញុំអម្ចាស់ = នេះគឺជាសទ្ធាដ៏ជ្រះថ្លាបីផ្នែកនៃខ្ញុំជាអម្ចាស់

នេះគិពោះត្រិពិធសុចរិតសទ្ធា(IMA-3)=*នេះគឺសទ្ធាដ៏ស្មោះទាំងបីប្រការ*

«ទាំងនេះ (IMA-4)**»**

«សូម»

សព្វនាម «សូម» ត្រូវបានប្រើប្រាស់សម្រាប់ការបួងសួង និងការធ្វើសច្ចាប្រណិធាន។

សូំខ្ញុំអំចស្សបានបំរេហជាឱបាសករត្ន (IMA-2)។



សូមខ្សេម សំម្វទ្ធិស្ថិរ ស្ពាពរហោង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៥.៨.៣. សព្វនាមឈ្នាប់

«មន»

ឈ្នាប់ «មន» មាននៅក្នុងសិលាចារឹកមុនអង្គរ ដែលត្រូវបានប្រើជាគុណនាមនៅក្នុងល្បះ។ នៅសតវត្សទី១៦ ឈ្នាប់ «មន» នៅបន្តប្រើទៀតនៅក្នុងសិលាចារឹកនគរវត្ត «មន្តិ» = «មនតិ» ដែលមានន័យថា នេះគឺ ។

IMA-4

មន្តិ អកហ្វូងអកៃយរាជនុអ្នកអកជម៌មា
មន តិកព្ភជាតកន្តារ = នេះ គឺកពជាតិជាផ្លូវដ៏លំបាក

ឈ្នាប់ «មន» មានន័យថា «ដែល»

IMA-17
សាគរមនលុះតលមហានគរនិព្វាន

សាគរ ដែលលុះដលមហានគរនិព្វាន

«ត់»

ឈ្នាប់ «ត» នៅក្នុងសិលាចារឹកសម័យអង្គរដែលត្រូវបានប្រើជាសព្វនាមក្នុងល្បះ នៅបន្តប្រើក្នុងភាសាខ្មែរកណ្តាល ហើយមានន័យថា «ចំពោះ»។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

IMA-2

ថ្វាយបង្គំប្រណម្យទូលចំពោះព្រះវរបាទារុពិន្ទុ នៃសម្តេចព្រះមហាគ្រីរតនត្រៃកម្រតែងយើង

IMA-3

កល្ប៍នាថ្វាយទោត់សំតេចព្រះ ជីត់បួនព្រះអង្គ នុសំតេចព្រះវរបិតាធិរាជស្មោង គុណាព្រះកន្ទោង

«តជា»

 ភាសាខ្មែរកណ្តាលប្រើគុណនាម «តជា» ជាឈ្នាប់សម្រាប់បញ្ជាក់នាមៗ នៅក្នុងសិលាចារឹកមុនអង្គរ (K.38) គេប្រើជាគុណនាម «ដែល» នៅក្នុងល្បះ ហើយមានន័យដូចពាក្យ «មន» ដែល។

ខ្មែរចាស់
ពហុឯកមន្ត្រ្ទយ តជាផ្តិចំទាវទេិព្វសុពារ
ខ្មែរទំនើប
ពហុឯកមន្ត្រី ដែលជាប្តីជំទាវទេព្វសុពារ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«នុ»

«នុ» សម្រាប់ភ្ជាប់កិរិយាសព្ទ ជាមួយកម្មបទ

ក្នុងភាសាខ្មែរគេមិនប្រើពាក្យភ្ជាប់កិរិយាសព្ទ និងកម្មបទទេ។ ក៏ប៉ុន្តែនៅក្នុងភាសាខ្មែរកណ្ដាលគេបន្ថែមពាក្យនូវនៅចន្លោះកិរិយាសព្ទ និងកម្មបទ ដែលជាកម្ចីពីសំស្ក្រឹត និងបាលី។ តែពាក្យ «នូវ» អាចមានន័យពីរយ៉ាង៖

១) ឈ្នាប់ «នុ» មាននៅក្នុងសិលាចារឹកនគរវត្ត។ នៅក្នុងភាសាខ្មែរទំនើប ឈ្នាប់ «នុ» បានក្លាយជាឈ្នាប់ «នូវ»។

IMA-3

(១៨) ស្តចមានព្រះរាជប្រាជ្ញានុ (១៩) លេកសាស្នាព្រះតថាគតប្រាកដកសាងមហាប្រា (២០) សាទ្ធព្រះពិស្នុលោក

ស្តចមានព្រះរាជប្រាជ្ញា នូវលើកសាសនាព្រះតថាគត សាងមហាប្រាសាទព្រះពិស្ណុលោក

កល្បនាថ្វាយទោត់សំតេចព្រះព្រះជីត់បួនព្រះអង្គ នុសំតេចព្រះវរបិតាធិរាជស្មោងគុណព្រះកន្ទោង(IMA-3)

ព្រះរាជបុត្រកោប្រនុលក្ស៌ = ព្រះរាជបុត្រប្រកបនូវលក្ខណៈ (IMA-3)

២) ឈ្នាប់ «នុ» ប្រើមានន័យថា «និង»

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

IMA-4

អកហ្វូងអកៃយរាជនុអ្នកអកជម្មុំមា   *នចិត្រស់ទ្វាសាងព្រះវិហារស្បាតនោះ*

អកហ្វូងអកៃយរាជ និងអ្នកអកជម្មុំមានចិត្រស់ទ្វាសាងព្រះវិហារស្បាត នោះ (IMA-4)។

សព្វនាមកន្លែង

សព្វនាម «ឰត» នៅក្នុងសិលាចារឹកសម័យអង្គរ នៅបន្តប្រើក្នុងភាសាខ្មែរកណ្ដាល។



សាងសាសនាព្រះតថាគតឱយប្រាកដឰត់កម្ពុជទេសនេះលេកយស ព្រះរាជសន្តានឱយសំបូណ្ណ៌ (IMA-3)។

សព្វនាមពេល

លុះនា

លុះនាបានបួស = នៅពេលបានបួស

លុះកាល្ណ

លុះកាលណាបិលាផ្នូសបព្វជាកម្មវិង

សព្វនាម«នោះ (IMA-4)»

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សព្វនាម«នោះឞី (IMA-4)»

សព្វនាម«ឞើហ (IMA-30)»

សព្វនាម«ស្ញុម (IMA-3)» សម្រាប់ការខ្លួនស្លួន



សុំវាស្រ្តដោងអំបាលកំលុងកំម្ពុជទេសនេះនោ

សុក្ខខ្សេមខ្សានកុំម្បីមានចលាចលលេយ

«ទោះ»

សព្វនាមកន្លែង «នៅលើ»

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ព្រះរាជ្ជសុមុង្គលសីលាចាយ៌្យបុពិត្រ
ទ្វតសសង់ផោងទំហ្យ ៥៥ មោកទ្រង
បាំងស្គួលព្រះអង្គទ្វលើហព្រះពន្ទនោះចចាយប្រថៃយ

ព្រះរាជ្ជសុមង្គលសីលាចាយ៌្យបពិត្រ ទ្វតសសង់ផោងទំហ្យ ៥៥ ទ្រង់បង្គ្រួលព្រះអង្គនៅលើព្រះពាន់នោះចូលបច្ច័យ (IMA-27)



សព៌សព៌មហោរត្តិ - មហោរឡារ - ពេចភូល

សព្វថ្ងៃសព្វយប់ (រាល់ថ្ងៃរាល់យប់) មហោរឡាឬក (ធំក្រៃលែង) កើតពេញឡើង

៥.៩. ពាក្យសម្រាប់ជាស្នៀត

«តេម្បិ» សម្រាប់ប្រាប់គោលបំណង

«កុំម្បី»

៥.១០. និបាតសព្ទ

ការប្រើប្រាស់និបាតសព្ទ «លេយ»

និបាតសព្ទ «លេយ» មានប្រើនៅក្នុងភាសាខ្មែរកណ្ដាល ដែលនៅក្នុងភាសាខ្មែរទំនើបបានក្លាយទៅជា «ឡើយ» ដែលមានន័យបដិសេធថា «ដាច់ខាត»។ អក្សរ «ឡ» ទើបតែប្រើនៅក្នុងភាសាខ្មែរទំនើបប៉ុណ្ណោះ។ ក្នុងភាសាខ្មែរកណ្ដាលគេប្រើ«ល៉» ឬ«ម្ល» ជំនួសឲ្យ«ឡ»។ ភាសាបាលីមានប្រើអក្សរ«ឡ» ខ្លះដូចជា គរុឡ, កីឡា, ចូឡាមណិ។ ភាសាសំស្ក្រឹតមិនប្រើអក្សរ «ឡ» ទេ ហើយប្រើអក្សរ «ឌ» ជំនួសវិញ ដូចជា គរុឌ, ក្រីឌា, ចូឌាមណិ។ និបាតសព្ទ «លេយ» មាននៅប្រើក្នុងភាសាសៀមនាពេលបច្ចុប្បន្ន។



សុំសំយក្ស័ក្តក្តីត់ព្រះសាស្នាព្រះតថាគតហោង កុម្បិចាកលែងព្រះសាស្នាលេយ

៥.១១. ការប្រើប្រាស់សញ្ញា

សញ្ញាភ្នែកមាន់

សញ្ញាភ្នែកមាន់ គឺជាសញ្ញាប្រើនៅដើមឃ្លា សម្រាប់បើកអត្ថបទ និងវគ្គ។

(IMA-3)

សញ្ញា (០)

ភាសាខ្មែរកណ្ដាលបន្តប្រើសញ្ញាមូល ០ ជាសញ្ញាខណ្ឌនៅចុងវគ្គ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះកាលជាព្រះឃ្លាំងហោង០ លុះបានជា

(IMA-16)

(IMA-13)

នៅក្នុងសិលាចារឹកគេប្រើសញ្ញាផ្សេងៗសម្រាប់សម្គាល់ខណ្ឌចប់។ ឃ្លាបញ្ចប់ត្រូវចប់ដោយពាក្យ «ហោង» និងមានចម្លាក់ផងដែរ។



៥.១២. ការវិវត្តសូរសព្ទ

សតវត្សទី១៦

ភាសាខ្មែរកណ្ដាល គឺជាដំណាក់កាលអន្តរកាលមួយ នៅចន្លោះភាសាខ្មែរចាស់ និងខ្មែរទំនើប ដែលមានការផ្លាស់ប្ដូរទាំងការប្រើពាក្យវេយ្យាករណ៍ និងសូរសព្ទ និងការចាប់ផ្ដើមនៃដំណាក់កាលភាសាខ្មែរទំនើបនៅក្នុងរជ្ជកាលព្រះបាទអង្គអេង នៅក្នុងឆ្នាំ១៧៧៧។

ខាងផ្នែកសូរសាស្ត្រដែរ ភាសាខ្មែរទំនើបត្រូវអានលេបពាក្យ ប្រសិនបើពាក្យនោះបញ្ចប់ដោយព្យញ្ជនៈ «រ»។ ការលេបពាក្យនេះ គឺជាការផ្លាស់ប្ដូរសូរបង្រ្គាបដ៏ធំមួយ នៅចុងសម័យកណ្ដាល។ ក៏ប៉ុន្តែ ការអានពាក្យខ្មែរចាស់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្ចីពីសំស្ក្រឹត ដែលមាន «រ» នៅខាងចុងបន្លឺសំឡេងឱ្យឮសូរ ដូចភាសាសំស្ក្រឹត ដែរ ហើយរបៀបអានដូច្នេះ ខ្មែរសុរិន្ទនៅបន្តបន្លឺសូរ «រ» នេះនៅឡើយដោយសារតែបងប្អូនខ្មែរសុរិន្ទបានកាត់ផ្ដាច់ពីការវិវត្តសូរបង្រ្កាបនៅចុងសម័យកណ្ដាល ដោយសារកត្តានយោបាយ និងដែនដី។

សូរសព្ទនៃភាសាខ្មែរបានផ្លាស់ប្ដូរ នៅក្នុងដំណាក់កាលនៃភាសាខ្មែរកណ្ដាល។ នៅចន្លោះសតវត្សទី១៦ ដល់ទី១៨ គេលែងអានព្យញ្ជនៈនៅខាងចុងពាក្យនីមួយៗ ដូចក្នុងភាសាខ្មែរបុរាណ ដែលអានពាក្យតាមលំនាំភាសាសំស្ក្រឹតដូចមុនទៀតហើយ (JENNER, 1976; JENKINS, 2014)។ យើងសង្កេតឃើញនូវការវិវត្តសូរបង្រ្កាបនេះទាំងព្យញ្ជនៈទាំងស្រៈ។

ខាងផ្នែកសូរសព្ទ ការអានពាក្យនៃភាសាខ្មែរកណ្ដាលមិនមានការបន្លឺសំឡេងនៃព្យាង្គចុងក្រោយ (voiced stops) ដូចនៅក្នុងភាសាខ្មែរចាស់ឡើយ។ ប្រការនេះ គឺជាការលេបព្យញ្ជនៈដែលនៅស្ថិតនៅខាងចុងពាក្យ (Devoicing of the Old Khmer voiced stops)។ ការបាត់បង់នៃសំឡេងព្យាង្គចុងក្រោយនេះនាំឱ្យមានការផ្លាស់ប្ដូរប្រព័ន្ធស្រៈ ដោយមានការបង្កើតស្រៈថ្មីៗ។

ការផ្លាស់ប្ដូរខាងសូរសព្ទនៃភាសាខ្មែរមួយទៀត គឺរបៀបអានព្យញ្ជនៈ «រ» នៅខាងចុងពាក្យ។ភាសាខ្មែរបុរាណ គេបន្លឺព្យញ្ជនៈ«រ» នៅខាងចុងពាក្យនេះយ៉ាងខ្លាំង ដូចភាសាសំស្ក្រឹត ឬភាសាខ្មែរ «សុរិន្ទ» ដូច្នេះដែរ។ តែភាសាខ្មែរទំនើប គេមិនបន្លឺ ឬគេលេបព្យញ្ជនៈ «រ» ដែលស្ថិតនៅខាងចុងពាក្យ។

សំឡេងនៃភាសាខ្មែរកណ្ដាលនៅសតវត្សទី១៦មានលក្ខណៈស្រដៀងភាសាខ្មែរចាស់។ នៅក្នុងភាសាខ្មែរចាស់ គេឃើញមានការបន្លឺសំឡេងនៃព្យាង្គចុងក្រោយនៃពាក្យ (voiced stops)។

ខ្មែរចាស់	ខ្មែរកណ្ដាល	ខ្មែរទំនើប
ខេ		ខែ
ថ្ម		ថ្ម

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្វេ		ធ្វើ
ឆ្នាំ		ឆ្នាំប
ស្វា		ស្វា
អំលូ		ម្លូ
លេ		លើ
ចារ		ចារ
ឈេ		ឈើ

ប្រភព៖ LEWITZ SAVAROS (1971)

ពាក្យខ្មែរបុរាណ «គិ (gi)» បានក្លាយទៅជាខ្មែរទំនើប «គឺ» ហើយ ពាក្យខ្មែរបុរាណ «គុ (gu)» បានក្លាយទៅជាខ្មែរទំនើប «គូ»។

ការផ្លាស់ប្តូរសំឡេងនេះអាចបញ្ជាក់បាន តាមរយៈការប្រៀបធៀបនៃអក្ខរាវិរុទ្ធនៅក្នុងសិលាចារឹកអង្គរវត្ត និងអក្ខរាវិរុទ្ធនៃភាសាខ្មែរទំនើប។

ខ្មែរកណ្តាល	ខ្មែរទំនើប	ការអាន
កន្តោរ	កណ្តុរ	កន់ដុល
ប្រាំពិរ	ប្រាំពីរ	ប្រាំពីរ ប្រាំពិល

ស្រៈនៃភាសាខ្មែរបុរាណនៅបន្តប្រើប្រាស់ក្នុងភាសាខ្មែរកណ្តាល ក៏ប៉ុន្តែគេឃើញមានការលេចឡើងនូវការប្រើប្រាស់ស្រៈថ្មីៗថែមទៀត ដោយសារការផ្លាស់ប្តូរសំឡេង ដូចជាពី «កេត» ទៅ «កើត» ដែលជាការគួបផ្សំរវាងស្រៈពីរ ដើម្បីបង្កើតស្រៈថ្មី និងការកាត់បន្ថយការបញ្ចេញសំឡេងនៅចុងពាក្យ។ ម្យ៉ាងវិញទៀត នៅក្នុងភាសាខ្មែរកណ្តាល គេឃើញបាត់នូវការអានព្យាង្គ «រ» ចុងពាក្យ និងការបញ្ចូលព្យាង្គចុងក្រោយ «ស» និង «ហ»

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាមួយគ្នា។ ភាសាខ្មែរកណ្តាលវិវត្តទៅជាភាសាខ្មែរទំនើបចំនួនបីប្រភេទ៖ (១) ភាសាខ្មែរខាងជើង (នៅប្រទេសថៃ) (២) ភាសាខ្មែរខាងលិច (តំបន់ភ្នំក្រវាញ) និង(៣) ភាសាខ្មែរកណ្តាល។ ការវិវត្តនៃការប្រើប្រាស់ស្រៈមានដូចតទៅ៖

១) នៅពាក់កណ្តាលសតវត្សទី១៦ ស្រៈ«អុំ» សរសេរដោយប្រើជើង «ុ»៖

IMA-3	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ពុំនាក្ក៍	ពុំនាក់

២) នៅចុងសតវត្សទី១៦ សំឡេង «អី» សរសេរដោយយកស្រៈ «ិ» និងជើងយ «្យ» ផ្សំគ្នា ឧ. ត្យិង (ដីង) (IMA-5)។

IMA-5	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ត្យិង	ដីង

៣) នៅចុងសតវត្សទី១៦ សំឡេង «អី» សរសេរដោយយកស្រៈ «ិ» និងព្យញ្ជនៈ «យ» ផ្សំគ្នា ឧ. ក្តិយ (ក្តី)៖ ស្រៈ «អី» សរសេរដោយ «ិ+យ»៖

IMA-5	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ក្តិយ	ក្តី
	ទោះកូនអញឯងក្តិយ	

៤) សំឡេង «អៀ» សរសេរជា «អ្យា» ដូចពាក្យ ទ្យាន (ទៀន) ទៀត ហើយ បែរមកសរសេរជា អៀ វិញដូចជា បៀតបៀន រៀង...។

IMA-6	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ប្យេតប្យេន	បៀតបៀន

៥) សំឡេង «អួ» សរសេរដោយយកអឌ្ឍស្រៈ «រ» និងស្រៈ «អូ» ផ្សំគ្នា ឧ.រ្វូច ឬរ្វួច (រួច)។

ចុងសតវត្សទី១៧ (IMA-30)

IMA-30	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ម្យ	មួយ

៦) ពាក់កណ្ដាលសតវត្សទី ១៦ យើងមានស្រៈ «អែ» ថែមមួយទៀត ដោយពីមុនសរសេរជា កម្រតេង លេង (កម្រតែង លែង)។

	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
IMA-3	នែះគិ	នេះគឺ
IMA-30	កែវ	កែវ
IMA-35	សំតែច	សម្ដេច
IMA-35	ត្រីចៅតូនបែន	ស្រីចៅតូនបែន

សតវត្សទី១៧

នៅឆ្នាំ១៦៣២ ទើបយើងមានស្រៈ «អឺ» (គឺ)

IMA	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
IMA-3	 IMA-17	នេះគិ > នេះគឺ

រហូតមកដល់ចុងសតវត្សទី១៧ នៅរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ ភាសាខ្មែរបានលូតលាស់ឡើងវិញ ដោយមានការកែទម្រង់ខាងផ្នែកភាសា។

នៅចុងសតវត្សទី១៧ និងដើមសតវត្សទី១៨ មានការផ្លាស់ប្ដូរខាង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្នែកសូរសព្ទ ដែលឈានទៅដល់ការលេចឡើងនូវភាសាខ្មែរទំនើប។ លក្ខណៈពិសេសមួយនៃភាសាខ្មែរកណ្ដាល គឺការលែងបន្ទឺសំឡេងនៃព្យាង្គចុងក្រោយនៃពាក្យ ការបន្តប្រើស្រៈដែលមាននៅក្នុងភាសាខ្មែរចាស់ និងការកើតឡើងនូវស្រៈថ្មី នៅចុងដំណាក់កាលខ្មែរកណ្ដាល ដោយសារការច្របាច់សំឡេងពីរបញ្ចូលគ្នា (diphthongization) នៅក្នុងព្យាង្គតែមួយ៖

១) នៅចុងសតវត្សទី ១៧ យើងមានស្រៈ «អី» ថែមមួយទៀត៖

IMA-30	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ស្វាមី	ស្វាមី
	សាក្សីសក្ខី	សាក្សីសក្ខី

ការបន្ទឺសំឡេងផ្លូវពី ស្រៈ «អិ» ទៅ ស្រៈ«អី» ឧទាហរណ៍៖

IMA-30	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
IMA-9	IMA-30	សតិវិញ្ញាណ> សក្ខីវិញ្ញាណ
IMA-36	IMA-37	ប្រាំបិ្យ> ប្រាំម្បី

២) ស្រៈ «អើ» ការបន្ទឺសំឡេងផ្លូវពី «កេត» ទៅ «កើត» ឧទាហរណ៍ «បង្កើត»

ពីស្រៈ «េ»	ទៅស្រៈ «ើ»	ខ្មែរទំនើប
IMA-4	IMA-36	កេត > បង្កើត

ការបង្កើតស្រៈ «អួ» ហើយការបន្ទឺសំឡេងផ្លូវពី «ក្ទូយ» ទៅ «ក្ទួយ» (IMA-37) និងពី «បូស» ទៅ «បួស»។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីស្រៈ «អូ»	ទៅស្រៈ «អួ»	ខ្មែរទំនើប
IMA-8	IMA-39	ត្រូវ > ត្រួ
 IMA-8	IMA-37	ក្មួយកូន > កូនក្មួយ
IMA-12	IMA-37	បូន > បួន
IMA-6	IMA-37	បូស > បួស្ស

លក្ខណៈពិសេសនៃការប្រើស្រៈក្នុងភាសាខ្មែរកណ្ដាលមានដូចតទៅ៖

១) ការប្រើប្រាស់«ហេ» ប្រើជំនួសស្រៈ «អើ» បំរេហ= បំរើ

ភាសាខ្មែរកណ្ដាល	ភាសាខ្មែរទំនើប
បំរេហ	បំរើ

២) ការប្រើប្រាស់«ូ» ប្រើជំនួសស្រៈ «ួ» មូយ = មួយ

ភាសាខ្មែរកណ្ដាល	ភាសាខ្មែរទំនើប
មូយ	មួយ
បូស (IMA-3)	បួស

៣) ការបង្កើតស្រៈ«ួ» នៅចុងសតវត្សទី១៧ និងដើមសតវត្សទី១៨

IMA-32 (1687)	IMA-37 (1701)	ខ្មែរទំនើប
បំបូស	បំម្បួស	បំបួស
 IMA-18 (1633) ក្មូយ	IMA-37 (1701) ក្មួយ	ក្មួយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣) ការប្រើប្រាស់«េ ្យ» ប្រើជំនួសស្រៈ «ៀ» និងការបង្កើតស្រៈ «ៀ» នៅចុងសតវត្សទី១៧

IMA-2	IMA-27	ខ្មែរទំនើប
		ពុំទៀង
ពុំទ្យេង	ពុំទៀង	

ស្រៈ «ៅ»

IMA-2	IMA-17 (1632)	IMA-37 (1701)
ទោ	ទោវ	ទៅ

ស្រៈ «ើ»

IMA-36	ខ្មែរទំនើប
	បង្កើត

ការផ្លាស់ប្តូរសំឡេងនៅចុងដំណាក់កាលខ្មែរកណ្តាលបានបង្កើតនូវព្យញ្ជនៈ «ឃោសៈ» (high register) ដែលបន្សល់ទុកពីភាសាខ្មែរចាស់ និង «អឃោសៈ» (low register) ដែលជាការវិវត្តនៃការផ្លាស់ប្តូរសំឡេងនៅក្នុងភាសាខ្មែរកណ្តាល និងការប្រើប្រាស់ស្រៈទៅលើព្យញ្ជនៈឃោសៈ និងព្យញ្ជនៈអឃោសៈ ហើយបង្កើតបានជាប្រព័ន្ធសំឡេងថ្មី មានលក្ខណៈសម្បូណ៌បែបជាងមុន។ ដំណើរការផ្លាស់ប្តូរសូរសព្ទនេះកើតឡើងនៅចន្លោះសតវត្សទី១៦ និងសតវត្សទី១៨។

ពីស្រៈ «អិ»	ទៅស្រៈ «អេ»	ខ្មែរទំនើប
IMA-8	IMA-37	ចិញ > ចេិញ

៤) មកដល់ឆ្នាំ១៧០១ ទើបយើងមានស្រៈ «អឺ» (តឺ) អួ (ជួយ) អើ (កើត) អឿ (គ្រឿង) អៀ (តេះដៀល)

ប៉ុន្តែស្រៈថ្មីទាំងនេះជួនកាលក៏ប្រើ ជួនកាលក៏នៅសរសេរបែបពីដើម ដូចជា តិ (តឺ) ព្រូយ (ព្រួយ)

បើកេត (បើកើត) ...។

៥) ការប្រើស្រៈ និងព្យញ្ជនៈ

ការប្រើប្រាស់ស្រៈ មិនមានសង្គតភាពឡើយ។

ខ្មែរកណ្តាល	ខ្មែរទំនើប
១. ការប្រើប្រាស់ស្រៈ	
ស្រៈ«អោ»	ស្រៈ«អ»
មោក	មក
ផោង	ផង
ស្រៈ«ុំម»	ស្រៈ«ុំ»
ខ្ញុំម	ខ្ញុំ
ស្រៈ« េិ »	ស្រៈ « ើ »
លេិក	លើក
២. ការប្រើព្យញ្ជនៈ	
តោ្យ, តោយ្យ	ដោយ
ថ្វ្យ	ថ្វាយ
ទិពារ	ទិវា

៣. ការប្រើវណ្ណយុត្តិ
មូសិកទន្ត ៖ នៅពេលដែលគេប្រើមូសិកទន្តនៅក្រោមព្យញ្ជនៈ មានន័យថា ព្យញ្ជនៈនោះគឺជាស្រៈ

ឧទាហរណ៍ ពាក្យដោយ ជួនកាលសរសេរ ដោ្យ ជួនកាលសរសេរ ដោយ្យ។ (១- ដោ្យសាថ្នាំអតិរេក តែពេលខ្លះ ដោយ្យគាថាព្រះបាឡី)។

ស្រៈ «អុ» ច្រើនសរសេរជាមួយស្រៈ «ា» ដូចជាពាក្យមកសរសេរ ជា មោក ពាក្យ ផង សរសេរ ជា ផោង។

ស្រៈ «អិ» សរសេរជា «េ ិ» ដូចជាពាក្យសិល្បសាស្ត្រ សរសេរជា សេិលសាស ពាក្យ តិច សរសេរជា តេិច។

ស្រៈ«អី» ពេលខ្លះសរសេរដោយប្រើស្រៈផ្សំ «ៀ» ដូចជាពាក្យស្រដី សរសេរជាស្រតិ ពាក្យពីដើម សរសេរជា ព្យិតេិម្ម។

ស្រៈ«អឹ» សរសេរជាស្រៈ«ិ» តែពេលខ្លះប្រើជើង«្យ»។ ឧទាហរណ៍ពាក្យ សឹង ចូលសរសេរជា សិងចូល ដឹង សរសេរជា ត្យង។

ស្រៈ «អឺ» សរសេរជា «ឺ» តែខ្លះជា «ិ»។ ដូចជា ហ៊ឺន សរសេរជា ហ៊ឺណ ហើយ ពាក្យ គឺបី សរសេរជាគិបិ។

ស្រៈ «អួ» សរសេរដោយយកជើងព្យញ្ជនៈ «វ» ជំនួស ឬសរសេរទឹង ស្រៈ «អូ» ដូចជាពាក្យ រួចសរសេរជា រ្វច ហើយពាក្យ មួយ សរសេរជា ម្យូ។

ស្រៈ «អើ» ជួនកាលសរសេរ «េ ិ» តែជួនកាលសរសេរស្រៈ « េ ី»។ ឧទាហរណ៍ពាក្យ លើក សរសេរជា លេិក ហើយពាក្យច្រើន សរសេរជាច្រេិន។

ស្រៈ «អឿ» មានសរសេរជាស្រៈ «អៀ» តែពេលខ្លះ ក្បឿងសរសេរជា ក្បៀង។

ស្រៈ «អេ» សរសេរដោយប្រើស្រៈ «ិ» ដូចជាពាក្យ ចេញ សរសេរជា ចិញ ហើយពាក្យ ចេក សរសេរជា ចិក។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការប្រើ

ដូចជាពាក្យ ជាចុងស្ស = ចារចង (ស្រៈអ) តែពេលខ្លះគឺជាស្រៈ«អា»។ ឧទាហរណ៍ ពុំនួក = ពំនាក់។

សំយោគសញ្ញាមានន័យពីរយ៉ាង គឺ៖

១ ជំនួសព្យញ្ជនៈ «ង» ឧទាហរណ៍ ស័យ = សង្ស្យ។

២ ជំនួសបន្តក់ ឧទាហរណ៍ តាក័ = ដាក់។ គ្រប្ប័ = គ្រប់។

តាមរយៈការសិក្សា «សិលាចារឹកនគរវត្ត» គេបានសង្កេតឃើញនូវការវិវត្តនៃអក្ខរាវិរុទ្ធខ្មែរនៅសតវត្សទី១៦ ១៧ និងទី១៨ (Ménétrier, 1933)។ អក្សរដែលប្រើក្នុង«សិលាចារឹកនគរវត្ត»វិវត្តនៅចន្លោះអក្សរ«ខ្មែរបុរាណ» និងអក្សរ «ខ្មែរទំនើប» ដូចខាងក្រោម (ព្រះមហាពិទូរ ក្រសេម, 1984)៖

ទីមួយ-ដោយសារការប្រើស្រៈ៖ ដូចជា ស្រៈ «អី អឺ» មិនទាន់មានប្រើក្នុងសិលាចារឹកដំបូងៗនៅឡើយទេ លុះមកដល់សិលាចារឹកលេខ១៧ ទើបមានប្រើ។ ចំណែកស្រៈ «អួ» វិញ គេប្រើជើង វ «ុ» ជំនួស។ ស្រៈ «អែ» ក៏មិនឃើញមានប្រើដែរ គេប្រើតែស្រៈ «អេ» ដូចពាក្យ«កើត» គេសរសេរជា «កេត», «លើក» ជា «លេក», «ច្រើន» ជា «ច្រេន»។ល។ លុះមកដល់សិលាចារឹកលេខ១៣ បន្ទាត់៨ ក្នុងគ.ស.១៦៣០ ទើបឃើញមានប្រើ។

ក្នុងសិលាចារឹកលេខ១០ ស្រៈ«បើ» គេសរសេរជា «ប្អេហ» ដូចភាសាសៀមដែរ។ តែមកដល់សិលាចារឹកលេខ២៧ គេសរសេរស្រដៀងសព្វថ្ងៃ តែដោយប្រើមូសិកទន្តពីក្រោម ដោយសរសេរ «លើក» ជា «ល្មើក»។

ទីពីរ-ការប្រើវិធីប្រើអក្សរប្រកប៖ ស្រៈ«អៀ» បុរាណគេប្រើជាពីរយ៉ាង គឺ៖ (១) គេប្រើស្រៈ «អែ» ដូចពាក្យ «ស្បៀក» គេសរសេរ «ស្បែក» (សិលាចារឹកលេខ១០បន្ទាត់១៨), «ទៀង» សរសេរជា «ទែង» (សិលាចារឹកលេខ១៩), «ទៀត» សរសេរជា «ទែត» (សិលាចារឹកលេខ២៤បន្ទាត់៣៣), និង (២) ប្រើស្រៈ «អេ» និង ជើង «្យ» ផ្សំគ្នា ដូចពាក្យ «រៀន» សរសេរជា «រេ្យន», ហើយ «បៀតបៀន» សរសេរជា «បេ្យតបេ្យន»។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្រៈ «ឹ» អាចសរសេរដោយប្រើជើង «្រ» មកជំនួស ដូចជាពាក្យ «សិង» សរសេរជា «ស្រង», «ដិង» សរសេរជា «ត្រង», និង «ពឹរ» សរសេរជា «ព្យរ»។

ទីបី-ដោយសារការប្រើពាក្យប្រកបដោយសញ្ញាៈ ពាក្យដែលគ្មានតួសង្កត់ដូចជាពាក្យ «ថ្ម» គេសរសេរជា «ថ្មំ», «ក» សរសេរជា «កំ», «ត» សរសេរជា «តំ», «សំណា» សរសេរជា «សំទំ», ហើយ «ព» សរសេរជា «ព្ជំ» ជាដើម។

វណ្ណយុត្តិ «៉» ដែលជាមូសិកទន្ត (ធ្មេញកណ្ដុរ) ភាសាខ្មែរកណ្ដាលប្រើស្រៈ «អ» តែពេលក្រោយមក ក៏ស្រាប់តែលុបចោលការគូសកណ្ដាលហើយនៅតែ «៉» ដូចជាពាក្យ «ចៅន្នក», «ប្អេហ», «ឈ្អេហ» ដែលក្រោយមកសរសេរជា «ចៅន្នក», «ប្អេហ», «ឈ្អេហ»។

វណ្ណយុត្តិ «់» ដែលជាសំយោគសញ្ញា ប្រើបានពីរយ៉ាងគឺ ៖ (១) ប្រើជំនួសព្យញ្ជនៈ «ង» ដែលសង្កត់តែម្ដង ដូចជាពាក្យ «សង្វរ» គេសរសេរជា «ស័រ», «សង្ឃ» សរសេរជា «ស័យ», «ទាំង» សរសេរជា «ទាំ», «អង្គ» សរសេរជា «អ័», «អានិសង្ស» សរសេរជា «អានិស័», ហើយ «ហោង» សរសេរជា «ហោ័» ជាដើម និង (២) ប្រើកាត់សំឡេងវែង ឱ្យទៅជាខ្លី ដូចជាពាក្យ «ស័ក», «ប្រនិប័ត», «ន័ក», «ច័ន្ទ្រ», «ស្ព័ល», និង «ប្រ័ក» ជាដើម។

២) ស្រៈ «អឺ» កើតក្រោយគេបង្អស់ តែមិនប្រាកដថាកើតនៅរជ្ជកាលណាទេ។ ក្នុងសម័យអង្គរយើងឃើញមានប្រើនិគ្គហិតដាក់ពីលើស្រៈ «អិ» មួយគ្រាដែរ តែឱ្យអានទៅតាមសំស្ក្រឹតគឺ និគ្គហិតបញ្ចេញសំឡេងដូចខ្យល់ ម ដូចពាក្យថា ថ្មី ដែលមានក្នុងសិលាចារឹកប្រាសាទកំពីស (K.668 គ.ស.៩៧២)។ ពាក្យ ថ្មី នេះត្រូវនឹងពាក្យខ្មែរបច្ចុប្បន្ន ធ្មឹម ក្នុងធ្មឹមអំពរ។

និគ្គហិតក្នុងសម័យបុរាណមានការប្រើច្រើនយ៉ាងជាងសព្វថ្ងៃ។ ឯសំឡេងដូចខ្យល់ ម ទាំងអស់ក្រៅពីដាក់លើស្រៈ៖

«អ» ជា «អំ» (សំល = សម្ល)

«អា» ជា «អាំ» (ប្រាំ)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«អុ» ជា «អុំ» (ខ្ញុំ)
ដូចក្នុងសម័យបច្ចុប្បន្ននេះ នៅមានដាក់លើស
«អិ» (ថ្មី = ធ្មិម) **«អេ» (តេំ =ដើម)

៥.១៣. ការវិវត្តនៃភាសាខ្មែរកណ្ដាលនៅសតវត្សទី១៦

តាមរយៈការសិក្សាសិលាចារឹកខាងលើ យើងឃើញពីការវិវត្តភាសាខ្មែរដូចខាងក្រោម៖

ការប្រើស្រះ:

ស្រៈ «អឹ»

IMA-5	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ត្បង	ដឹង

ស្រៈ «អី»

IMA-5	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ក្តិយ	ក្តី

ស្រៈ «អី»

IMA-3	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ព្យិរ	ពីរ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្រៈ «អួ»

IMA-2	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ប្យស	បួស

ស្រៈ «អើ»

IMA-2	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ត្រេយ	ត្រើយ
	កម្រតេងយេង	កម្រតេងយើង

ស្រៈ «អៀ»

IMA-2	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	ទ្យេង	ទៀង

វណ្ណយុត្តិ «់»

IMA	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
IMA-2	ក់សាង	កសាង
IMA-3	ថ្ម់ថ	ថ្ម

សិលាចារឹកលេខ ៣ (ស.ក. ១៥០១-គ.ស.១៥៧៩) ចារក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី១។

ខ្មែរកណ្ដាល	ខ្មែរទំនើប
ឡេង = ឡើង ចំរេន = ចំរើន អន្ទេ = អន្ទើ	ស្រៈ «េ» ប្រើជំនួស ស្រៈ «ើ»

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សោរពារ	ថ្ងៃសៅរ៍ = ស្រៈ «េា» ប្រើជំនួស ស្រៈ «ៅ»
លក្ខា	លក្ខណា= ព្យញ្ជនៈ «ន» ប្រើជំនួស «ណ»
គំរប្ប	គំរប់ ជើង «្ប» ប្រើជំនួស « ់ »
រិួចដល់	រួចដល់ ស្រៈ «ួ» ប្រើជំនួស ស្រៈ «ួ»
ជបនឥសហោង	ជាបង្គស់ហោង

សិលាចារឹកលេខ២

ការវិវត្តភាសា

ខ្មែរកណ្តាល	ការពន្យល់
កម្រតែង យេង	គម្តែងយើង ឬអម្ចាស់របស់យើង។ ស្រៈ «ើ» ទើបនឹងបង្កើតពេលក្រោយ។
រុ សំពៅ	រូ ជាពាក្យខ្មែរបុរាណ = បីដូចសំពៅ
មន តិ	មន តិ ជាពាក្យខ្មែរបុរាណ = នេះ គឺ
ស្រៈ «េ្យ»	ដូរទៅស្រៈ «ៀ»
ស្រៈ «េា»	ដូរទៅស្រៈ «ៅ»

៥.១៤. ព្យាង្គតម្រួត

ភាសាខ្មែរមានការផ្សំតួអក្សរតាមពីរបែបៈ (១) ព្យាង្គរាយ និង (២) ព្យាង្គតម្រួត។

ព្យាង្គតម្រួត

ព្យាង្គតម្រួត គឺជាវិធីសាស្ត្រនៃការសរសេរនៃពាក្យខ្មែរ ដែលត្រូវបាន

រក្សាទូវទម្រង់ផ្ទត់ដើមបង្កប់នៅក្នុងការសរសេរនោះ ដោយរបៀបសរសេរគឺ

ក្តៅ + [កម] -> កម្តៅ

ខ្ពស់ + [កម] -> កម្ពស់

ជ្រៅ + [ជម] -> ជម្រៅ

ប្រោស + [បម] -> បំម្រោស (IMA-8)

កម្ចីពាក្យពីភាសាសៀម

នៅសម័យអង្គរ ភាសាសៀមបានវិវត្តក្រោមឥទ្ធិពលនៃវប្បធម៌ខ្មែរ និងវប្បធម៌ឥណ្ឌាតាមរយៈវប្បធម៌ខ្មែរផងដែរ។ ក៏ប៉ុន្តែ នៅចុងសម័យកណ្តាល ដោយសារតែសង្គ្រាម អាណាចក្រខ្មែរបានបាត់បង់អស់នូវអ្នកប្រាជ្ញ និងវត្តអារាម ដែលជាកន្លែងសម្រាប់បណ្តុះធនធានមនុស្ស។ បញ្ញវន្ត និងព្រះសង្ឃខ្មែរត្រូវទៅរៀនសូត្រនៅតាមវត្តអារាមនៃប្រទេសថៃវិញ។ យ៉ាងហោចណាស់មានវណ្ណកម្មអក្សរសិល្ប៍ចំនួន ២ ដែលបង្ហាញពីឥទ្ធិពលសៀមមកលើភាសា និងអក្សរសិល្ប៍ខ្មែរ គឺរឿងហង្សយន្ត និងរឿងសព្វសិទ្ធិ (តែងដោយម៉ឺនភក្តី អញ្ចិត នៅឆ្នាំ១៨៩៩) ដែលជាអត្ថបទបកប្រែពីភាសាសៀម (ANTELME, 1996)។ តាមរយៈនេះហើយ ភាសាខ្មែរបានខ្ចីពាក្យពីភាសាសៀម។ កម្ចីនេះមានពីរផ្នែក៖

(១) កម្ចីពាក្យត្រឡប់មកវិញ (emprunts-retours) នូវពាក្យដែលសៀមខ្ចីពីភាសាខ្មែរចាស់នៅជំនាន់អង្គរ៖ (១) ប្រពាត (ประพาส)៖ មកពីពាក្យខ្មែរចាស់ ប្រពាស និងពាក្យសំស្ក្រឹត ប្រវាស (២) កំផែង (กำแพง)៖ មកពីពាក្យខ្មែរចាស់កំវេង (៣) តំបន់ (ตำบล)៖ មកពីពាក្យខ្មែរចាស់ តំបល (៤) ត្រួត (ตรวจ)៖ មកពីពាក្យខ្មែរចាស់ ត្រួច ។ល។

(២) កម្ចីពាក្យថ្មីពីភាសាសៀម៖ ដូចជាពាក្យ រយ, ពាន់, សែន ជាដើម។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជំពូកទី៦

ការវិវត្តភាសាខ្មែរក្នុងរយៈពេលបីសតវត្ស ភាសាខ្មែរកណ្ដាលមកភាសាខ្មែរទំនើប

៦.១. អាណាចក្រខ្មែរក្នុងដង្កៀបរវាងសៀម និងវៀតណាម

៦.១.១. ជម្លោះរវាងសៀម និងវៀតណាមដើម្បីឥទ្ធិពលលើកម្ពុជាក្នុងសតវត្សទី១៨

ជម្លោះរាជវង្សនៅបន្តយ៉ាងខ្លាំងក្លានៅក្នុងសតវត្សទី១៨ ដោយសារតែរាជវង្សានុវង្សមិនបានកំណត់ឱ្យបានច្បាស់លាស់នូវវិធាននិងរបៀបជ្រើសស្ដេចឡើងសោយរាជ្យសម្បត្តិ។ ប្រការនេះបង្កើតស្ថានភាពហែកហួរគ្នា និងជម្លោះក្នុងរាជវង្សខ្មែរ ដែលនាំឱ្យមានវិបត្តិរាជបល្ល័ង្ក អស្ថិរភាពនយោបាយ និងការបន្តបាត់បង់ទឹកដីទៅប្រទេសជិតខាង។ ម្យ៉ាងវិញទៀត ការប្រកួតប្រជែងរវាងសៀម និងវៀតណាម ដើម្បីអនុត្តរភាពលើកម្ពុជាបានធ្វើឱ្យមានអស្ថិរភាពនយោបាយ និងមានអរិភាពនៅក្នុងរាជវង្សានុវង្សយ៉ាងខ្លាំង។ វៀតណាមបានលូកដៃចូលកិច្ចការផ្ទៃក្នុងកម្ពុជាកាន់តែខ្លាំង ហើយសៀមនៅបន្តមានឥទ្ធិពលលើការតែងតាំងព្រះរាជានៅកម្ពុជា។

នៅឆ្នាំ១៧០០ ព្រះបាទជ័យជេដ្ឋាទី៣ បានដាក់រាជ្យសាជាថ្មីថ្វាយព្រះរាជបុត្រសុណិសាព្រះបាទកែវហ្វ៉ាទី៣ អង្គអិម (១៦៩៩-១៧០០) ដែលជាបុត្រអង្គទន់ គូប្រណាំងប្រជែងរបស់ព្រះអង្គ ដោយសង្កេតឃើញថា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្តេចអង្គនេះមានគុណសម្បត្តិក្នុងការប្រយុទ្ធជាមួយទ័ពវៀតណាម។ នៅពេលនោះ ព្រះបាទជ័យជេដ្ឋាទី៣ មានព្រះជន្មាយុត្រឹម៣៩ព្រះវស្សានៅឡើយ។ កំប៉ុន្តែដោយអង្គអិម គ្មានសមត្ថភាពគ្រប់គ្រងរដ្ឋ ព្រះបាទជ័យជេដ្ឋាទី៣ (១៧០០-១៧០៣) បានឡើងគ្រងរាជ្យសាជាថ្មី (រជ្ជកាលទី៣)។ ព្រះអង្គសោយរាជ្យបានតែមួយឆ្នាំប៉ុណ្ណោះ ក៏លើករាជ្យថ្វាយព្រះរាជបុត្រព្រះនាមព្រះបាទស្រីធម្មរាជាទី២ ឬជ័យជេដ្ឋាទី៤ (១៧០២-១៧០៣) និងជាចៅទួតរបស់ព្រះឧទ័យ ក្នុងព្រះជន្ម១២វស្សានៅក្នុងរជ្ជកាលទី១។ បន្ទាប់ពីសោយរាជ្យបានជាងមួយឆ្នាំរួចមក ព្រះបាទជ័យជេដ្ឋាទី៣ (១៧០៣-១៧០៦) បានឡើងគ្រងរាជ្យជាថ្មី (រជ្ជកាលទី៤) ដោយសារព្រះរាជបុត្រនៅក្មេងពេក។

នៅឆ្នាំ១៧០៧ បន្ទាប់ពីសោយរាជ្យបាន៣១ឆ្នាំរួចមក ព្រះបាទជ័យជេដ្ឋាទី៣ បានដាក់រាជ្យថ្វាយបុត្រ ព្រះបាទស្រីធម្មរាជាទី២ ឬជ័យជេដ្ឋាទី៤ (១៧០៦-១៧០៩) ដែលមានព្រះជន្ម១៧ព្រះវស្សា។ ការផ្លាស់ប្តូររាជ្យជាញឹកញាប់បង្ហាញពីអស្ថិរភាពនយោបាយក្នុងប្រទេស។ ជម្លោះផ្ទៃក្នុងក៏ចាប់ផ្តើមលេចឡើងផងដែរ ក្នុងព្រះរាជវង្សានុវង្ស។ ដោយសារតែជម្លោះផ្ទៃក្នុងរាជវង្សានុវង្ស នៅឆ្នាំ១៧០៧ ចិនឈ្មោះ ម៉ាក គីវ បានសម្តែងស្វាមីភ័ក្តិចំពោះស្តេចង្វៀង របស់វៀតណាមវិញ ហើយតំបន់ពាមទាំងមូលត្រូវបានបញ្ចូលក្នុងទឹកដីវៀតណាម។

នៅឆ្នាំ១៧០៩ សង្គ្រាមរវាងព្រះបាទធម្មរាជាទី៣ និងព្រះអង្គអិម បានផ្ទុះឡើង ដោយសារព្រះអង្គអិម មិនសប្បាយចិត្តនឹងជ័យជេដ្ឋាទី៣ ដែលដាក់រាជ្យថ្វាយបុត្រខ្លួន ហើយក៏បះបោរទៅសុំទ័ពវៀតណាមមកឡោមព័ទ្ធឧដុង្គ។ បន្ទាប់ពីចាញ់សង្គ្រាមព្រះបាទធម្មរាជាទី៣ បានភៀសព្រះកាយទៅប្រទេសសៀមជាមួយព្រះរាជបុត្រអង្គឥម និងបុត្រសុណិសាអង្គទងហើយសុំឱ្យសៀមជួយ។ ព្រះរាជពង្សាវតានៃអយុធ្យាបានសរសេរថា៖ «នៅឆ្នាំ១៧០៩អ្នកព្រះឥមបានភៀសខ្លួនមកពីកម្ពុជា បន្ទាប់ពីចាញ់សឹកសង្គ្រាម។ ព្រះចៅក្រុងស្រីអយុធ្យាបានចិត្តសណ្តោសប្រណីបញ្ជូនមន្ត្រីទៅទទួល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហើយសាងសង់ព្រះនិវាសនដ្ឋាននៅជិតវត្តសម្រាប់ព្រះអង្គ»។ ព្រះបាទធម្មរាជាទី៣ មានបុត្រ៣អង្គជាមួយអ្នកម្នាងសៀម (អង្គហ៊ីង អង្គឌួង អង្គសោភាក្សត្រី)។

ដោយបានជួយវាយទ័ពសៀមនៅកម្ពុជាវៀតណាមបានបន្តវាតទី និងកាន់កាប់ខេត្តជាច្រើននៅដើមសតវត្សទី១៨។ ប្រទេសវៀតណាមបន្តនយោបាយ «ដំណើរឆ្ពោះទៅទិសខាងត្បូង» ដែលចាប់ផ្តើមនៅក្នុងរាជ្យព្រះបាទជ័យជេដ្ឋាទី២ ដែលឡើងសោយរាជ្យនៅដើមសតវត្សទី១៧ នៅដើមសម័យឧដុង្គ ដែលជាស្តេចចង់ងាកចេញពីសៀមមករកវៀតណាមជួយ។ បន្ទាប់ពីលេបយកចម្ប៉ាអស់ក្នុងឆ្នាំ១៧២០ វៀតណាមចាប់ផ្តើមធ្វើដំណើរឆ្ពោះទៅទិសខាងត្បូង ដើម្បីកាន់កាប់ដំបន់កូសាំងស៊ីន ឬកម្ពុជាក្រោម៖

• នៅឆ្នាំ១៦៩៨៖ ខេត្តបារៀ (បារាយ) បៀងហ្វា និងយ៉ាឌិញ (ព្រៃនគរ) បានទៅវៀតណាម

• នៅឆ្នាំ១៧៣៣៖ ខេត្តវិញឡុង (លង់ហោរ) និងមិថរ (មេ-ស) បានទៅវៀតណាម

• នៅឆ្នាំ១៧៥៨-១៧៧៥៖ ខេត្តស្រុកទ្រាំង (ស្រុកឃ្លាំង) ត្រាវិញ (ព្រះត្រពាំង) សាដែក (ផ្សារដែក) គូឡៅយ៉ាង (កោះតែង) និងចូដុក (មាត់ជ្រូក) បានទៅវៀតណាម។

នៅឆ្នាំ១៧១២ ព្រះអង្គអិម ដែលជាបុត្រអង្គនន់ និងជាចៅឧទ័យបានឡើងសោយរាជ្យសម្បត្តិ ដោយមានព្រះនាមព្រះបាទកែវហ្វ៉ាទី៣ (១៧១០-១៧២២)។ ជម្លោះមិនត្រឹមតែមានរវាងរាជវង្សានុវង្សទេ ក៏ប៉ុន្តែ គឺជាជម្លោះរវាងសៀម និងវៀតណាមដើម្បីមានឥទ្ធិពលមកលើកម្ពុជា និងដើម្បីវាតទីយកទឹកដីកម្ពុជាផងដែរ។ តាមព្រះរាជពង្សាវតារនៃអយុធ្យាបានឱ្យដឹងថា នៅឆ្នាំ១៧១៥ ព្រះចៅក្រុងអយុធ្យាបានបញ្ជូនកងទ័ពជើងគោក និងជើងទឹកមកវាយកងទ័ពវៀតណាមនៅកម្ពុជា។ ទ័ពសៀមនាំព្រះបាទធម្មរាជាទី៣ និងអង្គទង មកច្បាំងផងដែរ។ ក៏ប៉ុន្តែកងទ័ពជើងទឹកត្រូវបានមេទ័ពចិន

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ម៉ាក គីវ វាយបង្រ្កាបបាន។ កង់ទ័ពជើងគោកវាយចូលខិតជិតឧដុង្គ។ ព្រះបាទកែវហ្វ៊ាទី៣ អង្គអិម បានចរចាជាមួយទ័ពសៀម ដោយសុខចិត្តថ្វាយស្លួយសារអាករឱ្យទៅសៀម ក្នុងលក្ខខណ្ឌដែលរាជវង្សទាំងបីព្រះអង្គត្រូវតែបន្តគង់ប្រថាប់នៅអយុធ្យា។

ចាប់ពីពេលនោះមក កម្ពុជាមានសន្តិភាពមួយរយៈ ហើយនៅឆ្នាំ ១៧២២ ព្រះបាទកែវហ្វ៊ាទី៣ បានដាក់រាជ្យថ្វាយបុត្រព្រះអង្គ ព្រះនាមព្រះបាទសត្ថាទី២ អង្គជី (១៧២២-១៧៣៧)។ ជម្លោះផ្ទៃក្នុងរាជវង្សនៅតែបន្តរវាងព្រះបាទកែវហ្វ៊ាទី៣ និងព្រះបាទសត្ថាទី២ អង្គជី ជាមួយសមាជិករាជវង្សនៃស្តេចដែលភៀសព្រះកាយទៅរស់នៅស្រុកសៀម។ នៅឆ្នាំ១៧៣៨ ជម្លោះរវាងព្រះបាទសត្ថាទី២ និងអគ្គមហេសីព្រះអង្គ សម្តេចព្រះស្រីសុជាតានិងស្តេចបីព្រះអង្គដែលគាំទ្រដោយស្តេចខ្មែរយាងមកពីសៀមបានផ្ទុះឡើង។ ព្រះបាទសត្ថាទី២បានភៀសព្រះកាយទៅប្រទេសវៀតណាម ហើយក្សត្រទាំងអស់បានព្រមព្រៀងលើករាជ្យសម្បត្តិថ្វាយទៅព្រះបាទធម្មរាជាទី៣ ដែលភៀសព្រះកាយទៅនៅស្រុកសៀមតាំងតែពីឆ្នាំ១៧០៩។

ព្រះបាទធម្មរាជាទី៣(ជ័យជេដ្ឋាទី៤)បានឡើងសោយរាជ្យសម្បត្តិឡើងវិញនៅឆ្នាំ១៧៣៨ ជាលើកទី៣ (១៧៣៨-១៧៤៧) គាំទ្រដោយក្រុងស្រីអយុធ្យា។ ចំណែកឯព្រះអង្គទង ដែលជាអនុជ (បុត្រព្រះបាទជ័យជេដ្ឋាទី៣) ក៏បានត្រលប់មកពីក្រុងស្រីអយុធ្យាវិញ និងត្រូវបានតែងតាំងជាមហាឧភយោរាជ។ ព្រះបាទធម្មរាជាទី៣ ដែលស្ថិតក្រោមឥទ្ធិពលសៀមដោយសារធ្លាប់នៅស្រីអយុធ្យាចំនួន២០ឆ្នាំ បានអនុវត្តគោលនយោបាយតុល្យភាពជាមួយវៀតណាមដើម្បីធានាសន្តិភាព។ ចំណែកឯព្រះបាទសត្ថាទី២ អង្គជីបន្តរស់នៅប្រទេសវៀតណាម។ ព្រះបាទធម្មរាជាទី៣ សោយរាជ្យបាន១០ឆ្នាំក៏សុគតទៅ។ បុត្រច្បងរបស់ព្រះអង្គ អង្គឥមឡើង សោយរាជ្យព្រះនាមព្រះបាទធម្មរាជាទី៤ឡើងស្នងរាជ្យពីព្រះបិតា។ មិនបានប៉ុន្មានខែផង ក៏ត្រូវព្រះអនុជដែលប្រសូតនៅសៀមអង្គហ៊ីងធ្វើគុត។ បុត្រសុណិសា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃព្រះបាទធម្មរាជាទី៣ អង្គទង ក៏ឡើងគ្រងរាជ្យសម្បត្តិបន្ត មានព្រះនាម ព្រះបាទរាមាធិបតីទី៣ អង្គទង (១៧៤៧-១៧៤៨)។

ដោយសង្កេតឃើញស្ថានភាពវឹកវរនៅកម្ពុជានៅឆ្នាំ១៧៤៨ ព្រះចៅក្រុងវៀបានបញ្ជូនកងទ័ពមកវាយកម្ពុជា ដោយនាំព្រះសត្ថាទី២ អង្គជីមកជាមួយផង។ ព្រះបាទធម្មរាជាទី៣ អង្គទង ព្រះឧបរាជ និងព្រះអង្គស្ងួនបានភៀសខ្លួនទៅក្រុងស្រីអយុធ្យា។ ព្រះបាទសត្ថាទី២ សោយរាជ្យបានតែមួយឆ្នាំប៉ុណ្ណោះ ហើយត្រូវឧកញ៉ាក្រឡាហោម ឱក ងើបឡើងបះបោរផ្តួលរំលំព្រះរាជា។ បន្ទាប់ពីចាញ់សង្គ្រាមព្រះបាទសត្ថាទី២ រត់ទៅរស់នៅវៀតណាមវិញ តែទ្រង់អាពាធហើយសុគតតាមផ្លូវ។

បន្ទាប់ពីស្រុកមានសន្តិភាពបរិបូណ៌ សេនាបតីបានទៅក្រុងស្រីអយុធ្យាដើម្បីយាងព្រះរាជវង្សានុវង្សត្រឡប់មកស្រុកវិញ។ ព្រះអង្គស្ងួន ជាបុត្រព្រះបាទធម្មរាជាទី៣ បានឡើងសោយរាជ្យសម្បត្តិនៅឧដុង្គ ដោយមានព្រះនាមព្រះបាទស្រីជ័យជេដ្ឋទី៣ (១៧៤៩-១៧៥៥)។ នៅឆ្នាំ១៧៥១ ព្រះចៅសៀមទ្រង់សព្វព្រះទ័យឱ្យរាជវង្សានុវង្ស ដែលភៀសព្រះកាយទៅនៅក្រុងស្រីអយុធ្យាត្រលប់មកវិញ។ ព្រះបាទស្រីជ័យជេដ្ឋទី៣ មានបុត្រពីរព្រះអង្គ៖ អង្គនន្ទ និងអង្គជី។

៦.១.២. ការបើកសករាជថ្មីនៃភាសាខ្មែរទំនើប

ការសិក្សា «សិលាចារឹកនគរវត្ត» ទី៣៩ (IMA-39) បង្ហាញឱ្យឃើញថា ភាសាខ្មែរមានការវិវត្តលឿនចាប់ពីពាក់កណ្តាលសតវត្សទី១៨មក ហើយឈានចូលដំណាក់កាលថ្មីមួយទៀត ដែលយើងអាចហៅថា ដំណាក់កាលនៃ «ភាសាខ្មែរទំនើប»។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិលាចារឹកលេខ៣៩ (ស.ក.១៦៦៩-គ.ស. ១៧៤៧ ក្នុងរជ្ជកាលព្រះបាទធម្មរាជាទី៣ ដែលជាបុត្រព្រះបាទជ័យជេដ្ឋាទី៣ និងជាចៅទួតរបស់ព្រះបាទឧទ័យ។ សិលាចារឹកចាប់ផ្ដើមពីធម៌នមស្សការជាភាសាបាលី «សព្វមស្តុសួស្ដីស្រីសព្វមង្គលពហុលចេស្តាជៃយ្យាតិរេក»។ នៅថ្ងៃព្រហស្បតិ៍ទី១៣កើត ខែមិគសិរ ឆ្នាំថោះ មហាសករាជឆ្នាំ១៦៦៩ត្រូវនឹងគ.ស.ឆ្នាំ១៧៤៧ មានការជំនុំនៃសម្ដេចព្រះសុមង្គលមហាសង្ឃរាជបពិត្រ និងសម្ដេចព្រះសុមង្គលមហាសង្ឃរាជបពិត្រ សម្ដេចព្រះគ្រូ ភិក្ខុថេរ និងសមណេរជាច្រើនជាប្រធានថ្ងៃនៃអ្នកឧកញ៉ាវង្សាអគ្គរាជ និងលោកជំទាវស្រីរត្នកេសរ ដែលមានសទ្ធាជ្រះថ្លា មកធ្វើបុណ្យដាក់ទាន និមន្តព្រះសង្ឃ បង្សុកូលនៅលើព្រះពាន់នៃប្រាសាទអង្គរវត្ត។

កាលអ្នកឧកញ៉ាវង្សាអគ្គរាជ នៅជាចៅពញាមន្ត្រីសង្គ្រាមនៅឡើយព្រះរាជា (ព្រះបាទធម្មរាជាទី៣ ឬជ័យជេដ្ឋាទី៤ ឡើងសោយរាជ្យសម្បត្តិឡើងវិញនៅឆ្នាំ១៧៣៨ ជាលើកទី៣ (១៧៣៨-១៧៤៧) គាំទ្រដោយក្រុងស្រីអយុធ្យា) ទ្រង់យាងមកពីក្រុងទេពមហានគរ (ទីក្រុងបាងកក) មកដល់ស្រុកចន្ទបុរី ទើបព្រះអង្គទ្រង់ប្រើចៅពញាមន្ត្រីសង្គ្រាមមករាជធានីបន្ទាយលង្វែក (ឧដុង្គ) ដើម្បីជួបនឹងសម្ដេចព្រះរាជបុត្រាតូច ព្រះនាមសម្ដេចព្រះកែវហ្វា។ នៅឆ្នាំម្សាញ់ ខែមាឃ ចៅពញាមានជីវភាពលំបាកខ្សត់ឥតទ្រព្យធនឡើយ ទើបជំទាវរត្នកញ្ញា ជាម្ដាយមីងបង្កើត និងនាងសរ ជាក្មួយធ្វើសំពត់ហូល១ អាវ១ ឱ្យចៅពញា។ ពីបន្ទាយលង្វែក ចៅពញាស្រូតរូតទៅដល់ស្រុកសំរោងសែន ហើយបានជួបនឹងសម្ដេចព្រះអនុជក្សត្រី សម្ដេចព្រះរាជបុត្រា សម្ដេចព្រះរាជបុត្រី សម្ដេចកត្តនិយោ សម្ដេចព្រះកត្តនិយា។ ចៅពញាបានជួបម្ដាយមីងទាំង៧សន្ដាន និងបានដណ្ដឹងនាងពៅ ដែលមានទ្រព្យធននិងខ្ញុំកំដរជាច្រើនជាប្រពន្ធ។ ចៅពញាវិលទៅបន្ទាយលង្វែកវិញ ហើយសម្ដេចព្រះរាជបុត្រាធំ ទ្រង់ព្រះនាមសម្ដេចស្រីធម្មរាជាប្រទាន

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ងារចៅពញា ជាឧកញាសុរិន្ទ្រាធិប្បតី និងប្រទានងារនាងពៅ ជាជំទាវស្រីរត្ន កេសរ ទើបសម្តេចព្រះវររាជបិត្តាធិរាជបរមនាថ (ព្រះបាទជ័យជេដ្ឋាទី២ ឬជម្មរាជាទី៣) ព្រះបាទបរមបពិត្រផ្តល់គោរមងារជា ឧកញាវង្សាអគ្គរាជ។

លុះដល់ឆ្នាំជូត ទើបសម្តេចព្រះបាទបរមនាថព្រះបាទបរមបពិត្រ ត្រាស់ប្រើឧកញាវង្សាអគ្គរាជ និងនាយពលត្រវល និងអស់កូនក្មួយលើក ទ័ពចេញទៅបង្ក្រាបចោរកំណាចនៅស្រុករលាប្អៀរ ស្រុកបរិបូរ ស្រុកខ្លុង ស្រុកក្រង ស្រុកក្រគរ។ ចោរកំណាចបាក់ខ្ទប់ខ្ទាចព្រះអំណាចព្រះបាទអ្នក ជាអម្ចាស់ ហើយស្រុកមានភាពក្សេមក្សាន្តសប្បាយ អស់ប្រជារាស្ត្រ និង ឈ្មួញអាចធ្វើដំណើរចេញចូលទៅវិញទៅមកបាន។ លុះដល់ថ្ងៃសុក្រទី៣ រោជ ខែអាសាធ ឆ្នាំឆ្លូវ ទើបសម្តេចព្រះបាទព្រះជ័យជេដ្ឋាធិរាជ រាមាធិបតី បរមនាថ ព្រះបាទបរមបពិត្រ អ្នកជាអម្ចាស់ ត្រាស់ប្រើឧកញាវង្សា...ជា មេកងធំ ហើយប្រទានព្រះអំណាចព្រះរាជទាន...ហើយក្រាបលាចេញ ទៅ និង...នាយពល និងអស់កូនក្មួយ លើកទ័ពចេញទៅតតាំងច្បាំងនឹង សម្តេចព្រះមហាក្សត្រី ជាបុត្រីអ្នកសម្តេចព្រះកែវហ្វា (ព្រះបាទកែវហ្វាទី៣ ១៧១៤-១៧២២)។

នៅពេលច្បាំងឈ្នះសម្តេចព្រះមហាក្សត្រី ដេញបាក់ទ័ពរត់ខ្ចាត់ខ្ចាយ ដោយតេជៈអំណាចព្រះបាទអ្នកជាអម្ចាស់ ហើយបានដោយសារតំនិតប្រាជ្ញា របស់ឧកញាវង្សាអគ្គរាជ ត្រិះរិះគិតតាក់តែងលៃងមេទ័ព មេកងតាមស្កាត់ រកសព្វផ្លូវច្រកល្ហក ចាប់បានខ្ញុំសម្តេចព្រះមហាក្សត្រី និងអស់ទ្រព្យរបស់ ផងជាច្រើន ហើយនាំចូលទៅក្រាបថ្វាយបង្គំ ថ្វាយខ្លួនអស់ខ្ញុំនិងអស់របស់ ទ្រព្យទាំងនោះ ទើបសម្តេចព្រះបាទបរមនាថ ព្រះបាទបរមបពិត្រអ្នកជា អម្ចាស់ព្រះរាជឱង្ការសរសើរពីព្រះឱស្សទិព្វពិសេសថ្លៃ ឱ្យព្រះទានឧកញា វង្សា អគ្គរាជ ជាឧកញាតេជោគ្រប់គ្រងស្រុកកំពង់ស្វាយ។

តែឧកញាអង្វរព្រះរាជហឫទ័យថ្ងៃទិព្វពិសេស ពុំព្រមទទួលឡើយ។ ហើយទើបព្រះរាជទានលើកឱ្យឧកញាពានមាស និងប្រទានឋានៈបាំងក្ងស់២

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទើបឧកញ៉ាក្រាបលាព្រះបាទសម្ដេចបរមនាថ ព្រះបាទបរមបុពិត្រចេញមកធ្វើបុណ្យ និងបំបួសជំទាវរតនកញ្ញាជាម្ដាយមីងបង្កើត និងជំទាវស្រីរតនកេសរជាប្រពន្ធ និងនាងកីមជាប្អូនថ្លៃ និងក្មួយស្រី២នាក់បួសជានាងជី ធ្វើបុណ្យមួយថ្ងៃ និមន្តអ្នកព្រះសង្ឃរាជ ទ្រង់បាំងស្កូលអនិច្ចា ជំទាវរតនកញ្ញាជាម្ដាយមីង ដោយមានព្រះសង្ឃរាជ៥អង្គ ភិក្ខុ១១អង្គ ហើយនិមន្តព្រះសង្ឃទ្រង់បាំងស្កូលអនិច្ចា ឧកញ៉ាវង្សាអគ្គរាជ ព្រះសង្ឃរាជ១អង្គ ភិក្ខុ៧អង្គ ហើយនិមន្តទ្រង់ បាំងស្កូលអនិច្ចាជំទាវស្រីរតនកេសរជាប្រពន្ធ ព្រះសង្ឃរាជ២អង្គ ភិក្ខុ៦ ប្រគេនព្រះសង្ឃរាជទាំងអស់១អង្គ១តម្លឹង ឯភិក្ខុប្រគេន៨ស្លឹង ហើយដារឆ្លង។ នោះអ្នកព្រះសង្ឃទ្រទ្រង់២សង្ឃរាជ៣អង្គសិងប្រគេន១អង្គ១តម្លឹង ឯភិក្ខុនោះសិងប្រគេន១អង្គ២បាត និមន្តអ្នកសាមនេរ សូត្រធម៌២អង្គប្រគេន១បាទ ឯអស់អ្នកសាមនេរទាំង បាំងស្កូលអនិច្ចាទាំងដារនោះ៧០សាមនេរ សិងប្រគេន១អង្គ១ស្លឹង ហើយនិមន្តមហាសង្ឃរាជសិលាចារ្យទេសនាព្រះមហាជាតក១លើក អ្នកគុងកូនប្រុសអាយុ៨ឆ្នាំ បូជាព្រះធម៌ ហើយបូជាប្រាក់៣បាត ទើបលោះខ្លួនអ្នកគុងកូនប្រុស៧តម្លឹង ហើយនិមន្តមហាសង្ឃរាជបញ្ញាលិខិតទេសនា អនិសង្សព្រះ និងអនិសង្សផ្នួស បូជាប្រាក់៣តម្លឹង ៣ស្លឹង និងប្រគេនសំពត់ស១ និងស្បែកាសាទង់មួ១ ឱ្យឈ្នួល អ្នកលេង៧បាទ គិតបូកអស់ចំណាយ ត្រូវជាប្រាក់៣ជិងជាទាន។

ឧកញ៉ាវង្សាអគ្គរាជដល់ជាកូនអ្នកឧកញ៉ាក្រលាហោមសេនាបរទេស និងអ្នកជំទាវកញ្ញាកេសរជាមាតាបិតា ឧកញ៉ាវង្សាអគ្គរាជ និងជំទាវគ្រិរត្នកេសរ និងអ្នកហិង អ្នកព្រំម និងអ្នកគុងមានចិត្រថ្វាសាទ្ធាសាងកុសលទាំងនេ ទៅមាតាបិតា និងញាតិកាទាំង៧សន្តាន ដែលមានធម៌សប្បុរស ហើយសូមបានអាយុវែងបាន៥០០០វស្សា ប្រកបដោយប្រាជ្ញា និងទ្រព្យសម្បត្តិ ហើយសូមបានជាព្រះមហាបរមចក្កពត្តិរាជ សោយសុកក្សេមក្សាន្តសប្បាយ លុះបានចូលនិព្វានហោង។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៦.១.៣. អស្ថិរភាពនយោបាយនៅចុងសតវត្សទី១៨

នៅក្នុងដំណាក់កាលទី២នៃសម័យឧដុង្គ ក្នុងសតវត្សទី១៨ និង១៩ នេះ កម្ពុជាបានបាត់នូវភាពម្ចាស់ការ ដោយសារជម្លោះដណ្តើមរាជ្យជាប្រចាំ និងការរត់ទៅពឹងពាក់ប្រទេសជិតខាង ដើម្បីជួយឱ្យឡើងសោយរាជ្យ។ ការពង្រីងអំណាចទៅប្រទេសសៀមក្នុងរជ្ជកាលចក្រី និងនៅប្រទេសវៀតណាមក្នុងរជ្ជកាលព្រះចៅអធិរាជង្វៀង បានធ្វើឱ្យកម្ពុជាស្ថិតនៅចន្លោះដង្កៀបពីរ ដែលគាបខ្មែរបាត់អស់ទឹកដី។ ព្រះមហាក្សត្រខ្មែរពេលនោះច្រើនមានវ័យក្មេង គ្មានបទពិសោធ ហើយការគ្រប់គ្រងរដ្ឋស្ថិតនៅក្នុងកណ្តាប់ដៃរបស់មន្ត្រីជាន់ខ្ពស់ ដែលឈ្លោះគ្នាដណ្តើមអំណាច។ ប្រជាពលរដ្ឋខ្មែររងទុក្ខវេទនា ដោយសារភាពចលាចល និងអសន្តិសុខ។ ក្នុងរយៈពេលជិតមួយសតវត្ស កម្ពុជាបានបាត់បង់ទាំងស្រុងនូវតួនាទីនៅជ្រោយ កូសាំងស៊ីន។ កម្ពុជាធ្លាក់ចុះបន្តិចម្តងៗទៅក្នុងកលិយុគ។ ខ្មែរបានធ្លាក់ចុះពីប្រទេសមួយដែលមានវប្បធម៌ និងអារ្យធម៌ខ្ពង់ខ្ពស់ ដល់កម្រិតមួយជិតស្មើសូន្យ។

ពាក់កណ្តាលទី១នៃសតវត្សទី១៩ គឺជាការប្រយុទ្ធរវាងសៀម និងវៀតណាម ដើម្បីឥទ្ធិពលលើកម្ពុជា។ កម្ពុជាធ្លាក់នៅក្រោមការគ្រប់គ្រងនិងត្រួតត្រារបស់សៀមនិងវៀតណាម ក្នុងពេលតែមួយ។ សតវត្សទី១៩ គឺជាសតវត្សដែលកម្ពុជាបាត់បង់នូវឯករាជ្យភាព ជាប្រទេសឯករាជ្យ។ កម្ពុជាស្ទើរតែបាត់បង់ឈ្មោះពីផែនទីពិភពលោក។ សង្គ្រាមបានបំផ្លាញដល់ឫសគល់នូវវត្តអារាម ដែលជាកន្លែងបណ្តុះបណ្តាលធនធានមនុស្សដ៏តិចតួចស្តួចស្តើងរបស់កម្ពុជា។ ក៏ប៉ុន្តែអក្សរសិល្ប៍ពុទ្ធនិយមខ្មែរបានឈានឡើងដល់កម្រិតកំពូល ដោយសារប្រជាជនត្រូវការស្នាដៃអក្សរសិល្ប៍សម្រាប់កម្សាន្តរំដោះទុក្ខព្រួយ។

ព្រះបាទស្រីជ័យជេដ្ឋ សោយទិវង្គតនៅឆ្នាំ១៧៥៥។ ព្រះបាទមហាឧបកយោរាជអង្គទង (រជ្ជកាលទី២) (១៧៥៦-១៧៥៧) ដែលជាចៅទួតលួតព្រះឧទ័យ បានឡើងសោយរាជ្យសម្បត្តិ ដោយមានព្រះនាមរាមាធិបតីទី៣។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយសារវិបត្តិធ្ងន់ធ្ងរក្នុងរាជវង្ស វៀតណាមគាបសង្កត់ហើយទាមទារយកខេត្តផ្សារដែក, ខេត្តលង់ហោរ, និងខេត្តមាត់ជ្រូក។ វិវាទក្នុងរាជវង្សខ្មែរបានកើតឡើងជាថ្មី រវាង អង្គតន់ និងអង្គហ៊ីង (ព្រះអនុជធម្មរាជា អង្គឥម) ដែលជាមហាឧបរាជ។ អង្គតន់ ដឹងពីគម្រោងធ្វើគុត ក៏កៀសខ្លួនចេញពីឧដុង្គទៅតាំងទីនៅកំពង់ហ្លួង ហើយកេណ្ឌទ័ពវាយឈ្នះ និងធ្វើគុត អង្គហ៊ីង។ ចំណែកឯបុត្ររបស់អង្គទង គឺអង្គនន្ទ និងអង្គជី ត្រូវបានលើកលែងទោស ហើយកៀសព្រះកាយទៅប្រទេសសៀម។

ដោយមានការជ្រោមជ្រែងពីវៀតណាម អង្គតន់ ដែលជាបុត្រអង្គស្ងួរ ចៅព្រះបាទធម្មរាជាទី៣ និងជាចៅទួតលួតព្រះឧទ័យបានឡើយសោយរាជ្យសម្បត្តិ ដោយមានព្រះនាមព្រះនារាយណ៍រាជាទី២ អង្គតន់ (១៧៥៨-១៧៧៥)។ ដើម្បីសងគុណ ព្រះអង្គបានប្រគល់ខេត្តពីរ ព្រះត្រពាំង និងឃ្លាំង ទៅឱ្យវៀតណាម។

ចំណែកឯនៅភូមាវិញ នៅចុងទសវត្ស១៧៤០ រាជាណាចក្រមននៅប៉េហ្គូ បានងើបឡើង និងទទួលបានជោគជ័យក្នុងការកាន់កាប់រាជធានី និងបញ្ចប់សន្តតិវង្សទូនហ្គូ។ ក៏ប៉ុន្តែពួកភូមាបានពួតដៃគ្នាងើបតស៊ូប្រឆាំងនឹងពួកមនបានក្នុងរយៈពេលមួយដ៏ខ្លី។ ស្តេចអាលុងផាយ៉ាបានស្ដាបនារាជាណាចក្រអាវ៉ាឡើងវិញ និងវាយយកប៉េហ្គូនៅឆ្នាំ១៧៥៧។ បន្ទាប់មកស្តេចភូមាថ្មីចាប់ផ្តើមធ្វើសង្គ្រាមជាមួយសៀមវិញម្តង។ នៅដើមឆ្នាំ១៧៦០ ស្តេចភូមា បានវាយចូលក្នុងទឹកដីសៀម វាយប្រហារយកឈៀងម៉ៃ ហើយកងទ័ពភូមាបានចូលមកហ៊ុមព័ទ្ធអយុធ្យាតែម្តង។ ភូមាប្រមូលផ្តុំកងទ័ពបានយ៉ាងច្រើន ដោយមានការចូលរួមពីកងទ័ពឡានណា និងឡានសាងផង។ នៅដើមឆ្នាំ១៧៦៦ កងទ័ពភូមាបានឡោមព័ទ្ធក្រុងអយុធ្យាតែម្តង។ នៅឆ្នាំ១៧៦៧ កងទ័ពភូមាបានចូលដុតបំផ្លាញអយុធ្យា ហើយបង្កចលាចលនៅគ្រប់ទិសទី។ នៅពេលនោះ ចៅហ្វ៊ាខេត្តតាក ដែលជាកូនកាត់ចិនម្នាក់ឈ្មោះ ពញាតាកស៊ីន បានកេណ្ឌទ័ពរំដោះកាន់កាប់កំពង់ផែនៅធនបុរី ប្រាំង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខាងលិចទន្លេចៅប្រះយ៉ាជិតបាងកក ហើយបានរំដោះប្រទេសសៀមពីភូមាបាន។ ពញាតាកស៊ិនបានសម្រេចចិត្តមិនត្រឡប់ទៅស្រីអយុធ្យា ហើយផ្លាស់ព្រះរាជាទីមកបាងកកវិញ។ គាត់បានច្បាំងពង្រីកទឹកដី ហើយឡើងសោយរាជ្យជាស្ដេចនៅចុងឆ្នាំ១៧៦៨។

នៅពេលដែលអយុធ្យាដួលរលំ ថងដួង គឺជាអ្នកស្នងរាជ្យនៅរាជបុរី ហើយបានក្លាយជាមេទ័ពម្នាក់ដ៏មានមហិច្ឆតា។ ថងដួង បានចូលបម្រើរាជវង្សថ្មី ហើយត្រូវបានតែងតាំងជាមន្ត្រីខាងយមរាជ នៅឆ្នាំ១៧៧១ ហើយនៅឆ្នាំ១៧៧៥ បានក្លាយជាចក្រី។

នៅក្នុងរាជ្យព្រះបាទនារាយណ៍រាជាទី២ អង្គតន់ នៅឆ្នាំ១៧៦៨ ស្ដេចតាកស៊ិន បន្ទាប់ពីឡើងសោយរាជ្យ បានបញ្ជាឱ្យព្រះបាទអង្គតន់ ទទួលស្គាល់ព្រះអង្គជាស្ដេច ហើយលើកសួយសារអាករទៅថ្វាយ តែទ្រង់មិនព្រមទទួលស្គាល់ ដោយសារព្រះចៅពញាតាក មិនមែនជាពូជក្សត្រ។ ព្រះចៅពញាតាកអាក់អន់ព្រះទ័យយ៉ាងខ្លាំង។ ក្នុងឆ្នាំ១៧៧១ ស្ដេចតាកស៊ិន បានចាត់ចៅពញា-ចក្រីដួង ឱ្យនាំទ័ពជើងគោក ឯព្រះអង្គបញ្ជាកងទ័ពជើងទឹកវាយចូលកម្ពុជាតាមកំពត ដើម្បីលើកអង្គនន់ ដែលរត់ទៅជ្រកនៅជាយដែនសៀមឱ្យឡើងសោយរាជ្យសម្បត្តិ។ ព្រះរាជាអង្គតន់ ទប់ទល់មិនបានក៏ភៀសខ្លួនទៅវៀតណាមដើម្បីសុំទ័ពវៀតណាមជួយទប់ទល់ជាមួយទ័ពសៀម។ ព្រះចៅតាកស៊ីន បានលើកអង្គនន់ ឱ្យឡើងសោយរាជ្យនៅឧដុង្គ ការពារដោយកងទ័ពរបស់ពញាចក្រី។

នៅពេលដែលសៀមដកទៅស្រុកសៀមវិញ ព្រះបាទនារាយណ៍រាជាទី២ អង្គតន់ ដោយមានជំនួយពីទ័ពវៀតណាមបានវាយអង្គនន់ឱ្យដកថយទៅខេត្តកំពត។ កម្ពុជាត្រូវបានចែកជាពីរ ដោយព្រះអង្គតន់ សោយរាជ្យនៅឧដុង្គ ហើយអង្គនន់ សោយរាជ្យនៅកំពត។ នៅពេលនោះ មន្ត្រីម្នាក់ឈ្មោះបែន ដែលមានដើមកំណើតនៅស្រុកតាកែវ បានចូលបម្រើព្រះបាទអង្គនន់។

នៅឆ្នាំ១៧៧២ ព្រះរាជាអង្គតន់ ទ្រង់ក៏សុខចិត្តលើកសួយសារអាករ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យសៀមក្នុងលក្ខខណ្ឌដែលសៀមសុខចិត្តដកកងទ័ពចេញពីកម្ពុជា ដើម្បីបង្រួបបង្រួមប្រទេសឡើងវិញ។ នៅឆ្នាំ១៧៧៣ បុត្ររបស់ព្រះអង្គ ព្រះនាមអង្គអេងបានប្រសូត។ នៅឆ្នាំ១៧៧៥ ព្រះអង្គតន់ ទ្រង់សម្រេចចិត្តដាក់រាជ្យថ្វាយអង្គនន់ ដើម្បីជៀសវាងសង្គ្រាមដែលអាចកើតឡើងម្តងទៀត ហើយព្រះអង្គនៅជាមហាឧកយោរាជវិញ។

នៅឆ្នាំ១៧៧៥ បុត្រព្រះស្រីជ័យជេដ្ឋ អង្គស្ងួន និងត្រូវជាចៅទួតលាព្រះឧទ័យបានឡើងសោយរាជ្យសម្បត្តិ ដែលមានព្រះនាមរាមាធិបតីអង្គនន់ (១៧៧៥-១៧៧៩)។ កម្ពុជាក៏ទទួលបានសន្តិភាពឡើងវិញ តែជម្លោះរវាងមន្ត្រីដែលគាំទ្រស្តេចចាស់អង្គតន់ ដែលរណបវៀតណាម និងមន្ត្រីដែលគាំទ្រស្តេចថ្មីអង្គនន់ដែលរណបសៀមនៅតែបន្ត។

នៅឆ្នាំ១៧៧៧ ឧកញ៉ាវិបុលរាជស៊ូ បានញុះញង់បំបែកបំបាក់ព្រះមហាឧបរាជអង្គធម្ម ជាមួយព្រះរាជារាមាធិបតីអង្គនន់។ នៅពេលដឹងថាមហាឧបរាជមិនចូលដៃជាមួយខ្លួន ក៏ក័យខ្លួនហើយរៀបចំសម្លាប់ព្រះឧបរាជចោល។ នៅឆ្នាំ១៧៧៧ ឧកយោរាជអង្គតន់ ប្រឈួនហើយក៏សុគតទៅហើយនាហ្មឺនសព្វមុខមន្ត្រីបានប្រមូលផ្តុំគ្នាជុំវិញបុត្ររបស់អង្គតន់ ព្រះនាមអង្គអេង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អធិវង្សាប៉ុក។

ដូចនេះ នៅចុងសតវត្សទី១៨ រាជាណាចក្រកម្ពុជាស្ថិតនៅសភាពទន់ខ្សោយ ហើយអំណាចស្ថិតនៅក្នុងដៃរបស់ឧត្តមមន្ត្រីក្នុងវាំងមាន៖ (១) ចៅហ្វា ម៉ូ (២) ឧកញ៉ាវិបុលរាជ ស៊ូ និង (៣) បែន និង (៤) ឧកញ៉ាអធិវង្សាប៉ុក។ ជម្លោះភូមិសាស្ត្រនយោបាយរវាងសៀម និងវៀតណាមបាននាំឱ្យមានការបែកបាក់ក្នុងចំណោមមន្ត្រីខ្មែរ និងបង្កើតឱ្យមានជម្លោះរវាងមន្ត្រីនិយមសៀម និងមន្ត្រីនិយមយួន។

ចៅហ្វាម៉ូ ធ្លាប់បម្រើក្នុងរាជការនៃរជ្ជកាលអង្គតន់ នៅក្នុងឆ្នាំ១៧៥៧ ហើយត្រូវបានតម្លើងយសសក្តិជាឧកញ៉ាតេជោ ហើយនៅឆ្នាំ១៧៦០ ត្រូវបានតម្លើងយសទៅជាសម្តេចចៅហ្វាទឡ្ហៈ មានឋានៈស្មើនាយករដ្ឋមន្ត្រី។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លោកមានបងប្អូនបីនាក់៖ (១) ឧកញ៉ាតេជោទែន ចៅហ្វាយខេត្តកំពង់ស្វាយ (២) ឧកញ៉ាសែន្យខាងហ្វាពាង ចៅហ្វាយខេត្តបាភ្នំ និង (៣) ឧកញ៉ាមន្ត្រីស្នេហាសួរចៅមឿងគោកសេះ។

ឧកញ៉ាវិបុលរាជស៊ូ ធ្លាប់បម្រើការនៅក្នុងរជ្ជកាលអង្គតន់ ជាឧកញ៉ាបវរនាយក។ នៅឆ្នាំ១៧៧៦ នៅពេលដែលមានការបះបោរនៅព្រៃនគរ ដឹកនាំដោយតៃសុន ចៅហ្វាយខេត្តព្រៃនគរបានសុំជំនួយពីខ្មែរ តែអង្គនន់បដិសេធ ហើយឆ្លៀតយកឱកាសលែងលើកសួយសារអាករទៅឱ្យវៀតណាម។ កងទ័ពវៀតណាមក៏ចូលមកបោះទីតាំងនៅជ្រោយចង្វារ តែត្រូវសម្តេចព្រះមហាឧបរាជអង្គធម្មនិងឧកញ៉ាវិបុលរាជស៊ូវាយបណ្តេញចេញអស់ទៅ។

ឧកញ៉ាវង្សអគ្គរាជបែន បានចូលបម្រើរាជការនៃរជ្ជកាលអង្គនន់ នៅក្នុងឆ្នាំ១៧៧០ នៅពេលដែលព្រះអង្គដកថយទៅខេត្តកំពត បន្ទាប់ពីកងទ័ពសៀមដឹកនាំដោយពញាចក្រីដួងថង ដកថយទៅវិញ។ ដោយសារសមត្ថភាព និងភាពស្មោះត្រង់ លោកត្រូវបានតម្លើងយសទៅជាឧកញ៉ាយមរាជ។ បែន ជាមន្ត្រីដែលជិតស្និទ្ធនឹងអង្គនន់ ហើយធ្លាប់ដឹកនាំទ័ពប្រយុទ្ធជាមួយអង្គតន់ ហើយស្គាល់ពញាចក្រីដួងថង ដែលនឹងក្លាយជាព្រះចៅសៀមព្រះរាមទី១យ៉ាងច្បាស់។ដូចនេះហើយទើបបែនជាឧត្តមមន្ត្រីដែលរណបនឹងសៀម។

ឧកញ៉ាអធិវង្សាប៉ុក ជាព្រះញាតិព្រះមហាឧកយោរាជអង្គតន់ និងជាអ្នកអាណាព្យាបាល និងព្រះធម្មបិតារបស់បុត្រាព្រះអង្គ ព្រះអង្គអេង និងព្រះរាជធីតា។

នៅឆ្នាំ១៧៧៨ ព្រះចៅតាកស៊ិន ទ្រង់ចាត់ពញាចក្រីដួង ជាមហាក្សត្រសឹក និងចៅពញាសុរសី ប៊ុនម៉ា ជាមេទ័ពឱ្យទៅវាយប្រទេសលាវ។ សៀមបានសុំជំនួយជាសេនាទាហាន និងស្បៀងអាហារពីខ្មែរ។ ព្រះរាជារាមាធិបតីអង្គនន់ ទ្រង់បានចាត់ឧកញ៉ាតេជោទែន ចៅហ្វាយខេត្តកំពង់ស្វាយ ឧកញ៉ាសែន្យខាងហ្វា ពាង ចៅហ្វាយខេត្តបាភ្នំ និងឧកញ៉ាមន្ត្រីស្នេហា សួរ ចៅ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មឿងគោកសរ ឱ្យកេណ្ឌពល និងប្រមូលស្បៀងឱ្យកងទ័ពសៀម។ ប្រជាពល-រដ្ឋក៏កើតក្ដីក្ដៅក្រហាយបះបោរប្រឆាំងនឹងរាជការ។ ប្រជារាស្ត្របានទៅពឹងឧកញ៉ាមន្ត្រីស្នេហា សួរ ឱ្យជួយ។ ព្រះរាជាទ្រង់ចាត់ឧកញ៉ាព្រះឃ្លាំងធិបតី សំ ជាព្រះរាជអាជ្ញាហ្លួង ទៅរកចាប់ខ្លួនអ្នកបះបោរ។ ប្រជារាស្ត្របានលើកទ័ពទៅព័ទ្ធវាយបន្ទាយ និងសម្លាប់ឧកញ៉ាព្រះឃ្លាំងធិបតីចោលទៅ។

ព្រះរាជាអង្គនន់ ទ្រង់ខ្វាល់ណាស់ ទើបទ្រង់ត្រាស់ឱ្យឧកញ៉ាទាំងបីចូលគាល់នៅឧដុង្គ។ ព្រះរាជាបានត្រាស់នាំខ្លួន ឧកញ៉ាមន្ត្រីស្នេហា សួរ ទៅប្រហារជីវិត ឧកញ៉ាសែនទ្យខាងហ្វា ពាងវាយ៥០រំពាត់ ហើយឧកញ៉ាតេជោ ទែន ត្រូវទ្រង់ជេរប្រដៅ។ ជំទាវឡង់ជាម្ដាយប្ដេជ្ញាសងសឹកជួសកូន។ ឧកញ៉ាទាំងពីរបានបញ្ជូនមនុស្សឱ្យទៅបញ្ចុះបញ្ចូលរាស្ត្រឱ្យបះបោរ ដោយយល់ថា អង្គនន់ ទ្រង់មិនមានទសពិធរាជធម៌ទេ។ ឧកញ៉ាទាំងពីរបានផ្ញើលិខិតទៅចៅហ្វាមូ៉ ជាបងដែលដឹកនាំទ័ពទប់ទល់ជាមួយវៀតណាមនិង ឱ្យរួមគ្នាកម្ចាត់ព្រះរាជាអង្គនន់ ហើយយាងព្រះអង្គអេង ជាព្រះរាជបុត្រាព្រះនារាយណ៍រាជាអង្គតន់ឡើងសោយរាជ្យវិញ។

ដោយខ្លាចចៅហ្វាមូ៉ ជាបងចូលជាមួយប្អូន ព្រះរាជាអង្គនន់ ទ្រង់ព្រះតម្រាស់ឱ្យចៅហ្វាទឡ្ហៈចូលគាល់ ដើម្បីទៅនិយាយឱ្យប្អូនទាំងពីរចុះចូលឈប់បះបោរ។ បន្ទាប់ពីចេញពីសវនាការចៅហ្វាមូ៉ បានប្រឹក្សាជាមួយឧកញ៉ាវិបុលរាជស្ទិ ដើម្បីរៀបផែនការកម្ចាត់ស្ដេច។ នៅពេលដែលចៅហ្វាមូ៉ ទៅដល់កំពង់ស្វាយ មិនបានបង្ក្រាបទេ តែចូលដៃជាមួយពួកបះបោរទៅវិញ។ ព្រះរាជាអង្គនន់ ទ្រង់បានលើកទ័ពទៅបង្ក្រាបពួកបះបោរ។ នៅឆ្នាំ១៧៧៩ តំបន់ខាងកើតទន្លេមេគង្គស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកបះបោរ។ នៅពេលនោះ ឧកញ៉ាវិបុលរាជស្ទិ បានសុំទ័ពពីវៀតណាមដើម្បីជាជំនួយ។ ក្នុងឆ្នាំ១៧៧៩ ចៅហ្វាមូ៉ បានកេណ្ឌទ័ពវាយសម្លាប់ព្រះអង្គនន់ ហើយតែងតាំងខ្លួនឯងជាសម្ដេចចៅហ្វា មហារាជបពិត្រ តែងតាំងឧកញ៉ាអធិវង្សរាប៉ុក ជាឧកញ៉ាវាំង និងឧកញាវិបុលរាជស្ទិ ជាឧកញ៉ាក្រឡាហោម។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅឆ្នាំ១៧៧៩ ព្រះអង្គអេងដែលមានព្រះជន្ម៧វស្សានៅឡើយត្រូវបានលើកឱ្យគ្រងរាជសម្បត្តិ តែកិច្ចការរាជការក្នុងព្រះនគរសម្រេចដោយចៅហ្វាម៉ូ។ ឧកញ៉ាយោមរាជបែន ដែលជាជំនិតរបស់ព្រះអង្គនន់ ត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅខេត្តកំពង់ស្វាយ។ ព្រះចៅក្រុងធនបូរី តាកស៊ុន ខឹងយ៉ាងខ្លាំងចំពោះព្រឹត្តិការណ៍នៅកម្ពុជា។ នៅឆ្នាំ១៧៨០ ព្រះអង្គបានបញ្ជូនព្រះកែវដួង នីរសាររបស់អង្គតន់ ដែលរស់នៅធនបុរី ជាបេសកជនមកជួបចៅហ្វ៊ាម៉ូ សុំឱ្យបញ្ជូនចៅហ្វាបែន ទៅកាន់ប្រទេសសៀម។ ចៅហ្វ៊ាម៉ូ សប្បាយចិត្តចង់ឱ្យបែនទៅបាត់ពីមុខមាត់។

បន្ទាប់ពីឱ្យចៅហ្វាបែន ចូលគាល់ព្រះចៅតាកស៊ីន បានបញ្ជាឱ្យធ្វើទោសចៅហ្វាបែនដោយវាយ១០០រំពាត់ កាត់សាច់មួយដុំពីស្លឹកត្រចៀកទាំងពីរ ហើយដាក់គុក។ នៅឆ្នាំ១៧៨២ ព្រះអង្គបញ្ជាឱ្យចៅពញាមហាក្សត្រសឹកដួង លើកទ័ពមកឧដុង្គជាមួយចៅហ្វាបែន ដើម្បីសង់សឹក។ កង់ទ័ពសៀមបានវាយយកបានខេត្តកំពង់ស្វាយ។ បក្សពួកអង្គនន់ បានចុះចូលជាមួយទ័ពសៀម ដើម្បីសង់សឹក។ ចៅហ្វ៊ាម៉ូ និងនាហ្មឺនបានកេណ្ឌទ័ពដើម្បីទប់ទល់ និងបានសុំជំនួយពីវៀតណាម។

ចំណែកនៅសៀមវិញស្តេចតាកស៊ីនបានបូជាព្រះកាយដើម្បីសាសនា និងបានលះបង់ពេលវេលាធ្វើសមាធិ ដើម្បីអាចហោះហើរតាមអាកាស។ ព្រះអង្គបង្កើតឱ្យមាននិកាយពីរក្នុងព្រះពុទ្ធសាសនា និងបង្ខំឱ្យគោរពទ្រង់ជាព្រះ។ ព្រះសង្ឃដែលបដិសេធត្រូវទម្លាក់បុណ្យសក្តិ វាយធ្វើបាប និងផ្សឹក។ ព្រះអង្គចាប់មន្ត្រី និងរាជវង្សានុវង្សធ្វើបាបតាមអំពើចិត្ត។ នៅឆ្នាំ១៧៨១ ការបះបោរមួយបានកើតឡើង ដើម្បីធ្វើគុតស្តេច នៅពេលដែលចក្រីថង់ដួងត្រូវបានតែងតាំងជាមេបញ្ជាការទទួលបន្ទុកយុទ្ធនាការនៅកម្ពុជា។ អ្នកបះបោរបានហែរក្បួននៅធនបុរី ដើម្បីចាប់ស្តេចតាកស៊ុន និងអញ្ជើញចៅពញាចក្រីឱ្យត្រឡប់ពីកម្ពុជាវិញ ដើម្បីឡើងសោយរាជ្យ។ នៅពេលនោះ ចៅពញាមហាក្សត្រសឹកដួង កំពុងស្ថិតនៅខេត្តសៀមរាប ហើយវិលត្រឡប់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មកប្រទេសសៀមវិញ ដើម្បីសោយរាជសម្បត្តិជាម្ចាស់ផែនដីក្រុងសៀមក្នុងឆ្នាំ១៧៨២ រួចហើយបញ្ជាឱ្យចាប់ផ្ញើកពញាតាក រួចដាក់ទោសប្រហារជីវិត។ នេះគឺជាដំណាក់កាលថ្មីនៃសម័យកាលរាជវង្សចក្រីនៅប្រទេសសៀម ដែលព្រះចៅស្ដេចសៀមយកព្រះនាម ព្រះពុទ្ធយ័តហ្វាចូឡាលោក ឬព្រះរាមទី១។

ការបែកបាក់ក្នុងជួរឧត្តមមន្ត្រីខ្មែរ ខេត្តបាត់ដំបង និងសៀមរាបក្រោមការត្រួតត្រាសៀម៖ ដើម្បីកម្ចាត់ចៅហ្វ៊ាម៉ូដណ្ដើមរាជ្យ ឧកញ៉ាក្រឡាហោមស៊ូបានផ្ញើលិខិតសុំឱ្យចៅហ្វាបែន ត្រឡប់មកឧដុង្គវិញ ដើម្បីរៀបចំផែនការសម្លាប់ចៅហ្វាម៉ូ។ ក្រោយពីបានសម្លាប់ចៅហ្វ៊ាម៉ូ រួចយោមរាជបែនតាំងខ្លួនជាសម្ដេចចៅហ្វ៊ាវិញម្ដង។ ចៅហ្វាបែន សម្រេចថ្វាយព្រះខ័នរាជ្យដល់ព្រះចៅជូឡាលោក ដែលស្មើនឹងទទួលស្គាល់កម្ពុជា ជាសាមន្តរដ្ឋនៃប្រទេសសៀម និងបានកាត់ខេត្តពោធិ៍សាត់បាត់ដំបង និងសៀមរាបឱ្យទៅសៀម។

កម្ពុជាកើតចលាចលម្ដងទៀត ដោយចៅហ្វាយខេត្តស្ដេចត្រាញ់ត្បូងឃ្មុំ និងជាប្អូនប្រុសចៅហ្វាម៉ូ ឈ្មោះទែន បានលើកទ័ពមកចូលចាប់ចៅហ្វ៊ាបែន។ នាហ្មឺនសព្វមុខមន្ត្រីមិនសប្បាយចិត្តនឹងចៅហ្វ៊ាបែន ហើយងើបឡើងប្រឆាំង។ ចៅហ្វ៊ាបែន រត់ទៅរស់នៅខេត្តបាត់ដំបង ហើយបញ្ជូនក្រឡាហោមប៉ុក ដែលជាព្រះធម្មបិតានៃព្រះបាទអង្គអេង និងព្រះបាទអង្គអេង រត់ (ព្រះជន្ម១០វស្សា) ទៅសៀម។ ស្ដេចសៀមឃាត់ព្រះអង្គទុករហូតដល់អាយុ២២វស្សា។

កម្ពុជានៅពេលនោះបែងចែកជាពីរ ផ្នែកខាងលិច ដែលមានខេត្តបាត់ដំបង ពោធិ៍សាត់និងសៀមរាប គ្រប់គ្រងដោយបែន និងតំបន់ផ្សេងទៀតគ្រប់គ្រងដោយទែន។ នៅឆ្នាំ១៧៨៣ ស្ដេចរាមាទី១ តែងតាំងនាហ្មឺនខ្មែរបីរូប គឺចៅពញាអភ័យភូបែសបែន ឱ្យត្រួតខេត្តបាត់ដំបង កែប ជាចៅហ្វាយខេត្តសៀមរាប និងកន ជាចៅហ្វាយខេត្តពោធិ៍សាត់ហើយត្រូវរាយការណ៍រាល់កិច្ចការទាំងឡាយ ដោយផ្ទាល់ឱ្យស្ដេចក្រុងសៀម។ នៅឆ្នាំនោះសៀមបានបញ្ជូនទ័ពមកជួយវាយពួកបះបោរវៀតណាមពីរលើក តែទទួលបរាជ័យ។ ទែនបានដឹកនាំកងទ័ពវៀតណាមត្រឡប់ចូលមកគ្រប់គ្រងនៅឧដុង្គ។ បន្ទាប់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មកទែន ត្រូវចាប់បានហើយបញ្ជូនទៅក្រុងបាងកក។ ព្រះចៅក្រុងបាងកក បានដោះលែងទែន ហើយផ្តល់គោរមងារស្មើឧត្តមមន្ត្រីសៀម។

ចៅពញាអភ័យភូបែស បែន បានត្រឡប់មកគ្រប់គ្រងកម្ពុជាវិញ ដោយបម្រើផលប្រយោជន៍ប្រទេសសៀមពីឆ្នាំ១៧៨៧ ដល់១៧៩២។ បែន ជាមនុស្សមានមហិច្ឆតាធំ ហើយតែងតែចង់ធ្វើដូចព្រះចៅចូឡាលោក និងព្រះចៅតាកស៊ិន ដើម្បីក្លាយជាស្តេច។ ដោយសារបែនគ្រប់គ្រងប្រទេសដោយផ្តាច់ការ និងដោយភ័យខ្លាចថាថ្ងៃក្រោយបែន អាចក្បត់នឹងសៀម ព្រះចៅចូឡាលោក សម្រេចកោះហៅ បែន ឱ្យត្រឡប់មកប្រទេសសៀមវិញ។

ព្រះអង្គអេង (១៧៩៤-១៧៩៦) បានរៀបអភិសេកក្នុងឆ្នាំ១៧៩៤ នៅក្នុងព្រះជន្ម២២វស្សានៅទីក្រុងបាងកក ព្រះនាមនារាយណ៍រាជាទី៣ អង្គអេង។ គ្រឿងបញ្ចក្សេតជាពិសេស គឺព្រះខ័នរាជ្យ ដែលចៅហ្វាបែនបានថ្វាយឱ្យព្រះចៅសៀមក៏ត្រូវបង្វិលមកឱ្យខ្មែរវិញ។ ឧកញ៉ាក្រឡាហោម ប៉ុក ត្រូវបានតែងតាំងជាចៅហ្វាទឡ្ហៈ។ ព្រះអង្គអេងមានបុត្របីអង្គ៖ អង្គច័ន្ទ, អង្គអិម, និងអង្គឌួង។ ព្រះអង្គគ្រងរាជ្យបានតែ៣ឆ្នាំប៉ុណ្ណោះ។ ប្រទេសកម្ពុជាពេលនោះបានបាត់បង់ពួកមន្ត្រីដែលមានសមត្ថភាព និងស្មោះត្រង់ ចំណែកឯវិស័យការពារប្រទេស យើងក៏គ្មានទ័ពសម្រាប់ការពារខ្លួនទប់ទល់នឹងការវាយលុកណាមួយពីខាងក្រៅ។ ចំណែកឯវិស័យសេដ្ឋកិច្ចទៀតសោត បានធ្លាក់ចុះដុនដាបដោយសង្គ្រាមក្នុងស្រុក។

សតវត្សទី១៨ ដែលជាសតវត្សចំណេះដឹងនៅទ្វីបអឺរ៉ុប តែសម្រាប់កម្ពុជា គឺជាសតវត្សនៃការធ្លាក់ចុះ ការបាត់បង់ឯករាជ្យ សង្គ្រាមដណ្តើមអំណាច និងសង្គ្រាមរាតទីនៃប្រទេសជិតខាង។ កម្ពុជានៅបន្តជាប្រទេសដែលមានសេដ្ឋកិច្ច និងរចនាសម្ព័ន្ធសង្គមបែបបុរាណ ស្ថាប័ននយោបាយទន់ខ្សោយ និងកង្វះខាតធនធានមនុស្ស ខ្វះនាហ្មឺនស្មោះត្រង់ មានសមត្ថភាពដែលអាចដឹកនាំប្រទេសជាតិបាន។

ចៅពញាអភ័យធិបែស បែន លើកទ័ពនាំព្រះអង្គអេង ត្រឡប់មក

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្ពុជាវិញ ហើយនៅត្រួតត្រាខេត្តបាត់ដំបង និងអង្គរនៅឆ្នាំ១៧៩៥។ ចៅហ៊្វាឡុះ ប៉ុក និងបែន រៀបចំពិធីអភិសេកម្តងទៀតថ្វាយព្រះអង្គអេង។ នៅក្នុងរជ្ជកាលព្រះអង្គ ប្រជារាស្ត្រនៅក្នុងនគរហាក់ដូចជាបានសុខស្រួលលើកលែងតែខេត្តភាគខាងត្បូង រាស្ត្រខ្មែរត្រូវរងទុក្ខវេទនាដោយសារគួបដិបក្ខយួន គឺតៃសឺន និងពួកស្តេចង្វៀនតែងតែយកប្រទេសខ្មែរធ្វើជាសមរភូមិ។ ប្រជារាស្ត្រខ្មែរត្រូវជាប់កំណែនទ័ព ដោយសារស្តេចខ្មែរកេណ្ឌទ័ព និងផ្តល់ស្បៀងទៅជួយច្បាំងវៀតណាម។ ជម្លោះនេះបានបង្កវិនាសកម្មដល់អាយុជីវិត ទ្រព្យ សម្បត្តិ ដុតបំផ្លាញផ្ទះសម្បែង និងឆក់ប្លន់ទ្រព្យសម្បត្តិរបស់ខ្មែរឥតឈប់ឈរ។ ព្រះរាជាបានតែងតាំងព្រះកែវដួង ជាចៅហ្វាយខេត្តពាម តែទៅបានមួយឆ្នាំក៏រត់មកវិញ។

ចៅពញាអភ័យធីបែស បែន មិនសប្បាយចិត្តឡើយដែលឃើញព្រះអង្គអេងត្រឡប់មកវិញ ហើយបានសុំឱ្យតែងតាំងខ្លួន ជាចៅហ្វាយខេត្តបាត់ដំបង និងបានចេញទៅជាមួយកែប ដែលជាចៅហ្វាយខេត្តសៀមរាប។ មន្ត្រីទាំងពីរបានសុំឱ្យស្តេចថៃបញ្ចូលខេត្តបាត់ដំបង ខេត្តសៀមរាប និងចុងកាល់ឱ្យស្ថិតនៅក្រោមអាជ្ញានៃព្រះចៅក្រុងសៀមវិញ។ បន្ទាប់ពីទទួលបានសំណើរបស់ព្រះចៅចូឡាលោក ព្រះអង្គអេង ដោយពិបាកនឹងជំទាស់បានឆ្លើយថា៖ «ទូលបង្គំយល់ព្រមប្រគល់ខេត្តទាំងពីរ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់សៀម ក្នុងរជ្ជកាលព្រះចៅចូឡាលោកប៉ុណ្ណោះ។ បន្ទាប់ពីព្រះអង្គចូលទិវង្គត ខេត្តទាំងពីរនេះត្រូវយកត្រឡប់មកកម្ពុជាវិញ។

ចៅហ្វាប៉ុក (១៧៩៦-១៨០៥)

ដោយព្រះអង្គដឹងថាទ្រង់រស់ទៀតមិនបានយូរ នៅក្នុងខែមីនា ១៧៩៦ ក្នុងពេលប្រជុំក្រុមប្រឹក្សារាជបល្ល័ង្ក ព្រះអង្គអេង បានផ្ទេរកិច្ចការប្រទេសទៅឱ្យឧបរាជប៉ុក រួចក៏យាងទៅកាន់រាជធានីបាងកក ក្នុងបំណងសុំឱ្យព្រះចៅសៀមប្រគល់ខេត្តខ្មែរមកវិញ។ ដោយស្តេចសៀមមិនព្រមព្រះអង្គក៏បានយាងនិវត្តន៍ចូលប្រទេសវិញ។ ព្រះអង្គអេងក៏សុគតនៅរាជធានីឧដុង្គ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយជំងឺគ្រុនចាញ់នៅចុងឆ្នាំ១៧៩៦។ ព្រះចៅចូឡាលោកទាមទារឱ្យបូជាព្រះសពព្រះអង្គអេង នៅទីក្រុងបាងកក ហើយតែងតាំងព្រះរាជបុត្របួងព្រះអង្គច័ន្ទ ជាអ្នកស្នងរាជ្យ ក្រោមការគ្រប់គ្រងរបស់ចៅហ្វាប៉ុក។ តែដោយជាប់ដៃប្រយុទ្ធជាមួយភូមា ក៏សម្រេចឱ្យបូជាព្រះសពនៅឧដុង្គវិញ។ ចៅហ្វាប៉ុក បានជូនដំណឹងពីការសម្រេចព្រះទ័យរបស់ព្រះចៅចូឡាលោក ដល់ក្រុមប្រឹក្សារាជបល្ល័ង្ក។

ចាប់ពីឆ្នាំ១៧៩៦ ដល់១៨០៥ មក កិច្ចការប្រទេសជាតិស្ថិតនៅក្នុងដៃចៅហ្វាប៉ុក។ ចៅហ្វាប៉ុកនៅបន្តមានស្វាមីភក្តិជានិច្ចចំពោះព្រះរាជវង្សានុវង្ស។ នៅឆ្នាំ១៧៩៨ លោកបានបញ្ជាឱ្យសង់ចេតិយនៅលើកំពូលភ្នំឧដុង្គប៉ែកខាងកើត សម្រាប់ដាក់អដ្ឋិធាតុព្រះអង្គអេង។ ចៅហ្វាប៉ុកមានទំនាក់ទំនងល្អជាមួយសៀម និងវៀតណាម ហើយជួយច្បាំងប្រទេសទាំងពីរ។ នៅចុងឆ្នាំ១៨០៥ ព្រះអង្គច័ន្ទ និងចៅហ្វាប៉ុក បានធ្វើដំណើរទៅទីក្រុងបាងកក។ នៅពាក់កណ្តាលឆ្នាំ១៨០៦ ចៅហ្វាប៉ុក បានឈឺស្លាប់ក្នុងជន្មាយុ៦៥ឆ្នាំ នៅទីក្រុងបាងកក។ ប្អូនរបស់ចៅហ្វាប៉ុក យមរាជនួន ត្រូវបានតែងតាំងជាចៅហ្វាទឡ្ហៈ។

៦.១.២. សង្គ្រាមរវាងសៀម និងវៀតណាមលើទឹកដីកម្ពុជា

ព្រះឧទ័យរាជាអង្គច័ន្ទ(១៨០៦-១៨៣៥)ត្រូវបានព្រះចៅចូឡាលោករៀបអភិសេកនៅឆ្នាំ១៨០៦ នៅទីក្រុងបាងកក ក្នុងព្រះជន្ម១៦វស្សា ដែលមាននាមសម្រាប់រាជ្យថា ព្រះឧទ័យរាជា។ ព្រះអង្គយាងមកសោយរាជ្យនៅឧដុង្គវិញ ហើយព្រះកែវដួង បានរៀបចំពិធីអភិសេកម្តងទៀត។ ព្រះរាជវង្សានុវង្សជិតស្និទ្ធនឹងព្រះរាជាត្រូវឃាត់ទុកនៅបាងកក ដើម្បីឱ្យសៀមមានឥទ្ធិពលលើស្តេចខ្មែរ។ ព្រះអង្គច័ន្ទបានសង់វាំងចំនួនបីនៅឧដុង្គ ហើយបានគង់ប្រថាប់នៅព្រះបរមរាជវាំង ដែលជាទីតាំងនៃវត្តវាំងចាស់បច្ចុប្បន្ន។ នៅឆ្នាំ១៨០៧ សម្តេចព្រះអយ្យការព្រះអង្គអី ស្តេចយាងមកជាមួយចៅពញាបែន ដែលបាននាំបុត្រីរបស់ខ្លួនឈ្មោះនាងទេពមកជាមួយ។ ព្រះអង្គច័ន្ទបានទទួលនាងទេព ជាអ្នកម្នាង និងទទួលយកបុត្ររបស់បែន ឈ្មោះម៉ាឱ្យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចូលបម្រើរាជការខ្មែរ។ នៅឆ្នាំ១៨២៥ ម៉ាត្រូវបានតម្លើងយសជាព្រះអង្គកែវ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងការឈ្លានពានវៀតណាម។

នៅឆ្នាំ១៨០៩ ព្រះចៅសៀម ចូឡាលោក បានចូលទិវង្គត។ ព្រះរាជបុត្រាច្បងឡើងសោយរាជសម្បត្តិ ទ្រង់ព្រះនាមព្រះពុទ្ធឡឹតឡា នភាល័យ ឬព្រះរាមទី២។ នៅឆ្នាំ១៨១០ ស្តេចសៀមតែងតាំងអង្គស្ងួន ជាមហាឧភយោរាជ និងអង្គអិម ជាមហាឧបរាជ។ ចៅពញាបែន បានស្លាប់នៅឆ្នាំ១៨០៩ដែរ។ ព្រះចៅរាមាទី២ បានតែងតាំងកូនប្រុសបែន ឈ្មោះវិបុលរាជបែន ជាចៅហ្វាយខេត្តបាត់ដំបងជំនួសឪពុក។

នៅឆ្នាំ១៨១០ព្រះអង្គកែវដួង ដែលជាឧត្តមមន្ត្រីមានសមត្ថភាពម្នាក់ បានស្លាប់។ ចាប់ពីពេលនោះមក ខ្មែរលែងមានមេទ័ពខ្លាំងអាចតទល់ជាមួយប្រទេសជិតខាងទៀតហើយ។ អស្ថិរសុខ ស្ថានភាពសេដ្ឋកិច្ច និងនយោបាយក្នុងប្រទេសកង្វះខាងធនធានមនុស្ស និងវត្តអារាមសម្រាប់បណ្តុះបញ្ញវន្តជាពិសេសស្ថាប័ននយោបាយខ្សត់ខ្សោយ ជម្លោះដណ្តើមរាជ្យការមិនទុកចិត្ត និងសង្ស័យគ្នា និងគំនាបពីប្រទេសជិតខាង មិនអាចឱ្យកម្ពុជាអាចអភិវឌ្ឍប្រទេសបានឡើយ។

នៅឆ្នាំ១៨១០ ក្រោយពីបានទទួលដំណឹងពីព្រះអយ្យកោ អគ្គរាជតី ថាមានមន្ត្រីពីរនាក់ឈ្មោះឧកញ៉ាក្រឡាហោមមឿង និងឧកញ៉ាចក្រីកែប បានផ្សំគំនិតគ្នាក្បត់ដើម្បីធ្វើឃាតព្រះអង្គ ព្រះអង្គច័ន្ទបានប្រគល់កិច្ចការទៅអគ្គរាជតី រៀបចំផែនការសម្លាប់មន្ត្រីទាំងពីរនាក់។ តេជោមឿង ចៅហ្វាយខេត្តកំពង់ស្វាយ និងចៅហ្វាយខេត្តបាត់ដំបងចាប់ផ្តើមប្រុងប្រយ័ត្ន ខ្លាចរាលដាលដល់ខ្លួន។ ព្រះរាជាអង្គច័ន្ទ ទ្រង់ខ្វាល់នឹងតេជោមឿង។ នៅឆ្នាំ១៨១១ ព្រះរាជាបញ្ជូនទ័ព ឱ្យទៅកម្ចាត់ចៅហ្វាយខេត្តកំពង់ស្វាយ មឿង។ មឿងក៏រត់ទៅប្រទេសសៀមបាត់។ នៅពេលនោះអង្គឌួង ទ្រង់បានបួសជាព្រះសង្ឃជាមួយព្រះព្រហ្មមុនីនង់នៅវត្តចតុទិស។

នៅឆ្នាំ១៨១២ ជម្លោះដណ្តើមរាជ្យរវាងអង្គច័ន្ទនិងអង្គស្ងួន បានកើត

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឡើង។ អង្គស្ងួន បាននាំព្រះរាជវង្សានុវង្សទៅរស់នៅខេត្តពោធិសាត់។ ព្រះអង្គច័ន្ទ ប្រើព្រះរាជាគណៈ និងមន្ត្រីសេនាបតីទៅយាងព្រះអង្គត្រឡប់មកវិញ តែអង្គស្ងួនមិនព្រម។ ព្រះអង្គច័ន្ទយល់ថានេះគឺជាផែនការរបស់សៀម ហើយបានសុំទ័ពពីស្តេចយ៉ាឡុង។ វៀតណាមចាត់មេទ័ព ឡឿង ឌិញ ទៀង ឱ្យនាំទ័ព ៥០០នាក់មកបោះជំរុំនៅកោះចិនដើម្បីការពារស្តេច។ ជម្លោះរវាងសៀម និងវៀតណាមបានចាប់ផ្តើមលើទឹកដីខ្មែរ។ ស្តេចសៀមក៏លើកទ័ពមកខេត្តពោធិ៍សាត់ដើម្បីគាំទ្រអង្គស្ងួន។

បន្ទាប់ពីបានទទួលដំណឹងថាទ័ពសៀមបានវាយមកកាន់ខេត្តកំពង់ឆ្នាំង ទ័ពវៀតណាមបានហែរព្រះអង្គច័ន្ទ និងព្រះរាជវង្សានុវង្សទៅដល់កោះដីឥដ្ឋ ហើយចតព្រះទីនាំងនាវានៅទីនោះ។ នៅពេលនោះ អង្គឌួង និងព្រះអនុជ អង្គអិម ទ្រង់បាននាំព្រះវររាជមាតាចុះពីនាវា ដើម្បីភៀសព្រះកាយទៅនៅស្រុកសៀម ដោយមានព្រះព្រហ្មមុនីនង អមដំណើរផង។ ព្រះអង្គច័ន្ទក៏ចេញព្រះទីនាំងនាវាទៅវៀតណាម។ កងទ័ពសៀមវាយចូលដល់ឧដុង្គ ដោយគ្មានការប្រយុទ្ធអ្វីឡើយ ហើយលើកអង្គស្ងួនឱ្យគ្រងរាជ្យ។ ព្រះចៅនភាល័យ ឬព្រះរាមទី២ គ្រាន់តែចង់បង្ហាញដល់អង្គច័ន្ទ ពីអំណាចរបស់សៀមមកលើកម្ពុជាតែប៉ុណ្ណោះ។ ប្រទេសជាតិស្ថិតនៅក្នុងភាពចលាចល។ ក្សត្រិយ៍ទាំងបីព្រះអង្គចេញព្រះរាជដំណើរដោយព្រះទីនាំងគជេន្ទ្រទៅក្រុងទេពបុរី។

ក្នុងខែមេសា ឆ្នាំ១៨១៣ បន្ទាប់ពីបានសម្រុះសម្រួលគ្នាជាមួយសៀមរួចមក ស្តេចយ៉ាឡុងបានបញ្ជាឱ្យទ័ពវៀតណាមដង្ហែអង្គច័ន្ទ មកសោយរាជ្យវិញនៅក្រុងកម្ពុជាធិបតី។ ព្រះអង្គសុខចិត្តលើកសួយសារអាករថ្វាយស្តេចសៀមព្រះបាទព្រះរាមទី២ ទើបសៀមព្រមដកទ័ពចេញពីកម្ពុជា។ ថ្វីត្បិតតែស្តេចខ្មែរសុខចិត្តចំណុះឱ្យសៀម នៅឆ្នាំ១៨១៤ សៀមបានបញ្ជូនទ័ពមកកាន់កាប់ខេត្តកំពង់ស្វាយ ម្លូព្រៃ, ទន្លេរពៅ, និងស្ទឹងត្រែង។ ដូច្នេះពាក់កណ្តាលប្រទេសស្ថិតនៅក្រោមឥទ្ធិពលសៀម ហើយម្ខាងទៀតនៅក្រោមឥទ្ធិពលវៀតណាម។ អង្គច័ន្ទ គង់ប្រថាប់ក្នុងព្រះបរមរាជវាំងនៅ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភ្នំពេញដែលជាកន្លែងមានសន្តិសុខជាងនៅឧដុង្គ។ ក្នុងរយៈពេល២៥ឆ្នាំ សៀម និងវៀតណាម មិនបានច្បាំងគ្នាលើទឹកដីខ្មែរទៀតទេ។ ចំណែក អង្គស្ងួនសុគតនៅឆ្នាំ១៨២២ នៅទីក្រុងបាងកក។

ក្នុងរជ្ជកាលព្រះអង្គច័ន្ទ កម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម។ គេបានកេណ្ឌខ្មែរឱ្យជីកព្រែកពីរនៅឆ្នាំ១៨១៥ ព្រែកវិញតេ ខ្មែរហៅថាព្រែកជីក ឬព្រែកយួនដែលភ្ជាប់ពីមាត់ជ្រូកទៅពាម ទម្លាក់ទៅក្នុងសមុទ្រចិនមានប្រវែង៥៣គីឡូម៉ែត្រ ទទឹង៣៣ម៉ែត្រ។ ព្រែកជីកមួយទៀត ឈ្មោះព្រែកវិញអាន ខ្មែរហៅថាឡុងសែន ភ្ជាប់ពីទន្លេបាសាក់ទៅមេគង្គមានប្រវែង១៤គីឡូម៉ែត្រ។ នៅពេលនោះហើយ ដែលគេហៅថាសម័យតែអុង។

តាគុន ជាទេសាភិបាលនៃស្តេចយ៉ាឡុងនៅព្រៃនគរ ហើយដែលប្រគល់អំណាចឱ្យមេបញ្ជាការយោធា បា ហូ (ឡឿង វ៉ាន់ ធុយ) ជាអ្នកត្រួតត្រាកម្ពុជា ដើម្បីប្រែក្លាយឱ្យទៅជាខេត្តវៀតណាម។ វៀតណាមមានគម្រោងការសំខាន់ពីរទៀតគឺៈ (១) ការដាំដើមឈើនៅហាន់ជ័យៈ ប្រជាពលរដ្ឋខ្មែរ រងទុក្ខវេទនាយ៉ាងខ្លាំង ដោយត្រូវធ្វើការគ្មានឈប់សម្រាក ដើម្បីដាំចម្ការឈើ ក្នុងគោលដៅប្រែក្លាយកម្ពុជា ឱ្យទៅជាចម្ការឈើសម្រាប់នាំចេញទៅវៀតណាម និង (២) ការសម្លាប់មន្ត្រីជាន់ខ្ពស់សំខាន់ៗ ដែលគេសង្ស័យថាជិតស្និទ្ធជាមួយសៀម។

នៅឆ្នាំ១៨៣៣ ព្រះអង្គកែវ ម៉ា ដែលជាបុត្រចៅហ្វាបែន ត្រូវបានមេបញ្ជាការយោធា បា ហូ កោះហៅទៅជួប។ ម៉ាដឹងមុនពីគម្រោងនេះ បានរត់គេចទៅបាត់ដំបង។ អ្នកម្នាងទេពជាបងស្រីបានផ្ញើសំបុត្រសុំអន្តរាគមន៍យោធាពីប្រទេសសៀម ដើម្បីរំដោះកម្ពុជាពីការគ្រប់គ្រងរបស់វៀតណាម។ ចុងឆ្នាំ១៨៣៣ សៀមបានបញ្ជូនទ័ពមកដល់បាត់ដំបង ដោយមានព្រះអង្គកែវ ម៉ា និងព្រះអនុជរបស់ព្រះអង្គច័ន្ទ ដែលឃាត់ទុកនៅក្រុងទេព គឺអ្នកអង្គម្ចាស់អង្គឯម និងអង្គឌួង។ សម្តេចពញាសួសទូលសុំព្រះអង្គច័ន្ទ តែង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាំងឧកញ៉ាចក្រី ឡុង ជាមេបញ្ជាការដើម្បីទប់ទល់នឹងការឈ្លានពាននៃទ័ពសៀម។ ចំណែកព្រះរាជានាំព្រះរាជវង្សានុវង្សចេញព្រះរាជដំណើរទៅគង់ប្រថាប់នៅស្រុកលុងហោ វៀតណាម។ ឧកញ៉ាចក្រីឡុង និងឧកញ៉ាយមរាជហ៊ូ បានកេណ្ឌទ័ពច្បាំងនឹងទ័ពសៀមរហូតដល់បានទទួលជោគជ័យ។

នៅឆ្នាំ១៨៣២ព្រះអង្គច័ន្ទ នាំព្រះរាជវង្សានុវង្សនិងនាហ្មឺនសព្វមុខមន្ត្រីត្រឡប់មកភ្នំពេញវិញ ហើយបានលើកឧកញ៉ាចក្រីឡុង ឱ្យឡើងយសសក្តិជាសម្តេចចៅហ្វាទឡ្ហៈ ឯឧកញ៉ាយមរាជហ៊ូ ជាសម្តេចចៅពញា។ ព្រះឧទ័យរាជាអង្គច័ន្ទទ្រង់សុគតនៅឆ្នាំ១៨៣៤ ដោយរោគាពាធក្នុងព្រះជន្ម៤៤វស្សា។ ព្រះអង្គច័ន្ទ មានបុត្រី៤អង្គ គឺក្សត្រីអង្គប៉ែន អង្គមី អង្គពៅ និងអង្គស្ងួន។ ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កមិនយល់ព្រមប្រគល់ព្រះរាជបល្ល័ង្ក ទៅឱ្យព្រះរាជបុត្រីច្បងរបស់ព្រះអង្គច័ន្ទ ព្រះនាមប៉ែនឡើយ ព្រោះព្រះនាងត្រូវជាចៅរបស់ចៅហ្វាបែន ដែលបានប្រគល់ដីបាត់ដំបងឱ្យទៅសៀម។

៦.១.៣. កម្ពុជាក្នុងឆ្នាំសូន្យ

នៅឆ្នាំ១៨៣៥ វៀតណាមបានលើកព្រះអង្គម្ចាស់ក្សត្រីអង្គមី(១៨៣៥-១៨៤៧) ដែលមានអាយុ២០វស្សាឱ្យឡើងសោយរាជ្យ ហើយព្រះអនុជក្សត្រីគឺព្រះអង្គពៅ ត្រូវបានលើកឡើងធ្វើជាឧបរាជិនី និងក្សត្រីអង្គស្ងួន ជាកែវហ្វា។ ក្នុងរជ្ជកាលក្សត្រីអង្គមី (១៨៣៤-១៨៤០) កិច្ចការប្រទេសជាតិត្រូវធ្លាក់ទៅក្នុងដៃឧត្តមសេនីយត្រឿងមិញយ៉ាង ហើយគោលដៅ គឺប្រែក្លាយកម្ពុជាឱ្យទៅជាខេត្តនៃប្រទេសវៀតណាម។ ព្រះចៅសៀមរាមាទី៣ ទ្រង់តាមដានសភាពការណ៍នៅកម្ពុជាយ៉ាងប្រុងប្រយ័ត្ន។ នៅឆ្នាំ១៨៣៦ សៀមបានបញ្ជូនអ្នកអង្គម្ចាស់អង្គឯម ឱ្យគង់ប្រថាប់នៅបាត់ដំបង និងអង្គឌួង នៅមង្គលបុរី។

ត្រឿងមិញយ៉ាងបានរៀបចំវៀតណាមការូបនីយកម្មនៃរដ្ឋបាលខ្មែរ ដោយផ្លាស់ឈ្មោះភ្នំពេញ និងខេត្តខ្មែរទាំងអស់ទៅជាឈ្មោះវៀតណាម។ កងទ័ពវៀតណាមត្រូវបានរៀបចំសារជាថ្មី ហើយគេបានបញ្ជូនជនជាតិវៀតណាមឱ្យមករស់នៅកម្ពុជា។ ព្រះរាជា និងនាហ្មឺនសព្វមុខមន្ត្រីត្រូវ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្មៀកពាក់ដូចជាមន្ត្រីវៀតណាម។ នៅថ្ងៃបុណ្យវៀតណាម មន្ត្រីត្រូវទៅវត្ត វៀតណាម ដើម្បីគោរពរូបព្រះចៅក្រុងអណ្ណាមមិញម៉ាង (១៨២០-១៨៤១)។ នយោបាយនេះបានធ្វើឱ្យមានការបះបោរគ្រប់ទីកន្លែង។

នៅឆ្នាំ១៨៣៩ ឧត្តមសេនីយ ត្រឿង គុន បានបញ្ជូនបេសកជនឱ្យទៅជួបអង្គឯមនៅបាត់ដំបង ដើម្បីយាងព្រះអង្គមកសោយរាជ្យនៅឧដុង្គ។ នៅពេលដែលបេសកជនវៀតណាមឈាងទៅជួបអង្គឌួង នៅមង្គលបុរី ព្រះអង្គយល់ពីល្បិចរបស់វៀតណាម។ ដោយភ័យខ្លាចថា ថ្ងៃណាមួយអង្គឌួងនឹងក្លាយជាគូប្រជែងរបស់ព្រះអង្គ អង្គឯមបានទូលព្រះចៅព្រះរាមទី៣ ពីផែនការជាមួយវៀតណាម។ ក្រោយពីដឹងរឿងនេះ ព្រះណាំងក្លាវ (ព្រះរាមទី៣) បានបញ្ជូនមនុស្សឱ្យទៅនាំ អង្គឌួងត្រឡប់មកបាងកកវិញ។ ចំណែកឯអង្គឯមលួចធ្វើដំណើរសំដៅទៅឧដុង្គ តែត្រូវចៅហ្វាយខេត្តបាត់ដំបងចាប់មកវិញ។ តែអង្គឯមបានលួចរត់ដល់ខេត្តពោធិសាត់។ នៅពេលមកដល់ភ្នំពេញ ឧត្តមសេនីយ ត្រឿង គុន សម្លាប់មន្ត្រីដែលហែហមទ្រង់ ហើយបញ្ជូនអង្គឯមទៅក្រុងហ្វេ។

ឧត្តមសេនីយ ត្រឿង គុន ដែលមានអំណាចដល់កំពូលបានធ្វើទុក្ខបុកម្នេញប្រជារាស្ត្រ ចាប់ព្រះអម្ចាស់ក្សត្រីទាំងបួនដាក់គុក និងចាប់ឧត្តមមន្ត្រីបីនាក់ គឺឧកញ៉ាក្រឡាហោម ឧកញ៉ាយមរាជ និងឧកញ៉ាវាំងទៅដាក់គុកនៅកោះត្រឡាច ហើយបានចាប់ចងប្រពន្ធមន្ត្រីជាន់ខ្ពស់ទាំងនោះ។ ការបះបោរបើបម្រះបានកើតឡើងទូទាំងប្រទេស។

នៅដើមស.វ.ទី១៩ កម្ពុជាស្ទើរតែធ្លាក់ដល់ចំណុចសូន្យ ដោយសារតែសង្គ្រាមជាមួយសៀម និងវៀតណាម ព្រមទាំងការបះបោរនៅក្នុងស្រុកជាច្រើនទសវត្សរ៍។ ដើម្បីបញ្ចប់ទុក្ខវេទនារបស់ប្រជាជនខ្មែរ នៅឆ្នាំ ១៨៤១ នាហ្មឺនអស់មុខមន្ត្រីក៏សម្រេចចិត្តទៅបញ្ជូនឧកញ៉ាវិបុលរាជឡុង និងឧកញ៉ាសួគ៌ា លោកម៉ុក ទៅយាងព្រះបាទអង្គឌួង ពីប្រទេសសៀមមកឡើងសោយរាជ្យ។ ព្រះចៅណាំងក្លាវបញ្ជូនកងទ័ពសៀម និងខ្មែរនៅបាត់ដំបង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដឹកនាំដោយពញាបឌិន និងព្រះអង្គឌួងចូលមកវាយយកបានខេត្តពោធិ៍សាត់ ហើយបន្ទាប់ពីការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លាមក ព្រះអង្គឌួងបានចូលដល់ព្រះបរមរាជវាំងនៅឧដុង្គ ហើយកងទ័ពវៀតណាមដកថយមកភ្នំពេញ។ នៅដើមឆ្នាំ១៨៤៣ ស្តេចធៀវ ជី បានបញ្ជូនរាជវង្សានុវង្សមកម្ពុជាវិញ។ ដោយមានជំនួយពីទ័ពសៀមទ័ពខ្មែរបានដេញទ័ពវៀតណាមរហូតដល់មាត់ជ្រូក។

សន្តិភាពដ៏ផុយស្រួយបានកើតឡើងដល់ឆ្នាំ១៨៤៥ នៅពេលដែលសង្គ្រាមរវាងសៀម និងវៀតណាមបានចាប់ផ្តើមឡើងវិញ។ ពញាបឌិន បានត្រឡប់ទៅក្រុងបាងកក ដោយទុកព្រះអង្គឌួង អមដោយមន្ត្រីសៀមមួយ៣នាក់នៅឧដុង្គ។ មន្ត្រីចំនួន១២នាក់បានរៀបចំផែនការផ្តួលរំលំព្រះរាជា។ បន្ទាប់ពីផែនការនេះត្រូវបានបកអាក្រាត មន្ត្រីបួននាក់បានរត់រួច ហើយនៅខែកញ្ញា ឆ្នាំ១៨៤៥ វៀតណាមបានវាយលុកសារជាថ្មីចូលកម្ពុជា។ សង្គ្រាមរវាងសៀម និងវៀតណាមមិនមានអ្នកឈ្នះ និងអ្នកចាញ់ឡើយ។

បន្ទាប់ពីការចរចារគ្នាមក ប្រទេសសៀម និងវៀតណាមបានចុះសន្ធិសញ្ញានៅខែធ្នូ ឆ្នាំ១៨៤៥ ដើម្បីប្រគល់រាជបល្ល័ង្កខ្មែរមកព្រះអង្គឌួងវិញ។

៦.១.៤. ការរស់ឡើងវិញនៃកម្ពុជា និងកំណែទម្រង់ព្រះបាទអង្គឌួង

ព្រះបាទសម្តេចព្រះហរិរក្សរាមាអង្គឌួង (១៨២០-១៨៥៩) បានឡើងគ្រងរាជសម្បត្តិនៅក្រុងឧដុង្គ នៅឆ្នាំ១៨៤៧ ដោយមានតំណាងសៀម និងវៀតណាមជាអធិបតី។ ចាប់តាំងពីពេលនោះមក ប្រទេសខ្មែរបានស្គាល់នូវសុខសន្តិភាពបរិបូណ៌ ជាហេតុឱ្យព្រះអង្គអាចដាក់ចេញនូវកំណែទម្រង់រដ្ឋ និងបានកសាងឡើងវិញនូវប្រព័ន្ធអប់រំ។

ព្រះបាទហរិរក្សរាមាឥស្សរាធិបតីអង្គឌួង ជាព្រះរាជាដែលប្រកបដោយទសពិធរាជធម៌ ដែលយកព្រះទ័យទុកដាក់ដល់ការស្តារសន្តិភាពឡើងវិញ ការអភិវឌ្ឍកម្ពុជា និងបង្កើតនូវប្រព័ន្ធរាជការថ្មី។ សង្គ្រាមបាននាំមកនូវមហន្តរាយ ដោយសារភូមិស្រុកត្រូវបានដុតបំផ្លាញ ដីស្រែចម្ការត្រូវបោះបង់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចោលផ្លូវថ្នល់ និងស្ពានរង់ការខូចខាតជាដំណាំ។ អសន្តិសុខកើតមានឡើង លើផ្ទៃប្រទេស ប្រជាជនជួបទុក្ខវេទនា។

ក្នុងអំឡុងស.វ.ទី១៩ នៅពេលដែលមានជម្លោះរវាងពួកសៀម និងពួកវៀតណាម ក្នុងការកាន់កាប់ត្រួតត្រាកម្ពុជា វប្បធម៌ខ្មែរគឺសឹងផុតរលត់ ក៏ព្រោះថាវត្តអារាមត្រូវបានកម្ទេច និងបំផ្លាញចោល(រឿងបណ្ដាំតាមាស, ១៩០៨)។ ប្រព័ន្ធអប់រំនៃប្រទេសខ្មែរនៅដើមស.វ.ទី១៩ ត្រូវបានបំផ្លាញដល់ឫសគល់។ កម្ពុជានៅពេលនោះខ្វះអ្នកប្រាជ្ញ និងឧត្តមមន្ត្រីដែលមានប្រាជ្ញា ថាមពល និងសមត្ថភាពដែលអាចជួយសង្គ្រោះប្រទេសជាតិឱ្យរួចចាកផុតពីគ្រោះមហន្តរាយបាន (ឃីង ហុកឌី, ២០០៣)។ តាមការពិតប្រព័ន្ធអប់រំនៅកម្ពុជាមុនស.វ.ទី២០ ជាប្រព័ន្ធមួយ ដែលឈរលើមូលដ្ឋាននៃរចនាសម្ព័ន្ធសង្គម ដែលមិនមែន ស្ថាប័នទេ តែគឺបុគ្គលជាអ្នកដើរតួនាទីឈានមុខនៅក្នុងរដ្ឋបាល។ ក្នុងប្រព័ន្ធអប់រំបែបប្រពៃណីនេះ ព្រះសង្ឃរាជ បព្វជិត ព្រាហ្មណ៍អ្នកប្រាជ្ញកវីនិពន្ធគឺជាសសរស្ដម្ភនៃប្រព័ន្ធអប់រំតាមបែបប្រពៃណី (Mak Phoeun 1980, Edwards, P.2007)។ នៅពេលខ្វះចតុស្ដម្ភ នៃរដ្ឋបាលសាធារណៈ គឺឧកញ៉ាយមរាជ ឧកញ៉ាវាំង ឧកញ៉ាក្រឡាហោម និងឧកញ៉ាចក្រី ក៏អាចជាអ្នកប្រាជ្ញបានដែរ។ ជានិច្ចកាលព្រះមហាក្សត្រតែងតែជ្រើសរើសមន្ត្រី និងឧត្តមមន្ត្រី ក្នុងចំណោមអ្នកចេះដឹង និងកវីនិពន្ធ។ ឧត្តមមន្ត្រីគឺជាប្រភព និងជាសសរស្ដម្ភនៃអំណាច និងភាពស្មោះត្រង់ ហើយកិច្ចដំណើរការរបស់រដ្ឋត្រូវប្រព្រឹត្តទៅតាមរយៈទំនាក់ទំនងជាបុគ្គល (Mabbet, Chandler, Edwards, P.2007),។ នៅពេលដែលធនធានមនុស្សទាំងនោះបាត់បង់ទៅ ប្រព័ន្ធអប់រំក៏ដួលរលំដែរ។ព្រះបាទអង្គឌួងបានខិតខំប្រឹងប្រែងក្នុងការស្ដារ និងកសាងប្រព័ន្ធអប់រំខ្មែរឡើងវិញ នៅក្នុងរជ្ជកាលរបស់ទ្រង់ ដោយស្ដារឡើងវិញនូវព្រះពុទ្ធសាសនា និងសាលាវត្ត។

ការកសាងប្រទេសនៅក្នុងស.វ.ទី១៩ បានចាប់ផ្ដើមដំបូង ដោយលើកតម្កើងជាថ្មីនូវព្រះពុទ្ធសាសនា។ នេះក៏ព្រោះថាព្រះបាទអង្គឌួង បានចាត់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទុកវិស័យព្រះពុទ្ធសាសនាជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើឱ្យមានសន្តិភាព និងការរស់ឡើងវិញនៃកម្ពុជា (Hansen, 2008, Leclère, 1914 Chandler, 1996)។ ព្រះអង្គមានព្រះរាជបញ្ជាឱ្យប្រមូលនូវពុទ្ធវចនៈទាំងឡាយ មានគម្ពីរព្រះត្រៃ-បិដកជាដើម។ ការលើកតម្កើងជាថ្មីនៃវិស័យព្រះពុទ្ធសាសនានៅកម្ពុជា ក៏បានជួយក្នុងការបង្កើតលក្ខខណ្ឌចាំបាច់ ក្នុងការកសាងឡើងវិញនូវវិស័យអប់រំ។ ព្រះសង្ឃខ្មែរពីរអង្គ គឺសម្តេចព្រះមហាព្រហ្មមុនី និល ទៀង (១៨២៣-១៩១៣) (ព្រះភិក្ខុ និល ទៀង, ១៨៣៤) ដែលជាសម្តេចព្រះសង្ឃរាជសង្ឃនាយក ខាងគណៈមហានិកាយ និងសម្តេចព្រះវិមលធម្ម ប៉ានបញ្ញាសីលោ (១៨២៤-១៨៩៤) ដែលជាសម្តេចព្រះសុគន្ធាធិបតីសង្ឃនាយកខាងគណៈធម្មយុត្តិ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចបាននូវមហិច្ឆតារបស់ព្រះបាទអង្គឌួង ក្នុងការកសាងព្រះពុទ្ធសាសនាឡើងវិញ។ សម្តេចសង្ឃទាំងពីរព្រះអង្គបានទទួលនូវការគោរពជាខ្លាំង ហើយទ្រង់ក៏មានការអប់រំបែបពុទ្ធចក្របានយ៉ាងជ្រៅជ្រះ។ ព្រះបាទអង្គឌួង ទ្រង់និមន្តសម្តេចទាំងពីរព្រះអង្គឱ្យបង្រៀនព្រះត្រៃបិដកដល់សិស្សានុសិស្ស។ ព្រះតេជគុណ និល ទៀង បានរៀបចំឡើងវិញផ្នែករដ្ឋបាលសង្ឃ (Hansen, 2008)។ ព្រះបាទអង្គឌួង កាលនោះក៏បានជួសជុល និងកសាងព្រះវិហារនានា។ ព្រះបាទអង្គឌួង បាននាំគណៈធម្មយុត្តិកនិកាយពីសៀមមកដែរ ដោយបានសាងសង់វត្តធម្មយុត្តិកនិកាយនៅឧដុង្គ គឺវត្តសាលាគូ ឬវត្តអំពិលបី ហើយនៅពេលដែលព្រះបាទនរោត្តមចាកចោលក្រុងឧដុង្គមានជ័យមកភ្នំពេញ សម្តេចព្រះមហាសុគន្ធា-ធិបតី ប៉ាន ដែលជាសម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ក៏បាននិមន្តពីវត្តអំពិលបី មកគង់នៅវត្តវត្តបុទុមវតីរាជវរារាម (ស៊ិន ស៊ុវណ្ណនិ, ២០១២)។

ក្នុងរជ្ជកាលព្រះបាទអង្គឌួង ព្រះពុទ្ធសាសនាថេរវាទ ឬហីនយាន សិល្បៈខ្មែរ អក្សរសាស្ត្រ និងវប្បធម៌បានរស់រានមានជីវិតឡើងវិញ។

សេដ្ឋកិច្ចចំណុះប្រទេសជិតខាង៖ កម្ពុជាជាប្រទេសក្រីក្រខ្លាំង ដោយសារសេដ្ឋកិច្ចពឹងផ្អែកលើវិស័យកសិកម្មបែបបុរាណ សម្រាប់គ្រប់គ្រាន់តែ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បរិភោគក្នុងស្រុក។ កម្ពុជាជាប្រទេស ដែលបិទទ្វារមិនទទួលឥទ្ធិពលពីខាងក្រៅ។ ពាណិជ្ជកម្មក្រៅប្រទេសមានទំហំតិចតួច ដោយកម្ពុជានាំចេញតែភ្លុកដំរី ម្រេច ក្រវាញ ស្បែក និងខ្លឹមច័ន្ទ។ កម្ពុជាខ្ចីប្រមុះគេដកដង្ហើម ដោយពឹងផ្អែកទាំងស្រុងលើសេដ្ឋកិច្ចសៀម និងវៀតណាម។ ស្តេចខ្មែរមិនអាចជួបបរទេសបានទេ ប្រសិនបើគ្មានការអនុញ្ញាតពីសៀម និងវៀតណាម។

កំណែទម្រង់ព្រះបាទអង្គឌួង៖ ការកសាងប្រទេសនៅក្នុងស.វ.ទី១៩ បានចាប់ផ្តើមដំបូងដោយ៖ (១) លើកតម្កើងជាថ្មីនូវព្រះពុទ្ធសាសនា ដោយស្តារឡើងវិញនូវព្រះពុទ្ធសាសនា និងសាលាវត្ត និងបង្រៀនព្រះត្រៃបិដក និងបញ្ជាឱ្យកុមារចូលរៀនសាលាវត្ត (២) សាងសង់សាលាទាន សម្រាប់ធ្វើសង្ឃទាន និងធ្វើទានដល់ជនក្រីក្រ (៣) កែច្បាប់ និងតាក់តែងច្បាប់ថ្មី (៤) ជ្រើសតាំងអ្នកដែលមានចំណេះវិជ្ជាជ្រៅជ្រះជាមន្ត្រី (៥) ដាក់ទណ្ឌកម្មដល់មន្ត្រីជក់អាភៀន និងទុច្ចរិត (៦) មិនយកពន្ធពីពស្ត្រ និងមិនយកការប្រាក់ធ្ងន់ពេក (៧) បោះប្រាក់សម្រាប់ចាយ (៨) សាងសង់ផ្លូវពីឧដុង្គទៅកំពតកសាងកំពង់ផែសមុទ្រ និងសាងសង់សំពៅសម្រាប់ដឹកទំនិញទៅលក់នៅសិង្ហបុរី (៩) បញ្ជូននិស្សិតទៅរៀនភាសាបារាំង និងអង់គ្លេសនៅសិង្ហបុរីសម្រាប់បម្រើការងារក្នុងរាជការ។

ការគ្រប់គ្រងប្រទេស៖ ព្រះបាទអង្គឌួងបានកែទម្រង់រដ្ឋបាលបុរាណរបស់ខ្មែរ ឱ្យមានលក្ខណៈទំនើប ពង្រឹងសណ្តាប់ធ្នាប់សង្គម និងសន្តិសុខសង្គមលើផ្ទៃប្រទេស។ ព្រះអង្គរៀបចំឱ្យមានសវនការយ៉ាងទៀងទាត់ជាមួយនាហ្មឺនសព្វមុខមន្ត្រី ដើម្បីពិភាក្សា និងដោះស្រាយបញ្ហាធំៗរបស់ប្រទេសជាតិ។ ព្រះអង្គតែងតែយកព្រះទ័យទុកដាក់ដោះស្រាយពាក្យបណ្តឹងរបស់ប្រជាជន និងបានសុំឱ្យអ្នកប្រាជ្ញខ្មែរពិនិត្យច្បាប់ពីបរមបុរាណឡើងវិញ ជាពិសេសករមរតនីតិសាស្ត្ររបស់ព្រះបាទជ័យជេដ្ឋា ចាប់តាំងពីសតវត្សទី១៧ និងដើមសតវត្សទី១៨ ហើយដែលបង្កើតបានជាក្រមច្បាប់ ដែលមានឈ្មោះជា ក្រមកម្ពុជា (Les codes cambodgiens) ដែលក្លាយទៅជាមូលដ្ឋាននៃ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រព័ន្ធយុត្តិធម៌របស់កម្ពុជាមុនសម័យបារាំង។ កម្រងច្បាប់កម្ពុជាមានចំនួន ១៥០០ទំព័រ ត្រូវបានបោះពុម្ពនៅឆ្នាំ១៨៩១ ដែលចែកចេញជា២៨ក្បាល។

កំណែទម្រង់សេដ្ឋកិច្ចៈ ព្រះបាទអង្គឌួងបានកែទម្រង់ការគ្រប់គ្រងសេដ្ឋកិច្ចរបស់កម្ពុជា ឱ្យមានលក្ខណៈទំនើប លើកកម្ពស់ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស កាត់បន្ថយបន្ទុកពន្ធដារទៅលើប្រជាជនក្រីក្ររបស់ព្រះអង្គ និងរៀបចំបោះកាក់ប្រាក់ ដែលមានរូបហង្សជាសញ្ញា ដើម្បីប្រើប្រាស់ទូទាំងប្រទេស។ ព្រះអង្គបញ្ជាឱ្យសាងសង់ផ្លូវពីក្រុងឧដុង្គទៅកាន់កំពង់ផែទន្លេនៅកំពង់ហ្លួង នៅឆ្នាំ១៨៥២ និងសាងសង់ផ្លូវស្តេច ភ្ជាប់ឧដុង្គមានជ័យទៅនឹងកំពង់ផែសមុទ្រ ហើយនៅឆ្នាំ១៨៥៧ ព្រះអង្គបានសាងសង់ផ្លូវពីឧដុង្គមានជ័យទៅភ្នំពេញ។

កិច្ចការបរទេសៈ ព្រះបាទអង្គឌួង មានការព្រួយបារម្ភថា ថ្ងៃណាមួយកម្ពុជាអាចនឹងត្រូវប្រទេសជិតខាងលេបត្របាក់បាត់ពីផែនទីពិភពលោក។ ព្រះអង្គក៏បានផ្ញើញត្តិមួយទៅកាន់ព្រះចៅណាប៉ូឡេអុងទី៣ ស្នើសុំបារាំងជួយរំដោះប្រទេសខ្មែរ ចេញពីឥទ្ធិពលសៀម និងវៀតណាម តែមិនបានទទួលចម្លើយអ្វី។

ការងើបឡើងនៃវប្បធម៌ជាតិៈ អក្ខរកម្មភាសាខ្មែរមានវិបុលភាពជាខ្លាំងក្នុងរជ្ជកាលព្រះបាទអង្គឌួង ហើយទ្រង់ព្រះអង្គឯងក៏ជាអ្នកនិពន្ធដ៏ល្បីល្បាញផងដែរ។ ស្នាព្រះហស្តរបស់ព្រះអង្គមានៈ រឿងចម្ប៉ាថោង (១៨១០) រឿងកាកី (១៨១៥-នៅពេលទ្រង់មានព្រះជន្ម១៩វស្សានៅឡើយ) និងច្បាប់ស្រី (១៨៣៧)។

៦.២. អក្សរសិល្ប៍ពុទ្ធនិយមនៅស.វ.ទី១៨ និង១៩

ការវិភាគស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរផ្តោតលើទិដ្ឋភាពធំៗចំនួនបីគឺៈ អត្ថរូប អត្ថន័យ និងអត្ថរស។

អក្សរសិល្ប៍សម័យកណ្តាលមានដូចជាសិលាចារឹក (សិលាចារឹកជ័យ-នន្ទ) របាក្សត្រ ឬព្រះរាជពង្សាវតារ ក្រម-ក្បួន-តម្រា (Les codes cambodgiens)

ច្បាប់-សុភាសិត រឿងព្រេង រឿងល្បែង និងវីរកថា (ឃីង ហុកឌី, ២០០៣)។

៦.២.១. អត្តរូបនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ

៦.២.១.១. ប្រភពនៃអក្សរសិល្ប៍ពុទ្ធនិយម

អរិយធម៌ខ្មែរមានប្រភពចេញពីលទ្ធិព្រាហ្មណ៍និយមផង ជាពិសេសគឺអរិយធម៌ជំនាន់អង្គរ និងលទ្ធិពុទ្ធនិយមផង ដែលជាអរិយធម៌ខ្មែរជំនាន់ក្រោយអង្គរ។ ចលនាអក្សរសិល្ប៍បែបពុទ្ធនិយមមានរូបសេចក្តី និងសណ្ឋានដែលដកស្រង់ចេញពីប្រភពនៃគម្ពីរព្រះត្រៃបិដក។ ពោល គឺការយកគោលគំនិត និងទស្សនវិជ្ជាព្រះពុទ្ធសាសនាមកចុះបញ្ចាំង ក្នុងស្នាដៃអក្សរសិល្ប៍៖

១- វិន័យបិដក (ព្រះវិន័យ)

២- សុត្តន្តបិដក (ព្រះសូត្រ)

៣- អភិធម្មបិដក (ព្រះអភិធម្ម) ។

គេនិយមបែងចែកអក្សរសិល្ប៍ពុទ្ធនិយមជាពីរប្រភេទ៖

ទីមួយគឺអក្សរសិល្ប៍ពុទ្ធនិយមពិតដែលអ្នកនិពន្ធបានដកស្រង់ចេញពីគម្ពីរទសជាតក គឺជាប្រវត្តិរបស់ព្រះសក្យមុនីគោតមបរមសម្ពុទ្ធក្នុង១០ជាតិ ហើយចែងក្នុងរឿងទាំង១០។ រឿងទាំងនេះផ្តល់នូវជំបូន្មាន និងភាសិតសំខាន់ៗ ប្រកបដោយឧត្តមគតិ។ នៅក្នុងឆ្នាំ១៩៥៨ គណៈកម្មការរៀបចំកម្មវិធីសិក្សានៃក្រសួងអប់រំជាតិ បានបញ្ចូលរឿងសង្ខេបទសជាតក ក្នុងកម្មវិធីសិក្សា៖

(១) តេមិយជាតក និយាយពីការបំពេញនេក្ខម្មបារមី គឺការចេញបួសរបស់ពោធិសត្វ

(២) មហាជនកជាតក និយាយពីការបំពេញវិរិយបារមីគឺសេចក្តីព្យាយាមដ៏មុតមាំ

(៣) សុវណ្ណសាមជាតក និយាយពីការបំពេញមេត្តាបារមីគឺការកាន់ចិត្តមេត្តាករុណាចំពោះមនុស្សសត្វ

(៤) នេមិរាជជាតក និយាយពីការបំពេញអធិដ្ឋានបារមី គឺការតាំងចិត្តមាំក្នុងសីល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(៥) មហោសថជាតក និយាយពីការបំពេញបញ្ញាបារមីគឺអ្នកមានបញ្ញាដ៏លើសលប់
(៦) ភូរិទត្តជាតក និយាយពីការបំពេញសីលបារមី
(៧) ចន្ទកុមារជាតក និយាយពីការបំពេញខន្តីបារមី គឺការកាន់ចិត្តអត់ធ្មត់
(៨) នារទជាតក និយាយពីការបំពេញឧបេក្ខាបារមី គឺការកាន់ចិត្តជាកណ្តាល
(៩) វិធុរជាតក និយាយពីការបំពេញសច្ចបារមី គឺការកាន់ពាក្យទៀងត្រង់
(១០) មហាវេស្សន្តរជាតក និយាយពីការបំពេញទានបារមី គឺការចំណាយធនធានឱ្យទៅជាទានអ្នកដទៃ។

មូលហេតុអ្វីបានជាគេចាត់ទុករឿងទាំងនេះ ថាជាចលនាអក្សរសិល្ប៍ពុទ្ធនិយមពិត? អក្សរសិល្ប៍ពុទ្ធនិយមពិត គឺដោយសារជារឿងរបស់ព្រះពោធិសត្វ និងការកសាងបារមីដើម្បីត្រាស់ជាព្រះពុទ្ធ។ តួអង្គឯកប្រុសជាព្រះពោធិសត្វ ចំណែកតួអង្គឯកស្រីជាកន្សែរសពេជ្រ។

អក្សរសិល្ប៍ពុទ្ធនិយមពិត គឺជាអក្សរសិល្ប៍ដែលមានលក្ខណៈទេវនិយម មានអន្តរាគមន៍ពីព្រះឥន្ទ តែមិនឆ្លុះបញ្ចាំងពីតថភាពក្នុងសង្គមឡើយ។ ឧទាហរណ៍ រឿងមហាវេស្សន្តរជាតក គឺជារឿងដែលបានបង្ហាញពីព្រឹត្តិការណ៍សំខាន់តាមរយៈការបំពេញទានបរិច្ចាគទាំងប្រាំយ៉ាងរបស់តួអង្គព្រះពោធិសត្វព្រះនាមព្រះវេស្សន្ត ដែលមានធនបរិច្ចាគ គឺលះបង់ទ្រព្យសម្បត្តិជាទាន អង្គបរិច្ចាគ គឺលះបង់សរីរាង្គណាមួយជាទាន ជីវិតបរិច្ចាគ គឺលះបង់អាយុជីវិតជាទាន បុត្តបរិច្ចាគ គឺលះបង់កូនជាទាន និងភរិយាបរិច្ចាគ គឺលះបង់ប្រពន្ធជាទាន។ សំណួរដែលយើងសួរថា តើរឿងនេះមានពិតមែនក្នុងសង្គមទេ។ ទាល់តែព្រះទើបមានចិត្តដូច្នេះ។ អ្នកនិពន្ធដោះស្រាយបញ្ហា ដោយប្រើវិធីអហិង្សា ហើយបញ្ចប់រឿង ដោយការសរជាតិ។

ទីពីរគឺអក្សរសិល្ប៍ពុទ្ធនិយមក្លាយដែលអ្នកនិពន្ធបានដកស្រង់ចេញពីគម្ពីរ បញ្ញាសជាតក ដែលមានរឿងនិទានចំនួន៥០រឿង ដូចជារឿងគ្រងសុភមិត្រ រឿងព្រះសុធន រឿងគោតកុលកុមារ រឿងសព្វសិទ្ធិ រឿងមរណមាតា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រឿងចៅស្រទបចេកជាដើម (ម៉ុញ សារី, ២០១១)។ ហេតុអ្វីបានជាហៅថា ពុទ្ធនិយមក្លាយ? គឺដោយសារតែអក្សរសិល្ប៍នេះមើលទៅដូចពិតដែរ ដោយសារតែរឿងរ៉ាវទាំងឡាយមានមូលដ្ឋានពីទស្សនវិជ្ជាពុទ្ធសាសនា។ ក៏ប៉ុន្តែពុទ្ធនិយមក្លាយ គឺមកពីមិនពិត ពោលគឺជាអត្ថបទដែលទាក់ទងនឹងទស្សនៈក្នុងព្រះពុទ្ធសាសនតិចតួចតែប៉ុណ្ណោះ ហើយមិនមែនជារឿងក្នុងគម្ពីរព្រះត្រៃបិតកឡើយ។ ការតែងនិពន្ធអត្ថបទអក្សរសិល្ប៍ខ្មែរ និងច្បាប់ជាពាក្យកាព្យបានឈានដល់ចំណុច កំពូលក្នុងស.វ.ទី១៨-១៩។

ក្នុងការតែងនិពន្ធ កវីនិពន្ធប្រើប្រាស់នូវសិល្បវិធីជាច្រើន ដូចជាវចនវិធី (ការប្រើពាក្យ) វចនាវិធី (ការប្រើឃ្លាល្បះទាក់ទាញ) ឧបមានវិធី (ប្រៀបធៀបតួអង្គទៅនឹងអ្វីមួយ) សំវាទវិធី (តួអង្គឆ្លើយឆ្លងគ្នា) សន្ទេហវិធី (ធ្វើឱ្យចង់តាមដាន) ឯកវាទវិធី (និយាយតែម្នាក់ឯង) វណ្ណនាវិធី (លើកតួអង្គធម្មជាតិមកពណ៌នាដូចឃើញនឹងភ្នែកស្រស់) បដិវិធី (តួអង្គខុសគ្នា) ជាដើម។

៦.២.១.២. អ្នកនិពន្ធពីសតវត្សរ៍ទី១៧ ដល់១៩

ខ្ញុំសូមសម្រាំងជ្រើសរើសតែអ្នកនិពន្ធខ្មែរល្បីៗសម័យកណ្តាលតែមួយចំនួនប៉ុណ្ណោះ ៖

(១) ឧកញ៉ាកោសាធិបតី កៅ

ឧកញ៉ាកោសាធិបតី កៅ ជាកវីឯកក្នុងរជ្ជកាលព្រះបាទអង្គច័ន្ទទី២។ លោកត្រូវបានតែងតាំងជាចៅហ្វាយឃ្លាំងមណីរតន៍ក្នុងព្រះបរមរាជវាំង និងជាទីប្រឹក្សាច្បាប់របស់ព្រះមហាក្សត្រ។ លោកបានសរសេររឿង «ក្រុងសុភមិត្រ» នៅឆ្នាំ១៧៩៨។ រឿងនេះអ្នកនិពន្ធបានដកស្រង់ចេញពីរឿងក្នុងបញ្ញាសជាតក ត្រង់ជាតកទី៩ ជាភាសាបាលី ដែលលោកយកមកតែងជាពាក្យកាព្យខ្មែរ និងមានសេចក្តីសង្ខេបដូចតទៅ៖ «ព្រះរាជាព្រះនាមក្រុងសុភមិត្រ មានព្រះអនុជព្រះនាមអសុភមិត្រ ដែលចង់ធ្វើឃាតព្រះអង្គ ដើម្បីដណ្តើមរាជសម្បត្តិ។ ព្រះអង្គក៏នាំមហេសីនិងបុត្រគៀសព្រះអង្គ ដើម្បីកុំឱ្យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រជាជនលំបាកវេទនា។ លុះទៅដល់ទន្លេធំមួយ ក៏ដាក់បុត្រទាំងពីរទុក ហើយនាំមហេសីហែលទៅត្រើយម្ខាង។ នៅពេលត្រលប់មកវិញរកបុត្រមិនឃើញ ដោយសារមានគេលើកដាក់ទូកបាត់ទៅ។ នៅពេលដែលហែលឆ្លងទៅរកមហេសីនៅត្រើយម្ខាងទៀត មហេសីក៏ត្រូវគេចាប់ដាក់សំពៅទៀត។ ព្រះអង្គក៏យាងកាត់ព្រៃរហូតដល់នគរមួយឈ្មោះនគរតក្កសីលា ដែលឥតមានព្រះមហាក្សត្រ ហើយស្វែងរកអ្នកមានបុណ្យដើម្បីឡើងគ្រងរាជ្យ និងបានសុំឱ្យព្រះអង្គឡើងគ្រងរាជ្យ។ ក្រោយមកព្រះអង្គក៏បានជួបជុំជាមួយបុត្រទាំងពីរ និងមហេសីព្រះនាមកេសនីវិញ។»

បទភុជង្គលីលា

មើលផ្កាបុប្ផាស្រស់ស្រេច បូបុស្បរំលេច រីករុះសាយសព្វ។
ចម្ប៉ាក្តាំងរាំងឈ្មុយឈ្ងប់ ដោរដូចអ្នកអប់ ទាំងព្រៃព្រឹក្សា។
កាកែសចេកទេសយុថ្កា ម្លិះរួតម្លិះលា ខ្សឹងខ្សំស្នូរកើ។
មហាហិង្គុប្រយង្គុនួនស្រី ស្រឡិតមាលតី លាយលេចច្បាប្រាល។
លន្ទៃពុតធ្មេរន្ទាល រំចេកដាសដាល ដុះដោយទីទួល។
ព្រឹក្សាបុប្ផាជង្ហួរ ហាក់ដូចអ្នកព្យួរ សំយុងយោនយាន។
កន្ទងត្រាច់ត្រងសព្វសាន សៀងស្នូររូហាន ភ្លេងតូរ្យតន្ត្រី។
ត្រាច់ត្រើបជញ្ជាប់ភ្ញិនភ្ញី កេសររីកថ្មី ពិដោរសព្វសាយ។
ពណ៌នាព្រឹក្សាដោយថ្នល់ រុះរោយរាយផល អនេកត្រៀបត្រា។
ព្រួសព្រើងបុស្សបេងទន្ទា ទន្ទាប់កេកា សំរោងសំរង។
ស្មែស្មាច់លាយលេចអង្ក្រង ត្រៀបត្រាចភ្លូភ្លង ច្រេសជ្រួយក្រស្នា។
មង្ឃុតស្នុតសេដា ស្រល់ស្រូលធាំធា ត្រឡាត់ត្រឡក។
សម៉ពង្រងទូវធ្ងក ត្រៀកត្រាចប៉ប្រេក ខ្ទារខ្ទិតខ្នុរខ្នារ។
ស្វាតស្វាយក្រូចក្រាយរកា ពពេលពពារ កប្បាសក្របៅ។
ផ្តកផ្តៀតកង្រៀកតាក្រៅ ចាកចេកញ្ញិលញ្ញៅ ផ្ទឹករាំងក្រកោះ។
ត្រើលគ្រងលពង់លំពស់ រលួយរលោះ រលាយរលា។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្កាវផ្គុងផ្ចាផ្ចង់ពុទ្រា ត្រួយត្រល់ត្រៀលស្វា ទ្រមូងទ្រមួច។
មង្ឃុតល្មុតពោនពួច បុស្សបេងសង្ឃូច សង្ឃ័រសង្ឃា។
ក្រឡាញ់អង្គាញ់ចន្ទន៍ចារ សៀងព្រាសំព័រ ស្ដឹស្ដង់ស្ដឹស្ដៅ។
ពោធីពៃប្រេសជ្រៃត្រៀបត្រៅ បុស្សបេងបង្គៅ ក្រវាញក្រវ៉ាន់។
គរគុយរុយសណ្ដាន់ លំពស់លំពាន់ ដកពដកពាយ។
អំពៅក្របៅលេចលាយ លៀបលោតវល្លិវ៉ាយ វល្លិវែកទាស់ទាល។
សុក្រំរាំងភ្នំសត្បា កោដ្ឋកែវក្រូចឆ្មារ កន្ទោកន្ទៃ។
ក្រសាំងមានទាំងលាំងដៃ ភ្ជូភ្ជងឈ្វេឈ្វៃ រំដួញរំដេញ។
ក្រិន្ទាពុទ្រាឆ្មាឆ្មេញ ត្រីត្រាចប្រផេញ ខ្ទឹងក្ដម្ពសុរភី។
ម៉ោងជាងមាក់ប្រាងកាកី មាក់ដោកស្រឡី បង្គៅបង្គាវ។
ប្រេសជ្រួយប្រមួយខ្ទិតខ្ទារ ក្ដាតក្ដួចវល្លីយាវ វល្លិប្រេងផ្ទាល់មាន់។

(២) ឧកញ៉ាព្រះឃ្លាំង នង

ឧកញ៉ាព្រះឃ្លាំង នង ជាប្អូនបង្កើតរបស់ព្រះមាតានៃព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម។ លោកបានបួសរៀន និងបានធ្វើជាចៅអធិការនៅវត្តចតុទិសនៃក្រុងឧដុង្គដោយបានទទួលសមណ សក្ដិជាមហាព្រហ្មមុនី។ ឧកញ៉ាព្រះឃ្លាំង នង ជាកវីឯកនៅក្នុងរាជ្យព្រះបាទអង្គអេង និងព្រះបាទអង្គច័ន្ទ។ លោកបានសរសេរស្នាដៃខាងអក្សរសាស្ត្រជាច្រើន រហូតដល់បានឡើងងារជាឧកញ៉ាព្រះឃ្លាំង ជាងារចាងហ្វាងក្រុមព្រះរាជបណ្ឌិត និងជាព្រះរាជនិពន្ធរបស់ព្រះរាជាទៀតផង។ ស្នាដៃរបស់លោកមាន៖ ច្បាប់សុភាសិត (១៧៩០) លោកនយបករណ៍(១៧៩៤) បុញ្ញសារសិរសា(១៧៩៧) រឿង «គោគកុលកុមារ» (១៨០៤) ព្រះសមុទ្រ(១៨០៨ និងពង្សាវតារ (១៨១៨)។

នៅមានកវីបណ្ឌិតជាច្រើនទៀត ដែលបាននិពន្ធស្នាដៃនៅក្នុងស.វ. ទី១៨-១៩ តែមិនបានដាក់ឈ្មោះនៅលើស្នាដៃអក្សរសិល្ប៍របស់ខ្លួន ដូចជារឿងពុទ្ធិសែន ព្រះសុធន ទិព្វសង្វារ ហង្សយន្ត រាជកុល រតនាវង្ស សង្ខសិល្ប៍ជ័យ ជាដើម។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រឿង«គោគកុលកុមារ» មានសេចក្ដីសង្ខេបដូចតទៅ៖ «គោគកុលកុមារជាក្មេងកំព្រា ប្រកបរបរធ្វើចម្ការ។ ឃើញដូច្នោះ ព្រះឥន្ទ្របាននាំបុត្រីឱ្យមកធ្វើជាភរិយាគោគកុលកុមារ។ គូស្វាមីភរិយានេះស្រឡាញ់គ្នាណាស់ ហើយនាងជាភរិយាមានរូបឆោមល្អស្រស់អស់លើស្រី។ លុះបានដឹងដល់ព្រះបាទព្រហ្មទត្ត ក៏ប្រើរាជអាមាត្យឱ្យយកនាងទៅរាំងឱ្យបាន។ អាមាត្យបានចាប់គោគកុលកុមារបង្ខាំងទុក ភរិយាដឹងក៏លួចរត់។ គោគកុលកុមារបានដើររកភរិយាហើយបានត្មាតនាំផ្លូវរហូតដល់សួនច្បាររបស់បិតាក្មេក។ គោគកុលកុមារបានលួចទម្លាក់ចិញ្ចៀនចូលក្នុងក្អមរបស់កិលៀង នៅពេលស្រោចទឹកលើកាយរបស់ភរិយា ចិញ្ចៀនក៏ធ្លាក់ចូលក្នុងម្រាមព្រះហស្ត។ គេក៏បានដង្ហែគោគកុលកុមារចូលនគរ ហើយក្រោយមកគោគកុលកុមារក៏បានដណ្ដើមរាជ្យពីព្រះបាទព្រហ្មទត្ត។»

បទកាកគតិ

ព្រះបាទសត្តកុដ រាជាវិសុទ្ធ វិសេសត្រាស់ថា
ហៅកូនសំឡាញ់ ចង់ចេញឃ្លាតឃ្លា ទៅនគរា
ពារាណសី។

អាពុកបើកតាម ចិត្តពុំឃាត់ហាម កូនស្ងួនប្រិមប្រិយ
ចូរបាផ្គត់ផ្គង់ តម្រង់ស្មារតី គ្រប់គ្រងធរណី
នានាំរាស្ត្រផង។

តាមដោយទសពិធ រាជធម៌សុចរិត កុំឱ្យមានហ្មង
រង្គរាស្ត្រសព្វហាន ឥតមានភ័យផង តាមដោយគន្លង
ធម៌ព្រះទូន្មាន។

មួយគឺធម៌ថា ឱ្យសង់សាលា ជីកស្រះសង់ស្ពាន
ឧស្សាហ៍ខ្វល់ខ្វាយ ចែកចាយធនធាន ធ្វើបុណ្យឱ្យទាន

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សព្វថ្ងៃប្រក្រតី។

គំរប់ពីរចាំ រក្សាសីលប្រាំ លុះថ្ងៃអដ្ឋមី
ថ្ងៃឧបោសថ ស្រគត់ឥន្ទ្រិយ សូមសីលប្រាំបី
កាន់កុំខាតខាន។

ជាគំរប់បី ចូរបាប្រណី ដាក់ព្រះរាជទាន
ចិញ្ចឹមយោធា សេនាទាហាន បរិពារគ្រប់ប្រាណ
ថែទាំរក្សា។

ជាគំរប់បួន ចូរចិញ្ចឹមខ្លួន តាមដោយសម្មា
សមានបរិភោគ អធ្យោគអធ្យា កុំគិតបំពារ
បំពានទ្រព្យគេ។

ជាគំរប់ប្រាំ ចូរចងចិត្តចាំ កុំកាន់វៀចវេ
គិតដោះទុក្ខរាស្ត្រ ទាំងផ្កាសឱ្យថៃ ឱ្យជួនប្រើប្រែ
ព្រះទ័យឱ្យទន់។

ជាប្រាំមួយមាន តបៈឱ្យបាន ឈ្នះចិត្តលោភលន់
លះលែងទោសា មោហាទុជ៌ន បានបរិបូណ៌បុណ្យ
បំបាត់បាបបង់។

ជាប្រាំពីរសោត កុំឱ្យក្រេវក្រោធ ធុរធាបឱ្យរង់
ឱ្យរិះរំពឹង ជញ្ជឹងគិតក្នុង ហឫទ័យឱ្យត្រង់
ឱ្យត្រូវធម្មា។

គំរប់ប្រាំបី កុំបៀតជីវី ជីវិតហឹង្សា
មនុស្សសត្វឥតទោស សន្តោសមេត្តា អាសូរករុណា
ជួយជន្មជីវី។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាប្រាំបួនបទ ឱ្យមានអំណត់ អំណរខន្តី
សច្ចំបរមត្ថ កាន់កតវេទី គិតគុណជនទី
ជនកប្រជាន។

គំរប់ដប់ដោយ ធម៌ផ្តែផ្តាំឱ្យ មហាក្សត្រក្សេមក្សាន្ត
ត្រូវកទ្រង់សណ្តាប់ តាមច្បាប់បុរាណ កុំឱ្យបំពាន
បំពារក្រៅក្រឹត្យ។

បើក្សត្រឯណា គិតកាន់សីលា តាមដោយទសពិធ
រាជធម៌ទូន្មាន នឹងបានសម្រិទ្ធិ សម្រេចដូចចិត្ត
ដូចក្តីប្រាថ្នា។

ក្នុងលោកិយគាប់ កើតកេរ្តិ៍គំនាប់ គំនិតថ្លៃថ្លា
បរលោកនឹងបាន បិតឋានសួគ៌ា ដល់តុសិតា
សោយសម្បត្តិបុណ្យ។

(៣) ហ្មឺនកក្តីអក្សរ តន់

រឿង«សព្វសិទ្ធិ» និពន្ធដោយអ្នកនិពន្ធ ហ្មឺនកក្តីអក្សរតន់ នៅក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម ក្នុងឆ្នាំ១៨៩៩។ ប្រភពរឿងនេះត្រូវបានដកស្រង់ចេញពីគម្ពីរបញ្ញាសជាតកបាលី យកមកច្នៃជារឿងល្បើកក្នុងរចនាបទកំណាព្យពាក្យ៧។

ដំណើររឿងនេះមានដូចតទៅ៖ «កាលពីព្រះពុទ្ធនៅជាពោធិសត្វនៅឡើយ ទ្រង់បានកើតជាសត្វជៀបកប្បាស។ សត្វឈ្មោលធ្វើសំបុកឱ្យកូននៅជាមួយជៀបកប្បាសញីក្នុងព្រៃ។ ថ្ងៃមួយជៀបកប្បាសឈ្មោលទៅរកចំណីក៏ចុះក្រេបលំអងផ្កាឈូកជំមួយ។ ត្រូវកម្តៅផ្កាឈូកក៏ក្តោបជៀបកប្បាសឈ្មោលដល់យប់ជ្រៅ។ ចៃដន្យថ្ងៃនោះមានភ្លើងឆេះព្រៃ ជៀបកប្បាសញីមិនអាចយកកូនចេញពីសំបុកបានក៏បោកយំខ្លួនម្នាក់ឯង។ លុះជៀបកប្បាស

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឈ្មោលមកដល់ ជាប់ក្លិនផ្កាឈូកផង ជៀបកប្បាសញីយល់ច្រឡំស្មានថាមានស្រី ក៏ហើរចូលភ្លើងស្លាប់មួយរំពេច។ ជៀបកប្បាសឈ្មោលក៏ហើរចូលភ្លើងដែរ។

ជៀបកប្បាសឈ្មោលបានទៅកើតជាកូនសេដ្ឋី មានឈ្មោះថា សព្វសិទ្ធិ។ ជៀបកប្បាសញីកើតជាព្រះរាជធីតា មានឈ្មោះថា សុវណ្ណកេសរ។ សុវណ្ណកេសរមិនព្រមនិយាយជាមួយបុរសណាទាំងអស់។ ព្រះបាទព្រហ្មទត្តក៏ប្រកាសថា បើប្រុសណាអាចធ្វើឱ្យ សុវណ្ណកេសរនិយាយរកនឹងផ្សំផ្គុំឱ្យ។ ដោយសព្វសិទ្ធិអាចធ្វើឱ្យព្រះនាងនិយាយបាន ទ្រង់ក៏រៀបអភិសេកព្រះរាជធីតាជាមួយសព្វសិទ្ធិ។» រឿងនេះពាក់ព័ន្ធនឹងជំនឿថាមានជាតិក្រោយ។

ខ្ញុំសូមលើកឡើងពីសម្រស់នាងសុវណ្ណកេសរដូចតទៅ៖

បទពាក្យ៧

សម្តេចបិតុរង្គអង្គមាតុវេត ឱ្យនាមតាមភេទភាពនង្គប្រាណ
ឈ្មោះនាងសុវណ្ណកេសរសាន្ត ស្មោះស្មានស្មើស្ម័គ្រក្យប្រិតា។
លុះនាងចម្រើនព្រះជន្មគ្រប់ បានប្រាំដណ្តប់ព្រះវស្សា
រឹតល្អអស់អង្គទ្រង់រូបា ដូចទេពកញ្ញានាសួគ៌ស្រី។
ព្រះភក្រ្តកុំក្លួងដួងបុប្ផានំ ដូចកលព្រះចន្ទវែងស្មើ
ព្រះអង្គទ្រង់ដូចកិន្នរី ឆវីលឿងខ្ចីស៊ីទ្ធូនក្វាយ។
សុដន់ដោះតូចដូចទន្ទាប់- មាសផ្កាប់ជាប់នឹងព្រះកាយ
ក្រពុំក្បោះក្បំសមឆោមឆាយ ល្អចប់សព្វសាយកាយសព៌ាង្គ។
ទាំងរូបទាំងឫកក៏រម្យទម មិនតូចមិនធំសមរូបរាង
ដំណើរវិលាសនិងយាសយាង ហាក់ដូចជានាងស្រីសុជាតា។
ធម្មតាជាស្រីក្នុងដីដែន កពផែនត្បូងភ្នំសុមេរា
នឹងជ្រើសរើសរកស្រីឯណា ផ្ទៀងផ្ទឹមរូបាក៏ពុំបាន។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៦.២.២. អត្ថន័យនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ

ន័យសេចក្តីដ៏សំខាន់បំផុតនៃអក្សរសិល្ប៍បែបពុទ្ធនិយម គឺបង្ហាញពីជំនឿ និងជីវិតរបស់ព្រះពោធិសត្វ។ ក្នុងអក្សរសិល្ប៍ពុទ្ធនិយមក្លាយរឿង និងទំនាស់ឆ្លុះបញ្ចាំងពីរឿងព្រេងនិទានក្នុងគម្ពីរបញ្ញាសជាតក ដែលមានលក្ខណៈមនុស្ស លក្ខណៈសង្គម និងលក្ខណៈប្រជាជន ជាងអក្សរសិល្ប៍ពុទ្ធនិយមពិត ដែលមានលក្ខណៈទេវៈយ៉ាងខ្លាំងក្លា។ ក្នុងការដោះស្រាយបញ្ហាទៀតសោត អក្សរសិល្ប៍ពុទ្ធនិយមក្លាយ តួអង្គពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន តែនៅក្នុងអក្សរសិល្ប៍ពុទ្ធនិយមពិត គេតែងឃើញមានអន្តរាគមន៍របស់ព្រះឥន្ទ។ ឧត្តមគតិនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរផ្តោតលើការអប់រំ ឱ្យស្គាល់បុណ្យ និងបាបកម្ម និងផល អំពើល្អ និងអំពើអាក្រក់ ឱ្យខំប្រឹងតស៊ូ និងជឿជាក់លើខ្លួនឯង ដោយឆ្លុះបញ្ចាំងទស្សនៈក្នុងព្រះពុទ្ធសាសនា។

ទស្សនវិជ្ជាពុទ្ធសាសនាមានគោលដៅស្វែងយល់រកហេតុផលនៃសេចក្តីសុខ និងសេចក្តីទុក្ខ។ អរិយសច្ចៈបួនយ៉ាង៖ គឺទុក្ខ ហេតុរបស់ទុក្ខ និព្វាននិងមាគ៌ាឆ្ពោះទៅរកការរលត់ទុក្ខ។

ទស្សនវិជ្ជាពុទ្ធនិយមក្នុងអក្សរសិល្ប៍ពុទ្ធនិយមខ្មែរផ្តោតលើចំណុចសំខាន់ៗដូចតទៅ៖

១. ទ្រឹស្តីពុទ្ធនិយម គឺជាទ្រឹស្តីសន្តិភាព មិនបៀតបៀនគ្នា មិនឈ្លោះគ្នា មនុស្សជឿលើបុណ្យ និងបាប។

អ្នកនិពន្ធខ្មែរសម័យក្រោយអង្គរ ដែលយើងនិយមហៅថាអក្សរសិល្ប៍សម័យកណ្តាលបានបង្កើតស្នាដៃជាអក្សរសិល្ប៍ពុទ្ធនិយម ដោយសារអ្នកនិពន្ធជ្រើសរើសយករឿងក្នុងជាតកបែបបាលី (មានបញ្ញាសជាតក ឬជាតកក្នុងអដ្ឋកថានៃព្រះត្រៃបិដក) មកច្នៃតែងតាមចិត្តរបស់ខ្លួន ដើម្បីសម្រេចទៅតាមទស្សនសម័យនោះ គឺបញ្ហាល្អ អាក្រក់ បុណ្យ បាប ក្នុងកម្មផល និងអត្ថន័យនៃរឿងរ៉ាវជាច្រើននៅសម័យឧដុង្គ (លាង ហាប់អាន, ១៩៦៧)។ ប្រជាពលរដ្ឋខ្មែរយកវត្តអារាមជាទីសក្ការៈផង ជាកន្លែងដែលជួបជុំគ្នាផង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងជាកន្ទេងបណ្ដុះបណ្ដាលធនធានមនុស្សផងៗ នៅពេលជួបការលំបាក ប្រជាជនខ្មែរតែងតែនាំគ្នាបន់ស្រន់សុំសេចក្ដីសុខ សុំឱ្យគុណបុណ្យព្រះរតនត្រ័យ ជួយគេឱ្យរួចចាកពីទុក្ខផងទាំងពួងៗ ការលំបាកដែលកើតឡើង គឺជាកម្មផល នៅពេលអស់កម្ម យើងនឹងលែងលំបាកទៀតហើយៗ ដូច្នេះ ការលំបាកនេះគឺមានតែមួយរយៈទេៗ ត្រូវតស៊ូឡើងដើម្បីធ្វើឱ្យផុតវាលបីៗ

ក្នុងរឿងគ្រុងសុភមិត្រ៖

«ស្ដេចលោមព្រះប្អូន ហឫទ័យសោះសូន្យ ជាឱប្អូនអើយ
វេរាពៀរព្រេង កម្មឯងដល់ហើយ ព្រលឹងអូនអើយ
កុំសោយសោកាៗ»

ក្នុងរឿងសព្វសិទ្ធិ៖

«ហេតុបុណ្យបារមីពង្សពោធិ បានសាងអំពីអតីតា
ដល់ថ្ងៃនេះឯងជាអស្ចារ្យ សារិកាក្សិណក្ស័យប្រល័យជន្មៗ»

នៅពេលដែលប្រជាជនត្រូវរត់លួនធ្វងកាត់សង្គ្រាមយ៉ាងលំបាកវេទនា ព្រះពុទ្ធសាសនា និងអក្សរសិល្ប៍ពុទ្ធនិយមបានផ្ដល់ឱ្យប្រជាជនខ្មែរនូវសេចក្ដីសង្ឃឹមថា ដោយសារតែអំពើល្អរបស់ពួកគេ នោះថ្ងៃណាមួយគេនឹងមានសេចក្ដីសុខសប្បាយជាមិនខាន ដូចពាក្យស្លោកមួយបានពោលថា «ពូជព្រះជិនវង្សមិនស្លាប់ទេ គ្រាន់តែលំបាកមួយគ្រាតែប៉ុណ្ណោះ»ៗ ប្រការនេះ គឺជាមូលហេតុសំខាន់នៃការរីកកាលដាលនៃអក្សរសិល្ប៍ពុទ្ធនិយមនៅក្នុងសម័យឧដុង្គ ជាសម័យមួយដែលខ្មែរត្រូវធ្វងកាត់នូវសង្គ្រាមក្នុងស្រុកយ៉ាងរាំរ៉ៃៗ

២.តួអង្គក្នុងរឿងសុទ្ធសឹងតែជាមនុស្សពិតប្រាកដ មាននៅក្នុងសង្គមមនុស្សៗ ព្រះពុទ្ធជាមនុស្សពិតប្រាកដ៖ ពុទ្ធសាសនាជាបដិបទាផ្លូវប្រតិបត្តិជាកម្មនិយម ឬជាវិធីបំបាត់អវិជ្ជា និងតណ្ហាៗ មនុស្សគ្រប់រូបអាចប្រើសក្ដានុភាពខ្លួន ជាមនុស្សឱ្យបានសម្រេចភាពជាព្រះពុទ្ធបាន បើមានបំណង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មាំ និងមានវិរិយភាពធំ។ មនុស្សជាម្ចាស់ខ្លួនឯង ឥតមានអំណាចអ្វីមួយប្រសើរជាងវាសនាខ្លួនជាមនុស្សនេះទេ។

៣.ខន្តីធម៌ និងមេត្តាប្រោសប្រណី៖ ព្រះសម្ពុទ្ធទ្រង់មានព្រះហឫទ័យទូលាយ និងប្រកបដោយខន្តីធម៌ មេត្តាប្រោសប្រណីសន្តោសសាវក និងប្រទានការយោគយល់ទៅវិញទៅមកទៀតផង។ ទ្រង់ត្រាស់ទូន្មានឱ្យពិចារណាហ្មត់ចត់ ទើបសម្រេចចិត្ត ជាការប្រសើរបំផុត។ អ្នកគ្រប់គ្នាមិនត្រូវលើកដម្កើងសរសើរតែលទ្ធិសាសនារបស់ខ្លួន ហើយប្រទុស្តលទ្ធិសាសនាដទៃទេ។

៤.សច្ចធម៌៖ អ្នកស្វែងរកសច្ចធម៌មិនមានប្រយោជន៍អ្វីនឹងដឹងថាសច្ចធម៌នេះកើតមកពីណាទេ។ កិច្ចការជាសារវន្ត គឺការរកឃើញធម៌ពិតហើយបាន លុះធម៌នោះដោយប្រពៃ។ ជំនឿក្នុងព្រះពុទ្ធសាសនា ជាជំនឿប្រកបដោយហេតុផល (Cause et effet) ជាជំនឿប្រកបដោយវិចារណញ្ញាណ (Raisonnement) ពោលគឺសទ្ធា ដែលជាជំនឿប្រកបដោយបញ្ញា (Confiance = confidence et sagesse)។ ជំនឿពុទ្ធសាសនាសំដៅយកការឃើញច្បាស់ ការដឹងច្បាស់ និងការយល់ច្បាស់។

៥. អរិយសច្ចធម៌៖ អរិយសច្ចធម៌ បួនប្រការនោះគឺ៖

ទីមួយទុក្ខជាសេចក្តីពិត មានជីវិត គឺមានទុក្ខ

ទីពីរហេតុដែលនាំឱ្យកើតទុក្ខ ព្រោះអវិជ្ជានិងតណ្ហា

ទីបីការរលត់ទុក្ខជាសេចក្តីពិត ដោយបំបាត់អវិជ្ជា និងតណ្ហា ដែលជាប្រភពដើមនៃទុក្ខ។

ទីបួនមាគ៌ាដែលនាំទៅកាន់រលត់ទុក្ខជាសេចក្តីពិត។ មាគ៌ាដែលនាំទៅកាន់រលត់ទុក្ខ គឺជា មជ្ឈិមា បដិបទា«ផ្លូវកណ្តាល» ដែលប្រកបដោយអង្គ៨ប្រការដ៏ប្រសើរគឺ៖ (១) សម្មាទិដ្ឋិ (ការយល់ត្រូវ) (២) សម្មាសង្កប្ប (ការត្រិះរិះត្រូវ) (៣)សម្មាវាចា (វាចាត្រូវ) (៤) សម្មាកម្មន្ត (ការងារត្រូវ) (៥) សម្មាអាជីវ (ការចិញ្ចឹមជីវិតត្រូវ) (៦) សម្មាវាយាម (ការព្យាយាមត្រូវ) (៧)

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្មាសតិ (ការរលឹកត្រូវ) (៨)សម្មាសមាធិ (ការតម្កល់ចិត្តត្រូវ) ។

៦.២.៣. អត្ថរសនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ

ដោយសារតែអក្សរសិល្ប៍ពុទ្ធនិយមក្លាយភាគច្រើនសរសេរជាកំណាព្យ ខ្ញុំសូមលើកយកអក្សរសិល្ប៍កំណាព្យខ្មែរយកមកបកស្រាយ ដូចតទៅ៖

១) ទិដ្ឋភាពអក្សរសាស្ត្រនៃការវិវត្តអក្សរសិល្ប៍កំណាព្យខ្មែរ

ខ្មែរចាប់សរសេរកំណាព្យជាយូរលង់ណាស់មកហើយ។ គេឃើញមានសិលាចារឹកតែងជាកំណាព្យ ជាភាសាខ្មែរបុរាណ និងជាភាសាសំស្ក្រឹត ចាប់តាំងពីសតវត្សរ៍ទី៩មកម៉្លេះ។

ចាប់តាំងពីសតវត្សរ៍ទី១៤ នៅពេលដែលពុទ្ធសាសនាថេរវាទត្រូវបាននាំចូលកម្ពុជា ជំនួសព្រហ្មញ្ញសាសនា ភាសាបាលីចាប់ផ្តើមប្រើប្រាស់ជាភាសាយាន។ កវីនិពន្ធខ្មែរក៏ចាប់ប្រើប្រាស់ភាសាបាលី ក្នុងការនិពន្ធធម៌ និងតែងកំណាព្យ។

វណ្ណកម្មអក្សរសិល្ប៍សម័យក្រោយអង្គរ ឬសម័យកណ្តាល គឺស្ទើរតែ ១០០ភាគរយ ជាអក្សរសិល្ប៍ពាក្យកាព្យ ហើយមានតែពីរបីប៉ុណ្ណោះជាពាក្យរាយ។

មូលហេតុអ្វីបានជាស្នាដៃអក្សរសិល្ប៍ភាគច្រើនសុទ្ធសឹងជាកំណាព្យ?

ប្រជាជននៅជំនាន់នោះភាគច្រើនលើសលុបមិនចេះអក្សរ។ នៅពេលនោះមិនទាន់មានយុទ្ធនាការរំដោះគ្រោះមិនចេះអក្សរនៅឡើយ។ ដូច្នេះ អ្នកចេះដឹងមានតិចតួច។ កវីនិពន្ធក៏ត្រូវសម្របខ្លួនតាមតម្រូវការសង្គម ដោយផ្តោតយកការនិទានតៗគ្នា ជាវិធីសាស្ត្រផ្សព្វផ្សាយស្នាដៃអក្សរសិល្ប៍។ ការសរសេរកំណាព្យមានសោភ័ណជាច្រើន ធ្វើឱ្យមានភាពទាក់ទាញ ងាយស្រួលចងចាំ និងទន្ទេញចាំមាត់។

ដើម្បីឱ្យមានភាពទាក់ទាញអ្នកនិពន្ធបានរៀបចំអក្សរសិល្ប៍ពុទ្ធនិយមនេះជាកំណាព្យ ដែលជាកម្រងពាក្យសម្តី មានន័យចាប់ចុងចួន ណែងណង

មានបង្វាក់ សូរសៀង សំនៀងពីរោះរណ្ដំៗ កំណាព្យខ្មែរមានសោភ័ណផ្សេងៗ ដូចតទៅ៖

នៅចុងសតវត្សរ៍ទី៦ សម័យចេនឡា គេឃើញមានកំណាព្យជាបទ បថ្យាវត្ត៖

ត្រដោលបោលបាញ់លាបខ្លាញ់គីង្គក់

ត្រដោលដេកលក់គីង្គក់លោតថើបៗ

នៅសម័យក្រោយអង្គរ ចាប់ពីសតវត្សរ៍ទី១៥មក គេឃើញមាន កំណាព្យតែងជា៥បទៗ រឿងរាមកេរ្តិ៍ ពីខ្សែ១ ដល់១០ និងរឿង ល្បើកអង្គរវត្ត របស់អ្នកប៉ាងតាត តែងជា៥បទ គឺ៖

១.បទពំនោល៖

សេចក្ដីពោល គឺជាសេចក្ដីបើកបទ ក្នុងការសម្ដែងល្ខោនៗ

២.បទព្រហ្មគីតិ៖ ចម្រៀងព្រះព្រហ្ម ដែលលន្លង់លន្លោចដើម្បីសម្ដែង ទុក្ខសោក ការនិរាសព្រាត់ប្រាសៗ

៣.បទកាកគតិ៖ ដំណើរក្អែក ប្រើក្នុងការសន្ទនា និងក្នុងសេចក្ដីផ្ដើម រឿងៗ

៤.បទភុជង្គលីលា៖ ដំណើរនាគ ដែលមានលក្ខណៈទន់ភ្លន់ អែនអន ផ្អែមល្ហែម ប្រើប្រាស់ក្នុងការរៀបរាប់ពិពណ៌នា និងការស្ញើចសរសើរៗ

ច្បាប់ស្រី៖

«នេះបទកំណត់ចង់ជា កុជង្គលីលា ចង់ជាច្បាប់ស្រីៗ
កាលនាងឥន្ទ្ទតី ចរចាកតាមប្ដី បណ្ដូកយក្សាៗ
នាងវិមលាជាមាតា បើកបន្ទូលថា ហៃកូនពិសីៗ
នាងនឹងត្រាច់ត្រង់តាមប្ដី ចេញចាកអំពី ពិភពនាគនេះៗ

៥.បទបន្ទោលកាក៖ ដំណើរកង្កែប លោតឈប់ៗ ប្រើជាត្នុកកំប្លែង ក្រមាច់ក្រមើមៗ

នៅសម័យក្រោយៗចាប់ពីសតវត្សរ៍ទី១៩ និង២០ កវីនិពន្ធខ្មែរតែង

កំណាព្យជាបទថ្មីៗ ដូចជាបទពាក្យ៧, ពាក្យ៨, ពាក្យ៩, ពាក្យ១០, ពាក្យ១១ ដែលកើតឡើងនៅចុងសម័យកណ្ដាល ហើយដែលកវីនិពន្ធប្រើបទនេះក្នុងចម្រៀងផ្សេងៗផងដែរ។

រឿងសព្វសិទ្ធិ តែងដោយហ្លួងកក្តីអក្សរគន់ រៀបរៀងជាបទពាក្យ៧។

ក្រោយមកទៀតមានបទបំភ្លៃច្រើនទៀត ដូចជាបទកង្កែបលោតលើគោក បទកង្កែបលោត កណ្តាលស្រះ បទអក្សរលូន បទសត្វកាងស្ទាប បទអើយក៉ាៗល។

ខាងក្រោមនេះ គឺបទគោព័ទ្ធស្ទឹង៖

ប្រាសាទអង្គរត្រឹះជាតិខ្មែរ ខ្មែរយើងត្រូវតែថែឱ្យគង់
គង់កេរ្តិ៍ដំណែលតដៅពង្ស ពង្សយើងជាវង្សសាងប្រាង្គប្រា។

ទំព័រប្រវត្តិសាស្ត្រខ្មែរដ៏ឈឺចាប់បានបណ្តុះកវីនិពន្ធជាច្រើនជំនាន់ ដើម្បីធ្វើការតស៊ូតាមរយៈកំណាព្យដើម្បីឱ្យវប្បធម៌ជាតិបានរស់។ ម៉្យាងវិញទៀត កវីនិពន្ធជំនាន់នោះ មានការជួយទំនុកបម្រុង និងឧបត្ថម្ភដោយមជ្ឈដ្ឋានផ្លូវការ ហើយព្រះមហាក្សត្រក៏តែងតែយកព្រះទ័យទុកដាក់លើកវីនិពន្ធណាស់ ដោយផ្តល់គោរមងារ និងតែងតាំងកវីនិពន្ធឱ្យកាន់ការធំក្នុងរាជការទៀតផង។

ខ្ញុំសូមរៀបរាប់ដូចតទៅ៖

១. ល្បើកអង្គរ ដោយអ្នកប៉ាងតាត ឆ្នាំ១៦២០។

២. កាព្យនិរាស ច្បាប់ព្រះរាជសម្ភារ ដោយព្រះរាជសម្ភារ ឆ្នាំ១៦៣៤។

៣. សិលាចារឹកអង្គរវត្ត ដោយបណ្ឌិត ជ័យ នន្ទ ឆ្នាំ១៧០១។

៤. រឿងខ្យងស័ង្ខ ចុងសតវត្សរ៍ទី១៧។

៥. រឿងគ្រុងសុភមិត្រ ដោយឧកញ៉ាកោសាធិបតី កៅ ចុងសតវត្សរ៍ទី១៨។

៦. ច្បាប់សុភាសិត លោកនយបករណ៍ ភោគកុលកុមារ រឿងវរនេត្រ-

វរនុជ រឿងព្រះសមុទ្ទ ដោយព្រះឃ្លាំង នង ចុងសតវត្សរ៍ទី១៨ និងដើមសតវត្សរ៍ទី១៩។

៧. រឿងដាវរឿង ដោយឧកញ៉ាចក្រី កែវ ឆ្នាំ១៧៤១។

៨. រឿងនាងកាកី ជាស្នាព្រះហស្តព្រះបាទអង្គឌួង ឆ្នាំ១៨១៥ (ព.ស. ២៣៥៨)។

៩. រឿងល្បើកជេតពន ដោយឧកញ៉ាសោទសខែក ឆ្នាំ១៨១៥។

១០. រឿងចម្ប៉ាថោង ឆ្នាំ១៨១០។

១១. រឿងរបាក្សត្រ ដោយព្រះបទុមបារមី ពេជ្រ ឆ្នាំ១៨១៨។

១២. រឿងមុជលិន ដោយបណ្ឌិត សំអាត ឆ្នាំ១៨៣៣។

១៣. រឿងព្រះជិនវង្ស ដោយអារិយគា មុនី ឆ្នាំ១៨៥៦។

១៤. រឿងពេជតា ដោយធម្មបញ្ញា ម៉ែន ឆ្នាំ១៨៥៧។

១៥. រឿងវិមានចន្ទ ដោយឧកញ៉ាធិបតី យ៉ែម ឆ្នាំ១៨៥៨។

១៦. ល្បើកស្រីវិជ័យ ដោយពញាវិជិត្រស្រី ឆ្នាំ១៨៥៨។

១៧. រឿងទេវន្ទ ល្បើកចចក ដោយឧកញ៉ាសន្ធរម៉ុក ឆ្នាំ១៨៥៩។

១៨. រឿងទុំទាវ ដោយព្រះបទុមថេរសោម ឆ្នាំ១៩១៦។

ក្រៅពីនេះនៅមានរឿងស្រដៀងគ្នាផ្សេងៗទៀត ដែលមិនបានបញ្ជាក់ពីអ្នកនិពន្ធ ហើយដែលខ្ញុំមិនបានលើកឡើងដោយសារតែមិនមានពេលគ្រប់គ្រាន់។

ចំណែកឯស្នាដៃអក្សរសិល្ប៍ប្រភេទពាក្យកាយមានៈ សិលាចារឹកនគរវត្តពីសតវត្សរ៍ទី១៦ និងរឿងមហាវេស្សន្តរជាតក ដែលកែសម្រួលដោយលោកញ៉ុក ថែម។

អក្សរសិល្ប៍ពុទ្ធនិយម គឺជាប្រភេទអក្សរសិល្ប៍ដែលតែងជាពាក្យកាព្យតាមលំនាំសាច់រឿងនៃទសជាតក និងបញ្ញាសជាតក នៅក្នុងអំឡុងសតវត្សរ៍ទី១៨១៩។

អក្សរសិល្ប៍កំណាព្យខ្មែរ ជាពិសេសអក្សរសិល្ប៍ពុទ្ធនិយមសម័យ

ក្រោយអង្គរ ពិតជាកំណាប់វិជ្ជាមហាសាលរបស់ខ្មែរពិតមែនៗ ការវិវត្តនៃអក្សរសិល្ប៍កំណាព្យខ្មែរឆ្លុះបញ្ចាំងពីការវិវត្តនៃអក្សរសាស្ត្រខ្មែរជារួម ពីការសរសេរជាភាសាបាលីសំស្រ្កឹត និងខ្មែរបុរាណ និងខ្មែរកណ្តាលមកសរសេរជាភាសាខ្មែរក្នុងចុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០ ទាំងការវិវត្តខាងផ្នែកក្បួនវេយ្យាករណ៍ ការសរសេរពាក្យដ៏សម្បូណ៌បែបដែលអាចចាត់ទុកជាបេតិកភណ្ឌអរូបីនៃជាតិខ្មែរយើង ការតែងកំណាព្យជាបទដ៏ច្រើនសន្ធឹកសន្ធាប់ដែលឆ្លុះបញ្ចាំងពីភាពរស់រវើក និងការចេះច្នៃប្រឌិតរបស់កវីនិពន្ធខ្មែរៗ

គោលដៅនៃសៀវភៅនេះ គឺចង់គាស់កំណាប់មហាសាលមិនអាចកាត់ថ្លៃបាន ដែលកប់ចោលយ៉ាងយូរ ដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយបានយល់ដឹង និងចេះឱ្យតម្លៃលើទ្រព្យសម្បត្តិដ៏សម្បូណ៌បែបនេះ ហើយចេះអភិរក្សរក្សាទុកដល់ជនានុជនជំនាន់ក្រោយ ជាទ្រព្យជាប់អាត្មាៗ

៦.៣. ការបណ្តុះបណ្តាលធនធានមនុស្ស និង ទំនើបភាវូបនីយកម្មភាសាខ្មែរ

៦.៣.១. ការបណ្តុះបណ្តាលធនធានមនុស្ស

អត្ថបទនៃសិលាចារឹកនគរវត្តបង្ហាញឱ្យឃើញថា ភាសាខ្មែរសម័យកណ្តាលមិនទាន់មានការឯកភាពគ្នាក្នុងការសរសេរអក្ខរាវិរុទ្ធ មិនទាន់មានវិធានក្នុងការសរសេរពាក្យកម្ចីពីបាលី-សំស្រ្កឹតឱ្យបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធដើម និងមិនទាន់មានក្បួនច្បាប់វេយ្យាករណ៍ពេញលេញនៅឡើយៗ

នៅក្នុងរជ្ជកាលព្រះបាទអង្គឌួង ការស្តារឡើងវិញនូវវប្បធម៌ខ្មែរ គឺការបណ្តុះបណ្តាលធនធានមនុស្ស តាមរយៈការលើកតម្កើងព្រះពុទ្ធសាសនា និងការសិក្សាគម្ពីរព្រះត្រៃបិដក និងការលើកកម្ពស់អក្សរសិល្ប៍ ដែលធ្វើឱ្យអក្ខរកម្មភាសាខ្មែរមានវិបុលភាពជាខ្លាំង ដើម្បីបង្កើតលក្ខខណ្ឌចាំបាច់ក្នុងការកសាងឡើងវិញនូវវិស័យអប់រំៗ កំណែទម្រង់វិស័យអប់រំរបស់ព្រះបាទអង្គឌួង មានរួមបញ្ចូលទាំងការកសាងឡើងវិញនូវបណ្ណាល័យ និងការប្រមូល

គម្ពីរព្រះពុទ្ធសាសនា ដែលបានបាត់បង់ក្នុងអំឡុងពេលសង្គ្រាម ការប្រមូលកុមារឱ្យចូលរៀននៅតាមសាលាវត្ត ការទំនុកបម្រុងដល់មន្ត្រីខ្លះ ដើម្បីសិក្សាភាសាបរទេសនៅប្រទេសសិង្ហបុរី និងការរៀនសូត្រភាសាបាលី និងគម្ពីរព្រះត្រៃបិដក (លាង ហាប់អាន, ១៩៦៥)។

នៅក្នុងសម័យអាណាព្យាបាលនៅពាក់កណ្ដាលទី២នៃស.វ.ទី១៩ បារាំងបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសម្បត្តិវប្បធម៌។ អ្នកស្រាវជ្រាវបារាំងជាច្រើនបានចូលរួមចំណែកក្នុងការស្រាវជ្រាវ និងអភិរក្សវប្បធម៌ និងអរិយធម៌ខ្មែរ។ ការអភិវឌ្ឍធនធានមនុស្សក្នុងសម័យអាណាព្យាបាលបារាំងត្រូវបានលើកកម្ពស់ តាមរយៈការអនុវត្តវិធានការពីរសំខាន់ៗ ៖ ទីមួយ-ការបញ្ជូននិស្សិតកម្ពុជាឱ្យទៅរៀននៅតាមគ្រឹះស្ថានសិក្សានៅបារាំង និងនៅវៀតណាម និងទីពីរ-ការបង្កើតប្រព័ន្ធអប់រំផ្លូវការ តាមរយៈការបង្កើតសាលារដ្ឋខ្មែរ-បារាំងនៅកម្ពុជា។

ដើម្បីពង្រឹងរដ្ឋបាលអាណានិគម លោក August Pavie បានផ្ដួចផ្ដើមគំនិតបង្កើតសាលាកម្ពុជា (École Cambodgienne) នៅទីក្រុងប៉ារីស ហើយបានជ្រើសរើសកូនមន្ត្រី ជាន់ខ្ពស់ខ្មែរចំនួន១៣នាក់ ដើម្បីយកទៅបណ្ដុះបណ្ដាល ដើម្បីប្រើប្រាស់ក្នុងរដ្ឋបាលអាណានិគម។ ក្នុងឆ្នាំ១៨៨៦ សាលាកម្ពុជា ត្រូវបានបង្កើតឡើងនៅទីក្រុងប៉ារីស ហើយពីឆ្នាំ១៨៨៥ ដល់១៨៨៩ សាលានេះបណ្ដុះបណ្ដាលតែនិស្សិតកម្ពុជាប៉ុណ្ណោះ។ ក្នុងចំណោមនិស្សិតដែលទទួលការបណ្ដុះបណ្ដាលដំបូង មានអនាគតសេនាបតីក្រសួងសិក្សាធិការ និងយុទ្ធនាធិការ ពេជ្រ ប៉ុណ្ណ ដែលជាកូនឧកញ៉ាមេត្រីកូតុន និងអនាគតនាយករដ្ឋមន្ត្រី ជួន សម្បត្តិ (១៨៦៤-១៩៥០) ផងដែរ។

នៅដើមសតវត្សទី២០ «អត្តសញ្ញាណជាតិខ្មែរ» ត្រូវបានបង្កើតតាមរយៈការស្រាវជ្រាវពីវប្បធម៌ និងអារ្យធម៌ខ្មែរ ដើម្បីឱ្យជនជាតិខ្មែរមានមោទនភាពឡើងវិញ បន្ទាប់ពីការបាត់បង់ជំនឿលើខ្លួនឯងដោយសារមហន្តរាយនៃសង្គ្រាមរាប់រយឆ្នាំ ជាពិសេសតាមរយៈការបង្កើតសាលាបារាំង

ចុងបូព៌ា។ អត្តសញ្ញាណខ្មែរប្រាស្រ័យគ្នាប់គ្នា តាមរយៈមនោសញ្ចេតនា ជំនឿ សាសនា ភាសា ទំនៀមទម្លាប់ ប្រពៃណី សិល្បៈ សំណង់ សង្គម ការរស់នៅ របស់ជនជាតិខ្មែរ។ល។ (ហម ឆាយលី,២០១០)

ក្នុងឆ្នាំ១៩០០ អាជ្ញាធរបារាំងបានចេញប្រកាសស្តីពីការអភិរក្ស បេតិកភណ្ឌប្រវត្តិសាស្ត្រនៅជ្រោយឥណ្ឌូចិន ហើយលោក Étienne Lunet de Lajonquière ត្រូវបានតែងតាំងឱ្យធ្វើការសិក្សា និងរៀបចំបញ្ជីប្រាសាទបុរាណ ខ្មែរ (Edwards, P.2007)។

បេសកកម្មអចិន្ត្រៃយ៍បុរាណវិទ្យានៅឥណ្ឌូចិន ត្រូវបានបង្កើតឡើង ដោយក្រឹត្យចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៨៩៨ ដែលស្ថិតនៅក្រោមឱវាទអគ្គ-ទេសាភិបាលឥណ្ឌូចិន (មាត្រា១) ក្នុងគោលដៅធ្វើការស្រាវជ្រាវបេតិកភណ្ឌ បុរាណវិទ្យា និងអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ និងចូលរួមចំណែកក្នុងការសិក្សា អរិយធម៌ឥណ្ឌា ចិន ម៉ាឡេ ។ល។ នៅក្នុងឆ្នាំ១៩០០ បេសកកម្មនេះត្រូវបាន ដូរឈ្មោះទៅជាសាលាបារាំងចុងបូព៌ា (EFEO) ហើយប្រធានាធិបតីបារាំង Émile Loubert បានចេញក្រឹត្យចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩០១ ដើម្បីទទួល ស្គាល់ស្ថាប័នស្រាវជ្រាវនេះ។ សាលាបារាំងចុងបូព៌ា បានចូលរួមចំណែក ក្នុងការសិក្សាស្រាវជ្រាវអំពីវប្បធម៌ និងអរិយធម៌ខ្មែរ ជាពិសេសប្រាសាទ អង្គរ (Edwards, P. 2007) ដែលជាដួងព្រលឹងរបស់ជាតិខ្មែរ និងដែលបង្កើតឡើង នូវស្មារតីស្នេហាជាតិ និងជាតិនិយម និងអត្តសញ្ញាណខ្មែរក្នុងចំណោម ប្រជាជន និងបញ្ញវន្តខ្មែរ។ សាលាបារាំងចុងបូព៌ានេះក៏បានចូលរួមចំណែក ផងដែរ ក្នុងការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា ដូចជាការបញ្ជូន សម្តេចជួន ណាត និងសម្តេចហួត តាត ឱ្យទៅរៀនភាសាសំស្ក្រឹតនៅហាណូយ ជាដើម។ ដើម្បីលើកកម្ពស់ការសិក្សាសិល្បៈ និងស្ថាបត្យកម្មខ្មែរលោក George Groslier បានបង្កើតសាលារចនាឡើងនៅឆ្នាំ១៩១៧ ដែលក្រោយ មកបានក្លាយទៅជាសាកលវិទ្យាល័យវិចិត្រសិល្បៈ។

ទន្ទឹមនឹងការសិក្សា និងការអភិរក្សប្រាង្គប្រាសាទបុរាណ សាលាបារាំង

ចុងបូព៌ា បានធ្វើការសិក្សាលើសិលាចារឹកខ្មែរ ដែលជាកេរដំណែលប្រវត្តិ-សាស្ត្រ និងជាប្រភពនៃចំណេះដឹងខាងផ្នែកប្រវត្តិសាស្ត្រកម្ពុជា។ អ្នកដែលចាប់ផ្តើមផ្តិតយកសិលាចារឹកខ្មែរដំបូង គឺលោក Doudart de Lagrée នៅពេលលោកធ្វើបេសកកម្មនៅប្រាសាទអង្គរនៅឆ្នាំ១៨៦៦ ហើយអ្នកដែលបានបកប្រែសិលាចារឹកសំស្ក្រឹតខ្មែរលើកទី១ គឺអ្នកប្រាជ្ញហូឡង់ លោក Hendrik Kern (Clémentin-Ojha, et Manguin, 2001)។ ក៏ប៉ុន្តែគឺលោក George Coedès ដែលជានាយក សាលាបារាំងចុងបូព៌ា ចាប់ពីឆ្នាំ១៩២៩ ដែលជាអ្នកបានចំណាយពេលស្ទើរតែពេញមួយជីវិត ដើម្បីសិក្សាសិលាចារឹកខ្មែរ និងបានបោះពុម្ពសៀវភៅចំនួន៨ក្បាលចំណងជើងថា «សិលាចារឹកនៃប្រទេសកម្ពុជា (១៩៣៧-១៩៦៦)» ដែលក្លាយជាប្រភពដ៏សំខាន់ សម្រាប់ការសិក្សាប្រវត្តិសាស្ត្រកម្ពុជា។ លោកបានសរសេរសៀវភៅ និងអត្ថបទជាច្រើនស្តីពីប្រវត្តិសាស្ត្រ ខ្មែរ។ ការសិក្សាប្រវត្តិសាស្ត្រខ្មែរ ក៏ជាអាទិភាពមួយរបស់សាលាបារាំងចុងបូព៌ាផងដែរ។ លោកសាស្ត្រាចារ្យ ឃិន សុខ និងលោកសាស្ត្រាចារ្យ ម៉ក់ភីន បានធ្វើការសិក្សាអត្ថបទផ្សេងៗនៃព្រះរាជពង្សាវតារប្រទេសកម្ពុជា ដែលជាប្រភពមួយដ៏សំខាន់នៃប្រវត្តិសាស្ត្រខ្មែរសម័យក្រោយអង្គរ។

បន្ទាប់ពីការបង្កើតអាណាព្យាបាលបារាំងនៅកម្ពុជាអ្នកឯកទេសបារាំងបានចាប់ផ្តើមដើរប្រមូលអត្ថបទអក្សរសិល្ប៍ ចរិយាធម៌ និងសាស្ត្រាស្តីពីប្រវត្តិសាស្ត្រកម្ពុជា ដើម្បីធ្វើការសិក្សាពីកម្ពុជា (Edwards, 2007)។ ក៏ប៉ុន្តែសាស្ត្រាទាំងនេះ គឺជាអត្ថបទចម្លងដោយដៃ លើស្លឹករឹតហើយមិនសូវមានច្រើនទេ។ មន្ត្រីជាន់ខ្ពស់ បញ្ញវន្ត ព្រះសង្ឃរាជ និងព្រះញាតិវង្សានុវង្សរក្សាទុកសាស្ត្រាទាំងនេះ ដោយប្រុងប្រយ័ត្ន ដោយចាត់ទុកសាស្ត្រាទាំងនេះជាវត្ថុមានតម្លៃ ហើយពេលខ្លះជាវត្ថុស័ក្តិសិទ្ធិទៀតផង។

ការបង្កើតសាលាបាលីទី១ (សាលាបាលីជាន់ខ្ពស់អង្គរវត្ត) ក្នុងឆ្នាំ១៩០៩ នៅក្រុងសៀមរាប តាមព្រះរាជតម្រិះព្រះបាទសម្តេចព្រះស៊ីសុវត្ថិ គឺជាដំណាក់កាលថ្មីមួយទៀតក្នុងការកសាងជាតិ។ តែសាលានេះត្រូវបាន

បិទទ្វារនៅឆ្នាំ១៩១១ ដោយសារគ្មានសិស្សចូលរៀន។ ដូចនេះហើយទើបសាលាបាលីជាន់ខ្ពស់ថ្មីមួយទៀតត្រូវបានបង្កើតឡើងនៅភ្នំពេញក្នុងឆ្នាំ១៩១៥។ ការបង្កើតសាលាបាលីជាន់ខ្ពស់ បានបណ្តុះបណ្តាលទូវបញ្ញវន្តខ្មែរឆ្នើមៗជាច្រើន ដូចជាសម្តេចព្រះសង្ឃរាជ ជួន ណាត (សម្តេចជួន ណាត ១៩៤៨) និងសម្តេចព្រះសង្ឃរាជ ហួត តាត (សម្តេចហួត តាត, ១៩៦៩)។ ដូចជំនាន់ព្រះបាទអង្គឌួង ដែរ ខ្មែរបានលើកតម្កើងព្រះពុទ្ធសាសនា ជាពិសេសការអប់រំជាភាសាបាលី ដែលជាមធ្យោបាយ ដ៏ស័ក្តិសិទ្ធិក្នុងការថែរក្សាវប្បធម៌ជាតិ។

ទន្ទឹមនឹងនេះ ប្រព័ន្ធអប់រំបែបសាសនាថ្មីមួយត្រូវបានបង្កើតឡើងដោយមានពីរកម្រិតសិក្សា គឺសាលាពុទ្ធិកបឋមសិក្សា និងសាលាពុទ្ធិកមធ្យមសិក្សា។ សាលាបាលីរង (École élémentaire de Pâli) ត្រូវបានបង្កើតឡើងទូទាំងប្រទេសនៅឆ្នាំ១៩៣៣ ហើយត្រូវបានផ្លាស់ឈ្មោះជាសាលាពុទ្ធិក-បឋមសិក្សានៅឆ្នាំ១៩៥៧។ នៅឆ្នាំ១៩៦៣ សាលាពុទ្ធិកបឋមសិក្សាមានចំនួន៥៩០ និងមានសមណសិស្សចំនួន១០ ១៥០ អង្គ។ សាលាបាលីដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩១៥ ត្រូវបានក្លាយទៅជាសាលាបាលីជាន់ខ្ពស់នៅឆ្នាំ១៩២២ និងត្រូវបានប្តូរឈ្មោះទៅជាគ្រឹះស្ថានមធ្យមសិក្សានៃពុទ្ធ-សាសនា ឬពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត នៅឆ្នាំ១៩៥៥។ ចំនួនសមណសិស្សក៏បានកើនឡើងពី២៥អង្គក្នុងមួយឆ្នាំ ក្នុងឆ្នាំ១៩២២ ដល់១០០អង្គ ក្នុងឆ្នាំ១៩៤៧ ហើយកើនដល់៦៨០អង្គ ក្នុងឆ្នាំ១៩៦២ (ស៊ិន សំណាង) ។ កម្មវិធីសិក្សាក៏ត្រូវបានកែលម្អឱ្យបានដូចសាលារដ្ឋផងដែរ។ ដើម្បីពង្រឹងគុណភាពអប់រំ កំណែទម្រង់វិស័យអប់រំផ្តោតផងដែរទៅលើ «ការធ្វើទំនើបកម្ម សាលា-វត្ត» ដោយបញ្ចូលកម្មវិធីថ្មី រួមទាំងលេខនព្វន្ត ប្រវត្តិសាស្ត្រ ជីវវិទ្យា និងភូមិសាស្ត្រ ដោយប្រែក្លាយសាលាវត្ត ឱ្យទៅជាសាលាវត្តបែបថ្មី (École de pagode rénovée) នៅឆ្នាំ១៩២៤ និងត្រូវបានពង្រីកទូទាំងប្រទេសចាប់ពីឆ្នាំ១៩៣០។

ការបង្កើត «ប្រព័ន្ធអប់រំទំនើប» ចូលរួមចំណែកយ៉ាងខ្លាំងក្លា ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សនៅកម្ពុជា និងការកសាងរដ្ឋកម្ពុជាមួយទំនើប និងស៊ីវិល័យ។ ក្នុងឆ្នាំ១៩០៥ ក្រុមប្រឹក្សាកែលម្អការអប់រំ ត្រូវបានបង្កើតឡើង ដោយមានព្រះអង្គម្ចាស់ សុធារស សម្ដេចចៅហ្វាវាំង ជួន ព្រះសង្ឃរាជទាំងពីរគណៈ និងទីប្រឹក្សាបារាំងជាសមាជិក ក្នុងគោលដៅពិនិត្យឡើងវិញនូវកម្មវិធីសិក្សា (២) ការពង្រឹងការអប់រំតាមសាលាវត្ត តាមរយៈការធ្វើពិការកិច្ចនៅតាមសាលាវត្តដើម្បីលើកកម្ពស់ការអប់រំជាខេមរភាសា (៣) ការបង្កើតសាលារដ្ឋបារាំង-ខ្មែរ និងរៀបចំប្រព័ន្ធអប់រំនៅកម្ពុជាឱ្យមានលក្ខណៈរៀបរយ និងមានស្តង់ដាដូចនៅប្រទេសបារាំង និងការរៀបចំឱ្យមានការអប់រំជាកាតព្វកិច្ចនៅកម្ពុជា ជាពិសេសការបង្កើតអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងឆ្នាំ១៩០៥ លើទីតាំងបច្ចុប្បន្ន ដែលជាព្រះរាជអំណោយរបស់ហ្លួងស៊ីសុវត្ថិ (៤) ការបង្កើតប្រព័ន្ធបណ្ដុះបណ្ដាលគ្រូក្នុងឆ្នាំ១៩២៥ ដោយបង្កើតវគ្គគរុកោសល្យសម្រាប់បណ្ដុះបណ្ដាលគ្រូ និងនាយកសាលាចំនួន៤ ឆ្នាំនៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ មុននឹងការបង្កើតមហាវិទ្យាល័យគរុកោសល្យឆ្នាំ១៩៤២។

៦.៣.២. ការបង្កើតស្ថាប័នជាតិសម្រាប់ស្រាវជ្រាវវប្បធម៌ខ្មែរ

ការបង្កើត ព្រះរាជបណ្ណាល័យ ក្នុងឆ្នាំ១៩២៥ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់មួយទៀត ក្នុងការលើកកម្ពស់ការរៀន និងការអាននៅកម្ពុជា។ នៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩២០ លោកស្រី Suzanne Karpelès ត្រូវបានចាត់តាំងឱ្យគ្រប់គ្រង និងចាត់ចែងបណ្ណាល័យ ព្រមទាំងលើកកម្ពស់ការបោះពុម្ពផ្សាយអត្ថបទព្រះពុទ្ធសាសនា។ ចំនួនអ្នកអានបានកើនឡើងពី ៣ ៧៨២ ក្នុងឆ្នាំ១៩២៦ ទៅ៥ ៤៣៧ ក្នុងឆ្នាំ១៩៣០ (សិន សំណាង)។ ទន្ទឹមនឹងនេះ ការបង្កើតព្រះរាជបណ្ណាល័យជាតិក៏បានលើកទឹកចិត្តឱ្យអ្នកប្រាជ្ញខ្មែរធ្វើការស្រាវជ្រាវ និងបោះពុម្ពសៀវភៅ ដើម្បីបណ្ដុះបញ្ញវ័ន្តជាតិផងដែរ ដែលក្នុងនោះក៏មានសម្ដេចសង្ឃ ជួន ណាត និងសម្ដេចសង្ឃ ហួត តាត

ផងដែរ។ អ្នកប្រាជ្ញបារាំងផ្នែកភាសាបាលីក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្រាវជ្រាវ ពីកម្ពុជាដែរ។ ក្នុងនោះ តួឯកដ៏សំខាន់គឺលោកស្រី Suzanne Karpelès ដែលជាភាសាវិទូ ពុទ្ធសាសនវិទូ និងជាអ្នកឯកទេសខាងផ្នែកគម្ពីរស្លឹករឹតជាភាសាបាលី និងជាភាសាខ្មែរ។ លោកស្រីបានចូលបម្រើការងារនៅក្នុងឆ្នាំ១៩២២ និងបានបង្កើតព្រះរាជបណ្ណាល័យភ្នំពេញ នៅឆ្នាំ១៩២៥ ដើម្បីប្រមូល និងអភិរក្សអក្សរសិល្ប៍ជាភាសាខ្មែរ និងបាលី។ លោកស្រីក៏បានផ្តួចផ្តើមគំនិតឱ្យខ្មែរយើងបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យឡើង ដើម្បីធ្វើការស្រាវជ្រាវខាងផ្នែកពុទ្ធសាសនា និងបោះពុម្ពផ្សាយព្រះត្រៃបិដក ដោយយកឯកសារ ពី Pali Text Society នៅទីក្រុងឡុងដ៍ជាគោល (Clémentin-Ojha, et Manguin, 2001)។

ការបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលត្រូវបានសម្ពោធនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៣០ ក្នុងគោលដៅឆ្លើយតបទៅនឹងតម្រូវការនៃសាលាបាលីបណ្ណាល័យ សារមន្ទីរជាដើម ដើម្បីលើកកម្ពស់ការសិក្សាស្រាវជ្រាវព្រះពុទ្ធសាសនាថេរវាទ។ ភារកិច្ចសំខាន់របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គឺត្រួតពិនិត្យ និងរៀបចំការងារកែសម្រួល ការបកប្រែ និងសរសេរគម្ពីរព្រះត្រៃបិដកជាភាសាបាលី-ខ្មែរ និងបោះពុម្ពផ្សព្វផ្សាយអត្ថបទស្រាវជ្រាវស្តីពីវប្បធម៌ និងអារ្យធម៌ខ្មែរ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានក្លាយជាមជ្ឈដ្ឋានបណ្តុះបណ្តាលបញ្ញវន្តថ្មីរបស់កម្ពុជា។

ក្រុមជំនុំប្រែគម្ពីរព្រះត្រៃបិដកត្រូវបានបង្កើតឡើង ក្នុងឆ្នាំ១៩២៩ ដើម្បីបកប្រែព្រះត្រៃបិដក ពីភាសាបាលីមកខេមរភាសា។ ក្រុមជំនុំប្រែគម្ពីរព្រះត្រៃបិដកមាន៦ក្រុម។ ក្រុមជំនុំ អ្នកចម្លងបានចម្លងព្រះត្រៃបិដកពីគម្ពីរស្លឹករឹតខ្មែរ ហើយបញ្ជូនទៅក្រុមជំនុំផ្ទៀងបាលី។ ក្រុមនេះបានផ្ទៀងអត្ថបទស្លឹករឹត ជាមួយព្រះត្រៃបិដក សៀម ភូមា លង្កា និងអឺរ៉ុប។ មូលហេតុដែលត្រូវផ្ទៀងផ្ទាត់ គឺដោយសារការប្រើប្រាស់ពាក្យខ្មែរដែលខ្ចីពីបាលី និងសំស្ក្រឹតត្រូវបានប្រើប្រាស់ខុសពីពាក្យដើម (Edwards, 2007)។ ប្រសិនបើមានការខុស

ប្លែកគ្នា ក្រុមនេះធ្វើគំនូសចំណាំ រួចបញ្ជូនទៅឱ្យក្រុមបកប្រែពីភាសាបាលីមកភាសាខ្មែរ និងក្រុមជំនុំពិនិត្យសេចក្តីប្រែ។ ក្រុមនេះ ត្រូវពិនិត្យសេចក្តីប្រែរួចបញ្ជូនទៅឱ្យក្រុមជំនុំ សរសេរចម្លងឱ្យសរសេរសម្អាត រួចត្រូវបញ្ជូនទៅឱ្យក្រុមជំនុំពិនិត្យសេចក្តីប្រែមើលម្តងទៀត។លុះឃើញថាត្រឹមត្រូវហើយទើបបញ្ជូនទៅឱ្យក្រុមមួយ ទៀត គឺក្រុមជំនុំពិនិត្យសេចក្តីប្រែសម្រេច។ បន្ទាប់ពីបានពិនិត្យយ៉ាងហ្មត់ចត់ហើយ ទើបអត្ថបទបកប្រែត្រូវបានបញ្ជូនទៅសុំសេចក្តីយល់ព្រមពីព្រះសង្ឃនាយកទាំងពីរគណៈ មុននឹងបញ្ជូនសំណៅគម្ពីរព្រះត្រៃបិដក ដើម្បីសុំការសម្រេចជាចុងក្រោយពីការជំនុំរដ្ឋមន្ត្រី (ស៊ិន សុវណ្ណនិ, ២០១២)។ នៅក្នុងឆ្នាំ១៩៥៧ គម្ពីរព្រះត្រៃបិដកចំនួន៥០ក្បាលត្រូវបានប្រែ និងបោះពុម្ព។

នៅក្នុងសង្គមណាក៏ដោយ បញ្ញវន្តដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គម ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ តាមមតិលោក វ៉ាន់ឌី កាអុន សង្គមកម្ពុជាចាត់ទុកគរូ បណ្ឌិត និងអ្នកនិពន្ធថាជាបញ្ញវន្ត(Vandy Kaon et Ly Kimsok, 1982)។ តាមមតិលោក Gramsci «បញ្ញវន្តបំពេញតួនាទីរបស់ខ្លួនក្នុងនាមនៃវណ្ណៈត្រួតត្រា ជាអ្នកបង្កើតនិងផ្សព្វផ្សាយចំណេះដឹង និងមនោគមន៍វិជ្ជារៀបចំផលិតកម្ម និងពាណិជ្ជកម្ម និងជាពិសេសបំពេញតួនាទីក្នុងការគ្រប់គ្រងអំណាច។ ទន្ទឹមនឹងនេះ បញ្ញវន្តដើរតួនាទីមួយទៀត គឺទិតៀនដើម្បីស្ថាបនា»(Vandy Kaon et Ly Kimsok,1982)។ បញ្ញវន្តខ្មែរបានខិតខំស្រាវជ្រាវពីវប្បធម៌ និងអារ្យធម៌ខ្មែរ ហើយបោះផ្សាយស្នាដៃនៅក្នុងទស្សនាវដ្តីកម្ពុជសុរិយា។

ចាប់តាំងពីឆ្នាំ១៩២៦ ទស្សនាវដ្តីកម្ពុជសុរិយា ត្រូវបានបង្កើតឡើងដើម្បីផ្សព្វផ្សាយអត្ថបទព្រះពុទ្ធសាសនា និងអក្សរសាស្ត្រខ្មែរ។ កម្ពុជសុរិយាបានក្លាយជាវេទិកា ដើម្បីផ្សព្វផ្សាយវប្បធម៌ និងអារ្យធម៌ខ្មែរ និងជាកន្លែងសម្រាប់អ្នកប្រាជ្ញខ្មែរ ធ្វើការស្រាវជ្រាវនិងផ្សព្វផ្សាយវណ្ណកម្មស្តីពីភាសាខ្មែរទំនើប។

ការបង្កើត ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ មានតួនាទីស្រាវជ្រាវពីទំនៀមទម្លាប់ខ្មែរ ហើយចងក្រងជាសៀវភៅសម្រាប់ជនកម្ពុជាជំនាន់ក្រោយៗ នៅអំឡុងក្រោយឯករាជ្យ លោក ចាប- ពិន ត្រូវបានតែងតាំងជាអធិបតីក្រុមជំនុំទំនៀមទម្លាប់ខ្មែរ និងជាអ្នកចាត់ការខាងទស្សនាវដ្ដីកម្ពុជសុរិយាផងដែរ។ ស្នាដៃរបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរមានដូចជា៖

ក-«ប្រជុំរឿងព្រេងខ្មែរ»៖ នៅប្រទេសកម្ពុជាយើង មានរឿងព្រេងជាច្រើនអនេក ដែលអាចធ្វើចំណាត់ថ្នាក់ជាក្រុមដូចតទៅ៖ (១) រឿងទាក់ទងនឹងប្រវត្តិសាស្ត្រ៖ រឿងភ្នំប្រុស ភ្នំស្រី នៅខេត្តកំពង់ចាម ភ្នំទ្រុងមាន់ ភ្នំបាណន់ ភ្នំសំពៅ នៅខេត្តបាត់ដំបង ភ្នំសែនហាន នៅខេត្តកំពត ភ្នំនាងកង្រីនៅខេត្តកំពង់ឆ្នាំងជាដើម (២) រឿងទាក់ទងនឹងតុលាការកាត់ក្ដី៖ រឿងសុភាទន្សាយ និងរឿងផ្សេងៗ ដែលមានក្នុងសាស្ត្រាគីងកង្រ្កែជាដើម (៣) រឿងទាក់ទងនឹងការនេសាទ ការទាក់ ការបាញ់ មានការទាក់ដំរីជាដើម និង (៤) រឿងទាក់ទងនឹងទំនៀមទម្លាប់ មានទំនៀមមង្គលការជាដើមៗ រឿងព្រេងនិទានទាំងនេះត្រូវបានអ្នកប្រាជ្ញនិពន្ធបុរាណសរសេរ និពន្ធ ចារទុកនៅលើក្រាំង ឬស្លាសឹករឹត ឬនិទានតៗមាត់គ្នា ដែលមាននៅតាមវត្តអារាមភូមិស្រុក ពាសពេញផ្ទៃប្រទេសកម្ពុជា។ ក្រុមជំនុំទំនៀមទម្លាប់បានខិតខំស្រាវជ្រាវរក និងប្រមែប្រមូល ទាំងរឿងព្រេងដែលចារជាសាស្ត្រា ទាំងរឿងដែលនិទានតមាត់ទទេ ដែលមាននៅតាមស្រុកខេត្តនានា និងកត់ត្រាតាមមាត់ចាស់ៗ ដែលចេះចាំស្ទាត់ មកតម្កល់ទុកក្នុងមន្ទីរក្រុមជំនុំទំនៀមទម្លាប់ និងដោយវិធីសរសេរចម្លងអំពីវត្តអារាមទាំងឡាយ ក្នុងព្រះរាជអាណាចក្រមកតម្កល់ទុកក្នុងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងដោយវិធីចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជាសុរិយា ជាយូរឆ្នាំមកហើយ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យបានស្រង់រឿងព្រេងទាំងប៉ុន្មានដែលមានក្នុងមន្ទីរ ក្រុមជំនុំទំនៀមទម្លាប់ក្នុងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ និងក្នុងទស្សនាវដ្ដីកម្ពុជាសុរិយា ដែលបានសន្សំទុកជាយូរ

ឆ្នាំហើយនោះមកប្រមូលរៀបចំបោះពុម្ពជាសៀវភៅតូចៗ ឱ្យឈ្មោះថា «ប្រជុំរឿងព្រេងខ្មែរ» ដោយចែកជា៩ភាគ ហើយដើម្បីរក្សាស្នាដៃកវីនិពន្ធខ្មែរសម័យបុរាណទុកជាកេរតទៅ កុំឱ្យបាត់បង់ និងទុកឱ្យយុវជនអ្នកអានបានឃើញច្បាស់ថា ជាតិខ្មែរយើងមានកេរមត៌ក អក្សរសាស្ត្រច្រើនជាអនេក។ ការបោះផ្សាយសៀវភៅប្រជុំរឿងព្រេងខ្មែរនេះបានជួយជាកម្លាំងមួយ ដើម្បីពង្រីកអក្សរសាស្ត្រជាតិឱ្យមានវឌ្ឍនាការជាកិយោភាព។

អត្ថរសក្នុងរឿងព្រេងនិទានទាំងអស់នោះ មានលក្ខណពីរោះជក់ចិត្ត មានខ្លឹមសារ មានប្រយោជន៍ដ៏សំខាន់ក្រៃលែង ដល់ជនានុជនទាំងឡាយដែលបានសិក្សារៀនសូត្រចេះចាំនូវរឿងទាំងអស់នោះ រឿងព្រេងខ្លះ អ្នកនិពន្ធបានសរសេរជារឿងពិតនៃប្រវត្តិសាស្ត្រខ្មែរតែម្តង រឿងខ្លះទៀតអ្នកនិពន្ធបានសរសេរឱ្យបានជាគតិបណ្ឌិត គតិធម៌ធ្វើឱ្យមានបញ្ញាស្មារតីភ្លឺស្វាងក្នុងការប្រៀបធៀប ទាញអារម្មណ៍អ្នកអានអ្នកស្តាប់ ឱ្យជឿបុណ្យ ជឿងបាប ជឿកម្មផលទៅតាមទ្រឹស្តីព្រះពុទ្ធសាសនាទៀតផង ហើយក៏មានរឿងស្នេហាផ្អែមត្រជាក់ ស្នេហាជិតក្បត់ ស្នេហាប្រាត់ប្រាស់សង្គ្រាមច្បាំងកាប់ចាក់គ្នាផងដែរ។

ខ-«ព្រះរាជពិធីទ្វាទសមាស»៖ ក្រុមជំនុំទំនៀមទម្លាប់បានកត់ត្រាព្រះរាជពិធី និងពិធីផ្សេងៗដែលរៀបចំឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបោះផ្សាយជា៣ភាគ។ ភាគ១៖ ព្រះរាជពិធី ក្នុងខែចេត្រ និងភាគ២៖ ព្រះរាជពិធីក្នុងខែពិសាខ និងខែជេស្ឋ មានឧកញ៉ាទេពពិទូ ឈឹម ក្រសេម និងយុទ្ធឧត្តមប្រឹជា ចាប ពិន និពន្ធដោយមានអ្នកស្រី អឺ ប៉ូរ៉េ ម៉ាស្ប៉េរ៉ូ ជាប្រធាន សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក ជួន ណាត សម្តេចព្រះស្រីស្វាគ្គវឌ្ឍនា មាលិកា សម្តេចឥសីកទ្ធាធិបតី ម៉ាំង និងអស់លោកឯទៀតច្រើនរូបជាទីប្រឹក្សា។ ភាគ៣ ឧត្តមប្រឹជា ចាប ពិន រៀបរៀង ដោយមានសម្តេចឥសីកទ្ធធិបតី ម៉ាំង ចាងហ្វាងផ្នែកបាឝ្គ, ឧកញ៉ារាជវរានុកូល គឹម យ៉ឹង ចាងហ្វាងផ្នែកព្រះទីនាំងគជេន្ទ្រ, ឧកញ៉ាព្រះស្តេចធិបតី គឹម សាយ ចាងហ្វាងផ្នែក

សង្ឃការី និងអស់លោកឯទៀតច្រើនរូប ជាទីប្រឹក្សា។

ឥ-«ល្បែងប្រជាប្រិយខ្មែរ»៖ តាមការស្រាវជ្រាវរបស់ក្រុមជំនុំទំនៀមទម្លាប់ ព្រមទាំងសមាជិកឆ្លើយឆ្លងគ្រប់ខេត្ត លោក ចាប ពិន អធិបតីក្រុមជំនុំ, អ្នកស្រី ពេជ្រ សល់, លោក លី ធាមតេង និង ស្តើង ធូរបានរៀបរៀងសៀវភៅល្បែងប្រជាប្រិយខ្មែរ ដើម្បីឱ្យកូនខ្មែរបានដឹងពីប្រពៃណីរបស់ខ្លួន។

ឃ-«សិល្បៈខាងដូរ្យតន្ត្រីនិងរបាំខ្មែរ»៖ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរបានរៀបរៀងសៀវភៅស្តីពីរាជសិល្បៈ (សិល្បៈខាងដូរ្យតន្ត្រី) និងអំពីដើមកំណើតល្ខោនជារបាំរបស់ខ្មែរ ដោយបានបញ្ជាក់ថា ល្ខោនខ្មែរកើតមានឡើងតាំងពីរជ្ជកាលព្រះបាទជយវ៌្មនទី២ និងរបាំខ្មែរជាច្រើនទៀត គឺ ១-ល្ខោនខោល, ២-ល្ខោនយន្ត, ៣-ណាំងស្បែក និងណាំងទ្រលុង ៤-កន្តែរ៉ែ, ៥-រាំស្នែងទន្សោង ដើម្បីសម្តែងនូវឧបត្ថមគតិនៃរបាំទាំងនេះ។

៦.៣.៣. ការធ្វើទំនើបកម្មភាសាខ្មែរ

ទំនើបភាវូបនីយកម្មនៃភាសាខ្មែរ គឺជាការរៀបចំឱ្យភាសាខ្មែរមានក្បួនវេយ្យាករណ៍ត្រឹមត្រូវ មានលក្ខណៈវិទ្យាសាស្ត្រ មានស្តង់ដាក្នុងការសរសេរអក្ខរាវិរុទ្ធ និងមានពាក្យសម្បូណ៌បែបក្នុងគោលដៅលើកកម្ពស់អក្សរសិល្ប៍ខ្មែរ និងជាភាសាដែលអាចប្រើប្រាស់បានសម្រាប់ការអភិវឌ្ឍខាងផ្នែក ទាំងវិទ្យាសាស្ត្រពិត ទាំងវិទ្យាសាស្ត្រសង្គម។ ភាសា «ខ្មែរទំនើប» សម្រេចបាននូវបុគ្គលិកលក្ខណៈជាក់លាក់នៅចុងសតវត្សទី១៨។

នៅដើមសតវត្សទី២០ អ្នកប្រាជ្ញខ្មែរបានចាប់ផ្តើមគិតគូរពីការរៀបចំភាសាខ្មែរ ឱ្យមានលក្ខណៈវិទ្យាសាស្ត្រតាមរយៈ៖ (១) ការរៀបចំវិធានវេយ្យាករណ៍ត្រឹមត្រូវ (២) ការសរសេរអក្ខរាវិរុទ្ធឱ្យមានការឯកភាព និង (៣) ការបង្កើតពាក្យថ្មីដើម្បីលើកកម្ពស់តួនាទីអក្សរសាស្ត្រ និងអក្សរសិល្ប៍ជាតិ ជាពិសេសដើម្បីឆ្លើយតបទៅនឹងតម្រូវការខាងផ្នែករដ្ឋបាល សេដ្ឋកិច្ច និងសង្គមកម្ពុជាក្នុងសតវត្សទី២០។ ភារកិច្ចចម្បង គឺការបង្កើតវចនានុក្រមជាតិមួយ និងការបង្កើតពាក្យថ្មី។ ការអភិវឌ្ឍភាសាខ្មែរ និងការលើកកម្ពស់

អក្សរសិល្ប៍ជាតិនេះ ដំណើរការទៅជាមួយនឹងនិន្នាការក្នុងការបង្កើតនូវអត្តសញ្ញាណជាតិ តាមរយៈការបង្កើតប្រព័ន្ធអប់រំទំនើប និងការសិក្សាពីបេតិកភណ្ឌវប្បធម៌ និងប្រពៃណីជាតិ និងការកាត់បន្ថយឥទ្ធិពលនៃប្រទេសសៀមមកលើបញ្ញវន្ត និងព្រះសង្ឃខ្មែរ ដោយមានការចូលរួមយ៉ាងសកម្ម និងការគាំទ្រពីអាជ្ញាធរ និងអ្នកប្រាជ្ញបារាំងផងដែរ។ ភាសា «ខ្មែរទំនើប» គឺជា៖ (១) វេយ្យាករណ៍ (២) អក្ខរាវិរុទ្ធ (៣) ការបង្កើតពាក្យថ្មី (៤) អក្សរសិល្ប៍។

វចនានុក្រមខ្មែរ ដើរតួនាទីយ៉ាងសំខាន់ក្នុងការវិវត្តភាសាខ្មែរ អក្សរសិល្ប៍ខ្មែរ ការកសាងវប្បធម៌ និងជាតិខ្មែរឡើងវិញ។ គំនិតបង្កើតវចនានុក្រមភាសាខ្មែរ គឺជាការចាប់ផ្តើមគិតគូរពីវេយ្យាករណ៍ អក្ខរាវិរុទ្ធ និងក្បួនច្បាប់ក្នុងការសរសេរក្នុងភាសាខ្មែរ ដើម្បីបង្កើតឡើងនូវស្តង់ដារួមមួយ និងក្បួនខ្នាតត្រឹមត្រូវតាមវិទ្យាសាស្ត្រ។ ក្រុមជំនុំជាតិខ្មែរត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩១៥ ដែលមានសម្តេចចក្រីកុញ្ញរាធិបតី ពេជ្រ ប៉ុណ្ណ សេនាបតីក្រសួងសិក្សាធិការ និងយុទ្ធនាធិការជាអធិបតី និងមានសមាជិកសុទ្ធសឹងតែជាបញ្ញវន្ត ដូចជាព្រះមហាវិមលធម្ម ថោង ព្រះពុទ្ធឃោសាចារ្យ ជួន ណាត ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ព្រះឧត្តមមុនី អ៊ុម ស៊ូ ព្រះសក្យវង្ស ហួត តាត និងឧកញ៉ាទេពពិទូរ ឈឹម ក្រសេម ជាដើម ដោយមានការទំនុកបម្រុងពីលោក Goerge Cordès ចាងហ្វាងសាលាបារាំងចុងបូព៌ា។ ក៏ប៉ុន្តែ ក្នុងចំណោមក្រុមជំនុំទាំង១៩ មានអ្នកខ្លះធ្វើការយ៉ាងពេញដៃពេញជើង អ្នកខ្លះជួយមួយដងមួយកាល ហើយអ្នកខ្លះទៀតមានតែឈ្មោះប៉ុណ្ណោះ។ មានតែព្រះពុទ្ធឃោសាចារ្យ ជួន ណាត មួយរូបគត់ដែលបានខិតខំប្រឹងប្រែងបំពេញការងាររៀបចំឱ្យកើតជាវចនានុក្រមនេះឡើងនៅឆ្នាំ១៩៣៨ និងចំណាយពេលពេញមួយជីវិត ដើម្បីពិនិត្យឡើងវិញរហូតដល់ការបោះពុម្ពលើកទី៥ ក្នុងឆ្នាំ១៩៦៧ បន្ទាប់ពីបានផ្ទៀងផ្ទាត់ឡើងវិញដោយអ្នកស្ទាត់ជំនាញខាងអក្សរសាស្ត្រខ្មែរផងដែរ។

ក្រុមជំនុំវចនានុក្រមភាសាខ្មែរមានតួនាទី ក្នុងការរៀបចំវិធានអក្ខរាវិរុទ្ធ កែលម្អវេយ្យាករណ៍ រៀបចំភាសាខ្មែរឱ្យសរសេរមានឯកភាព អនុម័តមេពាក្យថ្មី និងបំពេញបន្ថែមពាក្យដើម្បីប្រើប្រាស់ទៅតាមតម្រូវការ ជាពិសេសការបន្តខ្ចីវាក្យសព្ទបាលី និងសំស្ក្រឹត ដើម្បីឱ្យភាសាខ្មែរសម្បូណ៌ពាក្យប្រើប្រាស់ក្នុងការតែងនិពន្ធ។ អ្នកប្រាជ្ញខ្មែរដែលចេះភាសាបាលី និងសំស្ក្រឹតច្បាស់លាស់ក៏ចាប់ផ្ដើមរៀបចំភាសាជាតិឡើងវិញ ដោយសរសេរពាក្យកម្ចីបាលី និងសំស្ក្រឹតឱ្យបានត្រឹមត្រូវតាមនិរុត្តិសាស្ត្រនៃពាក្យដើម។

៦.៣.៣.១. ការកំណត់អក្ខរាវិរុទ្ធភាសា «ខ្មែរទំនើប» តាមនិរុត្តិសាស្ត្រ

ការកែប្រែអក្ខរាវិរុទ្ធបានបង្កើតជាជម្លោះជាញឹកញាប់ នៅក្នុងប្រវត្តិសាស្ត្រខ្មែរនៅសតវត្សទី២០កន្លងទៅនេះ។ ដូចយើងបានឃើញខាងលើការសរសេរពាក្យក្នុងភាសាខ្មែរកណ្ដាលមិនមានការឯកភាពគ្នាឡើយ។ បញ្ហានេះបន្តទៀត នៅក្នុងភាសាខ្មែរទំនើប។ ភាសានៅអាស៊ីអាគ្នេយ៍ដែលខ្ចីអក្ខរក្រមឥណ្ឌាមកប្រើមានជម្រើសពីរ ក្នុងការសរសេរវាក្យសព្ទ (SASAGAWA, 2015)៖ (ទី១) ការសរសេរតាមនិរុត្តិសាស្ត្រ (ពាក្យដើមដែលខ្ចីពីសំស្ក្រឹត ឬបាលី) ដោយសរសេរតាមពាក្យដើម ទាំងអក្សរនៅខាងចុងដែលមិនត្រូវបញ្ចេញសំឡេងផងដែរ ដូចជាប្រយោជន៍ (ការសរសេរវាក្យសព្ទកម្ចីក្នុងភាសាថៃ) និង (ទី២) ការសរសេរទៅតាមការបញ្ចេញសំឡេង (ការសរសេរវាក្យសព្ទកម្ចីក្នុងភាសាឡាវ)។

នៅពេលដែល«ក្រុមជំនុំរៀបចំវចនានុក្រមខ្មែរ»ដែលមានសមាជិកចំនួន១៨រូប ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសិក្សាធិការ ពេជ្រ ប៉ុណ្ណ បញ្ហាសរសេរពាក្យក្នុងភាសាខ្មែរបានកើតឡើង។ សមាជិកភាគច្រើនរៀនចប់សាលាបាលី។ បញ្ហាទីមួយ គឺនៅក្នុងភាសាខ្មែរ ពាក្យមួយអាចសរសេរបានច្រើនយ៉ាង ដូចជា ដំរាប់ ជម្រាប់ ឬតម្រាប់។ បញ្ហាទីពីរ គឺតើត្រូវសរសេរពាក្យកម្ចីបាលី និងសំស្ក្រឹតតាមពាក្យដើមឬ សរសេរទៅតាមការបញ្ចេញសំឡេង។ អ្នកដែលធ្លាប់រៀនភាសាបាលីមានទំនោរសរសេរតាមពាក្យកម្ចីដើម

ពោលគឺតាមនិរុត្តិសាស្ត្រ។ ក្រុមជំនុំបានរៀបចំសៀវភៅសិក្សាភាសាខ្មែរ ដោយបង្កើតសញ្ញាអឌ្ឍចន្ទ សម្រាប់សម្គាល់ឃោសៈ និងអឃោសៈ (ល្អ, ប្រកប) និងប្រើ «់» សម្រាប់សម្គាល់ព្យាង្គសំឡេងខ្លី។ ការប្រើប្រាស់សញ្ញានេះនាំឱ្យមានការជំទាស់ពីព្រះអង្គម្ចាស់ក្សត្រី ម៉ាលិកា (ឃីន សុខ. 2007)។

ពាក្យប្រើអឌ្ឍចន្ទ	ពាក្យខ្មែរដើម
	ល្អ
	ប្រកប

គណៈកម្មាធិការថ្មីត្រូវបានបង្កើតឡើងតាមរាជក្រមលេខ៥៣ចុះថ្ងៃ១៩/០៧ ១៩២៦ ដើម្បីសើរើអក្ខរាវិរុទ្ធខ្មែរ ដែលបានស្នើឡើងដោយគណៈកម្មាធិការចាស់ដែលបង្កើតឡើងតាមរាជក្រមលេខ៨៨ចុះថ្ងៃ១៥/១១/១៩១៩។ គណៈកម្មាធិការនេះបានសម្រេចកំណត់សរសេរអក្ខរាវិរុទ្ធតាមនិរុត្តិសាស្ត្រ ពោលគឺតាមពាក្យកម្ចីពីបាលី និងសំស្ក្រឹត។ សេចក្ដីសម្រេចនេះក៏បានបញ្ចប់ជំលោះរវាងក្រុមនិយមនិរុត្តិសាស្ត្រ និងក្រុមនិយមសូរសាស្ត្រ មួយអន្លើ (Bulletin administratif du Cambodge 25(7) jul 1926) ហើយត្រូវបានអនុមតិដោយក្រុមប្រឹក្សារដ្ឋមន្ត្រីនៅឆ្នាំ១៩២៦ (SASAGAWA, 2015; ANC RSC Box No. 2928)។

ដើម្បីរៀបចំការសរសេរពាក្យឱ្យត្រូវតាមនិរុត្តិសាស្ត្រ ការប្រជុំនៅថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ១៩២៦ ក្រោមអធិបតីនៃឧកញ៉ាចក្រី ពេជ្រ ប៉ុណ្ណ បានកំណត់ការប្រើវណ្ណយុត្តិ ដូចខាងក្រោម ដោយមានអនុមតិពីក្រុមប្រឹក្សារដ្ឋមន្ត្រីចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩២៧ និងមានព្រះហស្តលេខាយល់ព្រមពីព្រះបាទមុនីវង្ស (ឃីន សុខ. 2007)៖

១) បន្តក់ (់)៖ សម្រាប់ប្រើដាក់ថែមលើតួប្រកបនៃពាក្យ ដែលកើតឡើងពីស្រៈ « អ » និងស្រៈ «អា» ហើយកាត់សព្ទវែងឱ្យទៅជាខ្លី ដែលត្រូវអាន

លឿនរហ័ស។ ឧទាហរណ៍ ៖ កាត = សព្ទវែង, កាត់ = សព្ទខ្លី, ចប = សព្ទវែង, ចប់ = សព្ទខ្លី ។

២) សំយោគសញ្ញា (៍)៖ សម្រាប់ប្រើក្នុងពាក្យខ្ចីពីបាលី និងសំស្ក្រឹត៖ ភយ > ភ័យ, ជយ > ជ័យ, នយ > ន័យ, អាស្រយ > អាស្រ័យ, អាលយ > អាល័យ ។

ដើម្បីបម្លែងពាក្យដែលបានមកពីបាលីសំស្ក្រឹតឱ្យត្រូវតាមទំនួលសម្ដីខ្មែរបុរាណាចារ្យបានប្រើវណ្ណយុត្តិសំយោគសញ្ញា « ៍ » ដូចជា៖

សំស្ក្រឹត	អានជា	ខ្មែរ
គព្ទ	(សាប់-ព:-ទ:)	សព្ទ
ភយ	(ភ:-យ:)	ភ័យ

ប្រភព៖ អៀវ កើស, 1947

ក៏ប៉ុន្តែ មានពាក្យខ្លះប្រើសំយោគសញ្ញា តែក៏មានពាក្យខ្លះគ្មានសំយោគសញ្ញាដូចជាពាក្យ៖

សំស្ក្រឹត	ខ្មែរ
ប្រត្យក្ស	ប្រត្យក្ស
ប្រតិពទ្ធ	ប្រតិព័ទ្ធ
ទុក្ខសច្ច	ទុក្ខសច្ច
ប្រយត្ន	ប្រយ័ត្ន
ចន្ទ	ចន្ទ
សមគ្រ	ស្ម័គ្រ

ប្រភព៖ អៀវ កើស, 1947

៣) ទណ្ឌឃាត(៍)៖ សម្រាប់បដិសេធន៍តួអក្សរដែលមានលើសពីការអាន។ គេប្រើវណ្ណយុត្តិទណ្ឌឃាត ដើម្បីសម្គាល់ថាអក្សរដែលដាក់សញ្ញា

នេះពីលើ មិនត្រូវបញ្ចេញសំឡេងឡើយ។ ឧទាហរណ៍ ទូរទស្សន៍ ប្រយោជន៍ គមនាគមន៍ ព្រឹត្តិការណ៍ ពាក្យពេចន៍ ត្រ័យរតន៍...។ គេប្រើវណ្ណយុត្តិទណ្ឌឃាត «៍» ចំពោះពាក្យណា ដែលបានមកពីបាលីសំស្ក្រឹត។ ពាក្យខ្មែរសុទ្ធ មិនប្រើវណ្ណយុត្តិទណ្ឌឃាតឡើយ (អៀវ កើស, 1947)។

៤) មូសិកទន្ត (៉)៖ សម្រាប់កែសំឡេងព្យញ្ជនៈ៧តួ ដែលមានសំឡេងឃោសៈ ឱ្យទៅជាអឃោសៈគឺ ង ញ ប ម យ រ វ ឱ្យទៅជាសំឡេងអឃោសៈវិញ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉។

៥) វិសជ្ជនីយ (ះ)៖ សម្រាប់ប្រើប្រកបជំនួសខ្យល់ «ហ» ជាពាក្យកាត់កំបុតខ្លី ហើយអានដោយបើកចំហមាត់ដូចជា តិះ រិះ ចុះ ចង្កេះ ផ្ទោះ។ល។

៦) ត្រីសព្ទ(៊)៖ សម្រាប់កែសំឡេងព្យញ្ជនៈ៤តួ ពីអឃោស «ប ស ហ អ» ឱ្យទៅជាឃោសៈវិញ «ប៊ិ ស៊ិ ហ៊ិ អ៊ិ»។ ព្យញ្ជនៈប្តូរសំឡេងទាំងនេះ ត្រូវបានប្រើក្នុងពាក្យ សាប៊ូ សម្ភស៊ុប ហ៊ាន ទ្រអ៊ូ។

៧) កាកបាទ(័)៖ សម្រាប់សម្គាល់សំឡេងតូច ដូចជា ទុំហ្វ៊ី និងប្រើសម្រាប់ដាក់លើឧទានសព្ទខ្លីៗមួយចំនួន ដែលមានសូរសៀងបន្លឺស ឬត្អូញ ដូចជាពាក្យ ចាំ! ចាំះ! ប៉ាទ! ណាំ! ណាំះ ហ្ន៎ អ្ហ៎ អ្ហ៊...។

៨) របាទ(៌)៖ សម្រាប់ប្រើជំនួស«រ» កាលណា«រ» ជាជំនួសតួអក្សរតម្រួត។ វាជាវណ្ណយុត្តិសម្រាប់ដាក់នូវពាក្យសំស្ក្រឹតក្លាយ៖ ពាក្យដើម ពណ្ណ ផ្លាស់ជា ពណ៌, ធម្ម ទៅជា ធម៌, គព្ភ ទៅជា គភ៌, បុញ្ញ ទៅជា បុណ៌, បរិបុណ្ណ ទៅជាបរិបូរណ៌។

៩) អស្តា(៏)៖ សម្រាប់ប្រើលើតួអក្សរ ក និង ដ ទៅជា ក៏ និង ដ៏។

១០) គោមូត្រ (៚)៖ សម្រាប់បញ្ចប់វគ្គ ឬជំពូក។

នៅពេលក្រោយមក សម្តេចសង្ឃរាជ ជួន ណាត បង្កើតវណ្ណយុត្តិយុគលពិន្ទុ «ៈ» ឡើង ដើម្បីធ្វើឱ្យព្យញ្ជនៈខ្មែរ អាចបញ្ចេញសំឡេងខ្លីតាមភាសាបាលីនិងសំស្ក្រឹតបាន។ ឧទាហរណ៍ ពាក្យឧបការៈ ខេមរៈ (អៀវ កើស, 1947)។ គេប្រើវណ្ណយុត្តិនេះសម្រាប់ដាក់នៅចុងពាក្យមានកំណើតពីបាលី

ឬសំស្ក្រឹត ដែលមានសូរ «អាក់» ឬ «អ៊ាក់» ដូចជា លោភៈ, មោហៈ, ទោសៈ។

បើពាក្យទាំងនេះនៅខាងដើមគេ ដូចជា ពលកម្ម, វណ្ណកម្ម សច្ចភាព, ខេមរភាសា នោះគេមិនចាំបាច់ដាក់យុគលពិន្ទុទេ ព្រោះពាក្យទាំងនេះជាសមាសនាម។ លើកលែងតែពាក្យ ៖ គណៈដែលទោះបីវានៅដើមគេ ឬកណ្ដាលគេក្ដី ក៏ត្រូវតែប្រើយុគលពិន្ទុជាដរាប ឧទាហរណ៍ គណៈប្រតិភូ, គណៈកម្មការ, គណៈសង្ឃ, គណៈរដ្ឋមន្ត្រី, គណៈប្រធានរដ្ឋ... ព្រោះថាក្នុងពាក្យទាំងនេះ «គណៈ» មិនចូលក្នុងសមាសនាមតាមក្បួនខ្នាតវេយ្យាករណ៍បាលី លើកលែងតែពាក្យ ៖ គណបក្ស, គណនា, គណនេយ្យ...ដែលគេមិនត្រូវប្រើយុគលពិន្ទុទេ ។

រីឯពាក្យ ៖ កាលៈទេសៈ គេត្រូវប្រើយុគលពិន្ទុកទាំងពីរម៉ាត់តែម្ដង។ ក៏ប៉ុន្តែបើគេសរសេរពាក្យនេះ «បញ្ច្រាស» មកវិញ «ទេសកាល» នោះ គេមិនត្រូវប្រើយុគលពិន្ទុឡើយ ។

៦.៣.៣.២. អក្សរសិល្ប៍ខេមរនិយមនិងការវិវត្តនៃភាសាខ្មែរទំនើប

អក្សរសិល្ប៍ខេមរនិយមនៅដើមសតវត្សទី២០ និងនៅសម័យឯករាជ្យ គឺជាវណ្ណកម្មដ៏សម្បូណ៌បែប ដែលលើកទឹកចិត្តឱ្យអ្នកនិពន្ធខ្មែរសរសេរ ដើម្បីលើកម្ពស់អំណាន និងធ្វើឱ្យភាសាជាតិខ្មែរមានពណ្ណរាយ។ នៅជំនាន់អាណាព្យាបាលបារាំង និងនៅជំនាន់ឯករាជ្យ យើងឃើញមានលេចឡើងនូវចលនាអក្សរសិល្ប៍ខេមរនិយម និងពុទ្ធនិយមក្រោយសម័យអាណាព្យាបាលបារាំង ឆ្នាំ១៩៥៣។ ចលនាអក្សរសិល្ប៍នេះបានលើកឡើងពីការរស់នៅរបស់ខ្មែរពិតៗ ហើយដែលក្រសួងអប់រំ និងសិក្សាធិការបានដាក់បញ្ចូលស្នាដៃអក្សរសិល្ប៍នេះទៅក្នុងកម្មវិធីសិក្សាជាតិដែលក្នុងនោះមានស្នាដៃរបស់លោក រីម គិន លោក ញ៉ុក ថែម និងលោក នូ ហាច។

៦.៤.គណៈកម្មការវប្បធម៌និងកម្ចីពាក្យសព្ទបាលីក្នុងភាសាខ្មែរទំនើប

ក្រោយពីបានទទួលឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ កម្ពុជាបានចាប់ផ្ដើមគិតគូរពីការបង្កើតពាក្យថ្មី ដើម្បីប្រើជំនួសពាក្យបារាំង តាមរយៈការអនុម័តពាក្យបច្ចេកទេស ដើម្បីឱ្យភាសាខ្មែរអាចដើរតួនាទីមិនមែនត្រឹមតែភាសា អក្សរសិល្ប៍ឡើយ តែជាភាសាវិទ្យាសាស្ត្រ និងបច្ចេកទេសផងដែរ។ ការពិភាក្សា នៅទសវត្សឆ្នាំ៥០ និង៦០ផ្ដោតទៅលើ៖ (១) ការខ្ចីពាក្យពីភាសាបាលី និង (២)ការបង្កើតពាក្យថ្មី។

៦.៤.១. កម្ចីពាក្យសព្ទបាលីក្នុងដំណាក់កាលថ្មី

ដើម្បីលើកកម្ពស់ការប្រើប្រាស់ភាសាជាតិ នៅឆ្នាំ១៩៤៦ «គណៈកម្មការវប្បធម៌» ត្រូវបានបង្កើតឡើង ដើម្បីបង្កើតពាក្យថ្មី។ គណៈកម្មការនេះមានសមាជិក១៥រូប ដែលចេញពីសាលាបាលីជាន់ខ្ពស់ភ្នំពេញ។ ដើម្បីបង្កើតពាក្យឱ្យសម្បូរ គណៈកម្មការបានស្រង់ពាក្យសំស្ក្រឹត និងមគធៈ (បាលី) ជាច្រើន ក្រៅពីពាក្យដែលធ្លាប់ប្រើ យកមកទុកក្នុងវចនានុក្រម ទុកជាសម្បត្តិឬជារបស់លំអរសៀវភៅ ហើយអ្នកនិពន្ធយល់ថា ពាក្យទាំងនេះនឹងផ្ដល់ផលប្រយោជន៍នៅពេលណាពុំខាន។ អ្នករៀបចំចាត់ទុកពាក្យទាំងនោះជា «មេពាក្យ» ដែលអាចយកទៅបំបែកប្រើបានទៀត។

ដើម្បីឱ្យកម្ចីពាក្យក្នុងភាសាខ្មែរខុសពីកម្ចីពាក្យក្នុងភាសាសៀម ដែលនិយមពាក្យសំស្ក្រឹត សមាជិកគណៈកម្មការវប្បធម៌សម្រេចខ្ចីពាក្យពីភាសាបាលី ដើម្បីយកមកប្រើក្នុងការបង្កើតពាក្យថ្មី។ គណៈកម្មការវប្បធម៌ថែងអំពីរបៀបកែតម្រង់ពាក្យក្នុងភាសាជាតិ ឱ្យបានត្រឹមត្រូវតាមក្បួនខ្នាត និងបានស្រង់យកពាក្យខ្លះដែលជាប់ទាក់ទងនឹងពាក្យបាលី មកអធិប្បាយពន្យល់ជូនក្នុងទំព័រទស្សនាវដ្ដីកម្ពុជសុរិយា។ ពាក្យថ្មីត្រូវបានគណៈកម្មការវប្បធម៌យកមកចុះផ្សាយ នៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា និងតាមវិទ្យុជាតិយ៉ាង

ទូលំទូលាយ ក្នុងគោលដៅបង្កើតឯកភាពជាតិក្នុងការសរសេរពាក្យ។

ដូច្នេះ «គណៈកម្មការវប្បធម៌» និងការបង្កើតវចនានុក្រមខ្មែរបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការរៀបចំភាសាខ្មែរ ឱ្យមានក្បួនខ្នាតត្រឹមត្រូវ និងកំណត់អក្ខរាវិរុទ្ធក្នុងការសរសេរពាក្យឱ្យបានត្រឹមត្រូវ ជាពិសេសការបង្កើតជាគោលការណ៍រួមសម្រាប់បង្កើតពាក្យថ្មីប្រើប្រាស់ ទៅតាមតម្រូវការនៃការវិវត្តនៃសង្គមជាតិយើង។ មានអ្នកប្រាជ្ញជាច្រើនដែលចូលរួមនៅក្នុងគណកម្មការវប្បធម៌នេះ ដូចជា៖ ចាប ពិន, សម្ដេចជួន ណាត, សម្ដេចហួត តាត, គីម ហាក់, ព្រះអគ្គសូ ហាយ, ព្រះអគ្គប៉ុណ្ណ សម្ភាជ, ញ៉ឹក នូវ, ឈឹម ក្រសេម, ញ៉ុក ថែម, ចៅ សៅ, តាន់ គឹមហួន, ហូ តុងលីប, ម៉ៅ សាយ, កេង វ៉ាន់សាក់, អេង សុត, ហ៊ែល សំផា ។ល។

«គណៈកម្មការវប្បធម៌» បានរៀបចំវិធានក្នុងការបង្កើតពាក្យថ្មី តាមការផ្គុំពាក្យខ្ចីពីបាលី និងសំស្ក្រឹត (ឃីន សុខ, 2007)៖

ទីមួយ-ដោយប្រើបុព្វបទ៖ (១) «អ» សម្រាប់ពាក្យបដិសេធ(អយុត្តិធម៌) (២) «អតិ» សម្រាប់ពាក្យខ្លាំងក្រៃលែង (អតិសុខុមទស្សន៍) (៣) «អធិ» សម្រាប់ពាក្យខ្ពស់ក្រៃលែង (អធិបតី) (៤) «អភិ» សម្រាប់ពាក្យខ្ពង់ខ្ពស់ (អភិបាល) (៥) «អនុ» សម្រាប់ពាក្យបន្ទាប់ (អនុប្រធាន) (៦) «អប» សម្រាប់ពាក្យគ្មាន (អបមង្គល) (៧) «ឧប» សម្រាប់ពាក្យរង (ឧបរាជ) (៨) «ទុរ» សម្រាប់ពាក្យលំបាក (ទុរគត) (៩) «និរ» សម្រាប់ពាក្យគ្មាន (និរទោស) (១០) «ប្រតិ» និង «បដិ» សម្រាប់ពាក្យតទល់គ្នា (ប្រតិកម្ម និងបដិវត្តន៍) (១១) «បរ» សម្រាប់ពាក្យខាងក្រៅ (បរទេស) (១២) «បរិ» សម្រាប់ពាក្យណាស់ (បរិសុទ្ធ) (១៣) «វិ» សម្រាប់ពាក្យដាច់ឡែក (វិសាមញ្ញ) (១៤) «សុ» សម្រាប់ពាក្យល្អ (សុគត)។

ទីពី-ដោយប្រើបច្ឆិមបទ៖ (១) «និយម» សម្រាប់ពាក្យចូលរួមគំនិត (ខ្មែរនិយម) (២) «ឧបនីយកម្ម» សម្រាប់ពាក្យផ្លាស់ប្តូរភាវៈ (ឧស្សាហូបនីយកម្ម) (៣) «សាស្ត្រ ឬវិទ្យា» សម្រាប់ពាក្យវិទ្យាសាស្ត្រ (គណិតវិទ្យា)

(៤) «ភាព» សម្រាប់ពាក្យបញ្ជាក់ពីភាវៈ (សមភាព) (៥) «វិទូ» សម្រាប់បញ្ជាក់ពីមុខងារ(គណិតវិទូ)(៦)«សភា»សម្រាប់ពាក្យបញ្ជាក់ពីអង្គប្រជុំ (រដ្ឋសភា) (៧) «ស្ថាន» សម្រាប់ពាក្យបញ្ជាក់ពីទីកន្លែង (វិទ្យាស្ថាន)។

ទីបី-ដោយផ្សំពាក្យ៖ (១) «ចលន + វត្ត» ដើរ និង វត្ត (ចលនវត្ត) (២) «អត្ត + នាយក» ជំ និងមេ (អត្តនាយក) (៣) «សាស្ត្រ + ចារ្យ» វិជ្ជា និង គ្រូ (សាស្ត្រាចារ្យ)។

៦.៤.២. ជម្លោះភាសារវាងពួកបាលីនិយម និងពួកខ្មែរនិយម

ការជ្រើសរើសយកពាក្យបាលីមកធ្វើជាប្រភពតែមួយគត់ សម្រាប់បង្កើតពាក្យថ្មីបានបង្កើតឱ្យមានទំនាស់រវាងពួកបាលីនិយម និងពួកខ្មែរនិយម (ឃីន សុខ.2007)។ ប្រការនេះបង្កើតឱ្យមានពាក្យពីរថ្នាក់ គឺពាក្យបាលីដែលជាពាក្យវប្បធម៌សម្រាប់សរសេរផ្លូវការ និងពាក្យខ្មែរដែលប្រើប្រាស់ដោយប្រជាជនទូទៅ។

ពាក្យបាលី	ពាក្យខ្មែរ
ទោចក្រយាន	កង់
អយស្ម័យយាន	រទេះភ្លើង ឬ រថភ្លើង
ទូរលេខ	ខ្សែលួស
វិក្កយបត្រ	បង្កាន់ដៃ

នៅទសវត្សរ៍ឆ្នាំ១៩៦០ មានចរន្តពីរ ដែលមិនសូវចុះសម្រុងគ្នាក្នុងការកែលម្អភាសា និងអក្សរខ្មែរ គឺចរន្តសម្តេចព្រះសង្ឃរាជ ជួន ណាត តំណាងអភិរក្សនិយម និងចរន្តលោក កេង វ៉ាន់សាក់ តំណាងទំនើបកម្ម ដែលបណ្តាលឱ្យមានបក្សសាវ៉ក ឬសិស្សគណៈផ្សេងៗគ្នា។ ក្នុងការបង្កើតពាក្យថ្មី ចរន្តសម្តេចព្រះសង្ឃរាជ ជួន ណាត ច្រើនខ្ចីពីពាក្យបាលី និងសំស្ក្រឹត។ ចំណែកលោក កេង វ៉ាន់សាក់ បានស្នើឡើងនូវមូលភាពធំៗចំនួន៥ នៅក្នុង

ស្នាដៃរបស់លោកស្តីពី «មូលភាពនៃការបង្កើតពាក្យថ្មី»។

លោក កេង វ៉ាន់សាក់ (១៩២៥-២០០៨) បានប្រឡងជាប់បរិញ្ញាបត្រផ្នែកទស្សនវិជ្ជា នៅសាកលវិទ្យាល័យស័របោន ក្រុងប៉ារីស នៅឆ្នាំ១៩៥១។ នៅឆ្នាំ១៩៥២-១៩៥៤ លោកជាសាស្ត្រាចារ្យនៅវិទ្យាល័យស៊ីសុវត្ថិ។ លោកជាមេដឹកនាំគណបក្សប្រជាធិបតេយ្យនៅពេលបោះឆ្នោតឆ្នាំ១៩៥៥។ បន្ទាប់ពីបរាជ័យនៃគណបក្សប្រជាធិបតេយ្យ រដ្ឋាភិបាលសង្គមរាស្ត្រនិយមបានបញ្ជាឱ្យចាប់លោកដាក់គុកពីខែកញ្ញា ដល់តុលា ឆ្នាំ១៩៥៥។ ដល់ពេលចេញពីពន្ធនាគារ លោកបានបោះពុម្ពផ្សាយកម្រងកំណាព្យដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លា ទៅលើកវីនិពន្ធខ្មែរជំនាន់នោះ។ ពីឆ្នាំ១៩៥៨ ដល់ ១៩៦២ លោកមានតំណែងជាព្រឹទ្ធបុរសមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ និងជាចាងហ្វាងវិទ្យាស្ថានជាតិគរុកោសល្យ (១៩៥៨-១៩៦០)។ លោកបានការពារនិក្ខេបបទថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យស័របោន ដែលមានចំណងជើងថា «ការស្រាវជ្រាវឫសគល់នៃវប្បធម៌ខ្មែរ»។ លោកបានបង្កើតពុម្ពអក្សរខ្មែរ សម្រាប់ប្រើក្នុងម៉ាស៊ីនអង្គុលីលេខ។ ដើម្បីជាគារវកិច្ចនិងជាអភិវន្ទនាការចំពោះលោក កេង វ៉ាន់សាក់ បណ្ឌិតសភាចារ្យ ឃីង ហុកឌី បានសរសេរថា៖«សាស្ត្រាចារ្យកេង វ៉ាន់សាក់ជាគ្រូអក្សរសាស្ត្រទី១ នៅឧត្តមសិក្សា លោកបានបង្ហាត់បង្រៀនសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរជាច្រើនជំនាន់ ហើយសាស្ត្រាចារ្យទាំងនេះបានចេញអប់រំយុវជនខ្មែរផ្នែកអក្សរសាស្ត្រ នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនានាទូទាំងប្រទេសរហូតដល់ឆ្នាំ១៩៧៥។ សាស្ត្រាចារ្យកេង វ៉ាន់សាក់ ជាកវីមួយរូបបានផ្តើមកំណាព្យកាព្យឃ្លោងបែបទំនើប ជាអ្នកស្រាវជ្រាវ និងជាគ្រូដ៏ចំណានប្រកបដោយគរុកោសល្យខ្ពស់ បានផ្តល់ចំណេះដឹងអ្វីជាខ្មែរជាប់ក្នុងអារម្មណ៍ និងជាអនុស្សាវរីយ៍ជានិរន្តរ៍ ដែលយើងជាសិស្សចាស់ មិនអាចបំភ្លេចបាននូវឧបការគុណនេះឡើយ»(ឃីង ហុកឌី,២០០៦)។ លោកបានបង្កើតពុម្ពអក្សរអង្គុលីលេខខ្មែរ (១៩៥២) និពន្ធស្នាដៃមួយចំនួនដូចជាកំណាព្យចិត្តក្រមុំ

(១៩៥២) និងបាននិពន្ធសិក្សាស្ដីពី «មូលភាពនៃការបង្កើតពាក្យថ្មី»(១៩៦២) និង«សូរសព្ទខ្មែរ» (១៩៦៦)(ឃីង ហុកឌី,២០០៦)។

លោក កេង វ៉ាន់សាក់ បានលើកឡើងពីមូលភាព (principes) ចំនួន៥ ក្នុងការបង្កើតពាក្យថ្មី គឺ៖

ទីមួយ-បង្កើតពាក្យថ្មី ក្នុងករណីគ្មានពាក្យក្នុងភាសាជាតិ៖ (១) ត្រូវយកភាសាជាតិមកប្រើឱ្យគ្រប់សព្វសិន (២) មិនត្រូវបង្កើតពាក្យថ្មីជំនួសពាក្យមានក្នុងភាសាជាតិ (៣) យកពាក្យខ្មែរបុរាណមកប្រើសិន។

ទីពីរ-បង្កើតពាក្យថ្មី ដោយការបកប្រែ និងអធិប្បាយឱ្យបានគ្រប់សព្វ៖ (១)មិនមែនគ្រាន់តែបកប្រែពាក្យពីបរទេសមកភាសាជាតិប៉ុណ្ណោះទេ (២) ត្រូវសម្រួលពាក្យថ្មីឱ្យសមស្របទៅនឹងភាសាជាតិ (៣) ត្រូវបង្កើតពាក្យថ្មីក្នុងការបកប្រែ (៤) ត្រូវខ្ចីពាក្យបរទេសខ្លះមកប្រើ (៥) ត្រូវប្រើពាក្យចាស់ដោយកែប្រែឱ្យមានន័យថ្មី (៦) ត្រូវរក្សាទុកពាក្យបច្ចេកទេសអន្តរជាតិ ដែលពិភពលោកស្គាល់។

ទីបី-បង្កើតពាក្យថ្មីតាមវិចារណវិធី ដើម្បីវឌ្ឍនភាព ឯកភាព និងរបៀបរៀបរយនៃភាសា៖ (១) យកសេចក្ដីត្រូវការក្នុងវប្បធម៌ និងសង្គមធម៌ជាមូលហេតុបង្កើតពាក្យថ្មី (២) យកវិជ្ជា និងការអនុវត្តជាមូលដ្ឋាន (៣) គោរពឫសគល់ និងមូលបទនៃពាក្យ។

ទីបួន-បង្កើតពាក្យថ្មី ដោយខេមរយានកម្ម ដោយកុំចម្លងតាមបរទេស តែខំបង្កើត ខំប្រើ និងខំគិតជាខ្មែរ។ និង

ទីប្រាំ-បង្កើតពាក្យថ្មី ដោយសម្រេចយកជាផ្លូវការ ដោយការភ្ជាប់ទ្រឹស្ដី ទៅនឹងអនុវត្តន៍។

៦.៥.ចលនាខេមរយានកម្ម និងកំណើនភាគរូបនីយកម្មភាសាខ្មែរ

នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ភាសាខ្មែរត្រូវបានបញ្ចូលជាបណ្ដើរៗក្រោមចលនាខេមរយានកម្ម។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៦៧ អង្គប្រជុំ

ជាន់ខ្ពស់នៃសាកលវិទ្យាល័យនៃក្រសួងអប់រំជាតិ សម្រេចបង្កើតគណៈកម្មការរៀបចំធ្វើខេមរយានកម្មក្នុងការសិក្សា។ គោលដៅនៃចលនាខេមរ-យានកម្មនេះ គឺដើម្បីលើកតម្កើងភាសាខ្មែរក្នុងប្រព័ន្ធអប់រំ ដើម្បីឱ្យ «ភាសា និងអក្សរជាតិក្លាយជាកណ្ដៀវសម្រាប់ច្រូតកាត់ប្រមូលចំណេះវិជ្ជាពីបរទេសមកទុកក្នុងជង្រុកជាតិ សម្រាប់ផ្សព្វផ្សាយបន្តទៅប្រជាជាតិខ្មែរទាំងមូល» (ក្រសួងអប់រំជាតិ, ១៩៧២)។ ក្នុងខែកក្កដា ឆ្នាំ១៩៦៧ អង្គប្រជុំនៃក្រសួងអប់រំជាតិបានសម្រេចឱ្យអនុវត្ត ខេមរយានកម្មគ្រប់មុខវិជ្ជានៅមធ្យមសិក្សានៅថ្នាក់ទី៦ ចាប់ពីឆ្នាំ១៩៦៧-៦៨ តទៅ។ មូលហេតុដែលមានការសម្រេចឱ្យអនុវត្តខេមរយានកម្មនៅមធ្យមសិក្សា គឺដោយសារតែក្រោយពីបានទទួលឯករាជ្យពីបារាំងមក នៅកម្រិតបឋមសិក្សា ការរៀន និងការបង្រៀនមិនអាចយកភាសាបារាំងជាភាសាយានទៀតបាន ដោយសារខ្វះគ្រូជំនាញខាងភាសាបារាំង។ ម្យ៉ាងវិញទៀត ចលនាខេមរយានកម្មនេះមានគោលដៅផ្ដល់ការអប់រំប្រកបដោយសមធម៌ ដើម្បីឱ្យ «ប្រជាជាតិខ្មែរដែលកំពុងស្រេកឃ្លានសេចក្ដីចម្រើនលូតលាស់ខាងផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ព្រមទាំងផ្នែកវប្បធម៌ទូទៅ...ទទួលបានចំណេះដឹងទាំងនេះបានលុះត្រាតែប្រើមធ្យោបាយភាសា និងអក្សរខ្មែរជាយាន»។

ដើម្បីអនុវត្តគោលនយោបាយខេមរយានកម្មឱ្យបានជោគជ័យ ក្រសួងអប់រំជាតិបានបង្កើតគណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្ម[3] ដែលមានគណៈកម្មការពិសេស និងអគ្គលេខាធិការដ្ឋាននៅក្រោមឱវាទ និងមានមុខងារ និងភារកិច្ចដូចតទៅ ៖ (១) អនុវត្តខេមរយានកម្មក្នុងការសិក្សា (២) ផ្សព្វផ្សាយចំណេះវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ទូទៅដោយប្រើអក្សរ និងភាសាខ្មែរ (៣) រៀបរៀងបោះពុម្ព និងផ្សព្វផ្សាយព្រឹត្តិបត្រទស្សនាវដ្ដីសៀវភៅសិក្សា សៀវភៅវប្បធម៌ទូទៅបែបខេមរយានកម្ម (៤) ប្រមូលផ្ដុំឯកសារស្រាវជ្រាវគ្រប់មុខវិជ្ជា (៥) សិក្សាស្រាវជ្រាវអំពីអក្សរខ្មែរ ភាសាខ្មែរ

3 តាមរយៈលិខិតបង្គាប់ការលេខ៥០៦ កន ចុះថ្ងៃទី៥ សីហា ឆ្នាំ១៩៦៧។

ព្រមទាំងវិជ្ជាឯកទេសនានា ដើម្បីជាមូលដ្ឋាននៃអនុវត្តន៍ខេមរយានកម្ម និង (៦) ទាក់ទង និងផ្លាស់ប្ដូរលទ្ធផលសិក្សាស្រាវជ្រាវនៃវិជ្ជាឯកទេសនានា ជាមួយនឹងអង្គការជាតិ និងអន្តរជាតិដែលមានសមត្ថកិច្ចដូចគ្នា។

ក្រសួងអប់រំជាតិបានបង្កើតគណៈកម្មការបច្ចេកទេសខាងផ្នែកពាក្យវេយ្យាករណ៍ អក្សរសាស្ត្រ ប្រវត្តិវិទ្យា ភូមិវិទ្យា ទស្សនវិជ្ជា សិល្បៈ គណិតវិទ្យា រូបវិទ្យា–គីមី ធម្មជាតិវិទ្យា ពេទ្យជាង កសិកម្ម កីឡា វិជ្ជាមេផ្ទះ ដើម្បីរៀបចំសៀវភៅគោលសិក្សាតាមមុខវិជ្ជាទាំងនេះ។ ខេមរយានកម្មនៅមធ្យមសិក្សាត្រូវបានអនុវត្តជាដំណាក់កាល ៖ ឆ្នាំ១៩៦៧-៦៨ នៅថ្នាក់ទី៦, ឆ្នាំ១៩៦៨-៦៩ នៅថ្នាក់ទី៥, ឆ្នាំ១៩៦៩-៧០ នៅថ្នាក់ទី៤, ឆ្នាំ១៩៧០-៧១ នៅថ្នាក់ទី៣, ឆ្នាំ១៩៧១-៧២ នៅថ្នាក់ទី២, ឆ្នាំ១៩៧២-៧៣ នៅថ្នាក់ទី១, និងឆ្នាំ១៩៧៣-៧៤ នៅថ្នាក់ទីបញ្ចប់។ ក្នុងដំណាក់កាលនោះ មានការប្រជុំអនុម័តពាក្យបច្ចេកទេសគ្រប់មុខជំនាញទាំងភាសាជាតិ ទាំងពាក្យបរទេស ដែលពាក្យទាំងនោះត្រូវបានផ្សព្វផ្សាយតាមទស្សនាវដ្ដីខេមរយានកម្ម និងបោះពុម្ពផ្សាយសទ្ទានុក្រមបារាំង-ខ្មែរខ្នាតតូចមួយ។ គោលការណ៍ និងពាក្យបច្ចេកទេសទាំងអស់ ដែលគណៈកម្មការជាតិខេមរយានកម្មបានសម្រេចហើយ ត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងអនុម័តចុងក្រោយដោយសម្ដេចព្រះសង្ឃរាជ ជួន ណាត។ បន្ទាប់ពីសម្ដេចព្រះសង្ឃរាជ ជួន ណាត សុគតទៅ ត្រូវបានជំនួសដោយសម្ដេចព្រះសង្ឃរាជ ហួត តាត។

តាមផែនការដែលបានដាក់ចេញនេះ ការអនុវត្តខេមរយានកម្មនៅមធ្យមសិក្សាត្រូវអនុវត្តចប់សព្វគ្រប់នៅក្នុងឆ្នាំសិក្សា ១៩៧៣-៧៤ ដែលមានសិស្សជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិតាមកម្មវិធីខេមរយានកម្មជាលើកដំបូង។ នៅដំណាក់កាលបន្ទាប់ទៀត ក្រសួងអប់រំមានគម្រោងចាប់ផ្ដើមអនុវត្តកម្មវិធីខេមរយានកម្មនៅឧត្តមសិក្សា ចាប់ពីឆ្នាំ១៩៧៤-៧៥។ ក៏ប៉ុន្តែរបបកម្ពុជាប្រជាធិបតេយ្យប្រល័យពូជសាសន៍បានបញ្ឈប់ចលនា-ខេមរយានកម្មត្រឹមនេះតែម្ដង។

ការអប់រំត្រូវបានសាធារណជនចាត់ទុកថា ជាមធ្យោបាយប្រកបដោយប្រសិទ្ធភាព សម្រាប់យុវជនក្រីក្រជាច្រើន ដែលមកពីតំបន់ជនបទដាច់ស្រយាលនានា ដើម្បីរំដោះ ពួកគេឱ្យងើបចេញផុតពីភាពក្រីក្រ ក្លាយខ្លួនជាវណ្ណៈកណ្តាល និងអាចធ្វើឱ្យពួកគេចូលប្រឡូកជីវិតនយោបាយថែមទៀតផង។ ទោះជាយ៉ាងណា ដោយមានអតីតភាពជាអ្នកក្រីក្រ ក្រុមបញ្ញវន្តទាំងនោះតែងតែមានទំនោរទៅរកនិន្នាការនយោបាយឆ្វេងនិយម។ គ្រូបង្រៀនជាច្រើនបានចូលរួមក្នុងការស្វែងរកយុត្តិធម៌សង្គម ដោយទៅចូលរួមជាមួយពួកខ្មែរក្រហម។ ប្រការនេះបាននាំទៅដល់ការធ្លាក់ចុះនៃរបបសីហនុនិយម។

៦.៥.១. ការកែប្រែអក្ខរាវិរុទ្ធពីទសវត្សឆ្នាំ១៩៧០ ដល់ ១៩៩០

ការកែប្រែអក្ខរាវិរុទ្ធបានធ្វើឱ្យមានការព្រួយបារម្ភ និងជម្លោះជាច្រើនលើកច្រើនសារនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ចាប់តាំងពីទសវត្សឆ្នាំ១៩៧០ ចលនាខេមរយានកម្មបានឈានទៅដល់ការកែទម្រង់អក្ខរាវិរុទ្ធ។ នៅឆ្នាំ ១៩៧២ លោក ឡុប ផ្វែង បានស្នើសុំឱ្យមានការកែប្រែអក្ខរាវិរុទ្ធ ដើម្បីកាត់បន្ថយចំនួនអក្សរនៅក្នុងភាសាខ្មែរ និងលើកកម្ពស់វិស័យអប់រំ (KHIN SOK, 1999; SASAGAWA, 2015; *លី សុវី.* 2006)។ *ការកែប្រែអក្ខរាវិរុទ្ធនេះទទួលឥទ្ធិពលពីលោក ឃួន សុខម្ភូ ដែលជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ លោក វ៉ាន់ឌី កាអុន បានជំទាស់យ៉ាងខ្លាំងចំពោះការកែប្រែអក្ខរាវិរុទ្ធនេះ។*

លោក ឃួន សុខម្ភូ (១៩៣១-១៩៧៥) កើតនៅសង្កាត់ទូកមាស ខេត្តកំពត។ លោកមានសញ្ញាបត្របណ្ឌិតអក្សរសាស្ត្រផ្នែកភាសាវិទ្យាពីសាកលវិទ្យាល័យ ហ៊ុម ប៊ុល អាល្លឺម៉ង់។ លោកបានពន្យល់ពីមូលដ្ឋាននៃអក្សរសាស្ត្រខ្មែរក្នុងស្នាដៃរបស់លោក ដែលជានិក្ខេបបទថ្នាក់បណ្ឌិតមានចំណងជើងថា «ទម្រង់សូរវិទ្យាខ្មែរ» (ឆ្នាំ១៩៧១)។

អក្ខរាវិរុទ្ធចាស់	អក្ខរាវិរុទ្ធថ្មី
តម្លៃ	តំលៃ
កំណើត	កំនើត
ឯណា	អែណា

ជម្លោះអក្សរសាស្ត្របានកើតឡើងម្តងទៀតនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ដោយសារសិស្សគណរបស់លោក ឃួន សុខម្ភ បានបង្កើតចលនាទំនាញសូរក្នុងភាសាខ្មែរ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ក្រសួងអប់រំបានសម្រេចប្រើទម្រង់សំណេរពាក្យ តាមគោលការណ៍ខេមរយានកម្ម។ នៅឆ្នាំ១៩៨៥ ក្រសួងអប់រំបានបោះផ្សាយសៀវភៅ«បញ្ហាទំនាញសូរក្នុងសំណេរ ៖ ពាក្យមួយចំនួនដែលអាចសរសេរបានពីរយ៉ាង»។ ការអនុវត្តគោលការណ៍ទំនាញសូរនេះ គឺជាការបោះជំហានទៅមុខមួយជំហានទៀត ពីគោលការណ៍បង្កើតពាក្យថ្មីនៃខេមរយានកម្ម។ នៅដំណាក់កាល ខេមរយានកម្ម គណៈកម្មការបានអនុម័តគោលការណ៍បញ្ចូលពាក្យវែង ឬឃ្លា ឱ្យមកក្លាយជាពាក្យដុំ តាមកម្លាយរបស់ក្បួនកម្លាយភាសាខ្មែរ។

ពាក្យចាស់	ពាក្យថ្មី
ការថែទាំ	តំហែទាំ
ការកើត	កំនើត
ការទទួលខុសត្រូវ	ទំនួលខុសត្រូវ

ការអនុម័តលើគោលការណ៍ទំនាញសូរ ជាពិសេសការអនុម័តលើពាក្យដែលអាចសរសេរបានពីរយ៉ាង បានធ្វើឱ្យសង្គ្រាមអក្សរសាស្ត្រផ្ទុះឡើងរវាងលោក វ៉ាន់ឌី កាអុន ដែលជាសមាជិកក្រុមប្រឹក្សារដ្ឋនិងជានាយកវិទ្យាស្ថានសង្គមវិទ្យា ដែលប្រកាន់យកការសរសេរភាសាខ្មែរតាមវចនានុក្រមខ្មែររបស់សម្តេចសង្ឃ ជួន ណាត ជាមួយនឹងក្រុមអ្នកអក្សរសាស្ត្រនៃក្រសួងអប់រំ យុវជន និងកីឡា ដែលប្រកាន់យកការសរសេរភាសាខ្មែរតាមខេមរ-

យានកម្ម និងតាមបែបទំនាញសូរ។ ឧទាហរណ៍ «កំណក»អាចសរសេរជា «កំនក» «អំណាច» អាចសរសេរជា «អំនាច»។ ម្យ៉ាងវិញទៀត ពាក្យព្យាង្គតម្រួតខ្លះត្រូវបានសរសេរ ជាព្យាង្គរាយវិញ ដូចជា ៖ «កម្ទា» អាចសរសេរជា «កំលា» «ចម្លង» អាចសរសេរជា «ចំលង»។ល។ និងការដូរពីអក្សរ «ឡ» ទៅសរសេរជាអក្សរ «ល» វិញដូចជា «ក្រឡោត» អាចសរសេរជា «ក្រលោត»។

នៅក្នុងឆ្នាំ១៩៨៥ សង្គ្រាមអក្សរសាស្ត្រនេះត្រូវបានយកមកពិភាក្សាក្នុងរបៀបវារៈនៃការប្រជុំការិយាល័យនយោបាយនៃគណបក្សប្រជាជនកម្ពុជា និងការពិភាក្សាក្នុងរដ្ឋសភាជាតិនៅពេលនោះ។ ក្រុមប្រឹក្សារដ្ឋបានសម្រេចក្នុងសម័យប្រជុំថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៨៥ លើបីចំណុច ដើម្បីដោះស្រាយចំពោះមុខ ៖

ទី១-អនុវត្តតាមក្បួនរបៀបចាស់ និងរក្សាការសរសេរក្នុង៦ឆ្នាំកន្លងមក។

ទី២-ធ្វើតារាងស្តីពីពាក្យដែលបានប្រើក្នុង៦ឆ្នាំកន្លងមក និងពាក្យគូដែលធ្លាប់ប្រើតាមរបៀបទម្លាប់ចាស់។

ទី៣-ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវព្រាងសមាសភាពគណៈកម្មាធិការជាតិមួយស្តីពីការប្រើប្រាស់អក្សរខ្មែរ[4]។

ក្រសួងអប់រំក៏បានរៀបចំប្រជុំអន្តរក្រសួងមួយ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៨៥ដើម្បីត្រៀមរៀបចំការរៀន និងបង្រៀនជាភាសាខ្មែរ នៅឧត្តមសិក្សា និងសិក្សាបច្ចេកទេស ហើយអង្គប្រជុំបានដាក់ចេញជាគោលការណ៍រួមដូចតទៅ ៖

ទី១-បន្តស្នាដៃខេមរយានកម្មតទៅទៀត

ទី២-យកភាសាបារាំងជាគោល ក្នុងការពិគ្រោះ និងបកប្រែពាក្យ (សូរបារាំង)

ទី៣-ខិតខំស្រាវជ្រាវ ប្រើពាក្យខ្មែរសុទ្ធ ទាំងសំណោរ និងសំណួរ

ទី៤-បើរកពាក្យខ្មែរសុទ្ធមិនបាន ទើបរកពាក្យខ្មែរបុរាណពាក្យបាលី

[4] ក្រសួងអប់រំ (១៩៨៥) កំណត់ហេតុស្ដីពីសម័យប្រជុំអន្តរក្រសួងនៅវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ ថ្ងៃទី១៩ ខែមេសា ១៩៨៥។

សំស្ក្រឹត ឬបរទេសផ្សេងៗ

ទី៥-ពាក្យដែលស៊ីជម្រៅទៅក្នុងស្រទាប់មហាជនរួចហើយ មិនត្រូវបង្កើតទៀតទេ

ទី៦-ក្នុងការបង្កើតពាក្យ ត្រូវអនុវត្តតាមវិធីផ្ទួលពាក្យតាមឫសរបស់ពាក្យ

ទី៧-ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដោយក្រសួងអប់រំ

ទី៨-បង្កើតគណៈកម្មការទូលំទូលាយមួយ ដើម្បីឱ្យមានការឯកភាពក្នុងការបង្កើត និងប្រើប្រាស់ទូទាំងប្រទេស

ទី៩-ចំពោះវិទ្យាសាស្ត្រសង្គម ត្រូវអនុវត្តតាមគោលការណ៍ខាងលើ តែត្រូវឱ្យអាទិភាពទៅលើពាក្យខ្មែរសុទ្ធ

ទី១០-ចំពោះវិទ្យាសាស្ត្រពិត ត្រូវអនុវត្តតាមគោលការណ៍រួមដែរ តែត្រូវឱ្យអាទិភាពទៅលើពាក្យអន្តរជាតិ ដែលធ្លាប់ប្រើប្រាស់កន្លងមកហើយ ឬក៏សម្របសម្រួលតាមលក្ខណៈខ្មែរ ដោយរក្សាពាក្យដើម ងាយស្រួលទាក់ទងអន្តរជាតិផងៗ

បញ្ហាជម្លោះអក្សរសាស្ត្រនេះនៅតែបន្តរហូតដល់ឆ្នាំ២០០០ៗ នៅក្នុងឱកាសបិទសន្និសីទជាតិស្ដីពីការស្រាវជ្រាវឯកភាព និងអភិវឌ្ឍភាសាខ្មែរនៅរាជបណ្ឌិត្យសភាកម្ពុជា នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០០ ឯកឧត្តម ស ខេង នាយករដ្ឋមន្ត្រីស្ដីទីបានមានប្រសាសន៍ថា ៖ «ដើម្បីសម្រេចបាននូវការឯកភាពភាសាជាតិខ្មែរយើង ពីលើវេទិកានៃអង្គសន្និសីទនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមអំពាវនាវឱ្យជនរួមជាតិខ្មែរទាំងអស់ ទាំងក្នុងប្រទេស ទាំងបងប្អូនជនរួមជាតិខ្មែរដែលកំពុងតែរស់នៅឯបរទេស នៅពេលសរសេរអក្សរខ្មែរ ត្រូវគោរពប្រតិបត្តិតាមក្បួនច្បាប់នៃការសរសេរ និងអក្ខរាវិរុទ្ធទាំងឡាយនៅក្នុងវចនានុក្រមខ្មែរ និពន្ធ និងចងក្រងឡើងដោយសម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលជនរួមជាតិខ្មែរគ្រប់គ្នាទទួលស្គាល់ថា ព្រះអង្គជាអ្នកប្រាជ្ញភាសា អក្សរសាស្ត្រខ្មែរនា ស.វ.ទី២០ៗ

ខ្ញុំគិតថា វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ជាច្បាប់ដែល យើងត្រូវប្រតិបត្តិតាមក្នុងការសរសេរអក្សរខ្មែរ។ ការដែលត្រូវសរសេរតាមវចនានុក្រមនេះ យើងទាំងអស់គ្នាត្រូវតែធ្វើឡើង ដោយគោរពដល់វិន័យនៃការសរសេរអក្សរសាស្ត្រជាតិ។ វិន័យនេះមានសារៈសំខាន់យ៉ាងក្រៃលែងដល់ការស្រាវជ្រាវឯកសារ និងអភិវឌ្ឍន៍ភាសាខ្មែរ»។ ជម្ពោះអក្សរសាស្ត្រនេះត្រូវបានបញ្ចប់ត្រឹមនេះ។

ឧបសម្ព័ន្ធទី១៖ ព្រះនាមព្រះមហាក្សត្រសម័យក្រោយអង្គរ

លរ	នាមសម្រាប់រាជ្យ នាមផ្ទាល់	កាល បរិច្ឆេទ	រាជវង្ស និង ព្រឹត្តិការណ៍សំខាន់ៗ
១	ជ័យជេដ្ឋាទី២	(១៦១៩ -១៦២៧)	បុត្រ **ស្រីសុរិយោពណ៌** -មានទំនាក់ទំនងជាមួយ ក្រុមហ៊ុនហូឡង់ East Indies -នៅឆ្នាំ១៦១៦ រៀបអភិសេកជាមួយបុត្រីស្តេចយួនអង្គចូវ ជាអគ្គមហេសី -អនុញ្ញាតឱ្យវៀតណាមបង្កើតគ្រឹះស្ថានជំនួញនៅព្រៃនគរ និងកំពង់ក្របី -សៀមវាយចូលកម្ពុជានៅឆ្នាំ ១៦២២ និង ១៦២៣ -ពិនិត្យឡើងវិញនូវច្បាប់មួយចំនួន -មានបុត្រ ២ អង្គ៖ ពញាតូ ពញានូ ពញាចន្ទនិងបុប្ផាវតី -ព្រះឧទ័យមានបុត្រ៤អង្គ៖ អង្គនន់ អង្គសូរ អង្គតន់ និងអង្គអិមៗ
២	ស្រីធម្មោរាជាទី១ ព្រះរាជសំភារ ចៅពញាតូ	(១៦២៧- ១៦៣២)	បុត្រ ជ័យជេដ្ឋាទី២ -បួសនៅនគរវត្តនិងសរសេរកំណាព្យ -ចាកចេញពីឧដុង្គមកសង់វាំងនៅគោកធ្លក ទន្លេធំ ជិតជ្រោយចង្វារ -ព្រះបរមរាជាឧទ័យជា ឧកយោរាជតែកាន់អំណាចនិងប្រតិព័ទ្ធជាមួយក្សួយឯងច័ន្ទវតី -លួចទាក់ទងស្នេហាជាមួយ ច័ន្ទវតី ហើយត្រូវព្រះឧទ័យសម្លាប់

៣	អង្គទងរាជា ហៅពញានូ	(១៦៣២- ១៦៤០)	បុត្រទី២នៃព្រះបាទជ័យជេដ្ឋាទី២ -ទាមទារសុំព្រៃនគរ និង កំពង់ក្របីមកវិញ តែអង្គចូវ អន្តរាគនទម៌ពន្យាពេល។
៤	បទុមរាជា អង្គនន់	(១៦៤០- ១៦៤២)	-បុត្រព្រះឧទ័យ -ព្រះឧទ័យ ជាឧភយោរាជ កាន់អំណាច -ព្រះអង្គ និងព្រះឧទ័យ ត្រូវព្រះពញាចន្ទ បុត្រជ័យជេដ្ឋាទី២ បានធ្វើគុត -បង្កើតជាទំនាស់ក្នុងរាជវង្ស ដែលនាំឱ្យ បាត់បង់ទឹកដី
៥	រាមាធិបតីទី១ ហៅពញាចន្ទ	(១៦៤២- ១៦៥៨)	-បុត្រ ជ័យជេដ្ឋាទី២ ជាមួយអ្នកម្នាងឡាវ កើតនៅឆ្នាំ១៦០២ -ប្រតិព័ទ្ធជាមួយស្រីចាម ហើយកាន់ សាសនាអិស្លាម -ទាមទារសុំព្រៃនគរ និងកំពង់ក្របីមកវិញ -សង្គ្រាមជាមួយសៀមនៅឆ្នាំ១៦៥៨ -អន្តរាគមន៍យោធាវៀតណាមលើកទី១ នៅឆ្នាំ១៦៥៨-៥៩ -អង្គសូរ និងអង្គតន់ (បុត្រព្រះឧទ័យ) ពឹង អង្គចូវសុំទ័ពវៀតណាមច្បាំងដណ្តើមរាជ្យ។
៦	បរមរាជាទី៨ អង្គសូរ	(១៦៥៩- ១៦៧២)	-បុត្រព្រះឧទ័យ កើតនៅឆ្នាំ១៦០២ -គ្រឹះស្ថានជំនួយហូល្លង់ និងព័រទុយហ្គាល់ ត្រូវបិទទ្វារ ដោយសារចិនប្ញន់ -អភិសេកជាមួយព្រះអនុជមាតាជទៃ អង្គឡី ជាព្រះទេពី -ត្រូវក្មួយ ស្រីជ័យជេដ្ឋនិងជាបុត្រប្រសារ ធ្វើគុត ដើម្បីឡើងសោយរាជ្យ -ព្រះអនុជ អង្គតន់ ជាឧភយោរាជច្បាំងចាញ់ រួចរត់ទៅ វៀតណាមជាមួយក្មួយអង្គនន់។

៧	បទុមរាជាទី២ ស្រីជ័យជេដ្ឋ	(១៦៧១-១៦៧២)	-បុត្រ អង្គនន់ (៤) ចៅឧទ័យ កើតនៅឆ្នាំ ១៦៤១ -ព្រះអង្គយក អង្គឡី ព្រះមាតុច្ឆា ដែលជាអគ្គមហេសីព្រះអង្គសូរ ជាអគ្គមហេសី ហើយត្រូវអង្គឡី ធ្វើគុត
៨	កែវហ្វាទី២ អង្គជី	(១៦៧៣-១៦៧៥)	-បុត្រ អង្គសូរ (៦) ចៅ ឧទ័យ -ការប្រកួតប្រជែងរវាង អង្គជី និង អង្គនន់ (បុត្រ ឧទ័យ) ដែលជាព្រះបិតុលា -អង្គតន់ និង អង្គនន់ (បុត្រ ឧទ័យ) ពឹងទ័ពវៀតណាមមកច្បាំង -អន្តរាគមន៍យោធាវៀតណាមលើកទី២ នៅឆ្នាំ១៦៧៣-៧៩ -អង្គសូរ ចេញច្បាំងជាមួយ អង្គនន់ -អង្គតន់សោយទិវង្គត ហើយ អង្គនន់ ច្បាំងចាញ់ត្រឡប់ទៅវៀតណាមវិញ មានបុត្រម្នាក់ អង្គអិម នៅវៀតណាម។
៩	ជ័យជេដ្ឋាទី ទី៣ អង្គស៊ូ	(១៦៧៥-១៦៩៥)	បុត្រអង្គសូរ (៦) ចៅ ឧទ័យ -មេទ័ពចិនរដ្ឋកាលម៉េង៥០សំពៅ ភៀសខ្លួនសុំជ្រកកោនជាមួយវៀតណាម ហើយរស់នៅជិតព្រៃនគរ -ឈ្មួញចិន ម៉ាក គីវ មករស់នៅតំបន់ពាម -អង្គនន់សុំជំនួយទ័ពវៀតណាមមកច្បាំងទៀត -អន្តរាគមន៍យោធាវៀតណាមលើកទី៣ នៅឆ្នាំ១៦៨២-៨៨ -អន្តរាគមន៍យោធាវៀតណាមលើកទី៤ នៅឆ្នាំ១៦៨៨-៩០ -វៀតណាមដណ្ដើមយកម្កុជាក្រោម -ស្ដេចចាមច្បាំងចាញ់វៀតណាមបានសុំជ្រកកោនជាមួយខ្មែរនៅឆ្នាំ១៦៩២ -ដាក់រាជ្យដោយសារជំងឺ

១០	រាមាធិបតីទី២ អង្គយ៉ង	(១៦៩៥- ១៦៩៦)	បុត្រ អង្គជី (៨) ចៅខ្លួត ឧទ័យ -គ្មានព្រឹត្តិការណ៍គួរឱ្យកត់សម្គាល់
១១	ជ័យជេដ្ឋាទីទី៣ អង្គស៊ូ (រជ្ជកាលទី៣)	(១៦៩៦- ១៧០០)	បុត្រ អង្គសូរ (៦) ចៅ ឧទ័យ -នយោបាយបង្រួបបង្រួមរាជវង្ស ដោយលើកគ្រឿងបណ្ណាការ ទៅថ្វាយស្តេចយួន ដើម្បីសុំអង្គអិមមកវិញ -ទ័ពវៀតណាមលើកទ័ព មកច្បាំង តែបុត្រ ប្រសារ អង្គអិម បានច្បាំងឈ្នះ។ -ប្រគល់ព្រៃនគរ និងដូងណាយ ឱ្យវៀតណាម នៅឆ្នាំ១៦៩៨ -អន្តរាគមន៍យោធាវៀតណាម លើកទី៥ នៅឆ្នាំ១៦៩៩-១៧០០
១២	កែវហ្វាទី៣ អង្គឥម	(១៦៩៩- ១៧០០)	បុត្រអង្គទន់ (៤) ចៅ ឧទ័យ -គ្មានសមត្ថភាពគ្រប់គ្រងរដ្ឋ ទើបបិតាក្មេកឡើងសោយរាជ្យវិញ។
១៣	ជ័យជេដ្ឋាទីទី៣ អង្គស៊ូ (រជ្ជកាលទី៤)	(១៧០០- ១៧០២)	បុត្រអង្គសូរ (៦) ចៅ ឧទ័យ
១៤	ធម្មរាជាទី៣ ឬ ជ័យជេដ្ឋាទី ទី៤ (រជ្ជកាលទី១)	(១៧០២- ១៧០៣)	បុត្រជ័យជេដ្ឋាទី ទី៣ ចៅខ្លួតឧទ័យ -ឡើងសោយរាជ្យក្នុងព្រះជន្ម១២វស្សា។
១៥	ជ័យជេដ្ឋាទី ទី៣ អង្គស៊ូ (រជ្ជកាលទី៥)	(១៧០៣- ១៧០៦)	បុត្រអង្គសូរ (៦) ចៅ ឧទ័យ -ដាក់រាជ្យថ្វាយបុត្រនៅពេលមាន ព្រះជន្ម១៦វស្សាបន្ទាប់ពីសោយរាជ្យ បាន៣១ឆ្នាំ។

១៦	ធម្មរាជា ទី៣ ឬ ជ័យជេដ្ឋាទី ទី៤ (រជ្ជកាលទី២)	(១៧០៦-១៧០៩)	បុត្រ ជ័យជេដ្ឋាទីទី៣ ចៅទួត ឧទ័យ -ម៉ាក គីវលើកតង្វាយទៅថ្វាយសម្តែងស្វាមី ភក្តីភាពចំពោះស្តេចវៀង ដាក់ពាមជា សាមន្តរដ្ឋរបស់វៀតណាម -អង្គអិមមិនសប្បាយចិត្តនឹងជ័យជេដ្ឋា ទី៣ បះបោរទៅសុំទ័ពវៀតណាមមកឡោមព័ទ្ធឧដុង្គ -ធម្មរាជារត់ទៅសៀមជាមួយព្រះអង្គទង សុំឱ្យសៀមជួយ។
១៧	កែវហ៊្វាទី៣ អង្គឥម (រជ្ជកាលទី២)	(១៧១០-១៧២២)	បុត្រអង្គនន់ (២) ចៅ ឧទ័យ -ឡើងសោយរាជ្យបន្ទាប់ពីដណ្តើមរាជ្យបាន -ទ័ពសៀមនាំធម្មរាជា និងអង្គទងមកច្បាំង -ចងស្ពានមេត្រីជាមួយសៀម ហើយទ័ពសៀមនាំស្តេចខ្មែរត្រឡប់ទៅវិញ -ធម្មរាជាមានបុត្រ ៣ អង្គជាមួយអ្នកម្នាង សៀម (អង្គហ៊ីង អង្គឌួងអង្គសោភាក្សត្រី) -ដាក់រាជ្យថ្វាយបុត្រអង្គជី។
១៨	សត្ថាទី២ អង្គជី	(១៧២២-១៧២៩)	បុត្រ អង្គអិម (ចៅអង្គនន់) ចៅទួត ឧទ័យ -ប្រជាជនបះបោរ តែបង្ក្រាបបាន ហើយលើករាជសម្បត្តិថ្វាយបិតាវិញ។
១៩	កែវហ៊្វាទី៣ អង្គអិម (រជ្ជកាលទី៣)	១៧២៩	បុត្រអង្គនន់ (២) ចៅ ឧទ័យ -ដាក់រាជ្យថ្វាយបុត្រអង្គជី ជាលើកទី២។

២០	សត្ថាទី២ អង្គជី (រជ្ជកាលទី២)	(១៧២៩- ១៧៣៧)	បុត្រ អង្គអិម (ចៅអង្គទន់) ចៅខ្មួត ឧទ័យ -ទ័ពយួនចូលមកឈ្លានពាន -មានព្រទ័យសង្ស័យលើអគ្គមហេសីស្រី សុជាតា និងក្សត្របីអង្គ (អង្គស្ងួរ អង្គស្ងួន និងអង្គច័ន្ទ) ជាក្បត់ ហើយបញ្ជាឱ្យធ្វើគុត -ក្សត្រទាំងបីអង្គកេណ្ឌទ័ពមកច្បាំង -ធម្មរាជាយាងចូលស្រុក គាំទ្រដោយទ័ពសៀម -អគ្គមហេសីស្រីសុជាតាទាក់ទងជាមួយ ធម្មរាជា ដើម្បីផ្តួលរំលំ -គៀសខ្លួនទៅវៀតណាមៗ
២១	ធម្មរាជាទី៣ ឬ ជ័យជេដ្ឋាទី ទី៤ (រជ្ជកាលទី៣)	(១៧៣៨- ១៧៤៧)	បុត្រ ជ័យជេដ្ឋាទី៣ ចៅខ្មួត ឧទ័យ -ឡើងសោយរាជ្យគាំទ្រដោយសៀម -អង្គទង ឡើងជាមហាឧភយោរាជ -មានបុត្របីអង្គ៖ អង្គអិម, អង្គស្ងួន, និងអង្គស្ងួរ ឧទ័យរាជា -អង្គស្ងួរ ឧទ័យរាជា ឡើងជាមហាឧបរាជ
២២	ធម្មរាជាទី៤ អង្គអិម	១៧៤៧	បុត្រ ធម្មរាជា ទី៣ ចៅខ្មួតលួត ឧទ័យ -មានបុត្រ អង្គទង -ធ្វើគុតដោយព្រះអនុជនាម អង្គហីង ដែលប្រសូតនៅសៀមៗ
២៣	រាមាធិបតី ទី៣ អង្គទង	(១៧៤៧- ១៧៤៨)	បុត្រ ធម្មរាជា ទី៣ ចៅខ្មួតលួត ឧទ័យ -នៅឆ្នាំ១៧៤៧ ចៅហ្វាយ ស្រុកបាសាក់លើកទ័ពទៅប្រយុទ្ធឈ្នះ វៀតណាម តែនៅឆ្នាំ១៧៤៨ វៀតណាមបានលើកទ័ពមកវាយវិញ ដោយមានព្រះសត្ថាចូលរួមផង ហើយទទួលជ័យជម្នះ -គៀសព្រះអង្គទៅសៀម ជាមួយអង្គស្ងួន

២៤	សត្តាទី២ អង្គជី (រជ្ជកាលទី៣)	១៧៤៩	បុត្រ អង្គអិម (ចៅអង្គទន់) ចៅទួតឧទ័យ -ឡើងសោយរាជ្យដោយមេទ័ពវៀតណាម លើកបណ្តុប -ឧកញ៉ាក្រឡាហោម ឱក ដើបបះបោរ ប្រឆាំងវៀតណាម -ទ័ពវៀតណាមបរាជ័យ ហើយដកថយ ព្រះសត្តាសុគតតាមផ្លូវ។
២៥	ស្រីជ័យជេដ្ឋ អង្គស្ងួន	(១៧៤៩- ១៧៥៥)	បុត្រធម្មរាជាទី៣ ចៅទួតលួតឧទ័យ -ឧកញ៉ាក្រឡាហោមឱករៀបចំប្រទេស ឱ្យមានសន្តិភាព ហើយចាត់សេនាបតី យាងស្តេចខ្មែរពីសៀម -ស្តេចសៀមអនុញ្ញាតឱ្យអង្គស្ងួន ត្រឡប់មកវិញ ឡើងសោយរាជ្យ តែឃាត់ ទុកហ្វូងអង្គទង និងឧបរាជឧទ័យរាជា -នៅឆ្នាំ ១៧៥១ ព្រះចៅសៀមទ្រង់ សព្វព្រះទ័យឱ្យអង្គស្ងួន និងឧទ័យរាជា ត្រឡប់មកវិញ -ឧទ័យរាជាបួសនៅនគរវត្ត ហើយសុគត ព្រះរាជបុត្រ អង្គតន់ យកព្រះនាមថា ឧទ័យរាជា -មានបុត្រពីរអង្គ៖ អង្គទន់ និងអង្គជី។
២៦	រាមាធិបតីទី៣ អង្គទង (រជ្ជកាលទី២)	(១៧៥៦- ១៧៥៧)	បុត្រ ធម្មរាជាទី៣ ចៅទួតលួត ឧទ័យ -ប្រគល់ខេត្តផ្សារដែក, ខេត្តលង់ហោរ, និង ខេត្តមាត់ជ្រូក ឱ្យទៅវៀតណាម -វៀតណាមកៀបសង្កត់លើរាជការខ្មែរ ដោយសារវិបត្តិធ្ងន់ធ្ងរក្នុងរាជវង្ស -វិវាទរវាងអង្គតន់ (បុត្រឧទ័យរាជា) និងអង្គ ហឹង (បុត្រអង្គច័ន្ទ) ដែលជា មហាឧបរាជ -អង្គតន់កៀសខ្លួនទៅពាម កេណ្ឌទ័ពវាយ ឈ្នះហើយធ្វើគុតអង្គហឹង

២៧	នារាយណ៍រាជា ទី២ អង្គតន់	(១៧៥៨-១៧៧៥)	បុត្រឧទ័យរាជា (អង្គស្ងួរ) ចៅពញ្ញាធម្មរាជា ទី៣ ចៅទូតលួត ឧទ័យ -បានឡើងសោយរាជ្យ ហើយបានប្រគល់ខេត្តពីរ ព្រះត្រពាំង និងឃ្លាំងទៅឱ្យវៀតណាម -នៅឆ្នាំ១៧៦៧ ភូមារាំងយកអយុធ្យា ពញាតាកកេណ្ឌទ័ពវាយកម្ចាត់ភូមា រួចឡើងសោយរាជ្យ តែស្តេចខ្មែរមិនទទួលស្គាល់ -សៀមលើកទ័ពមកច្បាំង ព្រះរាជាភៀសខ្លួនទៅវៀតណាម -មានបុត្រ៖ អង្គអេង -នៅឆ្នាំ ១៧៧៥ ទ្រង់ដាក់រាជ្យ ថ្វាយអង្គនន់ ដើម្បីជៀសវាងសង្គ្រាម ហើយនៅជា មហាឧកយោរាជវិញ។
២៨	រាមរាជា អង្គនន់	(១៧៧៥-១៧៧៩)	បុត្រ ស្រីជ័យជេដ្ឋ អង្គស្ងួន (២៥) ចៅទូតលា ឧទ័យ -ពឹងស្តេចសៀមតាកសីន ដើម្បីរើបម្រះពីយួន -ព្រះរាជាចោទចៅហ្វាយខេត្ត បារាយណ៍ និងព្រៃក្តី ដែលជាបងប្អូនចៅហ្វាយខេត្តកំពង់ស្វាយ ហើយកាត់ទោសប្រហារជីវិត -នៅឆ្នាំ ១៧៧៩ ចៅហ្វាយខេត្តកំពង់ស្វាយបះបោរ -ព្រះរាជាចាត់ចៅហ្វាយ ខេត្តបាសាក់ ចៅហ៊្វាម្ញូទៅបង្ក្រាប តែចៅហ៊្វាម្ញូចូល ដៃ ហើយធ្វើគុតព្រះរាជា

២៩	នាយណ៍រាជាទី៣ អង្គអេង	(១៧៧៩-១៧៩៦)	បុត្រ អង្គតន់ -មន្ត្រីលើករាជសម្បត្តិថ្វាយព្រះអង្គអេង ដែលមានព្រះជន្មព៧វស្សា -អំណាចក្នុងដៃចៅហ៊្វា មូ -មានបុត្របីអង្គ៖ អង្គច័ន្ទ, អង្គអិម, និងអង្គឌួង -ស្តេចសៀមលើកទ័ព ២០០០០ នាក់មកប្រយុទ្ធជាមួយទ័ពយួនលើទឹកដីខ្មែរ -ព្រះចៅតាកសីន កើតវិកលចរិត ទ័ពសៀមដកថយទៅវិញ ហើយមេទ័ពឧកញ៉ាចក្រីថងដួង ឡើងសោយរាជ្យជារាមាទី១នៃរាជវង្សថ្មី -ជម្លោះរវាងចៅហ៊្វាមូ ឧកញ៉ាចក្រីពាង និងសម្តេចចៅពញាស៊ួ -នៅឆ្នាំ១៧៨៥ ហ៊្វាបែនត្រឡប់ពីសៀមមកវិញ ហើយសម្លាប់ចៅហ៊្វាមូ, ឧកញ៉ាចក្រីពាង -បន្ទាប់ពីឈ្លោះជាមួយពញាស៊ួ ចៅហ៊្វាបែន ភៀសខ្លួនទៅសៀម ដោយនាំព្រះអង្គអេង និងក្សត្រីបីអង្គផង -នៅឆ្នាំ ១៧៩៤ ព្រះចៅសៀមអភិសេកព្រះអង្គអេងនៅបាងកក ហើយតែងតាំងឧកញ៉ាក្រឡាហោម ប៉ុក ជាចៅហ៊្វាឡ: -ចៅពញាអភ័យធីបែស បែន លើកទ័ពនាំព្រះអង្គអេង ត្រឡប់មកកម្ពុជាវិញ ហើយនៅត្រួតត្រាខេត្តបាត់ដំបង និងអង្គរ នៅឆ្នាំ១៧៩៥

៣០	ចៅហ្វាប៉ុក	(១៧៩៦-១៨០៥)	-ទទួលខុសត្រូវក្នុងការដឹកនាំរាជការជំនួសព្រះអង្គអេង ដែលនៅក្មេង -មានទំនាក់ទំនងល្អជាមួយសៀម និងវៀតណាមហើយជួយច្បាំងប្រទេសទាំងពីរ -ស្លាប់នៅសៀមក្នុងជន្មាយុ៦៥ឆ្នាំ។
៣១	ឧទ័យរាជា អង្គច័ន្ទ	(១៨០៦-១៨៣៤)	បុត្រ អង្គអេង -អភិសេកនៅបាងកកនៅឆ្នាំ១៨០៦ ក្នុងជន្មាយុ១៥វស្សា -អង្គស្ងួនតែងតាំងជាឧកយោរាជ និងអង្គអិម ជាឧបរាជ -វិវាទរវាងអង្គច័ន្ទ និងអង្គស្ងួន -អង្គច័ន្ទសុំទ័ពវៀតណាមមកបង្ការ -សៀមមិនសប្បាយចិត្ត ក៏លើកទ័ពមកច្បាំងនឹងទ័ពយួនលើដីខ្មែរ -អង្គអិម និងអង្គឌួង នាំមាតារត់ទៅស្រុកសៀម -នៅឆ្នាំ ១៨១៣ សៀមនិងយួនសម្រុះសម្រួលគ្នា ហើយទ័ពវៀតណាមដង្ហែអង្គច័ន្ទមកសោយរាជ្យ -អង្គច័ន្ទនាំគ្រឿងបណ្ណាការទៅថ្វាយស្តេចសៀមក្នុងឋានៈជាប្រទេសរាជ -នៅឆ្នាំ ១៨១៤ ទ័ពសៀមកាន់កាប់ខេត្តមូលព្រៃ, ទន្លេរពៅ, និងស្ទឹងត្រែង -វៀតណាមដាក់អាណាព្យាបាលលើកម្ពុជា -ព្រះរាជា និងនាហ្មឺនសព្វមុខមន្ត្រីត្រូវស្លៀកពាក់ដូចមន្ត្រីវៀតណាម -កេណ្ឌប្រជាជនទៅជីកព្រែកវិញតេ និងវិញអាន និងមានរឿងកំពប់តែអុង -ព្រះអង្គច័ន្ទសុគតនៅឆ្នាំ ១៨៣៤។

៣២	ក្សត្រី អង្គមី	(១៨៣៤-១៤៤០)	បុត្រី អង្គច័ន្ទ -ស្ដេចវៀតណាមលើកក្សត្រីអង្គមី ឱ្យសោយរាជ្យ ហើយក្សត្រីអង្គពៅ ជាឧបរាជិនី និងក្សត្រីអង្គស្ងួន ជាកែវហ្វា -ប្រជារាស្ត្រដែលរងការគាបសង្កត់បាន ងើបបះបោរ -នាហ៊ឺនសព្វមុខមន្ត្រីសម្រេចយាង ព្រះអង្គឌួង ឱ្យត្រឡប់មកពីសៀម ឡើងសោយរាជ្យ
៣៣	ព្រះហរិរក្ស រាមាឥស្សរាធិបតី អង្គឌួង	(១៨៤០-១៨៥៩)	បុត្រ អង្គអេង -ជាព្រះមហាក្សត្រដែលបានកសាងកម្ពុជា ឡើងវិញក្នុងគ្រប់វិស័យ

ឧបសម្ព័ន្ធទី២៖ របៀបសរសេរពាក្យខ្មែរជាភាសាឡាតាំង

ពាក្យខ្មែរអាចសរសេរជាភាសាឡាតាំងបាន តាមពីរបែប (ANTELME, 2002)៖

(១) ការសរសេរតាមការអាន ឬការបញ្ចេញសូរ (TRANSCRIPTION)៖ ដូចជាពាក្យ «ភ្នំពេញ» ត្រូវសរសេរជា «Phnom Penh» តាមការអាន និង

(២) ការសរសេរតាមអក្ខរក្រម (TRANSLITERATION)៖ ដូចជាពាក្យ «ភ្នំពេញ» ត្រូវសរសេរជា «bhnaṃ beñ» តាមការសរសេរ។

ខាងក្រោមនេះ គឺជាតារាងនៃអក្ខរក្រមភាសាខ្មែរសរសេរជាភាសាឡាតាំង។

ស្រៈខ្មែរ និងឡាតាំង

អ	អា	ឥ	ឦ	ឧ	ឩ	ឯ	ឰ	ឱ	ឳ
a	ā	i	ī	u	ū	e	ai	o	au
ឫ	ឬ	ឭ	ឮ						
ṛ	ṝ	ḷ	ḹ						

ព្យញ្ជនៈខ្មែរ និងឡាតាំង

ក	ខ	គ	ឃ	ង	ច	ឆ	ជ	ឈ	ញ
k	kh	g	gh	ṅ	c	ch	j	jh	ñ
ដ	ឋ	ឌ	ឍ	ណ	ត	ថ	ទ	ធ	ន
ṭ	ṭh	ḍ	ḍh	ṇ	t	th	d	dh	n
ប	ផ	ព	ភ	ម	យ	រ	ល	វ	ឝ
p	ph	b	bh	m	y	r	l	v	ś
ឞ	ស	ហ							
ṣ	s	h							

ឧបសម្ព័ន្ធទី៣៖ ពាក្យសព្ទបាលី

IMA	សរសេរជាខ្មែរទំនើប	ខ្មែរទំនើប
	អ	
	អភិធម្ម	ព្រះអភិធម្ម
	អាកញ្ញាព	អត់លាភ
	អព្ទទិស្ស	គ្រប់ទិស
	អចិន្ត្យទ្រិយ	អចិន្ត្រៃយ៍
	អទិស្សស្ថាន	តាំងចិត្ត
	អកុសល	អកុសល/ អំពើមិនល្អ
	អកុសលមូលា	មូលហេតុនៃអកុសល
	អនគ្ឃអនាថ៌	មិនអាចប្រមាណបាន
	អនមោទនា	វាចាសម្ដែងសេចក្ដីត្រេកអរតាម
	អនិច្ច	មិនទៀង
	អន្និសង៍	អានិសង្សផលបុណ្យ/ កុសល
	អន្តរជាណ	អន្តរធាន/ការបាត់ទៅ
	អនិច្ចា	អនិច្ចា

	អង្គរ	អង្គរ ប្រទេស
	អបទិស្ស	សព្វទិស
	អរហត្តផល	ការសម្រេច ជាអរហត្ត
	អព្ជិបទ្មម	បទុម ផ្កាឈូក ដ៏ខ្ពង់ខ្ពស់
	អសង្ខារិក	រាប់មិនអស់
	អដ្ឋមី	ទី៨
	អតុល្យ	ច្រើនលើស
	អដ្ឋរស្ស	១៨
	អាទ្ធិស្ឋាន	តាំងចិត្ត
	អាជានៃយរត	អាជានេយ្យ (១. ព្រះពុទ្ធ ព្រះអរហន្ត ២. ដំរីបង្ហាត់ ៣.សេះបង្ហាត់ និង ៤. គោអាជានេយ្យ)
	អានាទរ	មិនយកចិត្តទុកដាក់
	អានិសង៍	ផលបុណ្យ
	អានុចធម្ម	ទទួលមរណភាព
	អាភទនា	សម្រេច ពេញចិត្ត

	អាស្សនា	អាសនៈ
	អាសខារិកចិត្រ	ចិត្រាប់មិនអស់
	អាសារ	អាសារបង់
	អាតុល	គ្មានអ្វីប្រៀប
	អាយុខៃយ្យ កាំម្មខៃ	អស់អាយុ អស់កម្ម
	អាយុក្ខយ្យ	អស់អាយុ
	ព្រះពរមង្គល	ព្រះពរ សូមឱ្យចម្រើន
	ភគ្គនិយា	បុត្ររបស់បង ឬប្អូនស្រី (រាជសព្ទ)
	ភគ្គេ(អ្នកចម្រើន) ភគវា(សម្បត្តិ)	បុគ្គលដ៏ចម្រើន ដោយសម្បត្តិ
	ភ្គិក	ភិក្ខុ
	ភិក្ខ	ភិក្ខុ
	ភិម្មង្គល (អភិមង្គល)	សេចក្ដីសុខ ចម្រើនខ្លាំងក្លា
	ពិបាក (វិបាក)	ពិបាក លំបាក
	ពិសាក	ពិសាខ
	ពិសាល	វិសាលភាព ធំ

	ពិសេស (វិសេស)	ពិសេស
	ពិភព (វិភវ)	ទ្រព្យសម្បត្តិ
	ព្យិពាធិ (វិវាទ)	វិវាទ
	ពោធិសម្ភារ	បារមីធម៌នៃ ព្រះពោធិញ្ញាណ
	ពោធិសត្វ	ពោធិសត្វ
	ពោធិ	ពោធិ
	ព្រំហ្មលោក	ព្រហ្មលោក
	ព្រះអភិធម្ម	ព្រះអភិធម្ម
	ព្រះអរិយសង៏	ព្រះអរិយសង្ឃ
	ព្រះក្ងុនទៀ (អរុណោទយ)	ពេលព្រឹកព្រហាម
	ព្រះគាថា	វាចាបណ្ឌិត
	ព្រះជិនរូប	ព្រះពុទ្ធ
	ព្រះជី	ព្រះបុព្វបុរស
	ព្រះកម្រតែងអញ	ព្រះចៅពុទ្ធជាអម្ចាស់
	ព្រមោគលាន	ព្រះសាវ័កនៃព្រពុទ្ធ
	ព្រះញាត	ទាំងអម្បាលមាណ
	ព្រះបូរិត្ត	ព្រះបរិត្ត

	ព្រះសព៌្វជ្ញពុទ្ធ	ព្រះពុទ្ធ
	ព្រះសារិបុត	ព្រះសាវ័កនៃព្រពុទ្ធ
	ព្រះស្តាចារ	ព្រះពុទ្ធជាគ្រូ
	ព្រះសាស្តាចារិក	ព្រះពុទ្ធជាគ្រូ
	ព្រះស្រិរត្នត្រៃ	ព្រះពុទ្ធ
	ព្រះសាស្ដា	ទ្រឹស្តីព្រះពុទ្ធ
	ព្រះសិសាក្យមណិ	ព្រះពុទ្ធ
	ព្រះគ្រិអាយ៌្យមៃត្រី	ព្រះពុទ្ធទៅថ្ងៃមុខ
	ព្រះស្រិយគោតំម	ព្រះពុទ្ធ
	ពុទ្ធញាណ	ត្រាស់ដឹង
	ចត្តាឡីសកំមឋាន	ឧបករណ៍ក្នុងការ ហ្វឹកអប់រំចិត្ត
	ចតុបារិសុទ្ធសិល	ប្រកបដោយ បាដិមោក្ខសំវរ ឥន្ទ្រីយសំវរ អាជីវបារិសុទ្ធិ បច្ចយសន្និសិត
	ចតុរាបាយ	ការៈទាំង៤៖ និរយ តិរច្ឆាន បិត្តិវិស័យ និងអសុរកាយ

	ទសសហស្ស៍ ចក្រ្កាវាឡ	ចក្រវាឡទាំង ១០ពាន់
	ទិ្វពសំម្ប័ត	សម្បត្តិទិព្វ
	ទេពតា	ទេវតា
	ទេព្វរក្ស៍	ទេវតារក្សា
	ទេព្វតា (ទេវតា)	ទេវតា
	ទេព្វឋារូវ	ព្រះពុទ្ធធ្វើពី ឈើឋារូវ
	ទេស្នានា	ទេសនា
	មណ្ណិ (មុនី)	រតនៈ កែវ អ្នកប្រាជ្ញ
	ធម្មអរិយ	ធម៌ដ៏ចម្រើន ខ្ពស់ជាងគេ
	ធម្មត្ថិតិ	ធម៌ដែលច្បាស់
	ធម្មបារម្មី	ធម៌ព្រះពោធិសត្វ ដ៏ឧត្ដម
	ធម្មសត្ថា	ធម៌នៃព្រះគ្រូ
	ធញ្ញបុញ្ញលក្សណ	លក្ខណៈសម្បត្តិ កុសល ផលបុណ្យ
	សំតេង៍ធទេស្សន្នា	សម្ដែងធម៌ទេសនា

	ធម្មន្តកាយ	អន្តកាយធម៌
	ធាព (បាលី ទព្វ)	ទ្រព្យ (សំ ទ្រវ្យ)
	ទង៑ជាម្មធ្វជ	ទង់ធម្មជ្វាលា
	ធារណា	រ៉ាប់រង
	ធិព្វសម្បត្តិ	សម្បត្តិទិព្វ
	ធូលី	ធូលី
	ទិព្ភមុន (ទិព្ភមន្ត)	សូត្រមន្តទិព្វ
	ទិព្វសម្ប័ត្ត	សម្បត្តិទិព្វ
	ទិឃាយុ (ទិឃ អាយុ)	អាយុយឺនយូរ
	ទិនេ (ទិវា)	ទិនទិវា (ថ្ងៃ)
	ទោពេន (ទារុណ)	ទារុណ
	ទោស	ទោស
	ទ្រទូង៑	ព្រះសង្ឃ ៨ អង្គ
	ទូរគត (ទុរគត)	ទុរគត
	ឯហិភិក្ខុ	នឹងទៅជាភិក្ខុ
	ឯកគ្គតា	សមាធិឱ្យចិត្តមាន អារម្មណ៍តែ១

	គន (គណន)	រាប់ គយគន់ រកមើល
	គនជន	ជនដែលកើតមក
	គន្ធាត្រា (ត្រា ១០ កត់ទុក)	គណនាទុក
	គន្ធ	គន្ធ ក្លិន
	គន្ធប (គន្ធព្វ)	ពួកទេវតាពាំ
	គភ្ភ៌ណិ	មានគភ៌
	គោរប្យ (គារវ)	គោរព គារវកិច្ច
	គ្រហាវាស (ឃរាវាស)	គ្រហស្ថ
	គ្រូវ (គរុ)	គ្រូ
	ក្តិយ (គតិ)	ក្តី
	ហត្តសុក្ខ (ហិត្តសុខ)	ប្រយោជន៍ នៃសេចក្តីសុខ
	ហត្តិរត	ដំរីកែវ
	ហេតុ	ហេតុ
	ហោរ	ហោរា
	ហោត	មាន ជា
	ឥទំ	នេះ

	ឥន្ទិបថម្ហានគរ	ក្រុងអង្គរធំ
	ជាក ព្យាធ (ព្យាធិ)	ជរាព្យាធិ
	ជាត	ជាតិកំណើត
	ជាតិជរាក្យា ទិមរទុក	កើត ចាស់ ឈឺ ស្លាប់
	ជេដ្ឋស័ត្ថា (ជេដ្ឋ+សត្ថា)	ចម្រើនបំផុត+គ្រូ
	ជេដ្ឋសិខាន្ទ (ជេដ្ឋ+សីល+ខន្ធ)	ប្រជុំសីល ចម្រើនបំផុត
	ជិនសាស្នធរ (ជិន+សាសន+ធរ)	អ្នកជឿសាសនា ព្រះពុទ្ធ
	ជិពរ	ចីវរ
	ជ្និជ្នក (ជននី ជនក)	ម្តាយ ឪពុក
	ជោតិ	រុងរឿង
	ជោតិកសេស្ថិ	សេដ្ឋីរុងរឿង
	កត្តញុ	កតញ្ញូ
	កត្តវេទិ	កតវេទី
	កេស	សក់
	កេសមោលី	ក្បួងសក់
	កិលេស	កិលេស

	គីទិរី គីនរ (កិន្នរី កិន្នរ)	កិន្នរ
	កិរិយ្យាបុត្ត	ឥរិយាបថ
	កុសល	កុសលផលបុណ្យ
	កុសលមូល	ឫសគល់នៃកុសល
	កង៍ចក្ក	កង៍ចក្រ
	មត្តាវរណ (មត្ត+ អាវរណ)	មាត់ជាគ្រឿង បិទបាំង
	មគោលការ	អ្នកប្រកប ដោយមណ្ឌល
	មនុវង្សេភាត្តរ	ព្រះមនុវង្សដ៏ប្រសើរ
	មហាអត្តិសៃ (មហា+អាទិសៃ)	មហាប្រសើរ
	មហាព្រំហ្មរសីហ	មហាព្រហ្មឥសី
	មហាចក្កពត្តរាជ	មហាចក្រពត្តិរាជ
	មហាខ្សត្រ	មហាក្សត្រ
	មហាខេ្សត្រ	ទេវតារក្សា ព្រះរាជាណាចក្រ
	មហាកុសល	មហាកុសល
	មហាមណ្ឌល	មហាមណ្ឌល
	មហានគរ	មហានគរ

	មហានុព្វស្រមុទ្ទ	មហាសមុទ្រ
	មហាបទុំ	ផ្កាឈូកដ៏ប្រសើរ
	មហាប្រត្ថព្យិ	មហាប្រថពី
	មហាបុរុស	មហាបុរស
	មហាសមុះ	មហាសមុហ (ពួក)
	មហាសព្វ៌ជ្ញពុទ្ធ	ព្រះពុទ្ធដែលចេះ អស់ធម៌
	មហាសឃ៌កាម្ម	មហាសង្ឃកម្ម (អំពើ)
	មហាស័ឃរាជ	មហាសង្ឃរាជ
	មហាសារិកធាតុ	សរីរិកធាតុ (ឆ្អឹងព្រះពុទ្ធ)
	មហាសុមៃយ	មហាសម័យ (ពេល)
	មហាត្រីរត្នត្រៃយ	មហាស្រីរតនត្រៃ
	មហាថេរ	ព្រះថេរ (ចាស់) ដ៏ប្រសើរ
	មហាឪបាសក	អ្នកនៅជិត ព្រះរតនត្រៃ
	មហាឪបាសិការត្ន បពិត្រ (បវិត្រ)	មហាឪបាសិកា រតនបពិត្រ (បរិសុទ្ធ)
	មហាវិបុល	មហាវិបុល (ធំដោយវិសេស)

	មហិមា	មហិមា (ធំធេង)
	មហោឡា	ធំសម្បើម
	មហោផ្សុត	ព្រះមហោសថ
	មហោរគា (មហា+ឧរគ)	ពស់ធំ
	មហោរត្តីង	ម៉ោងពេល
	មហោរាសិ	មហារាសី
	មហោត្តំ (មហា+ឧត្តម)	មហាឧត្តម (ខ្ពង់ខ្ពស់)
	មនស្សាភិលង្កិត (មន+អភិ+ អលង្កត)	ចិត្ត+ក្រៃពេក+ ដែលធ្វើ ប្រដាប់ហើយ
	មនោអនិជិត្រ (មនោ+ឥន្ទ្រ+ ជិត)	(ចិត្ត+ព្រះឥន្ទ្រ+ ឈ្នះហើយ)
	មនុវង្សោត្តរ (មនុ+វង្ស+ឧត្តរ)	វង្សព្រះមនុជ ខ្ពង់ខ្ពស់ (មនុស្សទី១)
	មន្យិជេត (មុនី+ជេដ្ឋ)	(អ្នកប្រាជ្ញ +ចម្រើនបំផុត)
	មន្យិស្ថា (មុនី+សត្ថា)	(អ្នកប្រាជ្ញ +ព្រះពុទ្ធជាគ្រូ)
	មន្យិវរ (មុនី+វរ)	(អ្នកប្រាជ្ញ+ខ្ពង់ខ្ពស់)
	មរវីនៃ (បរម+វីនៃ)	(ខ្ពង់ខ្ពស់+វិន័យ)

	មសីត្ត (និសីទន)	ទីនាំង
	មតា	ទទួលមរណភាព
	មត្តកភេត	អាហារសម្រាប់ មនុស្សស្លាប់
	មាត្តាបិត្តា	មាតាបិតា
	មាត្តិកា	មាតិកា
	មហាអវិចិយនរក	នរកធំទី១នៃនរក ៨ជាន់
	ម្ហាព្រំហ្មរសីហ	(មហា+ព្រហ្ម+ ឫសី (សំ)
	ម្ហាខ្សត្រ	(មហា+ក្សត្រ (សំ)
	ម្ហាមង្គល	មហាចម្រើន
	ម្ហានគរ	អង្គរធំ
	(មហា+បវរ+ថេរ)	ព្រះថេរដ៏មហា ប្រសើរ
	(មហា+សមូហ+រូចិ)	(មហា+ក្រុម+រស្មី)
	មហា មោកគលាន	សាវកនៃព្រះពុទ្ធ
	ម្ហាសប្បុរស	មហាសប្បុរស
	ម្ហាស្មត	(មហា+សមត្ថ)
	ម្ហាឳត្តុល (មហា+អតុល)	ដែលគ្មានគូប្រៀប

	មិច្ឆិម្មរិយ (មច្ឆិមវិយ)	វ័យកណ្ដាល
	ម៉្នីសុធម្ម(មុនី+សុធម៌)	(អ្នកប្រាជ្ញ+ ធម្មដ៏ប្រសើរ)
	មោះហិមា	មហិមា
	មុទ្វាភិសេក (មុទ្វា+អភិសេក)	ពិធីកោសក់
	មុនិសធម្ម (មុនិ+សធម្ម)	(អ្នកប្រាជ្ញ+ ធម្មដ៏ប្រសើរ)
	មុនិយកុសល	មុនីកុសល
	ម៉រ	មរណ
	នរក	នរក
	នាកា	នកា
	នានា	នានា
	នានាប្រាកាយ៉្យ	ប្រការនានា
